# អដ្ឋកថា ទីឃនិកាយ បឋមភាគ

## នៃព្រះសុត្តន្តបិដក

## ឈ្មោះ សុមង្គលវិលាសិនី

## សីលក្ខន្ធវគ្គ

## ភាគ ១៤

អធិប្បាយ

ព្រហ្មជាលសូត្រ-សាមញ្ញផលសូត្រ-អម្ពដ្ឋសូត្រ-សោណទណ្ឌសូត្រ

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ទីឃនិកាយ បឋមភាគ

## សីលក្ខន្ធវគ្គ

## នៃព្រះសុត្តន្តបិដក

### ភាគ ១៤

ឈ្មោះ

## សុមង្គលវិលាសិនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

ព្រហ្មជាលសូត្រ_សាមញ្ញផលសូត្រ_អម្ពដ្ឋសូត្រ_សោណទណ្ឌសូត្រ

# ស្រៈនិស្ស័យ

## *Signes et accents:*



# ស្រះពេញតួ

# *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| [illegible] Romain | *a* | *.ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូម<br>Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម<br>Siamois | ฎ | ฐ | ฑ | ฒ | ณ |
| លាវ<br>Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សង្ហ<br>Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា<br>Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រូម Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ប | ផ | ព | ភ | ម |
| [illegible]<br>Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម<br>Siamois | ป | ผ | พ | ภ | ม |
| លាវ<br>Laotien | ປ | ຜ | ພ | ຠ | ມ |
| លង្កា<br>Cinghalais | ප | ඵ | බ | භ | ම |
| ភូមា<br>Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមាន គាថា និងពុទ្ធវចនៈ ដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទូវសេចក្តីរីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**

**ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**

**មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**

**បណ្ឌិតគប្បីដឹងបាន ។**

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្តែងធម៌មានហេតុផល** ដែលអ្នកស្តាប់អាចពិចារណាឃើញតាម

សេចក្តីពិតបាន ។

**៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់ បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

**១ ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២ សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក

ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះ ធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្រ្តទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្វរខ្វារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួនទៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថាឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុជៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ឋឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ:ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្កាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរិយ: ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ឋឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន — ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទួន — ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត — ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី — ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា — ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ — ឧបាសិកា ថាប់ ឈឿម

ឧបាសិកា ហាយ សារ៉ាត់ — ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ — ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុយន្តទិន្នោ ផល សុភ័ណ សមណសិស្ស សាលាសតិប្បដ្ឋាន

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទួន ឧបាសក ហុក សឹងហួត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **អដ្ឋកថា ព្រហ្មជាលសូត្រ ទី១** | |
| និទានកថា | ៣ |
| ថ្ងៃផ្ដើមបឋមសង្គាយនា | ១៦ |
| ព្រះអានន្ទសម្រេចព្រះអរហន្ត | ២០ |
| អដ្ឋកថា ព្រហ្មជាលសូត្រ | ៦០ |
| ន័យមួយទៀត | ៧១ |
| អត្ថនៃបទថា ឯកំ សមយំ | ៧៥ |
| អត្ថនៃបទថា ភគវា | ៨២ |
| អត្ថនៃបទថា ឯវំមេ សុតំ ឯកំ សមយំ ភគវា | ៨៣ |
| អត្ថនៃបទថា អន្តរា ច រាជគហំ អន្តរា ច នាលន្ទំ | ៨៤ |
| អត្ថនៃបទថា អទ្ធានមគ្គប្បដិបន្នោ ហោតិ | ៨៦ |
| អត្ថនៃបទថា វណ្ណំ សព្វ | ៩២ |
| សុប្បិយបរិព្វាជក | ១០០ |
| អធិប្បាយ ភិក្ខុច្រើនរូប និងពាក្យថា សង្ឃ | ១០៤ |
| ពុទ្ធកិច្ច ៥ យ៉ាង | ១១១ |
| ពិណ៌នាហេតុនៃព្រះសូត្រ | ១២៤ |
| ពិណ៌នាការផ្ដើមអនុសន្ធិ | ១៣៥ |
| សីលមិនដល់សមាធិ | ១៤៩ |
| អធិប្បាយ បុថុជ្ជន | ១៤៣ |
| ពាក្យថា តថាគត ៨ ប្រការ | ១៤៥ |
| អធិប្បាយពាក្យថា បុច្ឆា | ១៦៤ |

ពណ៌នា ចូឡសីល ១៦៧
ពណ៌នា មជ្ឈិមសីល ១៩៦
ពណ៌នា មហាសីល ២២០
ពណ៌នា បុព្វន្តកប្បិកសស្សតវាទ ២៣៤
ឋានៈ ៤ ប្រការអ្វីខ្លះ ២៣៨
ពណ៌នា ឯកច្ចសស្សតវាទ ២៥៩
ពណ៌នា អន្តានន្តវាទ ២៧០
ពណ៌នា អមរាវិក្ខេបវាទ ២៧២
ពណ៌នា អធិមុច្ចសមុប្បន្នវាទ ២៧៨
ពណ៌នា អបរន្តកប្បិកវាទ ២៨១
ពណ៌នា សញ្ញីវាទ ២៨២
ពណ៌នា អសញ្ញីនេវសញ្ញីនាសញ្ញីវាទ ២៨៤
ពណ៌នា ឧច្ឆេទវាទ ២៨៥
ពណ៌នា ទិដ្ឋធម្មនិព្វានវាទ ២៨៨
សរុបទិដ្ឋិ ៦២ ២៩១
បរិតស្សិតវិប្ផន្ទិតវារៈ ២៩៥
ផស្សប្បច្ចយវារៈ ២៩៦
ទិដ្ឋិគតិកាធិដ្ឋានវដ្តកថា ២៩៨
វិវដ្តជាដើម ៣០៣

## អដ្ឋកថា សាមញ្ញផលសូត្រ ទី២

រាជាមច្ច ៣១៥
ជីវកកោមារភច្ច ៣៤២

| | |
|---|---|
| សាមញ្ញផលបុច្ឆា | ៣៥៥ |
| បូរណកស្សបៈ | ៣៧០ |
| មក្ខលិគោសាល | ៣៧៤ |
| អជិតកេសកម្ពល | ៣៨៤ |
| បកុធកច្ចាយន | ៣៨៨ |
| និគណ្ឋនាដបុត្ត | ៣៩០ |
| សញ្ជយវេលដ្ឋបុត្ត | ៣៩១ |
| បឋមសន្ទិដ្ឋិកសាមញ្ញផល | ៣៩២ |
| ទុតិយសន្ទិដ្ឋិកសាមញ្ញផល | ៣៩៦ |
| បណីតតរសាមញ្ញផល | ៣៩៨ |
| ចូឡមជ្ឈិមមហាសីល | ៤២៣ |
| សតិសម្បជញ្ញៈ | ៤២៥ |
| សន្តោសកថា | ៤៦៦ |
| នីវរណប្បហាន | ៤៧៥ |
| បឋមជ្ឈាន | ៤៩៣ |
| ទុតិយជ្ឈាន | ៤៩៥ |
| តតិយជ្ឈាន | ៤៩៦ |
| ចតុត្ថជ្ឈាន | ៤៩៧ |
| វិបស្សនាញាណកថា | ៤៩៩ |
| មនោមយិទ្ធិកថា | ៥០៤ |
| ឥទ្ធិវិធញ្ញាណាទិកថា | ៥០៦ |
| អាសវក្ខយញ្ញាណកថា | ៥០៩ |
| អជាតសត្តុបាសក | ៥១៦ |
| សរណគមនកថា | ៥២៤ |

## អដ្ឋកថា អម្ពដ្ឋសូត្រ ទី៣


| | |
|---|---|
| និទានរឿង អម្ពដ្ឋមាណព | ៥៤៣ |
| បោក្ខរសាតិព្រាហ្មណ៍ | ៥៥៥ |
| អម្ពដ្ឋមាណព | ៥៦៣ |
| ការពោលបន្ទះបន្ទាប់ទី ១ | ៥៧៨ |
| ការពោលបន្ទះបន្ទាប់ទី ២ | ៥៨៤ |
| ការពោលបន្ទះបន្ទាប់ទី ៣ | ៥៨៦ |
| ការញាំញីដោយពាក្យថា កូនទាសី | ៥៨៧ |
| វង្សរបស់អម្ពដ្ឋមាណព | ៦០៤ |
| ខត្តិយសេដ្ឋវាទ | ៦០៧ |
| ពណ៌នា វិជ្ជា ចរណៈ | ៦០៩ |
| ពណ៌នា ចតុអបាយមុខ | ៦១១ |
| ពួកឥសីដែលជាបុព្វបុរស | ៦១៨ |
| មហាបុរិសលក្ខណៈ ២ ប្រការ | ៦២៥ |
| រឿងព្រាហ្មណ៍ឈ្មោះ បោក្ខរសាតិ | ៦២៩ |


## អដ្ឋកថា សោណទណ្ឌសូត្រ ទី៤


| | |
|---|---|
| អដ្ឋកថា សោណទណ្ឌសូត្រ | ៦៣៣ |
| គុណកថារបស់សោណទណ្ឌព្រាហ្មណ៍ | ៦៣៥ |
| ពុទ្ធគុណកថា | ៦៤២ |
| សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍ | ៦៥៤ |
| ការបញ្ញត្តិថា ព្រាហ្មណ៍ | ៦៥៥ |
| សីលបញ្ញា | ៦៥៨ |
| សោណទណ្ឌព្រាហ្មណ៍សម្តែងខ្លួនជាឧបាសក | ៦៦៣ |

# សុមង្គលវិលាសិនី

## អដ្ឋកថា ទីឃនិកាយ សីលខន្ធវគ្គ

ខ្ញុំសូមនមស្ការដោយសិរសានូវព្រះសុគត ទ្រង់ផុតគតិ ( ៥ គឺ និរយគតិ បេត្តគតិ តិរច្ឆានគតិ មនុស្សគតិ ទេវគតិ) មានព្រះទ័យត្រជាក់ដោយករុណា មានងងឹត គឺ មោហៈ ដែលដួងប្រទីប គឺ បញ្ញាកម្ចាត់ហើយ ទ្រង់ជាគ្រូរបស់លោកព្រមទាំងមនុស្ស និងទេវតា ។

ក៏ព្រះពុទ្ធទ្រង់អប់រំ និងទ្រង់ធ្វើឲ្យច្បាស់នូវភាពជាព្រះពុទ្ធ ទ្រង់សម្រេចធម៌ណាដែលប្រាសចាកមន្ទិល ខ្ញុំសូមនមស្ការដោយសិរសា នូវព្រះធម៌ដ៏កំពូលនោះ ។

ខ្ញុំសូមនមស្ការដោយសិរសា នូវព្រះអរិយសង្ឃជាឱរសរបស់ព្រះសុគត ជាអ្នកញាំញីកងទ័ពមារ ។

បុណ្យណា ដែលសម្រេចដោយនមស្ការព្រះរតនត្រ័យ មានដល់ខ្ញុំជាអ្នកមានចិត្តជ្រះថ្លា សូមឲ្យខ្ញុំជាអ្នកមានអន្តរាយ ដែលអានុភាពនៃបុណ្យនោះកម្ចាត់ហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថាណា ដែលព្រះអរហន្ត ៥០០ អង្គ សង្គាយនាហើយអំពីខាងដើម និងសង្គាយនាតមក ដើម្បីប្រកាសសេចក្តីរបស់ទីឃនិកាយ ដែលកំណត់ទុកដោយសូត្រមានខ្នាតវែង ល្អិតល្អន់ ប្រសើរជាងនិកាយដទៃ ដែល

ព្រះសម្ពុទ្ធ និងព្រះសាកវកពណ៌នាទុក មានគុណតម្លៃក្នុងការបណ្តុះសទ្ធា តែក្រោយមកព្រះមហិន្ទត្ថេរ នាំមកកោះសីហឡៈ នឹងបានរៀបរៀងជាភាសាសីហឡៈ ដើម្បីប្រយោជន៍ដល់អ្នកសីហឡៈទាំងឡាយ ។

តពីនោះ ខ្ញុំទើបប្រែភាសាសីហឡៈជាភាសាមគធៈ ត្រឹមត្រូវតាមគោលភាសា មិនខុសក្បាត់អក្ខរសម័យ របស់ព្រះថេរៈគណៈមហាវិហារ ដែលជាប្រទីបនៃថេរវង្ស ដែលវិនិច្ឆ័យទុកល្អិតល្អន់ និងកាត់សេចក្តីដដែលៗ ហើយប្រកាសគោលសេចក្តី ដើម្បីសេចក្តីត្រេកអររីករាយនៃសាធុជន និងដើម្បីសេចក្តីយឺនយូរនៃព្រះសទ្ធម្ម ។

សីលកថា ធុតង្គធម៌ កម្មដ្ឋានទាំងពួង ឈាន សមាបត្តិ ពិស្តារដែលប្រកបដោយវិធីបដិបត្តិតាមចរិតអភិញ្ញាទាំងពួង សេចក្តីវិនិច្ឆ័យទាំងពួងដោយបញ្ញា ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ អរិយសច្ចៈ ៤ បច្ចយាការទេសនា និងវិបស្សនាភាវនា មានន័យបរិសុទ្ធល្អ និងល្អិតល្អន់ ដែលមិនក្រៅពីផ្លូវព្រះបាលី ធម៌ដូចពោលទាំងអស់នេះ ខ្ញុំម្ចាស់ពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គហើយ យ៉ាងបរិសុទ្ធល្អ ព្រោះដូច្នោះ ខ្ញុំម្ចាស់នឹងមិនពិចារណ៍ធម៌ទាំងអស់នោះ ក្នុងទីនេះឲ្យក្រៃលែងទេ ។ គម្ពីរវិសុទ្ធិមគ្គនេះ តាំងនៅក្នុងទីកណ្តាលនៃនិកាយទាំង ៤ នឹងប្រកាសសេចក្តី ដូចដែលពោលទុកក្នុងនិកាយទាំង ៤ នោះ ខ្ញុំតែងទុកដោយសេចក្តីប្រាថ្នាយ៉ាងនេះ ព្រោះដូច្នោះ សូមលោកទាំងឡាយ ចូរកាន់យកគម្ពីរវិសុទ្ធិមគ្គនោះ ជាមួយអដ្ឋកថានេះ

ហើយ នឹងយល់ដឹងខ្លឹមសារដែលអាស្រ័យទីឃនិកាយចុះ ។

## និទានកថា

ក្នុងពាក្យថា ទីឃគមនិស្សិតំ នោះ គប្បីជ្រាបសេចក្ដីល្អិត ដូច្នេះ គម្ពីរទីឃនិកាយ ពោលដោយវគ្គ មាន ៣ វគ្គ គឺ សីលខន្ធវគ្គ មហាវគ្គ បាដិកវគ្គ ។ ពោលដោយសូត្រ មាន ៣៤ សូត្រ ។ ក្នុងវគ្គទាំងឡាយ នោះ សីលខន្ធវគ្គ ជាវគ្គដើម ។ បណ្ដាសូត្រទាំងឡាយ ព្រហ្មជាលសូត្រ ជាសូត្រដើម ។ ពាក្យនិទាន មានពាក្យថា ឯវំមេ សុតំ ដូច្នេះ ជាដើម ដែលព្រះអានន្ទពោលក្នុងកាលធ្វើបឋមមហាសង្គាយនា ជាពាក្យដើមរបស់ព្រហ្មជាលសូត្រ ។

## មហាសង្គាយនាលើកដំបូង

ឈ្មោះថា បឋមមហាសង្គាយនានេះ សូម្បីបានឡើងកាន់ព្រះបាលីទុកក្នុងវិន័យបិដកហើយក៏ពិតមែន តែថា ក៏គួរជ្រាបបឋមមហាសង្គាយនាសូម្បីក្នុងអដ្ឋកថានេះ ដើម្បីភាពជាអ្នកឆ្លាតក្នុងហេតុដែលមានមក ដូចតទៅនេះ ៖

កាលព្រះដ៏មានព្រះភាគ ដែលជាទីពឹងរបស់សត្វលោក ទ្រង់បំពេញពុទ្ធកិច្ច ចាប់ផ្ដើមតាំងអំពីទ្រង់សម្ដែងព្រះធម្មចក្ក ដរាបដល់ប្រោសសុភទ្ទបរិព្វាជក ហើយស្ដេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ វេលា

ជិតក្ដីថ្ងៃវិសាខបូណ៌មី នាថន្ទោះដើមសាលៈទាំងគូ ក្នុងសាលវ័នឧទ្យាន របស់មល្លក្សត្រិយ៍ ត្រង់ទីដែលជាផ្លូវកោង ជិតក្រុងកុសិនារា ព្រះមហាកស្សបៈជាសង្ឃត្ថេររបស់ភិក្ខុប្រមាណ ៧ សែនរូប ដែលប្រជុំគ្នាក្នុងថ្ងៃបែងចែកព្រះបរមសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគ មករឭកដល់ពាក្យដែលសុភទ្ទវុឌ្ឍបព្វជិតពោល កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយបាន ៧ ថ្ងៃ ថា " ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ អ្នកទាំងឡាយកុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ចាកព្រះមហាសមណៈនោះ ព្រោះថា ពួកយើង មហាសមណៈនោះ តែងបៀតបៀនថា អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នក ក៏ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើអំពើនោះ មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន" ដូច្នេះ លោកពិចារណាឃើញថា "ការប្រជុំសង្ឃចំនួនច្រើនដូច្នេះតទៅ នឹងរកបានលំបាក" ទើបត្រិះរិះថា "កាលពួកបាបភិក្ខុ នឹងគប្បីជាអ្នក សម្គាល់ថា បាវចនៈមានព្រះសាស្ដាកន្លងទៅហើយ ដូច្នេះ បានបក្ខពួកអលជ្ជីហើយ នឹងញាំញីព្រះសទ្ធម្មឲ្យអន្ត-រធានបានមិនយូរឡើយ ក៏ដំណើរនេះ ជាឋានៈ (ជាហេតុ) ដែលនឹងមានជាប្រាកដ ។ សេចក្ដីពិត ព្រះវិន័យតាំងនៅដរាបណា បាវចនៈនៅមានព្រះសាស្ដាមិនកន្លងទៅដរាបនោះ សេចក្ដីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលអានន្ទ ធម៌ណាក្ដី វិន័យណាក្ដី

ដែលតថាគតសម្ដែងហើយ បញ្ញត្តិហើយ ដល់អ្នកទាំងឡាយ លុះអំណើះ ឥតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាសាស្ដា របស់អ្នកទាំងឡាយ” ដូច្នេះ បើដូច្នោះ យើងគប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ ដែលជាវិធីសម្រាប់ព្រះសាសនានេះ គប្បីតាំងនៅមាំអស់ កាលយូរ ។ មួយទៀត ខ្លួនយើងជាអ្នកដែលព្រះមានព្រះភាគត្រាស់ថា កស្សបៈ អ្នកអត់ទ្រាំបានឬទេ នូវសំពត់បង្សុកូលដែលតថាគតប្រើប្រាស់ចាស់ហើយ ដូច្នេះ ទ្រង់អនុគ្រោះដោយសាធារណៈបរិភោគក្នុងចីវរ និងទ្រង់លើកតម្កើងទុក ប្រៀបស្មើនឹងព្រះអង្គក្នុងធម៌ដ៏ក្រៃលែងរបស់មនុស្ស មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាដើម ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ តថាគតប្រាថ្នាការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈានត្រឹមណា ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបៈ ប្រាថ្នាការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំង-ឡាយ ចូលកាន់បឋមជ្ឈានត្រឹមនោះដែរ ដូច្នេះ ក្រៃលែងជាងនោះ នៅមានការសរសើរ ដោយភាពជាអ្នកមានចិត្តមិនជាប់នៅក្នុងត្រកូល ដូចគ្រវីដៃក្នុងអាកាស និងដោយបដិបទាប្រៀបដូចព្រះចន្ទ ទ្រង់អនុគ្រោះ និងទ្រង់សរសើរ សូម្បីដល់យើង កិច្ចដទៃក្រៅពីការសង្គាយនាដែលនឹងឲ្យយើងចៀសវាងមិនបាន ព្រះមានព្រះភាគទ្រង់ជ្រាបនូវយើងមិនមែនឬ ថា កស្សបៈនេះ នឹងជាអ្នកប្រតិស្ឋានវង្សព្រះសទ្ធម្មរបស់តថាគត ដូច្នេះ ហើយ

ទ្រង់អនុគ្រោះដោយសេចក្ដីអនុគ្រោះ ដែលមិនទូទៅនេះ និងទ្រង់សរសើរដោយការសរសើរដ៏កំពូលនេះ ដូចព្រះរាជាទ្រង់ជ្រាបព្រះរាជឱរស អ្នកនឹងប្រតិស្ឋានវង្សត្រកូលរបស់ព្រះអង្គ ហើយទ្រង់អនុគ្រោះដោយការប្រគល់អាវក្រោះ និងព្រះឥស្សរិយយសរបស់ព្រះអង្គ ដូច្នោះ ក៏ញុាំងសេចក្ដីឧស្សាហ៍ឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីសង្គាយនាព្រះធម៌វិន័យ ។ សមដូចពាក្យដែលព្រះសង្គីតិកាចារ្យពោលទុកក្នុងសុភទ្ទកណ្ឌថា ៖

លំដាប់នោះ ព្រះមហាកស្សបៈមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ សម័យមួយខ្ញុំដើរផ្លូវឆ្ងាយ ចាកក្រុងបាវាមកកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប ដូច្នេះ ជាដើម ។

សុភទ្ទកណ្ឌទាំងអស់ បណ្ឌិតគប្បីជ្រាបដោយពិស្ដារ ។ តែខ្ញុំនឹងពោល សេចក្ដីរបស់សុភទ្ទកណ្ឌនោះ ក្នុងអនាគតស្ថានពេលចប់មហា-បរិនិព្វានសូត្រប៉ុណ្ណោះ ។

ខាងមុខអំពីនោះ ព្រះមហាកស្សបៈបានពោលថា ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនាធម៌ និងវិន័យ តំណទៅមុខអធម៌មុខជានឹងរុងរឿង ធម៌មុខជានឹងសាបសូន្យទៅ តំណទៅមុខ អវិន័យមុខជានឹងរុងរឿង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ អធម្មវាទីនឹងមានកម្លាំងឡើង ធម្មវាទីនឹងថយកម្លាំងចុះ តំណទៅ អវិនយវាទីនឹង

មានកម្លាំងឡើង វិនយវាទីនឹងថយកម្លាំងចុះ ដូច្នេះ ។ ភិក្ខុទាំងឡាយបានទូលព្រះថេរៈថា បពិត្រព្រះថេរៈដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសនូវភិក្ខុទាំងឡាយចុះ ។

ចំណែកព្រះថេរៈវៀរភិក្ខុបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តសុក្ខវិបស្សកៈ អ្នកទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសន៍ទាំងអស់ មានចំនួនច្រើនរយច្រើនពាន់រូប ជ្រើសរើសយកចំពោះភិក្ខុដែលជាព្រះអរហន្តប្រភេទតេវិជ្ជាជាដើម ដែលទ្រទ្រង់ព្រះបរិយត្តិ គឺ ព្រះត្រៃបិដកទាំងអស់ សម្រេចបដិសម្ភិទា មានអានុភាពធំក្រៃលែង ដោយច្រើនព្រះមានព្រះភាគទ្រង់លើកតម្កើងជាឯតទគ្គៈ ដែលព្រះសង្គីតិកាចារ្យសំដៅពោលពាក្យនេះទុកថា គ្រានោះឯង "ទើបព្រះមហាកស្សបៈមានអាយុ ជ្រើសរើសនូវព្រះអរហន្តបាន ចំនួន ៤៩៩ អង្គ" ដូច្នេះជាដើម ។

សួរថា ក៏ព្រោះហេតុអ្វី ? ព្រះមហាកស្សបត្ថេរ ទើបធ្វើឲ្យខ្វះមួយអង្គ ។

ឆ្លើយថា ដើម្បីទុកឱកាសដល់ព្រះអានន្ទត្ថេរ ព្រោះរួមទាំងព្រះអានន្ទ បើវៀរព្រះអានន្ទចេញ មិនអាចធ្វើការសង្គាយនាធម៌បាន ។ សេចក្តីថា ព្រះអានន្ទនោះជាព្រះសេក្ខៈ នៅមានកិច្ចដែលត្រូវធ្វើដូច្នោះ ទើបមិនអាចរួមបាន ។ តែព្រោះនវង្គសត្ថុសាសន៍ មានសុត្តៈ និងគេយ្យៈ

ជាដើមប្រការណាមួយ ដែលព្រះទសពលទ្រង់សម្ដែងហើយ ដែលឈ្មោះថា មិនប្រចក្សច្បាស់ដល់ព្រះអានន្ទនោះមិនមាន ដូចគាថាប្រព័ន្ធដែលលោកពោលទុកថា ៖

**ធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងហឫទ័យ របស់ខ្ញុំ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨២,០០០ ធម្មក្ខន្ធ រៀនមកអំពីពួកភិក្ខុ ២,០០០ ធម្មក្ខន្ធ រួមជា ៨៤,០០០ ព្រះធម្មក្ខន្ធ ព្រោះដូច្នោះ ប្រសិនបើវៀរព្រះអានន្ទចេញ ក៏មិនអាចសម្រេចបាន ។**

ព្រោះដូច្នោះ បើវៀរព្រះអានន្ទចេញ ក៏មិនអាចធ្វើបាន ។

សួរថា បើដូច្នោះ សូម្បីព្រះអានន្ទជាព្រះសេក្ខៈនៅឡើយ ព្រះថេរៈក៏គួរជ្រើសរើស ព្រោះជាអ្នកមានឧបការៈក្នុងការសង្គាយនាធម៌ច្រើន តើហេតុដូចម្ដេច ទើបមិនជ្រើសរើស ? ។ ឆ្លើយថា ព្រោះចៀសវាងពាក្យតិះដៀលរបស់អ្នកដទៃ ។ សេចក្ដីពិត ព្រះថេរៈជាអ្នកជិតដិតនឹងព្រះអានន្ទយ៉ាងក្រៃលែង ។ ពិតមែន សូម្បីព្រះអានន្ទមានសក់ស្កូវហើយ ព្រះមហាកស្សបៈនៅតែហៅដោយពាក្យថា ក្មេង ក្នុងប្រយោគថា "ក្មេងម្នាក់នេះ មិនដឹងប្រមាណឡើយ" ដូច្នេះ ។ មួយវិញទៀត ព្រះអានន្ទកើតក្នុងត្រកូលសក្យៈ ជាព្រះអនុជរបស់ព្រះតថាគត ជាព្រះឱរសរបស់ព្រះរាជា ជាឱពុកមា ។

ក្នុងការជ្រើសរើសព្រះអានន្ទនោះ ភិក្ខុពួកខ្លះនឹងយល់ថា មើលដូចជាលំអៀងព្រោះស្រឡាញ់គ្នា នឹងនាំគ្នាតិះដៀលថា ព្រះមហាកស្សបត្ថេរ មើលរំលងភិក្ខុដែលបានសម្រេចបដិសម្ភិទា ប្រភេទអសេក្ខៈមានចំនួនច្រើន ហើយជ្រើសរើសព្រះអានន្ទ អ្នកសម្រេចបដិសម្ភិទាប្រភេទសេក្ខៈ កាលនឹងចៀសវាងពាក្យតិះដៀលនោះ ព្រះមហាកស្សបត្ថេរទើបមិន ជ្រើសរើសព្រះអានន្ទ ដោយពិចារណាឃើញថា វៀរព្រះអានន្ទនោះចេញ មិនអាចធ្វើការសង្គាយនាធម៌បាន យើងនឹងទទួលព្រះអានន្ទដោយអនុមតិរបស់ភិក្ខុទាំងឡាយនោះ ។

លំដាប់នោះ ភិក្ខុទាំងឡាយនាំគ្នាសូមអង្វរព្រះមហាកស្សបត្ថេរ ដើម្បីជ្រើសរើសព្រះអានន្ទដោយខ្លួនឯង ។ សមដូចពាក្យដែលព្រះសង្គីតិកាចារ្យពោលទុកថា ពួកភិក្ខុ បានពោលពាក្យនេះចំពោះព្រះមហាកស្សបៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទដ៏មានអាយុនេះ នៅជាព្រះសេក្ខៈក៏ពិត តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្តី វិន័យក្តី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុងសម្នាក់ព្រះមានព្រះភាគដ៏ច្រើន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈធ្វើការជ្រើសរើសយកព្រះអានន្ទមានអាយុចុះ ។ កាលសម្រេចហើយ ព្រះមហាកស្សបៈមានអាយុ ជ្រើសរើសយកព្រះអានន្ទដ៏មានអាយុបញ្ចូលផង ។

ដោយន័យដូចពោលហើយយ៉ាងនេះ ទើបជាព្រះថេរៈ ៥០០ អង្គ រួមទាំងព្រះអានន្ទ ដែលព្រះមហាកស្សបៈ ជ្រើសរើសដោយអនុមតិរបស់ភិក្ខុទាំងឡាយ ។ លំដាប់នោះឯង ពួកភិក្ខុជាព្រះថេរៈបានត្រិះរិះគ្នាថា ៖

យើងទាំងឡាយ គប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យក្នុងទីណាហ្ន៎ ។ គ្រានោះឯង ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្តីត្រិះរិះឃើញដូច្នេះថា ក្រុងរាជគ្រឹះ មានអាហារបិណ្ឌបាតច្រើន មានសេនាសនៈសមល្មម បើដូច្នោះ គួរតែយើងរាល់គ្នាទៅនៅចាំវស្សា សង្គាយនាព្រះធម៌និងព្រះវិន័យក្នុងក្រុងរាជគ្រឹះចុះ , ចំណែកភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅនៅចាំវស្សាក្នុងក្រុងរាជគ្រឹះឡើយ ។ ក៏ព្រោះហេតុអ្វី ព្រះថេរៈទាំងនោះ ទើបមានសេចក្តីត្រិះរិះដូច្នេះ ? ព្រោះព្រះថេរៈទាំងនោះ មានសេចក្តីត្រិះរិះស្របគ្នាថា ការសង្គាយនាព្រះធម៌វិន័យនេះ ជាថាវរកម្មរបស់យើង បុគ្គលក្រៅអំពីនេះ នឹងចូលទៅកាន់កណ្តាលសង្ឃហើយ ធ្វើឲ្យខូចកម្មបាន ។

លំដាប់នោះ ព្រះមហាកស្សបមានអាយុ បានប្រកាសឲ្យសង្ឃជ្រាបដោយញត្តិទុតិយកម្មវាចាថា ម្នាលលោកមានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃមានហើយ សង្ឃគប្បីសន្មតភិក្ខុ ៥០០ រូបទាំងនេះ ជាអ្នកនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ដើម្បីសង្គាយនានូវព្រះធម៌ និងព្រះវិន័យ ឯភិក្ខុទាំងឡាយដទៃ មិនត្រូវចាំ

វស្សាក្នុងក្រុងរាជគ្រិះឡើយ នេះជាញត្តិ ។ ម្នាលលោកមានអាយុទាំងឡាយ សូមសង្ឃស្ដាប់ខ្ញុំ ឥឡូវសង្ឃសន្មតភិក្ខុ ៥០០ រូបទាំងនេះថា ភិក្ខុ ៥០០ រូបទាំងនេះ ឲ្យនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ដើម្បីសង្គាយនានូវព្រះធម៌ និងព្រះវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ដូច្នេះ ។ ការសន្មតិភិក្ខុទាំង ៥០០ រូបនេះថាភិក្ខុ ៥០០ រូបទាំងនេះ ឲ្យនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវឲ្យនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ដូច្នេះ គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីនៅស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណាលោកមានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុទាំង ៥០០ រូបនេះសង្ឃសន្មតហើយថា ឲ្យនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវនៅចាំវស្សាក្នុងក្រុងរាជគ្រឹះឡើយ ។ ការសម្មតិនេះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ សង្ឃទើបនៅស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការនៅស្ងៀមយ៉ាងនេះ ។

កម្មវាចានេះ ព្រះមហាកស្សបៈធ្វើក្នុងថ្ងៃទី ២១ ក្រោយពីព្រះតថាគតបរិនិព្វាន ។ ព្រោះព្រះមានព្រះភាគ បរិនិព្វានវេលាជិតភ្លឺ ថ្ងៃវិសាខបូណ៌មី ។

គ្រានោះ ពុទ្ធបរិស័ទបានបូជាព្រះពុទ្ធសរីរៈដែលមានពណ៌ដូចមាស ដោយរបស់ក្រអូប និងផ្កាឈើជាដើម រហូតអស់ ៧ ថ្ងៃ ។ ថ្ងៃសាធុ-កីឡា ក៏អស់វេលា ៧ ថ្ងៃដូចគ្នា ។ តពីនោះ ភ្លើងនៅចិតកាធារមិនទាន់រលត់រហូតអស់ ៧ ថ្ងៃ ។ ពួកមល្លក្សត្រិយ៍បានធ្វើរបងលំពែង ហើយបូជាព្រះបរមសារីរិកធាតុក្នុងសណ្ឋាគារសាលា រហូតអស់ ៧ ថ្ងៃ ដូច្នោះ ទើបរួមបាន ២១ ថ្ងៃ ។ ពុទ្ធបរិស័ទ ដែលមានទោណព្រាហ្មណ៍ជាប្រធាន បានចាត់ចែងបែងចែកព្រះបរមសារីរិកធាតុទាំងឡាយ ក្នុងព្រឹកថ្ងៃ ៥ កើត ខែ ៧ នោះឯង ។ ព្រះមហាកស្សបៈ ជ្រើសរើសភិក្ខុទាំងឡាយរួចស្រេចហើយ ទើបសូត្រកម្មវាចា ដោយន័យដែលលោកបង្ហាញការប្រព្រឹត្តមិនសមគួរដល់សុភទ្ទៈបួសចាស់ ធ្វើហើយដល់ភិក្ខុសង្ឃចំនួនច្រើន ដែលមកប្រជុំគ្នាក្នុងថ្ងៃបែងចែកព្រះបរមសារីរិកធាតុនោះ ។

ក៏កាលសូត្រកម្មវាចានេះហើយ ព្រះថេរៈទើបដាស់តឿនភិក្ខុទាំងឡាយឲ្យជ្រាបថា ម្នាលលោកដ៏មានអាយុទាំងឡាយ ឥឡូវនេះខ្ញុំឲ្យវេលាដល់លោកទាំងឡាយចំនួន ៤០ ថ្ងៃ តពីនោះទៅ លោកនឹងពោលថា ខ្ញុំនៅមានកង្វល់ដូច្នេះ នៅមិនមាន ព្រោះដូច្នោះ ខាងក្នុង ៤០ ថ្ងៃនេះ លោកអង្គណា មានកង្វល់ជាប់ទាក់ទងនឹងរោគភ័យ អាពាធក្តី មានកង្វល់ជាប់ទាក់ទងនឹងអាចារ្យ និងព្រះឧបជ្ឈាយ៍ក្តី មានកង្វល់ជាប់ទាក់ទងនឹងមាតាបិតាក្តី ឬត្រូវជុតបាត្រ ត្រូវធ្វើចីវរក្តី សូមលោកអង្គ

នោះ កាត់កង្វល់នោះ ធ្វើកិច្ចដែលគួរធ្វើនោះឲ្យហើយ ។ ក៏ពោល យ៉ាងនេះហើយ ព្រះថេរៈហែហមទៅដោយបរិស័ទរបស់ខ្លួនប្រមាណ ៥០០ រូប ទៅកាន់ក្រុងរាជគ្រឹះ ។ សូម្បីព្រះថេរៈអង្គធំដទៃៗ ក៏នាំបរិវារ របស់ខ្លួន ៗ ទៅ មួយអង្គៗ ក៏ប្រាថ្នានឹងលួងលោមមហាជន អ្នកពោរ-ពេញទៅដោយសេចក្ដីសោក ទើបទៅកាន់ទិសផ្លូវនោះៗ ចំណែកព្រះ បុណ្ណត្ថេរ មានភិក្ខុជាបរិវារប្រមាណ ៧០០ រូប បាននៅក្នុងក្រុងកុសិនារា នុ៎ះឯង ដោយប្រាថ្នាថា នឹងលួងលោមមហាជនដែលនាំគ្នាមកកាន់ទីបរិ-និព្វានរបស់ព្រះតថាគត ។

ចំណែកព្រះអានន្ទ លោកក៏កាន់បាត្រ និងចីវររបស់ព្រះមានព្រះភាគ សូម្បីស្ដេចបរិនិព្វានហើយ ដូចកាលស្ដេចមិនទាន់បរិនិព្វាន ធ្វើដំណើរ ទៅកាន់ក្រុងសាវត្ថីព្រមដោយភិក្ខុសង្ឃ ៥០០ រូប ។ ក៏កាល ព្រះអានន្ទ នោះកំពុងដើរផ្លូវ ក៏មានភិក្ខុដែលជាបរិវារច្រើនឡើងៗ ដរាបរាប់មិន បាន ។ ក្នុងស្ថានទីដែលព្រះអានន្ទដើរផ្លូវទៅ បានឮសម្រែកយំ អឺងកង ។ កាលព្រះថេរៈទៅដល់ក្រុងសាវត្ថីហើយ មនុស្សក្នុងក្រុង សាវត្ថីបានជ្រាបថា ព្រះអានន្ទមកហើយ ក៏នាំគ្នាកាន់របស់ក្រអូប និងផ្កា ឈើជាដើមទៅទទួល ហើយស្រែកយំត្អូញត្អែរថា បពិត្រព្រះអានន្ទដ៏ ចម្រើន កាលមុនលោកមកជាមួយព្រះមានព្រះភាគ ថ្ងៃនេះ លោកចោល ព្រះមានព្រះភាគទុកទីណា ទើបមកតែមួយអង្គឯង ដូច្នេះជាដើម ។ បាន

មានការស្រែកយំយ៉ាងច្រើន ដូចក្នុងថ្ងៃបរិនិព្វានរបស់ព្រះមានព្រះភាគ ដូច្នោះ ។

បានឮថា ក្នុងក្រុងសាវត្ថីនោះ ព្រះអានន្ទទូន្មានមហាជនឲ្យយល់ដោយធម្មីកថា ប្រកបដោយសេចក្ដីមិនទៀងជាដើម ហើយចូលកាន់ព្រះវិហារជេតពន សំពះព្រះគន្ធកុដិដែលព្រះទសពលប្រថាប់ បើកទ្វារ នាំគ្រែ តាំងចេញ បោសសំអាត ព្រះគន្ធកុដិ ចោលសំរាម ផ្កាឈើស្ងួត ហើយនាំគ្រែ តាំង ចូលទៅតាំងទុកក្នុងទីដើមវិញ បានធ្វើនាទីគ្រប់យ៉ាងដែលជាវត្ត ដែលជាវត្តត្រូវបដិបត្តិក្នុងវេលាដែលព្រះមានព្រះភាគនៅមានព្រះជន្ម និងកាលធ្វើនាទី ក៏ថ្វាយបង្គំព្រះគន្ធកុដិ ក្នុងវេលាធ្វើកិច្ច មានការបោសសំអាតបន្ទប់ទឹក និងតាំងទឹកជាដើម បានធ្វើនាទីបណ្ដើរ យំរៀបរាប់បណ្ដើរ ដោយន័យជាដើមថា បពិត្រព្រះមានព្រះភាគ វេលានេះជាវេលាស្រង់ទឹករបស់ព្រះអង្គ មិនមែនឬ ? វេលានេះ ជាវេលាសម្ដែងធម៌ វេលានេះ ជាវេលាប្រទានឱវាទដល់ភិក្ខុទាំងឡាយ វេលានេះ ជាវេលាសម្រេចសីហសេយ្យា វេលានេះ ជាវេលាជម្រះព្រះភ័ក្ត្រ មិនមែនឬ ? ហេតុទាំងនេះ ព្រោះព្រះអានន្ទនោះ ជាអ្នកមានសេចក្ដីស្រឡាញ់យ៉ាងក្រៃលែងក្នុងព្រះមានព្រះភាគ ព្រោះជាអ្នកដឹងអមតរស ដែលជាទីរួមព្រះពុទ្ធគុណ និងមិនទាន់បានជាព្រះអរហន្ត ទាំងជាអ្នកមានចិត្តទន់ខ្សោយ ដែលធ្លាប់ឧបការៈគ្នានិងគ្នាមកច្រើនសែនជាតិ ។ ទេវតាមួយ

អង្គ បានធ្វើឲ្យព្រះអានន្ទនោះតក់ស្លុត ដោយពាក្យនិយាយថា បពិត្រព្រះអានន្ទដ៏ចម្រើន លោករវល់តែមកយំរៀបរាប់យ៉ាងនេះ នឹងលួងលោមអ្នកដទៃ បានយ៉ាងណា ។ ព្រះអានន្ទតក់ស្លុត ដោយពាក្យនិយាយរបស់ទេវតានោះ ធ្វើចិត្តឲ្យក្លាហាន ផឹកថ្នាំបញ្ចុះលាយទឹកដោះក្នុងថ្ងៃទី ២ ដើម្បីធ្វើកាយដែលមានធាតុធ្ងន់ឲ្យស្រាល ព្រោះតាំងពីព្រះតថាគតស្ដេចបរិនិព្វាន លោកត្រូវឈរច្រើន និងអង្គុយច្រើន ទើបអង្គុយនៅតែក្នុងព្រះវិហារជេតពនប៉ុណ្ណោះ ព្រះអានន្ទផឹកថ្នាំបញ្ចុះ លាយទឹកដោះប្រភេទណា លោកសំដៅយកថ្នាំបញ្ចុះលាយទឹកដោះប្រភេទនោះ បានពោលនឹងក្មេងកម្លោះ ដែលសុភមាណពប្រើទៅថា ម្នាលមាណព ថ្ងៃនេះជាកាលមិនគួរនឹងទៅទេ ដ្បិតថ្ងៃនេះ យើងបានឆាន់ថ្នាំបញ្ចុះខ្លះហើយ បើដូច្នោះចាំថ្ងៃស្អែក ទើបយើងទៅ ដូច្នេះ ។ ក្នុងថ្ងៃទី ២ ព្រះអានន្ទ មានព្រះចេតកត្ថេរជាប់តាមទៅ ត្រូវសុភមាណពសួរបញ្ហា បានពោលសូត្រទី ១០ ឈ្មោះសុភសូត្រ ក្នុងគម្ពីរទីឃនិកាយនេះ ។

ព្រះអានន្ទត្ថេរ សូមឲ្យធ្វើការជួសជុលវត្ថុដែលទ្រុឌទ្រោម ក្នុងព្រះជេតពនមហាវិហារ កាលជិតថ្ងៃចូលវស្សា លោកទូលលាភិក្ខុសង្ឃទៅក្រុងរាជគ្រឹះ ។ សូម្បីភិក្ខុទាំងឡាយដទៃដែលធ្វើសង្គាយនា ក៏ទៅដូចគ្នា សេចក្ដីពិត លោកសំដៅយកភិក្ខុទាំងនោះ ដែលទៅក្រុងរាជគ្រឹះយ៉ាងនេះ ពោលពាក្យនេះទុកថា គ្រានោះឯង ភិក្ខុជាព្រះថេរៈទាំងឡាយ

បានទៅកាន់ក្រុងរាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ" ។ ព្រះថេរៈទាំងនោះ ធ្វើឧបោសថ ក្នុងថ្ងៃ ១៥ កើត ខែ ៨ ប្រជុំចូលវស្សា ក្នុងថ្ងៃ ១ រោច ។

## បឋមសង្គាយនា ផ្ដើមថ្ងៃ ៥រោច ខែ ៩

សម័យនោះឯង មានវត្តធំ ១៨ វត្ត នៅជុំវិញក្រុងរាជគ្រឹះ ។ វត្តទាំងនោះ មានសំរាមត្រូវបោលរាត់រាយពាសពេញ ព្រោះក្នុងវេលាបរិនិព្វានរបស់ព្រះមានព្រះភាគ ភិក្ខុទាំងអស់ក៏កាន់បាត្រចីវររៀងៗ ខ្លួនបោលវត្ត និងបរិវេណទៅ ។ គ្រានោះ ព្រះថេរៈទាំងឡាយ កាលនឹងធ្វើការសម្រេចចិត្តនឹងជួសជុលវត្តទាំងនោះ បានគិតគ្នាថា ពួកយើង ត្រូវធ្វើការជួសជុលវត្តដែលទ្រុឌទ្រោម រហូតដល់អស់ខែដើមរបស់វស្សា ដើម្បីបូជាពាក្យទូន្មានរបស់ព្រះមានព្រះភាគ និងដើម្បីដោះពាក្យតិះដៀលរបស់តិរ្ថិយ ។ ព្រោះពួកតិរ្ថិយនឹងគប្បីពោលតិះដៀលយ៉ាងនេះថា សាវករបស់ព្រះសមណគោតមថែទាំវត្តអារាម តែកាលព្រះសាស្ដានៅមានព្រះជន្មប៉ុណ្ណោះ កាលព្រះអង្គបរិនិព្វានហើយ ក៏នាំគ្នាលះបង់បោលការបរិច្ចាគទ្រព្យជាចំនួនច្រើនរបស់ត្រកូលទាំងឡាយ រមែងវិនាសបាត់ទៅ ដោយ

ទំនងនេះ ។ មានពាក្យអធិប្បាយថា ការដែលព្រះថេរៈទាំងឡាយគិតគ្នា ដើម្បីនឹងដោះពាក្យតិះដៀលរបស់តិរ្ថិយទាំងនោះ ។ លុះគិតយ៉ាងនេះហើយ ទើបបានធ្វើការព្រមព្រៀងគ្នា ដែលលោកសំដៅយកការសម្រេចចិត្តនោះ ពោលថា គ្រានោះឯង ភិក្ខុទាំងឡាយជាព្រះថេរៈ បានប្រឹក្សាគ្នាថា ម្នាល អាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សរសើរបដិសង្ខរណកម្ម គឺ ការជួសជុលសេនាសនៈដែលទ្រុឌទ្រោម ឥឡូវនេះ យើងទាំងឡាយចូរ ធ្វើការជួសជុលវត្តដែលទ្រុឌទ្រោម អស់ ១ ខែ ជាដំបូងសិន ដល់មក ខែកណ្តាល យើងនឹងប្រជុំគ្នាសង្គាយនានូវព្រះធម៌ និងព្រះវិន័យ ។

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងនោះ បានទៅឈរត្រង់ទ្វារព្រះរាជវាំង ។ ព្រះបាទអជាតសត្តុស្តេចមកនមស្ការហើយ មានព្រះរាជតម្រាស់សួរដល់ កិច្ចដែលព្រះអង្គធ្វើថា លោកម្ចាស់ទាំងឡាយ មកដោយធុរៈអ្វី ? ព្រះ ថេរៈទាំងឡាយថ្វាយព្រះពរ ឲ្យទ្រង់ជ្រាបដល់ការងារហត្ថកម្ម ដើម្បី ប្រយោជន៍ដល់ការជួសជុលវត្តធំ ១៨ វត្ត ។ ព្រះបាទអជាតសត្តុ បាន ព្រះរាជទានអ្នកធ្វើការងារហត្ថកម្ម ។ ព្រះថេរៈឲ្យជួសជុលវត្តទាំងអស់ រហូតដល់អស់ ១ ខែ នាដើមរដូវភ្លៀងរួចស្រេចហើយ ថ្វាយព្រះពរ ចំពោះព្រះបាទអជាតសត្តុថា “សូមថ្វាយព្រះពរមហាបពិត្រ ការងារជួស ជុលវត្តរួចស្រេចហើយ ឥឡូវនេះអាត្មាភាពទាំងឡាយ នឹងធ្វើការសង្គាយនា ព្រះធម៌ និងព្រះវិន័យ” ។ ព្រះបាទអជាតសត្តុមានព្រះរាជតម្រាស់ថា “ព្រះ

ករុណាល្អហើយ លោកម្ចាស់ទាំងឡាយនិមន្តធ្វើចុះ មិនគប្បីជូនចិត្តឡើយ ការងារផ្នែកអាណាចក្រសូមឲ្យជានាទីរបស់ញោម ឯផ្នែកធម្មចក្រ សូមឲ្យជានាទីរបស់លោកម្ចាស់ទាំងឡាយ ញោមនឹងត្រូវធ្វើអ្វីខ្លះ មេត្តាបង្គាប់មកចុះលោកម្ចាស់” ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរថា “សូមថ្វាយព្រះពរមហាបពិត្រ សូមព្រះអង្គមេត្តាឲ្យធ្វើទីអង្គុយប្រជុំ សម្រាប់ភិក្ខុទាំងឡាយអ្នកធ្វើសង្គាយនា” ។ នឹងធ្វើទីណា លោកម្ចាស់ ? សូមថ្វាយព្រះពរមហាបពិត្រ គួរធ្វើជិតទ្វារល្អាងសត្តបណ្ណិៈ ខាងភ្នំវេភារៈ ។ ព្រះបាទអជាតសត្តុ មានព្រះរាជតម្រាស់ថា សមគួរល្អណាស់ លោកម្ចាស់ ហើយក៏ទ្រង់បញ្ជាឲ្យសាងមណ្ឌប មានគ្រឿងប្រដាប់វិសេសដែលគួរសរសើរ មានទ្រង់ទ្រាយសណ្ឋានដូចអាគារដែលវិស្សុកម្មទេវបុត្រនិម្មិតទុក មានជញ្ជាំងសសរ និងជណ្តើរ ចាត់ចែងទុកយ៉ាងល្អ មានសេចក្តីល្អវិចិត្រទៅដោយមាលាកម្ម និងលតាកម្មប្រភេទផ្សេងៗ ហាក់ដូចជាថា នឹងគ្របដណ្តប់លើភាពល្អនៃព្រះដំណាក់របស់ព្រះរាជា ល្អស្រស់ដូចជាចំអកឡកឡឺយសេចក្តីល្អរបស់ទេវវិមាន ប្រដូចជាស្ថានដែលរួមនៅរបស់ជោគវាសនា ហាក់បីដូចជាកំពង់ដែលរួមចុះរបស់ហ្វូងវិហគៈ គឺ ភ្នែកនៃទេវតា និងមនុស្សទាំងឡាយ ត្រឹមតែដូចភាពដែលល្អភ្នែក គួររីករាយក្នុងលោកដែលប្រមូលទុកក្នុងទីតែមួយ មានពិតានល្អទាក់ទាញភ្នែកដូចនឹងបញ្ចេញនូវក្បួងផ្កាឈើផ្សេងៗ និងគុជដែលបណ្តោងចុះ មើលដូចជាផែនដី ប្រដាប់

លំអដោយទន្ទឹម វិចិត្រទៅដោយរតនៈផ្សេងៗ មានទីទែនដែលសម្រេចរៀបរយល្អដោយផ្កាឈើបូជាប្រភេទផ្សេងៗ ប្រដាប់ឲ្យវិចិត្រស្រដៀងនឹងវិមានព្រហ្ម ទ្រង់បង្គាប់ឲ្យក្រាលអាសនៈ ដែលជាកប្បិយៈ ៥០០ ដែលមានតម្លៃរាប់មិនបានក្នុងមហាមណ្ឌបនោះ សម្រាប់ភិក្ខុ ៥០០ រូប ឲ្យក្រាលទីអង្គុយសម្រាប់ព្រះថេរៈ បែរមុខទៅទិសខាងជើង បែរខ្នងទៅផ្លូវទិសខាងត្បូង ឲ្យក្រាលទីអង្គុយសម្តែងធម៌ ដែលគួរដល់ការប្រថាប់របស់ព្រះពុទ្ធដ៏មានបុណ្យ បែរមុខផ្លូវទិសខាងកើត ត្រង់កណ្តាលមណ្ឌប ដាក់ផ្លិតធ្វើដោយភ្លុកដំរី ទុកលើធម្មាសនៈនោះ ហើយមានព្រះបន្ទូលប្រាប់ដល់ភិក្ខុសង្ឃថា កិច្ចរបស់ញោមរួចស្រេចហើយ លោកម្ចាស់ ។

ក៏ក្នុងថ្ងៃនោះ ភិក្ខុពួកខ្លះបាននិយាយប៉ះពាល់ដល់ព្រះអានន្ទយ៉ាងនេះថា "ក្នុងពួកភិក្ខុនេះ មានភិក្ខុមួយរូបដើរបង្ហើរក្លិនអ្នប" ព្រះអានន្ទត្រូវបានឮពាក្យនោះហើយ ដល់សេចក្តីសង្វេគថា "ភិក្ខុដទៃដែលឈ្មោះថាដើរបង្ហើរក្លិនអ្នប មិនមានក្នុងពួកភិក្ខុនេះ ភិក្ខុទាំងនេះ គង់និយាយសំដៅដល់យើងពិត" ។ ភិក្ខុពួកខ្លះពោលនឹងព្រះអានន្ទនោះថា "ម្នាលអានន្ទ ការប្រជុំធ្វើសង្គាយនានឹងមានក្នុងថ្ងៃស្អែកនេះ តែលោកនៅជាព្រះសេក្ខៈ នៅមានកិច្ចដែលនឹងត្រូវធ្វើ ដោយហេតុនោះ អ្នកមិនគួរចូលប្រជុំ អ្នកចូរកុំប្រមាទឡើយ" ។

## ព្រះអានន្ទសម្រេចព្រះអរហត្ត

គ្រានោះឯង ព្រះអានន្ទគិតថា "ស្អែកនេះ ជាថ្ងៃប្រជុំធ្វើសង្គាយនាការដែលយើងនៅជាព្រះសេក្ខៈ នឹងចូលប្រជុំនោះ មិនសមគួរដល់យើងឡើយ" ហើយឲ្យវេលាកន្លងទៅ ដោយកាយគតាសតិកម្មដ្ឋាន រហូតដល់អស់រាត្រីជាចំណែកច្រើន ក្នុងវេលាជិតភ្លឺរបស់រាត្រីនោះ ក៏ចុះចាកទីចង្ក្រមចូលវិហារ ទម្រេតកាយចុះបំណងនឹងដេក ។ ជើងទាំងពីរផុតពីផែនដីហើយ តែសីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនេះ ចិត្តក៏ផុតចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ព្រះអានន្ទត្ថេរនេះ ឲ្យវេលាកន្លងទៅក្នុងខាងក្រៅដោយការចង្ក្រម កាលមិនអាចឲ្យគុណវិសេសកើតឡើងបាន ក៏គិតថា "ព្រះដ៏មានព្រះភាគ បានត្រាស់ចំពោះយើងទុកមិនមែនឬថា ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមរឿយៗ ចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់ ដូច្នេះ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនត្រាស់ខុសភ្លាត់ តែយើងប្រារព្ធសេចក្តីព្យាយាមច្រើនពេកទៅ ដូច្នោះ ចិត្តរបស់យើងទើបរវើរវាយ ពេលនេះយើងនឹងប្រកបសេចក្តីព្យាយាមល្មមៗ លុះគិតដូច្នេះហើយ ចុះចាកទីចង្ក្រម ឈរក្នុងទីលាងជើង លាងជើងហើយក៏ចូលវិហារ អង្គុយលើគ្រែគិតថា នឹងសម្រាកត្រឹមតែបន្តិច ហើយទម្រេតកាយលើគ្រែ ជើងទាំងពីរ

ផុតពីផែនដី សីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនេះ ចិត្តក៏ផុតពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ភាពជាព្រះអរហន្តរបស់ព្រះអានន្ទត្ថេរ វៀរចាកឥរិយាបថ ៤ ដូច្នោះ កាលមានការពោលសួរគ្នាឡើងថា ក្នុងសាសនានេះ ភិក្ខុដែលមិនដេក មិន អង្គុយ មិនឈរ មិនដើរចង្ក្រម តែបានសម្រេចព្រះអរហត្ត គឺ ភិក្ខុរូបណា គួរឆ្លើយថា គឺព្រះអានន្ទត្ថេរ ។

គ្រានោះ ក្នុងថ្ងៃទី ២ តអំពីថ្ងៃដែលព្រះអានន្ទសម្រេចព្រះអរហត្ត គឺថ្ងៃ ៥ រោច ពួកភិក្ខុឆាន់ព្រះថេរៈឆាន់រួចស្រេចហើយ រក្សាបាត្រ និងចីវរ ហើយប្រជុំគ្នាក្នុងធម្មសភា ។ សម័យនោះឯង ព្រះអានន្ទមានអាយុបានជាព្រះអរហន្តហើយ ទើបបានទៅកាន់ទីប្រជុំសង្ឃ ។ លោកទៅយ៉ាងណា ។ ព្រះអានន្ទមានសេចក្តីត្រេកអរថា ឥឡូវនេះ យើងសមគួរចូលក្នុងកណ្តាលទីប្រជុំហើយ ដណ្តប់ចីវរឆៀងស្មាម្ខាង មានលក្ខណៈដូចផ្លែត្នោតទុំដែលជ្រុះចាកទង មានលក្ខណៈដូចត្បូងទទឹមដែលដាក់លើសំពត់កម្ពលពណ៌លឿង មានលក្ខណៈដូចព្រះចន្ទពេញវង់ ដែលអណ្តែតឆ្ពោះក្នុងផ្ទៃនភាកាស ដែលប្រាសចាកពពក និងមានលក្ខណៈដូចផ្កាឈូក មានកេសរ និងត្របក ក្រហមព្រឿងៗ កំពុងរីកដោយត្រូវពន្លឺព្រះអាទិត្យស្រទន់ៗ ហាក់ដូចជាប្រាប់រឿងដែលខ្លួនសម្រេចព្រះអរហត្ត ដោយមាត់ដ៏ប្រសើរបរិសុទ្ធិផូរផង់ មានរស្មី និងមានសិរី បានទៅកាន់ទីប្រជុំសង្ឃ ។

គ្រានោះ ព្រះមហាកស្សបៈពេលឃើញព្រះអានន្ទ ដូច្នោះ មានសេចក្តីរលឹកដឹងថា លោកដ៏ចម្រើន ព្រះអានន្ទសម្រេចព្រះអរហត្តហើយ ល្អពិតៗ បើព្រះសាស្តាទ្រង់នៅមានព្រះជន្ម ព្រះអង្គក៏នឹងគប្បីប្រទានសាធុការដល់ព្រះអានន្ទក្នុងថ្ងៃនេះពិតប្រាកដ ឥឡូវនេះ យើងនឹងឲ្យសាធុការដែលព្រះសាស្តា គួរប្រទានដល់ព្រះអានន្ទនោះ ដូច្នេះហើយ បានឲ្យសាធុការ ៣ ដង ។

ចំណែកព្រះមជ្ឈិមភាណកាចារ្យពោលថា ព្រះអានន្ទត្ថេរ ប្រាថ្នានឹងឲ្យសង្ឃជ្រាបរឿងដែលខ្លួនសម្រេចព្រះអរហត្ត ទើបមិនបានទៅព្រមនឹងភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយកាលអង្គុយលើអាសនៈដែលត្រូវបានដល់ខ្លួនៗ តាមលំដាប់អាវុសោ ក៏អង្គុយវៀរអាសនៈរបស់ព្រះអានន្ទត្ថេរៈទុក ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះសួរថា នុ៎ះអាសនៈរបស់អ្នកណា ? បានឆ្លើយថា របស់ព្រះអានន្ទ ។ ភិក្ខុទាំងនោះសួរទៀតថា ព្រះអានន្ទទៅណាហ្ន៎ ? សម័យនោះ ព្រះអានន្ទត្ថេរគិតថា ឥឡូវនេះ ជាវេលាដែលយើងគួរនឹងទៅ តពីនោះ កាលនឹងសម្តែងអានុភាពរបស់ខ្លួន លោកទើបមុជចុះក្នុងដី ហើយសម្តែងខ្លួនលើអាសនៈរបស់ខ្លួនតែម្តង ។ អាចារ្យមួយពួកទៀតពោលថា ព្រះអានន្ទទៅផ្លូវអាកាស ហើយអង្គុយលើអាសនៈរបស់ខ្លួន ដូច្នេះក៏មាន ។ យ៉ាងណាក៏ដោយ ការដែលព្រះមហាកស្សបៈឃើញព្រះអានន្ទហើយ ឲ្យសាធុការ ជាការសមរម្យដោយប្រការទាំងពួង

តែម្តង ។

កាលព្រះអានន្ទមកយ៉ាងនេះហើយ ព្រះមហាកស្សបត្ថេរ ទើបប្រឹក្សាសុំយោបល់ភិក្ខុទាំងឡាយថា “ ម្នាលលោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយនឹងសង្គាយនាអ្វីមុន ព្រះធម៌ ឬព្រះវិន័យ ?” ភិក្ខុទាំងឡាយពោលថា “ បពិត្រព្រះមហាកស្សបៈដ៏ចម្រើន ព្រះវិន័យជាអាយុរបស់ព្រះពុទ្ធសាសនា កាលព្រះវិន័យតាំងនៅ ព្រះសាសនាក៏ឈ្មោះថាតាំងនៅ ព្រោះដូច្នោះយើងទាំងឡាយចូរសង្គាយនា ព្រះវិន័យមុន ” ព្រះ-មហាកស្សបៈសួរថា យើងនឹងចាត់ឲ្យអ្នកណាទទួលជាធុរៈ ?

អង្គប្រជុំឆ្លើយថា ឲ្យព្រះឧបាលីទទួលជាធុរៈ ? លោកសួរជំទាស់ថា ព្រះអានន្ទមិនអាចឬ ? អង្គប្រជុំចង្អុលបង្ហាញថា មិនមែនព្រះអានន្ទមិនអាចទេ ក៏ប៉ុន្តែថា កាលព្រះសម្មាសម្ពុទ្ធនៅមានព្រះជន្ម បានស្ថាបនាព្រះឧបាលីទុកក្នុងឯតទគ្គៈ ព្រោះអាស្រ័យការរៀនសូត្រវិន័យថា “ម្នាលភិក្ខុទាំងឡាយ ឧបាលិជាកំពូលនៃភិក្ខុសាវករបស់តថាគត ផ្នែកខាងទ្រទ្រង់វិន័យ ដូច្នេះ ព្រោះដូច្នោះ យើងទាំងឡាយទើបត្រូវសួរព្រះឧបាលិត្ថេរសង្គាយនាព្រះវិន័យ ។ លំដាប់នោះ ព្រះមហាកស្សបត្ថេរ បានសន្មតខ្លួនឯងដើម្បីសួរព្រះវិន័យ សូម្បីព្រះឧបាលិត្ថេរ ក៏សន្មតខ្លួនឯង ដើម្បីឆ្លើយព្រះវិន័យ ក្នុងការសម្មតិនោះ មានបាលីដូចតទៅនេះ ៖

**គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានប្រកាសថា**

ម្នាលអាវុសោទាំងឡាយ សូមសង្ឃចូរស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃដល់ហើយ ខ្ញុំគប្បីសួរវិន័យនឹង ព្រះឧបាលិ ។ ចំណែកព្រះឧបាលិ ក៏បានប្រកាសថា សង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើនទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃដល់ហើយ ខ្ញុំដែលព្រះមហាកស្សបៈមានអាយុ ត្រូវសួរព្រះវិន័យ ខ្ញុំក៏ត្រូវដោះស្រាយ ។

គ្រានោះ ព្រះឧបាលិសន្មតខ្លួនយ៉ាងនេះហើយ ក្រោកចាកអាសនៈ ដណ្តប់ចីវរឆៀងស្មាម្ខាង នមស្ការភិក្ខុជាព្រះថេរៈហើយ អង្គុយលើធម្មាសនៈ ចាប់ផ្លិតវិជនីដែលវិចិត្រដោយដងភ្លុក ។ លំដាប់នោះ ព្រះមហាកស្សបត្ថេរអង្គុយលើថេរាសនៈ សួរវិន័យចំពោះព្រះឧបាលីថា ម្នាលឧបាលិមានអាយុ បឋមបារាជិក ព្រះមានព្រះភាគទ្រង់បញ្ញត្តិក្នុងទីណា ?

ព្រះឧបាលិឆ្លើយថា ទ្រង់បញ្ញត្តិក្នុងនគរវេសាលី លោកម្ចាស់ ។

ព្រះមហាកស្សប. ទ្រង់ប្រារព្ធនឹងបុគ្គលណា ? ។

ព្រះឧបាលិ. ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុជាកូននៃកលន្ទកសេដ្ឋី ។

ព្រះមហាកស្សប. ព្រោះរឿងអ្វី ?

ព្រះឧបាលីឆ្លើយថា រឿងសេពមេថុនធម្ម ។

លំដាប់នោះឯង ព្រះមហាកស្សប សួរព្រះឧបាលិទាំងវត្ថុ សួរ

ទាំងនិទាន សួរទាំងបុគ្គល សួរទាំងមូលបញ្ញត្តិ សួរទាំងអនុប្បញ្ញត្តិ សួរទាំងអាបត្តិ សួរទាំងអនាបត្តិ នៃបឋមបារាជិក ។ ព្រះឧបាលិ ត្រូវព្រះមហាកស្សបៈ សួរហើយ ក៏បានដោះស្រាយសព្វគ្រប់ ។

សួរថា ក៏ក្នុងបាលីបឋមបារាជិក ក្នុងវិន័យបិដកនេះ បទអ្វីៗ ដែលគួរកាត់ចេញ ឬដែលគួរបន្ថែមចូលមកនឹងមានខ្លះ ឬមិនមាន ។

ឆ្លើយថា បទដែលគួរកាត់ចេញ មិនមានឡើយ ព្រោះស្របគ្នាថា បទដែលគួរកាត់ចេញក្នុងភាសិតរបស់ព្រះពុទ្ធដ៏មានបុណ្យ នឹងមិនមានឡើយ ដោយសេចក្តីថា ព្រះតថាគតទាំងឡាយ រមែងមិនត្រាស់អក្សរដែលមិនមានប្រយោជន៍សូម្បីតែមួយតួ តែបទដែលគួរកាត់ចេញក្នុងភាសិតរបស់ព្រះសាវកទាំងឡាយក្តី របស់ទេវតាទាំងឡាយក្តី រមែងមានខ្លះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានកាត់បទនោះចេញហើយ ។ ចំណែកបទដែលគួរបន្ថែមចូលមក រមែងមានបាន សូម្បីក្នុងពុទ្ធភាសិត សាវកភាសិត និងទេវតាភាសិតទូទៅ ព្រោះដូច្នោះ បទណាគួរបន្ថែមចូលក្នុងទេសនាណា ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ក៏បានបន្ថែមបទនោះចូលមកហើយ ។

សួរថា បទដែលបន្ថែមចូលមកនោះ បានដល់ បទអ្វីខ្លះ ? ។

ឆ្លើយថា បទដែលបន្ថែមចូលមកនោះ បានដល់ បទដែលមានត្រឹមតែពាក្យភ្ជាប់សេចក្តីផ្នែកដើម និងផ្នែកចុង មានជាដើមយ៉ាង នេះថា

តេន សមយេន ខ្វះ តេន ខោ បន សមយេន ខ្វះ អថខោ ខ្វះ ឯវំ វុត្តេ ខ្វះ ឯតទវោច ខ្វះ មួយវិញទៀត ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានបន្ថែមបទដែលគួរបន្ថែមចូលមកយ៉ាងនេះហើយ តាំងទុកថា ឥទំ បឋមធារាជិកំ (សិក្ខាបទនេះ ឈ្មោះបឋមបារាជិក) កាលបឋមបារាជិក ឡើងកាន់សង្គាយនាហើយ ព្រះអរហន្ត ៥០០ អង្គ ក៏បានធ្វើគណៈ ស្វាធ្យាយ (សូត្រជាពួក) ដោយន័យដែលលើកឡើងកាន់សង្គាយនាថា តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ ជាដើម ។

ក្នុងវេលាដែលព្រះអរហន្ត ៥០០ អង្គទាំងនោះ ផ្តើមសូត្រ ផែនដីធំដូចជាឲ្យសាធុការ ញាប់ញ័រដរាបដល់ ទឹកទ្រផែនដី ។

ព្រះធម្មសង្គាហកត្ថេរៈទាំងឡាយ លើកបារាជិកដ៏សេស ៣ សិក្ខាបទ ឡើងកាន់សង្គាយនាដោយន័យនេះដូចគ្នា ហើយតាំងទុកថា ឥទំ ធារា-ជិកកណ្ឌំ កណ្ឌនេះ ឈ្មោះ **បារាជិកកណ្ឌ** , តាំងសង្ឃាទិសេស ១៣ ទុកថា **តេរសកណ្ឌំ** , តាំងសិក្ខាបទ ២ ទុកថា **អនិយត** , តាំង សិក្ខាបទ ៣០ ទុកថា **និស្សគ្គិយបាចិត្តិយ** , តាំងសិក្ខាបទ ៩២ ទុកថា **បាចិត្តិយ** , តាំងសិក្ខាបទ ៤ ទុកថា **បាដិទេសនីយ** , តាំងសិក្ខាបទ ៧៥ ទុកថា **សេខិយ** , តាំងធម៌ ៧ ប្រការទុកថា **អធិករណសមថ** ។ រួមជាសិក្ខាបទ ២២៧ ថា **គម្ពីរមហាវិភង្គ** តាំងទុកដោយប្រការដូច្នេះ ។

សូម្បីក្នុង វេលាសម្រេចការសង្គាយនាគម្ពីរមហាវិភង្គ ផែនដីធំ

ក៏បានកម្រើកញាប់ញ័រ ដោយន័យមុនដូចគ្នា ។

តពីនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានតាំងសិក្ខាបទ ៨ ក្នុងភិក្ខុនីវិភង្គ ទុកថា កណ្ឌនេះ **ឈ្មោះបារាជិកកណ្ឌ** , តាំងសង្ឃាទិសេស ១៧ សិក្ខាបទ ទុកថា នេះ **សត្តរសកណ្ឌ** , តាំងនិស្សគ្គិយបាចិត្តិយ ៣០ សិក្ខាបទ នេះទុកថា នេះ **និស្សគ្គិយបាចិត្តិយ** , តាំងបាចិត្តិយ ១៦៦ សិក្ខាបទទុកថា នេះ **បាចិត្តិយ** , តាំងបាដិទេសនីយៈ ៨ សិក្ខាបទទុកថា នេះ **បាដិទេសនីយ** , តាំងសេក្ខិយៈ ៧៥ សិក្ខាបទ ទុកថានេះ **សេក្ខិយ** , តាំងធម៌ ៧ ប្រការទុកថា នេះ **អធិករណសមថ** ។ រួមមានសិក្ខាបទ ៣១១ ថា **ភិក្ខុនីវិភង្គ** យ៉ាងនេះ ហើយតាំងទុកថា វិភង្គនេះ ឈ្មោះ **ឧភតោវិភង្គ** មាន ៦៤ ភាណវារៈ ។

សូម្បីក្នុងវេលាសម្រេចការសង្គាយនា គម្ពីរឧភតោវិភង្គ ផែនដីធំក៏បានកម្រើកញាប់ញ័រ ដោយន័យដូចពោលហើយដូចគ្នា ។

ដោយឧបាយវិធីនោះឯង ព្រះធម្មសង្គាហកត្ថេរទាំងឡាយ លើកគម្ពីរខន្ធកៈ (មហាវគ្គ និងចុល្លវគ្គ) ដែលមានប្រមាណ ៨០ ភាណវារៈ និងគម្ពីរបរិវារៈ ដែលមានប្រមាណ ២៥ ភាណវារៈ ឡើងកាន់សង្គាយនា ហើយតាំងទុកថា បិដកនេះឈ្មោះ **វិន័យបិដក** ។

សូម្បីក្នុងវេលាសម្រេចការសង្គាយនាវិន័យបិដក ផែនដីបានកម្រើកញាប់ញ័រ តាមន័យដូចពោលហើយនុ៎ះឯង ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានប្រគល់ព្រះឧបាលិឲ្យទៅទូន្មានកូនសិស្សរបស់លោក ក្នុងវេលាសម្រេចការសង្គាយនាវិន័យបិដក ព្រះឧបាលិត្ថេរ ដាក់ផ្ចិតក្តក្រ បានចុះចាកពីធម្មាសនៈ នមស្ការភិក្ខុជាព្រះ-ថេរៈទាំងឡាយ ហើយអង្គុយលើអាសនៈជារបស់ខ្លួន ។

លុះសង្គាយនាព្រះវិន័យស្រេចហើយ ព្រះមហាកស្សបៈ ប្រាថ្នានឹងសង្គាយនាព្រះធម៌តទៅ ទើបសួរភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងសង្គាយនាព្រះធម៌ (សុត្តន្តបិដក និងអភិធម្មបិដក) នឹងចាត់ឲ្យអ្នកណាទទួលជាធុរៈសង្គាយនាព្រះធម៌ ភិក្ខុទាំងឡាយពោលថា ឲ្យព្រះអានន្ទ-ត្ថេរទទួលជាធុរៈ ។ ម្នាលលោកមានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃដល់ហើយ ខ្ញុំនឹងសួរព្រះធម៌ និងព្រះអានន្ទ ។

> គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានប្រកាសថា សង្ឃឲ្យដឹងថា ម្នាលលោកមានអាយុទាំងឡាយ សូមសង្ឃចូរស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃដល់ហើយ ខ្ញុំគប្បីសួរព្រះធម៌ចំពោះព្រះអានន្ទ ។ គ្រានោះឯង ព្រះអានន្ទបានប្រកាសថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមសង្ឃចូរស្តាប់ខ្ញុំ បើការព្រមព្រៀងរបស់សង្ឃដល់ហើយ ខ្ញុំម្ចាស់ ដែលព្រះមហាកស្សបៈសួរព្រះធម៌ហើយ ខ្ញុំគប្បីដោះស្រាយ ។

លំដាប់នោះឯង ព្រះអានន្ទក្រោកឡើងចាកពីអាសនៈ ដណ្តប់ចីវរ ឆៀងស្មា ថ្វាយបង្គំភិក្ខុជាព្រះថេរៈទាំងឡាយ ហើយគង់លើធម្មាសនៈ ចាប់ផ្លិតវីជនីដែលវិចិត្រដោយភ្លុក ។

គ្រានោះឯង ព្រះមហាកស្សបៈសួរភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយនឹងសង្គាយនាបិដកណាមុន ? ភិក្ខុទាំងឡាយពោលថា សង្គាយនាសុត្តន្តបិដកមុន ព្រះមហាកស្សបៈសួរថា ក្នុងសុត្តន្តបិដកមានសង្គីតិ ៤ ប្រការ (គឺ ទីឃសង្គីតិ ការសង្គាយនាទីឃនិកាយ , មជ្ឈិមសង្គីតិ ការសង្គាយនាមជ្ឈិមនិកាយ , សំយុត្តសង្គីតិ ការសង្គាយនាសំយុត្តនិកាយ , អង្គុត្តរសង្គីតិ ការសង្គាយនា អង្គុត្តរនិកាយ ។ ចំណែកខុទ្ទកនិកាយ មានវិន័យបិដករួមផងនោះ ទើបមិនរាប់ក្នុងទីនេះ) ក្នុងសង្គីតិទាំងនោះ យើងទាំងឡាយនឹងសង្គាយនាសង្គីតិណាមុន ? ភិក្ខុទាំងឡាយពោលថា សង្គាយនាទីឃសង្គីតិមុន ។ ព្រះមហាកស្សបៈសួរថា ក្នុងទីឃសង្គីតិ មានសូត្រ ៣៤ សូត្រ , មាន ៣ វគ្គ ក្នុងវគ្គទាំងនោះ យើងទាំងឡាយ នឹងសង្គាយនាវគ្គណាមុន ? ភិក្ខុទាំងឡាយពោលថា សង្គាយនាសីលខន្ធវគ្គមុន ។ ព្រះមហាកស្សបៈសួរថា ក្នុងសីលខន្ធវគ្គមានសូត្រ ១៣ ក្នុងសូត្រទាំងនោះ យើងទាំងឡាយនឹងសង្គាយនាសូត្រណាមុន ? ភិក្ខុទាំងឡាយពោលថា បពិត្រលោកដ៏ចម្រើន ដែលឈ្មោះថាព្រហ្មជាលសូត្រ ប្រដាប់ដោយសីល ៣ ប្រភេទ ជាសូត្រកម្ចាត់នូវ

ទោស មានការបញ្ឆោតបន្លំ និងការនិយាយប្រចុបប្រចែងដែលជាមិច្ឆាជីវៈច្រើនយ៉ាងជាដើម ជាសូត្រស្រោយសំណាញ់ គឺ ទិដ្ឋិ ៦២ ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ យើងទាំងឡាយចូរសង្គាយនា ព្រហ្មជាលសូត្រនោះមុន ។

គ្រានោះឯង ព្រះមហាកស្សបត្ថេរ បានសួរព្រះធម៌ចំពោះព្រះអានន្ទថា ម្នាលអានន្ទមានអាយុ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគទ្រង់សម្តែងក្នុងទីណា ?

ព្រះអានន្ទឆ្លើយថា ត្រាស់នៅឯព្រះតំណាក់ ក្នុងព្រះរាជឧទ្យានអម្ពលដ្ឋិកា បពិត្រព្រះថេរៈដ៏ចម្រើន ជាចន្លោះនៃក្រុងរាជគ្រឹះ និងក្រុងនាលន្ទា ។

ព្រះមហាកស្សប. ទ្រង់ប្រារព្ធនឹងបុគ្គលណា ? ។

ព្រះអានន្ទឆ្លើយថា ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។

ព្រះមហាកស្សបៈសួរថា រឿងអ្វី ? ព្រះអានន្ទឆ្លើយថា រឿងសរសើរ និងតិះដៀល ។

គ្រានោះ ព្រះមហាកស្សបមានអាយុ សួរទាំងនិទាន សួរទាំងបុគ្គលនៃព្រហ្មជាលសូត្រចំពោះព្រះអានន្ទ ។ ព្រះអានន្ទក៏បានឆ្លើយហើយ ។

កាលឆ្លើយរួចស្រេចហើយ ព្រះអរហន្ត ៥០០ អង្គ បានធ្វើគណៈសាធ្យាយ ។ ផែនដីបានកម្រើកញាប់ញ័រ តាមន័យដូចបានពោលហើយ

ទុំះឯង ។

គ្រាសង្គាយនាព្រហ្មជាលសូត្រយ៉ាងនេះហើយ តពីនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានសង្គាយនាសូត្រទាំង ១៣ រួមទាំងព្រហ្មជាលសូត្រ តាមលំដាប់នៃបុច្ឆា និងវិសជ្ជនា ដោយន័យជាដើមថា ម្នាល អាវុសោអានន្ទ វគ្គនេះឈ្មោះ សីលខន្ធវគ្គ ។ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ សង្គាយនាបាលីប្រមាណ ៦៤ ភាណវារៈ ប្រដាប់ដោយសូត្រ ៦៤ សូត្រ ចាត់ជា ៣ វគ្គ យ៉ាងនេះ គឺ មហាវគ្គ តពីសីលខន្ធវគ្គនោះ បាដិកវគ្គ តពីមហាវគ្គនោះ ហើយពោលថា និកាយនេះ ឈ្មោះទីឃនិកាយ ហើយប្រគល់ព្រះអានន្ទ ឲ្យទៅបង្រៀនកូនសិស្សរបស់លោក ។ តពីការសង្គាយនាគម្ពីរទីឃនិកាយនោះ ព្រះធម្មសង្គាហកត្ថេរៈទាំងឡាយ បានសង្គាយនាមជ្ឈិមនិកាយប្រមាណ ៨០ ភាណវារៈ ហើយប្រគល់ឲ្យនិស្សិតរបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរថា លោកទាំងឡាយ ចូររក្សាគម្ពីរមជ្ឈិមនិកាយនេះ ។ តពីការសង្គាយនាគម្ពីរមជ្ឈិមនិកាយនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានសង្គាយនាសំយុត្តនិកាយប្រមាណ ១០០ ភាណវារៈ ហើយប្រគល់ឲ្យព្រះមហាកស្សបត្ថេរ ឲ្យទៅបង្រៀនកូនសិស្សរបស់លោក តពីការសង្គាយនាគម្ពីរសំយុត្តនិកាយនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានសង្គាយនាអង្គុត្តរនិកាយប្រមាណ ១២០ ភាណវារៈ ហើយប្រគល់ឲ្យព្រះអនុរុទ្ធត្ថេរ ឲ្យទៅបង្រៀនកូនសិស្សរបស់

លោកថា

**គម្ពីរធម្មសង្គណី គម្ពីរវិភង្គ គម្ពីរកថាវត្ថុ គម្ពីរបុគ្គលបញ្ញត្តិ គម្ពីរធាតុកថា គម្ពីរយមកៈ គម្ពីរបដ្ឋាន លោកហៅថា ព្រះអភិធម្ម ។**

តពីការសង្គាយនាគម្ពីរអង្គុត្តរនិកាយនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានសង្គាយនាបាលីព្រះអភិធម្ម ដែលជាអារម្មណ៍របស់ញាណដ៏សុខុម ដែលបណ្ឌិតទាំងឡាយសរសើរហើយយ៉ាងនេះ ហើយពោលថា បិដកនេះ ឈ្មោះអភិធម្មបិដក ព្រះអរហន្ត ៥០០ អង្គ បានធ្វើគណៈស្វាធ្យាយ ផែនដីបានកម្រើកញាប់ញ័រ តាមន័យដូចពោលហើយនុ៎ះឯង ។

តពីការសង្គាយនាអភិធម្មបិដកនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានសង្គាយនាព្រះបាលី គឺ ជាតក និទ្ទេស បដិសម្ភិទាមគ្គ អបទាន សុត្តនិបាត ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ព្រះទីឃភាណកាចារ្យពោលថា ប្រជុំគម្ពីរនេះឈ្មោះថា **ខុទ្ទកគន្ថ** និងពោលថា ព្រះធម្មសង្គាហកត្ថេរ លើកសង្គាយនាក្នុងអភិធម្មបិដកដូចគ្នា ។ ចំណែកព្រះមជ្ឈិមភាណកាចារ្យពោលថា ខុទ្ទកគន្ថៈទាំងអស់នេះ និងចរិយាបិដក និងពុទ្ធវង្ស រាប់បញ្ចូលក្នុងសុត្តន្តបិដក ។

ព្រះពុទ្ធវចនៈសូម្បីទាំងអស់នេះ គប្បីជ្រាបថា មាន ១ គឺ រស , មាន ២ គឺ ធម៌ និងវិន័យ , មាន ៣ គឺ បឋមវចនៈ មជ្ឈិមវចនៈ

និងបច្ឆិមវចនៈ , មាន ៣ ដោយអំណាចនៃបិដក , មាន ៥ ដោយអំណាចនៃនិកាយ , មាន ៩ ដោយអំណាចនៃអង្គ , មាន ៨៤,០០០ ដោយអំណាចធម្មក្ខន្ធ ដោយប្រការដូច្នេះ ។

ព្រះពុទ្ធវចនៈ មាន ១ គឺ **រស** រាប់យ៉ាងណា ? ពិតមែន ពាក្យណាដែល ព្រះមានព្រះភាគ បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏កំពូលហើយ ទ្រង់ប្រៀនប្រដៅទេវតា មនុស្ស នាគ និងយក្ខជាដើមក្តី ទ្រង់ពិចារណាហើយក្តី រហូតដល់អស់វេលា ៤៥ ឆ្នាំ ក្នុងចន្លោះនេះ ជរាបដល់ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ត្រាស់ទុកពាក្យទាំងអស់នោះ មានរសតែមួយ គឺ វិមុត្តិរសនុ៎ះឯង ព្រះពុទ្ធវចនៈ មាន ១ គឺ **រស** រាប់យ៉ាងនេះ ។

ព្រះពុទ្ធវចនៈ មាន ២ គឺ ធម៌ និងវិន័យ រាប់យ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នេះ រមែងរាប់ថា **ធម៌ និងវិន័យ** , ក្នុងធម៌ និងវិន័យនោះ វិន័យបិដក ឈ្មោះថា **វិន័យ** ព្រះពុទ្ធវចនៈដ៏សេស ឈ្មោះថា **ធម៌** ។ ព្រោះហេតុនោះឯង ព្រះមហាកស្សបៈទើបពោលថា "បើដូច្នោះ យើងទាំងឡាយគប្បីសង្គាយនាធម៌ និងវិន័យ និងថា ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលី , គប្បីសួរធម៌ចំពោះព្រះអានន្ទ" ព្រះពុទ្ធវចនៈមាន ២ គឺ ធម៌ និងវិន័យ ដោយរាប់យ៉ាងនេះ ។

ព្រះពុទ្ធវចនៈមាន ៣ គឺ បឋមវចនៈ មជ្ឈិមវចនៈ និងបច្ឆិមវចនៈ

រាប់យ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នេះមាន ៣ ប្រភេទ គឺ **បឋមពុទ្ធវចន មជ្ឈិមពុទ្ធវចន បច្ឆិមពុទ្ធវចន** ។ ក្នុង ៣ ប្រភេទនេះ បឋមពុទ្ធវចនៈ បានដល់ ពុទ្ធវចនៈនេះ គឺ ៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

តថាគតស្វែងរកជាងធ្វើផ្ទះ គឺ អត្តភាព កាលមិនជួប បាន ត្រាច់រន្ធាត់ទៅហើយ អស់សង្សាររាប់ដោយជាតិជាអនេក ការកើតរឿយៗ ជាទុក្ខ ម្នាលជាងអ្នកធ្វើផ្ទះ គឺ អត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ គឺ អត្តភាពរបស់តថាគតទៀត មិនបានឡើយ គ្រោងផ្ទះរបស់អ្នកទាំងអស់ តថាគតទម្លាយហើយ កំពូលផ្ទះ គឺ អវិជ្ជា តថាគតរុះរើហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន តថាគតបានសម្រេចធម៌ជាទីអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

អាចារ្យពួកខ្លះពោល ឧទានគាថា ក្នុងគម្ពីរខន្ធកៈ មានពាក្យថា យទា ហវេ បាតុភវន្តិ ធម្មា ក្នុងកាលណា ធម៌ទាំងឡាយរមែងប្រាកដ

ដូច្នេះជាដើមថា ជាបឋមពុទ្ធវចនៈ ក៏ឧទានគាថានេះ គប្បីជ្រាបថា ជាឧទានគាថា ដែលកើតដល់ព្រះមានព្រះភាគ ដែលទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់ពិចារណានូវបច្ចយាការដោយព្រះញាណ ដែលសម្រេចដោយសោមនស្សវេទនាក្នុងថ្ងៃ ១ កោច ខែ ៦ ។

ក៏ពាក្យដែល ព្រះមានព្រះភាគត្រាស់ក្នុងវេលាស្តេចជិតបរិនិព្វានថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតសូមដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាំងសម្មាបដិបត្តិឲ្យដល់ព្រមដោយការមិនប្រមាទ ដូច្នេះ **ជាបច្ឆិមពុទ្ធវចន** ។

ពាក្យដែលព្រះមានព្រះភាគ ត្រាស់ចន្លោះបឋមវចនៈ និងបច្ឆិមវចនៈ ឈ្មោះ **មជ្ឈិមវចន** ។ ពុទ្ធវចនៈ ៣ ប្រភេទ គឺ បឋមពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ រាប់យ៉ាងនេះឯង ។

ពុទ្ធវចនមាន ៣ ដោយអំណាចនៃបិដក រាប់យ៉ាងណា ? ពិតមែនព្រះពុទ្ធវចនៈទាំងអស់នេះមាន ៣ ប្រភេទ គឺ **វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក** ។ ក្នុង ៣ បិដកនោះ ព្រះពុទ្ធវចនៈនេះ គឺ បាតិមោក្ខទាំង ២ វិភង្គ ២ ខន្ធកៈ ២២ បរិវារៈ ១៦ ឈ្មោះ **វិន័យបិដក** ព្រោះរួមព្រះពុទ្ធវចនៈទាំងអស់ ដែលសង្គាយនាក្នុងគ្រាបឋមសង្គាយនា និងដែលសង្គាយនាតមក ។

ព្រះពុទ្ធវចនៈដែលឈ្មោះថា **សុត្តន្តបិដក** បានដល់ ព្រះពុទ្ធវចនៈ

តទៅនេះ គឺ ទីឃនិកាយ មានចំនួន ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម , មជ្ឈិមនិកាយ មានចំនួន ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម , សំយុត្តនិកាយ មានចំនួន ៧,៧៦២ សូត្រ មានឱឃតរណសូត្រជាដើម , អង្គុត្តរនិកាយ មានចំនួន ៩,៥៥០ សូត្រ មានចិត្តបរិយាទានសូត្រជាដើម , ខុទ្ទកនិកាយមាន ១៥ ប្រភេទ គឺ ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តក សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទា អបទាន ពុទ្ធវង្ស និងចរិយាបិដក ។

ព្រះពុទ្ធវចនៈដែល ឈ្មោះថា **អភិធម្មបិដក** បានដល់ ព្រះពុទ្ធវចនៈតទៅនេះ គឺ ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិ កថាវត្ថុ យមកៈ បដ្ឋាន ។ ក្នុងបិដក ៣ នេះ ។

## ( អត្ថាធិប្បាយពាក្យថា វិន័យ )

*វិន័យ សព្ទនេះ បណ្ឌិតអ្នកដឹងអត្ថនៃវិន័យសព្ទ ប្រែថា វិន័យ ព្រោះមានន័យផ្សេង ៗ ព្រោះមានន័យពិសេស និង ព្រោះទូន្មានកាយ និងវាចា ។*

ក៏ក្នុងវិន័យបិដកនេះ មានន័យផ្សេងៗ គឺ មានបាតិមោក្ខទ្ទេស ៥ , អាបត្តិ ៧ កង មានបារាជិកជាដើម មាតិកា និងវិភង្គជាដើម ជាប្រភេទ ចំណែកន័យអនុប្បញ្ញត្តិ ជាន័យពិសេស មានផលធ្វើឲ្យព្រះពុទ្ធប្បញ្ញត្តិពីដើមតឹងឡើង និងធូរបុះ និងវិន័យនេះ រមែងឃុំគ្រងកាយ និងវាចា ព្រោះហាមការប្រព្រឹត្តកន្លងផ្លូវកាយ និងផ្លូវវាចា ព្រោះដូច្នោះ លោកទើបប្រែអត្ថន័យថា **វិន័យ** ព្រោះមានន័យផ្សេងៗ ព្រោះមានន័យពិសេស និងព្រោះឃុំគ្រងកាយ និងវាចា ព្រោះហេតុនោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងសេចក្តីនៃពាក្យរបស់វិន័យនេះ ខ្ញុំទើបពោលថា ៖

*វិន័យ សព្ទនេះ បណ្ឌិតអ្នកដឹងអត្ថនៃវិន័យសព្ទ ប្រែថា វិន័យ ព្រោះមានន័យផ្សេង ៗ ព្រោះមានន័យពិសេស និង ព្រោះទូន្មានកាយ និងវាចា ។*

## ( អត្ថាធិប្បាយពាក្យថា សូត្រ )

*រីឯសូត្រសព្ទក្រៅអំពីនេះ លោកប្រែសេចក្តីថា សូត្រ ព្រោះ*

*បើកបង្ហាញនូវប្រយោជន៍ទាំងឡាយ ព្រោះពោលនូវប្រយោជន៍ទុកដ៏សមគួរ ព្រោះផ្តល់នូវប្រយោជន៍ ព្រោះបង្ហូរនូវប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយខ្សែបន្ទាត់ ។*

ក៏ព្រះសូត្រនោះ រមែងផ្តល់នូវប្រយោជន៍ទាំងឡាយ ដែលផ្សេងដោយប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃជាដើម ។ មួយវិញទៀត ប្រយោជន៍ទាំងឡាយ ព្រះមានព្រះភាគ ត្រាស់ទុកល្អហើយក្នុងបិដកនេះ ព្រោះត្រាស់អនុលោមតាមអធ្យាស្រ័យរបស់វេនេយ្យសត្វ ។ ក៏សុត្តន្ត-បិដកនេះ រមែងបញ្ចេញប្រយោជន៍ទាំងឡាយ អធិប្បាយថា បញ្ចេញផ្លែដូចស្រូវបញ្ចេញផ្លែ ដូច្នោះ ។ ព្រះសូត្រនេះ **រមែងបង្ហូរប្រយោជន៍ទាំងឡាយ** អធិប្បាយថា ដូចមេគោបង្ហូរទឹកដោះ ដូច្នោះ ។ មួយវិញទៀត ព្រះសូត្រនេះ **រមែងការពារ** អធិប្បាយថា រមែងរក្សាប្រយោជន៍ទាំងនោះយ៉ាងល្អ ។ មួយទៀត ព្រះសូត្រនេះ **មានចំណែកស្មើដោយខ្សែបន្ទាត់** ដោយសេចក្តីថា ខ្សែបន្ទាត់ ជាគ្រឿងកំណត់របស់ជាងឈើទាំងឡាយយ៉ាងណា សូម្បីព្រះសូត្រនេះ ក៏ជាគ្រឿងកំណត់របស់វិញ្ញូជនទាំងឡាយដូច្នោះ ។ ឧបមាដូចជា ផ្កាឈើទាំងឡាយដែលក្រងទុកដោយអំបោះ រមែងមិនរាត់រាយ រមែងមិនខ្ចាត់ខ្ចាយដោយ ខ្យល់យ៉ាងណា ប្រយោជន៍ ទាំងឡាយដែលរួបរួមទុកដោយព្រះសូត្រនេះ ក៏យ៉ាងនោះ ។

ព្រោះដូច្នោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងសេចក្តីនៃពាក្យរបស់សូត្រនេះ ខ្ញុំទើបពោលថា ៖

រីឯសូត្រសព្ទក្រៅអំពីនេះ លោកប្រែសេចក្តីថា សូត្រ ព្រោះបើកបង្ហាញនូវប្រយោជន៍ទាំងឡាយ ព្រោះពោលនូវប្រយោជន៍ទុកដ៏សមគួរ ព្រោះផ្តល់នូវប្រយោជន៍ ព្រោះបង្ហូរនូវប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយខ្សែបន្ទាត់ ។

## ( អត្ថាធិប្បាយពាក្យថា អភិធម្ម )

ក៏ធម៌ក្រៅអំពីនេះ លោកហៅថា អភិធម្ម ព្រោះព្រះមានព្រះភាគ ត្រាស់ទុកក្នុងអភិធម្មនេះថា ជាធម៌ដែលមានសេចក្តីចម្រើន ដែលកំណត់ជាមាត្រដ្ឋាន ដែលបុគ្គលបូជាហើយ ដែលកាត់ផ្តាច់ និងជាធម៌ដ៏ក្រៃលែង ។

ក៏ **អភិ** សព្ទនេះ រមែងប្រាកដក្នុងអត្ថថា **ចម្រើន** សេចក្តីថា ដែលបណ្ឌិតកំណត់ជាមាត្រដ្ឋាន សេចក្តីថា ដែលបុគ្គលបូជាហើយ មានប្រយោគជាឧទាហរណ៍ដូចតទៅនេះ ៖

**អភិ** សព្ទ មកក្នុងអត្ថថា **ចម្រើន** ក្នុងប្រយោគមានជាដើមថា ពាឡ្ហា មេ អាវុសោ ម្នាលអាវុសោ ទុក្ខវេទនាយ៉ាងខ្លាំងក្លា រមែង

ចម្រើនឡើងដល់ខ្ញុំ រមែងមិនធូរថយឡើយ ។

**អភិ** សទ្ទ មកក្នុងអត្ថថា **ដែលបណ្ឌិតកំណត់ជាមាត្រដ្ឋាន** ក្នុងប្រយោគមានជាដើមថា យា តា រត្តិយោ អភិញ្ញាតា អភិ-លក្ខិតា រាត្រីនោះណា (គឺថ្ងៃ ៨ , ១៤ , និង១៥) ដែលបណ្ឌិតកំណត់ដឹងហើយ (ដោយការពេញវង់ និងអស់វង់របស់ព្រះចន្ទ) ដែលបណ្ឌិតកំណត់ជាមាត្រដ្ឋានទុកហើយ (ដើម្បីសមាទានឧបោសថ ស្តាប់ធម៌ និងដើម្បីធ្វើសក្ការបូជាជាដើម) ។

**អភិ** សទ្ទ មកក្នុងអត្ថថា **ដែលបុគ្គលបូជាហើយ** ក្នុងប្រយោគមានជាដើមថា រាជាភិរាជា មនុជិន្ទោ សូមព្រះអង្គចូរជាព្រះរាជា ដែលព្រះរាជបូជាហើយ ចូរជាធំជាងពួកមនុស្ស ។

**អភិ** សទ្ទ មកក្នុងអត្ថថា **កាត់ផ្តាច់** ដូចក្នុងប្រយោគមានជាដើមថា បដិពលោ វិនេតុំ អភិធម្មេ អភិវិនយេ ជាអ្នកអាចទូន្មានក្នុងអភិធម្ម ក្នុងអភិវិន័យ ។ អធិប្បាយថា អញ្ញមញ្ញសង្ករវិរហិតេ ធម្មេ ច វិនយេ ច ក្នុងព្រះធម៌ និងក្នុងព្រះវិន័យ ដែលវៀរ ចាកការប្របូក-ប្របល់គ្នា ។

**អភិ** សទ្ទ មកក្នុងអត្ថថា **ក្រៃលែង** ក្នុងប្រយោគមានជាដើមថា អភិក្កន្តេន វណ្ណេន មានសម្បុរល្អក្រៃលែង ។

សូម្បីធម៌ទាំងឡាយ ដែលមានសេចក្តីចម្រើន ព្រះមានព្រះភាគ

ត្រាស់ទុកក្នុងព្រះអភិធម្មនេះ ដោយន័យមានជាដើមថា រូបុប្បត្តិយា មគ្គំ ភាវេតិ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ភិក្ខុចម្រើនមគ្គដើម្បីចូលដល់រូបភពនេះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិស ១ ។ សូម្បីធម៌ទាំងឡាយ ដែលបណ្ឌិតកំណត់ជាមាត្រដ្ឋាន ព្រោះមានសភាពដែលគួរកំណត់ ដោយជាអារម្មណ៍ជាដើម លោកពោលទុកដោយន័យមានជាដើមថា រូបារម្មណំ វា សទ្ទារម្មណំ វា មានរូបជាអារម្មណ៍ មានសំឡេងជាអារម្មណ៍ ។ សូម្បីធម៌ទាំងឡាយ ដែលបុគ្គលបូជាហើយ លោកពោលទុកដោយន័យមានជាដើមថា សេក្ខា ធម្មា អសេក្ខា ធម្មា លោកុត្តរា ធម្មា សេក្ខធម៌ អសេក្ខធម៌ លោកុត្តរធម៌ ។ សូម្បីធម៌ទាំងឡាយដែលកាត់ផ្តាច់ហើយ ព្រោះជាធម៌ដែលកាត់ផ្តាច់តាមសភាវៈ លោកពោលទុកដោយន័យមានជាអាទិថា ផស្សោ ហោតិ វេទនា ហោតិ ផស្សៈមាន វេទនាមាន ។ សូម្បីធម៌ទាំងឡាយដ៏ក្រៃលែង លោកពោលទុកដោយន័យជាដើមថា មហគ្គតា ធម្មា អប្បមាណា ធម្មា អនុត្តរា ធម្មា មហគ្គតធម៌ អប្បមាណធម៌ អនុត្តរធម៌ ។ ព្រោះហេតុនោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងខ្លឹមសាររបស់ពាក្យនៃអភិធម្មនេះ ខ្ញុំទើបពោលគាថាប្រព័ន្ធនេះទុកថា ៖

**ក៏ធម៌ក្រៅអំពីនេះ លោកហៅថា អភិធម្ម ព្រោះព្រះមាន**
**ព្រះភាគ ត្រាស់ទុកក្នុងអភិធម្មនេះថា ជាធម៌ដែលមាន**

***សេចក្តីចម្រើន ដែលកំណត់ជាមាត្រដ្ឋាន ដែលបុគ្គល***
***បូជាហើយ ដែលកាត់ផ្តាច់ និងជាធម៌ដ៏ក្រៃលែង ។***

*ក៏ក្នុងបិដកទាំងឡាយ មានវិន័យបិដកជាដើមនេះ បិដកណា ដែលនៅសល់*

***បណ្ឌិតទាំងឡាយ ដែលដឹងអត្ថនៃបិដក ហៅបិដក***
***នោះថា បិដក ដោយអត្ថថា បរិយត្តិ និងភាជនៈ***
***គប្បីជ្រាបថា មាន ៣ មានវិន័យជាដើម ព្រោះរួម***
***ចូលបិដកសព្វនោះ ។***

*ពិតហើយ សូម្បីបរិយត្តិលោកក៏ហៅថា បិដក ក្នុងប្រយោគមានជាដើមថា កុំទាន់ជឿដោយអាងបិដក ។ សូម្បីភាជនៈយ៉ាងណាមួយ លោកក៏ហៅថា* ***បិដក*** *ក្នុងប្រយោគជាដើមថា គ្រានោះ បុរសគប្បីកាន់ចប និងកញ្ជើដើរមក ។ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ដែលដឹងអត្ថនៃបិដកសព្ទ ទើបហៅបិដកសព្ទថា* ***បិដក*** *ដោយអត្ថថា បរិយត្តិ និងភាជនៈ ។*

*ឥឡូវនេះគប្បីជ្រាបថា មាន ៣ មានវិន័យជាដើម ព្រោះរួមចូលនឹងបិដកសព្ទនោះ គប្បីជ្រាបថា មាន ៣ មានវិន័យជាដើមទាំងនេះ យ៉ាងនេះថា ព្រោះធ្វើសមាសនឹងបិដកសព្ទ ដែលមានសេចក្តី ២ យ៉ាងនោះ យ៉ាងនេះ គឺ វិន័យផង វិន័យនោះជាបិដកផង ព្រោះជាបរិយត្តិ*

និងព្រោះជាភាជនៈនៃសេចក្តីនោះៗ ព្រោះដូច្នោះ ទើបឈ្មោះវិន័យបិដក , ដោយន័យតាមដែលពោលហើយ ព្រះសូត្រផង ព្រះសូត្រនោះជាបិដកផង ព្រោះដូច្នោះ ទើបឈ្មោះថា សុត្តន្តបិដក , អភិធម្មផង អភិធម្មនោះជាបិដកផង ព្រោះដូច្នោះ ទើបឈ្មោះថា អភិធម្មបិដក ។

ក៏គ្រាជ្រាបយ៉ាងនេះហើយ ដើម្បីភាពជាអ្នកឆ្លាតក្នុងប្រការផ្សេងៗ ក្នុងបិដក ទាំង ៣ នោះទៀត ៖

**បណ្ឌិត គប្បីសម្តែងប្រភេទនៃទេសនា ប្រភេទនៃសាសនា ប្រភេទនៃកថា និងសិក្ខា បហានៈ គម្ភីរភាព តាមសមគួរ ក្នុងបិដកទាំងនោះ ។ ភិក្ខុរមែងដល់នូវប្រភេទនៃបរិយត្តិណា សម្បត្តិណា សូម្បីវិបត្តិណា ក្នុងបិដកណា គប្បីសម្តែងនូវនៃបរិយត្តិទាំងអស់នោះ ដោយប្រការនោះ ។**

ក្នុងគាថាទាំងនោះ មានពាក្យអធិប្បាយយ៉ាងជាក់ច្បាស់ និងច្បាស់លាស់ ដូចតទៅនេះ ៖

ពិតមែន បិដក ៣ ទាំងនោះ លោកហៅតាមលំដាប់ថា អាណាទេសនា វោហារទេសនា បរមត្ថទេសនា យថាបរាធសាសនា យថានុលោមសាសនា យថាធម្មសាសនា និងសំវរាសំវរកថា ទិដ្ឋិវិនិវេធនកថា នាមរូបបរិច្ឆេទកថា ។

ក៏ក្នុងបិដក ៣ នេះ វិន័យបិដក លោកហៅថា **អាណាទេសនា**

ការទេសនា ដោយអំណាចហាមប្រាម ព្រោះជាបិដកដែលព្រះមានព្រះភាគជាអ្នកចេញពាក្យហាមឃាត់ ទ្រង់សម្តែងហើយដោយភាពជាទេសនាដែលច្រើនទៅដោយពាក្យហាមឃាត់ ។

សុត្តន្តបិដកលោកហៅថា **វោហារទេសនា** ការទេសនាដោយវោហារ ព្រោះជាបិដក ដែលព្រះមានព្រះភាគទ្រង់ឆ្លាតក្នុងការទូន្មាន ទ្រង់សម្តែងហើយដោយភាពជាទេសនា ដែលច្រើនទៅដោយពាក្យទូន្មាន ។

អភិធម្មបិដក លោកហៅថា **បរមត្ថទេសនា** ការទេសនាដោយបរមត្ថ ព្រោះជាបិដកដែលព្រះមានព្រះភាគទ្រង់ឆ្លាតក្នុងបរមត្ថ ទ្រង់សម្តែងហើយដោយភាពជាទេសនាដែលច្រើនទៅដោយបរមត្ថ ។

ម្យ៉ាងទៀត បិដកទី ១ (វិន័យបិដក) លោកហៅថា យថាបរាធ-សាសនា ការប្រៀនប្រដៅតាមការប្រព្រឹត្តខុស ព្រោះអត្ថវិគ្រោះថា ពួកសត្វទាំងឡាយពួកណាអ្នកមានការប្រព្រឹត្តខុសយ៉ាងច្រើន សត្វពួកនោះដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិតាមការប្រព្រឹត្តខុសក្នុងបិដកនេះ ។

បិដក ទី ២ (សុត្តន្តបិដក) ដែលលោកហៅថា យថានុលោម-សាសនា ការប្រៀនប្រដៅអនុលោមតាមអធ្យាស្រ័យ ព្រោះអត្ថវិគ្រោះថា សត្វទាំងឡាយអ្នកមានអធ្យាស្រ័យ អនុស័យ និងចរិយាវិមុត្តិមិនមែនតិច ដែលព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅហើយក្នុងបិដកនេះ តាមការអនុលោម ។

បិដកទី ៣ (អភិធម្មបិដក) លោកហៅថា យថាធម្មសាសនា ការប្រៀនប្រដៅតាមបរមត្ថធម៌ ព្រោះអត្ថវិគ្រោះថា សត្វទាំងឡាយមានសេចក្ដីសម្គាល់ក្នុងសភាវៈ ត្រឹមតែគំនរនៃបរមត្ថធម៌ថា នោះជាយើង នោះជារបស់យើង ដូច្នេះ ដែលព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅហើយ តាមបរមត្ថធម៌ក្នុងបិដកនេះ ។

មួយវិញទៀត បិដកទី ១ លោកហៅថា សំវរាសំវរកថា ដោយអត្ថថា សំវរាសំវរៈដែលជាបដិបក្ខចំពោះការល្មើស ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងបិដកនេះ ។ បទថា សំវរាសំវរោ បានដល់ សំវរៈតូច និងសំវរៈធំ ដូចកម្មាកម្មៈ ការងារតូច និងការងារធំ និងដូចផលាផលៈ ផ្លែឈើតូច និងផ្លែឈើធំ ។

បិដកទី ២ លោកហៅថា ទិដ្ឋិវិនិវេឋនកថា ពាក្យបរិយាយទំលាយទិដ្ឋិ ដោយអត្ថថា ការទំលាយទិដ្ឋិ ដែលជាបដិបក្ខចំពោះទិដ្ឋិ ៦២ ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងបិដកនេះ ។

បិដកទី ៣ លោកហៅថា នាមរូបបរិច្ឆេទកថា ពាក្យបរិយាយការកំណត់នាម និងរូប ដោយអត្ថថា ការកំណត់នាម និងរូប ដែលជាបដិបក្ខចំពោះកិលេស មានរាគៈជាដើម ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងបិដកនេះ ។

មួយវិញទៀត គប្បីជ្រាប សិក្ខា ៣ បហានៈ ៣ និងគម្ភីរភាព ៤

យ៉ាង ក្នុងបិដកទាំង ៣ នេះ ដូចតទៅនេះ ៖

ពិតយ៉ាងនោះ អធិសីលសិក្ខា ព្រះមានព្រះភាគត្រាស់ទុកដោយចំពោះក្នុងវិន័យបិដក , អធិចិត្តសិក្ខា ត្រាស់ទុកដោយចំពោះក្នុងសុត្តន្តបិដក , អធិប្បញ្ញាសិក្ខា ត្រាស់ទុកដោយចំពោះក្នុងអភិធម្មបិដក ។

មួយទៀត ការលះកិលេសគ្រោតគ្រាត ព្រះមានព្រះភាគត្រាស់ទុកក្នុងវិន័យបិដក ព្រោះសីល ជាបដិបក្ខចំពោះកិលេសគ្រោតគ្រាត ។ ការលះកិលេសយ៉ាងកណ្តាល ត្រាស់ទុកក្នុងសុត្តន្តបិដក ព្រោះសមាធិ ជាបដិបក្ខចំពោះកិលេសយ៉ាងកណ្តាល ។ ការលះកិលេសយ៉ាងល្អិត ត្រាស់ទុកក្នុងអភិធម្មបិដក ព្រោះបញ្ញា ជាបដិបក្ខចំពោះកិលេសយ៉ាងល្អិត ។

មួយទៀត ការលះកិលេសដោយខណៈ ត្រាស់ទុកក្នុងបិដកទី ១ ការលះកិលេសដោយគ្របសង្កត់ទុក និងការលះកិលេសដាច់សមុច្ឆេទ ត្រាស់ទុកក្នុងបិដកទាំង ២ ក្រៅនេះ ។

ការលះសង្កិលេស គឺ ទុច្ចរិត ត្រាស់ទុកក្នុងបិដកទី ១ , ការលះសង្កិលេស គឺ តណ្ហា និងទិដ្ឋិ ត្រាស់ទុកក្នុងបិដកទាំង ២ ក្រៅនេះ ។

ក្នុងបិដក ៣ នេះ គប្បីជ្រាបថា តែមួយបិដកមានគម្ភីរភាពទាំង ៤ គឺ សេចក្តីជ្រាលជ្រៅ ដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធ ។

ក្នុងគម្ពីរភាពទាំង ៤ នោះ **ធម៌** បានដល់ បាលី , **អត្ថ** បានដល់ សេចក្តីអធិប្បាយបាលីនោះឯង , **ទេសនា** បានដល់ ការសម្តែងបាលីនោះ ដែលកំណត់ទុកយ៉ាងល្អដោយចិត្ត , **បដិវេធ** បានដល់ ការយល់ដឹងបាលី និងសេចក្តីរបស់បាលីតាមសេចក្តីពិត ។ ក៏ព្រោះ ធម៌ អត្ថ ទេសនា និងបដិវេធទាំងនេះ ក្នុងបិដកទាំង ៣ នេះ អ្នកមានបញ្ញាតិចទាំងឡាយ យល់ដឹងបានលំបាក និងជាទីពឹងមិនបាន ដូចមហាសមុទ្រ សត្វតូចទាំងឡាយ មានទន្សាយជាដើម ពឹងមិនបានដូច្នោះ ទើបជារបស់ជ្រាលជ្រៅ ។

ក្នុងបិដក ៣ នេះ គប្បីជ្រាបគម្ពីរភាពទាំង ៤ យ៉ាង ក្នុងតែមួយបិដក ដោយប្រការដូច្នេះ ។

ន័យម្យ៉ាងទៀត ធម៌ បានដល់ **ហេតុ** សេចក្តីនេះសមដូចព្រះ-ពុទ្ធវចនៈដែលត្រាស់ទុកថា ញាណក្នុងហេតុ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ **អត្ថ** បានដល់ **ផលនៃហេតុ** សេចក្តីនេះ សមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុកថា ញាណក្នុងផលនៃហេតុ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ ទេសនា បានដល់ **បញ្ញត្តិ** អធិប្បាយថា ការសម្តែងធម៌តាមសភាវធម៌ ។

ម្យ៉ាងទៀត ការសម្តែងដោយអំណាចអនុលោម និងបដិលោម សង្ខេប និងពិស្តារជាដើម ហៅថា **ទេសនា** ។ បដិវេធ បានដល់ **ការត្រាស់ដឹង** និងបដិវេធនោះ បានទាំងលោកិយៈ បានទាំងលោកុត្តរៈ

បានដល់ ដឹងសេចក្តីពិតមិនប្រែប្រួល ក្នុងហេតុទាំងឡាយ សមគួរដល់ផល ក្នុងផលទាំងឡាយសមគួរដល់ហេតុ ក្នុងបញ្ញត្តិទាំងឡាយ សមគួរដល់ផ្លូវនៃបញ្ញត្តិ ដោយអារម្មណ៍ និងដោយការមិនវង្វេងក្នុងសភាវៈនៃធម៌ទាំងឡាយនោះៗ ដែលពោលហើយក្នុងបិដកនោះៗ មិនវិបរិត ពោលគឺ បណ្ឌិតកំណត់ជាមាត្រដ្ឋាន គួរចាក់ធ្លុះបាន ។

សភាវធម៌ដែលមានហេតុណា ៗ ក្តី សភាវធម៌ដែលមានផលណា ៗ ក្តី សេចក្តីដែលគួរឲ្យដឹងដោយប្រការណាៗ រមែងជាគោលដៅសំខាន់នៃញាណរបស់អ្នកស្តាប់ទាំងឡាយ ទេសនានេះណា ដែលបំភ្លឺសេចក្តីនោះឲ្យភ្លឺច្បាស់ដោយប្រការនោះៗ ក្តី បដិវេធណា ពោលគឺ ដឹងសេចក្តីពិតមិនវិបរិតក្នុងបិដក ៣ នេះ ណាមួយ សភាវៈនៃធម៌ទាំងឡាយនោះៗ ដែលមិនវិបរិត ពោលគឺ ដែលបណ្ឌិតកំណត់ជាមាត្រដ្ឋាន គួរចាក់ធ្លុះនូវគុណជាតនេះទាំងអស់ អ្នកមានបញ្ញាទន់ខ្សោយទាំងឡាយ ដែលមិនបានសន្សំកុសលសម្ភារទុក យល់ដឹងបានលំបាក និងពឹងមិនបាន ដូចមហាសមុទ្រ សត្វតូចទាំងឡាយ មានទន្សាយជាដើម ពឹងមិនបាន ព្រោះហេតុនោះ សភាវធម៌ដែលមានហេតុ ឬសភាវធម៌ដែលមានផលនោះៗ ទើបជ្រាលជ្រៅ គម្ពីរភាពទាំង ៤ យ៉ាង ក្នុងបិដក ៣ នេះ តែមួយបិដកអ្នកសិក្សា គប្បីជ្រាបក្នុងកាលឥឡូវនេះ សូម្បីដោយប្រការដូច្នេះ ។ ក៏គាថានេះថា ៖

**បណ្ឌិត គប្បីសម្តែងប្រភេទនៃទេសនា ប្រភេទសាសនា ប្រភេទនៃកថា និងសិក្ខា បហានៈគម្ភីរភាព ក្នុងបិដកទាំងនោះ តាមសមគួរ ។**

ជាគាថាមានអត្ថដែលខ្ញុំពោលហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ចំណែកប្រភេទនៃការរៀនសូត្រ ៣ យ៉ាង ក្នុងបិដក ៣ ក្នុងគាថានេះថា ៖

**ភិក្ខុរមែងដល់នូវប្រភេទនៃបរិយត្តិណា នូវសម្បត្តិណា សូម្បីវិបត្តិណា ក្នុងបិដកណា ដោយអាការណា គប្បីសម្តែងនូវប្រភេទនៃបរិយត្តិទាំងអស់នោះ ដោយអាការនោះ ដូច្នេះ**

គប្បីជ្រាបដូចតទៅ ៖

ពិតមែន ការសិក្សា មាន ៣ យ៉ាង គឺ **អលគទ្ទូបមាបរិយត្តិ** ការសិក្សា ដូចចាប់ពស់ពីកន្ទុយ , **និស្សរណត្ថបរិយត្តិ** ការសិក្សាប្រាថ្នាដើម្បីចេញចាកទុក្ខ , **ភណ្ឌាគារិកបរិយត្តិ** ការសិក្សា របស់ព្រះអរហន្តប្រៀបដូចនាយរក្សាឃ្លាំង ។

ក្នុងបរិយត្តិ ៣ ប្រភេទនោះ បរិយត្តិណាដែលបុគ្គលរៀនខុសផ្លូវ គឺ រៀន ព្រោះហេតុមានការតិះដៀលអ្នកដទៃជាដើម បរិយត្តិនេះ ឈ្មោះអលគទ្ទូបមា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំង

ឡាយ ដូចជាបុរសអ្នកត្រូវការពស់ ស្វែងរកពស់ ក៏ត្រាច់ទៅស្វែងរកពស់ពិស បុរសនោះបានឃើញពស់ ១ យ៉ាងធំ ហើយក៏ចាប់ពស់នោះត្រង់ខ្លួន ឬកន្ទុយ ពស់នោះ ក៏ងាកមកខាំបុរសនោះ ត្រង់ដៃ ឬដើមដៃ ឬត្រង់អវយវៈតូចធំណាមួយ បុរសនោះក៏ដល់សេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះត្រូវពស់នោះខាំជាហេតុ សេចក្តីនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះចាប់ពស់មិនល្អ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ មានមោឃបុរសពួកខ្លះក្នុងសាសនានេះ ក៏ដូច្នោះដែរ រៀនធម៌ គឺ សុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ មោឃបុរសទាំងនោះ លុះរៀនធម៌នោះហើយ មិនបានពិចារណាសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា កាលបើមោឃបុរសទាំងនោះ មិនបានពិចារ-ណាសេចក្តីដោយប្រាជ្ញា ធម៌ទាំងនោះ មិនអត់ធន់ដល់ការ សម្លឹងតពិនិត្យ មោឃបុរសទាំងនោះ មានវត្ថុបំណងតិះដៀលអ្នកដទៃ និងមានវត្ថុបំណងដើម្បីដោះស្រាយនូវវាទៈនោះៗ ទើបរៀនធម៌ មោឃបុរសទាំងនោះ រៀនធម៌ដើម្បីប្រយោជន៍នៃធម៌ណា រមែងមិនបានប្រយោជន៍នៃធម៌នោះ ធម៌ទាំងនោះ ដែលមោឃបុរសទាំងនោះ រៀនមិនល្អ រមែងប្រព្រឹត្តទៅដើម្បីអន្តរាយ ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ធម៌ទាំងឡាយដែលមោឃបុរសទាំងនោះរៀនមិនល្អ ដូច្នេះ ។

ចំណែកបរិយត្តិណា ដែលបុគ្គលរៀនត្រូវផ្លូវ គឺ ប្រាថ្នាសេចក្តីបរិបូណ៌នៃគុណ មានសីលក្ខន្ធជាដើមប៉ុណ្ណោះ រៀនហើយ មិនបានរៀនព្រោះហេតុមានការតិះដៀលអ្នកដទៃជាដើម នេះឈ្មោះថា និស្សរណត្ថ-បរិយត្តិ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ធម៌ទាំងឡាយ ដែលបុគ្គលរៀនហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរ សេចក្តីនោះ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ទាំងឡាយ បុគ្គលទាំងនោះរៀនល្អហើយ ។

ចំណែកព្រះអរហន្តអ្នកមានខន្ធដែលកំណត់ដឹងហើយ មានកិលេសដែលលះបានហើយ មានមគ្គដែលអប់រំហើយ មានព្រះអរហត្តផលដែលចាក់ធ្លុះហើយ មាននិរោធដែលធ្វើឲ្យច្បាស់ហើយ រមែងរៀននូវបរិយត្តិណា ដើម្បីត្រូវការរក្សាប្រពៃណី ដើម្បីត្រូវការអនុរក្សពុទ្ធវង្សជោយចំពោះ នេះឈ្មោះ ភណ្ឌាគារិកបរិយត្តិ ។

ម្យ៉ាងទៀត ភិក្ខុបដិបត្តិល្អក្នុងព្រះវិន័យ អាស្រ័យសីលសម្បទា រមែងសម្រេចវិជ្ជា ៣ ព្រោះលោកពោលប្រភេទនៃវិជ្ជា ៣ ទាំងនោះទុកក្នុងព្រះវិន័យនោះ ។ ភិក្ខុបដិបត្តិល្អក្នុងព្រះសូត្រ អាស្រ័យសមាធិ-សម្បទា រមែងសម្រេចអភិញ្ញា ៦ ព្រោះលោកពោលប្រភេទនៃអភិញ្ញា ៦ ទាំងនោះ ទុកក្នុងព្រះសូត្រនោះ ។ ភិក្ខុបដិបត្តិល្អ ក្នុងព្រះអភិធម្ម អាស្រ័យបញ្ញាសម្បទា រមែងសម្រេចបដិសម្ភិទា ៤ ព្រោះលោកពោល

ប្រភេទនៃបដិសម្ភិទា ៤ ទុក ក្នុងព្រះអភិធម្មនោះដូចគ្នា ។ ភិក្ខុបដិបត្តិល្អក្នុងបិដក ៣ ទាំងនោះ រមែងសម្រេចសម្បត្តិផ្សេង ៗ មានវិជ្ជា ៣ អភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាដើមនេះ តាមលំដាប់ដោយប្រការដូច្នេះ ។

ចំណែកភិក្ខុបដិបត្តិខុសក្នុងព្រះវិន័យ រមែងមានសេចក្តីសម្គាល់ថា មិនមានទោស ក្នុងផស្សៈទាំងឡាយ មានការពាល់ត្រូវវត្ថុដែលមានវិញ្ញាណគ្រប់គ្រងជាដើម ដែលត្រូវហាមដោយមានលក្ខណៈដូចស្នាប និងការពាល់ត្រូវវត្ថុមានកម្រាល និងសំពត់ដណ្តប់ដែលមានសម្ផស្សសប្បាយដែលទ្រង់អនុញ្ញាតទុកជាដើម ។ សមដូច ពាក្យដែលព្រះអរិដ្ឋៈពោលទុកថា យើងដឹងទូទៅដល់ធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយថា ជាធម៌ធ្វើឲ្យអន្តរាយ តែធម៌ទាំងនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពបានឡើយ ដូច្នេះ ។ តពីនោះ ភិក្ខុនោះរមែងដល់ភាពជាអ្នកទ្រុស្តសីល ។

ភិក្ខុបដិបត្តិខុសក្នុងព្រះសូត្រ មិនដឹងសេចក្តីបំណងក្នុង ព្រះ-បាលីមានជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ មានហើយប្រាកដហើយ ដូច្នេះ រមែងកាន់យកខុសៗ ដែលព្រះមានព្រះភាគទ្រង់មានបំណងត្រាស់ទុកថា បុគ្គលរមែងពោលបង្កាច់តថាគតផង រមែងគាស់រំលើងនូវខ្លួនឯងផង រមែងប្រសពូវវត្ថុដែលមិនមែនបុណ្យដ៏ច្រើនផង ដោយខ្លួនកាន់យកខុស ដូច្នេះ ។ តពីនោះ ភិក្ខុនោះ រមែងដល់ភាពជាមិច្ឆាទិដ្ឋិ ។

ភិក្ខុបដិបត្តិខុសក្នុងព្រះអភិធម្ម កាលគិតធម៌ច្រើនពេកទៅ រមែង គិតសូម្បីរឿងដែលមិនគួរគិត តពីនោះ រមែងមានចិត្តវិបល្លាស សមដូច ពុទ្ធភាសិតដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលគិតនូវរឿងមិន គួរគិតទាំងឡាយណា គប្បីជាអ្នកមានចំណែកនៃសេចក្តីឆ្កួត វិនាសចរិត រឿងមិនគួរគិតទាំងឡាយនេះ មាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ ដូច្នេះ ។

ភិក្ខុបដិបត្តិខុសក្នុងបិដក ៣ ទាំងនេះ រមែងដល់សេចក្តីវិបត្តិ ផ្សេងដោយភាពជាអ្នកទ្រុស្តសីល ភាពជាមិច្ឆាទិដ្ឋិ និងចិត្តវិបល្លាសនេះ តាមលំដាប់ដោយប្រការ ដូច្នេះ ។ គាថានេះថា ៖

**ភិក្ខុរមែងដល់នូវប្រភេទនៃបរិយត្តិណា សម្បត្តិណា**
**សូម្បីនូវវិបត្តិណា ក្នុងបិដកណា ដោយអាការណា គប្បី**
**សម្តែងប្រភេទនៃបរិយត្តិទាំងអស់នោះ ដោយអាការនោះ**
**ដូច្នេះ ។**

ជាគាថាមានអត្ថដែលខ្ញុំម្ចាស់ពោលហើយ ដោយពាក្យមាន ប្រមាណ ប៉ុណ្ណេះ ។

គ្រាជ្រាបបិដកទាំងឡាយដោយប្រការផ្សេងៗ ហើយ អ្នកសិក្សា គប្បីជ្រាបព្រះពុទ្ធវចនៈនេះថា មាន ៣ យ៉ាង ដោយអំណាចនៃបិដកទាំង នោះ ដោយប្រការដូច្នេះ ។

ព្រះពុទ្ធវចនៈមាន ៥ ប្រភេទ ដោយអំណាចនៃនិកាយ រាប់យ៉ាងណា ? សេចក្ដីពិត ព្រះពុទ្ធវចនៈទាំងអស់នោះ មាន ៥ ប្រភេទ គឺ **ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ខុទ្ទកនិកាយ** ។

បណ្ដានិកាយ ៥ នោះ ទីឃនិកាយ គឺអ្វី ? គឺ និកាយដែលមានសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម ចាត់ជា ៣ វគ្គ ។

និកាយណា មានសូត្រ ៣៤ សូត្រ ចាត់ជា ៣ វគ្គ

និកាយទី ១ នេះ ឈ្មោះថា ទីឃនិកាយ មានឈ្មោះថា អនុលោម

ក៏ព្រោះហេតុអ្វី និកាយទី ១ នេះ ទើបហៅថា ទីឃនិកាយ ? ព្រោះជាទីប្រជុំ និងជាទីនៅរបស់សូត្រទាំងឡាយដែលមានខ្នាតវែង ។

ពិតមែន ពួក និងទីនៅ លោកហៅថា **និកាយ** ។ ក៏ក្នុងប្រការ**និកាយ** ស័ព្ទ សំដៅដល់ពួក និងទីនៅនេះ មានឧទាហរណ៍ជាគ្រឿងសាធកៈទាំងផ្លូវសាសនា និងផ្លូវលោក មានជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញនូវពួកធម៌ដទៃ សូម្បីតែមួយដែលផ្សេងគ្នា ដូចពួកសត្វតិរច្ឆាន និងដូចទីនៅរបស់ក្សត្រិយ៍បោណិកៈទនៅរបស់ក្សត្រិយ៍ចិក្ខល្លិកៈឡើយ ដូច្នេះ ។ សេចក្ដីរបស់ពាក្យក្នុងអត្ថដែលនិកាយទាំង ៤ ដ៏សេស ហៅថា **និកាយ** បណ្ឌិតគប្បីជ្រាបដោយន័យ ដូចពោលហើយយ៉ាងនេះ ។

**មជ្ឈិមនិកាយ** គឺអ្វី ? គឺ និកាយដែលមានសូត្រ ១៥២ សូត្រ

មានមូលបរិយាយសូត្រជាដើម មានខ្នាតកណ្ដាល ចាត់ជា ១៥ វគ្គ ។ ក្នុងនិកាយណា មានសូត្រ ១៥២ សូត្រ ចាត់ជា ១៥ វគ្គ និកាយនោះ ឈ្មោះមជ្ឈិមនិកាយ ។

**សំយុត្តនិកាយ** គឺអ្វី ? គឺ និកាយដែលមានសូត្រ ៧,៧៦២ សូត្រមានឱឃតរណសូត្រជាដើម ដែលត្រាស់ទុកដោយអំណាចនៃទេវតាសំយុត្តជាដើម ។ និកាយ ដែលមានសូត្រ ៧,៧៦២ សូត្រនេះ ចាត់ជាសំយុត្តនិកាយ ។

**អង្គុត្តរនិកាយ** គឺអ្វី ? គឺ និកាយដែលមានសូត្រ ៩,៥៥៧ សូត្រមានចិត្តបរិយាទានសូត្រជាដើម ដែលត្រាស់ទុកដោយអំណាចនៃការបន្ថែមឡើង បែកជាពួកៗ ចំនួនសូត្រក្នុងអង្គុត្តរនិកាយមានដូច្នេះ គឺ ៩,៥៥៧ សូត្រ ។

**ខុទ្ទកនិកាយ** គឺអ្វី ? គឺ វិន័យបិដកទាំងអស់ អភិធម្មបិដកទាំងអស់ គម្ពីរ ១៥ ប្រភេទ មានខុទ្ទកបាឋៈជាដើម និងព្រះពុទ្ធវចនៈដ៏សេស វៀរនិកាយ ៤ ។

វៀរលែងតែនិកាយទាំង ៤ មានទីឃនិកាយជាដើមទាំងនេះចេញ ព្រះពុទ្ធវចនៈដទៃចាកពីនោះ លោកហៅថា ខុទ្ទកនិកាយ ។ ព្រះពុទ្ធវចនៈមាន ៥ យ៉ាង ដោយអំណាចនៃនិកាយ រាប់យ៉ាងនេះឯង ។

ព្រះពុទ្ធវចនៈមាន ៩ យ៉ាង ដោយអំណាចនៃអង្គ រាប់យ៉ាងណា ?

ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នេះ មាន ៩ ប្រភេទ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។

ក្នុងព្រះពុទ្ធវចនៈមានអង្គ ៩ នោះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និងបរិវារៈ មង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្តកសូត្រ ក្នុងសុត្តនិបាត និងពាក្យទូន្មានរបស់ព្រះតថាគត ដែលមានឈ្មោះថា សូត្រ សូម្បីដទៃ គប្បីជ្រាបថា **សុត្ត** ។

សូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា **គេយ្យ** ដោយចំពោះយ៉ាងក្រៃលែង សគាថវគ្គ សូម្បីទាំងអស់ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា គេយ្យៈ ។

អភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងព្រះពុទ្ធ-វចនៈ សូម្បីដទៃណា ដែលមិនបានរួបរួមទុកដោយអង្គ ៨ ព្រះពុទ្ធវចនៈនោះ គប្បីជ្រាបថា **វេយ្យាករណ** ។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថា សុទ្ធដែលមិនមានឈ្មោះថា សូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា **គាថា** ។

សូត្រ ៨២ សូត្រ ដែលប្រកបដោយគាថាសម្រេចដោយញាណកើតរួមដោយសោមនស្សវេទនា គប្បីជ្រាបថា **ឧទាន** ។

សូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅ ដោយន័យមានជាដើមថា វុត្តំ ហេតំភគវតា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ គប្បីជ្រាបថា

**ឥតិវុត្តក** ។

ជាតក ៥៥០ រឿង មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា **ជាតក** ។

ព្រះសូត្រ ដែលប្រកបដោយរឿងដែលមិនធ្លាប់មាន មកមានឡើង គួរអស្ចារ្យ ៤ យ៉ាងទាំងនេះ មាននៅក្នុងព្រះអានន្ទ ដូច្នេះ គប្បីជ្រាបថា **អព្ភូតធម៌** ។

ព្រះសូត្រដែលត្រូវសួរ បានញាណ និងបីតិ សូម្បីទាំងអស់ មាន ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថា **វេទល្ល** ។

ព្រះពុទ្ធវចនៈមាន ៩ យ៉ាង ដោយអំណាចនៃអង្គ រាប់យ៉ាងនេះឯង ។

ព្រះពុទ្ធវចនៈមាន ៨៤,០០០ ដោយអំណាចនៃធម្មក្ខន្ធ រាប់យ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នេះ មាន ៨៤,០០០ ប្រភេទ ដោយអំណាចនៃធម្មក្ខន្ធ ដែលព្រះអានន្ទ សម្តែងទុកហើយយ៉ាងនេះថា ៖

> *ធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងហឫទ័យរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់រៀនធម៌ទាំងឡាយនោះ ពីព្រះមានព្រះភាគ ៨២,០០០ ព្រះធម្មក្ខន្ធ រៀនអំពីភិក្ខុ ២,០០០ ព្រះធម្មក្ខន្ធ រួម ៨៤,០០០ ព្រះធម្មក្ខន្ធ ។*

ក្នុងធម្មក្ខន្ធ ៨៤,០០០ នោះ ព្រះសូត្រដែល មានមាតិការឿង តែមួយ រាប់ជាធម្មក្ខន្ធ ១ ។ ព្រះសូត្រណាមានមាតិកា រឿងច្រើនរឿង រួមគ្នា ក្នុងព្រះសូត្រនោះ រាប់ធម្មក្ខន្ធតាមចំនួនមាតិការឿង ។

ក្នុងគាថាប្រព័ន្ធ ពាក្យសួរបញ្ហារឿង ១ រាប់ជាធម្មក្ខន្ធ ១ ពាក្យវិសជ្ជនាបញ្ហារឿង ១ រាប់ជាធម្មក្ខន្ធ ១ ។ ក្នុងព្រះអភិធម្ម ការចែកតិកៈ និងទុកៈតែមួយយ៉ាងៗ និងការចែកចិត្តវារៈតែមួយយ៉ាងៗ រាប់ជាធម្មក្ខន្ធ ១ ៗ ។ ក្នុងព្រះវិន័យ មានវត្ថុ មានមាតិកា មានបទ ភាជនីយ៍ មានអន្តរាយបត្តិ មានអាបត្តិ មានអនាបត្តិ មានតិកច្ឆេទៈ (ការកំណត់អាបត្តិជា ៣ ចំណែក) ក្នុងវត្ថុ និងមាតិកាជាដើមទាំងនោះ ចំណែកមួយៗ គប្បីជ្រាបថា ធម្មក្ខន្ធមួយៗ ។ ព្រះពុទ្ធវចនៈមាន ៨៤,០០០ ដោយអំណាចនៃធម្មក្ខន្ធ រាប់យ៉ាងនេះឯង ។

ព្រះពុទ្ធវចនៈនេះ ដោយមិនចែកប្រភេទ មានមួយ គឺ រស , ដោយចែកប្រភេទ មានប្រភេទ ២ យ៉ាងជាដើម គឺ ជាព្រះធម៌ ១ យ៉ាង ជាវិន័យ ១ យ៉ាង ជាដើម ដែលគណៈអ្នកស្មាត់ជំនាញ មានព្រះមហាកស្សបៈជាប្រមុខ កាលទីងសង្គាយនា បានកំណត់ប្រភេទនេះមុនហើយ ទើបសង្គាយនាថា នេះជាធម៌ នេះជាវិន័យ នេះជាបឋមពុទ្ធវចនៈ នេះជាមជ្ឈិមពុទ្ធវចនៈ នេះជាបច្ឆិមពុទ្ធវចនៈ នេះជាវិន័យបិដក នេះជា

សុត្តន្តបិដក នេះជាអភិធម្មបិដក នេះជាទីឃនិកាយ នេះជាមជ្ឈិមនិកាយ នេះជាសំយុត្តនិកាយ នេះជាអង្គុត្តរនិកាយ នេះជាខុទ្ទកនិកាយ នេះជាអង្គ ៩ មានសុត្តៈជាដើម នេះជាព្រះធម្មក្ខន្ធ ៨៤,០០០ ដោយប្រការដូច្នេះ ។ នឹងថា លោកកំណត់ប្រភេទនេះប៉ុណ្ណោះតែម្យ៉ាង ហើយបានសង្គាយនាក៏ទេ តែលោកនៅកំណត់ប្រភេទនៃសង្គហៈសូម្បីដទៃៗ ដែលមានប្រការមិនមែនតិចជាដើមថា ឧទានសង្គហៈ វគ្គសង្គហៈ បេយ្យាលសង្គហៈ និងនិបាតសង្គហៈ មានឯកនិបាត និងទុកនិបាតជាដើម សំយុត្តសង្គហៈ និងបញ្ញាសសង្គហៈជាដើម ដែលប្រាកដនៅក្នុងបិដក ៣ សង្គាយនាហើយ ប្រើវេលា ៧ ខែ ដោយប្រការដូច្នេះ ។

ក៏ក្នុងអវសាននៃការសង្គាយនាព្រះពុទ្ធវចនៈនោះ ផែនដីធំនេះបានកម្រើករញ្ជួយញាប់ញ័រជាអនេកប្បការ ទូទៅដរាបដល់ទឹកទ្រផែនដី ដូចជាកើតសេចក្ដីបាមោជ្ជៈ ឲ្យសាធុការថា សាសនារបស់ព្រះទសពលនេះ ព្រះមហាកស្សបត្ថេរ បានធ្វើឲ្យអាចមានអាយុយូរអង្វែងទៅបាន រហូតដល់អស់កាលប្រមាណ ៥,០០០ ឆ្នាំ និងបានប្រាកដភាពមហស្ចារ្យទាំងឡាយមិនមែនតិច ដោយប្រការដូច្នេះ ។ សង្គាយនាណាក្នុងលោក ហៅថា **បញ្ចសតា** ព្រោះព្រះអរហន្ត ៥០០ អង្គ បានធ្វើទុក និងហៅថា **ថេរិកា** ព្រោះព្រះសង្ឃជាព្រះថេរៈទាំងនោះបានធ្វើទុក សង្គាយនានេះ **ឈ្មោះថា បឋមមហាសង្គាយនា** ដោយប្រការដូច្នេះ ។

**និទានកថា ចប់**

# អដ្ឋកថា ព្រហ្មជាលសូត្រ

## ពណ៌នាបរិត្យាជកកថា

[១] កាលបឋមមហាសង្គាយនានេះកំពុងប្រព្រឹត្តទៅ នៅវេលាសង្គាយនាព្រះវិន័យចប់ស្រេច ព្រះមហាកស្សបៈ កាលសួរព្រហ្មជាលសូត្រដែលជាសូត្រដំបូងនៃនិកាយដំបូង ក្នុងសុត្តន្តបិដក បានពោលពាក្យយ៉ាងនេះថា ម្នាលអានន្ទមានអាយុ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគទ្រង់-សម្តែងក្នុងទីណា ដូច្នេះជាដើមរហូតចប់ ព្រះអានន្ទកាលនឹងប្រកាសស្ថានទីដែលព្រះមានព្រះភាគត្រាស់ព្រហ្មជាលសូត្រ និងបុគ្គល ដែលព្រះអង្គត្រាស់ប្រារព្ធឲ្យជាហេតុនោះ ឲ្យគ្រប់ក្រសែសេចក្តី ទើបពោលពាក្យថា ឯវម្មេ សុតំ ដូច្នេះជាដើម ។ ដោយហេតុនោះ លោកទើបពោលថា សូម្បីព្រហ្មជាលសូត្រ ក៏មានពាក្យជានិទានថា ឯវម្មេ សុតំ ដែលព្រះអានន្ទពោលក្នុងបឋមមហាសង្គាយនា ជាខាងដើម ដូច្នេះ ។

ក្នុងពាក្យនិទាននៃព្រះសូត្រនោះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖

## ពន្យល់អត្ថបទថា ឯវំ

បទថា ឯវំ ជាបទនិបាត ។ បទថា មេ ជាដើម ជាបទនាមក្នុងពាក្យថា បដិប្បន្នោ ហោតិ នេះ បទថា បដិ ជាបទឧបសគ្គ ។ បទថា ហោតិ ជាបទអាខ្យាត ។ គប្បីជ្រាបការចែកបទដោយន័យប៉ុណ្ណោះមុន ។

តែដោយអត្ថ ឯវំ ស័ព្ទ ចែកសេចក្តីបានច្រើនយ៉ាង មានជាអាទិថា ការប្រៀបធៀប ការណែនាំ ការលើកតម្កើង ការតិះដៀល ការទទួលពាក្យ អាការ ការចង្អុលបង្ហាញ ការហាមសេចក្តីដទៃ ។

ពិតយ៉ាងនោះ ឯវំ ស័ព្ទនេះ ដែលមកក្នុង **ការប្រៀបធៀប** ដូចក្នុងប្រយោគជាដើមថា ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ សត្វកើតមកហើយ គួរបំពេញកុសលឲ្យច្រើនយ៉ាងនេះ ដូច្នោះ ។

ដែលមកក្នុង **ការណែនាំ** ដូចមានក្នុងប្រយោគថា ឯវំ តេ អភិ-ក្កមិតព្វំ ឯវំ បដិក្កមិតព្វំ អ្នកត្រូវឈានដើរទៅយ៉ាងនេះ ត្រូវថយក្រោយយ៉ាងនេះ ។

ដែលមកក្នុង **ការលើកតម្កើង** ដូចក្នុងប្រយោគមានជាដើមថា ឯវមេតំ ភគវា ឯវមេតំ សុគត បពិត្រព្រះមានព្រះភាគ ដំណើរនោះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនោះយ៉ាងហ្នឹងហើយ ។

ដែលមកក្នុង **ការតិះដៀល** ដូចក្នុងប្រយោគជាដើមថា ឯវមេវំ បនាយំ វសលី យស្មិំ វា តស្មិំ វា តស្ស មុណ្ឌកស្ស សមណកស្ស វណ្ណំ ភាសតិ មេចង្រៃនេះ ហ៊ានពោលសរសើរសមណៈត្រងោលយ៉ាងនេះយ៉ាងនេះ តែផ្តេសតែផ្តាស ។

ដែលមកក្នុង **ការទទួលពាក្យ** ដូចក្នុងប្រយោគមានជាដើមថា ឯវំ

ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ភិក្ខុទាំងនោះទទួលព្រះពុទ្ធ-ដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ដែលមកក្នុង **អាការ** ដូចក្នុងប្រយោគជាដើមថា ឯវំ ព្យាខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ យ៉ាងនេះឯង ។

ដែលមកក្នុង **ការចង្អុលបង្ហាញ** ដូចក្នុងប្រយោគមានជាដើមថា ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុភោ មាណវោ តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយ .

ម្នាលមាណព អ្នកចូលមកនេះ ឯងចូរទៅរកអានន្ទ ហើយសួរព្រះអានន្ទនូវអាការមានអាពាធតិច ការមានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ នឹងចូរនិយាយយ៉ាងនេះថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ផ្ដាំឲ្យសួរព្រះអានន្ទដ៏ចម្រើន នូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មាន

កម្លាំងនៅជាសុខសប្បាយ ហើយចូរពោលយ៉ាងនេះថា សូមព្រះអានន្ទជាម្ចាស់អាស្រ័យនូវសេចក្ដីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ។

ដែលមកក្នុងអវធារណៈ **ការហាមសេចក្ដីដទៃ** ដូចក្នុងប្រយោគមានជាដើមថា តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា ។បេ។ ឯវំ នោ ឯត្ថ ហោតិ ម្នាលកាលាមទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្ដេច ធម៌ទាំងនេះជា កុសល ឬជាអកុសល ពួកជនកាលាម ក្រាបទូលថា ជាអកុសល ព្រះអង្គ ។ មានទោស ឬមិនមានទោសទេ ។ មានទោស ព្រះអង្គ ។ អ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ? អ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ បុគ្គលណាសមាទានឲ្យបរិបូរណ៍ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬអ្នកទាំងឡាយមានការឃើញយ៉ាងណា ក្នុងសេចក្ដីនេះ ? ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ក្នុងសេចក្ដីនេះ ខ្ញុំព្រះអង្គទាំងឡាយមានការឃើញយ៉ាងនេះ ព្រះអង្គ ។ ឯវំ សព្ទនោះ ក្នុងព្រះបាលីនេះ គប្បីឃើញប្រើក្នុងអត្ថ គឺអាការ ការចង្អុលបង្ហាញ ការហាមសេចក្ដីដទៃ ។

បណ្ដាអត្ថ ៣ យ៉ាងនោះ ដោយ ឯវំ សព្ទ ដែលមានអាការជាអត្ថ ព្រះអានន្ទសម្ដែងសេចក្ដីនេះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ

នោះ ល្អិតល្អន់ដោយន័យផ្សេងៗ តាំងឡើង ដោយអធ្យាស្រ័យមិនមែនតិច សម្បូរណ៍ដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ជ្រាលជ្រៅដោយ ធម៌ អត្ថ ទេសនា និងបដិវេធ មកកាន់គន្លងសោត សមគួរដល់ភាសា របស់ខ្លួនៗ របស់សត្វលោកទាំងពួង អ្នកណាហ្ន៎ ដែលអាចយល់បាន ដោយប្រការទាំងពួង តែខ្ញុំម្ចាស់សូម្បីប្រើកម្លាំងទាំងអស់ ឲ្យកើត សេចក្ដីប្រាថ្នានឹងស្ដាប់ ក៏បានស្ដាប់មកយ៉ាងនេះ គឺ សូម្បីខ្ញុំម្ចាស់ក៏បាន ស្ដាប់មក ដោយអាការយ៉ាងហ្នឹងឯង ។

ដោយ ឯវំ ស័ព្ទ ដែលមាននិទស្សនៈជាអត្ថ ព្រះអានន្ទ កាលនឹង ដោះខ្លួនថា ខ្ញុំម្ចាស់មិនមែនព្រះសយម្ភូ ព្រះសូត្រនេះ ខ្ញុំម្ចាស់មិនបាន ធ្វើឲ្យច្បាស់ ទើបសម្ដែងព្រះសូត្រទាំងអស់ ដែលគួរពោលក្នុងពេល ឥឡូវនេះថា ឯវម្មេ សុតំ គឺ ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ។

ដោយ ឯវំ ស័ព្ទ ដែលមានអវធារណៈជាអត្ថ ព្រះអានន្ទកាល នឹងសម្ដែង កម្លាំងនៃការទ្រទ្រង់ចាំទុករបស់ខ្លួនដែលគួរដល់ការៈដែល ព្រះមានព្រះភាគទ្រង់សរសើរ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អានន្ទនេះ ប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ជាពហុស្សូត មានគតិ មានសតិ មានធិតិ ( ការចងចាំ ) ជាឧបដ្ឋាក ដូច្នេះ និង ដែលព្រះធម្មសេនាបតីសារីបុត្តត្រេកសរសើរ យ៉ាងនេះថា ព្រះអានន្ទ ដ៏មានអាយុ ជាអ្នកឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុង

ព្យញ្ជនៈ ១ ឈ្មោះសក្ខុងនិរុត្តិ ១ ឈ្មោះសក្ខុងទាំងដើមទាំងចុង ដូច្នេះ រមែងឲ្យកើតសេចក្តីប្រាថ្នានឹងស្តាប់ដល់សត្វលោកទាំងឡាយ ដោយពោលថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ និងការស្តាប់នោះ ក៏មិនខ្វះមិនលើស ទាំងអត្ថ ទាំងព្យញ្ជនៈ គឺ យ៉ាងនេះប៉ុណ្ណោះ មិនគប្បីឃើញជាយ៉ាងដទៃ ។

## ពន្យល់អត្ថ បទថា មេ

មេ សព្ទ ឃើញប្រើក្នុងសេចក្តី ៣ យ៉ាង ។ ពិតយ៉ាងនោះ មេ សព្ទនេះ មានសេចក្តីស្មើនឹង មយា ដូចក្នុងប្រយោគមានជាដើមថា គាថា ភិគីតំ មេ អភោជនេយ្យំ តថាគតមិនគួរបរិភោគភោជនដែលបានអំពីការពោលគាថា ដូចជាចម្រៀងទេ ។

មានសេចក្តីស្មើនឹង មយ្ហំ ដូចក្នុងប្រយោគមានជាដើមថា សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានវរោកាស សូមព្រះមានព្រះភាគប្រោសសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គចុះ ។ មានសេចក្តីស្មើនឹង មម ដូចក្នុងប្រយោគមានជាដើមថា ធម្មទាយាទា មេ ភិក្ខវេ ភវថ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាធម្មទាយាទរបស់តថាគត ។ តែក្នុងព្រះសូត្រនេះ មេ សព្ទ គួរប្រើក្នុងអត្ថ ២ យ៉ាង គឺ មយា សុតំ ខ្ញុំម្ចាស់បានស្តាប់មក និង

មម សុតំ ការស្តាប់របស់ខ្ញុំម្ចាស់ ។

## ពន្យល់អត្ថ បទថា សុតំ

សុត សព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ចែកសេចក្តីបានច្រើនយ៉ាង ដូចសេចក្តីថា ទៅ , ប្រាកដ , តម្រេក , សន្សំ , ខ្វល់ខ្វាយ , សទ្ទារម្មណ៍ដែលដឹងដោយសោត , និងថា ដឹងតាមសោតទ្វារជាដើម ។

ពិតយ៉ាងនោះ សុត សព្ទនេះ មានសេចក្តីថា **ទៅ** ដូចក្នុងប្រយោគជាដើមថា សេនាយ បសុតោ សេនាឃ្លាតទៅ មានសេចក្តីថាដើរទ័ព ។

មានសេចក្តីថា **ប្រាកដ** ដូចក្នុងប្រយោគជាដើមថា សុតធម្មស្ស បស្សតោ មានធម៌ដែលប្រាកដហើយ អ្នកឃើញហើយ មានសេចក្តីថា អ្នកមានធម៌ប្រាកដហើយ ។

មានសេចក្តីថា **តម្រេក** ដូចក្នុងប្រយោគមានជាដើមថា អវស្សុតា អវស្សុតស្ស ភិក្ខុនីមានតម្រេក ត្រេកអរនឹងបុរសដែលមានតម្រេកមកស្ទាបអង្អែលត្រង់កាយ មានសេចក្តីថា ភិក្ខុនីមានចិត្តជោគដោយរាគៈ ត្រេកអរនឹងបុរសអ្នកមានចិត្តជោគដោយរាគៈ មកចាប់ពាល់កាយ ។

មានសេចក្ដីថា **សន្សំ** ដូចក្នុងប្រយោគមានជាដើមថា តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ បុណ្យដ៏ច្រើន អ្នកទាំងឡាយបានសន្សំហើយ មានសេចក្ដីថា ចូលទៅសន្សំហើយ ។

មានសេចក្ដីថា **ខ្វល់ខ្វាយ** ដូចក្នុងប្រយោគជាដើមថា យេ ឈានបសុតា ធីរា អ្នកប្រាជ្ញទាំងឡាយណា ខ្វល់ខ្វាយក្នុងឈាន មានសេចក្ដីថា ប្រកបរឿយៗ ក្នុងឈាន ។

មានសេចក្ដីថា **សទ្ទារម្មណ៍ដែលដឹងដោយសោតៈ** ដូចក្នុងប្រយោគជាដើមថា ទិដ្ឋំ សុតំ មុតំ រូបារម្មណ៍ដែលចក្ខុឃើញ សទ្ទារម្មណ៍ដែលសោតៈឮ និងអារម្មណ៍ទាំងឡាយដែលបានជ្រាប មានសេចក្ដីថា សទ្ទារម្មណ៍ដែលឮដោយសោតៈ ។

មានសេចក្ដីថា **ដឹងតាមសោតទ្វារ** ដូចក្នុងប្រយោគមានជាដើមថា សុតធរោ សុតសន្និចយោ ទ្រទ្រង់សុតៈ សន្សំសុតៈ មានសេចក្ដីថា ទ្រទ្រង់ធម៌ដែលដឹងតាមសោតទ្វារ ។

តែក្នុងព្រះសូត្រនេះ សុត ស័ព្ទនេះ មានសេចក្ដីថា ចាំ ឬការចាំតាមសោតទ្វារ ។

ក៏ មេ ស័ព្ទ បើមានសេចក្ដីស្មើនឹង មយា រមែងប្រកបសេចក្ដីបានថា ខ្ញុំបានស្ដាប់មក គឺ ចាំតាមសោតទ្វារយ៉ាងនេះ បើមានសេចក្ដីស្មើនឹង មម រមែងប្រកបសេចក្ដីបានថា ការស្ដាប់របស់ខ្ញុំ

គឺ សេចក្តីចាំតាមសោតទ្វាររបស់ខ្ញុំ យ៉ាងនេះ ។

## ពន្យល់អត្ថ ឯវំ មេ សុតំ

បណ្តាបទទាំង ៣ ដូចពោលមកនេះ បទថា ឯវំ សម្តែងកិច្ចនៃវិញ្ញាណ មានសោតវិញ្ញាណជាដើម ។

បទថា មេ សម្តែងបុគ្គលអ្នកមានសេចក្តីព្រមព្រៀងដោយវិញ្ញាណ ដូចបានពោលហើយ ។

បទថា សុតំ សម្តែងការទទួលទុកមិនខ្វះមិនលើស និងមិនវិបរិត ព្រោះបដិសេធភាវៈដែលមិនបានឮ ។

មួយទៀត បទថា ឯវំ ប្រកាសភាវៈដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដែលប្រកបផ្សេងៗតាមវិថីវិញ្ញាណដែលប្រព្រឹត្តទៅតាមសោតទ្វារនោះ ។

បទថា មេ ជាពាក្យប្រកាសខ្លួន ។

បទថា សុតំ ជាពាក្យប្រកាសធម៌ ។

ក៏ក្នុងព្រះបាលីនេះ មានសេចក្តីសង្ខេបដូច្នេះថា ខ្ញុំមិនបានធ្វើវត្ថុដទៃ តែបានធ្វើវត្ថុនេះ គឺ បានស្តាប់ធម៌នេះ តាមវិថីវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ។

មួយវិញទៀត បទថា ឯវំ ជាពាក្យប្រកាសប្រការគួរសម្តែង ។

បទថា មេ ជាពាក្យប្រកាសដល់បុគ្គល ។

បទថា សុតំ ជាពាក្យប្រកាសដល់កិច្ចរបស់បុគ្គល ។

អធិប្បាយថា ខ្ញុំម្ចាស់នឹងសម្តែងព្រះសូត្រណា ព្រះសូត្រនោះ ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ ។

មួយទៀត បទថា ឯវំ ចង្អុលបង្ហាញអាការផ្សេងៗ របស់ចិត្តសន្តាន ដែលជាតួទទួលអត្ថ និងព្យញ្ជនៈផ្សេងៗ ដោយប្រព្រឹត្តទៅដោយអាការ ផ្សេងគ្នា ។

ពិតមែន សព្ទថា ឯវំ នេះ ជាអាការបញ្ញត្តិ ។

សព្ទថា មេ ជាពាក្យចង្អុលដល់អ្នកធ្វើ ។

សព្ទថា សុតំ ជាពាក្យចង្អុលដល់អារម្មណ៍ ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះ ក៏គឺ ដែលចិត្តសន្តានប្រព្រឹត្តទៅដោយ អាការផ្សេងគ្នា ធ្វើការផ្ចាក់ចុះទទួលអារម្មណ៍របស់អ្នកធ្វើដែលមានសេចក្តី ព្រមព្រៀងដោយចិត្តសន្តាននោះ ។

ប្រការមួយទៀត សព្ទថា ឯវំ ជាពាក្យចង្អុលកិច្ចរបស់បុគ្គល ។

សព្ទថា សុតំ ជាពាក្យចង្អុលដល់កិច្ចរបស់វិញ្ញាណ ។

សព្ទថា មេ ជាពាក្យចង្អុលដល់បុគ្គលអ្នកប្រកបកិច្ចទាំងពីរ ។

ក៏ក្នុងព្រះបាលីនេះ មានសេចក្តីសង្ខេបដូច្នេះថា ខ្ញុំម្ចាស់ គឺ បុគ្គលដែលប្រកបដោយសោតវិញ្ញាណ បានស្តាប់មក ដោយវោហារថា សវនកិច្ច ដែលបានមកដោយអំណាចវិញ្ញាណ ។

បណ្ដាសព្ទទាំង ៣ នោះ សព្ទថា ឯវំ និងសព្ទថា មេ ជាអវិជ្ជមានបញ្ញត្តិ ដោយអំណាចសច្ចិកត្ថបរមត្ថ ព្រោះក្នុងព្រះបាលីនេះ ប្រការដែលគួរនឹងបានចង្អុលបង្ហាញថា ឯវំ ក្ដី ថា មេ ក្ដី នោះ ពោលដោយបរមត្ថ និងមានយ៉ាងណា ។

បទថា សុតំ ជាវិជ្ជមានបញ្ញត្តិ ព្រោះអារម្មណ៍ដែលបាន តាមទ្វារសោតៈ ក្នុងបទនេះ ពោលដោយបរមត្ថមាន ។

មួយទៀត បទថា ឯវំ និង មេ ជាឧបាទាបញ្ញត្តិ ព្រោះប្រាថ្នាពោលអារម្មណ៍នោះៗ ។

បទថា សុតំ ជាឧបនិធាបញ្ញត្តិ ព្រោះពោលអាងដល់អារម្មណ៍មានអារម្មណ៍ដែលឃើញហើយជាដើម ។

ក៏ក្នុងព្រះបាលីនេះ ដោយពាក្យថា ឯវំ ព្រះអានន្ទសម្ដែងដល់សេចក្ដីមិនវង្វេង ។ ព្រោះអ្នកវង្វេង រមែងមិនអាចចាក់ធ្លុះដោយប្រការផ្សេងៗ បាន ។

ដោយពាក្យថា សុតំ ព្រះអានន្ទសម្ដែងការមិនភ្លេចពាក្យ ដែលបានស្ដាប់មក ព្រោះជាអ្នកភ្លេចពាក្យដែលបានស្ដាប់មកនោះ រមែងមិនដឹងច្បាស់ថា ខ្ញុំម្ចាស់បានស្ដាប់មកដោយកាលពិសេស ។

ដោយអាការយ៉ាងនេះ ព្រះអានន្ទនេះ រមែងមានការសម្រេចផ្លូវបញ្ញាដោយការមិនវង្វេង និងរមែងមានសេចក្ដីសម្រេចផ្លូវសតិ ដោយ

ការមិនភ្លេច ។

ក្នុងសេចក្តីសម្រេច ២ ប្រការនោះ សតិដែលមានបញ្ញានាំ អាចហាម (សេចក្តីដទៃ) ដោយព្យញ្ជនៈ , បញ្ញាដែលមានសតិនាំ អាចចាក់ធ្លុះដោយអត្ថ ។ ដោយអំណាចទាំង ២ ប្រការនោះ រមែងសម្រេចការៈដែលព្រះអានន្ទទីងបាននាមថា ជាឃ្លាំងនៃព្រះធម៌ ព្រោះអាចអនុរក្សព្រះធម៌ ដែលសម្បូរណ៍ដោយអត្ថៈ និងព្យញ្ជនៈ ។

## ន័យម្យ៉ាងទៀត

ដោយពាក្យថា ឯវំ ព្រះអានន្ទសម្តែងយោនិសោមនសិការ ព្រោះអ្នកដែលមិនមានយោនិសោមនសិការ មិនអាចចាក់ធ្លុះដោយប្រការផ្សេងៗ ។

ដោយពាក្យថា សុតំ ព្រះអានន្ទសម្តែងសេចក្តីមិនរវើរវាយ ព្រោះអ្នកដែលមានចិត្តរវើរវាយស្តាប់មិនបាន ។

ពិតយ៉ាងនោះ បុគ្គលអ្នកមានចិត្តរវើរវាយ សូម្បីគេនិយាយដោយសេចក្តីសម្បូរណ៍គ្រប់យ៉ាងក៏នៅនិយាយថា ខ្ញុំមិនបានឮ សូមនិយាយម្តងទៀត ។

ក៏ក្នុងគុណ ២ ប្រការនេះ ព្រះអានន្ទធ្វើអត្តសម្មាបណិធិ និងបុព្វេកតបុញ្ញតា ឲ្យសម្រេចបានដោយយោនិសោមនសិការ ព្រោះអ្នកមិនបានតាំងខ្លួនទុកប្រពៃ ឬមិនបានធ្វើសេចក្តីល្អទុកក្នុងកាលមុន នឹងមិនមាន

យោនិសោមនសិការ ព្រះអានន្ទធ្វើការស្តាប់ព្រះសទ្ធម្ម និងការសេពគប់សប្បុរសឲ្យសម្រេចបាន ដោយសេចក្តីមិនរវើរវាយ ព្រោះអ្នកមានចិត្តរវើរវាយ មិនអាចនឹងស្តាប់បាន និងអ្នកមិនសេពគប់សប្បុរស ក៏មិនមានការស្តាប់ ។

ន័យម្យ៉ាងទៀត ព្រោះខ្ញុំបានពោលទុកហើយថា បទថា ឯវំ សម្តែងនូវអាការផ្សេងៗ របស់ចិត្តសន្តាន ដែលខ្លួនទទួលអត្ថៈ និងព្យញ្ជនៈផ្សេងៗ ដោយប្រព្រឹត្តទៅដោយអាការផ្សេងគ្នា និងអាការដែលចម្រើនយ៉ាងនេះ រមែងមិនមានដល់បុគ្គលអ្នកមិនបានតាំងខ្លួនទុកប្រពៃ ឬមិនបានធ្វើសេចក្តីល្អទុកក្នុងកាលមុន ដូច្នោះ ដោយពាក្យថា ឯវំ នេះ ព្រះអានន្ទសម្តែងសម្បត្តិ គឺ ចក្រ ២ ប្រការ ខាងចុងរបស់ខ្លួន ដោយអាការដែលចម្រើននេះ ។ ដោយពាក្យថា សុតំ ព្រះអានន្ទសម្តែងសម្បត្តិ គឺ ចក្រធម៌ ២ ប្រការ ខាងដើមរបស់ខ្លួន ដោយការប្រកបការស្តាប់ ។ ព្រោះអ្នកដែលនៅក្នុងអាវាសស្ថានដែលមិនមែនជាបដិរូបទេសៈក្តី អ្នកដែលវៀរការសេពគប់សប្បុរសក្តី រមែងមិនមានការស្តាប់ដោយប្រការដូច្នេះ ។ សេចក្តីបរិសុទ្ធិនៃអធ្យាស្រ័យ រមែងជាការសម្រេចដល់លោក ព្រោះសេចក្តីសម្រេចនៃចក្រធម៌ ២ ប្រការខាងចុង សេចក្តីបរិសុទ្ធិនៃសេចក្តីព្យាយាមរមែងជាការសម្រេច ព្រោះសេចក្តីសម្រេចនៃចក្រ ២ ប្រការខាងដើម និងដោយសេចក្តីបរិសុទ្ធិនៃអធ្យាស្រ័យនោះ

រមែងជាការសម្រេចសេចក្តីធ្លាតក្នុងបដិវេធ ដោយសេចក្តីបរិសុទ្ធិនៃសេចក្តីព្យាយាម រមែងសម្រេចសេចក្តីធ្លាតក្នុងបរិយត្តិ ។ ដោយប្រការដូច្នេះ ពាក្យរបស់ព្រះអានន្ទអ្នកមានការព្យាយាម និងអធ្យាស្រ័យ បរិសុទ្ធិសម្បូរណ៍ដោយបរិយត្តិ និងបដិវេធរមែងគួរ ជាពាក្យផ្តើមដំបូងនៃព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចការប្រាកដឡើងនៃអរុណ ជាខាងដើមរបស់ព្រះអាទិត្យដែលកំពុងឧទ័យឡើង និងដូចយោនិសោមនសិការជាខាងដើមនៃកុសលកម្មដូច្នោះ ហេតុដូច្នោះព្រះអានន្ទ កាលនឹងតាំងពាក្យជានិទានក្នុងឋានៈដែលគួរ ទើបពោលពាក្យជាដើមថា ឯវម្មេ សុតំ ដូច្នេះ ។

ន័យម្យ៉ាងទៀត ដោយពាក្យសម្តែងការចាក់ធ្លុះ មានប្រការផ្សេងៗថា ឯវំ នេះ ព្រះអានន្ទសម្តែងដល់សភាពនៃសម្បត្តិ គឺ អត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ។ ដោយពាក្យសម្តែងដល់ការចាក់ធ្លុះនូវប្រភេទនៃធម៌ដែលគួរស្តាប់ថា សុតំ នេះ ព្រះអានន្ទសម្តែងដល់សភាពនៃសម្បត្តិ គឺ ធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ។

មួយទៀត ព្រះអានន្ទ កាលពោលពាក្យដែលសម្តែងយោនិសោ-មនសិការថា ឯវំ នេះ រមែងសម្តែងថា ធម៌ទាំងនេះ ខ្ញុំសម្លឹងដោយចិត្តចាក់ធ្លុះល្អហើយដោយទិដ្ឋិ កាលពោលពាក្យដែលសម្តែងការប្រកបដោយការស្តាប់ថា សុតំ នេះ រមែងសម្តែងថា ធម៌ជាច្រើនខ្ញុំបានស្តាប់ហើយ

ទ្រទ្រង់ចាំទុកហើយ យ៉ាងរត់មាត់ ។ កាលសម្តែងសេចក្តីបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ សូម្បីដោយពាក្យទាំងពីរនោះ រមែងឲ្យកើតសេចក្តីអើពើក្នុងការស្តាប់ ព្រោះថា អ្នកមិនស្តាប់ធម៌ ដែលបរិបូណ៌ដោយអត្ថៈ និងព្យញ្ជនៈ ដោយអើពើរមែងឃ្លាតឆ្ងាយចាកប្រយោជន៍ដ៏ធំ ព្រោះហេតុដូច្នេះ កុលបុត្រគប្បីឲ្យកើតសេចក្តីអើពើ ស្តាប់ធម៌នេះដោយគោរពចុះ ។

មួយទៀត ដោយពាក្យទាំងអស់ថា ឯវម្មេ សុតំ នេះ ព្រះអានន្ទមិនបានតាំងធម៌ ដែលព្រះតថាគតទ្រង់ប្រកាសហើយដើម្បីខ្លួន រមែងកន្លងផុតភូមិអសប្បុរស កាលបដិញ្ញាណភាពជាសាវក រមែងឈានចុះកាន់ភូមិសប្បុរស ។

មួយទៀត រមែងញុំាងចិត្តឲ្យចេញផុតពីអសទ្ធម្ម រមែងញុំាងចិត្តឲ្យតាំងនៅក្នុងព្រះសទ្ធម្ម កាលសម្តែងថា ក៏ព្រះតម្រាស់របស់ព្រះមាន-ព្រះភាគអង្គនោះប៉ុណ្ណោះ ខ្ញុំម្ចាស់បានស្តាប់មកដោយអស់ជើងតែម្យ៉ាង ឈ្មោះថា រមែងដោះខ្លួន រមែងសម្តែងអាងព្រះបរមសាស្តា ធ្វើព្រះតម្រាស់របស់ ព្រះជិនស្រីឲ្យតម្កល់មាំ និងប្រតិស្ឋានព្រះធម៌ទុក ។

ម្យ៉ាងទៀត ព្រះអានន្ទកាលមិនបដិញ្ញាណថា ធម៌ដែលខ្លួនឲ្យកើតឡើងថា ខ្ញុំបានស្តាប់មកយ៉ាងនេះ បើកបង្ហាញការស្តាប់ក្នុងខាងដើម រមែងញុំាងការមិនមានសទ្ធាឲ្យវិនាស រមែងញុំាងការដល់ព្រមនៃសទ្ធាក្នុងធម៌នេះឲ្យកើតឡើងដល់ទេវតា និងមនុស្សទាំងពួងថា ព្រះតម្រាស់នេះ

ខ្ញុំម្ចាស់បានទទួលមកចំពោះព្រះភក្ត្រព្រះមានព្រះភាគ ព្រះអង្គដ៏ក្លៀវក្លា ដោយវេសារជ្ជញ្ញាណទាំងបួន ទ្រទ្រង់នូវកម្លាំង ១០ អ្នកតាំងនៅក្នុងឋានៈដ៏អង់អាច អ្នកបន្លឺសីហនាទ អ្នកខ្ពស់បំផុតជាងសត្វទាំងពួង អ្នកជាធំក្នុងធម៌ អ្នកជាធម្មរាជា អ្នកជាធម្មាធិបតី អ្នកមានធម៌ជាប្រទីប អ្នកមានធម៌ជាសរណៈ អ្នកញ៉ាំងចក្រដ៏ប្រសើរ គឺ ព្រះសទ្ធម្មឲ្យវិលទៅ អ្នកជាព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ក្នុងព្រះតម្រាស់នេះ អ្នកណាៗ មិនគួរធ្វើសេចក្តីសង្ស័យ ឬងឿងឆ្ងល់ក្នុងអត្ថ ឬធម៌ ក្នុងបទ ឬព្យញ្ជនៈ ព្រោះដូច្នោះ ព្រះអានន្ទ រមែងញ៉ាំងភាពជាអ្នកមិនមានសទ្ធាឲ្យវិនាស ញ៉ាំងសទ្ធាសម្បទាឲ្យកើតឡើងក្នុងធម៌នេះ ដល់ទេវតា និងមនុស្សទាំងពួងដោយប្រការដូច្នេះ ដោយហេតុនោះ លោកទើបពោលគាថាប្រព័ន្ធទុកដូច្នេះថា ៖

*ព្រះអានន្ទត្ថេរ ជាសាវករបស់ព្រះគោតម ពោលយ៉ាងនេះថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ រមែងញ៉ាំងការមិនមានសទ្ធាឲ្យវិនាស រមែងញ៉ាំងសទ្ធាក្នុងព្រះសាសនាឲ្យចម្រើន ដូច្នេះ ។*

## ពន្យល់អត្ថនៃបទ ឯកំ សមយំ

បទថា ឯកំ សម្តែងការកំណត់រាប់ចំនួន ។

បទថា សមយំ សម្តែងសម័យដែលកំណត់ ។

ពីរបទថា ឯកំ សមយំ សម្តែងសម័យដែលមិនពិតប្រាកដ ។

សមយ ស័ព្ទ ក្នុងបទថា សមយំ នោះ ប្រាកដក្នុងសេចក្តីថា ព្រមព្រៀង ខណៈ កាល ប្រជុំ ហេតុ លទ្ធិ បានចំពោះ លះ និងចាក់ធ្លុះ ។

ពិតយ៉ាងនោះ **សមយ** ស័ព្ទនោះ មានសេចក្តីថា **ព្រមព្រៀង** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា អប្បេវនាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ ឈ្មោះសូម្បីឯណោះ យើងទាំងឡាយ កំណត់កាល និងការព្រមព្រៀងហើយ សឹមទៅរកក្នុងថ្ងៃស្អែក ។

មានសេចក្តីថា **ខណៈ** ដូចក្នុងប្រយោគជាដើមថា ឯកោ វ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ ម្នាលភិក្ខុទាំងឡាយ ឱកាស និងខណៈនៃការនៅប្រព្រឹត្តព្រហ្មចារ្យ មានតែមួយប៉ុណ្ណោះឯង ។

មានសេចក្តីថា **កាល** ដូចក្នុងប្រយោគជាដើមថា ឧណ្ហសមយោ បរិឡាហសមយោ កាលក្តៅ កាលស្អុះស្អាប់ ។

មានសេចក្តីថា **ប្រជុំ** ដូចក្នុងប្រយោគមានជាដើមថា មហាសមយោ បវនស្មិំ ថ្ងៃនេះ ជាថ្ងៃប្រជុំធំ ក្នុងជងព្រៃធំ ។

មានសេចក្តីថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុសាសនេ សិក្ខាយ ន

បរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ

ម្នាលភទ្ទាលិ សូម្បីហេតុនេះឯង ជាហេតុដែលអ្នកមិនចាក់ធ្លុះ ហើយថា ព្រះមានព្រះភាគប្រថាប់នៅជិតនគរសាវត្ថី សូម្បីព្រះមានព្រះភាគគង់ជ្រាបអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ ជាអ្នកមិនធ្វើឲ្យបរិបូរណ៍ក្នុងសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះ ម្នាលភទ្ទាលិ ហេតុនេះឯង បានជាហេតុដែលអ្នកមិនចាក់ធ្លុះ ។

មានសេចក្តីថា **លទ្ធិ** ដូចក្នុងប្រយោគមានជាដើមថា តេន ខោ បន សមយេន ឧគ្គហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចិរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ ក៏សម័យនោះឯង បរិព្វាជកឈ្មោះ **ឧគ្គហមាន** បុត្តរបស់នាងសមណមុណ្ឌិកា អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់សិក្សានូវលទ្ធិ ។

មានសេចក្តីថា **បានចំពោះ** ដូចក្នុងប្រយោគមានជាដើមថា ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ប្រយោជន៍ណាក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ។

មានសេចក្តីថា **លះបង់** ដូចក្នុងប្រយោគមានជាដើមថា សម្មា

មានាភិសមយា អន្តមកាសិ ទុក្ខស្ស បានធ្វើទីបំផុតនៃទុក្ខ ព្រោះលះបង់មានះដោយល្អ ។

មានសេចក្តីថា **ចាក់ធ្លុះ** ដូចក្នុងប្រយោគមានជាដើមថា “ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ ទុក្ខសច្ច ដោយអត្ថថា បៀតបៀន តាក់តែង ដុតកោល ប្រែប្រួល ចាក់ធ្លុះ ។

ក៏ក្នុងព្រះសុត្តន្តបិដកនេះ **សមយ** សព្ទ មានសេចក្តីថា កាល ព្រោះហេតុនោះ ព្រះអានន្ទទើបសម្តែងថា សម័យមួយក្នុងបណ្តាសម័យទាំងឡាយ ដែលជាប្រភេទនៃកាលជាដើមថា ឆ្នាំ រដូវ ខែ កន្លះខែ ពេលយប់ ពេលថ្ងៃ ព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយរំពេច ។

ក្នុងពាក្យថា **សម័យមួយ** នោះ ក្នុងបណ្តាសម័យទាំងឡាយ មានឆ្នាំជាដើមទាំងនេះ ព្រះសូត្រណាៗ ដែលព្រះមានព្រះភាគត្រាស់ក្នុងឆ្នាំ ក្នុងរដូវ ក្នុងខែ ក្នុងបក្ខ ក្នុងកាលដែលជាចំណែកពេលយប់ ឬក្នុងកាលដែលជាចំណែកពេលថ្ងៃណាៗ ទាំងអស់នោះ ព្រះអានន្ទត្ថេរៈក៏ជ្រាបយ៉ាងល្អ គឺ កំណត់ទុកយ៉ាងល្អដោយបញ្ញា ក៏ពិតមែនហើយ តែលោកពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ក្នុងឆ្នាំឯណោះ រដូវឯណោះ ខែឯណោះ បក្ខឯណោះ កាលដែលជាចំណែកពេលយប់ឯណោះ ឬកាល

ដែលជាចំណែកពេលថ្ងៃឯណោះ ដូច្នេះ អ្នកណាៗ ក៏មិនអាចចាំបាន ឬសម្តែងបាន ឬឲ្យអ្នកដទៃសម្តែងបានដោយងាយ និងជារឿងដែលត្រូវពោលច្រើន ដូច្នោះ ព្រះអានន្ទត្ថេរៈ ទើបប្រមូលសេចក្តីនោះទុក ដោយបទតែមួយប៉ុណ្ណោះ ពោលថា **សម័យមួយ** ដូច្នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទរមែងសម្តែងថា សម័យរបស់ព្រះមានព្រះភាគ ជាសម័យកាល មិនមែនតិចតែម្យ៉ាង ដែលប្រាកដច្រើនណាស់ក្នុងពួកទេវតា និងមនុស្សទាំងឡាយជាដើម យ៉ាងនេះ គឺ សម័យស្តេចយាងចុះកាន់ព្រះគភ៌ សម័យប្រសូតិ សម័យទ្រង់សង្វេគព្រះទ័យ សម័យស្តេចចេញព្រះផ្នួស សម័យទ្រង់បំពេញទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យត្រាស់ដឹង សម័យប្រថាប់ជាសុខក្នុងទិដ្ឋធម៌ សម័យត្រាស់ទេសនា សម័យស្តេចបរិនិព្វាន ទាំងនេះណា ក្នុងបណ្តាសម័យទាំងនោះ សម័យមួយ គឺ សម័យត្រាស់ទេសនា ។

មួយទៀត ក្នុងបណ្តាសម័យនៃញាណកិច្ច និងករុណាកិច្ច សម័យនៃករុណាកិច្ចនេះណា ក្នុងបណ្តាសម័យទ្រង់បំពេញប្រយោជន៍របស់ព្រះអង្គ និងទ្រង់បំពេញប្រយោជន៍របស់អ្នកដទៃ សម័យទ្រង់បំពេញប្រយោជន៍របស់អ្នកដទៃនេះណា ក្នុងបណ្តាសម័យនៃករណីយ៍ទាំងពីរដល់អ្នកប្រជុំគ្នា សម័យត្រាស់ធម្មីកថានេះណា ក្នុងបណ្តាសម័យនៃទេសនា និងបដិបត្តិ , សម័យនៃទេសនានេះណា ព្រះអានន្ទពោលថា សម័យមួយ

ដូច្នេះ សំដៅដល់ សម័យណាសម័យមួយ ក្នុងបណ្ដាសម័យទាំងឡាយ សូម្បីទាំងនោះ ។

សួរថា ក៏ហេតុអ្វីក្នុងព្រះសូត្រនេះ ទើបលោកធ្វើនិទ្ទេសដោយទុតិយាវិភត្តិថា ឯកំ សមយំ មិនធ្វើដូចក្នុងព្រះអភិធម្ម ដែលលោកបានធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា យស្មិំ សមយេ កាមាវចរំ និងក្នុងសុត្តបទដទៃៗ ចាកព្រះអភិធម្មនេះ ក៏ធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា យស្មិំ សមយេ ភិក្ខវេ ភិក្ខុវិវិច្ចេវ កាមេហិ ចំណែកក្នុងព្រះវិន័យ លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិថា តេន សមយេន ពុទ្ធោ ភគវា ។

ឆ្លើយថា ព្រោះក្នុងព្រះអភិធម្ម និងព្រះវិន័យនោះ មានអត្ថយ៉ាងនោះ ចំណែកក្នុងព្រះសូត្រនេះ មានអត្ថជាយ៉ាងដទៃ ។ ពិតមែនបណ្ដាបិដកទាំង ៣ នោះ ក្នុងព្រះអភិធម្ម និងក្នុងសុត្តបទដទៃចាកព្រះអភិធម្មនេះ រមែងសម្រេចអត្ថនៃអធិករណៈ និងអត្ថនៃការកំណត់ភាវៈដោយភាវៈ ។ ក៏អធិករណៈ គឺ សម័យដែលមានកាលជាអត្ថ និងមានការប្រជុំជាអត្ថ និងភាវៈនៃធម៌មានផស្សៈជាដើម លោកកំណត់ដោយភាវៈនៃសម័យ ពោលគឺ ខណៈ សេចក្ដីព្រមព្រៀង និងហេតុនៃធម៌ មានផស្សៈជាដើម ដែលត្រាស់ទុកក្នុងព្រះអភិធម្ម និងសុត្តបទដទៃនោះៗ ព្រោះដូច្នោះ ដើម្បីបំភ្លឺអត្ថនោះ លោកទើបធ្វើនិទ្ទេសដោយសត្តមីវិភត្តិ ក្នុងព្រះអភិធម្ម និងក្នុងសុត្តបទដទៃនោះ ។ ចំណែកក្នុងព្រះវិន័យ រមែង

សម្រេចអត្ថនៃហេតុ និងអត្ថនៃករណៈ ។ ពិតមែន សម័យនៃការទ្រង់បញ្ញត្តិសិក្ខាបទនោះណា សូម្បីព្រះសាវក មានព្រះសារីបុត្រជាដើម ក៏ដឹងបានលំបាក ដោយសម័យនោះ ដែលជាហេតុ និងជាករណៈ ព្រះមានព្រះភាគកាលទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ និងទ្រង់ពិចារណា ដល់ហេតុនៃការទ្រង់បញ្ញត្តិសិក្ខាបទ បានប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះដើម្បីបំភ្លឺសេចក្តីនោះ លោកទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិក្នុងព្រះវិន័យនោះ ។ ចំណែកក្នុងព្រះសូត្រនេះ និងព្រះសូត្រដទៃដែលមានកំណើតយ៉ាងនេះ រមែងសម្រេចអត្ថនៃអច្ចន្តសំយោគៈ ។ ពិតមែន ព្រះមានព្រះភាគទ្រង់សម្តែងព្រះសូត្រនេះ ឬព្រះសូត្រដទៃ រហូតដល់អស់សម័យណា ស្តេចប្រថាប់នៅដោយធម៌ជាគ្រឿងនៅ គឺ ករុណា រហូតអស់សម័យនោះតែម្តង ព្រោះដូច្នោះ ដើម្បីបំភ្លឺសេចក្តីនោះ លោកទើបធ្វើនិទ្ទេសដោយទុតិយាវិភត្តិក្នុងព្រះសូត្រនេះ ។ ព្រោះហេតុនោះ លោកទើបពោលគាថាប្រព័ន្ធទុកដូច្នេះថា ៖

**លោកពិចារណាអត្ថនោះ ៗ ពោលសមយសព្ទ ក្នុងបិដកដទៃ ដោយសត្តមីវិភត្តិនិងដោយតតិយាវិភត្តិ តែក្នុងព្រះសុត្តន្តបិដកនេះ ពោលសមយសព្ទនោះ ដោយទុតិយាវិភត្តិ ។**

តែព្រះបោរាណាចារ្យទាំងឡាយ អធិប្បាយថា **សមយ** សព្ទនេះផ្សេងគ្នាត្រឹមតែវោហារថា **តស្មឹ** សមយេ ឬថា តេន សមយេន ឬថា តំ

សមយំ ប៉ុណ្ណោះ គ្រប់បិដកមានខ្លឹមសារជាសត្តមីវិភត្តិតែម្យ៉ាង ព្រោះដូច្នោះ ដល់លោកពោលថា ឯកំ សមយំ ក៏គប្បីជ្រាបសេចក្តី ថា ឯកស្មឹ សមយេ ក្នុងសម័យមួយ ។

## ពន្យល់អត្ថនៃបទថា ភគវា

បទថា ភគវា ប្រែថា គ្រូ ។ ពិតមែន បណ្ឌិតទាំងឡាយ ហៅគ្រូថា ភគវា ក្នុងលោក ។ និងព្រះមានព្រះភាគនេះ ក៏ទ្រង់ជាគ្រូរបស់សព្វសត្វទាំងឡាយ ព្រោះទ្រង់ជាអ្នកប្រសើរជាទីបំផុតដោយគុណទាំងពួង ដូច្នោះ គប្បីជ្រាបថា ទ្រង់ជា ភគវា សូម្បីព្រះបោរាណាចារ្យទាំងឡាយក៏ពោលទុកថា ៖

> ពាក្យថា ភគវា ជាពាក្យប្រសើរបំផុត ពាក្យថា ភគវា ជាពាក្យខ្ពស់បំផុត ព្រោះព្រះមានព្រះភាគទ្រង់គួរដល់ការគោរព ដោយឋានៈជាគ្រូ ដូច្នោះ ទើបទ្រង់ព្រះនាមថា ភគវា ។

> ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់មានជោគ ទ្រង់កាច់បំបាក់កិលេស ទ្រង់ប្រកបដោយភគធម៌ ទ្រង់ចែកនូវធម៌ ទ្រង់សេពគប់ធម៌ និងទ្រង់ខ្ជាក់កិលេសជាគ្រឿងទៅកាន់ភពទាំងឡាយបានហើយ ហេតុនោះ ទើបទ្រង់ព្រះនាមថា

*ភគវា ។*

*បទថា ភគវា នេះ មានសេចក្តីដែលគួរជ្រាបដោយពិស្តារ ដោយអំណាចនៃគាថានេះ និងសេចក្តីនោះ ខ្ញុំម្ចាស់បានពោលទុកហើយក្នុងនិទ្ទេស នៃពុទ្ធានុស្សតិក្នុងគម្ពីរវិសុទ្ធិមគ្គ ។*

## ពន្យល់អត្ថនៃបទ ឯវម្មេ សុតំ ឯកំ សមយំ ភគវា

*ក៏ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ក្នុងបណ្តាពាក្យទាំងនេះ ដោយពាក្យថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ព្រះអានន្ទ កាលសម្តែងធម៌តាមដែលបានស្តាប់មក ឈ្មោះថា រមែងធ្វើព្រះធម្មកាយរបស់ព្រះមានព្រះភាគឲ្យប្រចក្ស ។*

*ដោយពាក្យនោះ លោករមែងញុំាងប្រជាជនអ្នកខ្វល់ខ្វាយ ព្រោះមិនបានឃើញព្រះសាស្តាឲ្យស្រោលចិត្តថា បាវចនៈ គឺ ព្រះធម៌វិន័យនេះ មានព្រះសាស្តាកន្លងទៅហើយក៏ទេ ព្រះធម្មកាយនេះ ជាព្រះសាស្តារបស់អ្នកទាំងឡាយ ដូច្នេះ ។*

*ដោយពាក្យថា* ***សម័យមួយ ព្រះមានព្រះភាគ*** *ដូច្នេះ ព្រះអានន្ទកាលសម្តែងថា ព្រះមានព្រះភាគ មាននៅក្នុងសម័យនោះ ឈ្មោះថា រមែងប្រកាស កាលស្តេចបរិនិព្វាននៃព្រះរូបកាយ ។ ដោយពាក្យនោះ*

ព្រះអានន្ទ រមែងញ៉ាំងប្រជាជនអ្នកស្រវឹងក្នុងជីវិតឲ្យសង្វេគ និងញ៉ាំងឧស្សាហ៍ក្នុងព្រះសទ្ធម្មឲ្យកើតដល់ប្រជាជននោះថា សូម្បីព្រះមានព្រះ-ភាគអង្គនោះ អ្នកមានព្រះវរកាយស្មើដោយពេជ្រ ទ្រទ្រង់ទុកនូវកម្លាំង ១០ ទ្រង់សម្ដែងអរិយធម៌ឈ្មោះយ៉ាងនេះ នៅតែស្ដេចបរិនិព្វាន អ្នកដទៃណាហ្ន៎ នឹងគប្បីញ៉ាំងសេចក្ដីប្រាថ្នាក្នុងជីវិតឲ្យតាំងនៅបាន ។

មួយវិញទៀត ព្រះអានន្ទ កាលពោលថាយ៉ាងនេះ ឈ្មោះថារមែងសម្ដែងនូវទេសនាសម្បត្តិ កាលពោលថា ខ្ញុំបានស្ដាប់មក ឈ្មោះថា រមែងសម្ដែងសាវកសម្បត្តិ កាលពោលថា សម័យមួយ ឈ្មោះថារមែងសម្ដែងកាលសម្បត្តិ កាលពោលថា ព្រះមានព្រះភាគ ឈ្មោះថារមែងសម្ដែងទេសកសម្បត្តិ ។

## ពន្យល់អត្ថនៃពាក្យ អន្តរា ច រាជគហំ អន្តរា ច នាលន្ទំ

អន្តរា សព្ទ ក្នុងពាក្យថា អន្តរា ច រាជគហំ អន្តរា ច នាលន្ទំ ក្នុងចន្លោះក្រុងរាជគ្រឹះ និងនាឡន្ទាគ្រាម ប្រព្រឹត្តទៅក្នុងសេចក្ដីថា ហេតុ ខណៈ ចិត្ត កណ្ដាល និងចន្លោះជាដើម ។

អន្តរា សព្ទ ប្រព្រឹត្តទៅក្នុងសេចក្ដីថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា តទន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតា នរណានឹងដឹងហេតុនោះ ក្រៅពីតថាគត និងថា ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច

កិមន្តរំ ហេតុអ្វី ជនទាំងឡាយមកប្រជុំប្រឹក្សាជាមួយនឹងខ្ញុំ ហើយនឹងលោក ។

ក្នុងសេចក្ដីថា **ខណៈ** ដូចក្នុងប្រយោគជាដើមថា អទ្ទស មំ ភន្តេអន្តរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តី បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់លាងភាជនៈ បានឃើញខ្ញុំព្រះអង្គ ក្នុងពេលមានផ្លេកបន្ទោរ ។

ក្នុងសេចក្ដីថា **ចិត្ត** ដូចក្នុងប្រយោគជាដើមថា យស្សន្តរតោ ន សន្តិ កោបា ការកម្រើក មិនមានក្នុងចិត្តរបស់បុគ្គលណា ។

ក្នុងសេចក្ដីថា **ពាក់កណ្ដាល** ដូចក្នុងប្រយោគជាដើមថា អន្តរាវោសានមាបាទិ ដល់ទីបំផុតក្នុងពាក់កណ្ដាល ។

ក្នុងសេចក្ដីថា **ចន្លោះ** ដូចក្នុងប្រយោគជាដើមថា អបិចាយំ តបោទាកុិន្នំ មហានិរយានំ អន្តរិកាយាគច្ឆន្តិ មួ៉ាងវិញទៀត អណ្ដូងទឹកក្ដៅ ឈ្មោះតបោទានេះ ហូរមកតាមចន្លោះនៃមហានរកទាំងពីរ ។

អន្តរ សព្ទនេះ ក្នុងទីនេះប្រព្រឹត្តទៅក្នុងសេចក្ដីថា **ចន្លោះ** ។ ព្រោះដូច្នោះ ក្នុងទីនេះគប្បីឃើញសេចក្ដីយ៉ាងនេះថា ក្នុងចន្លោះនៃក្រុងរាជគ្រឹះ និងនាលន្ទា ។ តែព្រោះលោកប្រកបដោយ អន្តរ សព្ទ លោកទើបធ្វើជាទុតិយាវិភត្តិ ។ ក៏ក្នុងឋានៈដូច្នេះ អ្នកអក្សរសាស្ត្រទាំងឡាយប្រើ អន្តរា សព្ទ តែមួយប៉ុណ្ណោះ យ៉ាងនេះថា អន្តរា គាមញ្ច នទិញ្ច យាតិ ទៅចន្លោះស្រុក និងស្ទឹង ។ អន្តរា សព្ទ នោះ

គួរប្រើក្នុងបទទីពីរផង កាលបើមិនប្រើ រមែងមិនមែនជាទុតិយាវិភត្តិ ។ តែក្នុងទីនេះ លោកប្រើហើយ ទើបពោលទុកយ៉ាងនេះឯង ។

## ពន្យល់អត្ថនៃបទ អទ្ធានមគ្គប្បដិបន្នោ ហោតិ ជាដើម

បទថា អទ្ធានមគ្គប្បដិបន្នោ ហោតិ សេចក្តីថា ទ្រង់ធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយ អធិប្បាយថា ផ្លូវវែង ។ ពិតមែន សូម្បីកន្លះយោជន៍ក៏ឈ្មោះថា ផ្លូវឆ្ងាយ ដោយព្រះបាលីក្នុងវិភង្គ នៃសម័យដើរផ្លូវឆ្ងាយមានជាដើមថា គប្បីបរិភោគដោយគិតថា យើងនឹងដើរផ្លូវកន្លះយោជន៍ ។ ក៏ចេញចាកក្រុងរាជគ្រឹះ ដល់ក្រុងនាលន្ទា ប្រមាណមួយយោជន៍ ។

បទថា **ធំ** ក្នុងពាក្យថា ជាមួយនឹងពួកភិក្ខុសង្ឃដ៏ធំ សេចក្តីថា ធំដោយគុណទាំងដោយចំនួន ។ ពិតមែន ភិក្ខុសង្ឃនោះ ឈ្មោះថា ធំដោយគុណ ព្រោះប្រកបដោយគុណធម៌ ជាអ្នកមានសេចក្តីប្រាថ្នាតិចជាដើម , ឈ្មោះថា ធំដោយចំនួន ព្រោះមានចំនួន ៥០០ ។ ពួកនៃភិក្ខុទាំងឡាយ ឈ្មោះថា **ភិក្ខុសង្ឃ** ដោយភិក្ខុសង្ឃនោះ អធិប្បាយថា ដោយពួកសមណៈ ពោលគឺ ជាពួកដែលមានការស្មើគ្នា ដោយទិដ្ឋិ និងសីល ។

បទថា **ជាមួយ** គឺ ដោយភាពជាមួយគ្នា ។

បទថា **ភិក្ខុប្រមាណ ៥០០ រូប** មានវិគ្រោះថា ប្រមាណរបស់

ភិក្ខុទាំងនោះ ៥ ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបឈ្មោះថា មានប្រមាណ ៥ ។ ប្រមាណ លោកហៅថា **មត្ត** ។ ព្រោះដូច្នោះ កាលពោលថា អ្នកស្គាល់ប្រមាណក្នុងភោជន ក៏មានសេចក្តីថា ស្គាល់ប្រមាណ គឺ ស្គាល់កម្រិតក្នុងការបរិភោគ យ៉ាងណា សូម្បីក្នុងបទថា មានប្រមាណ ៥ នេះ ក៏គប្បីឃើញសេចក្តីយ៉ាងនេះថា ប្រមាណ ៥ គឺ កម្រិត ៥ របស់ភិក្ខុចំនួនរយទាំងនោះ ។ រយរបស់ភិក្ខុទាំងឡាយ ឈ្មោះថា មួយរយ ។ ដោយភិក្ខុប្រមាណ ៥០០ ទាំងនោះ ។

បទថា **សុប្បិយ** ក្នុងពាក្យថា សូម្បីសុប្បិយបរិព្វាជកនោះឯង ជាឈ្មោះរបស់បរិព្វាជកនោះ ។ ចិ អក្សរ មានសេចក្តីប្រមូលបុគ្គល ព្រោះជាសម្មាញ់ដើរផ្លូវ ។ ១។ អក្សរ ជាពាក្យតបទ លោកពោលដោយអំណាចសេចក្តីល្អស្អាតនៃព្យញ្ជនៈ ។ ពាក្យថា បរិព្វាជក បានដល់បរិព្វាជកស្លៀកសំពត់ ជាសិស្សរបស់សញ្ជ័យ ។ អធិប្បាយថា ព្រះមានព្រះភាគស្តេចដំណើរផ្លូវឆ្ងាយនោះ ក្នុងកាលណា សូម្បីសុប្បិយបរិព្វាជក ក៏បានធ្វើដំណើរក្នុងកាលនោះ ។ ក៏ ហោតិ សទ្ទ ក្នុងព្រះបាលីនេះ មានអត្ថជាអតីតកាល ។

ក្នុងពាក្យថា ជាមួយនឹងព្រហ្មទត្តមាណព ដែលជាកូនសិស្សដែរនេះ មានវិគ្គហៈដូច្នេះ ឈ្មោះថា អន្តេវាសី ព្រោះអត្ថថា នៅខាងក្នុង ។ អធិប្បាយថា ត្រាច់ទៅក្នុងទីជិត ត្រាច់ទៅក្នុងសម្នាក់ បានដល់ ជាសិស្ស ។

ពាក្យថា ព្រហ្មទត្តោ ព្រហ្មទត្ត ជាឈ្មោះរបស់សិស្សនោះ ។

ពាក្យថា **មាណព** លោកហៅសត្វខ្លះ ចោរខ្លះ ក្មេងប្រុសជំទង់ខ្លះ ។

ពិតមែន **សត្វ** ហៅថា មាណព ដូចក្នុងប្រយោគមានជាដើម ថា មាណពទាំងឡាយណា ត្រូវទេវទូតដាស់តឿនហើយ ក៏នៅតែប្រមាទ មាណពទាំងនោះ ជាអ្នកចូលដល់ទីថោកទាប រមែងសោកសៅ អស់កាលយូរ ។

**ចោរ** ហៅថា មាណព ដូចក្នុងប្រយោគមានជាដើមថា សមាគម ជាមួយពួកមាណពអ្នកធ្វើកម្មខ្លះ មិនបានកម្មខ្លះ ។

**ក្មេងប្រុសជំទង់** ហៅថា មាណព ដូចក្នុងប្រយោគជាដើមថា អម្ពដ្ឋមាណព មណ្ឌព្យមាណព ។ សូម្បីក្នុងព្រះបាលីនេះ ក៏មានសេចក្តីយ៉ាងនេះដូចគ្នា ។

អធិប្បាយថា ជាមួយព្រហ្មទត្តជាសិស្សកម្លោះ ។

បទថា តត្រ ប្រែថា ក្នុងផ្លូវឆ្ងាយនោះ ឬក្នុងអ្នក ២ នាក់នោះ ។

បទថា សុទំ ត្រឹមតែជានិបាត ។

**បរិយាយ** សព្ទ ក្នុងបទថា ដោយអនេកបរិយាយ ប្រព្រឹត្តទៅក្នុងអត្ថថា វារៈ ទេសនា និងហេតុ ប៉ុណ្ណោះ ។

**បរិយាយ** សព្ទ ប្រព្រឹត្តទៅក្នុងអត្ថថា វារៈ ដូចក្នុងប្រយោគជាដើមថា កស្ស នុ ខោ អានន្ទ អជ្ជ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ

ម្នាលអានន្ទ ថ្ងៃនេះជាវារៈរបស់អ្នកណាហ្ន៎ ដែលនឹងឲ្យឱវាទពួកភិក្ខុនី ទាំងឡាយ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ទេសនា** ដូចក្នុងប្រយោគជាដើមថា មធុ-បិណ្ឌិកបរិយាយោតិ នំ ធារេហិ ចូរអ្នកចាំទុកនូវធម៌នោះថា ជាមធុបិណ្ឌិកទេសនា ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ហេតុ** ដូចក្នុងប្រយោគជាដើមថា ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ម្នាលរាជញ្ញៈ ដោយហេតុសូម្បីនេះរបស់លោក ទើបត្រូវជាយ៉ាងនោះ ។

សូម្បីក្នុងព្រះបាលីនេះ **បរិយាយ** ស័ព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា ហេតុដូច្នោះ សេចក្តីក្នុងព្រះបាលីនេះដូច្នេះថា ដោយហេតុច្រើនយ៉ាង អធិប្បាយថា ដោយហេតុជាច្រើន ។

បទថា សុប្បិយបរិព្វាជកពោលតិះដៀលព្រះពុទ្ធ សេចក្តីថា ពោលតិះដៀល គឺ ពោលទោស ពោលតិះដៀល ព្រះមានព្រះភាគជាម្ចាស់អ្នកវៀរចាកទោស ដែលមិនគួរសរសើរ អ្នកសូម្បីប្រកបដោយគុណដែលគួរសរសើររកប្រមាណមិនបាន យ៉ាងនោះៗ ដោយពោលហេតុដែលមិនសមគួរនោះ នុ៎ះឯងថា ជាហេតុយ៉ាងនេះថា ព្រះសមណគោតមជាមនុស្សឥតរសជាតិ ព្រោះហេតុដែលព្រះសមណគោតមមិនមានការធ្វើសាមីចិកម្ម មានការក្រាបថ្វាយបង្គំជាដើម ដែលគួរធ្វើក្នុងមនុស្សចាស់

ដែលចម្រើនដោយជាតិក្នុងលោក ដែលហៅថា សាមគ្គីរស , ព្រះសមណ-គោតមជាអ្នកមិនមានភោគៈ , ព្រះសមណគោតមជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ , ព្រះសមណគោតមជាអ្នកពោលពាក្យដាច់សូន្យ , ព្រះសមណគោតមជាអ្នកខ្ពើមរអើម , ព្រះសមណគោតមជាអ្នកបំផ្លាញ , ព្រះសមណគោតមជាអ្នកដុតកំដៅ , ព្រះសមណគោតមជាមនុស្សឥតកំណើត , ព្រះសមណគោតមមិនមានធម៌ដ៏ក្រៃលែងរបស់មនុស្ស ដែលជាញាណ និងទស្សនៈដ៏វិសេសដែលគួរដល់ព្រះអរិយជាម្ចាស់ ព្រះសមណ-គោតមសម្ដែងធម៌ដែលត្រិះរិះដោយខ្លួនឯង ដែលពិចារណាខ្លួនឯង ដែលដឹងដោយខ្លួនឯង ។ ព្រះសមណគោតមមិនមែនជាសព្វញ្ញូ មិនមែនលោកវិទូ មិនមែនបុគ្គលដ៏កំពូល មិនមែនជាអគ្គបុគ្គល ដូច្នេះ និងពោលហេតុដែលមិនគួរនោះៗ ឯងថា ជាហេតុ , ពោលទោសព្រះធម៌ដូចជាពោលទោសព្រះពុទ្ធ ដោយប្រការនោះៗ ថា ធម៌របស់ព្រះសមណ-គោតមពោលទុកអាក្រក់ ដឹងបានលំបាក មិនមែនជាធម៌ដែលនាំចេញចាកទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ និងពោលហេតុដែលមិនសមគួរ មិនពោលយ៉ាងណាមួយនុ៎ះឯង ថាជាហេតុ , ពោលទោសព្រះសង្ឃ ដូចពោលទោសព្រះធម៌ ដោយប្រការនោះៗ ថា ព្រះសង្ឃសាវករបស់ព្រះសមណគោតម បដិបត្តិខុស បដិបត្តិកោងកាច បដិបត្តិបដិបទាដែលទាស់ បដិបទាដែលទទឹងទទែង បដិបទាដែលមិនជាធម៌

សមគួរដល់ធម៌ ដូច្នេះ ដោយអនេកបរិយាយ ។

ចំណែកព្រហ្មទត្តមាណព សិស្សរបស់សុប្បិយបរិព្វាជកនោះ លេចគំនិតឡើងដោយឧបាយនៃប្រាជ្ញាយ៉ាងនេះថា អាចារ្យរបស់ពួកយើងពាល់ត្រូវវត្ថុដែលមិនគួរពាល់ត្រូវ ជាន់វត្ថុដែលមិនគួរជាន់ អាចារ្យរបស់ពួកយើងនេះ ពោលតិះដៀលព្រះរតនត្រ័យ ដែលគួរសរសើរប៉ុណ្ណោះ នឹងដល់សេចក្តីវិនាសអន្តរាយ ដូចមនុស្សលេបភ្លើង ដូចមនុស្សយកដៃស្ទាបមុខដាវ ដូចមនុស្សយកកែងដៃទម្លាយភ្នំសិនេរុ ដូចមនុស្សលេងធ្មេញរណា និងដូចអ្នកយកដៃចាប់ដំរីចុះប្រេង ក៏កាលអាចារ្យជាន់លាមកឬភ្លើង ឬបន្លា ឬពស់វែកក្តី ឡើងជាន់លំពែងក្តី ផឹកថ្នាំពិសដ៏សាហាវក្តី ផឹកទឹកក្រុតក្តី ហោតទម្លាក់ជ្រោះជ្រៅក្តី មិនមែនសិស្សនឹងត្រូវធ្វើតាមគ្រប់យ៉ាងនោះទេ ព្រោះថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន រមែងទៅកាន់គតិតាមគួរដល់កម្មរបស់ខ្លួនពិតប្រាកដ មិនមែនបិតានឹងទៅដោយកម្មរបស់បុត្រ មិនមែនបុត្រនឹងទៅដោយកម្មរបស់បិតា មិនមែនមាតានឹងទៅដោយកម្មរបស់បុត្រ មិនមែនបុត្រនឹងទៅដោយកម្មរបស់មាតា មិនមែនបងប្រុសនឹងទៅដោយកម្មរបស់ប្អូនស្រី មិនមែនប្អូនស្រីនឹងទៅដោយកម្មរបស់បងប្រុស មិនមែនអាចារ្យនឹងទៅដោយកម្មរបស់សិស្ស មិនមែនសិស្សនឹងទៅដោយកម្មរបស់អាចារ្យ ក៏អាចារ្យរបស់ពួកយើងពោលតិះដៀលព្រះរតនត្រ័យ និងការជេរព្រះអរិយៈក៏មានទោសច្រើនពិតៗ ដូច្នេះ កាល

នឹងញាំញីវាទៈរបស់អាចារ្យ អាងហេតុផលសមគួរ ផ្ដើមពោលសរសើរព្រះរតនត្រ័យដោយអនេកបរិយាយទាំងនេះ ព្រោះព្រហ្មទត្តមាណពជាកុលបុត្រមានជាតិជាបណ្ឌិត ដោយហេតុនោះ ព្រះអានន្ទទើបពោលថា ឯព្រហ្មទត្តមាណព ជាកូនសិស្សរបស់សុប្បិយបរិព្វាជក ក៏ពោលសរ-សើរព្រះពុទ្ធ ពោលសរសើរព្រះធម៌ ពោលសរសើរព្រះសង្ឃ ដោយអនេកបរិយាយវិញ" ។

## អធិប្បាយ វណ្ណ សព្ទ

ក្នុងសព្ទទាំងនោះ សព្ទថា វណ្ណ ក្នុងបទថា វណ្ណោ រមែងប្រាកដក្នុងសេចក្ដីថា សណ្ឋាន ជាតិ រូបាយតនៈ ការណៈ បមាណៈ គុណៈ និងបសង្សា ។

ក្នុងបណ្ដាសេចក្ដីទាំងនោះ **សណ្ឋាន** ហៅថា វណ្ណ ដូចក្នុងប្រយោគជាដើមថា មហន្តំ សប្បរាជវណ្ណំ អភិនិម្មិនិត្វា និម្មិតទ្រង់ទ្រាយជាស្ដេចពស់ធំ ។

**ជាតិ** ហៅថា វណ្ណ ដូចក្នុងប្រយោគជាដើមថា ព្រាហ្មណាវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ពួកព្រាហ្មណ៍ប៉ុណ្ណោះ មានជាតិប្រសើរ ជាតិដទៃថោកទាប ។

**រូបាយតន** ហៅថា វណ្ណ ដូចក្នុងប្រយោគមានជាដើមថា បរមាយ

វណ្ណទោក្ខរតាយ សមន្នាគតា ប្រកបដោយភាពស្អាតនៃ រូបាយតនៈ យ៉ាងក្រៃលែង ។

**ហេតុ** ហៅថា វណ្ណ ដូចក្នុងគាថាជាដើមថា ៖

ន ហរាមិ ន ភញ្ជាមិ អារា សិង្ឃាមិ វារិជំ
អថ កេន នុ វណ្ណេន គន្ធត្ថេនោតិ វុច្ចតិ

អាត្មាមិនបានលួច មិនបានកាច់ទេ គ្រាន់តែបានហិតក្លិន
ផ្កាឈូក អំពីចម្ងាយទេតើ ចុះហេតុដូចម្ដេចបានជាអ្នក
និយាយថា អាត្មាលួចក្លិន ។

**បមាណ** ហៅថា វណ្ណ ដូចក្នុងប្រយោគជាដើមថា តយោ បត្តស្ស វណ្ណា ខ្នាតនៃបាត្រ មាន ៣ យ៉ាង ។

**គុណ** ហៅថា វណ្ណ ដូចក្នុងប្រយោគមានជាដើមថា កទា សំញ្ញុឡ្ហា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា ម្នាលគហបតី លោកប្រមូលគុណរបស់ព្រះសមណគោតមទាំងនេះ ទុកពីកាលណា ។

**សរសើរ** ហៅថា វណ្ណ ដូចក្នុងប្រយោគមានជាដើមថា វណ្ណា-រហស្ស វណ្ណំ ភាសតិ ពោលសរសើរបុគ្គលដែលគួរសរសើរ ។

ក្នុងព្រះបាលីនេះ វណ្ណ សំដៅដល់ ទាំងគុណ ទាំងសរសើរ ។

បានឮថា ព្រហ្មទត្តមាណពនេះ បានអាងហេតុដែលមានពិតនោះៗ

ពោលសរសើរ ប្រកបដោយគុណនៃព្រះរតនត្រ័យ ដោយអនេកបរិយាយ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបគុណរបស់ព្រះពុទ្ធ ដោយន័យជាដើមថា សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះអរហន្តជាព្រះសម្មាសម្ពុទ្ធ ។

មានជាដើមថា ម្នាលភិក្ខុទាំងឡាយ ពួកជនណាជ្រះថ្លាក្នុងព្រះពុទ្ធពួកជនទាំងនោះ ឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ។

និងមានជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក មិនមានអ្នកស្មើ និងបុគ្គលដែលមិនមានអ្នកស្មើ កាលកើតឡើងរមែងកើតឡើងក្នុងលោក ដូច្នេះ ។

គប្បីជ្រាបគុណរបស់ព្រះធម៌ ដោយន័យមានជាដើមយ៉ាងនេះថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អថា ព្រះធម៌ដកនូវសេចក្តីអាល័យ ជាធម៌ផ្តាច់បង់នូវវដ្ដៈ និងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជនពួកណាជ្រះថ្លាក្នុងអរិយ-មគ្គប្រកបដោយអង្គ ៨ ជនពួកនោះ ឈ្មោះថា ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ។

មួយទៀត គប្បីជ្រាបគុណរបស់ព្រះសង្ឃ ដោយន័យមានជាដើមយ៉ាងនេះថា សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគ ប្រតិបត្តិល្អហើយ និងត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ ជនពួកណាជ្រះថ្លាក្នុងព្រះសង្ឃ ជនពួកនោះឈ្មោះថា ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ដូច្នេះ ។

ក៏ព្រះធម្មកថិក អ្នកអាចគប្បីប្រមូលនវង្គសត្ថុសាសន៍ ក្នុងនិកាយទាំង ៥ ចូលកាន់ព្រះធម្មក្ខន្ធ ៨៤.០០០ ប្រកាសគុណរបស់ព្រះរតន-ត្រ័យ មានព្រះពុទ្ធជាដើម ។ ព្រហ្មទត្តមាណព កាលប្រកាសគុណរបស់ព្រះពុទ្ធជាដើមក្នុងឋានៈនេះ នរណាៗ ក៏មិនអាចនឹងពោលថា ជាព្រះធម្មកថិកត្រាប់ទៅខុសកំពង់ ។

មយ៉ាងទៀត គប្បីជ្រាបកម្លាំងការអាចរបស់ព្រះធម្មកថិកក្នុងឋានៈដូច្នេះ ។ ចំណែកព្រហ្មទត្តមាណព ពោលសរសើរព្រះរតនត្រ័យ ដោយកម្លាំងសមត្ថភាពរបស់ខ្លួនដែលក៏ពូនឡើង ដោយត្រឹមតែដំណឹងដែលស្តាប់មកជាដើម ។

ពាក្យថា ឥតិហ តេ ឧភោ អាចរិយន្តេវាសី សេចក្តីថា ដោយប្រការដូច្នេះ អាចារ្យ និងសិស្សទាំងពីរនោះ ។ បទថា អញ្ញមញ្ញស្ស កាត់បទជា អញ្ញោ អញ្ញស្ស សេចក្តីថា បុគ្គលម្នាក់ ជាសត្រូវដល់បុគ្គលម្នាក់ទៀត ។

បទថា ឧជុវិបច្ចនិកវាទា សេចក្តីថា មានវាទៈជាសត្រូវច្រើនយ៉ាងដោយត្រង់ មិនបានចៀសវាងគ្នាសូម្បីតែបន្តិច អធិប្បាយថា មានវាទៈខុសប្លែកគ្នាច្រើនវារៈ ព្រោះថា កាលអាចារ្យពោលតិះដៀលព្រះរតនត្រ័យ

សិស្សពោលសរសើរ គឺ បុគ្គលម្នាក់ពោលតិះដៀល បុគ្គលម្នាក់ទៀតពោលសរសើរ ដោយទំនងនេះឯង ។ អាចារ្យពោលតិះដៀលព្រះរតនត្រ័យរឿយៗ យ៉ាងនេះ ដូចដំស្មៀតឈើសាច់ទន់ ចុះលើបន្ទះឈើសាច់រឹង ។ ចំណែកសិស្សពោលសរសើរព្រះរតនត្រ័យរឿយៗ ដូចយកស្មៀតដែលធ្វើដោយមាសប្រាក់ និងកែវមណី ការពារស្មៀតនោះ ។ ដោយហេតុនោះព្រះអានន្ទ ទើបពោលថា ពោលពាក្យជាសត្រូវដោយត្រង់ ដូច្នេះ ។

ពាក្យថា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ ភិក្ខុសង្ឃញ្ច សេចក្តីថា ជាអ្នកជាប់តាមទៅ ខាងក្រោយៗ ល្មមមើល ឃើញព្រះមានព្រះភាគ និងភិក្ខុសង្ឃ ដោយការជាប់តាមឥរិយាបថ អធិប្បាយថា នៅសម្លឹងមើលសីសៈតាមទៅ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបស្តេចដំណើរផ្លូវឆ្ងាយ ? ព្រោះហេតុអ្វី សុប្បិយបរិព្វាជកទើបជាប់តាមទៅ ? និងព្រោះហេតុអ្វីគាត់ទើបពោលតិះដៀលព្រះរតនត្រ័យ ?

ឆ្លើយថា ដើមដំបូង ព្រះមានព្រះភាគប្រថាប់នៅក្នុងមហាវិហារមួយកន្លែង ក្នុងបណ្តាមហាវិហារ ១៨ កន្លែង ដែលនៅវៀងគ្នាជុំវិញក្រុងរាជគ្រឹះ ក្នុងកាលនោះ វេលាព្រឹកព្រលឹម ទ្រង់បដិបត្តិព្រះពុទ្ធសរីរៈ ដល់វេលាភិក្ខាចារ មានភិក្ខុសង្ឃហែហមស្តេចត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ថ្ងៃនោះ ព្រះអង្គទ្រង់ធ្វើឲ្យភិក្ខុសង្ឃរកបិណ្ឌបាតបានងាយ

ក្នុងវេលាខាងក្រោយអាហារ ស្ដេចត្រឡប់អំពីបិណ្ឌបាតហើយ ឲ្យភិក្ខុសង្ឃទទួលបាត្រ និងចីវរ មានព្រះពុទ្ធតម្រាស់ថា នឹងទៅស្រុកនាលន្ទា ស្ដេចចេញចាកក្រុងរាជគ្រឹះ ស្ដេចដំណើរផ្លូវឆ្ងាយនោះ ។

ក្នុងកាលនោះ សុប្បិយបរិព្វាជក ក៏នៅក្នុងអារាមបរិព្វាជកមួយកន្លែង ដែលនៅរៀងគ្នា ជុំវិញក្រុងរាជគ្រឹះ មានបរិព្វាជកហែហមគ្រាប់ភិក្ខាចារក្នុងក្រុងរាជគ្រឹះ ថ្ងៃនោះ សុប្បិយបរិព្វាជក ក៏ធ្វើឲ្យបរិស័ទបរិព្វាជករកភិក្ខាបានងាយ បរិភោគអាហារព្រឹកហើយ ឲ្យពួកបរិព្វាជកទទួលបរិក្ខារនៃបរិព្វាជកពោលថា នឹងទៅក្រុងនាលន្ទា ដូចគ្នាមិនជ្រាបឡើយថា ព្រះមានព្រះភាគស្ដេចទៅផ្លូវនោះ , ឈ្មោះថា ជាប់តាមទៅ បើជ្រាបក៏មិនជាប់តាមទៅ ។ សុប្បិយបរិព្វាជកនោះមិនជ្រាបឡើយ កាលដើរទៅ អើតកឡើងមើល ទើបឃើញព្រះមានព្រះភាគល្អដោយព្រះពុទ្ធសិរី ដូចជាកំពូលភ្នំមាសដើរបាន ដែលរុំព័ទ្ធដោយសំពត់កម្ពលក្រហម ។

បានឮថា ក្នុងសម័យនោះ ព្រះឆព្វណ្ណរង្សីផ្សាយចេញចាកព្រះសរីរៈរបស់ព្រះទសពល វិលជុំវិញសរីរៈប្រទេសមានប្រមាណ ៨០ ហត្ថ ។ បរិវេណព្រៃនោះ រមែងពាសពេញទៅដោយចង្កោមរតនៈ ក្រួងរតនៈ និងកម្រួបផងរតនៈ ដូចផែនមាសដែលវិចិត្រដោយរតនៈដែលផ្សាយចេញ ដូចប្រោះព្រំដោយទឹកមាសពណ៌ក្រហមឆ្អិនឆ្អៅ ដូចពាសពេញដោយពពួក

ផ្កាយធ្លាក់ចុះ ដូចផង់ធូលីដែលហុយឡើងដោយ កម្លាំងព្យុះ និងដូចថែងចាំង ធ្លៀលធ្វាត់ដោយពន្លឺរស្មីនៃផ្លេកបន្ទោរ រន្ទះ និងពួកតារាក៏ដូចគ្នា ។

ក៏ឯព្រះសរីរៈរបស់ព្រះមានព្រះភាគ រុងរឿងដោយអនុព្យញ្ជនៈ ៨០ ដូចជាស្រះដែលមានផ្កាឈូកធំ និងឈូកសរីកខ្វាយ ដូចដើមបារិ-ឆត្តកចេញផ្ការីកស្គុះស្គាយទៅទាំងដើម ដូចជាសើចចំអកឲ្យផ្ទៃមេឃ ដូចជាបែកចេញដោយរស្មីតារា ដោយព្រះសិរី មួយ ទៀត កម្រងផ្កា គឺព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ របស់ព្រះអង្គ ដែលល្អវិសាលដោយព្រះរស្មីប្រមាណមួយព្យាម ក៏ដូចយកព្រះសិរីមកគ្របសង្កត់ នូវព្រះសិរីនៃស្តេចចក្រពត្តិ ៣២ ព្រះអង្គ ទេវរាជ ៣២ ព្រះអង្គ និងមហាព្រហ្ម ៣២ ព្រះអង្គ ដែលដាក់ទុក តាំងទុកតាមលំដាប់ នៃក្លួងកម្រងផ្កា គឺ ព្រះចន្ទ ៣២ ដួង ក្លួងកម្រងផ្កា គឺ ព្រះអាទិត្យ ៣២ ដួង ដែលក្រងហើយ ។

ក៏ឯភិក្ខុទាំងឡាយ ដែលឈរហែហមព្រះមានព្រះភាគអង្គនោះ ទាំងអស់សុទ្ធតែជាអ្នកប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ មិនច្រឡូកច្របល់គ្នា ដាស់តឿនគ្នា តិះដៀលបាប ប្រៀនប្រដៅគ្នា អ្នកពេញចិត្តធ្វើតាមអត់ធន់នឹងពាក្យប្រៀនប្រដៅ ប្រកបដោយសីល ប្រកបដោយសមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈ ។ ក្នុងកណ្តាលភិក្ខុទាំងនោះ

ព្រះមានព្រះភាគប្រៀបដូចសសរមាស លោមព័ទ្ធដោយកំពែង គឺ សំពត់កម្ពលក្រហម ដូចទូកមាសនៅកណ្តាលព្រៃឈូកក្រហម ដូចគំនរភ្លើងដែលវង់ជុំវិញដោយជុំកែវប្រវាឡ ដូចព្រះចន្ទពេញវង់ ដែលហែហមដោយពួកផ្កាយ រមែងចម្រើនភ្នែកសូម្បីនៃហ្វូងម្រឹគជាតិ និងបក្សីទាំងឡាយ នឹងចាំបាច់ពោលទៅថ្វីដល់ទេវតា និងមនុស្សហ្ន៎ ។

ក៏ក្នុងថ្ងៃនោះឯង ដោយច្រើនព្រះអសីតិមហាថេរៈមួយរូបៗ ក៏ស្លៀកសំពត់បង្សុកូល មានពណ៌ដូចមេឃ ធៀងស្មាម្ខាងកាន់ឈើច្រត់ ដូចជាដំរីត្រកូលគន្ធវង្ស ដែលបានទទួលការហ្វឹកហាត់យ៉ាងល្អ ប្រាសចាកទោសហើយ ខ្ជាក់ទោសហើយ ទម្លាយកិលេសហើយ សសោះគ្រឿងទ្រុបទ្រុលហើយ កាត់គ្រឿងចងហើយ នាំគ្នាហែហមព្រះមានព្រះភាគជាម្ចាស់ ព្រះមានព្រះភាគនោះ ខ្លួនព្រះអង្គទ្រង់ប្រាសចាករាគៈហើយ ហែហមទៅដោយភិក្ខុដែលប្រាសចាករាគៈហើយ ព្រះអង្គទ្រង់ប្រាសចាកទោសៈហើយ ហែហមទៅដោយភិក្ខុដែលប្រាសចាកទោសៈហើយ ព្រះអង្គទ្រង់ប្រាសចាកតណ្ហាហើយ ហែហមទៅដោយភិក្ខុដែលប្រាសចាកតណ្ហាហើយ ព្រះអង្គទ្រង់មិនមានកិលេស ហែហមទៅដោយភិក្ខុដែលមិនមានកិលេស ព្រះអង្គជាអ្នកត្រាស់ដឹងហើយ ហែហមទៅដោយព្រះសាវកអ្នកដឹងតាមស្តេចទាំងឡាយ ដូចជាកេសររាជសីហ ហែហមទៅដោយម្រឹគជាតិ ដូចជាផ្កាកណ្ណិការហែហមដោយកេសរ ដូចជាស្តេចដំរីឆទ្ទន្តហែហមដោយដំរី ៨

ពាន់ក្បាល ដូចជាស្ដេចហង្សឈ្មោះធតរដ្ឋហែហមដោយហង្ស ៩ ម៉ឺន ដូចជាស្ដេចចក្រពត្តិហែហមដោយសេនាង្គនិករ ដូចជាស្ដេចសក្កទេវរាជហែហមដោយពួកទេវតា ដូចជាស្ដេចហារិតមហាព្រហ្មហែហមដោយពួកព្រហ្ម បានស្ដេចដំណើរទៅផ្លូវនោះ ដោយពុទ្ធលីលាដែលមិនមានអ្វីប្រៀបផ្ទឹមបាន ជាអចិន្តេយ្យដែលអ្នកណាៗ មិនគួរគិត ដែលកើតដោយ ផលបុណ្យដែលទ្រង់សន្សំមកអស់កាលប្រមាណមិនបាន ដូចព្រះចន្ទដែលគោចរអស់ផ្ទៃមេឃដូច្នោះ ។

## សុប្បិយបរិព្វាជក ជួបព្រះមានព្រះភាគ

គ្រានោះ បរិព្វាជកលុះបានឃើញព្រះមានព្រះភាគស្ដេចទៅដោយពុទ្ធលីលា ដែលមិនមានអ្វីប្រៀបផ្ទឹមបាន និងឃើញភិក្ខុទាំងឡាយមានចក្ខុដាក់ចុះ មានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ កំពុងថ្វាយបង្គំនមស្សការព្រះមានព្រះភាគ ហាក់បីដូចជាព្រះចន្ទពេញវង់អណ្ដែតធ្លោរនៅឰដ៏នភា-កាស ដូច្នោះ យ៉ាងនេះហើយ បានក្រឡេកមើលបរិស័ទរបស់ខ្លួន ។ បរិស័ទរបស់បរិព្វាជកនោះ ច្រើនទៅដោយអម្រែកបរិក្ខារដ៏ច្រើន មានតាំងតូចៗ ល្អស្អាត បាត្រដីមានពណ៌ដូចផ្លែកន្ទុយក្អែក ក:ទេរ និងកន្ទោទឹកជាដើម ដែលពាក់ត្រង់ដងរែកមកក្នុងថ្ងៃស្អែកឡើង ទាំងមាត់ខ្លាំង ពោលវាចាឥតប្រយោជន៍ មានជាដើមយ៉ាងនេះថា ដៃរបស់អ្នក

ឯណោះល្អ ជើងរបស់អ្នកឯណោះល្អ” មានវាចាផ្ដេសផ្ដាស់ មិនគួរមើល មិនគួរជ្រះថ្លា ។ គ្រាឃើញដូច្នោះគេកើតវិប្បដិសារ ។ ក្នុងកាលឥឡូវនេះ គួរដល់គេនឹងពោលសរសើរព្រះមានព្រះភាគ តែព្រោះហេតុដែលបរិព្វាជកនេះប្រណែននឹងព្រះមានព្រះភាគ សូម្បីអស់កាលជានិច្ច ព្រោះសេចក្ដីសាបសូន្យនៃលាភសក្ការៈ និងសេចក្ដីសាបសូន្យបក្ខពួក ព្រោះថា លាភសក្ការៈ រមែងកើតដល់អន្យតិរ្ថិយទាំងឡាយ អស់វេលាដែលព្រះពុទ្ធទាំងឡាយ ស្ដេចមិនទាន់បានឧប្បត្តិក្នុងលោក តែចាប់តាំងពីព្រះពុទ្ធស្ដេចឧប្បត្តិឡើង អន្យតិរ្ថិយទាំងឡាយ ក៏នាំគ្នាសាបសូន្យលាភសក្ការៈ ដល់ភាពជាអ្នកគ្មានសិរី ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះឡើង ដូច្នោះ ។

ក៏ក្នុងវេលាដែលឧបតិស្សៈ និងកោលិតៈ បួសក្នុងសម្នាក់របស់សញ្ជ័យនោះ ពួកបរិព្វាជកក៏មានបរិស័ទច្រើន តែកាលឧបតិស្សៈ និងកោលិតៈចៀសចេញទៅ បរិស័ទរបស់ពួកគេសូម្បីនោះ ក៏នាំគ្នាបែកទៅ ។ ដោយហេតុ ២ ប្រការ ដូចពោលមកនេះ គប្បីជ្រាបថា សុប្បិយបរិព្វាជកនេះ កាលខ្ជាក់សេចក្ដីឫស្យានោះចេញមក ពោលតិះដៀលព្រះរតនត្រ័យតែម្ដង ព្រោះឫស្យាព្រះមានព្រះភាគជានិច្ច ។

ពាក្យថា អថខោ ភគវា អម្ពលដ្ឋិកាយំ រាជាគារកេ ឯករត្តិវាសំ ឧបគញ្ឆិ សទ្ធឹ ភិក្ខុសង្ឃេន សេចក្ដីថា ក្នុងគ្រានោះឯង ព្រះមានព្រះភាគ

ស្តេចទៅដោយពុទ្ធលីលានោះ ដល់ទ្វារព្រះរាជឧទ្យានអម្ពលដ្ឋិកា ដោយលំដាប់ ទតមើលព្រះអាទិត្យ មានព្រះពុទ្ធតម្រិះថា ឥឡូវនេះ មិនមែនកាលដែលនឹងទៅ ព្រះអាទិត្យជិតអស្តង្គត ទើបស្តេចចូលប្រថាប់ស្នាក់សម្រាកមួយរាត្រីក្នុងព្រះដំណាក់ហ្លួង ក្នុងព្រះរាជឧទ្យានអម្ពលដ្ឋិកា ។

ក្នុងព្រះបាលីនោះ ឧទ្យានរបស់ព្រះរាជា ឈ្មោះថា **អម្ពលដ្ឋិកា** ។ បានឮថា ក្នុងទីជិតទ្វារនៃឧទ្យាននោះ មានដើមស្វាយជំទង់ ដែលអ្នកទាំងឡាយហៅថា អម្ពលដ្ឋិកា សូម្បីឧទ្យានក៏ដាក់ឈ្មោះថា អម្ពលដ្ឋិកាផងដែរ ព្រោះនៅជិតដើមស្វាយជំទង់នោះ ។ ឧទ្យាននោះ សម្បូរណ៍ដោយម្លប់ និងទឹក មានកំពែងលោមព័ទ្ធជុំវិញ មានទ្វារប្រកបទុកយ៉ាងល្អ ឃុំគ្រងយ៉ាងល្អ ដូចជាហិបដូច្នោះ ។

ក្នុងឧទ្យាននោះ បានសាងព្រះដំណាក់ដ៏វិចិត្រដោយប្រតិស្ឋកម្មដើម្បីជាទីលេង ទ្រង់កំសាន្តព្រះរាជហឫទ័យក្នុងព្រះដំណាក់នោះ ទើបហៅថា ព្រះដំណាក់ហ្លួង ។

ពាក្យថា សុប្បិយោបិ ខោ សេចក្តីថា សូម្បីសុប្បិយបរិព្វាជកក្រឡេកមើលព្រះអាទិត្យត្រង់ទីនោះហើយ ត្រិះរិះថា ឥឡូវនេះមិនមែនកាលដែលនឹងទៅ បរិព្វាជកទាំងតូចទាំងធំមានច្រើន និងផ្លូវនេះក៏មានអន្តរាយច្រើន ដោយចោរខ្លះ ដោយយក្ខកាចខ្លះ ដោយសត្វសាហាវខ្លះ ក៏ព្រះសមណគោតមនេះ ស្តេចចូលទៅកាន់ឧទ្យាន ក្នុងស្ថានទីប្រថាប់

របស់ព្រះសមណគោតម ទេវតារមែងនាំគ្នារក្សា បើដូច្នោះ សូម្បីយើង ក៏នឹងចូលទៅស្នាក់មួយរាត្រីក្នុងឧទ្យាននេះឯង ព្រឹកស្អែកនេះសឹមទៅ កាល ត្រិះរិះដូច្នេះហើយ ទើបចូលទៅកាន់ឧទ្យាននោះឯង ។

លំដាប់នោះ ភិក្ខុសង្ឃសម្តែងវត្ត ថ្វាយបង្គំព្រះមានព្រះភាគហើយ កំណត់ស្ថានទីសម្រាករបស់ខ្លួនៗ ។ សូម្បីសុប្បិយបរិព្វាជក ក៏ឲ្យដាក់ បរិក្ខាររបស់បរិព្វាជកនៅផ្នែកម្ខាងរបស់ឧទ្យាន ហើយចូលស្នាក់សម្រាក នឹងបរិស័ទរបស់ខ្លួន ។ តែក្នុងព្រះបាលីលោកពោលទុកដោយអំណាច ពាក្យដែលលើកឡើងជាប្រធានតែម្យ៉ាងថា ជាមួយនឹងព្រហ្មទត្តមាណព ដែលជាកូនសិស្សរបស់ខ្លួន ។ ក៏បរិព្វាជកនោះ ចូលស្នាក់នៅយ៉ាងនេះ បានក្រឡេកមើលព្រះទសពលក្នុងពេលកណ្តាលយប់ ។ ហើយក្នុង សម័យនោះ ក៏មានប្រទីបទុកបំភ្លឺដូចតារាដេរដាសដោយជុំវិញ ។ ព្រះ មានព្រះភាគប្រថាប់នៅត្រង់កណ្តាល និងភិក្ខុសង្ឃក៏នាំគ្នាអង្គុយលោមព័ទ្ធ ព្រះមានព្រះភាគ ។ សូម្បីភិក្ខុត្រឹមតែមួយរូបក្នុងទីប្រជុំនោះ ក៏មិនបាន មានការឃ្នើសឃ្នងដៃ ឃ្នើសឃ្នងជើង ឬសម្លេងក្អក សម្លេងកណ្តាស់ ឡើយ ។ ព្រោះថា បរិស័ទនោះ អង្គុយប្រជុំគ្នាស្ងប់ស្ងៀម ហាក់បីដូច អណ្តាតប្រទីបក្នុងទីឥតខ្យល់ ដោយហេតុ ២ ប្រការ គឺ ព្រោះជាអ្នក សិក្សាអប់រំហើយ និងដោយសេចក្តីគោរពក្នុងព្រះសាស្តា ។ បរិព្វាជក ឃើញគុណសម្បត្តិដូច្នោះ ទើបក្រឡេកមើលបរិស័ទរបស់ខ្លួន ។ ក្នុងទី

ប្រជុំបរិព្វាជកនោះ ពួកខ្លះក៏ដេកលើកដៃ ពួកខ្លះក៏ដេកលើកជើង ពួកខ្លះក៏ដេកមមើមមាយ ពួកខ្លះក៏ដេកលៀនអណ្តាត ទឹកមាត់ហូរ ខាំធ្មេញស្រមុកសំឡេងខ្លាំងៗ ។ សូម្បីកាលគួរនឹងពោលសរសើរព្រះរតនត្រ័យ សុប្បិយបរិព្វាជកនោះ ក៏ពោលតិះដៀលដដែលនុ៎ះឯងទៀត ដោយអំណាចសេចក្តីឫស្យា ចំណែកព្រហ្មទត្តមាណពពោលសរសើរតាមន័យដែលពោលហើយនុ៎ះឯង ។ ដោយហេតុនោះ ព្រះអានន្ទ ទើបពោលថា បានឮថា សូម្បីព្រះរាជឧទ្យានអម្ពលដ្ឋិកានោះ សុប្បិយបរិព្វាជក ដូច្នេះ គួរពោលពាក្យទាំងអស់ ។ ក្នុងព្រះបាលីនោះ បទថា តត្របិ សេចក្តីថា ក្នុងឧទ្យានឈ្មោះ **អម្ពលដ្ឋិកា** សូម្បីនោះ ។

## អធិប្បាយពាក្យថា ភិក្ខុច្រើនរូប និងពាក្យថា សង្ឃ

បទថា សម្ពហុលានំ សេចក្តីថា ច្រើនរូប ។ ក្នុងសេចក្តីនោះ តាមបរិយាយក្នុងព្រះវិន័យ ភិក្ខុ ៣ រូប ហៅថា ច្រើនរូប លើសពីនោះទៅ ហៅថា **សង្ឃ** តែតាមបរិយាយក្នុងព្រះសូត្រ ភិក្ខុ ៣ រូប ហៅថា ៣ រូបនោះឯង ច្រើនជាងនោះ ហៅថា **ច្រើនរូប** ។ ក្នុងទីនេះ គប្បីជ្រាបថា **ច្រើនរូប** តាមបរិយាយក្នុងព្រះសូត្រ ។

បទថា មណ្ឌលមាឡេ សេចក្តីថា កន្លែងខ្លះ កូដាគារសាលា

ដែលគេភ្ជាប់ហោជាង សាងទុកដោយការប្រក់ដូចហង្ស ហៅថា មណ្ឌលមាឡក៏មាន កន្លែងខ្លះឧបដ្ឋានសាលា សាលាដែលគេភ្ជាប់ហោជាងទុកតែមួយ សាងសសររបៀងទុកជុំវិញ ហៅថា មណ្ឌលមាឡក៏មាន ។ តែក្នុងទីនេះគប្បីជ្រាបថា បន្ទប់អង្គុយ ហៅថា មណ្ឌលមាឡ ។

បទថា សន្និសិន្នានំ អង្គុយប្រជុំ លោកពោលជាប់ដោយការអង្គុយ ។

បទថា សន្និបតិតានំ ប្រជុំ លោកពោលជាប់ដោយការរួមផ្តុំគ្នា ។

ពាក្យអធិប្បាយថា **កថាធម៌** ហៅថា **ការសន្ទនា** ក្នុងបទថា អយំ សន្ធិយធម្មោ ។

បទថា ឧទបាទិ ប្រែថា កើតឡើងហើយ ។

ក៏ការសន្ទនានោះ តើដូចម្តេច ? គឺ សន្ទនាគ្នាយ៉ាងនេះថា ម្នាលអ្នកមានអាយុ គួរអស្ចារ្យណាស់ ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ ដែលថា គួរអស្ចារ្យ ព្រោះមិនមាននៅជានិច្ចដូចមនុស្សខ្វាក់ក្អែកឡើងភ្នំ ។ ន័យនៃសព្ទ ក៏ប៉ុណ្ណេះ ។ ចំណែកន័យនៃអដ្ឋកថា មានដូចតទៅនេះ ៖

ពាក្យថា គួរអស្ចារ្យណាស់ ព្រោះគួរទះម្រាមដៃ អធិប្បាយថា គួរដល់ការទះម្រាម ។

ពាក្យថា មិនធ្លាប់មាន ព្រោះមិនធ្លាប់មានមក ស្រាប់តែមានឡើង ។

ទាំង ២ បទនេះ ជាឈ្មោះនៃសេចក្ដីចម្លែកចិត្តទាំងឯង ។

បទថា យាវញ្ចិទំ កាត់ជា យាវ ច ឥទំ ។ ដោយបទនោះ លោកសម្ដែងសេចក្ដីពាក្យនោះរកប្រមាណមិនបាន ។ ព្រោះព្រះមានព្រះភាគទ្រង់ជ្រាបល្អហើយ ។

ក្នុងពាក្យថា តេន ភគវតា ជានតា បស្សតា ។បេ។ សុបដិវិទិតា មានសេចក្ដីសង្ខេបដូចតទៅនេះ ៖

ព្រះមានព្រះភាគអង្គនោះ ទ្រង់បានបំពេញបារមី ៣០ ហើយ ទ្រង់ទម្លាយកិលេសទាំងពួង ត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបអាសយៈ និងអនុសយៈ របស់ពួកសត្វនោះៗ ទ្រង់ឃើញញេយ្យធម៌ទាំងពួង ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតព្រះហស្ត ។ មួយទៀត ទ្រង់ជ្រាបដោយព្រះញាណ មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ឬទ្រង់ជ្រាបដោយវិជ្ជា ៣ ខ្លះ ដោយអភិញ្ញា ៦ ខ្លះ ទ្រង់ឃើញដោយព្រះសមន្តចក្ខុ ដែលមិនមានអ្វីរាំងក្នុងធម៌ទាំងពួង ឬទ្រង់ជ្រាបដោយព្រះបញ្ញា ដែលអាចដឹងធម៌ទាំងពួង ទ្រង់ឃើញរូបដែលរួចផុតវិស័យចក្ខុនៃសត្វទាំងពួង ឬសូម្បីរូបដែលនៅក្រោយជញ្ជាំងជាដើម ដោយព្រះមំសចក្ខុដ៏បរិសុទ្ធិក្រៃលែង ឬទ្រង់ជ្រាបដោយព្រះបញ្ញាជាគ្រឿងចាក់ធ្លុះ ដែលមានព្រះសមាធិជាបទដ្ឋាន ឲ្យសម្រេចប្រយោជន៍ដល់ព្រះអង្គ ទ្រង់ឃើញដោយព្រះបញ្ញាជា

គ្រឿងសម្ដែង ដែលមានព្រះករុណាជាបទដ្ឋាន ឲ្យសម្រេចប្រយោជន៍ ជួយសង្គ្រោះដល់អ្នកដទៃ ទ្រង់ជាព្រះអរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវ គឺ កិលេស និងព្រោះទ្រង់ជាអ្នកគួរដល់សក្ការៈ មានបច្ច័យជាដើម ទ្រង់ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ ដោយព្រះអង្គឯង ឬទ្រង់ជ្រាបធម៌ដែលធ្វើឲ្យអន្តរាយ ទ្រង់ឃើញធម៌ដែលនាំចេញចាកទុក្ខ ទ្រង់ជាព្រះអរហន្ត ព្រោះទ្រង់កម្ចាត់សត្រូវ គឺ កិលេស និងព្រោះទ្រង់ជាអ្នកគួរដល់សក្ការៈ មានបច្ច័យជាដើម ទ្រង់ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ទ្រង់បានទទួលការសរសើរដោយអាការទាំង ៤ ដោយអំណាចនៃវេសារជ្ជញ្ញាណ ៤ ដូចពណ៌នាមកដូច្នេះ ទ្រង់ជ្រាបដោយល្អដល់សត្វទាំងឡាយជាអ្នកមានអធិមុត្តិផ្សេងគ្នា និងមានអជ្ឈាស្រ័យផ្សេងគ្នា និងទ្រង់ជ្រាបរហូតដោយល្អត្រឹមណា ។

ឥឡូវនេះ ដើម្បីសម្ដែងអំពីព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបល្អហើយ លោកទើបពោលពាក្យថា ក៏សុប្បិយបរិព្វាជកនេះ ដូច្នេះជាដើម ។ មានពាក្យអធិប្បាយថា ក៏សត្វទាំងឡាយមានអធិមុត្តិផ្សេងគ្នា មានអជ្ឈាស្រ័យផ្សេងគ្នា មានទិដ្ឋិផ្សេងគ្នា មានសេចក្ដីពេញចិត្តផ្សេងគ្នា មានការចូលចិត្តផ្សេងគ្នានេះ ដែលព្រះមានព្រះភាគទ្រង់ជ្រាប ដោយព្រះសព្វញ្ញុតញ្ញាណ ដែលជាគ្រឿងដឹងនូវសត្វទាំងឡាយ មានអធិមុត្តិ

ផ្សេងគ្នា ដូចទ្រង់វាល់ដោយនាឡិ និងដូចទ្រង់ថ្លឹងដោយជញ្ជីង ដោយព្រះបាលីយ៉ាងនេះថា

“ម្នាលភិក្ខុទាំងឡាយ ពោលដោយធាតុ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា គឺ ពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប , ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ម្នាលភិក្ខុទាំងឡាយ សូម្បីអតីតកាល ពោលដោយធាតុ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា គឺ ពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប , ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ , ម្នាលភិក្ខុទាំងឡាយ សូម្បីអនាគតកាល ពោលដោយធាតុ សត្វទាំងឡាយ ក៏នឹងត្រូវគ្នា សមគ្នា គឺ ពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប , ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ , ម្នាលភិក្ខុទាំងឡាយ សូម្បីបច្ចុប្បន្នកាលនេះ ពោលដោយធាតុ សត្វទាំងឡាយ

សត្វទាំងឡាយ ត្រូវគ្នា សមគ្នា គឺ ពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប , ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ដូច្នេះ ។

សភាពដែលសត្វទាំងឡាយ មានអធិមុត្តិផ្សេងគ្នានោះ ព្រះមានព្រះភាគទ្រង់ជ្រាបល្អហើយត្រឹមណា ដែលឈ្មោះថា សត្វសូម្បីពីរនាក់មានអធ្យាស្រ័យដូចគ្នា រកបានដោយកម្រក្នុងលោក កាលម្នាក់ត្រូវការដើរ ម្នាក់ត្រូវការឈរ កាលម្នាក់ត្រូវការផឹក ម្នាក់ត្រូវការបរិភោគ និងសូម្បីក្នុងអាចារ្យ និងសិស្សពីរនាក់នេះ សុប្បិយបរិព្វាជកនេះ ពោលតិះដៀលព្រះពុទ្ធ តិះដៀលព្រះធម៌ តិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ ចំណែកព្រហ្មទត្តមាណពដែលជាសិស្សរបស់សុប្បិយបរិព្វាជកគង់ពោលសរសើរព្រះពុទ្ធ សរសើរព្រះធម៌ សរសើរព្រះសង្ឃ ដោយអនេកបរិយាយ អាចារ្យ និងសិស្សទាំងពីរនោះ មានពាក្យជាសត្រូវដល់គ្នា និងគ្នាដោយត្រង់ ដូច្នេះ ដើរតាមព្រះមានព្រះភាគ និងភិក្ខុសង្ឃទៅខាងក្រោយៗ ដោយប្រការដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា ឥតិហាមេ កាត់បទជា ឥតិហ ឥមេ មានសេចក្ដីថា ទាំងនេះ... ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក៏ន័យដូច

ពោលហើយនុ៎ះឯង ។

ក្នុងពាក្យថា អថខោ ភគវា តេសំ ភិក្ខូនំ ឥមំ សង្ខិយធម្មំ វិទិត្វា នេះ បទថា វិទិត្វា សេចក្តីថា ទ្រង់ជ្រាបដោយព្រះសព្វញ្ញុតញ្ញាណ ។

ពិតហើយ ក្នុងបាលីកន្លែងខ្លះ ព្រះមានព្រះភាគទតឃើញដោយមំសចក្ខុ ទើបទ្រង់ជ្រាប ដូចក្នុងប្រយោគមានជាដើមថា ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើធំ កំពុងអណ្តែតតាមក្រសែទឹក ក្នុងទន្លេគង្គា ។

ក្នុងបាលីកន្លែងខ្លះ ទ្រង់ឃើញដោយទិព្វចក្ខុ ទើបទ្រង់ជ្រាប ដូចក្នុងប្រយោគជាដើមថា ព្រះមានព្រះភាគបានទតឃើញពួកទេវតាទាំងនោះចំនួនរាប់ពាន់ៗ កំពុងគន់មើលទីដីសង់ផ្ទះក្នុងបាដលិគ្រាម ដោយទិព្វ-ចក្ខុដ៏បរិសុទ្ធិកន្លងបង់នូវចក្ខុរបស់មនុស្សសាមញ្ញ ។

ក្នុងបាលីកន្លែងខ្លះ ទ្រង់ស្តាប់ដោយព្រះសោតធម្មតា ទើបទ្រង់ជ្រាប ដូចក្នុងប្រយោគជាដើមថា ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ព្រះអានន្ទដ៏មានអាយុប្រាស្រ័យសន្ទនាជាមួយនឹងសុភទ្ទបរិព្វាជក ។

ក្នុងបាលីកន្លែងខ្លះ ទ្រង់ស្តាប់ដោយទិព្វសោត ហើយទ្រង់ជ្រាប ដូចក្នុងប្រយោគមានជាដើមថា ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់សន្ធានគហបតី ប្រាស្រ័យសន្ទនាជាមួយនឹងនិគ្រោធបរិព្វាជក ដោយទិព្វ-

សោតដ៏បរិសុទ្ធិ កន្លងបង់នូវសោតធាតុរបស់មនុស្សសាមញ្ញ ។

ក៏ក្នុងព្រះបាលីនេះ ទ្រង់ឃើញដោយព្រះសព្វញ្ញុតញ្ញាណ ទើបទ្រង់ជ្រាប ។ ទ្រង់ធ្វើអ្វី ទើបទ្រង់ជ្រាប ? ទ្រង់ធ្វើកិច្ចក្នុងបច្ឆិមយាម ។

## ពណ៌នាពុទ្ធកិច្ច ៥ ប្រការ

ដែលឈ្មោះថា កិច្ចនេះ មាន ២ យ៉ាង គឺ កិច្ចដែលមានប្រយោជន៍ និងកិច្ចដែលមិនមានប្រយោជន៍ ។

បណ្តាកិច្ច ២ យ៉ាងនោះ កិច្ចដែលមិនមានប្រយោជន៍ ព្រះមានព្រះភាគ ទ្រង់ផ្តាច់បង់ហើយដោយអរហត្តមគ្គនៅឯពោធិបល្ល័ង្ក ។ ព្រះ-មានព្រះភាគ ទ្រង់មានតែកិច្ចដែលជាប្រយោជន៍ប៉ុណ្ណោះ ។ កិច្ចដែលមានប្រយោជន៍របស់ព្រះមានព្រះភាគនោះមាន ៥ យ៉ាង គឺ ៖

| | |
|---|---|
| **១. កិច្ចក្នុងបុរេភត្ត** | ទ្រង់យាងបិណ្ឌបាត |
| **២. កិច្ចក្នុងបច្ឆាភត្ត** | ទ្រង់សម្តែងធម៌ដល់បរិស័ទ |
| **៣. កិច្ចក្នុងបុរិមយាម** | ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ |
| **៤. កិច្ចក្នុងមជ្ឈិមយាម** | ទ្រង់ដោះស្រាយបញ្ហារបស់ទេវតា |
| **៥. កិច្ចក្នុងបច្ឆិមយាម** | ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ |

ក្នុងបណ្តាកិច្ច ៥ យ៉ាងនោះ កិច្ចក្នុងបុរេភត្តមានដូច្នេះ ក៏ព្រះមាន

ព្រះភាគ ស្តេចក្រោកឡើងពីព្រឹកព្រលឹម ទ្រង់បដិបត្តិព្រះសរីរៈ មានខ្ពុរព្រះឱស្ឋជាដើម ដើម្បីទ្រង់អនុគ្រោះឧបដ្ឋាក និងដើម្បីសេចក្តីសប្បាយនៃព្រះសរីរៈស្រេចហើយ ទ្រង់ប្រថាប់សម្រាកនៅលើពុទ្ធាសនៈដ៏ស្ងៀមស្ងាត់ ដរាបដល់វេលាភិក្ខាចារ គ្រាដល់វេលាភិក្ខាចារ ទ្រង់ស្លៀកស្បង់ ទ្រង់ក្រវាត់វត្ថពន្ធបង្កេះ ទ្រង់គ្រងចីវរ ទ្រង់កាន់បាត្រ ពេលខ្លះ ស្តេចយាងតែព្រះអង្គឯង ពេលខ្លះហែហមទៅដោយភិក្ខុសង្ឃ ស្តេចចូលទៅបិណ្ឌបាតតាមស្រុកឬនិគម ពេលខ្លះស្តេចចូលទៅតាមប្រក្រតី ពេលខ្លះក៏ស្តេចចូលទៅដោយបាដិហារ្យច្រើនប្រការ ។ គឺយ៉ាងណា ? កាលព្រះបរមលោកនាថ ស្តេចចូលទៅបិណ្ឌបាត ខ្យល់ដែលបក់រំភើយៗ ក៏បក់ទៅខាងមុខ បោសសម្អាតផែនពសុធាឲ្យស្អាតបរិសុទ្ធ វលាហកៈក៏បង្អុរតំណក់ទឹកចុះរម្ងាប់ល្អងធូលីក្នុងមគ្គា រនាំងបាំងជាពិតាននៅខាងលើ ក្រសែខ្យល់ក៏ត្រងយកផ្កាឈើទាំងឡាយ មករោយចុះក្នុងមគ្គា ទីដែលខ្ពស់ក៏ស្រុតចុះ ទីដែលទាបក៏ខ្ពស់ឡើង ផ្ទៃផែនដីក៏រៀបស្មើ ក្នុងខណៈដែលទ្រង់យាងដោយព្រះយុគលបាទ ឬមានបទុមបុប្ផជាតិ ដែលមានសម្ផស្សទន់ល្មើយ ជាទីសប្បាយចាំទ្រព្រះយុគលបាទ លុះព្រះបាទខាងស្តាំប្រតិ-ស្ឋានចុះខាងក្នុងធរណីទ្វារ ព្រះឆព្វណ្ណរង្សីក៏ផ្សាយឡើង ចេញអំពីព្រះពុទ្ធសរីរៈ បាញ់ពន្លឺភ្លែតៗ ប្រដាប់ប្រាសាទរាជមណ្ឌបជាដើម ដូចពន្លឺពណ្ណរាយនៃមាស និងដូចជាព័ន្ធព័ទ្ធទុកដោយផ្ទាំងសំពត់ដ៏វិចិត្រ បណ្តាសត្វទាំង

ឡាយមានដំរី សេះ និងសត្វស្វាប ជាដើម ដែលនៅក្នុងស្ថានទីនៃខ្លួនៗ ក៏នាំគ្នាបន្លឺសំនៀងយ៉ាងពីរោះ ទាំងតន្ត្រីដ៏ពីរោះ ដូចភេរី និងពិណ ជាដើម ក៏សំឡេងភ្លេងតន្ត្រីសូត្រ និងសព្វាភរណៈនៃមនុស្សទាំងឡាយ ក៏ប្រាកដដូចពាក់ជាប់រាងកាយក្លាម ដោយសញ្ញាយ៉ាងនេះ ធ្វើឲ្យមនុស្សទាំងឡាយជ្រាបបានថា ថ្ងៃនេះ ព្រះមានព្រះភាគ ស្ដេចចូលទៅបិណ្ឌបាត ក្នុងភូមិនេះ មនុស្សទាំងនោះ ម្នាក់ៗតែងខ្លួន ស្លៀកដណ្ដប់រៀបរយ នាំគ្នាកាន់របស់ក្រអូប និងផ្កាឈើជាដើម ចេញចាកផ្ទះ ដើរទៅតាមថ្នល់ បូជាព្រះមានព្រះភាគដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ដោយគោរព ថ្វាយបង្គំហើយ ក្រាបទូលសូមសង្ឃថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រទានភិក្ខុ ដល់ពួកខ្ញុំព្រះអង្គ ១០ រូប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រទានភិក្ខុដល់ពួកខ្ញុំព្រះអង្គ ២០ រូប ដល់ពួកខ្ញុំព្រះអង្គ ៥០ រូប ដល់ពួកខ្ញុំព្រះអង្គ ១០០ រូប ដូច្នេះ ហើយទទួលបាត្ររបស់ព្រះមានព្រះភាគ ក្រាលអាសនៈ បង្អោនថ្វាយបិណ្ឌបាត ដោយគោរព ។ ព្រះមានព្រះភាគ ធ្វើភត្តកិច្ចរួចស្រេចហើយ ទ្រង់ពិចារណាមើលចិត្តសន្តានរបស់សត្វពួកនោះ ទ្រង់សម្ដែងព្រះធម៌ទេសនាប្រោស ឲ្យពួកខ្លះតាំងនៅក្នុងសរណគមន៍ ពួកខ្លះតាំងនៅក្នុងសីល ៥ ពួកខ្លះតាំងនៅក្នុងសោតាបត្តិផល សកទាគាមិផល អនាគាមិផល យ៉ាងណាមួយ ពួកខ្លះបួសហើយតាំងនៅក្នុងព្រះអរហត្ត ដែលជាផលដ៏ប្រសើរ ទ្រង់អនុគ្រោះ

មហាជន ដូចពណ៌នាមកដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈ ស្តេចទៅកាន់ព្រះវិហារ រួចហើយប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលក្រាលទុកក្នុងមណ្ឌលសាលា ព្រះអង្គរង់ចាំការសម្រេចកត្តកិច្ចរបស់ភិក្ខុទាំងឡាយ កាលភិក្ខុទាំងឡាយសម្រេចកិច្ចរៀបរយហើយ ភិក្ខុជាឧបដ្ឋាក ក៏ក្រាបទូលព្រះមានព្រះភាគឲ្យទ្រង់ជ្រាប លំដាប់នោះ ព្រះមានព្រះភាគស្តេចក៏ចូលព្រះគន្ធកុដិ ។ នេះជាកិច្ចក្នុងបុរេភត្ត ។

កាលនោះឯង ព្រះមានព្រះភាគ គ្រាទ្រង់បំពេញកិច្ចក្នុងបុរេភត្តស្រេចហើយយ៉ាងនេះ ប្រថាប់នៅក្នុងសាលាប្រណិបត្តិ ជិតព្រះគន្ធកុដិ ទ្រង់លាងព្រះបាទហើយប្រថាប់ឈរលើតាំងទ្រព្រះបាទ ប្រទានឱវាទដល់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ និងថា ៖

ទុល្លភោ មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ
ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ
ទុល្លភា សទ្ធាសម្បត្តិ បព្វជ្ជា ច ទុល្លភា
ទុល្លភំ សទ្ធម្មស្សវនំ ។

ភាពជាមនុស្ស រកបានដោយកម្រ ការកើតឡើងរបស់
ព្រះពុទ្ធ រកបានដោយកម្រ សេចក្តីដល់ព្រមដោយខណៈ
រកបានដោយកម្រ ព្រះសទ្ធម្ម រកបានដោយកម្រយ៉ាងក្រៃ

ផែង ការដល់ព្រមដោយសទ្ធា រកបានដោយកម្រ ការបួស រកបានដោយកម្រ ការស្តាប់ព្រះសទ្ធម្ម រកបានដោយកម្រ ។

ក្នុងទីនោះ ភិក្ខុពួកខ្លះ ទូលសួរកម្មដ្ឋានចំពោះព្រះមានព្រះភាគ ។ សូម្បីព្រះមានព្រះភាគ ក៏ប្រទានកម្មដ្ឋានដែលសមគួរដល់ចរិតរបស់ភិក្ខុទាំងនោះ ។ លំដាប់នោះ ភិក្ខុទាំងពួងថ្វាយបង្គំព្រះមានព្រះភាគ ហើយទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃរបស់ខ្លួនៗ ។ ពួកខ្លះក៏ទៅព្រៃ ពួកខ្លះក៏ទៅកាន់គល់ឈើ ពួកខ្លះក៏ទៅកាន់ទីកន្លែងណាមួយ មានភ្នំជាដើម ពួកខ្លះក៏ទៅកាន់ភពរបស់ទេវតាជាន់ចាតុម្មហារាជិកា ។ល។ ពួកខ្លះក៏ទៅកាន់ភពរបស់ទេវតាជាន់វសវត្តី ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ស្តេចចូលព្រះគន្ធកុដិ បើមានព្រះពុទ្ធបំណង ក៏ទ្រង់មានព្រះសតិសម្បជញ្ញៈ សម្រេចសីហសេយ្យាមួយស្របក់ដោយព្រះចំហៀងខាងស្តាំ គ្រាមានព្រះវរកាយស្រស់បស់ហើយ ស្តេចក្រោកឡើងត្រួតមើលលោកក្នុងភាគទីពីរ ។ ក្នុងស្រុក ឬនិគម ដែលព្រះអង្គស្តេចចូលទៅអាស្រ័យប្រថាប់នៅ មហាជននាំគ្នាថ្វាយទាន មុនអាហារ វេលាក្រោយអាហារ ស្លៀកដណ្តប់រៀបរយ កាន់របស់ក្រអូបនិងផ្កាឈើជាដើម មកប្រជុំគ្នាក្នុងព្រះវិហារ ។ កាលបរិស័ទព្រមព្រៀងគ្នាហើយ ព្រះមានព្រះភាគ ស្តេចទៅដោយព្រះបាដិហារ្យដែលសមគួរ

ប្រថាប់សម្ដែងធម៌ ដែលគួរដល់កាលសម័យក្នុងពុទ្ធាសនៈដ៏ប្រសើរ ដែលចាត់ចែងទុកក្នុងធម្មសភា គ្រាទ្រង់ជ្រាបកាលដែលគួរហើយ ក៏ទ្រង់បញ្ជូនបរិស័ទត្រឡប់ ។ ពួកមនុស្ស ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយនាំគ្នាចៀសចេញទៅ ។ នេះជាកិច្ចក្រោយអាហារ ។

ព្រះមានព្រះភាគអង្គនោះ គ្រាសម្រេចកិច្ចក្រោយភត្តយ៉ាងនេះហើយ បើមានព្រះពុទ្ធបំណងនឹងស្រោចស្រប់ព្រះវរកាយ ក៏ស្ដេចក្រោកចាកពុទ្ធាសនៈ ចូលបន្ទប់ជាទីស្រង់ទឹក ទ្រង់ស្រង់ព្រះវរកាយដោយទឹកដែលភិក្ខុជាពុទ្ធុបដ្ឋាកចាត់ថ្វាយ ។ ចំណែកភិក្ខុដែលជាពុទ្ធុបដ្ឋាក ក៏នាំពុទ្ធាសនៈមកក្រាលទីបរិវេណព្រះគន្ធកុដិ ។ ព្រះមានព្រះភាគ ទ្រង់គ្រងចីវរពីរជាន់ដែលជ្រលក់ល្អហើយ ទ្រង់ក្រវាត់វត្តពន្ធចង្កេះ ទ្រង់គ្រងចីវរធៀងស្មាម្ខាង ហើយស្ដេចយាងប្រថាប់លើពុទ្ធាសនៈនោះ ។ ទ្រង់នៅពួនសម្ងំមួយស្របក់តែមួយព្រះអង្គឯង ។ គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាមកពីទីនោះៗ ហើយមកកាន់ទីប្រណិបត្តិរបស់ព្រះមានព្រះភាគ ។

ក្នុងទីនោះ ភិក្ខុពួកខ្លះក៏ទូលសួរបញ្ហា ពួកខ្លះក៏ទូលសូមកម្មដ្ឋាន ពួកខ្លះក៏ទូលសូមស្ដាប់ធម៌ ។ ព្រះមានព្រះភាគប្រថាប់សម្រាករហូតដល់អស់យាមដើម ទ្រង់ឲ្យសេចក្ដីប្រាថ្នារបស់ភិក្ខុទាំងនោះសម្រេច ។ នេះជាកិច្ចក្នុងបឋមយាម (បុរិមយាម) ។

ក៏កាលចុងបំផុតនៃកិច្ចក្នុងបឋមយាម ភិក្ខុទាំងឡាយ ថ្វាយបង្គំ

ព្រះមានព្រះភាគហើយ ចៀសចេញទៅ ពួកទេវតាក្នុងម៉ឺនលោកធាតុទាំងអស់ កាលបានឱកាស ក៏នាំគ្នាចូលគាល់ព្រះមានព្រះភាគ អង្គុយខ្លះទូលសួរបញ្ហាតាមដែលត្រៀមមក ដោយហោចទៅសូម្បីអក្ខរៈ ៤ តួ ។ ព្រះមានព្រះភាគ ទ្រង់តបបញ្ហាដល់ទេវតាទាំងនោះ ឲ្យមជ្ឈិមយាមកន្លងទៅ នេះជាកិច្ចក្នុងមជ្ឈិមយាម ។

ចំណែកបច្ឆិមយាម ព្រះមានព្រះភាគទ្រង់បែងចែកជា ៣ ចំណែក គឺ ទ្រង់នៅសម្រាក ដោយស្តេចចង្ក្រមមួយចំណែក ដើម្បីទ្រង់សម្រួលចាកពីសេចក្តីនឿយលំបាកនៃព្រះសរីរៈដែលត្រូវឥរិយាបថអង្គុយ តាំងពីមុនអាហារបៀតបៀនហើយ ។ ក្នុងចំណែកទីពីរ ស្តេចចូលព្រះគន្ធកុដិ ទ្រង់មានព្រះសតិសម្បជញ្ញៈ សម្រេចសីហសេយ្យាដោយផ្អៀងខាងស្តាំ ។ ក្នុងចំណែកទីបី ស្តេចក្រោកឡើងប្រថាប់ហើយ ទ្រង់មើលសត្វលោកដោយពុទ្ធចក្ខុ ដើម្បីសម្លឹងឃើញបុគ្គលអ្នកសន្សំបុញ្ញាធិការទុក ដោយអំណាចទាន និងសីលជាដើម ក្នុងសម្នាក់របស់ព្រះពុទ្ធអង្គមុនៗ ។ នេះជាកិច្ចក្នុងបច្ឆិមយាម ។

ក៏ថ្ងៃនោះ ព្រះមានព្រះភាគ ទ្រង់ញុំាងកិច្ចមុនភត្តឲ្យសម្រេចក្នុងក្រុងរាជគ្រឹះហើយ ដល់វេលាក្រោយភត្ត ស្តេចដំណើរមកកាន់ផ្លូវត្រាស់ប្រាប់កម្មដ្ឋានដល់ភិក្ខុទាំងឡាយក្នុងវេលាបឋមយាម ទ្រង់ដោះស្រាយបញ្ហាដល់ទេវតាទាំងឡាយក្នុងមជ្ឈិមយាម ស្តេចឡើងកាន់ទីចង្ក្រម ទ្រង់

ចង្រ្កមនៅក្នុងបច្ឆិមយាម ទ្រង់បានឮភិក្ខុប្រមាណ ៥០០ រូប សន្ទនាទាក់ទងដល់ព្រះសព្វញ្ញុតញ្ញាណនេះ ដោយព្រះសព្វញ្ញុតញ្ញាណនុ៎ះឯង បានទ្រង់ជ្រាបហើយ ។ ដោយហេតុនោះ ខ្ញុំទើបបានពោលថា "កាលទ្រង់ធ្វើកិច្ចក្នុងបច្ឆិមយាម ទ្រង់បានជ្រាបហើយ" ។ ក៏កាលទ្រង់ជ្រាបហើយ មានព្រះពុទ្ធតម្រិះដូច្នេះថា "ភិក្ខុទាំងនេះ ពោលគុណទាក់ទងដល់សព្វញ្ញុតញ្ញាណរបស់តថាគត ក៏កិច្ចនៃសព្វញ្ញុតញ្ញាណ មិនប្រាកដដល់ភិក្ខុទាំងនេះ ប្រាកដដល់តថាគតប៉ុណ្ណោះ កាលតថាគតទៅហើយ ភិក្ខុទាំងនេះ ក៏នឹងប្រាប់ការសន្ទនារបស់ខ្លួនរហូតអស់កាល" ។ បន្ទាប់ពីនោះ យើងនឹងធ្វើការសន្ទនារបស់ភិក្ខុទាំងនោះឲ្យជាដើមហេតុ ហើយចែកសីល ៣ យ៉ាង បន្លឺសីហនាទដែលនរណាៗ ជំទាស់មិនបាន ក្នុងឋានៈ ៦២ ប្រការ ប្រជុំបច្ចយាការធ្វើពុទ្ធគុណឲ្យប្រាកដ នឹងសម្ដែងព្រហ្មជាលសូត្រ ដែលនឹងញាំងម៉ឺនលោកធាតុឲ្យញាប់ញ័រ ឲ្យចប់ស្រេចដល់កំពូល គឺព្រះអរហត្ត ដូចជាលើកភ្នំសិនេរុរាជឡើង និងដូចវាយវាត់ផ្ទៃមេឃដោយកំពូលសុវណ្ណកូដ ទេសនានោះ សូម្បីកាលតថាគតបរិនិព្វានហើយ ក៏នឹងញាំងអមតមហានិព្វានឲ្យសម្រេចដល់សត្វទាំងឡាយ រហូតដល់អស់ ៥ ពាន់ឆ្នាំ គ្រាមានព្រះបរិវិតក្កៈយ៉ាងនេះហើយ ស្ដេចបានចូលទៅកាន់សាលាមណ្ឌលដែលភិក្ខុទាំងនោះអង្គុយ ដោយប្រការដូច្នេះ ។

បទថា យេន សេចក្ដីថា សាលាមណ្ឌលនោះ ដែលព្រះមាន-

ព្រះភាគគប្បីស្តេចចូលទៅតាមផ្លូវទិសខាងណា ។

ម្យ៉ាងទៀតថា បទថា យេន ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្ត-មីវិភត្តិ ។ ព្រោះដូច្នោះ ក្នុងបទនេះ ទើបមានសេចក្តីថា យស្មឹ បទេសេ សោ មណ្ឌលមាឡោ ស្តេចបានទៅក្នុងប្រទេសដែលមានសាលាមណ្ឌលនោះ ដូច្នេះ ។

ពាក្យថា បញ្ញត្តេ អាសនេ និសីទិ ទ្រង់គង់លើអាសនៈដែលគេតែងតាំងថ្វាយ សេចក្តីថា ឮថា ក្នុងគ្រាពុទ្ធកាល ស្ថានទីណាៗ ដែលមានភិក្ខុនៅសូម្បីតែមួយអង្គ ក៏ចាត់ពុទ្ធាសនៈទុកគ្រប់កន្លែងតែម្តង ។ ព្រោះហេតុអ្វី ? គឺថា ព្រះមានព្រះភាគទ្រង់មនសិការដល់ពួកភិក្ខុ ដែលទទួលកម្មដ្ឋានក្នុងសម្នាក់របស់ព្រះអង្គ ហើយនៅក្នុងទីសប្បាយថា ភិក្ខុរូបឯណោះ ទទួលកម្មដ្ឋានក្នុងសម្នាក់របស់តថាគតទៅ អាចនឹងញ៉ាំងគុណវិសេសឲ្យកើតឡើងឬទេ គ្រាទ្រង់ឃើញភិក្ខុរូបនោះ លះកម្មដ្ឋានកំពុងត្រិះរិះដល់អកុសលវិតក្កៈ លំដាប់នោះ ទ្រង់ត្រិះរិះថា “កុលបុត្រនេះ ទទួលកម្មដ្ឋានក្នុងសម្នាក់របស់សាស្តាដូចតថាគត តើហេតុដូចម្តេចនឹងត្រូវអកុសលវិតក្កៈគ្របសង្កត់ឲ្យលិចចុះក្នុងវដ្តទុក្ខ ដែលមានកំណត់ខាងដើមមិនប្រាកដ ?” ដើម្បីនឹងទ្រង់អនុគ្រោះភិក្ខុរូបនោះ ទើបទ្រង់សម្តែងព្រះអង្គក្នុងទីនោះតែម្តង ប្រទានឱវាទដល់កុលបុត្រនោះ ហើយស្តេចហោះឡើងកាន់អាកាស ត្រឡប់ទៅកាន់ទីប្រថាប់របស់ព្រះអង្គតទៅ ។

លំដាប់នោះ ភិក្ខុទាំងនោះ ដែលព្រះមានព្រះភាគប្រទានឱវាទយ៉ាងនេះ គិតគ្នាថា ព្រះបរមសាស្តាទ្រង់ជ្រាបសេចក្តីគិតរបស់ពួកយើងស្តេចមកសម្តែងព្រះអង្គ ប្រថាប់ឈរក្នុងទីជិតពួកយើង ជាការដែលពួកយើងនឹងត្រូវត្រៀមពុទ្ធាសនៈទុក សម្រាប់ទូលអាពធនាក្នុងខណៈនោះថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រថាប់លើពុទ្ធាសនៈនេះ សូមព្រះអង្គមេត្តាប្រថាប់លើពុទ្ធាសនៈនេះ" ។ ភិក្ខុទាំងនោះនាំគ្នាចាត់ពុទ្ធាសនៈទុកហើយ ទើបនៅ ។ ភិក្ខុដែលមានតាំង ក៏ចាត់តាំងទុក ដែលមិនមានក៏ចាត់គ្រែ ឬបន្ទះក្តារ ឬឈើ ឬផ្ទាំងសិលា ឬគំនរខ្សាច់ទុក កាលមិនបានយ៉ាងនោះ ក៏ទាញយកសម្បកឈើចាស់ៗ មកក្រាលសំពត់បង្សុកូលតាំងទុកលើទីនោះឯង តែព្រះជំណាក់ក្នុងព្រះរាជ-ឧទ្យានអម្ពលដ្ឋិកានេះ មានព្រះរាជាសនៈ ភិក្ខុទាំងនោះជួយគ្នាបោសសំអាតល្អងធូលី ព្រះរាជាសនៈនោះក្រាលទុក អង្គុយឡោមព័ទ្ធ ពោលសរសើរព្រះពុទ្ធគុណ ប្រារព្ធដល់ព្រះអធិមុត្តិញ្ញាណ (ញាណដឹងអធ្យា-ស្រ័យសត្វ) របស់ព្រះមានព្រះភាគ ។ ព្រះអានន្ទ សំដៅដល់ ព្រះ-រាជាសនៈនោះ ទើបពោលថា "ទ្រង់គង់លើពុទ្ធាសនៈដែលគេតែងតាំងថ្វាយ" ។ ក៏ព្រះមានព្រះភាគប្រថាប់យ៉ាងនេះ ទាំងដែលទ្រង់ជ្រាបហើយក៏ត្រាស់សួរភិក្ខុទាំងឡាយ ដើម្បីឲ្យកើតការសន្ទនា ទាំងភិក្ខុនោះ ក៏នាំគ្នាក្រាបទូលព្រះអង្គគ្រប់រឿង ។ ព្រោះហេតុនោះ ព្រះអានន្ទ ទើប

ពោលថា "លុះព្រះមានព្រះភាគគង់ហើយ" ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា កាយនុត្ថ សេចក្ដីថា ពួកអ្នកអង្គុយសន្ទនាគ្នាដល់រឿងអ្វី ? បាលីជា កាយន្វេត្ថ ក៏មាន ។ ព្រះបាលីនោះ មានសេចក្ដីថា ពួកអ្នកអង្គុយ សន្ទនាគ្នាដល់រឿងអ្វីក្នុងទីនេះ ។ បាលីជា កាយនោត្ថ ក៏មាន ។ ក្នុងធម្មបទ សូម្បីព្រះបាលីនោះក៏មានសេចក្ដីដូចមុននុ៎ះឯង ។

បទថា អន្តរាកថា សេចក្ដីថា សន្ទនាចន្លោះ ការមនសិការ-កម្មដ្ឋាន ឧទ្ទេស និងបរិបុច្ឆាជាដើម គឺ ក្នុងចន្លោះនៃរឿងដទៃមួយទៀត ។

បទថា វិប្បកតា សេចក្ដីថា មិនទាន់ចប់ គឺ មិនទាន់ដល់ទីបញ្ចប់ ព្រោះតថាគតមកដល់មុនពេលចប់ ។

ដោយបទនោះ ទ្រង់សម្ដែងទុកយ៉ាងណា ?

អធិប្បាយថា តថាគតមក ដើម្បីបញ្ឈប់ការសន្ទនារបស់ពួកភិក្ខុក៏មិនមែន តែមកដោយប្រាថ្នាថា នឹងសម្ដែង ឲ្យការសន្ទនារបស់ពួកភិក្ខុចប់ស្រេច គឺ ធ្វើឲ្យដល់ទីបំផុតដោយភាពជាសព្វញ្ញូ ដូច្នោះ ព្រះមាន-ព្រះភាគទើបប្រថាប់អង្គុយ ទ្រង់ហាមព្រះសព្វញ្ញូ ។

សូម្បីក្នុងពាក្យថា ព្រះអង្គ ពួកខ្ញុំព្រះអង្គផ្អាកការសន្ទនាទុក ក៏ស្រាប់តែព្រះមានព្រះភាគស្ដេចមកដល់នេះ មានអធិប្បាយដូចតទៅនេះ ៖

បពិត្រព្រះអង្គដ៏ចម្រើន ការសន្ទនាព្រះពុទ្ធគុណ ប្រារព្ធព្រះ-

សព្វញ្ញុតញ្ញាណរបស់ព្រះមានព្រះភាគរបស់ពួកខ្ញុំព្រះអង្គ ផ្អាកទុកហើយ មិនមែនតិរច្ឆានកថា មានរាជកថាជាដើមទេ ក៏ស្រាប់តែព្រះមានព្រះភាគស្តេចមកដល់ សូមព្រះអង្គ មេត្តាបានសម្តែង ឲ្យការសន្ទនារបស់ពួកខ្ញុំព្រះអង្គនោះចប់សព្វគ្រប់ ក្នុងកាលឥឡូវនេះផងចុះ ។ ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះអានន្ទបានភាសិតពាក្យដែលជានិទាន ដែលប្រដាប់ដោយកាលៈ ទេសៈ អ្នកសម្តែងរឿងបរិស័ទ និងទីអាស្រ័យ ដើម្បីឲ្យយល់ដោយងាយនូវព្រះសូត្រនេះ ដែលបង្ហាញពីអានុភាពនៃព្រះពុទ្ធ-គុណដែលសម្បូរណ៍ដោយអត្ថៈ និងព្យញ្ជនៈ ឧបមាដូចកំពង់ទឹក មានភូមិភាគដែលបរិសុទ្ធិស្អាត ពេញទៅដោយខ្សាច់ ដូចសរសៃកែវមុក្តាដែលពាសពេញ មានជណ្តើរកែវដែលល្អរលើប រចនាដោយផែនសិលាដែលបរិសុទ្ធិ ដើម្បីឲ្យធ្លាក់ចុះបានដោយសប្បាយកាន់ស្រះបោក្ខរណី ដែលមានទឹកមានរសល្អ ថ្លាស្អាត រុងរឿងដោយផ្កាឧប្បល និងផ្កាបទុមដូច្នោះ និងឧបមាដូចជណ្តើរដែលល្អរុងរឿងកើតពន្លឺនៃកែវមណី មានផែនក្តាររលោងទន់ល្មើយដែលធ្វើដោយភ្លុក ដែលវល្លិមាសចងទុកដើម្បីឲ្យឡើងបានដោយសប្បាយកាន់ប្រាសាទដ៏ប្រសើរ មានជញ្ជាំងដែលចែកទុកយ៉ាងល្អ ហែ-ហមដោយគ្រឿងដ៏វិចិត្រ ទាំងទ្រង់ទ្រាយក៏សោភិតខ្ពស់ត្រដែត ដូចជាប្រាថ្នាប៉ះពាល់ដល់ផ្លូវពួកផ្កាយ និងឧបមាដូចមហាវិហារ ដែលមានទ្វារវិសាល ជាប់យ៉ាងមាំល្អ រុងរឿងដោយរស្មីនៃមាស ប្រាក់ កែវមណី

កែវមុក្តា និងកែវប្រវាឡជាដើម ដើម្បីចូលបានដោយសប្បាយកាន់ផ្ទុះធំ ដែលល្អទៅដោយឥស្សរិយសម្បត្តិដ៏ឱឡារ មានការដើរឆ្ងាត់ឆ្ងៃងរបស់ពួកគេហជន អ្នកមានសំឡេងពីរោះ ចរចារីកករាយលាយនឹងសំឡេងប៉ះខ្ទប់គ្នានៃអាភរណៈ មានមាសដ៏វិចិត្រ និងគ្រឿងប្រដាប់ដើងជាដើម ដូច្នោះ ។

( ចប់ វណ្ណនាសេចក្តីរបស់ពាក្យថា និទាននៃព្រះសូត្រ )

## ពណ៌នាហេតុដែលតាំងព្រះសូត្រ

ឥឡូវនេះ ដល់លំដាប់ឱកាសដែលនឹងពណ៌នាព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់ លើកឡើងសម្ដែងដោយន័យមានជាដើមថា "ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃ ពោលតិះដៀលតថាគតក្ដី" ដូច្នេះ ។ ក៏ការពណ៌នាព្រះសូត្រនេះ កាលបានពិចារណាហេតុ ដែលទ្រង់តាំងព្រះសូត្រហើយទើបពោល រមែងជាក់ច្បាស់ ដូច្នោះ ខ្ញុំនឹងពិចារណាហេតុដែលទ្រង់តាំងព្រះសូត្រមុន ។

### ក៏ហេតុដែលទ្រង់តាំងព្រះសូត្រមាន ៤ ប្រការ គឺ

១. **អត្តជ្ឈាសយ** ប្រព្រឹត្តទៅតាមព្រះអជ្ឈាស្រ័យរបស់ព្រះអង្គ

២. **បរជ្ឈាសយ** ប្រព្រឹត្តទៅតាមអជ្ឈាស្រ័យរបស់អ្នកដទៃ

៣. **បុច្ឆាវសិក** ប្រព្រឹត្តទៅដោយអំណាចការសួរ

៤. **អដ្ឋុប្បត្តិក** ប្រព្រឹត្តទៅដោយហេតុដែលកើតឡើង

ក្នុងបណ្ដាហេតុ ៤ ប្រការនោះ ព្រះសូត្រពួកណាដែលអ្នកដទៃមិនបានទូលអារាធនា ព្រះមានព្រះភាគត្រាស់ទេសនាដោយព្រះអជ្ឈាស្រ័យរបស់ព្រះអង្គឯងតែម្យ៉ាង មានជាដើមយ៉ាងនេះ គឺ អាកង្ខេយ្យសូត្រ វត្ថសូត្រ មហាសតិប្បដ្ឋានសូត្រ មហាសឡាយតនវិភង្គសូត្រ អរិយ-វង្សសូត្រ ចំណែកសម្មប្បធានសូត្រ ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ

និងមគ្គ ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុដែលទ្រង់តាំងឡើង , ឲ្យប្រព្រឹត្តទៅតាមព្រះអធ្យាស្រ័យរបស់ព្រះអង្គ ។

មួយវិញទៀត ព្រះសូត្រពួកណា ដែលព្រះមានព្រះភាគត្រាស់ដោយអំណាចនៃអធ្យាស្រ័យរបស់អ្នកដទៃ សម្លឹងមើលអធ្យាស្រ័យ ការពេញចិត្ត ការចូលចិត្ត អភិនិហារ និងភាវៈដែលនឹងត្រាស់ដឹងបានរបស់ជនពួកដទៃ យ៉ាងនេះថា ធម៌ទាំងឡាយដែលធ្វើវិមុត្តិឲ្យចាស់ក្លារបស់រាហុលចាស់ក្លាហើយតើ បើដូច្នោះ គួរតែតថាគតទូន្មានរាហុលក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវខាងលើ ដូច្នេះ មានជាដើមយ៉ាងនេះ គឺ ចូឡរាហុ-លោវាទសូត្រ មហារាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រ ធាតុ-វិភង្គសូត្រ ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុទ្រង់ឲ្យប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់អ្នកដទៃ ។

មយ៉ាងទៀត ព្រះសូត្រពួកណាដែលពួកសត្វទាំងឡាយ មានជាដើមយ៉ាងនេះ គឺ បរិស័ទ ៤ វណ្ណៈ ៤ នាគ គ្រុឌ គន្ធព្វ អសុរ យក្ខស្តេចមហារាជ ទេវតាតាវត្តឹង្សជាដើម និងស្តេចមហាព្រហ្ម នាំគ្នាទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហា ដោយន័យមានជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ពោជ្ឈង្គៈ ពោជ្ឈង្គៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា នីវរណៈ នីវរណៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានខន្ធនេះ មាន ៥ ឬហ្ន៎ ក្នុងលោកនេះ អ្វីជា

ទ្រព្យដ៏ប្រសើររបស់បុរស កាលត្រូវសួរយ៉ាងនេះហើយ ព្រះមានព្រះភាគបានត្រាស់ទេសនា មានពោជ្ឈង្គសំយុត្តជាដើម ឬក៏ព្រះសូត្រសូម្បីដទៃពួកណា មានទេវតាសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត សក្កបញ្ហសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សាមញ្ញផលសូត្រ អាឡវកសូត្រ សូចិលោមសូត្រជាដើម ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុដែលទ្រង់តាំងឡើង ឲ្យប្រព្រឹត្តទៅដោយអំណាចការសួរ ។

មយ៉ាងទៀត ព្រះសូត្រទាំងនោះណា ដែលព្រះមានព្រះភាគទ្រង់អាស្រ័យហេតុការណ៍ដែលកើតឡើង ទើបត្រាស់ទេសនា មានជាដើមយ៉ាងនេះ គឺ ធម្មទាយាទសូត្រ ចូឡសីហនាទសូត្រ ចន្ទូបមសូត្រ បុត្តមំសូបមសូត្រ ទារុក្ខន្ធូបមសូត្រ អគ្គិក្ខន្ធូបមសូត្រ ផេណុបិណ្ឌូបមសូត្រ បារិឆត្តកូបមសូត្រ ព្រះសូត្រទាំងនោះឈ្មោះថា មានហេតុដែលទ្រង់តាំងឡើងឲ្យប្រព្រឹត្តទៅដោយមានហេតុកើតឡើង ។

ក្នុងបណ្តាហេតុដែលទ្រង់តាំងព្រះសូត្រ ៤ ប្រការ ដូចពណ៌នាមកនេះ ព្រហ្មជាលសូត្រនេះ មានហេតុដែលទ្រង់ឲ្យតាំងឡើង ប្រព្រឹត្តទៅដោយហេតុដែលកើតឡើង ។

ក៏ព្រហ្មជាលសូត្រនេះ ព្រះមានព្រះភាគទ្រង់តាំង ព្រោះហេតុដែលកើតឡើង ។ ព្រោះហេតុដែលកើតឡើងយ៉ាងណា ? ព្រោះការសរសើរនិងការតិះដៀល គឺ អាចារ្យតិះដៀលព្រះរតនត្រ័យ សិស្សសរសើរ

ព្រះរតនត្រ័យ ។ ព្រះមានព្រះភាគ ទ្រង់ជាទេសនាកោសល ទ្រង់ធ្វើការសរសើរ និងការតិះដៀលនេះ ឲ្យជាហេតុដែលកើតឡើង ដោយប្រការដូច្នេះ ហើយទ្រង់ផ្តើមទេសនាថា ម្នាលភិក្ខុទាំងឡាយ ពួកជនដទៃពោលតិះដៀលតថាគតក្តី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា មមំ ជាឆដ្ឋីវិភត្តិ សេចក្តីស្មើនឹង មម ។ វា សំពូជាវិកប្បត្ថៈ ។ បទថា បរេ បានដល់ ពួកសត្វដែលជាសត្រូវ ។ បទថា តត្រ សេចក្តីថា ក្នុងពួកអ្នកដែលពោលតិះដៀលទាំងនោះ ។ ដោយពាក្យថា ន អាឃាតោ សូម្បីថា ភិក្ខុទាំងនោះមិនមានសេចក្តីអាឃាតក៏ពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ការពារមិនឲ្យអកុសលកើតឡើងក្នុងឋានៈដូច្នេះ ដល់កុលបុត្រទាំង-ឡាយក្នុងកាលជាអនាគត ទើបបានទ្រង់តាំងទុកជាធម្មទំនៀម ។

ពាក្យថា សេចក្តីអាឃាត ក្នុងព្រះបាលីនោះមានវិគ្រោះថា ជាការថ្នាំងថ្នាក់នៃចិត្ត ។ ពាក្យនេះ ជាឈ្មោះនៃសេចក្តីក្រោធ ។

ពាក្យថា ការមិនត្រេកអរ មានវិគ្រោះថា ជាហេតុមិនឲ្យរីករាយចិត្ត គឺ មិនត្រេកអរ មិនសប្បាយចិត្ត ។ ពាក្យនេះ ជាឈ្មោះរបស់ទោមនស្ស ។

ពាក្យថា ការមិនអភិរម្យចិត្ត មានវិគ្រោះថា មិនត្រេកអរនូវប្រ-យោជន៍អនុគ្រោះដល់ខ្លួន មិនត្រេកអរនូវប្រយោជន៍អនុគ្រោះដល់អ្នក

ដទៃ ។ ពាក្យនេះ ជាឈ្មោះ របស់សេចក្តីក្រោធ ។

បណ្តាបទទាំងបីនេះ ព្រះមានព្រះភាគត្រាស់ខន្ធពីរ គឺ ត្រាស់សង្ខារក្ខន្ធ ដោយបទទាំងពីរ ( អាឃាត និងអនភិរទ្ធិ ) , ត្រាស់វេទនាខន្ធ ដោយបទតែមួយ ( អប្បច្ចយោ ) ដោយប្រការដូច្នេះ ។

ដោយអំណាចនៃខន្ធទាំងពីរនោះ បានត្រាស់បដិសេធការធ្វើនាទីនៃសម្បយុត្តធម៌ សូម្បីដ៏សេសតែម្យ៉ាង ។ លុះទ្រង់ហាមការឈឺចិត្តដោយន័យដំបូងយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងទោសក្នុងការឈឺចិត្តនោះ ដោយន័យទីពីរទើបត្រាស់ថា បើអ្នកទាំងឡាយនឹងក្រោធ ឬអាក់អន់ចិត្តចំពោះពួកសត្វទាំងនោះ សេចក្តីអន្តរាយនឹងកើតមាន ដល់អ្នកទាំងឡាយ ព្រោះហេតុនោះ ពិតប្រាកដ ដូច្នេះ ។

បណ្តាបទទាំងនោះ ត្រើនបទថា តត្រ ចេ តុម្ហេ អស្សថ សេចក្តីថា ប្រសិនបើអ្នកទាំងឡាយចង្អៀតចង្អល់ចិត្តដោយសេចក្តីក្រោធ នឹងគប្បីតូចចិត្តដោយសេចក្តីទោមនស្សក្នុងពួកជន ដែលពោលតិះដៀលទាំងនោះ ឬក្នុងពាក្យតិះដៀលនោះ ។

ត្រើនបទថា តុម្ហាញ្ញេវស្ស តេន អន្តរាយោ សេចក្តីថា អន្តរាយនឹងគប្បីមានដល់គុណធម៌ទាំងឡាយ មានបឋមឈានជាដើម ដោយសេចក្តីក្រោធនោះនិងដោយសេចក្តីអាក់អន់ចិត្តនោះ របស់អ្នកទាំងឡាយ នុ៎ះឯង ។

លុះទ្រង់សម្តែងទោសដោយន័យទីពីរយ៉ាងនេះហើយ ដើម្បីនឹងទ្រង់សម្តែងថា អ្នកដែលតូចចិត្ត ជាអ្នកមិនអាចសូម្បីក្នុងហេតុត្រឹមតែកំណត់សេចក្តីរបស់ពាក្យដោយន័យទីបី ទើបត្រាស់ថា អ្នកទាំងឡាយនឹងដឹងច្បាស់ដល់សុភាសិត ឬពាក្យអាក្រក់របស់សត្វដទៃដែរឬ" ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា បរេសំ សេចក្តីថា ក៏បុគ្គលចង់សេចក្តីក្រោធ រមែងមិនដឹងនូវទៅដល់សេចក្តីរបស់ពាក្យដែលជាសុភាសិត និងពាក្យដែលជាទុព្ភាសិត របស់ពួកជនណាមួយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក ឬមាតាបិតា ឬអ្នកដែលជាសត្រូវបានឡើយ ។ ដូចដែលត្រាស់ទុកថា ៖

**បុគ្គលក្រោធ រមែងមិនដឹងអត្ថ បុគ្គលក្រោធ រមែងមិនឃើញធម៌ កាលនរជនត្រូវសេចក្តីក្រោធគ្របសង្កត់ រមែងងងឹតឈឹង សេចក្តីក្រោធធ្វើឲ្យកើតសេចក្តីវិនាស សេចក្តីក្រោធធ្វើឲ្យចិត្តកម្រើក ជនមិនដឹងនូវសេចក្តីក្រោធ ដែលជាភ័យកើតក្នុងចិត្ត ដូច្នេះ ។**

ព្រះមានព្រះភាគត្រាទ្រង់ហាមការអាក់អន់ចិត្ត ព្រោះការតិះដៀលសូម្បីដោយប្រការទាំងពួងយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងអាការដែលគួរបដិបត្តិ ទើបបានត្រាស់ពាក្យមានជាអាទិថា ក្នុងពាក្យដែលគេពោលតិះដៀលនោះ ពាក្យដែលមិនពិត អ្នកទាំងឡាយគប្បីដោះស្រាយ

ឲ្យឃើញដោយសេចក្ដីមិនពិត ដូច្នេះ ។

ប្រជុំបទទាំងនោះ បទថា តត្រ តុម្ហេហិ សេចក្ដីថា ក្នុងពាក្យដែលគេពោលតិះដៀលនោះ អ្នកទាំងឡាយ ។ បទថា អភូតំ អភូតតោ និព្វេឋេតព្វំ សេចក្ដីថា ពាក្យណាដែលមិនពិត ពាក្យនោះ អ្នកទាំងឡាយគប្បីបែកដោយសេចក្ដីមិនពិតតែម្យ៉ាង ។ ដោះស្រាយដូចម្ដេច ? គប្បីដោះស្រាយដោយន័យមានជាអាទិថា ពាក្យនោះមិនពិត សូម្បីព្រោះហេតុនេះដូច្នេះ ។

ក្នុងសេចក្ដីនោះ មានពាក្យប្រកបដូចតទៅនេះ ៖

អ្នកទាំងឡាយបានស្ដាប់គេនិយាយថា សាស្ដារបស់ពួកលោក មិនមែនព្រះសព្វញ្ញូ ព្រះធម៌ដែលសាស្ដារបស់ពួកលោកពោលហើយអាក្រក់ ព្រះ-សង្ឃប្រតិបត្តិអាក្រក់ ដូច្នេះជាដើម មិនគួរស្ងៀមទេ តែគួរពោលប្រាប់ គេយ៉ាងនេះថា ពាក្យនោះមិនពិត សូម្បីព្រោះហេតុនេះ គឺ ពាក្យដែល ពួកលោកពោលនោះ មិនពិតសូម្បីព្រោះហេតុនេះ មិនពិតសូម្បីព្រោះ ហេតុនេះប្រាកដ ដោយហេតុនេះ សេចក្ដីនេះរកមិនមានក្នុងពួកយើងទេ ព្រះ-សាស្ដារបស់ពួកយើងជាព្រះសព្វញ្ញូពិត ព្រះធម៌ព្រះអង្គត្រាស់ល្អហើយ ព្រះសង្ឃប្រតិបត្តិល្អហើយ ក្នុងសេចក្ដីនោះ មានហេតុដូច្នេះៗ ។

ក្នុងបទទាំងនេះ បទទីពីរ គប្បីជ្រាបថា ជាវេវចនៈរបស់បទទីមួយ , បទទីបួន គប្បីជ្រាបថា ជាវេវចនៈរបស់បទទីបី ។ នឹងគួរធ្វើការដោះស្រាយក្នុងការតិះដៀលទាំងនោះ ដូច្នេះ មិនត្រូវដោះស្រាយ

ទូទៅ ។ តែកាលបើត្រូវគេពោលថា លោកជាអ្នកទ្រុស្តសីល អាចារ្យរបស់លោកជាអ្នកទ្រុស្តសីល វត្ថុនេះៗ លោកបានធ្វើហើយ អាចារ្យរបស់លោកបានធ្វើហើយ ដូច្នេះ ក៏អត់ធន់នៅស្ងៀមបាន រមែងជាទីខ្វាចញញើតដល់អ្នកពោលដូច្នោះ មិនត្រូវធ្វើសេចក្តីទាស់ចិត្ត ដោះស្រាយការតិះដៀល ចំណែកបុគ្គលដែលជេរដោយអក្កោសវត្ថុ ១០ ដោយ ន័យថា អាអូដ្ឋ អាគោជាដើម គួរប្រងើយចុះ ប្រើអធិវាសនខន្តិតែម្យ៉ាង ក្នុងបុគ្គលនោះ ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងលក្ខណៈរបស់អ្នករឹងមាំ ក្នុងឋានៈនៃការតិះដៀលយ៉ាងនេះហើយ ឥឡូវនេះ មានព្រះពុទ្ធបំណងនឹងទ្រង់សម្តែងលក្ខណៈរបស់អ្នករឹងមាំ ក្នុងឋានៈនៃការតិះដៀលយ៉ាងនេះហើយ ទើបត្រាស់ ព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកដទៃនឹងគប្បីពោលសរសើរតថាគត ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា បុគ្គលពួកដទៃ បានដល់ ពួកទេវតានិងមនុស្សទាំងឡាយដែលជ្រះថ្លាណាមួយ ។ **ភ្ញើតភ្ញើន** មានវិគ្រោះថាជាហេតុនាំមកនូវសេចក្តីត្រេកអរនៃចិត្ត ។ ពាក្យនេះជាឈ្មោះ របស់បីតិ ។

ភាវៈនៃចិត្តល្អ ឈ្មោះថា **សោមនស្ស** ។ ពាក្យថា សោមនស្សនេះ ជាឈ្មោះរបស់សេចក្តីសុខផ្លូវចិត្ត ។

ភាវៈនៃបុគ្គលអ្នករីករាយ ឈ្មោះថា សេចក្ដីរីករាយ សួរថា សេចក្ដីរីករាយនៃអ្វី ? ឆ្លើយថា នៃចិត្ត ។ ពាក្យថា សេចក្ដីរីករាយ នេះ ជាឈ្មោះរបស់បីតិដែលធ្វើឲ្យរីករាយ នាំមកនូវសេចក្ដីរាយមាយ ។

សួម្បីក្នុងទីនេះ ព្រះមានព្រះភាគ ក៏ត្រាស់សង្វារក្ខន្ធដោយបទទាំងពីរ , ត្រាស់វេទនាខន្ធដោយបទតែមួយ (សោមនស្ស) ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ គ្រាទ្រង់ហាមសេចក្ដីរីករាយ ដោយន័យទីមួយយ៉ាងនេះហើយ កាលទីងទ្រង់សម្ដែងទោសក្នុងសេចក្ដីរីករាយនោះ ដោយន័យទីពីរ ទើបបានត្រាស់ពាក្យមានជាដើមថា បើអ្នកទាំងឡាយក្ដៅក្រហាយ និងត្រេកអររីករាយ ក្នុងពាក្យសរសើរនោះ អន្តរាយនឹងកើតមានដល់អ្នកទាំងឡាយ ព្រោះហេតុនោះជាប្រាកដ ដូច្នេះ ។

សួម្បីក្នុងទីនេះ ក៏គប្បីជ្រាបសេចក្ដីថា បទថា តុម្ហាកញ្ញេវស្ស តេន អន្តរាយោ សេចក្ដីថា អន្តរាយនឹងគប្បីមានដល់គុណធម៌ទាំងឡាយ មានបឋមឈានជាដើមរបស់អ្នកទាំងឡាយនុ៎ះឯង ព្រោះសេចក្ដីរីករាយនោះ ។

សួរថា ក៏ព្រោះហេតុអ្វីទើបត្រាស់ដូច្នេះ ព្រះមានព្រះភាគត្រាស់សរសើរបីតិ និងសោមនស្សក្នុងព្រះរតនត្រ័យនោះ ដោយព្រះសូត្រច្រើនរយសូត្រ មានជាដើមយ៉ាងនេះថា អ្នកដែលប្រកាសថា ពុទ្ធោ ធម្មោ សង្ឃោ កើតបីតិទូទៅសព្វកាយ ក៏បីតិនោះប្រសើរជាងការបានជម្ពូទ្វីប

ទៅទៀត និងថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វទាំងនោះ ឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ដូច្នេះមិនមែនឬ ?

ឆ្លើយថា ត្រាស់សរសើរទុកពិត តែបីតិនិងសោមនស្សនោះ ទាក់ទងនឹងនេក្ខម្មៈ ក្នុងទីនេះទ្រង់ប្រាថ្នាបីតិនិងសោមនស្ស ដែលជាប់ដោយការគ្រប់គ្រងផ្ទះ ដូចកើតឡើងដល់ព្រះឆន្នៈ ដោយន័យថា ព្រះពុទ្ធ របស់យើង ព្រះធម៌របស់យើង ដូច្នេះជាដើម ។ ពោលថា បីតិនិងសោមនស្ស ដែលជាប់ដោយការគ្រប់គ្រងផ្ទះនេះ រមែងធ្វើអន្តរាយដល់ ការសម្រេចឈានជាដើម ។ ដោយហេតុនោះឯង សូម្បីព្រះឆន្នៈ ទើបមិនអាចនឹងធ្វើគុណវិសេសឲ្យសម្រេចបាន រហូតដល់វេលាដែលព្រះពុទ្ធ មិនទាន់ស្តេចបរិនិព្វាន ។ តែលោកបានត្រូវគំរាមដោយព្រហ្មទណ្ឌ ដែលទ្រង់បញ្ញត្តិទុកក្នុងបរិនិព្វានសម័យ លះបីតិនិងសោមនស្សនោះបានហើយ ទើបញ៉ាំងគុណវិសេសឲ្យកើតបាន ។ ព្រោះដូច្នោះ គប្បីជ្រាបថា បីតិនិងសោមនស្ស ដែលត្រាស់ហើយនេះ ព្រះមានព្រះភាគត្រាស់ សំដៅបីតិនិងសោមនស្ស ដែលធ្វើអន្តរាយប៉ុណ្ណោះ ។ ក៏បីតិនេះ ដែលកើតព្រមនឹងសេចក្តីលោភ ហើយសេចក្តីលោភ ក៏ដូចនឹងសេចក្តីក្រោធ នុ៎ះឯង ។ ដូចដែលត្រាស់ទុកថា ៖

*បុគ្គលលោក រមែងមិនដឹងអត្ថ បុគ្គលលោក រមែងមិន*

*ឃើញធម៌ កាលនរជនត្រូវសេចក្តីលោភគ្របសង្កត់ រមែង*

*ងងឹតឈឹង សេចក្តីលោភធ្វើឲ្យកើតសេចក្តីវិនាស សេចក្តី*

*លោភធ្វើឲ្យចិត្តចង់បាន ជនមិនដឹងនូវសេចក្តីលោភ ដែលជា*

*ភ័យកើតក្នុងចិត្ត ដូច្នេះ ។*

*ក៏វារៈទីបីសូម្បីមិនបានមកក្នុងទីនេះ ក៏គប្បីជ្រាបថា មកហើយដោយអត្ថដូចគ្នា ។ សូម្បីបុគ្គលលោភ ក៏មិនដឹងអត្ថដូចជាបុគ្គលក្រោធ ។*

*ក្នុងវារៈនៃការសម្តែងអាការដែលនឹងគប្បីបដិបត្តិ មានពាក្យប្រកបដូចតទៅនេះ ៖*

*អ្នកទាំងឡាយបានស្តាប់គេនិយាយថា ព្រះសាស្តារបស់អ្នកទាំងឡាយ ជាព្រះសព្វញ្ញូ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះអង្គត្រាស់ល្អហើយ ព្រះសង្ឃបដិបត្តិល្អហើយ ដូច្នេះជាដើម មិនគួរស្ងៀមទេ តែត្រូវបេ្តជ្ញាដោយពាក្យយ៉ាងនេះថា ពាក្យដែលពួកលោកនិយាយនោះ ជាពាក្យពិត ព្រោះហេតុនេះ ជាពាក្យពិត ព្រោះហេតុនេះ ព្រះ-មានព្រះភាគអង្គនោះ ជាព្រះអរហន្តដោយហេតុនេះ ជាព្រះសម្មាសម្ពុទ្ធ*

សូម្បីព្រោះហេតុនេះ ព្រះធម៌ ដែលព្រះអង្គត្រាស់ល្អហើយ សូម្បីព្រោះហេតុនេះ ជាព្រះធម៌ដែលអ្នកបដិបត្តិនឹងគប្បីឃើញដោយខ្លួនឯង សូម្បីព្រោះហេតុនេះ ព្រះសង្ឃបដិបត្តិល្អហើយសូម្បីព្រោះហេតុនេះ បដិបត្តិត្រង់សូម្បីហេតុនេះ ដូច្នេះ ។

សូម្បីត្រូវសួរថា លោកមានសីលឬ ? បើមានសីលក៏គប្បីពោលប្ដេជ្ញាថា យើងជាអ្នកមានសីល ដូច្នេះ សូម្បីត្រូវសួរថា លោកជាអ្នកបានបឋមឈានឬ ? ។ល។ លោកជាព្រះអរហន្តឬ ? ដូច្នេះ គប្បីពោលប្ដេជ្ញាដល់ភិក្ខុទាំងឡាយ ដែលជាសភាគៈគ្នាប៉ុណ្ណោះ ។ ក៏ការបដិបត្តិតាមដែលពោលមកនេះ រមែងជាការលះភាពជាអ្នកប្រាថ្នាលាមក និងរមែងជាការសម្ដែងសេចក្ដីដែលព្រះសាសនាមិនជាមោឃៈ ដូច្នេះ ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

## ពណ៌នាការផ្ដើមអនុសន្ធិ

[២] អនុសន្ធិផ្ដើមថា ម្នាលភិក្ខុទាំងឡាយ កាលបើបុថុជ្ជនពោលសរសើរតថាគត នឹងគប្បីពោលដោយប្រការណា នោះមានប្រមាណតិចតួចណាស់

ស្ដួចស្ដើងណាស់ បានត្រឹមតែសីល ដូច្នេះ ។

ព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមដោយបទ ពីរបទ គឺ ការសរសើរ និងការតិះដៀល ។ ក្នុងពីរប្រការនោះ ការតិះដៀលត្រូវបញ្ឈប់ទុកដូចភ្លើង លុះដល់ទឹកក៏រលត់ ដូច្នោះ ដូចក្នុងពាក្យនេះថា នុ៎ះមិនពិត ព្រោះហេតុនេះ នុ៎ះមិនពិត សូម្បីព្រោះហេតុនេះ ដូច្នេះ ។ ចំណែកការសរសើរ ក៏គួរពោលអះអាងដែលពិតថា ពិត ស្របតាមទៅយ៉ាងនេះតែម្យ៉ាងថា នុ៎ះពិត សូម្បីព្រោះហេតុនេះ ។ ក៏ពាក្យសរសើរនោះមានពីរយ៉ាង គឺ ពាក្យសរសើរ ដែលព្រហ្មទត្តមាណពពោលមួយយ៉ាង ពាក្យសរសើរដែលភិក្ខុសង្ឃប្រារព្ធដោយន័យមានជាដើមថា ម្នាលអាវុសោទាំងឡាយ គួរអស្ចារ្យណាស់តើហ្ន៎ ដូច្នេះ មួយយ៉ាង ។ ក្នុងពីរយ៉ាងនោះ ពាក្យសរសើរដែលភិក្ខុសង្ឃពោល ព្រះមានព្រះភាគទ្រង់នឹងសម្ដែងអនុសន្ធិ ក្នុងការប្រកាសសេចក្ដីសុញ្ញតខាងមុខ តែក្នុងទីនេះ មានពុទ្ធបំណងនឹងទ្រង់សម្ដែងអនុសន្ធិ ពាក្យសរសើរដែលព្រហ្មទត្តមាណពពោល ទើបទ្រង់ផ្ដើមទេសនាថា ម្នាលភិក្ខុទាំងឡាយ កាលបើបុថុជ្ជនពោលសរសើរតថាគត នឹងគប្បីពោលដោយប្រការណា នោះមានប្រមាណតិចណាស់ មានប្រមាណស្ដួចស្ដើង ត្រឹមតែសីលប៉ុណ្ណោះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **មានប្រមាណតិច** ជាឈ្មោះរបស់វត្ថុបន្តិចបន្តួច ពាក្យថា **មានប្រមាណស្តួចស្តើង** ជាវេវចនៈរបស់ពាក្យថា មានប្រមាណតិច ។ ខ្នាតហៅថា ប្រមាណ ។ ឈ្មោះថា មានប្រមាណតិច ព្រោះមានប្រមាណនោះតិច ។ ឈ្មោះថា មានប្រមាណស្តួចស្តើង ព្រោះមានប្រមាណទាប ។ ឈ្មោះថា **បានត្រឹមតែសីល** គឺ សីលនុ៎ះឯង ។ មានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក៏កាលបុថុជ្ជនពោលសរសើរ តថាគតសូម្បីធ្វើឧស្សាហ៍ថា យើងនឹងពោលសរសើរ នឹងគប្បីពោលសរសើរ ដោយប្រការណា នោះមានប្រមាណតិចណាស់ បានត្រឹមតែសីល ដូច្នេះ ។

ក្នុងសេចក្តីនោះ បើនឹងគប្បីមានពាក្យសួរថា ធម្មតាថា សីលនេះជាគ្រឿងប្រដាប់ដ៏ប្រសើររបស់ព្រះយោគី ដូចព្រះបោរាណាចារ្យទាំង-ឡាយពោលថា ៖

> ***សីលជាអលង្ការរបស់ព្រះយោគី សីលជាគ្រឿងប្រដាប់***
> ***របស់ព្រះយោគី ព្រះយោគីអ្នកតាក់តែងដោយសីលទាំងឡាយ***
> ***ដល់ភាពជាអ្នកប្រសើរ ក្នុងការប្រដាប់ ដូច្នេះ ។***

ម្យ៉ាងទៀត សូម្បីព្រះមានព្រះភាគក៏បានត្រាស់សីល ទ្រង់ធ្វើឲ្យធំក្រៃលែងតែម្យ៉ាង ក្នុងព្រះសូត្រ ច្រើនរយសូត្រ ដូចទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់

ជាទីពេញចិត្ត ជាទីគោរព និងជាទីសរសើររបស់ពួកមិត្តព្រហ្មចារីទាំង-ឡាយ ដូច្នេះ គប្បីធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ដូច្នេះ និងថា ៖

សត្វត្រដេវិច រក្សាពងយ៉ាងណា ចាមរីរក្សារោមកន្ទុយ
យ៉ាងណា អ្នកមានបុត្រតែមួយ រក្សាបុត្រអ្នកជាទីស្រឡាញ់
យ៉ាងណា បុគ្គលដែលមានភ្នែកតែម្ខាង រក្សាភ្នែកដែល
នៅសល់ម្ខាងទៀតយ៉ាងណា អ្នកទាំងឡាយចូរតាមរក្សា
សីលដូច្នោះឯង ចូរជាអ្នកមានសីលជាទីស្រឡាញ់ដោយល្អ
មានសេចក្ដីគោរពគ្រប់កាលចុះ ដូច្នេះ និងថា ក្លិនផ្កា
ឈើផ្សាយច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ ឬក្លិនខ្លឹម
ក្រឹស្នា និងក្លិនផ្កាម្លិះរួតក្ដី ក៏ផ្សាយច្រាសខ្យល់មិនបាន
រីឯក្លិនរបស់សប្បុរស រមែងផ្សាយទៅច្រាសខ្យល់បាន
ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។
ចន្ទន៍ក្ដី ក្រឹស្នាក្ដី ឧប្បលក្ដី ម្លិះក្ដី ក្លិន គឺ សីល
ប្រសើរជាង បណ្ដាគន្ធជាតទាំងនោះ អ្នកមានសីលបរិបូណ៌
មានប្រក្រតី នៅដោយសេចក្ដីមិនប្រមាទ រលាស់ផុត
ហើយ ព្រោះដឹងប្រពៃ ។
ភិក្ខុជាអ្នកមានបញ្ញា តាំងនៅក្នុងសីលហើយ ញុំាងចិត្តនិង
បញ្ញាឲ្យចម្រើន ជាអ្នកមានសេចក្ដីព្យាយាម មានបញ្ញារក្សា

**ខ្លួននោះ គប្បីគ្មារព្រៃនេះបាន ដូច្នេះ និងថា ៖**

ម្នាលភិក្ខុទាំងឡាយ ពីជគាម និងភូតគាមឯណានីមួយ រមែងដល់នូវការចម្រើនលូតលាស់ឡើងបាន ពីជគាម និងភូតគាមទាំងនោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ទើបដល់នូវការចម្រើនលូតលាស់ឡើងបាន មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល តាំងនៅក្នុងសីល ចម្រើនពោជ្ឈង្គៈ ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គៈ ៧ រមែងដល់ភាពជាធំ ឬការលូតលាស់ក្នុងធម៌ទាំងឡាយ ឧបមេយ្យនេះក៏ដូចគ្នាដូច្នេះ ព្រះសូត្រដទៃៗ ទៀតដ៏ច្រើន ក៏គប្បីឃើញយ៉ាងនេះ ព្រះមាន-ព្រះភាគបានត្រាស់សីល ទ្រង់ធ្វើឲ្យធំក្រៃលែងតែម្យ៉ាងក្នុងព្រះសូត្រច្រើនរយសូត្រយ៉ាងនេះ មិនមែនឬ ហេតុដូចម្ដេច ? ក្នុងទីនេះ ទើបត្រាស់សីលនោះថា មានប្រមាណតិចហ្ន៎ ?

ឆ្លើយថា ព្រោះទ្រង់ប្រៀបធៀបនឹងគុណធម៌ជាន់ខ្ពស់ ៗ ព្រោះថាសីលមិនដល់សមាធិ សមាធិមិនដល់បញ្ញា ដូច្នោះ ទ្រង់ប្រៀបធៀបគុណ-ធម៌ខ្ពស់ៗ ឡើងទៅ សីលនៅខាងក្រោម ទើបឈ្មោះថា មានប្រមាណទាប ។

## សីលមិនដល់សមាធិ តើដូចម្ដេច ?

គឺថា **ព្រះមានព្រះភាគ** ក្នុងឆ្នាំទី ៧ រាប់ពីត្រាស់ដឹង បានប្រថាប់លើរតនបល្ល័ង្ក ប្រមាណមួយយោជន៍ ក្នុងរតនមណ្ឌបប្រមាណ ១២

យោជន៍ ***ក្បែរគល់ដើមគណ្ឌាមព្រឹក្ស*** ជិតទ្វារនគរសាវត្ថី កាលទេវតាបាំងទិព្វស្វេតឆត្រប្រមាណ ៣ យោជន៍ ទ្រង់សម្ដែងយមកបាដិហារ្យញាំញីតិរ្ថិយ ទ្រង់សម្ដែងការកាន់យកជាចំណែកព្រះអង្គ ក្នុងបរិស័ទប្រមាណ ១២ យោជន៍ គឺ ទ្រង់សម្ដែងយមកប្បាដិហារ្យ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ផ្ការភ្លើងផ្សាយចេញចាកព្រះវរកាយចំណែកលើ ផ្ការទឹកហូរចេញចាកព្រះវរកាយចំណែកក្រោម ។ល។ ផ្ការភ្លើងផ្សាយចេញចាករណ្ដៅព្រះលោមាតែមួយរណ្ដៅៗ ផ្ការទឹកហូរចេញចាករណ្ដៅព្រះលោមាតែមួយរណ្ដៅ មានវណ្ណៈ ៦ ប្រការ ដូច្នេះ ។ ព្រះរស្មីមានវណ្ណៈដូចមាស ផ្សាយឡើងពីព្រះសរីរៈដែលមានវណ្ណៈដូចមាស នៃព្រះមានព្រះ-ភាគនោះ ទៅដរាបដល់ភវគ្គព្រហ្ម ដូចគ្នាក្នុងកាលតែមួយ ក្នុងម៉ឺនចក្រវាឡទាំងអស់ ។ រស្មីទីពីរ និងទីមួយ ជាគូៗ ផ្សាយចេញហាក់បីដូចជាក្នុងខណៈតែមួយគ្នា ។ ដែលឈ្មោះថា ចិត្តពីរដួងនឹងកើតក្នុងខណៈតែមួយ រមែងមិនមាន ។ តែព្រះមានព្រះភាគជាម្ចាស់ទាំងឡាយទ្រង់មានការបញ្ឈប់ភវង្គចិត្តរហ័ស និងទ្រង់មានភាពជំនាញ ដែលសន្សំទុកដោយអាការ ៥ យ៉ាង ដូច្នោះ ព្រះរស្មីទាំងនោះ ទើបប្រព្រឹត្តទៅហាក់បីដូចជាក្នុងខណៈតែមួយ ។ តែព្រះរស្មីនោះៗ នៅមានអាវជ្ជនៈបរិកម្ម និងអធិដ្ឋានផ្សេងគ្នាន៊ុះឯង គឺ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងក្នុងរស្មីពណ៌ខៀវ ទ្រង់ចូលឈានមាននីលកសិណជាអារម្មណ៍ មាន

ព្រះពុទ្ធបំណងក្នុងរស្មីពណ៌លឿង ក៏ទ្រង់ចូលឈានមានបីតកសិណជាអារម្មណ៍ មានព្រះពុទ្ធបំណងក្នុងរស្មីពណ៌ក្រហម និងពណ៌ស ក៏ទ្រង់ចូលឈានមានលោហិតកសិណជាអារម្មណ៍ ឱទាតកសិណជាអារម្មណ៍ មានព្រះពុទ្ធបំណងញុំាងផ្ការភ្លើងឲ្យកើត ក៏ទ្រង់ចូលឈានមានតេជោកសិណជាអារម្មណ៍ មានព្រះពុទ្ធប្រាថ្នាផ្ការទឹក ក៏ទ្រង់ចូលឈានមានអាបោកសិណជាអារម្មណ៍ ។ ព្រះសាស្ដាស្ដេចចង្ក្រម ព្រះពុទ្ធនិម្មិត ក៏ប្រថាប់ឈរ ឬប្រថាប់អង្គុយ ឬផ្ទំ បណ្ឌិតគប្បីអធិប្បាយឲ្យពិស្ដារគ្រប់បទ ដោយប្រការដូច្នេះ ។ ក្នុងសេចក្ដីនេះ កិច្ចនៃសីលសូម្បីតែម្យ៉ាង ក៏មិនមានគ្រប់យ៉ាងជាកិច្ច របស់សមាធិនោះឯង សីលមិនដល់សមាធិ យ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់បំពេញព្រះបារមីមកបួនអសង្ខេយ្យ ក្រៃលែងដោយសែនកប្បហើយ កាលដែលទ្រង់មានព្រះជន្មាយុបាន ២៩ វស្សា ស្ដេចចេញចាកទីប្រថាប់ ដែលជាទីនៅអាស្រ័យ ដែលជាសិរីនៃស្ដេចចក្រពត្តិ ទ្រង់ព្រះផ្នួសក្បែរមាត់ស្ទឹងអនោមា ទ្រង់បំពេញសេចក្ដីព្យាយាមរហូតដល់អស់ ៦ វស្សា លុះដល់ថ្ងៃវិសាខបុណ្ណមី តិថីពេញបូណ៌មីខែ ៦ សោយមធុបាយាសប្រកបដោយទិព្វឱជា ដែលនាងសុជាតានៅស្រុកឧរុវេលគាមថ្វាយ វេលាសាយណ្ហសម័យ ស្ដេចចូលទៅកាន់ពោធិមណ្ឌលស្ថានឯទិសទក្សិណ និងទិសឧត្តរ ទ្រង់ធ្វើប្រទក្សិណពោធិព្រឹក្ស ៣ ជុំ ហើយប្រថាប់ឈរក្នុងខាងទិសឦសាន ទ្រង់ក្រាលស្មៅ

ចម្រើនសមាធិបីថ្នាក់ ទ្រង់ធ្វើកម្មដ្ឋានមានមេត្តាជាអារម្មណ៍ ដែលប្រកប ដោយអង្គ ៤ ឲ្យជាខាងដើម ទ្រង់អធិដ្ឋានសេចក្តីព្យាយាម ស្តេចឡើង កាន់បល្ល័ង្កដ៏ប្រសើរ ១៤ ហត្ថ បែរព្រះបិដ្ឋិកាន់ដើមដើមពោធិ ដែលខ្ពស់ ៥០ ហត្ថ ហាក់ដូចដើមប្រាក់ដែលតាំងនៅលើតាំងមាស ក្នុងខាងលើមាន មែកពោធិបាំងការពារ ដូចឆត្រកែវមណី មានបណ្តូលពោធិស្រដៀងនឹង កែវប្រវាឡ ជ្រុះចុះលើចីវរដែលមានពណ៌ដូចមាស ពេលព្រះអាទិត្យជិត អស្តង្គត ទ្រង់កម្ចាត់មារ និងពលមារបានហើយ ទ្រង់សម្រេចបុព្វេនិវាសា-នុស្សតិញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម វេលា បច្ចូសសម័យជិតភ្លឺ ទ្រង់ញាំងព្រះញាណចុះក្នុងបច្ចយាការ ដែលព្រះ សព្វញ្ញុពុទ្ធទាំងឡាយទ្រង់សន្សំមក ញាំងចតុត្ថជ្ឈាន មានអានាបានស្សតិ ជាអារម្មណ៍ឲ្យកើត ទ្រង់ធ្វើចតុត្ថជ្ឈាននោះឲ្យជាបាទ ទ្រង់ចម្រើនវិប-ស្សនា ទ្រង់ញាំងកិលេសទាំងពួង អស់ទៅដោយមគ្គទី ៤ ដែលព្រះអង្គ ទ្រង់របផុតស្រេចហើយ តាមលំដាប់នៃមគ្គ ទ្រង់ចាក់ធ្លុះនូវព្រះពុទ្ធគុណ ទាំងពួង ។ នេះជាកិច្ចនៃបញ្ញារបស់ព្រះអង្គ ។ សមាធិមិនដល់បញ្ញា ដូច្នេះ ។

ក្នុងសេចក្តីនោះ ទឹកក្នុងដៃមិនដល់ទឹកក្នុងថាស ទឹកក្នុងថាសមិន ដល់ទឹកក្នុងឆ្នាំង ទឹកក្នុងឆ្នាំងមិនដល់ទឹកក្នុងក្អម ទឹកក្នុងក្អមមិនដល់ទឹក ក្នុងពាង ទឹកក្នុងពាងមិនដល់ទឹកក្នុងឆ្នាំងធំ ទឹកក្នុងឆ្នាំងធំមិនដល់ទឹក

ក្នុងអណ្តូង ទឹកក្នុងអណ្តូងមិនដល់ទឹកក្នុងប្រឡាយ ទឹកក្នុងប្រឡាយមិនដល់ទឹកក្នុងស្ទឹង ទឹកក្នុងស្ទឹងមិនដល់ទឹកក្នុងបញ្ចមហានទី ទឹកក្នុងបញ្ចមហានទីមិនដល់ទឹកក្នុងមហាសមុទ្រចក្រវាឡ ទឹកក្នុងមហាសមុទ្រចក្រវាឡមិនដល់ទឹកក្នុងមហាសមុទ្រជើងភ្នំសិនេរុ ។ ទឹកក្នុងដៃប្រៀបនឹងទឹកក្នុងថាស ក៏បន្តិចបន្តួច ។ល។ ទឹកក្នុងមហាសមុទ្រចក្រវាឡប្រៀបនឹងទឹកក្នុងមហាសមុទ្រជើងភ្នំសិនេរុ ក៏បន្តិចបន្តួច ដូច្នោះ ។ ទឹកក្នុងខាងដើមៗ សូម្បីច្រើន ក៏ជាទឹកបន្តិចបន្តួច ដោយប្រៀបនឹងទឹកដែលច្រើនតៗ ទៅ ដោយប្រការដូច្នេះ សេចក្តីនេះមានឧបមាយ៉ាងណា សីលក្នុងខាងក្រោមក៏មានឧបមេយ្យដូច្នោះឯង គប្បីជ្រាបថា មានប្រមាណតិច មានប្រមាណស្តួចស្តើង ដោយប្រៀបនឹងគុណក្នុងខាងលើៗ ។ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលបើពោលសរសើរតថាគត នឹងគប្បីពោលដោយប្រការណា ការពោលនោះមានប្រមាណតិច មានប្រមាណស្តួចស្តើង បានត្រឹមតែសីលប៉ុណ្ណោះ ដូច្នេះ ។

## អធិប្បាយពាក្យថា បុថុជ្ជន

ក្នុងពាក្យថា យេន បុថុជ្ជនោ នេះ មានពាក្យអធិប្បាយដូចតទៅនេះ ៖

ព្រះពុទ្ធជាផៅពង្សដូចព្រះអាទិត្យ ទ្រង់ត្រាស់ថា ៖

បុថុជ្ជនមាន ២ ពួក គឺ **អន្ធបុថុជ្ជន** ១ **កល្យាណបុថុជ្ជន** ១ ដូច្នេះ ។

ក្នុងបុថុជ្ជនទាំង ២ នោះ បុគ្គលអ្នកមិនមានការរៀន ការជេញដោល សាកសួរ ការស្ដាប់ ការចងចាំ និងការពិចារណាក្នុងខន្ធ ធាតុ និងអាយតនៈជាដើម នេះឈ្មោះថា **អន្ធបុថុជ្ជន** , បុគ្គលអ្នកមានកិច្ចទាំងនោះ ឈ្មោះថា **កល្យាណបុថុជ្ជន** ។ មួយវិញទៀត បុថុជ្ជនទាំង ២ នេះ

**ឈ្មោះថា បុថុជ្ជន ដោយហេតុទាំងឡាយ មានការញុំាង**
**កិលេសដ៏ច្រើនឲ្យកើតជាដើម ជននេះជាពួកមួយ ព្រោះ**
**ធ្លាក់ចុះខាងក្នុងចំណែកបុថុជ្ជន ដូច្នេះ ។**

ពិតហើយ បុថុជ្ជននោះ ឈ្មោះថា **បុថុជ្ជន** ដោយហេតុជាដើមថា ញុំាងកិលេសជាដើម មានប្រការផ្សេងៗ ជាច្រើនឲ្យកើត ។ ដូចព្រះធម្មសេនាបតីសារីបុត្តត្ថេរ ពោលទុកថា ឈ្មោះថា **បុថុជ្ជន** ព្រោះញុំាងកិលេសដ៏ច្រើនឲ្យកើត ។ ព្រោះកម្ចាត់សក្កាយទិដ្ឋិមិនបាន ។ ព្រោះចំណែកច្រើនធ្លាប់តែងើយមើលមុខគ្រូទាំងឡាយ ។ ព្រោះចំណែកច្រើនចេញចាកគតិទាំងពួងមិនបាន ។ ព្រោះចំណែកច្រើនសាងបុណ្យបាបផ្សេងៗ ។ ព្រោះដោយច្រើនត្រូវឱឃៈផ្សេងៗ បន្សាត់ទៅ ត្រូវសេចក្ដីក្ដៅ

ក្រហាយ ធ្វើឲ្យក្តៅក្រហាយ តម្រេក ពេញចិត្ត ស្រឡាញ់ ញ៉ាម ជាប់ចិត្ត ជ្រប់ងប់ ជាប់ចំពាក់ ក្នុងកាមគុណ ៥ ។ ព្រោះត្រូវនីវរណៈ ៥ រាំង រួបរឹត គ្របសង្កត់ សន្ធប់ បិទបាំង គ្របសង្កត់ ។ ព្រោះធ្លាក់ចុះខាងក្នុងជន ចំនួនច្រើន ដែលរាប់មិនបាន សុទ្ធតែបែរមុខគេចចេញពីអរិយធម៌ មាន តែប្រព្រឹត្តធម៌អាក្រក់ថោកទាប ដូច្នេះក៏មាន ។ ព្រោះជននេះជា ពួកមួយ គឺ ដល់ការរាប់ថា ជាជនផ្សេងៗ តែម្យ៉ាង មិនជាប់ទាក់ទងនឹងអរិយជន ទាំងឡាយអ្នកប្រកបដោយគុណ មានសីលនិងសុតៈជាដើម ដូច្នេះក៏មាន ។

## ពាក្យថា តថាគត មានន័យ ៨ យ៉ាង

បទថា តថាគតស្ស សេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ដោយហេតុ ៨ ប្រការ គឺ ៖

១. ព្រោះស្តេចមកយ៉ាងនោះ

២. ព្រោះស្តេចទៅយ៉ាងនោះ

៣. ព្រោះស្តេចមកកាន់លក្ខណៈដែលពិត

៤. ព្រោះត្រាស់ដឹងធម៌ដែលពិតប្រាកដ តាមសេចក្តីពិត

៥. ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត

៦. ព្រោះមានព្រះវាចាដែលពិត

៧. ព្រោះទ្រង់ធ្វើខ្លួនឯង និងឲ្យអ្នកដទៃធ្វើ

៨. ព្រោះទ្រង់គ្របសង្កត់

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះស្តេចមកយ៉ាងនោះ តើដូចម្តេច ?**

ដូចព្រះសម្មាសម្ពុទ្ធអង្គមុនៗ ទ្រង់ខ្វល់ខ្វាយដើម្បីប្រយោជន៍ សេចក្តីចម្រើនដល់លោកទាំងពួង ស្តេចមកហើយ ដូចព្រះមានព្រះភាគព្រះវិបស្សី ស្តេចមក ដូចព្រះមានព្រះភាគព្រះសិខីស្តេចមក ដូចព្រះមានព្រះភាគព្រះវេស្សភូស្តេចមក ដូចព្រះមានព្រះភាគព្រះកកុសន្ធៈស្តេចមក ដូចព្រះមានព្រះភាគព្រះកោនាគមនៈស្តេចមក ដូចព្រះមានព្រះភាគព្រះកស្សបៈស្តេចមក សេចក្តីនេះ មានអធិប្បាយដូចម្តេច ? មានអធិប្បាយថា ព្រះមាន-ព្រះភាគទាំងនោះ ស្តេចមកដោយអភិនិហារណា ព្រះមានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមកដោយអភិនិហារនោះដូចគ្នា ។

មួយយ៉ាងទៀត ព្រះមានព្រះភាគព្រះវិបស្សី ។ល។ ព្រះមានព្រះភាគព្រះកស្សបៈ ទ្រង់បំពេញទានបារមី ទ្រង់បំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ទ្រង់បំពេញបារមី ៣០ ទសទាំងនេះ គឺ បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ ប្រការ គឺ បរិច្ចាគអវយវៈ បរិច្ចាគទ្រព្យ បរិច្ចាគកូន បរិច្ចាគប្រពន្ធ បរិច្ចាគជីវិត

ទ្រង់បំពេញបុព្វប្រយោគ បុព្វចរិយា ការសម្ដែងធម៌ និងញាតត្ថចរិយាជាដើម ទ្រង់ដល់ទីបំផុតនៃពុទ្ធចរិយា ស្ដេចមកហើយយ៉ាងណា ព្រះមានព្រះភាគរបស់យើងទាំងឡាយ ក៏ស្ដេចមកដូចយ៉ាងនោះ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគព្រះវិបស្សី ។ល។ ព្រះមានព្រះភាគព្រះកស្សបៈ ទ្រង់ចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ស្ដេចមកហើយយ៉ាងណា ព្រះមានព្រះភាគជាម្ចាស់របស់យើងទាំងឡាយ ក៏ស្ដេចមកដូចយ៉ាងនោះ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកយ៉ាងនោះ យ៉ាងនេះឯង ។

**ព្រះមុនីទាំងឡាយ មានព្រះវិបស្សីជាដើម**
**ស្ដេចមកកាន់ភាពជាព្រះសព្វញ្ញូ ក្នុងលោក**
**នេះយ៉ាងណា សូម្បីព្រះសក្យមុនីអង្គនេះ ក៏**
**ស្ដេចមកដូចយ៉ាងនោះ ដោយហេតុនោះ ព្រះ**
**ដ៏មានចក្ខុ ទើបទ្រង់ព្រះនាមថា តថាគត**
**ដូច្នេះ ។**

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចមកយ៉ាងនោះ ដូច្នេះ ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះស្ដេចទៅយ៉ាង**

នោះ ដូចម្ដេច ?

ដូចព្រះមានព្រះភាគព្រះវិបស្សី ប្រសូតិក្នុងមួយរំពេច ក៏ស្ដេចទៅ ។ល។ ដូចជាព្រះមានព្រះភាគព្រះកស្សបៈ ប្រសូតិក្នុងមួយរំពេចនោះ ក៏ស្ដេចទៅ ព្រះមានព្រះភាគនោះ ស្ដេចទៅយ៉ាងណា ? ពិតហើយ ព្រះមានព្រះភាគនោះ ប្រសូតិក្នុងមួយរំពេចនោះឯង ប្រថាប់ឈរលើប្រថពីដោយព្រះយុគលបាទដ៏រាបស្មើ បែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ ស្ដេចទៅដោយព្រះបាទ ៧ ជំហាន ដូចព្រះបាលីដែលត្រាស់ទុកថា ៖

> ម្នាលអានន្ទ ព្រះពោធិសត្វប្រសូតិភ្លាម ក៏ប្រថាប់ឈរដោយព្រះយុគលបាទដ៏រាបស្មើ ផ្ទោះព្រះភក្ត្រទៅកាន់ទិសឧត្តរ ស្ដេចទ្រង់យាងទៅដោយព្រះបាទ ៧ ជំហាន កាលស្ដេចមហាព្រហ្មបាំងស្វេតឆត្រ ទ្រង់រមិលមើលនូវទិសទាំងពួងផង ទ្រង់បន្លឺនូវអាសភិវាចាថា យើងជាបុគ្គលខ្ពង់ខ្ពស់ក្នុងលោក យើងជាបុគ្គលធំបំផុតក្នុងលោក យើងជាបុគ្គលប្រសើរបំផុតក្នុងលោក នេះជា កំណើតពេលនេះ ជាកំណើតចុងក្រោយ ឥឡូវនេះ ភពថ្មីមិនមានតទៅទៀតឡើយ ដូច្នេះ ។

និងការយាងទៅរបស់ព្រះមានព្រះភាគនោះ ក៏បានជាអាការដែលពិត មិនប្រែប្រួល ដោយភាពជាបុព្វនិមិត្តនៃការសម្រេចគុណវិសេស

ច្រើនប្រការ គឺ ការដែលព្រះអង្គប្រសូតិភ្លាម ទ្រង់ប្រថាប់ឈរដោយព្រះយុគលបាទដ៏រាបស្មើ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ព្រះអង្គ ។ មួយវិញទៀត ការដែលព្រះអង្គបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការបានលោកុត្តរធម៌ទាំងពួង ។ ការយាងព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺ ពោជ្ឈង្គៈ ៧ ប្រការ ។ មួយវិញទៀត ការលើកផ្លិតចាមរឡើង ដែលពោលទុកក្នុងពាក្យនេះថា ផ្លិតចាមរទាំងឡាយ មានដងជាវិការនៃមាសសំយុងចុះ នេះជាបុព្វនិមិត្តនៃការញាំញីតិរ្ថិយទាំងពួង ។ មួយវិញទៀត ការបាំងស្វេតច្ឆត្រថ្វាយ ជាបុព្វ-និមិត្តនៃការបានស្វេតច្ឆត្រដ៏បរិសុទ្ធិ ប្រសើរ គឺ ព្រះអរហត្តវិមុត្តិធម៌ ។ ការប្រថាប់ឈរលើជំហានទី ៧ ទតក្រឡេកមើលទិសទូទៅ ជាបុព្វនិមិត្តនៃការបានព្រះអនាវរណញ្ញាណ គឺ ភាពជាព្រះសព្វញ្ញូ ។ ការបន្លឺអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសព្រះធម្មចក្រដ៏ប្រសើរ ដែលនរណាៗផ្លាស់ប្តូរមិនបាន ។ សូម្បីព្រះមានព្រះភាគអង្គនេះ ក៏ស្តេចទៅយ៉ាងនោះនិងការស្តេចទៅរបស់ព្រះអង្គនោះ ក៏បានជាអាការដែលពិត មិនប្រែប្រួលដែលជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសទាំងនោះឯង ដោយហេតុនោះ ព្រះបោរាណាចារ្យទាំងឡាយទើបពោលថា ៖

**ព្រះគវម្បតីគោតមនោះ កាលដែលប្រសូតិហើយភ្លាម ទ្រង់**

**ក៏សម្ទុស្សផែនដីដោយព្រះយុគលបាទដ៏រាបស្មើ ស្តេចយាង**

ទៅបាន ៧ ជំហាន ឯពពួកទេវតាក៏បាំងស្វេតឆត្រ ព្រះគោតមនោះ លុះស្តេចទៅបាន ៧ ជំហាន ក៏ទត ព្រះនេត្រ ក្នុងទិសជុំវិញស្មើគ្នា ទ្រង់បន្លឺព្រះសូរសៀង ប្រកបដោយអង្គ ៨ ប្រការ ដូចរាជសីហ៍ឈរលើកំពូល ភ្នំដូច្នោះ ដូច្នេះ ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** សូម្បីព្រោះស្តេចទៅ យ៉ាងនោះ ដូច្នេះ ។

ន័យមួយទៀត ដូចព្រះមានព្រះភាគព្រះវិបស្សីស្តេចទៅហើយ ។ល។ ព្រះមានព្រះភាគព្រះកស្សបៈស្តេចទៅហើយ យ៉ាងណា សូម្បីព្រះមាន-ព្រះភាគអង្គនេះ ក៏ដូច្នោះ ទ្រង់លះកាមច្ឆន្ទៈដោយនេក្ខម្មៈ ស្តេចទៅ ហើយ ទ្រង់លះព្យាបាទដោយការមិនព្យាបាទ ទ្រង់លះថីនមិទ្ធៈ ដោយ អាលោកសញ្ញា ទ្រង់លះឧទ្ធច្ចកុក្កុច្ចៈដោយការមិនរាយមាយ ទ្រង់លះ វិចិកិច្ឆាដោយការកំណត់ធម៌ ស្តេចទៅហើយ ទ្រង់ទម្លាយអវិជ្ជាដោយ ព្រះប្រាជ្ញាញាណ ទ្រង់បន្ទោបង់អរតិដោយបាមោជ្ជៈ ទ្រង់បើកទ្វារ គឺ នីវរណៈដោយបឋមជ្ឈាន ទ្រង់ញ៉ាំងវិតក្កៈ និងវិចារៈឲ្យស្ងប់ដោយ ទុតិយជ្ឈាន ទ្រង់នឿយណាយបីតិដោយតតិយជ្ឈាន ទ្រង់លះសុខ និង ទុក្ខដោយចតុត្ថជ្ឈាន ទ្រង់ឈានកន្លងរូបសញ្ញា បដិឃសញ្ញា និងនា-នត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ ទ្រង់ឈានកន្លងអាកាសា-

នញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ , ទ្រង់ឈានកន្លង វិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ , ទ្រង់ឈាន កន្លងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ , ស្តេចទៅហើយ ទ្រង់លះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា , ទ្រង់លះ សុខសញ្ញា ដោយទុក្ខានុបស្សនា , ទ្រង់លះអត្តសញ្ញា ដោយអនត្តានុ- បស្សនា , ទ្រង់លះសេចក្តីត្រេកត្រអាល ដោយនិព្វិទានុបស្សនា , ទ្រង់លះ តម្រេក ដោយវិរាគានុបស្សនា , ទ្រង់លះសមុទ័យ ដោយនិរោធានុ- បស្សនា , ទ្រង់លះអាទានៈ ដោយបដិនិស្សគ្គានុបស្សនា , ទ្រង់លះ ឃនសញ្ញា ដោយខយានុបស្សនា , ទ្រង់លះអាយូហនៈ ដោយវយានុ- បស្សនា , ទ្រង់លះធុវសញ្ញា ដោយវិបរិណាមានុបស្សនា , ទ្រង់លះ និមិត្តសញ្ញា ដោយអនិមិត្តានុបស្សនា , ទ្រង់លះបណិធិ ដោយអប្បណិ- ហិតានុបស្សនា , ទ្រង់លះអភិនិវេស ដោយសុញ្ញតានុបស្សនា , ទ្រង់លះ សារាទានាភិនិវេស ដោយអធិប្បញ្ញាធម្មវិបស្សនា , ទ្រង់លះសម្មោ- ហាភិនិវេស ដោយយថាភូតញ្ញាណទស្សនៈ , ទ្រង់លះអាលយាភិនិវេស ដោយអាទីនវានុបស្សនា , ទ្រង់លះអប្បដិសង្ខា ដោយបដិសង្ខានុបស្សនា , ទ្រង់លះសំយោគាភិនិវេស ដោយវិវដ្តានុបស្សនា , ទ្រង់កាច់បំបាក់ កិលេសដែលតាំងនៅរួមនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ , ទ្រង់លះ

កិលេសគ្រោតគ្រាត ដោយសកទាគាមិមគ្គ , ទ្រង់លះកិលេសយ៉ាងល្អិត ដោយអនាគាមិមគ្គ , ទ្រង់កាត់កិលេសទាំង អស់បាន ដោយអរហត្តមគ្គ ស្តេចទៅហើយ ។ ព្រះមានព្រះភាគ ទ្រង់ ព្រះនាមថា **តថាគត** ព្រោះស្តេចទៅយ៉ាងនោះ ដូច្នេះ ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះស្តេចមកកាន់ លក្ខណៈដែលពិត ដូចម្តេច ?**

បឋវីធាតុមានភាពរឹងជាលក្ខណៈ មានលក្ខណៈពិតមិនប្រែប្រួល ,អាបោធាតុមានការហូរសើមជាលក្ខណៈ , តេជោធាតុមានភាពក្តៅជា លក្ខណៈ , វាយោធាតុមានភាពតឹង ញ័រជាលក្ខណៈ , អាកាសធាតុមាន ការប៉ះពាល់មិនបានជាលក្ខណៈ , វិញ្ញាណធាតុមានការដឹងអារម្មណ៍ជា លក្ខណៈ , រូបមានបែកធ្លាយជាលក្ខណៈ , វេទនាមានការសោយអារម្មណ៍ ជាលក្ខណៈ , សញ្ញាមានការចាំអារម្មណ៍បានជាលក្ខណៈ , សង្ខារមានការ ប្រជុំតាក់តែងចិត្តជាលក្ខណៈ , វិញ្ញាណមានការដឹងច្បាស់ជាលក្ខណៈ ។ វិតក្កៈមានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ , វិចារៈ មានការតាមស្ទាបអង្អែល (ពិចារណា) អារម្មណ៍ជាលក្ខណៈ , បីតិមាន ការផ្សាយទៅជាលក្ខណៈ , សុខមានការសប្បាយជាលក្ខណៈ , ឯកគ្គ- តាចិត្តមានការមិនរវើរវាយជាលក្ខណៈ , ផស្សៈមានការប៉ះខ្ទប់អារម្មណ៍ ជាលក្ខណៈ ។

សទ្ធិន្ទ្រិយមានការបង្អោនចិត្តជឿជាលក្ខណៈ , វីរិយិន្ទ្រិយមានការផ្គងជាលក្ខណៈ , សតិន្ទ្រិយមានការប្រុងជាលក្ខណៈ , សមាធិន្ទ្រិយមានសេចក្តីមិនរវើរវាយជាលក្ខណៈ , បញ្ញិន្ទ្រិយមានការដឹងអារម្មណ៍ផ្សេងៗជាលក្ខណៈ ។

សទ្ធាពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ដែលជាទីតាំងនៃការមិនជឿជាលក្ខណៈ , វីរិយពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ដែលជាទីតាំងនៃសេចក្តីខ្ជិលច្រអូសជាលក្ខណៈ , សតិពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ដែលជាទីតាំងនៃការភ័ន្តច្រឡំជាលក្ខណៈ , សមាធិពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ដែលជាទីតាំងនៃការរវើរវាយជាលក្ខណៈ ។ បញ្ញាពលៈ មានការមិនញាប់ញ័រក្នុងអារម្មណ៍ ដែលជាទីតាំងនៃអវិជ្ជាជាលក្ខណៈ ។

សតិសម្ពោជ្ឈង្គៈ មានឧបដ្ឋានៈ (ការប្រុង) ជាលក្ខណៈ , ធម្មវិចយសម្ពោជ្ឈង្គៈ មានបវិចយៈ (ការជ្រើសរើស) ជាលក្ខណៈ , វីរិយសម្ពោជ្ឈង្គៈ មានបគ្គហៈ (ការផ្គង) ជាលក្ខណៈ , បីតិសម្ពោជ្ឈង្គៈ មានផរណៈ (ការផ្សាយទៅ) ជាលក្ខណៈ , បស្សទ្ធិសម្ពោជ្ឈង្គៈ មានឧបសមៈ (សេចក្តីស្ងប់) ជាលក្ខណៈ , សមាធិសម្ពោជ្ឈង្គៈ មានអវិក្ខេបៈ (សេចក្តីមិនរាយមាយ) ជាលក្ខណៈ , ឧបេក្ខាសម្ពោជ្ឈង្គៈ មានបដិសង្ខារៈ

(ការសម្ងំចំពោះ) ជាលក្ខណៈ ។

សម្មាទិដ្ឋិ មានការឃើញជាលក្ខណៈ , សម្មាសង្កប្បៈ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ , សម្មាវាចា មានការកំណត់កាន់យកជាលក្ខណៈ , សម្មាកម្មន្តៈ មានការតាំងឡើងជាលក្ខណៈ , សម្មាអាជីវៈ មានសេចក្តីបរិសុទ្ធិផូរផង់ជាលក្ខណៈ , សម្មាវាយាមៈ មានការផ្គងជាលក្ខណៈ , សម្មាសតិ មានការប្រុងជាលក្ខណៈ , សម្មា-សមាធិ មានសេចក្តីមិនរវើរវាយជាលក្ខណៈ ។

អវិជ្ជា មានការមិនដឹងជាលក្ខណៈ , សង្ខារ មានសេចក្តីតាក់តែងជាលក្ខណៈ , វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ , នាម មានការបង្អោនទៅកាន់អារម្មណ៍ជាលក្ខណៈ , រូប មានការបែកធ្លាយ ប្រែ-ប្រួលជាលក្ខណៈ , សឡាយតនៈ មានការបន្តជាលក្ខណៈ , ផស្សៈ មានការប៉ះផ្ទប់អារម្មណ៍ជាលក្ខណៈ , វេទនា មានការសោយអារម្មណ៍ ជាលក្ខណៈ , តណ្ហា មានសភាពជាហេតុជាលក្ខណៈ , ឧបាទាន មាន ការប្រកាន់មាំជាលក្ខណៈ , ភព មានការកពូនឡើងជាលក្ខណៈ , ជាតិ មានការកើតឡើងជាលក្ខណៈ , ជរា មានការទ្រុឌទ្រោម ជាលក្ខណៈ , មរណៈ មានការចុតិជាលក្ខណៈ ។

ធាតុ មានសភាពសោះសូន្យទទេជាលក្ខណៈ , អាយតនៈ មានការបន្តជាលក្ខណៈ, សតិប្បដ្ឋាន មានការប្រុងជាលក្ខណៈ , សម្មប្បធាន

មានការចាប់ផ្តើមជាលក្ខណៈ , ឥទ្ធិបាទ មានសេចក្តីសម្រេចជា លក្ខណៈ , ឥន្ទ្រិយ មានភាពជាធំក្រៃលែងជាលក្ខណៈ ។

ពលៈ មានសេចក្តីមិនញាប់ញ័រជាលក្ខណៈ , ពោជ្ឈង្គៈ មានការនាំចេញចាកទុក្ខជាលក្ខណៈ , មគ្គ មានសភាពជាហេតុជាលក្ខណៈ , សច្ចៈ មានសភាពពិតជាលក្ខណៈ , សមថៈ មានសភាពមិនរវើរវាយជាលក្ខណៈ , វិបស្សនា មានការតាមពិចារណាឃើញជាលក្ខណៈ , សមថៈ និងវិបស្សនា មានរសតែមួយជាលក្ខណៈ , ធម៌ដែលស្របគ្នាគូគ្នា មានការមិនផុយគ្នាជាលក្ខណៈ ។ សីលវិសុទ្ធិ មានការសង្រួមជាលក្ខណៈ , ចិត្តវិសុទ្ធិ មានសេចក្តីមិនរវើរវាយជាលក្ខណៈ , ទិដ្ឋិ-វិសុទ្ធិ មានការឃើញជាលក្ខណៈ , ខយញ្ញាណ មានការកាត់ផ្តាច់ជាលក្ខណៈ , អនុប្បាទញ្ញាណ មានការរម្ងាប់ជាលក្ខណៈ , ឆន្ទៈ មានមូលជាលក្ខណៈ , មនសិការៈ មានការតាំងឡើងជាលក្ខណៈ , ផស្សៈ មានការប្រជុំជាលក្ខណៈ , វេទនា មានការជ្រួតជ្រាបទៅក្នុងអារម្មណ៍ជាលក្ខណៈ , សមាធិ មានសភាពជាប្រមុខជាលក្ខណៈ , សតិ មានភាពជាធំជាលក្ខណៈ ។

បញ្ញា មានភាពប្រសើរជាងនោះជាលក្ខណៈ , វិមុត្តិ មានសារៈជាលក្ខណៈ , ព្រះនិព្វានដែលឈានចុះកាន់អមតៈ មានបរិយោសានជាលក្ខណៈតែម្យ៉ាង ជាលក្ខណៈពិត មិនប្រែប្រួល ។

ព្រះមានព្រះភាគស្តេចមកកាន់លក្ខណៈដែលពិត ដោយព្រះញាណគតិ គឺ ទ្រង់សម្រេច ទ្រង់សម្រេចដោយលំដាប់មិនក្លាំងក្លាត់យ៉ាងនេះ ហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកកាន់លក្ខណៈដែលពិត ជាយ៉ាងនេះ ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្តីពិត ដូចម្តេច ?**

អរិយសច្ច ៤ ឈ្មោះថា ធម៌ដែលពិត ដូចទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ ទាំងនេះ ជាធម៌ពិត មិនប្រែប្រួល មិនក្លាយទៅជាយ៉ាងដទៃឡើយ ។ អរិយសច្ច ៤ គឺអ្វីខ្លះ ? ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ ដូច្នេះ ជាធម៌ពិត មិនប្រែប្រួល មិនក្លាយទៅជាយ៉ាងដទៃឡើយ ដូច្នេះ ។

គប្បីជ្រាបសេចក្តីពិស្តារតទៅ ។ ព្រះមានព្រះភាគ ត្រាស់ដឹងអរិយសច្ច ៤ ទាំងនោះ ហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត ក៏ **គត** សព្ទក្នុងទីនេះ មានន័យថា ត្រាស់ដឹង ។

ម្យ៉ាងទៀត ជរា និងមរណៈ ដែលកើតពីជាតិជាបច្ច័យ មានសេចក្តីថា **ប្រាកដ** ជាសេចក្តីដែលពិត មិនប្រែប្រួល មិនក្លាយជាយ៉ាងដទៃ ។ល។ សង្ខារដែលកើតពីអវិជ្ជាជាបច្ច័យ មានសេចក្តីថា ប្រាកដ ជា

សេចក្ដីដែលពិត មិនប្រែប្រួល មិនក្លាយជាយ៉ាងដទៃ ។ល។ អវិជ្ជាមានសេចក្ដីថា ជាបច្ច័យដល់សង្ខារ សង្ខារមានសេចក្ដីថា ជាបច្ច័យដល់វិញ្ញាណ ។ល។ ជាតិមានសេចក្ដីថា ជាបច្ច័យដល់ជរា និងមរណៈ ជាសេចក្ដីដែលពិត មិនប្រែប្រួល មិនក្លាយជាយ៉ាងដទៃ ។ ព្រះមានព្រះភាគត្រាស់ដឹងធម៌ដែលពិតនោះទាំងអស់ ស្ដូប្បីព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិតប្រាកដតាមសេចក្ដីជាពិត យ៉ាងនេះឯង ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិតប្រាកដ ដូចម្ដេច ?**

ព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ឃើញដោយប្រការទាំងពួង នូវអារម្មណ៍ដែលឈ្មោះថា រូបារម្មណ៍ ដែលមកប្រាកដតាមចក្ខុទ្វាររបស់ពួកសត្វព្រមទាំងទេវតា និងមនុស្សក្នុងលោក ព្រមទាំងទេវតា គឺ របស់សត្វទាំងឡាយដែលរកប្រមាណមិនបាន និងអារម្មណ៍នោះ ដែលព្រះអង្គទ្រង់ដឹង ទ្រង់ឃើញហើយយ៉ាងនេះ ទ្រង់ចែកដោយអំណាចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ឬដោយអំណាចបទដែលបានក្នុងអារម្មណ៍ ដែលបានឃើញ ដែលបានឮ ដែលបានជ្រាប និងដែលបានដឹង ១៣ វារៈ ៥២

ន័យខ្លះ មានឈ្មោះច្រើនយ៉ាង ដោយន័យជាដើមថា រូប គឺ រូបាយតនៈ តើដូចម្តេច ? គឺ រូបណា អាស្រ័យមហាភូតរូប ៤ ជាពណ៌ ជារូបដែលឃើញបាន ជារូបដែលប៉ះខ្ទប់បាន ជារូបពណ៌ខៀវ ជារូបពណ៌លឿង ដូច្នេះ រមែងជាអារម្មណ៍ដែលពិតប្រាកដតែម្យ៉ាង មិនមានប្រែប្រួល ។ សូម្បីក្នុងអារម្មណ៍ មានសម្លេងជាដើម ដែលមកប្រាកដសូម្បីក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ សេចក្តីនេះ សមដូចព្រះបាលីដែលព្រះមានព្រះភាគ ត្រាស់ទុកថា ៖

*ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទាំងទេវតា មារ ព្រហ្ម ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្ស បានឃើញ បានឮ បានជ្រាប បានដឹងដល់ហើយ ស្វែងរកហើយ ពិចារណាហើយ ដោយចិត្ត តថាគតរមែងដឹងនូវអារម្មណ៍នោះ ដឹងក្រៃលែងហើយនូវអារម្មណ៍នោះ អារម្មណ៍នោះ តថាគតជ្រាបហើយ ប្រាកដហើយក្នុងតថាគត ដូច្នេះ ។*

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត យ៉ាងនេះ ។ គប្បីជ្រាប សេចក្តីសម្រេចបទថា **តថាគត** មានន័យថា ទ្រង់ឃើញអារម្មណ៍ដែលពិត ។

*ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះមានវាចាដែល*

**ពិត ដូចម្តេច ?**

អស់រាត្រីណា ដែលព្រះមានព្រះភាគប្រថាប់លើអបរាជិតបល្ល័ង្ក ត្រង់ពោធិមណ្ឌលស្ថាន ទ្រង់ញាំញីមារទាំង ៣ ហើយ ត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ និងអស់រាត្រីណា ដែលព្រះអង្គស្តេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះឈើសាលៈទាំងគូ ក្នុងចន្លោះនេះ គឺ ក្នុងកាលប្រមាណ ៤៥ វស្សា ព្រះវាចាណាដែលព្រះមានព្រះភាគត្រាស់ទុក ទាំងក្នុងបឋមពោធិកាល ទាំងក្នុងមជ្ឈិមពោធិកាល ទាំងក្នុងបច្ឆិមពោធិកាល គឺ សុត្តៈ គេយ្យៈ ។ល។ វេទល្លៈ ព្រះវាចាទាំងអស់នោះ ដែលនរណាៗ តិះដៀលមិនបាន មិនខ្វះ មិនលើស ដោយអត្ថៈ និងដោយព្យញ្ជនៈ បរិបូណ៌ដោយអាការទាំងពួង បន្ទោបង់សេចក្តីស្រវឹង គឺ រាគៈ ទោសៈ មោហៈ ក្នុងព្រះវាចានោះមិនមានសេចក្តីក្លាំងក្លាត់សូម្បីត្រឹមតែប៉ុនចុងរោមទ្រាយ ព្រះវាចាទាំងអស់នោះ រមែងពិតតែម្យ៉ាង មិនប្រែប្រួល មិនក្លាយជាយ៉ាងដទៃ ដូចប្រថាប់ទុកដោយត្រាតែមួយដូចគ្នា ដូចវាល់ទុកដោយនាឡិតែមួយ និងដូចថ្លឹងទុកដោយជញ្ជីងដែលតែមួយ ដោយហេតុនោះ ទើបត្រាស់ថា ៖

**ម្នាលចុន្ទៈ អស់រាត្រីណា ដែលតថាគតត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ និងអស់រាត្រីណា ដែលតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះនេះ**

**ក្នុងវេលាយប់ណាផង រមែងសម្ដែងហៅ ពាក្យណាដែលតថាគត ពោល និយាយ សម្ដែង ពាក្យទាំងអស់នោះជាពាក្យពិតតែម្យ៉ាង មិនជាយ៉ាងដទៃ ហេតុនោះ ទើបបាននាមថា** តថាគត **ដូច្នេះ ។**

ក៏ក្នុងទីនេះ ស័ព្ទ គត មានន័យស្មើ គទ ប្រែថា ពាក្យនិយាយ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះមានព្រះវាចាពិត យ៉ាងនេះ ។

ម្យ៉ាងទៀត មានអធិប្បាយថា អាគទនំ ជា អាគទោ ប្រែថា ពាក្យនិយាយ មានវិគ្រោះថា តថោ អវិបរិតោ អាគទោ អស្សាតិ តថាគតោ ប្រែថា ឈ្មោះថា **តថាគត** ព្រោះមានព្រះវាចាពិត មិនវិបរិត ដោយផ្លាស់ **ទ** ជា **ត** ក្នុងអត្ថនេះ គប្បីជ្រាបសេចក្ដីសម្រេចបទយ៉ាងនេះឯង ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើដោយព្រះអង្គឯង និងឲ្យអ្នកដទៃធ្វើ ដូចម្ដេច ?**

ពិតហើយ ព្រះមានព្រះភាគទ្រង់មានព្រះវរកាយត្រង់នឹងព្រះវាចា ទ្រង់មានព្រះវាចាត្រង់នឹងព្រះវរកាយ ដូច្នោះ ទ្រង់មានព្រះវាចាយ៉ាងណា ក៏ទ្រង់ធ្វើយ៉ាងនោះ និងទ្រង់ធ្វើយ៉ាងណា ក៏ទ្រង់មានព្រះវាចាយ៉ាងនោះ

អធិប្បាយថា ក៏ព្រះអង្គទ្រង់ជាយ៉ាងនេះ មានព្រះវាចាយ៉ាងណា សូម្បីព្រះវរកាយក៏ទ្រង់ប្រព្រឹត្តទៅ គឺ ទ្រង់ប្រព្រឹត្តយ៉ាងនោះ និងព្រះវរកាយយ៉ាងណា សូម្បីព្រះវាចាក៏ទ្រង់ប្រព្រឹត្តទៅ គឺ ទ្រង់ប្រព្រឹត្តយ៉ាងនោះ ដោយហេតុនោះឯង ទើបត្រាស់ថា

**ម្នាលភិក្ខុទាំងឡាយ តថាគតថានិយាយយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា និយាយយ៉ាងនោះ ។ ដោយហេតុនេះទើបឈ្មោះថា យថាវាទី តថាវាទី យថាការី តថាវាទី ហេតុនោះ ទើបបានព្រះនាមថា តថាគត ដូច្នេះ ។**

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ធ្វើដោយព្រះអង្គឯង និងឲ្យអ្នកដទៃធ្វើ ដូច្នេះឯង ។

**ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់គ្របសង្កត់ដូចម្តេច ?**

ព្រះមានព្រះភាគទ្រង់គ្របសង្កត់សព្វសត្វ ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវិចីជាទីបំផុត ខាងទទឹងក្នុងលោកធាតុដែលរកប្រមាណមិនបាន ដោយសីលខ្ធៈ ដោយសមាធិខ្ធៈ ដោយបញ្ញាខ្ធៈ ដោយវិមុត្តិខ្ធៈ ដោយវិមុត្តិញ្ញាណទស្សនៈខ្ធៈ ការថ្លឹងថ្លឹង ឬប្រមាណព្រះអង្គមិនមានទេ ព្រះអង្គជាអ្នកមិនមានអ្នកណាប្រៀបផ្ទឹមបាន ដែលអ្នកណាៗ ប្រមាណ

*មិនបាន ជាបុគ្គលកំពូល ជាព្រះរាជាដែលព្រះរាជាទ្រង់បូជា គឺ ជាទេពរបស់ទេព ជាសក្កៈក្រៃលែងជាងសក្កៈទាំងឡាយ ជាព្រហ្មក្រៃលែងជាងព្រហ្មទាំងឡាយ ដោយហេតុនោះ ទើបត្រាស់ថា*

> ***“ម្នាលភិក្ខុទាំងឡាយ ក្នុងលោក ព្រមទាំងទេវតា មារ ព្រហ្ម ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្ស តថាគត ជាបុគ្គលដ៏កំពូល ដែលនរណាៗ គ្របសង្កត់មិនបាន ជាអ្នកឃើញពិត ជាអ្នកមានអំណាច ទើបបានទទួលព្រះនាមថា តថាគត” ដូច្នេះ ។***

*ក្នុងសេចក្តីនោះ គប្បីជ្រាបសេចក្តីសម្រេចបទយ៉ាងនេះ អគទោ ប្រែថា* ***ឱសថ*** *ក៏ដូច អាគទោ ដែលប្រែថា* ***វាចា*** *។ ក៏ឱសថនេះ គឺ អ្វី ? គឺ ទេសនាវិលាស និងបុណ្យពិសេស ។ សេចក្តីថា ព្រះមាន-ព្រះភាគនេះ ទ្រង់គ្របសង្កត់អ្នកមានវាទៈផ្ទុយគ្នាទាំងអស់ ចំពោះលោក ព្រមទាំងទេវតា ដូចគ្រូពេទ្យអ្នកមានអានុភាពច្រើន គ្របសង្កត់ពស់ទាំងឡាយដោយទិព្វឱសថដូច្នោះ ។ ព្រះមានព្រះភាគ បណ្ឌិតគប្បីជ្រាបថា ទ្រង់ព្រះនាមថា* ***តថាគត*** *ព្រោះហេតុថា ទ្រង់មានព្រះឱសថ គឺ ទេសនាវិលាស និងបុណ្យពិសេស ដែលពិត មិនវិបរិត ដោយការគ្របសង្កត់*

លោកទាំងពួង ដូច្នេះ ព្រោះផ្លាស់ ទ ជា ត អក្សរ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា ទ្រង់គ្របសង្កត់ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅដោយកិរិយាដែលពិត ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ដល់កិរិយាដែលពិត ដូច្នេះក៏មាន ។

បទថា គតោ មានសេចក្តីថា យល់ដឹង ប្រព្រឹត្តកន្លង សម្រេច បដិបត្តិ ។ ក្នុងន័យ ៤ យ៉ាងនោះ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់យល់ដឹងលោកទាំងអស់ដោយតីរណបរិញ្ញា ឈ្មោះថា ដោយកិរិយាដែលពិត ។ ព្រោះទ្រង់ប្រព្រឹត្តកន្លងនូវលោកសមុទ័យ ដោយបហានបរិញ្ញា ឈ្មោះថា ដោយកិរិយាដែលពិត ។

ព្រោះទ្រង់សម្រេចលោកនិរោធដោយសច្ឆិកិរិយា ឈ្មោះថា ដោយកិរិយាដែលពិត ។ ព្រោះទ្រង់បដិបត្តិបដិបទាដែលឲ្យដល់លោកនិរោធ ឈ្មោះថា កិរិយាដែលពិត ។ ដោយហេតុនោះ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ថា ៖

**ម្នាលភិក្ខុទាំងឡាយ លោក តថាគតបានត្រាស់ដឹងហើយ តថាគតប្រាសហើយចាកលោក លោកសមុទ័យ តថាគតត្រាស់ហើយ លោកសមុទ័យ តថាគតលះបង់បានហើយ លោកនិរោធ តថាគតត្រាស់ដឹងហើយ លោកនិរោធ**

**តថាគតធ្វើឲ្យជាក់ច្បាស់ហើយ បដិបទាឲ្យដល់លោក-និរោធ តថាគតត្រាស់ដឹងហើយ បដិបទាដែលឲ្យដល់លោកនិរោធ តថាគតបានចម្រើនហើយ ។**

ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណារបស់លោក ព្រមទាំងទេវតា ។បេ។ ធម្មជាតិទាំងអស់នោះ តថាគតត្រាស់ដឹងហើយ ហេតុនោះទើបបានព្រះនាមថា **តថាគត** ដូច្នេះ គប្បីជ្រាបសេចក្តីនៃពាក្យនោះ យ៉ាងនេះ ។ មួយទៀត សូម្បីប្រការនេះ ក៏ជាត្រឹមតែមុខក្នុងការសម្តែងការៈ ដែលព្រះតថាគត មានព្រះនាមថា **តថាគត** ប៉ុណ្ណោះ ។ ដែលពិត ព្រះតថាគតប៉ុណ្ណោះ នឹងគប្បីពណ៌នាការៈដែលព្រះតថាគត មានព្រះនាមថា **តថាគត** ដោយអាការទាំងពួងបាន ។

## អធិប្បាយពាក្យបុច្ឆា

ពាក្យជាដើមថា កតមញ្ចំ ភិក្ខវេ ជាដើម សេចក្តីថា ព្រះ-មានព្រះភាគ ត្រាស់សួរដល់បុថុជ្ជន កាលពោលសរសើរតថាគត គប្បីពោលដោយប្រការណា ដែលមានប្រមាណតិច មានប្រមាណស្តួចស្តើងបានត្រឹមតែសីលប៉ុណ្ណោះនោះ តើដូចម្តេច ?

ឈ្មោះថា ពាក្យសួរក្នុងព្រះបាលីនោះ មាន ៥ យ៉ាង គឺ ៖

១. **អទិដ្ឋជោតនាបុច្ឆា** ពាក្យសួរដើម្បីបញ្ជាក់លក្ខណៈដែលនៅមិនទាន់ឃើញឲ្យជាក់ច្បាស់ ។

២. **ទិដ្ឋសំសន្ទនាបុច្ឆា** ពាក្យសួរដើម្បីប្រៀបធៀបលក្ខណៈដែលឃើញហើយ ។

៣. **វិមតិច្ឆេទនាបុច្ឆា** ពាក្យសួរដើម្បីកាត់នូវសេចក្តីសង្ស័យ ។

៤. **អនុមតិបុច្ឆា** ពាក្យសួរដើម្បីការយល់ស្រប ។

៥. **កថេតុកម្យតាបុច្ឆា** ពាក្យសួរដើម្បីឆ្លើយខ្លួនឯង ។

ក្នុងបណ្តាពាក្យសួរទាំងនោះ **អទិដ្ឋជោតនាបុច្ឆា** តើដូចម្តេច ? តាមប្រក្រតីលក្ខណៈ ដែលនៅមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់បានពិចារណា មិនទាន់បានរិះគិត មិនទាន់ជាក់ច្បាស់ មិនទាន់បានអធិប្បាយ បុគ្គលរមែងសួរបញ្ហា ដើម្បីដឹង ដើម្បីឃើញ ដើម្បីពិចារណា ដើម្បីរិះគិត ដើម្បីអធិប្បាយលក្ខណៈនោះ នេះឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

**ទិដ្ឋសំសន្ទនាបុច្ឆា** តើដូចម្តេច ? តាមប្រក្រតីលក្ខណៈ ដែលដឹងហើយ ឃើញហើយ ពិចារណាហើយ រិះគិតហើយ ជាក់ច្បាស់ហើយ អធិប្បាយហើយ បុគ្គលរមែងសួរបញ្ហាដើម្បីត្រូវការនឹងប្រៀបធៀបលក្ខណៈនោះនឹងបណ្ឌិតពួកដទៃ នេះឈ្មោះថា **ទិដ្ឋសំសន្ទនាបុច្ឆា** ។

**វិមតិច្ឆេទនាបុច្ឆា** តើដូចម្តេច ? តាមប្រក្រតី បុគ្គលជាអ្នកច្រើនសង្ស័យ ច្រើនវង្វេង កើតសេចក្តីងឿងឆ្ងល់ថា តើយ៉ាងនេះឬ ? ឬមិន

មែន ? តើជាអ្វីហ្នឹង ? តើយ៉ាងដូចម្ដេច ? បុគ្គលនោះ រមែងសួរបញ្ហាដើម្បីត្រូវការកាត់សេចក្ដីសង្ស័យ នេះឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** ។

**អនុមតិបុច្ឆា** តើដូចម្ដេច ? ព្រះមានព្រះភាគ ត្រាស់សួរបញ្ហាដើម្បីការយល់ស្របតាមរបស់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ដូចម្ដេច រូបទៀង ឬមិនទៀង មិនទៀងទេព្រះអង្គ រូបដែលមិនទៀងនោះ ជាទុក្ខ ឬជាសុខ ជាទុក្ខព្រះអង្គ ។

គប្បីពោលពាក្យទាំងអស់ នេះឈ្មោះថា **អនុមតិបុច្ឆា** ។

**កថេតុកម្យតាបុច្ឆា** ដូចម្ដេច ? ព្រះមានព្រះភាគ ត្រាស់សួរបញ្ហាដោយមានពុទ្ធបំណងនឹងឆ្លើយដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ទាំងនេះ សតិប្បដ្ឋាន ៤ អ្វីខ្លះ ? ។ល។ ម្នាលភិក្ខុទាំងឡាយ អង្គនៃមគ្គ ៨ ទាំងនេះ អង្គនៃមគ្គ ៨ អ្វីខ្លះ ? នេះឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

ក្នុងបណ្ដាបុច្ឆា ៥ ប្រការដូចពណ៌នាមកនេះ ខាងដើម **អទិដ្ឋជោតនាបុច្ឆា** រមែងមិនមានដល់ព្រះតថាគត ព្រោះធម៌អ្វីៗ ដែលព្រះអង្គទ្រង់មិនឃើញមិនមាន សូម្បី **ទិដ្ឋសំសន្ទនាបុច្ឆា** ក៏មិនមាន ព្រោះមិនកើតការប្រមូល ព្រះតម្រិះថា លក្ខណៈឈ្មោះនេះ តថាគតនឹងសម្ដែងប្រៀបធៀបនឹងសមណព្រាហ្មណ៍ដែលជាបណ្ឌិតពួកដទៃ ដូច្នេះឡើយ ។

មួយ៉ាងទៀត ព្រោះហេតុដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនមានការ

កើតឡើងចំពោះ ស្រពិចស្រពិល ស្ងប់ក្នុងធម៌ត្រឹមតែមួយប្រការ ព្រះអង្គទ្រង់កម្ចាត់សេចក្តីសង្ស័យទាំងពួងបាន ក្នុងពោធិមណ្ឌលស្ថានទុះឯង ដូច្នោះ ស្ងប់ **វិមតិច្ឆេទនាបុច្ឆា** ក៏មិនមាន ។ តែបុច្ឆា ២ ប្រការ ក្រៅពីការពោលមកហើយ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ។ ក្នុងបុច្ឆា ២ ប្រការនោះ នេះឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

## ពណ៌នាចូឡសីល

[៣] ឥឡូវនេះ ព្រះមានព្រះភាគមានព្រះពុទ្ធបំណងនឹងទ្រង់ដោះស្រាយសេចក្តីដែលបានត្រាស់សួរដោយកថេតុកម្យតាបុច្ឆានោះ ទើបត្រាស់ព្រះបាលីមានអាទិថា ចាណាតិចាតំ បហាយ ដូច្នេះ ។

ក្នុងពាក្យថា លះបង់ **បាណាតិបាត** ។ **បាណាតិបាត** ប្រែថា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះ អធិប្បាយថា សម្លាប់សត្វ ផ្តាច់ជីវិតសត្វ ។ ក៏ក្នុងពាក្យថា **បាណះ** នេះ ដោយវោហារ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ។ មួយវិញទៀត ចេតនាសម្លាប់ ដែលជាហេតុញាំងសេចក្តីព្យាយាមដើម្បីផ្តាច់បង់ជីវិតិន្ទ្រិយឲ្យតាំងឡើង ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ របស់អ្នកមានសេចក្តីសម្គាល់ក្នុងជីវិតនោះថា ជាសត្វមានជីវិត ឈ្មោះថា **បាណាតិបាត** ។ បាណាតិបាតនោះ ឈ្មោះថា មានទោសតិចក្នុងសត្វតូច បណ្តាសត្វដែលវៀរចាក

គុណ មានសត្វតិរច្ឆានជាដើម , ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានរាងកាយធំ ។ ព្រោះហេតុអ្វី ? ព្រោះត្រូវព្យាយាមច្រើន ។ សូម្បីកាលមានសេចក្តីព្យាយាមស្មើគ្នា ក៏មានទោសច្រើន ព្រោះមានវត្ថុធំ ។ ក្នុងបណ្តាសត្វដែលមានគុណ មានមនុស្សជាដើម សត្វមានគុណតិច មានទោសតិច សត្វមានគុណច្រើន មានទោសច្រើន ។ សូម្បីកាលមានសរីរៈនិងគុណស្មើគ្នា ក៏គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមខ្សោយ , មានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ។

## បាណាតិបាតនោះ មានអង្គ ៥ គឺ

១. បាណោ សត្វមានជីវិត

២. បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត

៣. វធកចិត្តំ ចិត្តគិតនឹងសម្លាប់

៤. ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥. តេន មរណំ សត្វស្លាប់ដោយសេចក្តីព្យាយាមនោះ ។

## បាណាតិបាតនោះ មានប្រយោគ ៦ គឺ ៖

១. **សាហត្ថិកប្រយោគ** ប្រយោគដែលសម្លាប់ដោយដៃខ្លួនឯង ។

២. **អាណត្តិកប្រយោគ** ប្រយោគដែលបង្គាប់ឲ្យអ្នកដទៃសម្លាប់ ។

៣. **និស្សគ្គិយប្រយោគ** ប្រយោគដែលសម្លាប់ដោយអាវុធ ដែល

បោះទៅ ។

៤. **ថាវរប្រយោគ** ប្រយោគដែលសម្លាប់ដោយឧបករណ៍ដែលនៅនឹងកន្លែង ។

៥. **វិជ្ជាមយប្រយោគ** ប្រយោគដែលសម្លាប់ដោយវិជ្ជា ។

៦. **ឥទ្ធិមយប្រយោគ** ប្រយោគដែលសម្លាប់ដោយឫទ្ធិ ។

ក៏កាលខ្ញុំនឹងពណ៌នាសេចក្ដីនេះឲ្យពិស្ដារ ក៏នឹងយឺតយូរ ដូច្នោះនឹងមិនពណ៌នាសេចក្ដីនោះ និងសេចក្ដីដទៃដែលមានសភាពដូច្នោះ ឲ្យពិស្ដារ ចំណែកអ្នកដែលត្រូវការ គប្បីសិក្សាក្នុងសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យ[១] កាន់យកសេចក្ដីចុះ ។

បទថា បហាយ សេចក្ដីថា លះបង់ទោសដែលជាហេតុនៃការទ្រុស្ដសីលនេះ ពោលគឺ ចេតនាធ្វើបាណាតិបាត ។ បទថា បដិវិរតោ សេចក្ដីថា វៀរ គឺ វៀរចាកទោសដែលជាហេតុទ្រុស្ដសីលនោះ ចាប់ផ្ដើមតាំងពីកាលដែលលះបង់បាណាតិបាតបានហើយ ។ ព្រះមានព្រះភាគនោះ មិនមានធម៌ដែលនឹងគប្បីដឹងតាមចក្ខុ និងសោតៈថា តថាគតនឹងល្មើស ដូច្នេះ នឹងចាំបាច់ពោលទៅថ្វីដល់ធម៌ដែលប្រព្រឹត្តទៅផ្លូវកាយ ។ សូម្បីក្នុងបទដទៃៗ ដែលមានសភាពយ៉ាងនេះ ក៏គប្បីជ្រាបសេចក្ដីដោយ

---

**១. អដ្ឋ. បាភ. ភាគ ២. តតិយបារាជិក ។**

ន័យនេះឯង ។

ព្រះមានព្រះភាគទ្រង់បានវោហារថា **សមណ** ព្រោះជាអ្នកមានបាបស្ងប់ហើយ ។ បទថា គោតមោ សេចក្តីថា ទ្រង់ព្រះនាមថា **គោតម** ដោយអំណាចនៃព្រះគោត្រ ។ មិនមែនតែព្រះមានព្រះភាគ មួយអង្គតែប៉ុណ្ណោះទេ ដែលវៀរចាកបាណាតិបាត សូម្បីភិក្ខុសង្ឃក៏វៀរចាកផងដែរ ។ តែទេសនាមានមកយ៉ាងនេះតាំងអំពីដើម តែកាលនឹងសម្តែងសេចក្តី នឹងសម្តែងសូម្បីដោយអំណាចនៃភិក្ខុសង្ឃក៏គួរ ។

បទថា និហិតទណ្ឌោ និហិតសត្ថោ សេចក្តីថា មានដំបងដាក់ចុះហើយ និងមានកាំបិតដាក់ចុះហើយ ព្រោះមិនកាន់ដំបង ឬកាំបិតទៅដើម្បីត្រូវការនឹងសម្លាប់អ្នកដទៃ ។ ក៏ក្នុងព្រះបាលីនេះ ក្រៅពីឈើឧបករណ៍ ដ៏សេសទាំងអស់ គប្បីជ្រាបថា ឈ្មោះថា **កាំបិត** ព្រោះធ្វើឲ្យសត្វទាំងឡាយវិនាសបាន ។ ចំណែកឈើច្រត់មនុស្សចាស់ក្តី ឈើក្តី កាំបិតក្តី កាំបិតកោរដែលភិក្ខុទាំងឡាយកាន់ត្រាច់ទៅនោះ មិនមែនដើម្បីត្រូវការនឹងសម្លាប់អ្នកដទៃ ដូច្នោះទើបរាប់ថា ដាក់ឈើ ដាក់កាំបិតដូចគ្នា ។

បទថា លជ្ជី សេចក្តីថា ប្រកបដោយការខ្មាស ដែលមានលក្ខណៈស្អប់បាប ។ បទថា ទយាបន្នោ ដល់នូវសេចក្តីអាណិតអាសូរ សេចក្តីថា ដល់សេចក្តីអាណិត គឺ ភាពជាអ្នកមានមេត្តាចិត្ត ។ បទថា សព្វ-

ចាណភូតហិតានុកម្បី សេចក្តីថា អនុគ្រោះសត្វមានជីវិតទាំងពួង ដោយការអនុគ្រោះ អធិប្បាយថា មានចិត្តអនុគ្រោះដល់សត្វមានជីវិតគ្រប់ជំពូក ព្រោះដល់សេចក្តីអាណិតនោះ ។ បទថា វិហរតិ សេចក្តីថា ផ្លាស់ឥរិយាបថ គឺ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ បានដល់ រក្សាខ្លួន ។

ពាក្យថា ឥតិ វា ហិ ភិក្ខវេ សេចក្តីស្មើគ្នានឹង ឯវំ វា ភិក្ខវេ ។ វា សព្ទ ត្រាស់ជាសេចក្តីវិកប្ប (ចែកសេចក្តី) សម្ព័ន្ធដល់ពាក្យថា លះបង់អទិន្នាទានជាដើម ខាងមុខ ។ គប្បីជ្រាបសេចក្តីវិកប្ប សម្ព័ន្ធដល់ពាក្យដើមខ្លះ ពាក្យក្រោយខ្លះ គ្រប់កន្លែងយ៉ាងនេះ ។

ក៏ក្នុងអធិការនេះ មានសេចក្តីសង្ខេបដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលសរសើរតថាគត គប្បីពោលយ៉ាងនេះថា ព្រះសមណគោតម មិនសម្លាប់សត្វ មិនប្រើឲ្យអ្នកដទៃសម្លាប់ មិនពេញចិត្តក្នុងការសម្លាប់សត្វ ជាអ្នកវៀរចាកទោសជាហេតុទ្រុស្តសីល នេះគួរសរសើរពិត ព្រះគុណរបស់ព្រះពុទ្ធធំក្រៃលែង ដូច្នេះ សូម្បីត្រូវការនឹងពោលសរសើរធ្វើឱស្សាហ៍ធំ ដូច្នេះ ក៏នឹងពោលបានត្រឹមតែអាចារៈនិងសីលប៉ុណ្ណោះ ដែលជាគុណមានប្រមាណតិច នឹងមិនអាចពោលព្រះគុណអាស្រ័យសភាពដែលមិនទូទៅក្រៃលែងឡើងបានឡើយ និងមិនមែនតែបុថុជ្ជនតែម្យ៉ាងប៉ុណ្ណោះដែលមិនអាច សូម្បីព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្ត សូម្បីព្រះបច្ចេកពុទ្ធទាំងឡាយ ក៏មិនអាចដូចគ្នា តែ

តថាគតប៉ុណ្ណោះអាច តថាគតនឹងពោលសេចក្តីនោះ ដល់អ្នកទាំងឡាយក្នុងខាងមុខ ។ នេះជាការពណ៌នាសេចក្តី ព្រមទាំងអធិប្បាយក្នុងព្រះបាលីនេះ ។ អំពីនេះទៅ តថាគតនឹងពណ៌នាតាមលំដាប់ ។

ក្នុងពាក្យថា លះអទិន្នាទាននេះ ការកាន់យករបស់ដែលគេមិនបានឲ្យ ឈ្មោះ **អទិន្នាទាន** មានអធិប្បាយថា ការលួចទ្រព្យរបស់អ្នកដទៃ គឺសភាពលួច បានដល់ កិរិយាដែលជាចោរ ។ ពាក្យថា របស់ដែលគេមិនបានឲ្យ ក្នុងពាក្យថា អទិន្នាទាននោះ បានដល់ របស់ដែលមានម្ចាស់គេហួងហែង គឺ ជាទ្រព្យដែលអ្នកដទៃប្រើឲ្យធ្វើតាមប្រាថ្នា រមែងមិនគួរត្រូវដាក់អាជ្ញា និងមិនត្រូវតិះដៀល ។ មយ៉ាងទៀត ចេតនាគិតលួច ដែលជាហេតុឲ្យកើតសេចក្តីព្យាយាម នឹងកាន់យករបស់ដែលម្ចាស់គេហួងហែងនោះ របស់បុគ្គលអ្នកមានការសម្គាល់ក្នុងរបស់ដែលម្ចាស់គេហួងហែងថា ជារបស់ដែលម្ចាស់គេហួងហែង ឈ្មោះថា **អទិន្នាទាន** ។ អទិន្នាទាននោះ លួចរបស់អាក្រក់ មានទោសតិច លួចរបស់ល្អ មានទោសច្រើន ។ ព្រោះហេតុអ្វី ? ព្រោះវត្ថុប្រណីត ។ អទិន្នាទាននោះ កាលវត្ថុស្មើគ្នា ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុជារបស់អ្នកដែលក្រៃលែងដោយគុណ ឈ្មោះថា មានទោសតិច ព្រោះវត្ថុជារបស់អ្នកមានគុណតិចជាង អ្នកដែលក្រៃលែងដោយគុណនោះៗ ។

**អទិន្នាទាននោះ មានអង្គ ៥ គឺ**

១. បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់គេហួងហែង ។

២. បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថាទ្រព្យនោះមានម្ចាស់គេហួងហែង ។

៣. ថេយ្យចិត្តំ ចិត្តគិតលួច ។

៤. ឧបក្កមោ ព្យាយាមនឹងលួច ។

៥. តេន ហរណំ លួចបានមកដោយសេចក្តីព្យាយាមនោះ ។

អទិន្នាទាននោះ មាន ៦ ប្រយោគ មានសាហត្ថិកប្រយោគ ជាដើមនុ៎ះឯង ។ នឹងប្រយោគទាំងនេះឯង ប្រព្រឹត្តទៅដោយអំណាចអវហារទាំងនេះ គឺ ៖

១. ថេយ្យាវហារ លួចដោយភាពជាចោរ

២. បសយ្ហាវហារ លួចដោយសេចក្តីសង្កត់សង្កិន

៣. បរិកប្បាវហារ លួចតាមសេចក្តីកំណត់ទុក

៤. បដិច្ឆន្នាវហារ លួចដោយកិរិយាបិទបាំង

៥. កុសាវហារ លួចដោយការផ្លាស់ប្តូរស្លាក

នេះជាសេចក្តីសង្ខេបក្នុងអធិការនេះ ចំណែកសេចក្តីពិស្តារ ខ្ញុំពោលទុកហើយក្នុងសមន្តបាសាទិកាអដ្ឋកថាព្រះវិន័យ ។ ព្រះសមណគោតម ឈ្មោះថា ទិន្នាទាយី ព្រោះកាន់យកតែរបស់ដែលគេឲ្យប៉ុណ្ណោះ ។ ឈ្មោះថា ទិន្នបាដិកង្ខី ព្រោះត្រូវការតែរបស់ដែលគេ ឲ្យប៉ុណ្ណោះ

សូម្បីដោយចិត្ត ។ អ្នកដែលឈ្មោះថា ថេន ព្រោះលួច ។ អ្នកដែលមិនលួច ឈ្មោះថា អថេន ។ ព្រះសមណគោតម ប្រព្រឹត្តខ្លួនជាអ្នកស្អាត ព្រោះមិនមែនជាអ្នកលួចនុ៎ះឯង ។ បទថា អត្តនា គឺ អត្តភាព ។ មានអធិប្បាយថា ធ្វើខ្លួនឲ្យជាអ្នកមិនលួច ជាអ្នកស្អាត ។ ពាក្យដ៏សេស គប្បីប្រកបតាមន័យដែលពោលហើយក្នុងសិក្ខាបទទីមួយ នុ៎ះឯង ។ គ្រប់សិក្ខាបទក៏ដូចក្នុងសិក្ខាបទនេះ ។

បទថា អព្រហ្មចរិយំ សេចក្ដីថា ការប្រព្រឹត្តមិនប្រសើរ ។ ឈ្មោះថា ព្រហ្មចារី ព្រោះប្រព្រឹត្តអាចារៈដ៏ប្រសើរបំផុត ។ អ្នកដែលមិនមែនព្រហ្មចារីឈ្មោះថា អព្រហ្មចារី ។ បទថា អាចារី សេចក្ដីថា ទ្រង់ប្រព្រឹត្តឆ្ងាយចាកកម្មដែលជាសត្រូវចំពោះព្រហ្មចរិយៈ ។ បទថា មេថុនា សេចក្ដីថា ចាកអសទ្ធម្ម , ដែលរាប់ថា **មេថុន** ព្រោះបុគ្គលបានបញ្ញត្តិថា ជាគូគ្នា ព្រោះដូចគ្នាដោយអំណាចសេចក្ដីរួបរឹតនៃរាគៈគប្បីសេព ។ បទថា គាមធម្មា សេចក្ដីថា ជាធម៌របស់អ្នកស្រុក ។

[៤] ក្នុងពាក្យថា មុសាវាទំ បហាយ នេះ ពាក្យថា **មុសា** បានដល់ វចីបយោគ ឬកាយបយោគ ដែលទម្លាយប្រយោជន៍របស់បុគ្គលអ្នកប្រាថ្នានឹងពោលឲ្យឃ្លៀងឃ្លាត ។

ក៏ចេតនាដែលឲ្យកើតកាយបយោគ និងវចីបយោគ ដែលនិយាយឲ្យអ្នកដទៃឃ្លៀងឃ្លាត របស់បុគ្គលអ្នកប្រាថ្នានឹងពោលឲ្យឃ្លៀងឃ្លាតនោះ

ដោយប្រាថ្នានឹងពោលឲ្យឃៀនឃ្លាតឈ្មោះថា **មុសាវាទ** ។

ន័យមួយទៀត ពាក្យថា **មុសា** បានដល់ រឿងដែលមិនពិត ។ ពាក្យថា **វាទ** បានដល់ កិរិយាដែលធ្វើឲ្យគេយល់រឿងដែលមិនពិតនោះថា ជារឿងពិត រឿងប្រាកដ ។ ពោលអំពីលក្ខណៈ ចេតនាដែលឲ្យកើតវិញ្ញត្តិយ៉ាងនោះ របស់អ្នកប្រាថ្នានឹងឲ្យអ្នកដទៃយល់រឿងដែលមិនពិតថា ជារឿងពិត ឈ្មោះថា មុសាវាទ ។ មុសាវាទនោះ មានទោសតិច ព្រោះប្រយោជន៍ដែលទម្លាយនោះតិច មានទោសច្រើន ព្រោះប្រយោជន៍ដែលទម្លាយនោះច្រើន ។

មយ៉ាងទៀត សម្រាប់ពួកគ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅដោយន័យថា មិនមានជាដើម ព្រោះប្រាថ្នានឹងមិនឲ្យរបស់ខ្លួន មានទោសតិច ដែលជាសាក្សីពោលដើម្បីធ្វើទម្លាយប្រយោជន៍ មានទោសច្រើន ។ ចំពោះពួកបព្វជិត មុសាវាទដែលប្រព្រឹត្តទៅដោយន័យនៃការនិយាយថា ជារបស់បរិបូណ៌ ដូចជា ថ្ងៃនេះប្រេងក្នុងស្រុកហូរដូចទន្លេជាដើម ដោយប្រាថ្នានឹងសើច ព្រោះបានប្រេង ឬទឹកដោះថ្លាមកតិច , មានទោសតិច តែការនិយាយដល់វត្ថុដែលមិនឃើញ , ដោយន័យថា ឃើញហើយជាដើមមានទោសច្រើន ។

**មុសាវាទនោះ មានអង្គ ៤ គឺ**

១. អតថំ វត្ថុំ រឿងមិនពិត ។

២. វិសំវាទនចិត្តំ ចិត្តគិតនឹងពោលឲ្យឃ្លៀងឃ្លាត ។

៣. តជ្ជោ វាយាមោ សេចក្ដីព្យាយាមកើតអំពីចិត្តគិតនឹងពោលឲ្យឃ្លៀងឃ្លាតនោះ ។

៤. បរស្ស តទត្ថវិជ្ជាននំ អ្នកដទៃដឹងរឿងនោះ ។

មុសាវាទនោះ មានប្រយោគតែមួយ គឺ **សាហត្ថិកប្រយោគ** ។ មុសាវាទនោះគប្បីឃើញដោយការប្រើកាយខ្លះ ប្រើរបស់ដែលជាប់ដោយកាយខ្លះ ប្រើវាចាខ្លះ ធ្វើកិរិយាបញ្ឆោតអ្នកដទៃ ។ បើអ្នកដទៃយល់សេចក្ដីនោះ ដោយកិរិយានោះ អ្នកនេះរមែងជាប់ដោយកម្ម គឺ មុសាវាទក្នុងខណៈដែលគិតនឹងឲ្យកើតកិរិយាតែម្ដង ។ ក៏ព្រោះហេតុដែលបុគ្គលបង្គាប់ថា លោកចូរនិយាយរឿងនេះដល់អ្នកនេះ ដូច្នេះក៏មាន សរសេរសៀវភៅហើយបោះទៅត្រង់មុខក៏មាន សរសេរជាប់ទុកត្រង់ជញ្ជាំងផ្ទះជាដើម ឲ្យដឹងថា សេចក្ដីនេះគប្បីដឹងយ៉ាងនេះ ដូច្នេះក៏មាន ដោយទំនងដែលបញ្ឆោតបន្ទំអ្នកដទៃដោយកាយ របស់ដែលជាប់ដោយកាយ និងវាចា ដូច្នោះ សូម្បីអាណត្តិកប្រយោគ និស្សគ្គិយប្រយោគ និងថាវរ-ប្រយោគ ក៏រមែងគួរក្នុងមុសាវាទនេះ ។ តែព្រោះប្រយោគទាំង ៣ នោះមិនបានមកក្នុងអដ្ឋកថាទាំងឡាយ ទើបត្រូវពិចារណាមុនហើយគប្បីកាន់យក ។

ឈ្មោះថា សច្ចវាទី ព្រោះនិយាយតែពាក្យពិត ។ ឈ្មោះថា

សច្ចសន្ធោ ព្រោះភ្ជាប់ គឺ បន្តពាក្យសច្ចៈដោយពាក្យសច្ចៈ អធិប្បាយថា មិននិយាយមុសាក្នុងចន្លោះៗ ។ ពិតហើយ បុរសណានិយាយមុសា សូម្បីក្នុងកាលខ្លះ និយាយពាក្យសច្ចៈក្នុងកាលខ្លះ មិនយកពាក្យសច្ចៈបន្តពាក្យសច្ចៈ ព្រោះបុរសនោះយកមុសារាំងទុក ដូច្នោះ បុរសនោះមិនឈ្មោះថា តម្កល់ពាក្យសច្ចៈ តែព្រះសមណគោតមនេះមិនដូច្នោះ មិននិយាយមុសា សូម្បីព្រោះហេតុនៃជីវិត យកពាក្យសច្ចៈភ្ជាប់ពាក្យសច្ចៈតែម្យ៉ាង ហេតុនោះ ទើបឈ្មោះថា **សច្ចសន្ធោ** ។

បទថា ថេតោ សេចក្តីថា ជាអ្នករឹងមាំ អធិប្បាយថា មានពាក្យពេចន៍ជាគោល ។ បុគ្គលម្នាក់ជាអ្នកមានពាក្យមិនជាគោល ដូចជ្រលក់ដោយល្មៀត ដូចបង្គោលដែលបោះទុកក្នុងគំនរអង្កាម និងដូចត្រឡាចដែលដាក់លើខ្នងសេះ ។ បុគ្គលម្នាក់មានពាក្យជាគោល ដូចស្នាមចារឹកលើផ្ទាំងថ្ម និងដូចសសរខឿន សូម្បីកាលគេយកដាវកាត់សីសៈ ក៏មិនព្រមនិយាយពាក្យពីរ បុគ្គលនេះហៅថា **ថេតៈ** ។

បទថា បច្ចយិកោ សេចក្តីថា ជាអ្នកគួរកាន់យក អធិប្បាយថា ជាអ្នកគួរជឿតាម ។ ក៏បុគ្គលខ្លះមិនជាអ្នកគួរជឿ កាលត្រូវគេសួរថា ពាក្យនេះអ្នកណានិយាយ ? អ្នកឯណោះនិយាយឬ ? បើគេនិយាយរមែងនឹងដល់ភាពជាអ្នកគួរឆ្លើយថា អ្នកទាំងឡាយកុំជឿពាក្យរបស់អ្នកនោះ , អ្នកខ្លះជាអ្នកគួរជឿ កាលត្រូវសួរថា ពាក្យនេះអ្នកណានិយាយ

អ្នកឯណោះនិយាយឬ ? បើគេនិយាយ ក៏នឹងដល់ភាពជាអ្នកគួរឆ្លើយថា ពាក្យនេះប៉ុណ្ណោះជាប្រមាណ ឥឡូវនេះ មិនត្រូវពិចារណាក៏បាន ពាក្យនេះយ៉ាងនេះឯង អ្នកនេះហៅថា **បច្ចយិក** ។

បទថា អវិសំវាទកោ លោកស្ស សេចក្តីថា មិននិយាយបោកបញ្ឆោតសត្វលោក ព្រោះភាពជាអ្នកនិយាយពាក្យពិតនោះ ។

ក្នុងពាក្យថា បិសុណំ វាចំ បហាយ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

វាចា ដែលជាហេតុធ្វើខ្លួនជាទីស្រឡាញ់ ក្នុងចិត្តរបស់អ្នកដែលខ្លួននិយាយជាមួយ និងជាហេតុស៊កសៀតអ្នកដទៃ ឈ្មោះថា **បិសុណាវាចា** ។

មយ៉ាងទៀត វាចាដែលជាហេតុធ្វើឲ្យខ្លួនឯងខ្លះ អ្នកដទៃខ្លះគ្រោតគ្រាត ទាំងគ្រោតគ្រាតសូម្បីខ្លួនឯង មិនសមត្រចៀក មិនសុខចិត្ត ឈ្មោះថា **ផរុសវាចា** ។

វាទៈ ដែលជាហេតុឲ្យបុគ្គលនិយាយភេយភាយ ឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាបះ** ។

សូម្បីចេតនាដែលជាដើមហេតុនៃពាក្យនិយាយទាំងនោះ ក៏បណ្តោយតាម ឈ្មោះថា **បិសុណាវាចា** ផងដែរ ។ ក៏ក្នុងទីនេះ ប្រាថ្នាយកចេតនានោះឯង ។

ក្នុងបណ្ដាវាចាទាំង ៣ យ៉ាងនោះ ចេតនារបស់បុគ្គលអ្នកមានចិត្តសៅហ្មង ដែលឲ្យកើតកាយបយោគ និងវចីបយោគ ដើម្បីឲ្យអ្នកដទៃបែកគ្នាក្ដី ដើម្បីត្រូវការធ្វើខ្លួនឲ្យជាទីស្រឡាញ់ក្ដី ឈ្មោះថា **បិសុ-ណាវាចា** ។ បិសុណាវាចានោះ ឈ្មោះថា មានទោសតិច ព្រោះអ្នកធ្វើការញុះញង់អ្នកមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះអ្នកនោះមានគុណច្រើន ។

**បិសុណាវាចានោះ មានអង្គ ៤ គឺ**

១. ភិន្ទិតព្វោ បរោ អ្នកដទៃដែលគប្បីឲ្យបែកគ្នា

២. ភេទបុរេក្ខារតា ប្រាថ្នាឲ្យគេបែកគ្នាថា អ្នកទាំងនេះនឹងជាអ្នកផ្សេងគ្នា នឹងបែកគ្នាដោយឧបាយយ៉ាងនេះ ឬ **បិយកម្យតា** ប្រាថ្នាឲ្យខ្លួនជាទីស្រឡាញ់ថា យើងនឹងជាទីស្រឡាញ់ នឹងជាទីទុកចិត្ត ដោយឧបាយយ៉ាងនេះ ។

៣. តជ្ជោ វាយាមោ សេចក្ដីព្យាយាមដែលកើតពីសេចក្ដីប្រាថ្នាឲ្យគេបែកគ្នានោះ ។

៤. តស្ស តទត្ថវិជានំ អ្នកនោះដឹងរឿងនោះ ។

បទថា ឥមេសំ ភេទាយ សេចក្ដីថា ស្ដាប់ក្នុងសម្នាក់របស់មនុស្សពួកណា ដែលត្រាស់ទុកថា អំពីខាងនេះ ដើម្បីឲ្យអ្នកទាំងនោះបែកគ្នា ។

បទថា ភិន្នានំ វា សន្ធាតា សេចក្ដីថា មិត្ត ២ អ្នកក្ដី , ភិក្ខុរួម

ឧបជ្ឈាយ៍ជាដើម ២ រូបក្ដី បែកគ្នាដោយហេតុណាៗ ក៏ដោយ ចូលទៅរកម្ដងម្នាក់ ហើយពោលពាក្យជាដើមថា ការបែកគ្នានេះ មិនគួរដល់លោកអ្នកកើតក្នុងត្រកូលយ៉ាងនេះ អ្នកជាពហុស្សូតយ៉ាងនេះ ដូច្នេះ ធ្វើរឿយៗ នូវសមានភាព ។

បទថា អនុប្បទាតា សេចក្ដីថា តាំទ្រនូវសមានភាព អធិប្បាយថា ឃើញមនុស្ស ២ នាក់ ព្រមព្រៀងគ្នាហើយ ពោលពាក្យជាដើមថា ការព្រមព្រៀងនេះ សមគួរដល់អ្នកទាំងឡាយ ដែលកើតក្នុងត្រកូលបែបនេះ អ្នកប្រកបដោយគុណបែបនេះ ដូច្នេះ ធ្វើឲ្យរឹងមាំ ។

ឈ្មោះថា បុគ្គលដែលព្រមព្រៀងគ្នា ព្រោះមានអ្នកដែលព្រមព្រៀងគ្នាដែលនាំមកនូវសេចក្ដីត្រេកអរ អធិប្បាយថា ក្នុងទីណាមិនមានអ្នកព្រមព្រៀងគ្នា មិនប្រាថ្នាសូម្បីនឹងនៅក្នុងទីនោះ ។ ព្រះបាលីជាសមគ្គារាមោ ក៏មានសេចក្ដីដូចគ្នា ។

បទថា សមគ្គរតោ ប្រែថា ត្រេកអរហើយក្នុងមនុស្សព្រមព្រៀងទាំងឡាយ អធិប្បាយថា មិនប្រាថ្នាសូម្បីនឹងលះបង់មនុស្សព្រមព្រៀងទាំងនោះ ទៅនៅទីដទៃ ។

ឈ្មោះថា សេចក្ដីត្រេកអរក្នុងការព្រមព្រៀងគ្នា គឺ រីករាយក្នុងអ្នកដែលព្រមព្រៀងគ្នា ព្រោះឃើញក្ដី ឮក្ដី ដែលមនុស្សអ្នកព្រមព្រៀងគ្នាហើយ ត្រេកអរ ។

បទថា សមគ្គករណី វាចំ ភាសិតា ទ្រង់ពោលវាចាដែល សេចក្ដីថា ពោលតែវាចាដែលធ្វើឲ្យពួកសត្វព្រមព្រៀងគ្នាតែម្យ៉ាង ដែលជាវាចាសម្ដែងគុណនៃសាមគ្គីប៉ុណ្ណោះ មិនពោលវាចាក្រៅនេះ ។ ចេតនាគ្រោតគ្រាតដោយចំណែកមួយ ដែលឲ្យកើតកាយប្រយោគ និងវចីប្រយោគ ដែលជាហេតុកាត់សេចក្ដីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **ផរុសវាចា** ។ ដើម្បីយល់ផរុសវាចានោះ បានច្បាស់លាស់ គប្បីជ្រាបរឿងដូចតទៅនេះ ៖

## រឿងវាចាគ្រោតគ្រាត តែចិត្តមិនគ្រោតគ្រាត

បានឮថា ក្មេងម្នាក់មិនអើពើពាក្យរបស់មាតា ហើយក៏ចេញទៅព្រៃ មាតាមិនអាចឲ្យក្មេងនោះត្រឡប់មកវិញបាន ទើបបានជេរថា សូមឲ្យមេក្របីដេញវា ភ្លាមនោះ មេក្របីព្រៃបានប្រាកដដល់ក្មេងនោះ ដូចមាតាពោលតែម្ដង ក្មេងនោះបានធ្វើសច្ចកិរិយាថា វត្ថុដែលមាតារបស់យើងនិយាយដោយមាត់ ចូរកុំមាន វត្ថុដែលមាតាគិតដោយចិត្ត ចូរមានចុះ មេក្របីបានឈរដូចត្រូវចងទុកក្នុងព្រៃនោះឯង ។

ប្រយោគសូម្បីកាត់សេចក្ដីស្រឡាញ់យ៉ាងនេះ ក៏មិនជាផរុសវាចា ព្រោះមានចិត្តទោរទន់ ។ ពិតហើយ ពេលខ្លះមាតាបិតា រមែងពោលនឹងកូនតិចៗ យ៉ាងនេះថា "ពួកចោរចូរច្រៀកពួកអ្នកឯងជាចម្រៀកៗ" ដូច្នេះ តែក៏មិនប្រាថ្នាសូម្បីឲ្យត្របកឈូកធ្លាក់លើខ្លួនរបស់កូនតូចៗ ទាំងនោះ ម្យ៉ាងទៀត អាចារ្យ និងឧបជ្ឈាយ៍ ពេលខ្លះក៏ពោលនឹងពួកសិស្សយ៉ាង

នេះថា "ពួកនេះមិនមានអៀនខ្មាស់ មិនខ្លាចក្រែង ចាំអីទៀត ចូរដេញវាចេញទៅ" ក៏ប៉ុន្តែថា រមែងប្រាថ្នាឲ្យសិស្សទាំងនោះសម្រេចការសិក្សា និងសម្រេចមគ្គផល ។ ដូចសេចក្ដីថា វាចាមិនជាផរុសវាចា ព្រោះពាក្យផ្អែមល្ហែមក៏ទេ ។ ដោយថា អ្នកត្រូវការនឹងសម្លាប់ និយាយថា "ចូរឲ្យអ្នកនេះដេកឲ្យសប្បាយ" ដូច្នេះ នឹងមិនជាផរុសវាចាក៏ទេ ។ ក៏វាចានេះ ជាផរុសវាចាតែម្ដង ព្រោះមានចិត្តគ្រោតគ្រាត ។ ផរុសវាចានោះ មានទោសតិច ព្រោះអ្នកដែលខ្លួននិយាយសំដៅដល់នោះ មានគុណតិច មានទោសច្រើន ព្រោះអ្នកនោះមានគុណច្រើន ។

**ផរុសវាចានោះ មានអង្គ ៣ គឺ**

១. អក្កោសិតព្វោ បរោ អ្នកដទៃដែលខ្លួនជេរ ។

២. កុបិតចិត្តំ ចិត្តក្រោធ ។

៣. អក្កោសនា ការជេរ ។

បទថា នេលា ឥតមានទោស សេចក្ដីថា ទោស ហៅថា **ឯលៈ** វាចាដែលឈ្មោះថា នេលា ព្រោះមិនមានទោស អធិប្បាយថា មានទោសទៅប្រាសហើយ ។ ដូចជា នេលំ មិនមានទោស ដែលព្រះអង្គត្រាស់ទុកក្នុងប្រយោគនេះថា នេលង្គោ សេតបច្ឆាទោ រថោ គឺ អរិយមគ្គមានអង្គ ឥតមានទោស មានដំបូលស ដូច្នេះ ។

បទថា កណ្ណសុខា សេចក្ដីថា សប្បាយត្រចៀក ព្រោះមាន

ព្យញ្ជនៈស្អាតរៀបរយ គឺ មិនឲ្យកើតការចាក់ដោតត្រចៀក ដូចចាក់ដោយម្ជុល ។

វាចាឈ្មោះថា បេមនីយា គួរឲ្យស្រឡាញ់ ព្រោះមិនឲ្យកើតសេចក្ដីក្រោធ ឲ្យកើតពីសេចក្ដីស្រឡាញ់ក្នុងសរីរៈទាំងអស់ ព្រោះមានសេចក្ដីស្អាតរៀបរយ ។

វាចាឈ្មោះថា គួរចាប់ចិត្ត ព្រោះដល់ចិត្ត គឺ ចូលទៅកាន់ចិត្តបានស្រួល មិនខ្វាំងខ្វប់ ។

វាចាឈ្មោះថា ជាសំដីរបស់អ្នកក្រុង ព្រោះនៅក្នុងក្រុង ដោយហេតុដែលបរិបូណ៌ដោយគុណ ។ ឈ្មោះថា ជាពាក្យអ្នកក្រុង ព្រោះជាពាក្យពីរោះ ផ្អែមល្ហែម ដូចនារីដែលធំធាត់ក្នុងក្រុង ។ ឈ្មោះថា ជាពាក្យអ្នកក្រុង ព្រោះវាចានេះជារបស់អ្នកក្រុង អធិប្បាយថា ជាពាក្យរបស់អ្នកក្រុង ។ ពិតហើយ អ្នកក្រុង រមែងជាអ្នកមានពាក្យសមរម្យ ហៅអ្នកប្រហែលឪពុកថា ឪពុក ហៅអ្នកប្រហែលបងថា បង ។

វាចាឈ្មោះថា ជនច្រើននាក់ពេញចិត្ត ព្រោះពាក្យយ៉ាងនេះ ជាពាក្យដែលមនុស្សភាគច្រើនស្រឡាញ់រាប់អាន ។

វាចាឈ្មោះថា ពេញចិត្តនៃជនច្រើននាក់ ព្រោះជាទីពេញចិត្ត គឺ ធ្វើសេចក្ដីចម្រើនចិត្តដល់មនុស្សភាគច្រើន ដែលមនុស្សភាគច្រើនស្រឡាញ់ប្រាថ្នានុ៎ះឯង ។

អកុសលចេតនាដែលឲ្យកើតកាយបយោគ និងវចីបយោគ ដែលជាហេតុឲ្យយល់រឿងដែលមិនមានប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ។ សម្ផប្បលាបនោះ ឈ្មោះថា មានទោសតិច ព្រោះមានអាសេវនៈតិច ឈ្មោះថា មានទោសច្រើន ព្រោះមានអាសេវនៈច្រើន ។

**សម្ផប្បលាបនោះ មានអង្គ ២ គឺ**

១. និរត្ថកកថា បុរេក្ខារតា ប្រាថ្នាពោលពាក្យដែលគ្មានប្រយោជន៍ មានរឿងភារតយុទ្ធ និងរឿងដណ្តើមនាងសីតាជាដើម ។

២. តថារូបីកថា កថនំ ពោលរឿងដូច្នោះ ។

ឈ្មោះថា និយាយត្រូវកាលគួរ ព្រោះនិយាយតាមកាល អធិប្បាយថា និយាយកំណត់វេលាឲ្យសមគួរ ដល់រឿងដែលនឹងនិយាយ ។

ឈ្មោះថា ពោលតែពាក្យពិតប្រាកដ ព្រោះនិយាយពាក្យពិត ពាក្យមែន ពាក្យប្រាកដ តាមសភាពប៉ុណ្ណោះ ។

ឈ្មោះថា ពោលតែពាក្យដែលជាប្រយោជន៍ ព្រោះនិយាយធ្វើឲ្យជាប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខទុំះឯង ។

ឈ្មោះថា ពោលតែពាក្យដែលជាធម៌ ព្រោះនិយាយពាក្យអាស្រ័យលោកុត្តរធម៌ ៩ ។

ឈ្មោះថា ពោលតែពាក្យដែលជាវិន័យ ព្រោះនិយាយពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ។

ឱកាសទីតាំងទុក ហៅថា និធានវតី មានគោលឋាន ។ ពាក្យឈ្មោះថា មានគោលឋាន ព្រោះគោលឋានរបស់ពាក្យនោះមាន អធិប្បាយថា និយាយពាក្យដែលគួររក្សាទុកក្នុងចិត្ត ។

បទថា កាលេន សេចក្តីថា សូម្បីកាលនិយាយពាក្យបែបនេះ ក៏មិនបាននិយាយដោយកាលដែលមិនគួរ ដោយគិតថា យើងនឹងនិយាយពាក្យដែលមានគោល ដូច្នេះ អធិប្បាយថា កាលនិយាយក៏ពិចារណាដល់កាលដែលគួរប៉ុណ្ណោះ ។

បទថា សាបទេសំ សេចក្តីថា មានឧបមាមានហេតុ ។

បទថា បរិយន្តវតី សេចក្តីថា សម្តែងកំណត់ទុកហើយ និយាយដោយប្រការដែលកំណត់នៃពាក្យនោះនឹងប្រាកដ ។

បទថា អត្ថសញ្ហិតំ សេចក្តីថា និយាយពាក្យដែលប្រកបដោយប្រយោជន៍ ព្រោះអ្នកនិយាយចែកទៅដោយន័យយ៉ាង ក៏មិនមានបំផុត ។ មួយ៉ាងវិញទៀត និយាយពាក្យដែលប្រកបដោយប្រយោជន៍ ព្រោះប្រកបដោយប្រយោជន៍ ដែលអ្នកនិយាយដល់ប្រយោជន៍នោះពោលដល់ មានអធិប្បាយថា មិនមែនតាំងរឿងមួយទុក ហើយទៅនិយាយរឿងមួយទៀត ។

[៥] បទថា ពីជគាមភូតគាមសមារម្ភា សេចក្តីថា វៀរស្រឡះចាកការផ្តាច់ គឺ ចាកការបំផ្លាញ ដោយការៈនៃកិរិយាមានការកាត់ ការទម្លាយ និងការដុតជាដើម នូវពីជគាម ៥ យ៉ាង គឺ ៖ ពូជកើតពីឫស ១

ពូជកើតពីដើម ១ ពូជកើតពីថ្នាំង ១ ពូជកើតពីត្រួយ ១ ពូជកើតពីគ្រាប់ ១ និងដែលកូតគាមមានស្មៅ និងដើមឈើរស់ជាដើម ណាមួយ ។

[៦] បទថា ឯកភត្តិកោ សេចក្តីថា ភត្តមាន ២ ពេល គឺ ភត្តដែលគប្បីបរិភោគពេលព្រឹក ១ ភត្តដែលគប្បីបរិភោគពេលល្ងាច ១ ។ ក្នុងភត្ត ២ កាលនោះ ភត្តដែលគប្បីបរិភោគពេលព្រឹក កំណត់ដោយវេលាខាងក្នុងថ្ងៃត្រង់ ភត្តដែលគប្បីបរិភោគពេលល្ងាចក្រៅនេះ កំណត់ដោយវេលាថ្ងៃត្រង់ដរាបដល់មុនអរុណរះ ដូច្នោះ ។ សូម្បីឆាន់ ១០ ដង ក្នុងវេលាខាងក្នុងថ្ងៃត្រង់ ក៏ជាអ្នកឈ្មោះថា ឆាន់តែមួយពេលដែរ ។ ដែលទ្រង់ត្រាស់ថា មានភត្តតែមួយពេល ដូច្នេះ ទ្រង់សំដៅដល់ភត្តដែលគប្បីបរិភោគពេលព្រឹកនោះ ។

ឈ្មោះថា រត្តូបរតោ ព្រោះវៀរចាកការឆាន់ក្នុងរាត្រីនោះ ។ ការឆាន់ក្នុងកាលដែលហួសពីថ្ងៃត្រង់ទៅ ដរាបដល់វេលាព្រះអាទិត្យលិច ឈ្មោះថា **វិកាលភោជន** ។

ឈ្មោះថា វៀរលែងឆាន់ក្នុងវេលាវិកាល ព្រោះវៀរការឆាន់បែបនោះ ។ វៀរកាលណា ? វៀរតាំងពីថ្ងៃបួសនៅត្រង់ត្រើយស្ទឹងអនោមា ។ ឈ្មោះថា មើលការលេង ដែលជាសត្រូវដល់កុសល ព្រោះការមើលជាសត្រូវ គឺ ជាសត្រូវ ព្រោះជំទាស់ចំពោះព្រះសាសនា ។ ដែលថា ចាកការមើលនូវរបាំ និងការស្តាប់នូវចម្រៀង និងប្រគំភ្លេង ដែលជាសត្រូវ

សត្រូវដល់កុសល គឺ ចាកការរាំ ការច្រៀង និងការប្រគំភ្លេងដោយខ្លួនឯង ដោយអំណាចការរាំខ្លួនឯង និងឲ្យអ្នកដទៃរាំជាដើម និងការមើលរបាំជាដើម ដោយហោចទៅ សូម្បីប្រព្រឹត្តទៅដោយអំណាចការរាំរបស់សត្វក្ងោកជាដើម ដែលជាសត្រូវ ។ ពិតហើយ ការប្រកបដោយខ្លួនឯងនូវកិច្ច មានការរាំរបាំជាដើមក្តី ការឲ្យអ្នកដទៃប្រកបក្តី និងការមើលរបាំដែលគេប្រកបក្តី មិនគួរដល់ភិក្ខុទាំងឡាយឡើយ និងមិនគួរដល់ភិក្ខុនីទាំងឡាយផង ។

ក្នុងបណ្តាគ្រឿងប្រដាប់ទាំងឡាយ មានផ្កាឈើជាដើម ឈ្មោះថា មាលា បានដល់ ផ្កាឈើយ៉ាងណាមួយ ។

ឈ្មោះថា គន្ធ បានដល់ គន្ធជាតយ៉ាងណាមួយ ។

ឈ្មោះថា វិលេបន បានដល់ គ្រឿងចម្រើនសម្បុរ ។

ក្នុងបណ្តាគ្រឿងប្រដាប់ទាំងនោះ បុគ្គលកាលប្រដាប់ ឈ្មោះថា ទ្រទ្រង់ ។ កាលធ្វើរាងកាយចំណែកដែលខ្វះខាតឲ្យពេញ ឈ្មោះថា មណ្ឌនប្រដាប់ ។ កាលត្រេកអរដោយអំណាចគ្រឿងក្រអូប និងដោយអំណាចការចម្រើនសម្បុរ ឈ្មោះថា **ស្អិតស្អាង** ។ ហេតុហៅថា ឋាន ដូច្នោះ ទើបមានសេចក្តីថា មនុស្សភាគច្រើនធ្វើការ ទ្រទ្រង់មាលាជាដើមទាំងនោះ ដោយចេតនាជាហេតុឲ្យទ្រុស្តសីលណា ព្រះសមណគោតមវៀរស្រឡះចាកចេតនាជាហេតុឲ្យទ្រុស្តសីលនោះ ។

ទីដេកដែលខ្ពស់ហួសប្រមាណ ហៅថា **ទីដេកដ៏ខ្ពស់** កម្រាលដែលជាអកប្បិយហៅថា **ទីដេកដ៏ធំ** សេចក្តីថា ទ្រង់វៀរស្រឡះចាកទីដេកដ៏ខ្ពស់ ទីដេកដ៏ធំនោះ ។

បទថា ជាតរូបំ បានដល់ មាស ។ បទថា រជតំ បានដល់អកប្បិយដែលបញ្ញត្តិហៅថា កហាបណៈ ជាមាសកៈធ្វើដោយលោហៈ មាសកៈធ្វើដោយអាចម៍ល័ក្ខ មាសកៈធ្វើដោយឈើ ។ ព្រះសមណគោតមទ្រង់វៀរស្រឡះចាកការទទួលមាស និងប្រាក់ ទាំង ២ នោះ ។ អធិប្បាយថា ព្រះសមណគោតមមិនចាប់កាន់មាស និងប្រាក់នោះឯង មិនឲ្យអ្នកដទៃចាប់ មិនព្រមទទួលមាស និងប្រាក់ ដែលគេរក្សាទុកដើម្បីខ្លួន ។

**[៧]** បទថា អាមកធញ្ញប្បដិគ្គហណា សេចក្តីថា ចាកការទទួលធញ្ញជាតិឆៅទាំង ៧ យ៉ាង ពោលគឺ ស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រូវស្រងែ ថ្កៅ ស្គួយ ស្មៅគេលលក ។ មួយទៀត មិនមែនតែការទទួលធញ្ញជាតិឆៅទាំងនេះតែម្យ៉ាងប៉ុណ្ណោះ សូម្បីការចាប់ពាល់ ក៏មិនគួរដល់ភិក្ខុទាំងឡាយដូចគ្នា ។

ក្នុងបទថា អាមកមំសបដិគ្គហណា សេចក្តីថា ការទទួលសាច់និងត្រីឆៅ វៀរតែទ្រង់អនុញ្ញាតទុកចំពោះ រមែងមិនគួរដល់ភិក្ខុទាំងឡាយ ការចាប់ពាល់ក៏មិនគួរ ។

ក្នុងបទថា ឥត្ថីកុមារិកបដិគ្គហណា សេចក្តីថា ស្រីដែលមានប្តី

គ្រប់គ្រង ឈ្មោះថា ស្ត្រី , ស្រីក្រៅនេះ ឈ្មោះថា កុមារី ។ ទាំងការទទួល ទាំងការចាប់ពាល់ស្រីទាំងនោះ មិនគួរទាំងអស់ ។

ក្នុងបទថា ទាសីទាសបដិគ្គហណា សេចក្តីថា ការទទួលទាសី និងទាសៈទាំងនោះទុក ជាទាសី និងទាសៈប៉ុណ្ណោះ មិនគួរ តែកាលគេនិយាយថា សូមថ្វាយជាកប្បិយការកៈ សូមថ្វាយជាអ្នកបម្រើវត្ត ដូច្នេះ នឹងទទួលក៏គួរ ។

ន័យនៃកប្បិយៈ និងអកប្បិយៈ ក្នុងការទទួលទ្រព្យសម្បត្តិសូម្បីមានពពែ និងកែះជាដើម មានស្រែចំការ និងទីដីជាទីបំផុត គប្បីពិចារណាតាមព្រះវិន័យ ។

ក្នុងបណ្តាស្រែចំការ និងទីដីនោះ ដែលឈ្មោះថា ស្រែ បានដល់ផ្ទៃដី ព្រោះដាំបុព្វណ្ណជាតិ , ដែលឈ្មោះថា ចំការ បានដល់ ផ្ទៃដី ព្រោះដាំអបរណ្ណជាតិ ។

មយ៉ាងទៀត ផ្ទៃដីដែលពូជទាំង ២ យ៉ាងដុះឡើង ឈ្មោះថា ស្រែ ចំណែកនៃផ្ទៃដីដែលមិនបានប្រើប្រយោជន៍ទាំង ២ នោះ ឈ្មោះថា ទីដី ។ មួយទៀត សូម្បីអណ្តូង និងបឹងជាដើម ក៏សង្គ្រោះចូលក្នុងអធិការនេះដូចគ្នា ដោយលើកសព្ទ ស្រែចំការ និងទីដីជាគោល ។

[៨] ការងាររបស់ទូត ហៅថា ទូតកម្ម បានដល់ ការទទួលសំបុត្រ ឬដំណឹង ដែលពួកគ្រហស្ថប្រើទៅក្នុងទីនោះៗ ។

ការដើរទទួលបម្រើពីផ្ទះនេះទៅផ្ទះនោះ បន្តិចបន្តួច ហៅថា ការទទួលបម្រើ ។

ការធ្វើទាំង ២ យ៉ាងនោះ ឈ្មោះថា ការប្រកបរឿយៗ ព្រោះដូច្នោះ គប្បីជ្រាបក្នុងសេចក្តីនេះយ៉ាងនេះថា ចាកការប្រកបរឿយៗ នូវទូតកម្ម និងការទទួលបម្រើ ។

បទថា កយវិក្កយា គឺ ចាកការទិញ និងការលក់ ។

ក្នុងការឆបោកទាំងឡាយ មានការឆបោកដោយជញ្ជីងជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ការឆបោក ឬបន្លំ បានដល់ ការបញ្ឆោត ។

ក្នុងការឆបោកនោះ ឈ្មោះថា ការឆបោកដោយជញ្ជីងមាន ៤ យ៉ាង គឺ ៖

១. រូបកូដំ ការឆបោកដោយរូប

២. អង្គកូដំ ការឆបោកដោយអវយវៈ

៣. គហណកូដំ ការឆបោកដោយការចាប់

៤. បដិច្ឆន្នកូដំ ការឆបោកដោយការបិទបាំង

ក្នុងការឆបោកដោយជញ្ជីង ៤ យ៉ាងនោះ ដែលឈ្មោះថា ការឆបោកដោយរូប បានដល់ ធ្វើជញ្ជីង ២ ឲ្យមានរូបប៉ុនគ្នា កាលទទួល ទទួលដោយជញ្ជីងដងធំ កាលឲ្យ ដោយជញ្ជីងដងតូច ។

ដែលឈ្មោះថា ការឆបោកដោយអវយវៈ បានដល់ កាលទទួល ប្រើដៃសន្ធត់ជង្គង់ខាងក្រោយ , កាលឲ្យ ប្រើដៃសន្ធត់ជង្គង់ ខាងមុខ នុ៎ះឯង ។

ដែលឈ្មោះថា ការឆបោកដោយការចាប់ បានដល់ កាលទទួល ក៏ចាប់ខ្សែទុកត្រង់គល់ជញ្ជីង , កាលឲ្យ ក៏ចាប់ខ្សែទុកត្រង់ចុងជញ្ជីង ។

ដែលឈ្មោះថា ការឆបោកដោយបិទបាំង បានដល់ ធ្វើជង្គជញ្ជីងឲ្យមានប្រហោង ហើយដាក់កម្ទេចដែកទុកខាងក្នុង កាលទទួល ក៏រំកិលកម្ទេចដែកនោះទៅខាងចុងជញ្ជីង កាលឲ្យ ក៏រំកិលកម្ទេចផង់ដែកទៅខាងក្បាលជញ្ជីង ។

ភាជន៍មាស ហៅថា មាសសម្រិត ការបញ្ឆោតដោយភាជន៍មាសនោះ ឈ្មោះថា ឆបោកដោយសម្រិត ។ បោកបញ្ឆោតដូចម្តេច ? ធ្វើភាជន៍មាសទុកមួយ ហើយធ្វើភាជន៍លោហៈដទៃពីរបី ឲ្យមានពណ៌ដូចមាស តពីនោះទៅកាន់ជនបទ ចូលទៅកាន់ត្រកូលស្តុកស្តម្ភមួយពោលថា លោកទាំងឡាយចូរទិញភាជន៍មាស កាលត្រូវអ្នកដទៃៗ សួរតម្លៃប្រាថ្នានឹងលក់តម្លៃប៉ុនគ្នា តពីនោះ កាលគេសួរថា នឹងដឹងបានយ៉ាងណាថា ភាជនៈទាំងនេះជាមាស ប្រាប់ថា ពិសោធន៍មើល ហើយទើបទទួលទៅ ហើយដុសភាជន៍មាសលើថ្ម លក់ភាជន៍ទាំងអស់ ហើយទើបទៅ ។

ដែលឈ្មោះថា ការឆបោកដោយគ្រឿងវាល់ មាន ៣ យ៉ាង គឺ ទម្លាយត្រង់កណ្តាល ទម្លាយកំពូល និងទម្លាយខ្សែ ។

ក្នុង ៣ យ៉ាងនោះ ការឆបោកដោយគ្រឿងវាល់ ទម្លាយត្រង់កណ្តាល បានក្នុងវេលាវាល់ទឹកដោះថ្លា និងប្រេងជាដើម ។ ក៏កាលនឹងទទួលយកទឹកដោះថ្លា និងប្រេងជាដើមពួកនោះ ប្រើគ្រឿងវាល់មានប្រហោងខាងក្រោម ប្រាប់ឲ្យចាក់ថ្នមៗ ហើយឲ្យហូរចុះក្នុងភាជនៈរបស់ខ្លួនរហ័សៗ ទទួលយកទៅ កាលឲ្យបិទប្រហោងទុក ឲ្យពេញដោយឆាប់រហ័ស ហើយឲ្យទៅ ។

ការឆបោកដោយគ្រឿងវាល់ទម្លាយកំពូល បានក្នុងវេលាវាល់ល្ង និងអង្ករជាដើម ។ ក៏កាលទទួលយកល្ង និងអង្ករជាដើមទាំងនោះ ថ្នមៗ ធ្វើឲ្យកំពុងឡើងជាកំពូលហើយទទួលយកទៅ កាលឲ្យ ក៏ធ្វើឲ្យពេញដោយរហ័ស កៀសរួចឲ្យទៅ ។

ការឆបោកដោយគ្រឿងទម្លាយខ្សែ មានក្នុងវេលាវាស់ស្រែចំការ និងទីដីជាដើម សេចក្តីថា កាលមិនឲ្យថ្លៃឈ្នួល ស្រែចំការសូម្បីមិនធំ ក៏វាស់ធ្វើឲ្យធំ ។

ការទទួលថ្លៃឈ្នួលជាដើម មានវិនិច្ឆ័យដូចតទៅនេះ

បទថា ឧក្កោដនំ បានដល់ ការទទួលសំណូក ដើម្បីធ្វើម្ចាស់របស់ ឲ្យមិនជាម្ចាស់របស់ ។

បទថា វញ្ចនំ បានដល់ ការបញ្ឆោតអ្នកដទៃដោយឧបាយនោះៗ ។ ក្នុងសេចក្ដីនោះមានរឿងមួយបញ្ជាក់ដូច្នេះ ៖

បានឮមកថា មាននាយព្រានម្នាក់ចាប់ប្រើស និងកូនប្រើសមក អ្នកលេងម្នាក់សួរនាយព្រាននោះថា អ្នកដ៏ចម្រើន ប្រើសតម្លៃប៉ុន្មាន ? កូនប្រើសតម្លៃប៉ុន្មាន ? កាលនាយព្រានឆ្លើយថា ប្រើសធំតម្លៃ ២ កហាបណៈ កូនប្រើសតម្លៃមួយកហាបណៈ អ្នកលេងក៏ឲ្យមួយកហាបណៈ ទទួលយកកូនប្រើសមក ដើរទៅបានបន្តិច ហើយត្រឡប់មកប្រាប់ថា អ្នកដ៏ចម្រើន ខ្ញុំមិនត្រូវការកូនប្រើស លោកចូរឲ្យអាធំដល់ខ្ញុំចុះ នាយព្រានឆ្លើយថា បើដូច្នោះ លោកចូរឲ្យ ២ កហាបណៈមក ។ អ្នកលេងពោលថា អ្នកដ៏ចម្រើន ជាដំបូងខ្ញុំឲ្យលោកមួយកហាបណៈហើយមិនមែនឬ ? នាយព្រានឆ្លើយថា ត្រូវហើយ លោកឲ្យខ្ញុំហើយ ។

អ្នកលេងពោលថា លោកចូរទទួលយកកូនប្រើសនេះទៅ បើដូច្នេះ កហាបណៈនោះ និងកូនម្រឹគដែលមានតម្លៃមួយកហាបណៈនេះ រួមជា ២ កហាបណៈ ។ នាយព្រានពិចារណាមើលថា គេនិយាយមានហេតុផល ទើបទទួលយកកូនប្រើសមកហើយឲ្យប្រើសធំនោះទៅ ។

បទថា និកតិ បានដល់ ការបោកបញ្ឆោតដោយរបស់ប្លម ដោយធ្វើរបស់ដែលមិនមែនសង្វារ ឲ្យឃើញជាសង្វារ របស់ដែលមិនមែន កែវមណី ឲ្យឃើញជាកែវមណី របស់ដែលមិនមែនមាស ឲ្យឃើញជាមាស

ដោយអំណាចការប្រកបឡើង ឬដោយអំណាចកលល្បិច ។

បទថា សាវិយោគោ បានដល់ វិធីកោង ។ ពាក្យនេះ ជាឈ្មោះនៃការ (ទទួលសំណូក) ជាដើមទាំងនេះឯង ព្រោះដូច្នោះ គប្បីជ្រាបក្នុងសេចក្ដីនេះយ៉ាងនេះថា អំពើវៀច គឺ ការទទួលសំណូក , អំពើវៀច គឺ ការបញ្ឆោតបោកប្រាស , អំពើវៀច គឺ ការបន្លំដោយរបស់ប្លម ។ អាចារ្យពួកខ្លះពោលថា ការសម្ដែងវត្ថុមួយ ហើយផ្លាស់ប្ដូរជាវត្ថុមួយឈ្មោះថា ការត្រឡប់ត្រឡិន ។ ក៏ប្រការនោះ សង្គ្រោះចូលដោយការឆបោក នុ៎ះឯង ។

ក្នុងការកាត់ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **កាត់** បានដល់ ការកាត់ដៃជាដើម ។

បទថា **សម្លាប់** បានដល់ ធ្វើឲ្យស្លាប់ ។

បទថា **ចង** បានដល់ ចងដោយចំណង គឺ ខ្សែជាដើម ។

បទថា វិបរាមោសោ សេចក្ដីថា ការឆក់ដណ្ដើម មាន ២ យ៉ាង គឺ វាយដណ្ដើមដោយការបាំងអ័ព្ទ ១ វាយដណ្ដើមដោយការបាំងគុម្ព-ឈើ ១ ។ វេលាសន្សើមធ្លាក់ លាក់ខ្លួនដោយសន្សើម ដណ្ដើមអ្នកធ្វើដំណើរ នេះឈ្មោះថា វាយដណ្ដើមដោយការបាំងអ័ព្ទ ។ លាក់ខ្លួនដោយគុម្ពឈើជាដើម ដណ្ដើម នេះឈ្មោះថា វាយដណ្ដើមដោយការបាំងគុម្ពឈើ ។

ការធ្វើអំពើប្លន់ស្រុក និងនិគមជាដើម ហៅថា ការប្លន់ ។

បទថា សហសាការោ គឺ អំពើយ៉ាងសាហាវ បានដល់ ការចូលផ្ទះហើយយកសស្ត្រាផ្ជង់ទ្រូងពួកអ្នកស្រុក ប្រមូលយកវត្ថុដែលខ្លួនត្រូវការ ។

ព្រះសមណគោតម វៀរស្រឡះចាកការកាត់ ការសម្លាប់ ការចង ការវាយដណ្ដើម ការប្លន់ និងកំហែងយកទ្រព្យនេះ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយ៉ាងទៀត កាលបុថុជ្ជនពោលសរសើរតថាគត ក៏គប្បីពោលដូច្នេះឯង ។

(ចប់ ចូឡសីល)

# ពណ៌នាមជ្ឈិមសីល

[៩] ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់ផ្តើមសម្តែងមជ្ឈិមសីល ទើបត្រាស់ព្រះបាលីមានជាដើមថា យថា វា បនេកេ ភោន្តោ ដូច្នេះ ។

ក្នុងពាក្យនោះ មានវណ្ណនាបទដែលលំបាកៗ ដូចតទៅនេះ ៖

បទថា សទ្ធាទេយ្យានិ សេចក្តីថា ដែលអ្នកជឿកម្ម និងផលនៃកម្ម និងលោកនេះ លោកមុខ ហើយឲ្យ អធិប្បាយថា គេមិនបានឲ្យដោយប្រាថ្នាយ៉ាងនេះថា អ្នកនេះជាញាតិរបស់យើង ឬថា ជាមិត្តរបស់យើង ឬថា គេនឹងតបជំនួសវត្ថុនេះ ឬថា វត្ថុនេះគេធ្លាប់ធ្វើ ដូច្នេះ ។ ព្រោះថា ភោជនដែលគេឲ្យយ៉ាងនេះ រមែងមិនឈ្មោះថា ឲ្យដោយសទ្ធា ។

បទថា ភោជនានិ នេះ ជាត្រឹមតែបទទេសនា តែដោយសេចក្តីក៏ជាការពោលពាក្យនេះទាំងអស់តែម្តងថា បរិភោគភោជនដែលគេឲ្យដោយសទ្ធា ដណ្តប់ចីវរ ប្រើប្រាស់សេនាសនៈ បរិភោគគិលានភេសជ្ជៈដែលគេឲ្យដោយសទ្ធា ដូច្នេះ ។

បទថា សេយ្យថីទំ ជានិបាត មានសេចក្តីដូចម្តេច មានសេចក្តីថា ពីជគាម និងភូតគាមដែលសមណព្រាហ្មណ៍ដ៏ចម្រើនពួកខ្លះ ប្រកបការកាត់ផ្តាច់ ។

លំដាប់នោះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងពីជគាម និង

កូតគាមនោះ ទើបត្រាស់ថា **មូលពីជំ** ជាដើម ដូច្នេះ ។

ក្នុងព្រះបាលីនោះ ដែលឈ្មោះថា **ពូជកើតពីមើម (ឬឫស)** បានដល់ ពូជមានជាដើមយ៉ាងនេះគឺ ល្មៀត ខ្ញី ប្រទាលព្រោះព្រៃ ប្រទាលព្រោះស្រុក អាចម៍ត្រីស រំដេង ស្មៅដំរី ស្បូវក្លាំងនិងស្មៅក្រវាញជ្រូក ។

ដែលឈ្មោះថា **ពូជកើតដើម** បានដល់ ពូជមានជាដើម យ៉ាងនេះ ពោធិព្រឹក្ស ជ្រៃ ក្រសាំង ល្វា ជ្រៃក្រឹម ខ្វិត ។

ដែលឈ្មោះថា **ពូជកើតពីថ្នាំង** បានដល់ ពូជមានជាដើមយ៉ាងនេះ គឺ អំពៅ បបុស្ស ឫស្សី ។

ដែលឈ្មោះថា **ពូជកើតត្រួយ** បានដល់ ពូជមានជាដើមយ៉ាងនេះ គឺ ជីក្រហម ស្លឹកគ្រៃ ខ្ទឹមក្រហម ។

ដែលឈ្មោះថា **ពូជកើតគ្រាប់** បានដល់ ពូជមានជាដើមយ៉ាងនេះ គឺ បុព្វណ្ណជាតិ អបរណ្ណជាតិ ។

ពូជទាំងអស់នេះ ដែលបែកចេញពីដើមហើយ អាចដុះឡើងបាន ហៅថា **ពីជគាម** ។ ចំណែកពូជដែលមិនទាន់បែកចេញពីដើម មិនស្ងួត ហៅថា **ភូតគាម** ។ ក្នុងពូជ ២ យ៉ាងនោះ ការផ្តាច់ភូតគាម គប្បីជ្រាបថា ជាវត្ថុនៃបាចិត្តិយ , ការផ្តាច់ពីជគាម ជាវត្ថុនៃទុក្កដ ។

[១០] បទថា សន្និធិការកបរិភោគំ សេចក្តីថា បរិភោគរបស់ដែលធ្វើការសន្សំទុក ។ ក្នុងសេចក្តីនោះ មានពាក្យដែលគួរពោល ២ យ៉ាង គឺ

ជាប់ទាក់ទងនឹងព្រះវិន័យ ១ ជាប់នឹងការបដិបត្តិតឹងរឹង ១ ។

ពោលដល់ការជាប់ទាក់ទងនឹងព្រះវិន័យមុន ៖

បាយយ៉ាងណាមួយដែលទទួលប្រគេនថ្ងៃនេះ យកទុកថ្ងៃស្អែក ជាការធ្វើការសន្សំ កាលបរិភោគបាយនោះ ជាបាចិត្តិយ ។ តែឲ្យបាយដែលខ្លួនបានហើយដល់សាមណេរ ឲ្យសាមណេរទាំងនោះរក្សាទុក នឹងឆាន់ក្នុងថ្ងៃស្អែកគួរ តែមិនជាការបដិបត្តិតឹងរឹង ។ សូម្បីក្នុងការសន្សំទឹកបានៈ ក៏មានន័យនេះឯង ។

ក្នុងសេចក្ដីនោះ ដែលឈ្មោះថា **ទឹកបានៈ** បានដល់ ទឹកបានៈ ៨ យ៉ាង មានទឹកស្វាយជាដើម និងទឹកដែលអនុលោមចូលបាននឹងទឹកបានៈ ៨ យ៉ាងនោះ ។ វិនិច្ឆ័យទឹកបានៈទាំងនោះ ខ្ញុំបានពោលហើយក្នុងសមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ។

**ក្នុងការសន្សំសំពត់ មានវិនិច្ឆ័យដូចតទៅនេះ ៖**

សំពត់ដែលមិនទាន់បានអធិដ្ឋាន និងមិនទាន់បានវិកប្បទុក រមែងជាការសន្សំ និងធ្វើឲ្យខូចការបដិបត្តិតឹងរឹង នេះជាការពោលដោយអមចំណែកដោយត្រង់ ភិក្ខុគប្បីនឹងជាអ្នកសន្ដោសក្នុងត្រៃចីវរ បានផ្ទាំងទី ៤ ហើយ គួរឲ្យដល់អន្ធជនទៃ បើមិនអាចនឹងឲ្យដល់អន្ធណាមួយបាន តែប្រាថ្នានឹងឲ្យដល់អន្ធណា អន្ធនោះទៅដើម្បីប្រយោជន៍ដល់ឧទ្ទេស ឬដើម្បីប្រយោជន៍ដល់បរិបុច្ឆា ពេលលោកត្រឡប់មកគួរឲ្យចុះ នឹងមិនឲ្យ មិន

គួរ ។ តែកាលចីវរមិនគ្រប់គ្រាន់ នៅមានសេចក្តីប្រាថ្នានឹងបានមក នឹងរក្សាទុកខាងក្នុងវេលាដែលទ្រង់អនុញ្ញាតក៏គួរ កាលមិនទាន់បានម្ជុល អំបោះ និងអ្នកធ្វើចីវរ នឹងរក្សាទុកលើសអំពីនោះ ត្រូវធ្វើវិន័យកម្ម ទើបគួរ តែកាលចីវរផ្ទាំងនេះចាស់ នឹងរក្សាទុកវង់ចាំថា យើងនឹងបានចីវរដូច្នេះអំពីណាទៀត ដូច្នេះ មិនគួរ រមែងឈ្មោះថា ជាការសន្សំ និងធ្វើឲ្យខូចការបដិបត្តិតឹងរឹង ។

## ការសន្សំយាន មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា **យាន** បានដល់ គ្រែស្នែង រថ រទេះ រថទ្រង់-គ្រឿង អង្រឹង រទេះអូស ។ នេះមិនមែនយានរបស់បព្វជិត ។ បព្វជិតមានយានតែម្យ៉ាង គឺ ស្បែកជើង ។

ក៏ភិក្ខុមួយរូប គួរប្រើស្បែកជើងបាន ២ គូ យ៉ាងច្រើន គឺ មួយគូសម្រាប់ដើរព្រៃ មួយគូសម្រាប់ជើងដែលលាងហើយ ។ បានគូទី ៣ គួរឲ្យដល់ភិក្ខុដទៃ ។ តែនឹងរក្សាទុកដោយគិតថា កាលគូនេះចាស់ យើងនឹងបានគូដទៃអំពីណា ដូច្នេះ មិនគួរ ។ រមែងឈ្មោះថា ជាការសន្សំ និងធ្វើឲ្យខូចការបដិបត្តិតឹងរឹង ។

## ក្នុងការសន្សំទីដេក មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សយនំ បានដល់ គ្រែ ។ ភិក្ខុមួយរូប គួរមានគ្រែបាន យ៉ាងច្រើន ២ គឺ គ្រែមួយទុកក្នុងបន្ទប់ គ្រែមួយទុកក្នុងទីសម្រាកពេល

ថ្ងៃ ។ បានលើសពីនោះ គួរឲ្យដល់ភិក្ខុដទៃ ឬដល់គណៈ ។ មិនឲ្យ មិនគួរ ។ រមែងឈ្មោះថា ជាការសន្សំ និងធ្វើឲ្យខូចការបដិបត្តិតឹងរឹង ។

**ក្នុងការសន្សំរបស់ក្រអូប មានវិនិច្ឆ័យដូចតទៅនេះ ៖**

កាលភិក្ខុមានអាពាធ កើតបូស កម និងរោគស្រីស្បែកជាដើមនឹងប្រើរបស់ក្រអូបក៏គួរ ។ កាលរោគនោះស្រះស្បើយហើយ គួរឲ្យនាំរបស់ក្រអូបទាំងនោះមកឲ្យដល់ភិក្ខុអាពាធអង្គដទៃៗ ឬគួរនាំទៅប្រើក្នុងកិច្ចមានការលាបផ្ទៃផ្ទះ ដោយម្រាមដៃ ៥ ជាដើម ត្រង់ទ្វារ ។ តែនឹងរក្សាទុកដោយប្រាថ្នាថា កាលមានរោគទៀតនឹងបានប្រើ ដូច្នេះមិនគួរ ។ រមែងឈ្មោះថា ជាការសន្សំរបស់ក្រអូប និងធ្វើឲ្យខូចការបដិបត្តិតឹងរឹង ។

វត្ថុក្រៅពីបានពោលហើយ គប្បីឃើញថា ឈ្មោះថា **អាមិស** ។ គឺ ភិក្ខុអង្គខ្លះក្នុងព្រះសាសនានេះ ឲ្យគេនាំយកភាជនៈ ល្ង អង្ករសណ្តែកបាយ សណ្តែករាជមាស ដូង អំបិល ត្រី សាច់ សាច់ក្រៀម ទឹកដោះថ្លា ប្រេង និងដុំស្ករអំពៅជាដើម មករក្សាទុកដោយគិតថា នឹងដើម្បីឧបការៈក្នុងកាលបែបនោះ ។ គ្រាចូលវស្សានរដូវ ក្លៀងពីព្រឹកព្រលឹមតែម្តង លោកឲ្យពួកសាមណេរដាំបបរ ឆាន់ហើយប្រើសាមណេរទៅដោយបង្គាប់ថា សាមណេរ លោកចូរចូលទៅស្រុកដែលលំបាក ព្រោះទឹកកក់ គ្រាទៅដល់ត្រកូលនោះហើយ ប្រាប់ថា អាត្មានៅវត្ត ចូរនាំទឹកដោះជូរជាដើម ពីត្រកូលឯណោះមក ។ សូម្បីកាលភិក្ខុទាំងឡាយ

សួរថា លោកម្ចាស់នឹងចូលស្រុកឬ ? ក៏ឆ្លើយថា អ្នកមានអាយុ វេលានេះ ស្រុកចូលទៅលំបាក ។ ភិក្ខុទាំងនោះពោលថា ណ្ហើយចុះ លោកម្ចាស់និមន្តនៅចុះ ពួកខ្ញុំនឹងស្វែងរកអាហារមកថ្វាយ ដូច្នេះ ហើយនាំគ្នាទៅ ។ លំដាប់នោះ សូម្បីសាមណេរក៏នាំយកទឹកដោះជូរ ជាដើមមកផ្សំបាយ និងម្ហូប ហើយនាំចូលទៅថ្វាយ ។ កាលលោកកំពុងឆាន់អាហារនោះនៅទីនុ៎ះឯង ពួកឧបដ្ឋាកបញ្ជូនភត្តាហារទៅថ្វាយទៀត ។ លោកក៏ឆាន់តែអាហារជាទីពេញចិត្តប៉ុណ្ណោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយទទួលបិណ្ឌបាតមក ។ លោកក៏ឆាន់តែចង្ហាន់ដែលពេញចិត្ត ដរាបដល់តឹងពោះណែន ។ លោករស់នៅយ៉ាងនេះដល់ ៤ ខែ ។ ភិក្ខុរូបនេះ ហៅថា មានជីវិតនៅបែបជាសេដ្ឋីក្បាលត្រងោល មិនមែនមានជីវិតរស់នៅបែបជា សមណៈ ។ ភិក្ខុបែបនេះ រមែងឈ្មោះថា ជាអ្នកសន្សំអាមិស ។

ក្នុងទីនៅរបស់ភិក្ខុ នឹងរក្សាបានត្រឹមតែប៉ុណ្ណេះ គឺ អង្ករមួយនាឡិ ស្ករអំពៅមួយដុំ ទឹកដោះថ្លាប្រមាណ ៤ ចំណែក ដើម្បីប្រយោជន៍សម្រាប់ពួកអ្នកចូលមកខុសវេលា ។ ដោយថា ពួកចោរទាំងនោះ កាលមិនបានអាមិសបដិសណ្ឋារប៉ុណ្ណេះ គប្បីផ្តាច់សូម្បីជីវិត ព្រោះដូច្នោះ បើស្បៀងត្រឹមតែប៉ុណ្ណេះក៏មិនមាន សូម្បីនឹងឲ្យនាំមកដោយខ្លួនឯង រក្សាទុកក៏គួរ ។ ម្យ៉ាងទៀត ក្នុងវេលាមិនសប្បាយ ក្នុងទីនៅនេះ មានវត្ថុណាដែលជាកប្បិយៈនឹងឆាន់វត្ថុនោះ សូម្បីដោយខ្លួនឯងក៏គួរ ។ ចំណែក

ក្នុងកប្បិយកុដិ សូម្បីនឹងរក្សាទុកច្រើនក៏មិនឈ្មោះថា ជាការសន្សំ ។ តែចំពោះព្រះតថាគត ដែលនឹងឈ្មោះថា ទ្រង់រក្សាអង្ករមួយនាឡិ ជាដើម យ៉ាងណាមួយ ឬផ្កាំងសំពត់ចាស់ប្រមាណមួយធ្នាប់ ដោយមានព្រះពុទ្ធតម្រិះថា វត្ថុនេះនឹងមានដល់យើងក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែកនេះ ដូច្នេះមិនមានឡើយ ។

**[១១] ក្នុងការមើលដែលជាសត្រូវ មានវិនិច្ឆ័យដូចតទៅនេះ ៖**

ដែលឈ្មោះថា **របាំ** បានដល់ របាំយ៉ាងណាមួយ ។ ភិក្ខុសូម្បីដើរកាត់ផ្លូវនោះហើយអើតមើល ក៏មិនគួរ ។ ក៏វិនិច្ឆ័យដោយពិស្តារក្នុងអធិការនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យ នុ៎ះឯង ។

និងក្នុងបទព្រះសូត្រដែលជាប់ដោយសិក្ខាបទគ្រប់កន្លែង ក៏គប្បីជ្រាបវិនិច្ឆ័យដូចគ្នា ក្នុងអធិការនេះ ។

ខាងមុខមន្ទាប់ពីនេះទៅ នឹងមិនពោលត្រឹមតែប៉ុណ្ណេះ នឹងពណ៌នាឲ្យល្មមដល់ប្រយោជន៍ក្នុងសេចក្ដីនោះៗ តែម្ដងដូច្នេះឯង ។

បទថា បេក្ខំ បានដល់ មហោស្រពមានការរាំ ជាដើម ។

បទថា អក្ខានំ បានដល់ ការនិយាយរឿងសង្គ្រាម មានការតយុទ្ធនិងព្រះរាមជាដើម ។ ភិក្ខុទោះបីនឹងទៅក្នុងទីដែលគេនិយាយនោះ ក៏ មិនគួរ ។

បទថា ចាណាភិស្សរំ បានដល់ គងវង ។ អាចារ្យពួកខ្លះពោលថា ការលេងទះដៃ ដូច្នេះក៏មាន ។

បទថា វេតាឡំ បានដល់ វាយគង អាចារ្យពួកមួយពោលថា ដាស់រាងកាយរបស់អ្នកស្លាប់ឲ្យក្រោកឡើងដោយមន្ត ដូច្នេះ ក៏មាន ។

បទថា កុម្ភថូណំ បានដល់ វាយស្គរ ៤ ជ្រុង ។ អាចារ្យពួកមួយពោលថា សម្លេងផ្ទាំង ដូច្នេះក៏មាន ។

បទថា សោភនគរកំ បានដល់ ឆាកល្ខោន ឬស្រុក ក្រុងដែលស្អាតល្អ ។ អធិប្បាយថា ជាភាពវិចិត្រដោយបដិភាណ ។

បទថា ចណ្ឌាលំ បានដល់ ការលេងដុំដែក អាចារ្យពួកខ្លះពោលថា ការលេងនាំសំពត់សំបកឈើរបស់ពួកអ្នកចណ្ឌាល ។

បទថា វំសំ បានដល់ ការលេងលើកឫស្សីឡើង ។

បទថា ធោវនំ បានដល់ ការលេងលាងឆ្អឹង ។ បានឮថា ក្នុងជនបទកន្លែងខ្លះ កាលញាតិស្លាប់ គេមិនដុត រក្សាកប់ទុក គ្រាដឹងថាសាកសពទាំងនោះស្អុយរលួយហើយ ក៏នាំចេញមកលាងឆ្អឹង លាបដោយរបស់ក្រអូប ហើយរក្សាទុក ។ ក្នុងពេលនក្ខត្តឫក្ស គេតាំងឆ្អឹងទុកមួយកន្លែង តាំងសុរាជាដើមទុកមួយកន្លែង ហើយក៏នាំគ្នាស្រែកយំទួញយំ ផឹកស្រាជាមួយគ្នា ។ សេចក្ដីនេះសមដូចព្រះបាលីដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ មានពិធីឈ្មោះថា ការលេងលាង ឆ្អឹង ក្នុងទក្ខិណាជនបទ ក្នុងពិធីនោះ មានវត្ថុដែលគប្បី បាយខ្លះ ទឹកខ្លះ របស់ទំពារស៊ីខ្លះ របស់បរិភោគខ្លះ របស់ លិទ្ធខ្លះ ជាចំណែកច្រើន ។ ម្នាលភិក្ខុទាំងឡាយ ពិធី លាងឆ្អឹងនោះមានមែន តថាគតមិនពោលថា ពិធីលាង ឆ្អឹងនោះមិនមានទេ ។

តែអាចារ្យពួកខ្លះពោលថា ពិធីលាងឆ្អឹងដោយការលេងកល ឈ្មោះ ថា ការលេងមុខសាកសព ដូច្នេះក៏មាន ។

ក្នុងបណ្ដាការជល់ដំរីជាដើម ការប្រយុទ្ធនឹងដំរីជាដើមក្ដី ការ ឲ្យដំរីជល់គ្នាក្ដី ការមើលដំរីជល់គ្នាក្ដី មិនគួរដល់ភិក្ខុទាំងអស់នោះឯង ។

បទថា និព្ពុទ្ធំ បានដល់ ការប្រោកចំបាប់គ្នា ។

បទថា ឧយ្យោធិកំ បានដល់ ទីលានប្រជាល់ (មណ្ឌលកីឡា) ។

បទថា ពលគ្គំ បានដល់ ស្ថានទីរបស់ពួកពលចម្បាំង ។

បទថា សេនាព្យូហំ បានដល់ បន្ទាយកងទ័ព គឺ ការតាំងទ័ពដោយ អំណាចនៃការចាត់ក្បួនទ័ព មានក្បួនរទេះ ជាដើម ។

បទថា អនីកទស្សនំ បានដល់ ការមើលកងទ័ព ដែលលោក ពោលទុកដោយន័យមានជាដើមថា ដំរី ៣ ហៅថា ទ័ពដំរី យ៉ាងតិចបំផុត ហៅថា ទ័ពដំរី ដូច្នេះ ។

[១២] ឈ្មោះថា បមាទដ្ឋាន ព្រោះជាទីតាំងនៃសេចក្ដីប្រមាទ ។

ការភ្នាល់នោះផង ជាទីតាំងនៃសេចក្ដីប្រមាទផង ហេតុនោះ ឈ្មោះថា ការភ្នាល់ជាទីតាំងនៃសេចក្ដីប្រមាទ ។

អដ្ឋបទំ ឈ្មោះថា លេងមួយជួរ ៨ ក្រឡា ព្រោះមានក្រឡានៅមួយជួរ ៨ៗ សូម្បីក្នុងការលេងអុកមួយជួរ ១០ ក្រឡា ក៏មានន័យដូច្នេះដូចគ្នា ។

បទថា អាកាសំ បានដល់ ការលេងបាស្កា ដូចក្នុងការលេងអុកមួយជួរ ៨ ក្រឡា មួយជួរ ១០ ក្រឡា ។

បទថា បរិហារបថំ បានដល់ ការលេងរបស់អ្នកដែលធ្វើជាវង់មូលទុកច្រើនជួរជាមួយគ្នាលើផែនដី ដើរគេចគ្នាទៅក្នុងវង់មូលនោះៗ ។

បទថា សន្តិកំ បានដល់ លេងជិតៗ គ្នា (លេងផ្ទាត់គ្រាប់គ្រួស) ដោយយកបៀ ឬដុំគ្រួសកងរួមគ្នាទុក មិនឲ្យកម្រើក យកក្រចកកៀរចេញទៅ និងកៀរចូលមក បើគ្រាប់ណាមួយកម្រើកក្នុងនោះ ជាការបរាជ័យ នេះជាឈ្មោះ របស់ការលេងបែបនោះ ។

បទថា ខលិកំ បានដល់ ការលេងបាស្កាលើក្ដាបាស្កា ។

លេងយកឈើកំណាត់វែងវាយឈើកំណាត់ខ្លី ហៅថា ឃដិកំ ល្បែងហ៊ីង ឬកូនគោល ។

បទថា សលាកហត្ថំ បានដល់ ការលេងដោយយកល័ក្ខ ឬទឹកចត់ ឬម្សៅសើម ជ្រលក់ដៃដែលក្ដាប់ចម្រៀកឈើទុក ទាយថា នឹងជារូបអ្វី

គ្រវាសទៅលើផែនដី ឬត្រង់ជញ្ជាំង សម្ដែងរូបដំរី សេះជាដើម ។

បទថា អក្ខំ បានដល់ លេងជោះអង្គុញ ។

លេងផ្លុំបំពង់ដែលធ្វើដោយស្លឹកឈើនោះ ហៅថា បង្គចីរំ ល្បែងផ្លុំប៉ី ។

បទថា វង្កកំ បានដល់ នង្គ័លតូចៗ ជាគ្រឿងលេងរបស់ក្មេងអ្នកស្រុក ។

បទថា មោក្ខចិកំ បានដល់ ការត្រឡប់ខ្លួនទៅមក មានអធិប្បាយថា ចាប់ដំបងទុកក្នុងអាកាស ឬដាក់សីសៈទុកលើផែនដី លេងត្រឡប់ខ្លួនដោយយកខាងក្រោមទុកខាងលើ យកខាងលើទុកខាងក្រោម ។

ដែលហៅថា ចិង្គុលិកំ បានដល់ លេងចក្រដែលវិលបានដោយខ្យល់បក់ ដែលធ្វើដោយស្លឹកត្នោតជាដើម ។

ដែលហៅថា បត្តាឡ្ហកំ បានដល់ យកនាឡិដែលធ្វើដោយស្លឹកឈើ លេងវាល់ខ្សាច់ជាដើម ។

បទថា រថកំ សេចក្ដីថា លេងរថតូចៗ ។

បទថា ធនុកំ សេចក្ដីថា លេងធ្នូតូចៗ នុ៎ះឯង ។

ដែលហៅថា ល្បែងទាយអក្សរ បានដល់ លេងឲ្យដឹងអក្សរក្នុងអាកាស ឬលើខ្នង ។

ដែលឈ្មោះថា ល្បែងទាយចិត្ត បានដល់ លេងឲ្យដឹងរឿងដែល

គិតដោយចិត្ត (ស្តេចបង) ។

ដែលឈ្មោះថា ល្បែងត្រាប់មនុស្សពិការ បានដល់ លេងដោយសម្តែងធ្វើត្រាប់តាមទោសរបស់អ្នកពិការ មានអ្នកខ្វាក់ភ្នែក មនុស្សពិការ និងអ្នកគមជាដើម ។

[១៣] បទថា អាសន្ទិ បានដល់ អាសនៈដែលខ្ពស់ហួសប្រមាណ ។ ដែលធ្វើជាទុតិយាវិភត្តិគ្រប់បទ សម្ព័ន្ធដល់ពាក្យថា អនុយុត្តា វិហរន្តិ នេះ ។

បទថា បល្លង្កោ បានដល់ គ្រែដែលធ្វើរូបសត្វសាហាវទុកត្រង់ជើង ។

បទថា គោណកោ បានដល់ សំពត់ព្រំផ្ទាំងធំ មានរោមវែង ។ បានឮថា សំពត់ព្រំផ្ទាំងធំនោះ មានរោមវែងលើស ៤ ធ្នាប់ ។

បទថា ចិត្តកំ បានដល់ កម្រាលធ្វើដោយរោមចៀម វិចិត្រដោយគ្រឿងរចនាមួយប្រភេទ ។

បទថា បដិកា បានដល់ កម្រាលពណ៌ស ធ្វើដោយរោមចៀម ។

បទថា បដលិកា កម្រាលរោមសត្វមានរូបផ្កា បានដល់ កម្រាលធ្វើដោយរោមចៀម ជារូបផ្កាឈើក្រាស់ ដែលអ្នកខ្លះហៅថា មានទ្រង់ជាស្ទឹកកន្ទួតព្រៃ ដូច្នេះក៏មាន ។

បទថា តូលិកា បានដល់ កម្រាលញាត់សំឡី ពេញទៅដោយ

សំឡី ៣ ប្រភេទ ណាមួយ ។

បទថា វិកតិកា បានដល់ កម្រាលធ្វើដោយរោមចៀម វិចិត្រដោយរូបសីហៈ និងខ្លាជាដើម ។

បទថា ឧទ្ធលោមី បានដល់ កម្រាលធ្វើដោយរោមចៀមមានជាយ ២ ខាង ។ អាចារ្យខ្លះលោកពោលថា ជារូបផ្កាឈើផុសឡើងតែមួយចំហៀង ។

បទថា ឯកន្តលោមី បានដល់ កម្រាលធ្វើដោយរោមចៀមមានជាយតែម្ខាង ។ ខ្លះលោកពោលថា ជារូបផ្កាឈើផុសឡើង ២ ខាង ដូច្នេះក៏មាន ។

បទថា កដ្ឋិស្សំ បានដល់ កម្រាលធ្វើដោយសរសៃសូត្រ ឱនដោយកែវ ។

បទថា កោសេយ្យំ បានដល់ កម្រាលធ្វើដោយសរសៃសូត្រឱនដោយកែវដូចគ្នា ។ ចំណែកសំពត់សូត្រសុទ្ធ ត្រាស់ទុកក្នុងព្រះវិន័យថា គួរ ។ តែក្នុងអដ្ឋកថាទីឃនិកាយពោលថា វៀរកម្រាលញាត់សំឡីកម្រាលដែលត្បាញដោយរតនៈ មានព្រំដែលធ្វើដោយរោមសត្វជាដើម គ្រប់យ៉ាង មិនគួរ ។

បទថា កុត្តកំ បានដល់ កម្រាលធ្វើដោយរោមចៀម ល្មមដែលនាងរបាំ ១៦ នាក់ ឈររាំបាន ។

បទថា ហត្ថត្ថរំ អស្សត្ថរំ បានដល់ កម្រាលដែលប្រើក្រាលលើខ្នងដំរី ខ្នងសេះនោះឯង ។ សូម្បីកម្រាលក្នុងរថ ក៏ន័យនេះដូចគ្នា ។

បទថា អជិនប្បវេណិ បានដល់ កម្រាលដេរដោយស្បែកខ្លា ល្មមខ្នាតគ្រែ ។

បទថា កទលិមិគបវរបច្ចត្ថរណំ បានដល់ កម្រាលយ៉ាងល្អដែលធ្វើដោយស្បែកឈ្លូស ។ អធិប្បាយថា ជាគ្រឿងប្រដាប់ជាន់ខ្ពស់បំផុត ។ បានឮថា កម្រាលនោះ គេដេរស្បែកឈ្លូសលើសំពត់ស ។

បទថា សឧត្តរច្ឆទំ បានដល់ កម្រាលដែលត្រូវគ្នានឹងពិតាន គឺត្រូវគ្នានឹងពិដានពណ៌ក្រហម ដែលភ្ជាប់ទុកខាងលើ ។ សូម្បីពិតានពណ៌ស កាលមានកម្រាលជាអកប្បិយនៅខាងក្រោម មិនគួរ តែកាលមិនមាន គួរ ។

បទថា ឧភតោលោហិតកូបធានំ បានដល់ កម្រាលមានខ្នើយពណ៌ក្រហម ២ ខាងគ្រែ គឺ ខ្នើយកើយសីសៈ និងខ្នើយកល់ជើង នោះមិនគួរ ។ ចំណែកខ្នើយតែមួយប៉ុណ្ណោះ ទាំង ២ ខាង មានពណ៌ក្រហមក្តី មានពណ៌ផ្កាបទុមក្តី មានក្បាច់វិចិត្រក្តី បើត្រូវខ្នាត ក៏គួរ តែខ្នើយធំលោកហាម ។ ខ្នើយដែលមិនមានពណ៌ ក្រហមសូម្បី ២ ក៏គួរដូចគ្នា ។ បានច្រើនជាង ២ នោះ គួរឲ្យដល់ ភិក្ខុដទៃៗ ។ កាលមិនអាចនឹងឲ្យបាន សូម្បីនឹងក្រាលទទឹងលើគ្រែ ក្រាលកម្រាលទុកខាងលើហើយដេក ក៏រមែងបាន ។

និងគប្បីបដិបត្តិ តាមន័យដែលត្រាស់ទុកក្នុងរឿងគ្រែដែលមានជើងលើស ប្រមាណជាដើមនោះឯង ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកាត់ជើងអាសនៈ ដែលខ្ពស់ហួសប្រមាណ ហើយសឹមប្រើប្រាស់ អនុញ្ញាត ឲ្យទម្លាយ រូបសត្វសាហាវនៃគ្រែ មានជើងវិចិត្រដោយរូប សត្វសាហាវ ហើយសឹមប្រើប្រាស់ អនុញ្ញាតឲ្យកកាយ កម្រាលដែលញាត់សំឡីគ យកមកធ្វើជាខ្នើយ អាសនៈ ក្រៅអំពីនោះ អនុញ្ញាតឲ្យធ្វើកម្រាលចំពោះផ្ទាំងដ៏សេស ដូច្នេះ ។

**ក្នុងរឿងអប់ខ្លួនជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖**

[១៤] ក្លិនកាយរបស់ទារកដែលប្រសូតចាកគភ៌មាតា នឹងអស់ទៅ ក្នុងវេលាដែលមានអាយុប្រមាណ ១២ ឆ្នាំ មនុស្សទាំងឡាយ ទើបអប់ខ្លួន ដោយលំអិតរបស់គ្រឿងក្រអូបជាដើម ដើម្បីកម្ចាត់ក្លិនស្អុយរបស់កាយទារក ទាំងនោះ ការអប់ខ្លួនយ៉ាងនេះ មិនគួរ ។

មួយទៀត បើទារកដែលមានបុណ្យ គេឲ្យដេកលើចន្លោះភ្លៅទាំង ២ យកប្រេងលាបស្រឡាបអវយវៈ ដើម្បីឲ្យដៃ ជើង ភ្លៅ ពោះជាដើម បានសព្វចំណែក ។ ការស្រឡាបខ្លួនយ៉ាងនេះ មិនគួរ ។

បទថា ឆហាបនំ បានដល់ ការងូត ដូចងូតទឹកក្រអូបជាដើម

ឲ្យទារកទាំងនោះឯង ។

បទថា សម្ពាហនំ បានដល់ ដំ ដូចពួកអ្នកប្រដាល់ជំទង់ពេញវ័យ ប្រើព្រនង់ជាដើម វាយដៃជើង ធ្វើឲ្យដៃធំឡើង ។

បទថា អាទាសំ បានដល់ មិនគួរប្រើកញ្ចក់យ៉ាងណាមួយ ។

បទថា អញ្ជនំ បានដល់ ខ្មៅគូសភ្នែកធ្វើឲ្យល្អនុ៎ះឯង ។

បទថា មាលា បានដល់ ផ្កាឈើដែលក្រងខ្លះ ផ្កាឈើដែលមិនបានក្រងខ្លះ ។

បទថា វិលេបនំ បានដល់ ធ្វើការខាត់ពណ៌សម្បុរណាមួយ ។

ដោយបទថា មុខចុណ្ណកំ មុខាលេបនំ មនុស្សទាំងឡាយដាក់លំអិតដីដើម្បីត្រូវការកម្ចាត់ប្រជ្រុយ និងពកជាដើមនៅលើមុខ កាលលោហិតដើរទៅដោយលំអិតដីនោះ ក៏ដាក់លំអិតគ្រាប់ស្ពៃ កាលលំអិតគ្រាប់ស្ពៃខាំចំណែកដែលខូចអស់ហើយ ក៏ដាក់លំអិតល្ង កាលលោហិតឈប់ដោយលំអិតល្ងនោះ គេក៏ដាក់លំអិតល្មៀតនោះ កាលពណ៌សម្បុរស្រស់បស់ដោយលំអិតល្មៀតហើយ ក៏ផាត់មុខដោយម្សៅផាត់មុខ ការធ្វើទាំងអស់នោះ មិនគួរ ដូច្នេះឯង ។

**ក្នុងរឿងប្រដាប់កដៃជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖**

មនុស្សពួកខ្លះយកសង្ខ និងក្បៀងជាដើម ដែលវិចិត្រចងត្រង់ដៃត្រាច់ទៅ ។ គ្រឿងប្រដាប់ដៃយ៉ាងនោះក្តី យ៉ាងដទៃក្តី ទាំងអស់ មិនគួរ ។

មនុស្សមួយពួកទៀត ចងចុងសក់ត្រាច់ទៅ និងយកសរសៃមាស និងសរសៃមុក្តាជាដើម រុំព័ទ្ធចុងសក់នោះ ។ ទាំងអស់នោះ មិនគួរ ។

មនុស្សមួយពួកទៀត កាន់ឈើប្រចត់វែង ៤ ហត្ថ ឬឈើប្រចត់យ៉ាងដទៃ មានជងប្រដាប់ស្អាតល្អ ត្រាច់ទៅ ។ បំពង់ថ្នាំដែលវិចិត្រដោយរូបស្រីប្រុសជាដើមវង់ជុំវិញយ៉ាងល្អ បំពាក់ទុកខាងឆ្វេង ។

សូម្បីដាវដ៏មុត មានស្រោមលោមព័ទ្ធដោយរតនៈជារូបផ្កាកណ្ណិ-ការ ឆត្រដ៏វិចិត្រដោយធ្មេញមង្ករជាដើម ដេរដោយអំបោះ ៥ ពណ៌ ។

ស្បែកជើងរុំដោយរន្ទង់កន្ទុយក្ងោកជាដើម វិចិត្រដោយមាស និងប្រាក់ជាដើម ។

ពួកខ្លះសម្តែងចុងសក់ផ្អាក់វែងប្រមាណមួយហត្ថ ទទឹង ៤ ធ្នាប់ ភ្ជាប់ផ្ទៃមុខត្រង់ថ្ងាស់ ដូចផ្ទេកបន្ទោរក្នុងស្រទាប់ពពកអណ្តែតត្រសែត ប្រើផ្ចិតចាមរនិងផ្ចិតវាលវីជនី ។ ទាំងអស់នោះ មិនគួរ ។

[១៥] ដែលឈ្មោះថា តិរច្ឆានកថា ព្រោះជាពាក្យដែលទទឹងផ្លូវសួគ៌ និងផ្លូវនិព្វាន ព្រោះមិនមែនធម៌ដែលជាហេតុឲ្យចេញចាកទុក្ខ ។

បណ្តាតិរច្ឆានកថាទាំងនោះ រឿងដែលនិយាយប្រារព្ធដល់ព្រះរាជាដោយន័យមានជាដើមថា ព្រះបាទមហាសម្មតរាជ ព្រះបាទមន្ធាតុរាជ ព្រះបាទធម្មាសោករាជ មានអានុភាពច្រើនយ៉ាងនេះ ឈ្មោះថា រឿងព្រះរាជា ។ ក្នុងរឿងចោរជាដើម ក៏ន័យនេះ ។

ពាក្យដែលជាប់ដោយរឿងគ្រប់គ្រងផ្ទះ ដោយន័យជាដើមថា បណ្ដាលោកទាំងនោះ ព្រះរាជាអង្គឯណោះ មានរូបល្អគួរសរសើរ ដូច្នេះឯង ឈ្មោះថា តិរច្ឆានកថា ។ តែរឿងដែលនិយាយយ៉ាងនេះថា សូម្បីព្រះរាជាព្រះនាមនោះ មានអានុភាពច្រើនយ៉ាងនេះ សុគតហើយ ដូច្នេះ តាំងនៅក្នុងភាពជាកម្មដ្ឋាន ។

សូម្បីក្នុងការនិយាយអំពីចោរ ពាក្យដែលជាប់ដោយរឿងក្រុមគ្រួសារថា ឱ ខ្លាំងក្លាពិត ដូច្នេះ អាស្រ័យការធ្វើរបស់ចោរទាំងនោះថា ចោរឈ្មោះមូលទេវ មានអានុភាពច្រើនយ៉ាងនេះ ចោរឈ្មោះមេឃមាល មានអានុភាពច្រើនយ៉ាងនេះ ដូច្នេះ ឈ្មោះថា តិរច្ឆានកថា ។

សូម្បីក្នុងការនិយាយអំពីចម្បាំង មានរឿងការតយុទ្ធជាដើម ពាក្យដែលជាប់ទាក់ទងនឹងសេចក្ដីពេញចិត្តក្នុងរឿងទាយថា អ្នកឯណោះត្រូវអ្នកឯណោះសម្លាប់យ៉ាងនេះ ចាក់យ៉ាងនេះឯង ឈ្មោះថា តិរច្ឆានកថា ។ តែរឿងដែលនិយាយយ៉ាងនេះថា សូម្បីអ្នកឈ្មោះទាំងនេះក៏ដល់សេចក្ដីអស់ទៅ ដូច្នេះ រមែងជាកម្មដ្ឋានគ្រប់រឿងតែម្ដង ។

ម្យ៉ាងទៀត ក្នុងការនិយាយអំពីបាយជាដើម ការនិយាយជាប់ទាក់ទងនឹងសេចក្ដីពេញចិត្តក្នុងវត្ថុដែលគាប់ចិត្តថា យើងទំពារ យើងបរិភោគបាយមានពណ៌ស្អាត មានក្លិនក្រអូប មានរសឆ្ងាញ់ ទន់ ដូច្នេះ មិនគួរ ។ តែការនិយាយធ្វើឲ្យមានប្រយោជន៍ថា កាលមុន យើងបានថ្វាយបាយទឹក

សំពត់ ទីដេក ផ្កាឈើ របស់ក្រអូប ដែលដល់ព្រមដោយពណ៌ជាដើម ដល់លោកអ្នកសីល យើងបានបូជាព្រះចេតិយយ៉ាងនេះ ដូច្នេះ រមែងគួរ ។

**ក៏ក្នុងរឿងញាតិជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖**

ការនិយាយជាប់ទាក់ទងនឹងសេចក្តីពេញចិត្តថា ញាតិរបស់ពួកយើងក្លាហាន មានសមត្ថភាពដូច្នេះក្តីថា កាលមុនយើងត្រាច់ទៅដោយយានដែលល្អស្អាតយ៉ាងនេះ ដូច្នេះក្តី មិនគួរ ។ តែគួរនឹងនិយាយឲ្យមានប្រយោជន៍ថា ញាតិរបស់ពួកយើងសូម្បីទាំងនោះ ក៏ស្លាប់ទៅហើយ ឬថា កាលមុនយើងបានថ្វាយស្បែកជើងយ៉ាងនេះដល់ព្រះសង្ឃ ដូច្នេះ ។

**ក៏ក្នុងរឿងស្រុកជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖**

សូម្បីនិយាយអំពីស្រុកដែលជាប់ទាក់ទងនឹងរឿងថា ទីនៅអាស្រ័យល្អ ទីអាស្រ័យមិនល្អ ម្ហូបអាហាររកបានងាយ និងការអត់បាយជាដើម ឬដែលជាប់ទាក់ទងនឹងសេចក្តីពេញចិត្តយ៉ាងនេះថា អ្នកស្រុកឯណោះក្លាហាន អង់អាច ដូច្នេះ មិនគួរ តែនិយាយឲ្យមានប្រយោជន៍ថា អ្នកស្រុកឯណោះមានសទ្ធាជ្រះថ្លា ឬថា ដល់សេចក្តីអស់ទៅ សាបសូន្យទៅ ដូច្នេះ គួរ ។ សូម្បីក្នុងរឿងនិគម នគរ ជនបទ ក៏ន័យនេះឯង ។

សូម្បីរឿងស្ត្រី ដែលជាប់ទាក់ទងនឹងការស្រឡាញ់ពេញចិត្តអាស្រ័យពណ៌សម្បុរ និងទ្រង់ទ្រាយជាដើម មិនគួរ ។ តែនិយាយយ៉ាង នេះថា ស្ត្រីឯណោះមានសទ្ធាជ្រះថ្លា ដល់ការអស់ទៅ សាបសូន្យទៅ ដូច្នេះឯង

គួរ ។

សូម្បីរឿងមនុស្សដែលក្លាហាន ដែលជាប់ទាក់ទងទៅនឹងសេចក្តីពេញចិត្តថា ទាហានឈ្មោះនន្ទមិត្តជាអ្នកក្លាហាន ដូច្នេះ មិនគួរ ។ តែនិយាយយ៉ាងនេះថា ទាហានជាអ្នកមានសទ្ធា ដល់សេចក្តីអស់ទៅ ដូច្នេះគួរ ។

សូម្បីរឿងប្រកផ្លូវ ដែលជាប់ទាក់ទងនឹងសេចក្តីពេញចិត្តថា ប្រកផ្លូវឯណោះនៅល្អ នៅមិនល្អ មានអ្នកក្លាហាន មានអ្នកអង់អាច ដូច្នេះមិនគួរ ។ និយាយយ៉ាងនេះថា ប្រកផ្លូវឯណោះ មានអ្នកមានសទ្ធាជ្រះថ្លាដល់សេចក្តីអស់ទៅ សាបសូន្យទៅ ដូច្នេះ គួរ ។

បទថា កុម្ភដ្ឋានកថំ បានដល់ ការនិយាយរឿងទីតាំងទឹក ការនិយាយរឿងកំពង់ទឹក លោកហៅថា **កុម្ភទាសីកថា** ក៏មាន ។ និយាយជាប់ទាក់ទងនឹងសេចក្តីពេញចិត្តថា នាងកុម្ភទាសីនោះ គួរជ្រះថ្លា ឆ្លាតក្នុងរបាំ រាំ ច្រៀង ដូច្នេះឯង មិនគួរ ។ តែនិយាយដោយន័យជាដើមថា ជាអ្នកមានសទ្ធាជ្រះថ្លា ដូច្នេះ គួរ ។

បទថា បុព្វេបេតកថំ បានដល់ និយាយអំពីញាតិក្នុងអតីត ។ សេចក្តីវិនិច្ឆ័យ ក៏ដូចនឹងការនិយាយអំពីញាតិបច្ចុប្បន្នក្នុងទីនោះៗ ។

បទថា នានត្តកថំ បានដល់ និយាយរឿងគ្មានប្រយោជន៍ ជារឿងផ្សេងៗ ដែលនៅ សល់ ផុតពីពាក្យដើមនិងពាក្យចុង ។

បទថា លោកក្ខាយិកា សេចក្តីថា ការនិយាយលេងជាប់ទាក់ទង នឹងលោកជាដើមយ៉ាងនេះថា លោកនេះ អ្នកណាសាង អ្នកឯណោះសាង ក្អែកពណ៌ស ព្រោះឆ្អឹងស សត្វកុកពណ៌ក្រហម ព្រោះឈាមក្រហម ដូច្នេះ ។

ដែលឈ្មោះថា សមុទ្ទក្ខាយិកំ បានដល់ ពាក្យដែលពោលដល់ សមុទ្រ ដែលគ្មានប្រយោជន៍ជាដើមយ៉ាងនេះថា សមុទ្រឈ្មោះថា សាគរ ព្រោះហេតុអ្វី ? ព្រោះព្រះបាទសាគរទេវជីកទុក ដូច្នោះ ទើបឈ្មោះថា សាគរ ដែលឈ្មោះថា សមុទ្រ ព្រោះប្រកាសដោយមេដៃថា សាគរ យើងជីកទុក ដូច្នេះ ។

បទថា ភវោ ប្រែថា សេចក្តីចម្រើន ។

បទថា អភវោ ប្រែថា សេចក្តីវិនាស ។

[១៦] ពាក្យដែលនិយាយពោលដល់ហេតុ ដែលគ្មានប្រយោជន៍យ៉ាង ណាមួយថា ចម្រើនព្រោះហេតុនេះ វិនាសព្រោះហេតុនេះ ដូច្នេះ ឈ្មោះថា និយាយរឿងដែលទាក់ទងនឹងសេចក្តីចម្រើន និងសេចក្តីវិនាស ដោយ ប្រការដូច្នេះ ។

បទថា វិគ្គាហិកកថា បានដល់ ការនិយាយប្រកាន់ខុសគ្នា ការ និយាយប្រណាំងប្រជែង ។

បទថា សហិតំ មេ សេចក្តីថា ពាក្យនិយាយរបស់ខ្ញុំមាន

ប្រយោជន៍ មានរបៀបរៀបរយ ប្រកបដោយផល ប្រកបដោយហេតុ ។

បទថា អសហិតន្តេ បានដល់ ពាក្យនិយាយរបស់លោកមិនមានប្រយោជន៍ មិនមានរបៀបរៀបរយ ។

បទថា អធិចិណ្ណន្តេ វិបរាវត្តំ បានដល់ ពាក្យណាដែលលោកស្ទាត់ល្អ ដោយអ្នកប្រព្រឹត្តមកជាយូរអង្វែង ពាក្យនោះខុស ជំទាស់ផ្ទុយនឹងពាក្យយើងតែមួយគត់ អ្នកមិនដឹងឡើយ ។

បទថា អារោបិតោ តេ វាទោ បានដល់ កំហុសក្នុងវាទៈរបស់លោក ខ្ញុំចាប់បានហើយ ។

បទថា ចរ វាទប្បមោក្ខាយ សេចក្តីថា ដើម្បីដោះកំហុសលោកចូរត្រាច់ទៅ ត្រាច់មក ចូរទៅសិក្សាក្នុងសេចក្តីនោះៗ ចុះ ។

បទថា និព្វេឋេហិ វា សចេ បហោសិ ឬបើអ្នកអាច ចូរដោះស្រាយឲ្យរួចទោសចុះ សេចក្តីថា បើលោកឯងអាច ក៏ចូរដោះស្រាយចេញក្នុងកាលឥឡូវនេះចុះ ។

### [១៧] ក្នុងរឿងការធ្វើខ្ញុំជាទូត មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឥធ គច្ឆ សេចក្តីថា ចូរទៅអំពីទីនេះ ទៅកាន់ទីឈ្មោះឯណោះ ។

បទថា អមុត្រ គច្ឆ លោកចូរទៅក្នុងទីឯនោះ សេចក្តីថា ចូរទៅអំពីទីនោះ ទៅកាន់ទីឈ្មោះឯណោះ ។

បទថា ឥធំ ហរ សេចក្តីថា ចូរនាំរឿងនេះទៅអំពីទីនេះ ។

បទថា អមុត្រ ឥធំ អាហរ សេចក្តីថា ចូរនាំរឿងនេះ អំពីទីឯ-ណោះមកក្នុងទីនេះ ។

ក៏ដោយសង្ខេប ដែលឈ្មោះថា ការធ្វើខ្លួនជាទូតនេះ សម្រាប់សហធម្មិកទាំង ៥ និងដំណើររបស់គ្រហស្ថ ដែលទាក់ទងដោយឧបការៈចំពោះព្រះរតនត្រ័យ គួរ សម្រាប់អ្នកពួកដទៃ មិនគួរ ។

**[១៨] ក្នុងបទថា** កុហកា **ជាដើម មានវិនិច្ឆ័យ ដូចតទៅនេះ**

ដែលឈ្មោះថា **និយាយកុហក** ព្រោះបោកបញ្ឆោតអ្នកស្រុក គឺឲ្យចូលចិត្តដោយរឿងបញ្ឆោត ៣ យ៉ាង ។

ដែលឈ្មោះថា **និយាយរាក់ទាក់** ព្រោះជាអ្នកនិយាយមានសេចក្តីត្រូវការលាភសក្ការៈ ។

ដែលឈ្មោះថា **និយាយបញ្ចិតបញ្ចៀង** ព្រោះជាពាក្យនិយាយដៀងជាប្រក្រតី ។

ដែលឈ្មោះថា **និយាយប្រទេច** ព្រោះមានពាក្យនិយាយប្រទេចជាប្រក្រតី ។

ដែលឈ្មោះថា ស្វែងរកលាភដោយលាភ ព្រោះស្វែងរក គឺ ស្វះ-ស្វែងរកលាភដោយលាភ ។ នេះជាឈ្មោះរបស់បុគ្គលអ្នកប្រកបការដោយការលួងលោមទាំងនេះ គឺ និយាយកុហក និយាយរាក់ទាក់ និយាយ

បញ្ចិតបញ្ចៀង និយាយប្រទេច ស្វែងរកលាភដោយលាភ ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ តែដោយពិស្តារ រឿងនិយាយ មានលួងលោមជាដើម ខ្ញុំបាននាំព្រះបាលី និងអដ្ឋកថា មកប្រកាសទុកក្នុងសីលនិទ្ទេសក្នុងវិសុទ្ធិមគ្គ ដូច្នេះឯង ។

(ចប់ មជ្ឈិមសីល )

# ពណ៌នាមហាសីល

[១៩] បទថា អង្គំ បានដល់ តម្រាទាយអវយវៈ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា អ្នកដែលប្រកបដោយអវយវៈមានដៃនិងជើងបែបនេះយ៉ាងណាមួយ មានអាយុវែង មានយស ។

បទថា និមិត្តំ បានដល់ តម្រាទាយនិមិត្ត ។

បានឮថា ព្រះបាទបណ្ឌុរាជ ទ្រង់កាន់កែវមុក្តាទុក ៣ ដួង ហើយត្រាស់សួរគ្រូហោរមើលនិមិត្តថា អ្វីនៅក្នុងដៃរបស់ខ្ញុំ ? គ្រូហោរមើលនិមិត្តនោះ ក្រឡេកមើលខាងឯណោះខាងនេះ និងក្នុងវេលានោះ រុយត្រូវចីងចក់ពាំហើយរបូតទៅ គេទើបក្រាបទូលថា កែវមុក្តា ត្រាស់សួរតទៅថា ប៉ុន្មានដួង ? គេបានឮសម្លេងមាន់រងាវ ៣ ដង ទើបក្រាបទូលថា ៣ ដួង ។

សមណព្រាហ្មណ៍ដ៏ចម្រើនពួកខ្លះ ទាយនិមិត្ត អាងតម្រាទាយនិមិត្តនោះៗ យ៉ាងនេះ ។

បទថា ឧប្បាទំ បានដល់ ទាយវត្ថុធំ ៗ ដូចជា អសនីបាតជាដើមដែលធ្លាក់ចុះមក ។ ក៏សមណព្រាហ្មណ៍ពួកខ្លះឃើញដូច្នោះ ហើយទំនាយអាងថា នឹងមានរឿងនេះ នឹងជាយ៉ាងនេះ ។

បទថា សុបិនំ បានដល់ សមណព្រាហ្មណ៍ពួកខ្លះ ប្រកបរឿយៗ

នូវការទាយយល់សប្តិ ដោយន័យមានជាដើមថា អ្នកយល់សប្តិវេលាព្រឹក នឹងមានផលយ៉ាងនេះ អ្នកយល់សប្តិដូច្នេះ នឹងមានរឿងឈ្មោះនេះដូច្នេះ ៗ

បទថា លក្ខណំ បានដល់ តម្រាទាយលក្ខណៈ មានជាដើមថា អ្នកដែលប្រកបដោយលក្ខណៈនេះ នឹងជាព្រះរាជា ដោយលក្ខណៈនេះនឹងជាឧបរាជ ៗ

បទថា មូសិកច្ឆិន្នំ បានដល់ តម្រាទាយកណ្ដុរកកេរសំពត់ ៗ ក៏កាលសំពត់សូម្បីត្រូវកណ្ដុរនោះពាំមក ឬមិនពាំមកក៏ដោយ កកេរយ៉ាងនេះ តាំងពីទីនេះទៅ សមណព្រាហ្មណ៍ពួកខ្លះ ក៏ទំនាយអាងថា នឹងមានរឿងឈ្មោះនេះ ៗ

បទថា អគ្គិហោមំ បានដល់ ពិធីបូជាភ្លើងថា កាលប្រើឧសយ៉ាងនេះ បូជាភ្លើងយ៉ាងនេះ នឹងមានផលឈ្មោះនេះ ៗ សូម្បីពិធីបង្វិលទៀនជាដើម ក៏គឺ ពិធីបូជាភ្លើងនុ៎ះឯង ត្រាស់ទុកមួយផ្នែក ដោយអំណាចនៃការប្រព្រឹត្តទៅយ៉ាងនេះថា កាលបង្វិលទៀនបែបនេះ ប្រើវត្ថុមានកន្ទក់ជាដើមបូជាភ្លើង នឹងមានផលឈ្មោះនេះ ៗ

បទថា កណោ ក្នុងពិធីនោះ បានដល់ កន្ទក់ ៗ

បទថា តណ្ឌុល បានដល់ អង្ករនៃស្រូវសាលីជាដើម និងនៃតិណ្ណជាតិទាំងឡាយ ៗ

បទថា សប្បិ បានដល់ ទឹកដោះគោជាដើម ។

បទថា តេលំ បានដល់ ប្រេងល្ងជាដើម ។

ក៏ការបៀមគ្រាប់ស្ពៃជាដើម ព្រួសចូលក្នុងភ្លើង ឬការពាយវេទផ្លុំចូលក្នុងភ្លើង ឈ្មោះថា ធ្វើពិធីផ្លុំភ្លើង បូជាដោយមាត់ ។

ការបូជាយញ្ញដោយលោហិតនៃស្មា និងជង្គង់ខាងស្តាំជាដើម ឈ្មោះថា បូជាដោយលោហិត ។

បទថា អង្គវិជ្ជា បានដល់ សេចក្តីខាងដើម និយាយដល់អវយវៈដោយបានឃើញអវយវៈមុន ហើយទើបព្យាករណ៍ ក្នុងទីនេះត្រាស់ដល់វិជ្ជាមើលអវយវៈ ដោយបានឃើញឆ្អឹងម្រាមដៃ ហើយពាយវេទព្យាករណ៍ថា កុលបុត្រនេះមានទ្រព្យឬទេ ឬមានសិរីឬទេ ដូច្នេះជាដើម ។

បទថា វត្ថុវិជ្ជា បានដល់ វិជ្ជាគ្រូមើល កំណត់គុណ និងទោសនៃការធ្វើផ្ទះ និងផ្ទៃដីសួនជាដើម ។ សូម្បីបានឃើញសេចក្តីផ្សេងនៃដីជាដើម ក៏ពាយវេទឃើញគុណ និងទោស ក្នុងក្រោមផែនដី ក្នុងអាកាសប្រមាណ ៣០ ហត្ថ និងក្នុងផ្ទៃដីប្រមាណ ៨០ ហត្ថ ។

បទថា ខេត្តវិជ្ជា បានដល់ វិជ្ជានិតិសាស្ត្រ មានអព្ភេយ្យសាស្ត្រមានសុរក្ខសាស្ត្រ និងរាជសាស្ត្រជាដើម ។

បទថា សិវវិជ្ជា បានដល់ វិជ្ជាពោលពីការ ចូលទៅធ្វើសេចក្តីស្ងប់ក្នុងព្រៃដែលចោលសាកសព ។ អាចារ្យខ្លះលោកពោលថា ជាវិជ្ជា

ដឹងសម្លេងស្រែកល្អរបស់ចចកក៏មាន ។

បទថា ភូតវិជ្ជា បានដល់ មន្តរបស់គ្រូខ្មោច ។

បទថា ភូរិវិជ្ជា បានដល់ មន្តដែលអ្នកនៅក្នុងស្រុកនឹងត្រូវរៀនទុក ។

បទថា អហិវិជ្ជា បានដល់ វិជ្ជារក្សាអ្នកត្រូវពស់ខាំ និងវិជ្ជាហៅពស់ ។

បទថា វិសវិជ្ជា បានដល់ វិជ្ជាដែលប្រើព្យាបាលពិសចាស់ ឬពិសថ្មី ឬធ្វើពិសយ៉ាងដទៃ ។

បទថា វិច្ឆិកវិជ្ជា បានដល់ វិជ្ជាស្តោះខ្ទួយទិច ។ សូម្បីក្នុងវិជ្ជាពោលអំពីកណ្តុរ ក៏ន័យនេះឯង ។

បទថា សកុណវិជ្ជា បានដល់ ដឹងសម្លេងបក្សីដោយដឹងសម្លេងស្រែក និងការទៅជាដើមរបស់សត្វមានស្លាប និងមិនមានស្លាប និងសត្វជើង ២ ជើង ៤ ។

បទថា វាយសវិជ្ជា បានដល់ ដឹងសម្លេងរបស់ក្អែក ។ ការដឹងនោះជាតម្រាផ្នែកមួយ ដូច្នោះ ទើបបានត្រាស់ទុកជាផ្នែកមួយ ។

បទថា បក្កជ្ឈានំ បានដល់ វិជ្ជាដោះស្រាយគំនិត អធិប្បាយថាជាការដឹងក្នុងវត្ថុដែលខ្លួនមិនឃើញ ក្នុងកាលឥឡូវនេះ ប្រព្រឹត្តទៅយ៉ាងនេះថា អ្នកនេះនឹងរស់នៅបានប៉ុណ្ណេះ អ្នកនេះប៉ុណ្ណេះ ។

បទថា សរបរិត្តាណំ បានដល់ វិជ្ជាបញ្ចៀសគ្រោះ គឺ ជាវិជ្ជាធ្វើឲ្យកូនសរមិនមកត្រូវខ្លួនបាន ។

បទថា មិគចក្កំ វិជ្ជាសម្រាប់មើលស្នាមជើងម្រឹគ គឺ សត្វជើង ៤ ទាំងអស់នេះ ត្រាស់រួមសត្វគ្រប់ប្រភេទ ដោយដឹងសម្លេងស្រែករបស់បក្សី និងសត្វជើង ៤ ទាំងអស់ ។

**[២០] ក្នុងការទាយលក្ខណៈកែវមណីជាដើម មានអធិប្បាយដូច្នេះ**

សមណព្រាហ្មណ៍ពួកខ្លះប្រកបរឿយៗ នូវការទាយលក្ខណៈកែវមណីជាដើម ដោយអំណាចពណ៌ និងសណ្ឋានជាដើម យ៉ាងនេះថា កែវមណីយ៉ាងនេះល្អ យ៉ាងនេះមិនល្អ ជាហេតុ មិនមែនហេតុ ឲ្យម្ចាស់របស់ប្រាសចាករោគ និងមានភាពជំក្រៃលែងជាដើម ។

ក្នុងការទាយលក្ខណៈនោះ ពាក្យថា អាវុធំ បានដល់ វត្ថុរបស់មានមុខមុត មានដាវជាដើម ក្រៅពីនោះ ឈ្មោះថា អាវុធ ។

សូម្បីការទាយលក្ខណៈស្រីជាដើម ក៏គប្បីជ្រាបដោយសេចក្តីចម្រើន និងសេចក្តីសាបសូន្យរបស់ត្រកូលដែលស្រីប្រុសជាដើមទាំងនោះ ។

ចំណែកក្នុងការទាយលក្ខណៈពពែជាដើម គប្បីជ្រាបសេចក្តីផ្សេងគ្នាដូច្នេះថា សាច់របស់សត្វ មានពពែជាដើម យ៉ាងនេះគួរស៊ី យ៉ាងនេះមិនគួរស៊ី ។

មួយទៀត ក្នុងការទាយលក្ខណៈសត្វទន្សងនេះ គប្បីជ្រាបសេចក្តី

ផ្សេងគ្នា សូម្បីក្នុងភាពចិត្រកម្ម និងគ្រឿងប្រដាប់ជាដើម សូម្បីដូច្នេះថា កាលមានសត្វទន្សោងយ៉ាងនេះ នឹងមានផលយ៉ាងនេះ ។

និងក្នុងសេចក្ដីនេះ មានរឿងដូចតទៅនេះ ៖

បានឮថា ទីវត្តមួយកន្លែង គេគូររូបចិត្រកម្ម ជារូបសត្វទន្សោងកំពុងព្រួសភ្លើង តាំងពីនោះមកភិក្ខុទាំងឡាយកើតជំលោះឈ្លោះគ្នាធំ ។ ភិក្ខុអាគន្តុកៈមួយរូប ឃើញរូបភាពនោះ ទើបលុបចេញតាំងពីនោះមកការឈ្លោះក៏ស្រាលចុះ ។

ការទាយលក្ខណៈជហ្វា គប្បីជ្រាបដោយជហ្វាជាគ្រឿងប្រដាប់ខ្លះ ជហ្វាផ្ទុះខ្លះ ។

ការទាយលក្ខណៈអណ្ដើក ក៏ដូចគ្នានឹងការទាយលក្ខណៈសត្វទន្សោងនុ៎ះឯង ។

ការទាយលក្ខណៈម្រឹគ ត្រាស់រួមសត្វគ្រប់ប្រភេទដោយលក្ខណៈរបស់សត្វជើង ៤ ទាំងអស់ ។

[២១] ពាក្យថា រញ្ញោ និយ្យានំ ភវិស្សតិ បានដល់ ព្យាករណ៍ការប្រពាតរបស់ព្រះរាជាទាំងឡាយ យ៉ាងនេះថា ព្រះរាជាអង្គឯណោះ ស្ដេចនឹងចេញទៅថ្ងៃឯណោះ ដោយឫក្សឯណោះ ។ គ្រប់បទមានន័យ ដូច្នេះ ទើបអធិប្បាយក្នុងបទនេះតែមួយ ។

ចំណែកបទថា អនិយ្យានំ ក្នុងទីនេះតែម្យ៉ាង បានដល់ កាល

ព្រះរាជាស្តេចទៅស្នាក់សម្រាកហើយត្រឡប់មក ។

ពាក្យថា ព្រះរាជាខាងក្នុងនឹងរុករានចូលមក ។ ព្រះរាជាខាងក្រៅនឹងថយចេញទៅ សេចក្តីថា ព្យាករណ៍ការចូលជិត និងការថយរបស់ព្រះរាជាទាំងឡាយយ៉ាងនេះថា ព្រះរាជារបស់ពួកយើងខាងក្នុងព្រះនគរនឹងចូលជិតព្រះរាជាខាងក្រៅដែលជាសត្រូវ លំដាប់នោះ ព្រះរាជាខាងក្រៅព្រះអង្គនោះនឹងថយ ។ សូម្បីក្នុងបទទីពីរ ក៏ន័យនេះឯង ។ ការឈ្នះនិងបរាជ័យ ប្រាកដហើយ ។ រឿងចន្ទគ្រាសជាដើម គប្បីជ្រាបដោយព្យាករណ៍ថា រាហូនឹងចាប់ចន្ទក្នុងថ្ងៃឯណោះ ។ មួយទៀត សូម្បីផ្កាយនក្សត្ររួមចាប់ផ្កាយអង្គារជាដើម ក៏ឈ្មោះនក្សត្រគ្រាស ន៉ុះឯង ។

[២២] បទថា ឧក្កាបាតោ បានដល់ គប់ភ្លើងធ្លាក់ពីអាកាស ។

បទថា ទិសាឌាហោ បានដល់ ទិសងងឹតឈឹង ដូចជាក្តៅក្រហាយដោយអណ្តាតភ្លើង និងផ្សែងជាដើម ។

បទថា ទេវទុន្ទុភិ បានដល់ ផ្គរគម្រាមរដូវប្រាំង ។

បទថា ឧគ្គមនំ បានដល់ ឡើង ។

បទថា ឱគ្គមនំ បានដល់ ធ្លាក់ ។

បទថា សង្កិលេសំ ប្រែថា មិនបរិសុទ្ធិ ។

បទថា វោទានំ ប្រែថា បរិសុទ្ធិ ។

បទថា ឯវំ វិបាកោ សេចក្តីថា នឹងនាំសុខ និងទុក្ខផ្សេងៗ យ៉ាង

នេះមកឲ្យដល់លោក ។

[២៣] បទថា សុវុដ្ឋិកា សេចក្ដីថា ភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។

បទថា ទុព្វុដ្ឋិកា សេចក្ដីថា ភ្លៀងធ្លាក់មួនម្ដាល អធិប្បាយថា ភ្លៀងតិច ។

បទថា មុទ្ទា លោកពោលដល់ ការរាប់ដោយមេដៃ ។

បទថា គណនា បានដល់ ការរាប់មិនដាច់ខ្សែ ។

បទថា សង្ខានំ បានដល់ ការរាប់រួមដោយការបូក និងការគុណជាដើម ។ អ្នកដែលជំនាញការរាប់រួមនោះ ពេលឃើញដើមឈើក៏ដឹងបានថា ក្នុងដើមនេះមានស្លឹកប៉ុណ្ណេះ ។

បទថា កាវេយ្យំ សេចក្ដីថា កិរិយាដែលកវីទាំង ៤ ពួក ដូចដែលត្រាស់ទុកដូច្នេះថា ៖

ម្នាលភិក្ខុទាំងឡាយ កវីមាន ៤ ពួក គឺ ចិន្តាកវី សុតកវី អត្ថកវី បដិភាណកវី ដូច្នេះ , តែងកាព្យដើម្បីចិញ្ចឹមជីវិត ដោយការគិតរបស់ខ្លួនខ្លះ ដោយស្ដាប់ព្រោះបានស្ដាប់រឿងមានជាអាទិថា មានព្រះរាជាព្រះនាមវេស្សន្តរ ដូច្នេះខ្លះ ដោយន័យយ៉ាងនេះថា រឿងនេះមានន័យយ៉ាងនេះ យើងនឹងតែងរឿងនោះ យ៉ាងនេះ ដូច្នេះខ្លះ ដោយបដិភាណដែលកើតឡើងតាមហេតុការណ៍យ៉ាងនេះថា យើងបានឃើញហេតុការណ៍ខ្លះៗ នឹង

តែងការព្យឲ្យគេចូលចិត្តបានក្នុងរឿងនោះខ្លះ ។ រឿងដែលទាក់ទងជាមួយលោក ខ្ញុំម្ចាស់បានពោលហើយ ។

[២៤] ដែលឈ្មោះថា **ឲ្យរៀបអាវាហមង្គល** បានដល់ ឲ្យធ្វើពិធីអាវាហមង្គលថា លោកទាំងឡាយ ចូរនាំកូនស្រីពីត្រកូលឯណោះ មកឲ្យកូនប្រុសនេះ ដោយឫក្សឯណោះ ។

បទថា វិវាហំ សេចក្តីថា ឲ្យធ្វើពិធីវិវាហមង្គលថា លោកទាំងឡាយចូរនាំកូនស្រីនេះ ទៅឲ្យកូនប្រុសឯណោះ ដោយឫក្សឯណោះ គេនឹងមានសេចក្តីចម្រើន ។

បទថា សំវទនំ សេចក្តីថា ដែលឈ្មោះថា ឫក្សបញ្ជូនខ្លួន បានដល់ ពិធីធ្វើឲ្យគូកូនប្រុស និងកូនស្រី ស្រុះស្រួលគ្នាយ៉ាងនេះថា ថ្ងៃនេះឫក្សល្អ អ្នកទាំង ២ ចូរស្រុះស្រួលគ្នាក្នុងថ្ងៃនេះឯង អ្នកទាំង ២ នឹងមិនលែងលះគ្នា ដោយប្រការដូច្នេះ ។

ដែលឈ្មោះថា វិវទនំ បានដល់ បើស្វាមីភរិយាប្រាថ្នានឹងលែងលះគ្នា ក៏មើលឫក្ស ធ្វើពិធីលែងលះយ៉ាងនេះថា លោកចូរលែងគ្នាដាច់ក្នុងថ្ងៃនេះឯង លោកនឹងមិនរួមគ្នាទៀត ដោយប្រការដូច្នេះ ។

បទថា សង្កិរណំ សេចក្តីថា មើលឫក្សឲ្យរួបរួមទ្រព្យយ៉ាងនេះថា ទ្រព្យដែលឲ្យខ្ចីក្តី ជាបំណុលក្តី លោកចូរទារឲ្យបានក្នុងថ្ងៃនេះ ព្រោះទ្រព្យដែលទារក្នុងថ្ងៃនេះនឹងជាវរៈ ។

បទថា វិកិរណំ សេចក្ដីថា មើលឫក្សរកប្រយោជន៍ដោយខ្លួនឯង ឬឲ្យអ្នកដទៃរកប្រយោជន៍យ៉ាងនេះថា បើលោកត្រូវការនឹងរកប្រយោជន៍ដោយការចុះទុន និងឲ្យខ្ចីជាដើម ទ្រព្យដែលរកប្រយោជន៍ក្នុងថ្ងៃនេះ នឹងបន្ថែមជា ២ ដង ៤ ដង ។

បទថា សុភគករណំ សេចក្ដីថា មើលឫក្សធ្វើឲ្យជាទីស្រឡាញ់ ជាទីពេញចិត្ត ឬធ្វើឲ្យមានសិរី ។

បទថា ទុព្ភគករណំ សេចក្ដីផ្ទុយគ្នានឹងបទ សុភគករណំ នោះ ។

បទថា វិរុទ្ធគព្ភករណំ សេចក្ដីថា ធ្វើគភ៌ដែលធ្លាក់ ដែលទម្លាយ ដែលចាក់ ដែលស្លាប់ អធិប្បាយថា ឲ្យថ្នាំដើម្បីមិនឲ្យម៉ែវិនាសតទៅ ។

ក៏គភ៌ រមែងវិនាសដោយហេតុ ៣ យ៉ាង គឺ ខ្យល់ រោគ កម្ម ។

ក៏គភ៌វិនាស ៣ យ៉ាងនោះ កាលគភ៌វិនាសដោយខ្យល់ ត្រូវឲ្យថ្នាំត្រជាក់ៗ សម្រាប់រម្ងាប់ ។ កាលវិនាសដោយមេរោគ ត្រូវព្យាបាលរោគ ។ តែកាលវិនាសដោយកម្ម សូម្បីព្រះពុទ្ធទាំងឡាយ ក៏មិនអាចនឹងហាមបាន ។

បទថា ជិវ្ហានិពន្ធនំ បានដល់ វាយមន្តចងអណ្ដាតទុក ។

បទថា ហនុសំហននំ បានដល់ វាយមន្តចងមាត់ ចងទុកមិនអាចនឹងឲ្យថ្គាមកម្រើកបាន ។

បទថា ហត្ថាភិជប្បនំ បានដល់ រាយមន្តធ្វើឲ្យដៃទាំង ២ ញ័រ ។ បានឮថា កាលឈរខាងក្នុង ៧ ជំហាន រាយមន្តនោះហើយ បុគ្គលម្នាក់ទៀតក៏មានដៃញ័រ ត្រឡប់ទៅមក ។

បទថា កណ្ណជប្បនំ បានដល់ រាយវេទធ្វើឲ្យត្រចៀកទាំង ២ មិនបានឮសម្លេង ។ បានឮថា រាយមន្តនោះហើយ ពោលតាមប្រាថ្នាក្នុងសាលា ចំណែកបរបក្ខមិនបានឮសម្លេងនោះ ដូច្នោះ ទើបមិនអាចឆ្លើយឆ្លងបាន ។

បទថា អាទាសបញ្ហំ បានដល់ មន្តអញ្ជើញទេវតាចូលក្នុងកញ្ចក់ហើយសួរបញ្ហា ។

បទថា កុមារីបញ្ហំ បានដល់ មន្តអញ្ជើញទេវតា ចូលក្នុងរាងកាយរបស់ក្មេងស្រី ហើយសួរបញ្ហា ។

បទថា ទេវបញ្ហំ បានដល់ មន្តអញ្ជើញទេវតាចូលក្នុងរាងកាយរបស់នាងទាសី ហើយសួរបញ្ហា ។

បទថា អាទិច្ចុបដ្ឋានំ បានដល់ បម្រើព្រះអាទិត្យដើម្បីប្រយោជន៍ក្នុងការរស់នៅ ។

បទថា មហតុបដ្ឋានំ បានដល់ បម្រើស្តេចមហាព្រហ្មដើម្បីប្រយោជន៍តែម្យ៉ាងដូចគ្នា ។

បទថា អព្ភុជ្ជលនំ បានដល់ រាយមន្តផ្លុំភ្លើងចេញពីមាត់ ។

បទថា សិរីវ្ហាយនំ បានដល់ អញ្ជើញសិរីចូលខ្លួនយ៉ាងនេះថា សិរីអើយ ចូរមកនៅក្នុងរាងកាយយើង ។

[២៥] បទថា សន្តិកម្មំ បានដល់ ទៅទេវស្ថាន ធ្វើពិធីសញ្ញាលើផ្ទះដែលនឹងត្រូវធ្វើក្នុងវេលាដែលសម្រេចថា បើរឿងនេះនឹងសម្រេចដល់ខ្ញុំ ខ្ញុំនឹងលាបំណន់ដល់លោកដោយវត្ថុនេះៗ ។ និងកាលរឿងនោះរួចស្រេចហើយ ធ្វើតាមនោះឈ្មោះថា ធ្វើពិធីលាបំណន់ ។

បទថា ភូរិកម្មំ បានដល់ បង្រៀនការប្រើមន្តដែលអ្នកនៅក្នុងស្រុកនឹងត្រូវរៀន ។

ក្នុងប្រការថា វស្សកម្មំ វោស្សកម្មំ បទថា វស្សោ បានដល់ ប្រុស បទថា វោស្សោ បានដល់ ខ្ទើយ ។ ការធ្វើខ្ទើយឲ្យជាប្រុស ឈ្មោះថា វស្សកម្ម ការធ្វើប្រុសឲ្យជាខ្ទើយ ឈ្មោះថា វោស្សកម្ម ដោយប្រការដូច្នេះ ។ ក៏កាលធ្វើដូច្នោះ រមែងឲ្យដល់ត្រឹមតែភាវៈដែលកាត់ប៉ុណ្ណោះ មិនអាចធ្វើឲ្យភេទវិនាសទៅបាន បទថា វត្ថុកម្មំ បានដល់ ធ្វើពិធីសាងផ្ទះក្នុងផ្ទៃដីដែលនៅមិនបានតាក់តែង ។

បទថា វត្ថុបរិករណំ បានដល់ ពោលថា លោកទាំងឡាយ ចូរនាំវត្ថុនេះៗ មកដូច្នេះ ហើយធ្វើពិធីបួងសួងផ្ទៃដី ។

បទថា អាចមនំ បានដល់ ប្រើទឹកលាងមាត់ឲ្យស្អាត ។

បទថា ន្ហាបនំ បានដល់ ងូតទឹកមន្តឲ្យអ្នកដទៃ ។

បទថា ជុហានំ បានដល់ ធ្វើពិធីបូជាភ្លើង ដើម្បីប្រយោជន៍ដល់ពួកគេ ។

បទថា វមនំ បានដល់ ធ្វើថ្នាំសម្រក ។ សូម្បីក្នុងការផ្សំថ្នាំបញ្ចុះ ក៏ន័យនេះដូចគ្នា ។

បទថា ឧទ្ធវិរេចនំ បានដល់ ផ្សំថ្នាំបញ្ចុះរោគខាងលើ ។

បទថា អធោវិរេចនំ បានដល់ ផ្សំថ្នាំបញ្ចុះរោគខាងក្រោម ។

បទថា សីសវិរេចនំ បានដល់ ផ្សំថ្នាំព្យាបាលរោគឈឺសីសៈ ។

បទថា កណ្ណតេលំ បានដល់ ស្លប្រេងថ្នាំសម្រាប់បន្តក់ត្រចៀក ឬដើម្បីផ្សះដំបៅ ។

បទថា នេត្តប្បានំ បានដល់ ប្រេងបន្តក់ភ្នែក ។

បទថា នត្ថុកម្មំ បានដល់ ប្រើប្រេងផ្សំជាថ្នាំហិត ។

បទថា អញ្ជនំ បានដល់ ផ្សំថ្នាំលាប បន្ទាត់ចំរុះ អាចបកបាន ២ ឬ ៣ ជាន់ ។

បទថា បច្ចញ្ជនំ បានដល់ ផ្សំថ្នាំ ត្រជាក់រម្ងាប់ ។

បទថា សាលាកិយំ បានដល់ គ្រឿងប្រដាប់របស់ចក្ខុពេទ្យ ។

បទថា សល្លកត្តិយំ បានដល់ គ្រឿងប្រដាប់សល្យពេទ្យ ។

កិច្ចកម្មរបស់ពេទ្យរក្សារោគកុមារ ហៅថា ទារកតិកិច្ឆា កុមារវេជ្ជកម្ម ។

*ដោយពាក្យថា មូលភេសជ្ជានំ អនុប្បទានំ ( ដាក់ថ្នាំ ) នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ការរក្សាកាយ ។*

*បទថា ឱសធីនំ បដិមោក្ខោ បានដល់ ដាក់ក្បួនជាដើម កាលដំបៅដែលគួរដល់ក្បួនជាដើមនោះ ក៏យកក្បួនជាដើមនោះចេញទៅ ។*

ចប់ មហាសីល

# បុព្វន្តកប្បិកសស្សតវាទ

[២៦] ព្រះមានព្រះភាគ គ្រាទ្រង់ពណ៌នាសីល ៣ ប្រការ ដោយពិស្ដារ ដោយអនុសន្ធិនៃពាក្យសរសើរដែលព្រហ្មទត្តមាណពពោល ដោយប្រការដូច្នេះហើយ ឥឡូវនេះ ទ្រង់ផ្ដើមប្រកាសសេចក្ដីសូន្យទទេ ដោយន័យមានជាអាទិថា ម្នាលភិក្ខុទាំងឡាយ នៅមានធម៌ដទៃៗ ដែលជ្រាលជ្រៅឃើញបានលំបាក ដូច្នេះ ដោយអនុសន្ធិនៃពាក្យសរសើរ ដែលភិក្ខុសង្ឃពោល ។

ពាក្យថា ធម្មា ក្នុងព្រះបាលីនោះ ពាក្យថា ធម្ម ស័ព្ទ ប្រព្រឹត្តទៅក្នុងអត្ថទាំងឡាយ មានជាដើមយ៉ាងនេះថា គឺ គុណធម៌ ទេសនាធម៌ បរិយត្តិធម៌ និស្សត្តធម៌ ។

ពិតហើយ ធម្ម ស័ព្ទ ប្រព្រឹត្តទៅក្នុងគុណធម៌ ដូចក្នុងប្រយោគមានជាដើមថា

**ធម៌ និងអធម៌ ទាំងពីរនេះ មិនមានផលស្មើគ្នាទេ អធម៌នាំទៅនរក ធម៌ឲ្យសត្វដល់សុគតិ ។**

ប្រព្រឹត្តទៅក្នុងទេសនាធម៌ ដូចក្នុងប្រយោគមានជាដើមថា

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងធម៌មានលំអបទដើម....... ចំពោះអ្នក ទាំងឡាយ ។

ប្រព្រឹត្តទៅក្នុង**បរិយត្តិធម៌** ដូចប្រយោគមានជាដើមថា **ភិក្ខុក្នុងធម្មវិន័យនេះ រមែងរៀនធម៌ គឺ សុត្តៈ គេយ្យៈ ។ល។ ។**

ប្រព្រឹត្តទៅក្នុង**និស្សត្តធម៌** ដូចក្នុងប្រយោគមានជាដើមថា **ក្នុងសម័យនោះឯង ធម៌មានហើយ គឺ ខន្ធទាំងឡាយមានហើយ ។**

ក៏ក្នុងព្រះបាលីនេះ ធម្ម សព្ទ ប្រព្រឹត្តទៅក្នុងគុណធម៌ ។ ព្រោះដូច្នោះ គប្បីឃើញសេចក្តីក្នុងព្រះបាលីនេះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនៅមានគុណដទៃៗ ទៀត ។

បទថា គម្ភីរា សេចក្តីថា មានទីតាំងដែលញាណរបស់បុគ្គលដទៃចាក់ជ្រៅមិនបានវៀរលែងតែតថាគត ដូចមហាសមុទ្រ ដែលចុងមាត់មូសចាក់មិនដល់ ដូច្នោះ ។

ដែលឈ្មោះថា ឃើញបានដោយលំបាក ព្រោះជ្រាលជ្រៅនុ៎ះឯង ។

ដែលឈ្មោះថា បានដោយលំបាក ព្រោះឃើញបានលំបាកនុ៎ះឯង ។

ដែលឈ្មោះថា ស្ងប់ ព្រោះរលត់សេចក្តីក្តៅក្រហាយទាំងអស់ ។

ដែលឈ្មោះថា បណីត ព្រោះធ្វើឲ្យមិនស្គាល់ឆ្អែត ដូចភោជនដែលមានរសឆ្ងាញ់ ។

ដែលឈ្មោះថា សួងមិនបាន ព្រោះធ្វើការប៉ាន់ស្មានយកមិនបានហេតុជាវិស័យនៃញាណដែលខ្ពស់បំផុត ។

ដែលឈ្មោះថា ល្អិត ព្រោះមានសភាពល្អិត ។

ដែលឈ្មោះថា ដឹងបានចំពោះបណ្ឌិត ព្រោះបណ្ឌិតប៉ុណ្ណោះគប្បីដឹង ហេតុមិនមែនវិស័យរបស់បុគ្គលពាល ។

ពាក្យថា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សេចក្តីថា នូវគុណធម៌ដែលតថាគតជាអ្នកដែលមិនមានបុគ្គលដទៃណែនាំ ក៏ធ្វើឲ្យប្រចក្សដោយព្រះប្រាជ្ញាញាណដ៏វិសេសក្រៃលែងតែម្យ៉ាង ហើយទូន្មានអ្នកដទៃឲ្យដឹងច្បាស់ គឺ សម្តែង ពោល ប្រកាស ។

បទថា យេហិ សេចក្តីថា ដោយគុណធម៌ពួកណា ។

បទថា យថាភុច្ចំ ប្រែថា តាមសេចក្តីពិត ។

ប្រការថា វណ្ណំ សម្មា វទមានា វទេយ្យុំ សេចក្តីថា អ្នកប្រាជ្ញានឹងពោលសរសើរតថាគត គប្បីពោលបានដោយប្រពៃ អធិប្បាយថា អាចពោលបានមិនខ្វះខាត ។

សួរថា ក៏ធម៌ដែលព្រះមានព្រះភាគទ្រង់សរសើរយ៉ាងនេះ បានដល់អ្វី ?

ឆ្លើយថា បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។

សួរថា បើយ៉ាងនោះ ហេតុដូចម្តេច ទ្រង់ធ្វើនិទ្ទេសជាពហុវចនៈ ។

ឆ្លើយថា ព្រោះប្រកបដោយចិត្តច្រើនដួង និងមានអារម្មណ៍ច្រើន ។

ពិតហើយ ព្រះសព្វញ្ញុតញ្ញាណនោះ បានក្នុងមហាកិរិយាចិត្តដែលជាញាណសម្បយុត្ត ៤ ដួង ។ និងធម៌អ្វីៗ ដែលមិនឈ្មោះថា ជាអារម្មណ៍

របស់ព្រះសព្វញ្ញុតញ្ញាណនោះ មិនមាន ។ សមដូចពាក្យដែលព្រះសារីបុត្រពោលទុកជាដើមថា ឈ្មោះថា **ព្រះសព្វញ្ញុតញ្ញាណ** ព្រោះដឹងធម៌ទាំងអស់ ពោលគឺ ធម៌ជាអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា **អនាវរណញ្ញាណ** ព្រោះមិនមានគ្រឿងរាំងក្នុងព្រះញាណនោះ ។ ទ្រង់ធ្វើនិទ្ទេសជាពហុវចនៈ ព្រោះប្រកបដោយចិត្តច្រើនដួង និងព្រោះមានអារម្មណ៍ច្រើន ដោយអំណាចដែលកើតឡើងរឿយៗ ដោយប្រការដូច្នេះឯង ។

ចំណែកពាក្យថា អញ្ញេវ នេះ ជាពាក្យកំណត់ទុកក្នុងព្រះបាលីនេះ គប្បីប្រកបនឹងបទគ្រប់បទយ៉ាងនេះថា ធម៌ពួកដទៃមិនមែនធម៌មានវៀរចាកបាណាតិបាតជាដើម ជ្រាលជ្រៅពិតៗ មិនមែនរាក់ទេ ។

ក៏សាវកបារមីញាណជ្រាលជ្រៅ តែបច្ចេកពោធិញាណជ្រាលជ្រៅជាងនោះ ដូច្នោះ ទើបមិនមានពាក្យកំណត់ទុកក្នុងសាវកបារមីញាណនោះ និងព្រះសព្វញ្ញុតញ្ញាណ ជ្រាលជ្រៅជាងបច្ចេកពោធិញាណនោះ ដូច្នោះ ទើបមិនមានពាក្យកំណត់ទុកក្នុងបច្ចេកពោធិញាណនោះ ចំណែកញាណដទៃដ៏ជ្រាលជ្រៅជាង ព្រះសព្វញ្ញុតញ្ញាណនេះមិនមាន ដូច្នោះ ទើបបានពាក្យកំណត់ថា ជ្រាលជ្រៅតែម្យ៉ាង ។ គប្បីជ្រាបពាក្យទាំងអស់ថា ឃើញបានលំបាក ដឹងតាមបានលំបាក ដូច្នោះ ។

ក៏ពាក្យសួរក្នុងបទថា កតមេ ច តេ ភិក្ខវេ ធម្មា នេះ ជាពាក្យ

សួរដើម្បីប្រាថ្នានឹងដោះស្រាយធម៌ទាំងនោះ ។

[២៧] ក្នុងពាក្យជាដើមថា សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ដូច្នេះ ជាពាក្យឆ្លើយ និងពាក្យសួរ ។

បើនឹងមានពាក្យសួរថា ក៏ហេតុណាទើបទ្រង់ផ្ដើមពាក្យឆ្លើយ ពាក្យសួរនេះយ៉ាងណា ?

ឆ្លើយថា ការដែលព្រះពុទ្ធទាំងឡាយ ទ្រង់ដល់ឋានៈ ៤ ប្រការ ហើយទ្រង់បន្លឺជាការធំក្រៃលែង ព្រះប្រាជ្ញាញាណក៏ជាប់តាមមក សេចក្ដីដែលព្រះពុទ្ធញាណធំក្រៃលែង រមែងប្រាកដ ព្រះធម៌ទេសនាជ្រាលជ្រៅ សង្កត់ទុកដោយព្រះត្រៃលក្ខណ៍ ប្រកបដោយសុញ្ញតា ។

## ឋានៈ ៤ ប្រការអ្វីខ្លះ ។

គឺ ទ្រង់បញ្ញត្តព្រះវិន័យប្រការ ១ ទ្រង់កំណត់ធម៌ដែលជាភូមិពិសេសប្រការ ១ ទ្រង់ចែកបច្ចយាការប្រការ ១ ទ្រង់ដឹងដល់លទ្ធិដទៃប្រការ ១ ។

ព្រោះដូច្នោះ ធម្មតាថា ទ្រង់បញ្ញត្តសិក្ខាបទ ក្នុងកាលរឿងកំណត់គ្នាបានយ៉ាងនេះថា នេះទោសស្រាល នេះទោសធ្ងន់ នេះជាកំហុសដោះស្រាយមិនបាន នេះជាអាបត្តិ នេះមិនជាអាបត្តិ នេះជាអាបត្តិដល់កម្រិតដាច់ខាត នេះជាអាបត្តិដល់កម្ម នេះជាអាបត្តិថ្នាក់សម្ដែង នេះជាលោក-

វជ្ជៈ នេះជាបណ្ណត្តិវជ្ជៈ គួរបញ្ញត្តប្រការនេះចូលក្នុងរឿងនេះ ដូច្នេះ ក្នុងការបញ្ញត្តសិក្ខាបទនោះ អ្នកដទៃមិនអាចមានប្រាជ្ញា រឿងនេះមិនមែនវិស័យរបស់អ្នកដទៃ ជាវិស័យរបស់ព្រះតថាគតប៉ុណ្ណោះ ។ ដូច្នោះ កាលព្រះពុទ្ធទាំងឡាយទ្រង់ដល់ឋានៈ គឺ ទ្រង់បញ្ញត្តព្រះវិន័យ ដូច្នេះ ទ្រង់បន្ទឺទើបជាការធំក្រៃលែង ព្រះប្រាជ្ញាញាណក៏ជាប់តាមមក ប្រកបដោយសុញ្ញតា ដូច្នេះឯង ។

មួយទៀត បុគ្គលពួកដទៃមិនអាចមានប្រាជ្ញា នឹងពោលចែកអភិធម្មបិដក សមន្តបដ្ឋានអនន្តន័យ ២៤ ប្រការថា ឈ្មោះថា សតិបដ្ឋាន ៤ ។បេ។ ឈ្មោះថា អរិយមគ្គមានអង្គ ៨ ឈ្មោះថា ខន្ធ ៥ ឈ្មោះថា អាយតនៈ ១២ ឈ្មោះថា ធាតុ ១៨ ឈ្មោះថា អរិយសច្ច ៤ ឈ្មោះថា ឥន្ទ្រិយ ២២ ឈ្មោះថា ហេតុ ៩ ឈ្មោះថា អាហារ ៤ ឈ្មោះថា ផស្សៈ ៧ ឈ្មោះថា វេទនា ៧ ឈ្មោះថា សញ្ញា ៧ ឈ្មោះថា ចេតនា ៧ ឈ្មោះថា ចិត្ត ៧ ក្នុងធម៌ទាំងនេះ ឈ្មោះថា កាមាវចរធម៌ប៉ុណ្ណេះ ឈ្មោះថា រូបាវចរបរិយាបន្នធម៌ប៉ុណ្ណេះ ឈ្មោះថា អរូបាវចរអបរិយាបន្នធម៌ប៉ុណ្ណេះ ឈ្មោះថា លោកិយធម៌ប៉ុណ្ណេះ ឈ្មោះថា លោកុត្តរធម៌ប៉ុណ្ណោះ ដូច្នេះ ។ រឿងនេះមិនមែនជាវិស័យរបស់អ្នកដទៃ ជាវិស័យរបស់ព្រះតថាគតប៉ុណ្ណោះ ដូច្នោះ ។ ព្រះពុទ្ធទាំងឡាយទ្រង់ដល់ឋានៈ គឺ ទ្រង់កំណត់ធម៌ដែល ជាភូមិពិសេស ទ្រង់បន្ទឺ ទើបជាការធំក្រៃលែង ព្រះ-

ប្រាជ្ញាញាណក៏ជាប់តាមមក ប្រកបដោយសុញ្ញតា ដូច្នេះឯង ។

មួយទៀត អវិជ្ជាណា ជាបច្ច័យដល់សង្ខារទាំងឡាយ ដោយអាការ ៩ យ៉ាង គឺ អវិជ្ជានោះ ជាបច្ច័យដោយការៈដែលកើតឡើង ១ ជាបច្ច័យដោយការៈដែលប្រព្រឹត្តទៅ ១ ជាបច្ច័យដោយការៈដែលជានិមិត្ត ១ ជាបច្ច័យដោយការប្រមូលមក ១ ដោយជាការប្រកបរួម ១ ដោយសេចក្តីកង្វល់ ១ ដោយជាសមុទ័យ ១ ដោយជាហេតុ ១ ដោយជាបច្ច័យ ១ ។

មួយទៀត សង្ខារជាដើម ក៏ជាបច្ច័យដល់វិញ្ញាណជាដើម ដោយអាការ ៩ យ៉ាង ដូចដែលព្រះសារីបុត្រពោលទុកថា បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ តើដូចម្តេច ? គឺ អវិជ្ជាជាទីតាំងនៃការកើតរបស់សង្ខារ ១ ជាទីតាំងនៃការប្រព្រឹត្តទៅរបស់សង្ខារ ១ ជាទីតាំងនៃនិមិត្តរបស់សង្ខារ ១ ជាទីតាំងនៃការប្រមូលមករបស់សង្ខារ ១ ជាទីតាំងនៃការប្រកបរួមរបស់សង្ខារ ១ ជាទីតាំងនៃកង្វល់របស់សង្ខារ ១ ជាទីតាំងនៃសមុទ័យរបស់សង្ខារ ១ ជាទីតាំងនៃហេតុរបស់សង្ខារ ១ ជាទីតាំងនៃបច្ច័យរបស់សង្ខារ ១ អវិជ្ជាជាបច្ច័យដោយអាការ ៩ យ៉ាងនេះ , សង្ខារជាធម៌ដែលអាស្រ័យគ្នាកើតឡើង ធម៌ទាំង ២ នេះ ជាបច្ច័យ និងកើតពីបច្ច័យ បញ្ញាក្នុងការកំណត់បច្ច័យដូចពោលមកនេះ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ទាំងអតីតកាល ទាំងអនាគតកាល អវិជ្ជា

ជាទីតាំងនៃការកើតឡើងរបស់សង្ខារ ជាទីតាំងនៃបច្ច័យរបស់សង្ខារ អវិជ្ជាជាបច្ច័យដោយអាការ ៩ យ៉ាងនេះ ។ សង្ខារជាធម៌ដែលអាស្រ័យគ្នាកើតឡើង ធម៌ទាំងពីរប្រការនេះ ជាបច្ច័យ និងកើតពីបច្ច័យ បញ្ញាក្នុងការកំណត់បច្ច័យដូចពោលមកនេះ ឈ្មោះ **ធម្មដ្ឋិតិញាណ** , ជាតិ ជាទីតាំងនៃការកើតរបស់ជរាមរណៈ ១ និងជាទីតាំងនៃបច្ច័យរបស់ ជរា-មរណៈ ១ ជាតិជាបច្ច័យដោយអាការ ៩ យ៉ាងនេះ , ជរាមរណៈ កើតពីបច្ច័យ ធម៌ទាំង ២ ប្រការនេះ ជាបច្ច័យ និងកើតពីបច្ច័យ បញ្ញាក្នុងការកំណត់បច្ច័យ ដូចពោលមកនេះ ឈ្មោះ **ធម្មដ្ឋិតិញាណ** ដូច្នេះ ។ បុគ្គលពួកដទៃ មិនអាចមានប្រាជ្ញា នឹងពោលចែកបដិច្ចសមុប្បាទ ដែលមាន វដ្តៈ ៣ មានកាល ៣ មានសន្ធិ ៣ មានសង្ខេប ៤ មានអាការ ២០ ដែលប្រព្រឹត្តទៅដោយភាពជាបច្ច័យ ដោយប្រការនោះៗ ដល់ធម៌ នោះៗ ដូចពណ៌នាមកដូច្នេះបាន នេះមិនមែនវិស័យរបស់អ្នកដទៃ ជាវិស័យរបស់ព្រះតថាគតប៉ុណ្ណោះ ។ ដូច្នោះ ព្រះពុទ្ធទាំងឡាយទ្រង់ដល់ឋានៈ គឺបច្ចយាការ ទ្រង់បន្ទឺ ទើបជាការធំក្រៃលែង ព្រះប្រាជ្ញាញាណក៏ជាប់តាមមក ប្រកបដោយសុញ្ញតា ដូច្នេះឯង ។

មួយទៀត ពួកបុគ្គលដែលឈ្មោះថា សស្សតវាទៈ មាន ៤

ពួកបុគ្គលដែលឈ្មោះថា ឯកច្ចសស្សតវាទៈ មាន ៤

ពួកបុគ្គលដែលឈ្មោះថា អន្តានន្តិកៈ មាន ៤

ពួកបុគ្គលដែលឈ្មោះថា អមរាវិក្ខេប: មាន ៤

ពួកបុគ្គលដែលឈ្មោះថា អធិច្ចសមុប្បន្និក: មាន ២

ពួកបុគ្គលដែលឈ្មោះថា សញ្ញីវាទ: មាន ១៦

ពួកបុគ្គលដែលឈ្មោះថា អសញ្ញីវាទ: មាន ៨

ពួកបុគ្គលដែលឈ្មោះថា នេវសញ្ញីនាសញ្ញីវាទ: មាន ៨

ពួកបុគ្គលដែលឈ្មោះថា ឧច្ឆេទវាទ: មាន ៧

ពួកបុគ្គលដែលឈ្មោះថា ទិដ្ឋធម្មនិព្វានវាទ: មាន ៥

បុគ្គលទាំងនោះអាស្រ័យទិដ្ឋិនេះហើយ ប្រកាន់ទិដ្ឋិនេះ ដូច្នោះ ទើប រួមជាទិដ្ឋិ ៦២ បុគ្គលពួកដទៃមិនមានប្រាជ្ញា មិនអាចនឹងពោលទម្លាយទិដ្ឋិទាំងនោះ ជម្រះមិនឲ្យស្មុគ្រស្មាញបាន នេះមិនមែនវិស័យរបស់អ្នកដទៃ ជាវិស័យរបស់ព្រះតថាគតប៉ុណ្ណោះ ដូច្នោះ ព្រះពុទ្ធទាំងឡាយទ្រង់ដឹងដល់ឋាន: ដែលជាលទ្ធិដទៃ ដូច្នេះហើយទ្រង់បន្លឺ ទើបជាការដ៏ក្រៃលែងចាត់ចូលជាព្រះប្រាជ្ញាញាណ រមែងជាប់តាមមកនូវភាពដ៏ធំក្រៃលែងនៃព្រះពុទ្ធញាណក៏ប្រាកដ ទេសនារមែងជ្រាលជ្រៅ សន្កត់ទុកដោយលក្ខណ: ៣ ប្រកបដោយសុញ្ញតា ដូច្នេះឯង ។

តែក្នុងទីនេះ បានឋាន: គឺ លទ្ធិដទៃ ដូច្នោះ ព្រះមានព្រះភាគទ្រង់ជាធម្មរាជា កាលទ្រង់ជាប់តាមឋាន: គឺ លទ្ធិដទៃ ដើម្បីទ្រង់សម្តែងសេចក្តី ដែលព្រះសព្វញ្ញុតញ្ញាណធំក្រៃលែង និងដើម្បីទ្រង់ប្រកបសុញ្ញតា

ដោយព្រះធម៌ទេសនា ទើបទ្រង់ផ្តើមពាក្យសួរ និងឆ្លើយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា សន្តិ សេចក្តីថា មានប្រាកដកើតឡើង ។

បទថា ភិក្ខវេ ជាពាក្យអាលបនៈ ។

បទថា ឯកេ ក៏គឺ ពួកខ្លះ ។

បទថា សមណព្រាហ្មណា សេចក្តីថា ដែលឈ្មោះថា សមណៈ ព្រោះបានបួស ដែលឈ្មោះថា ព្រាហ្មណ៍ ដោយកំណើត ។ម្យ៉ាងទៀត លោកសន្មតយ៉ាងនេះថា សមណៈខ្លះ ព្រាហ្មណ៍ខ្លះ ។

សមណព្រាហ្មណ៍ ឈ្មោះថា បុព្វន្តកប្បិកា ព្រោះកំណត់ គឺ ចែកខន្ធចំណែកអតីតហើយប្រកាន់ ។ ម្យ៉ាងទៀត ឈ្មោះថា បុព្វន្ត-កប្បិកា ព្រោះការកំណត់ខន្ធចំណែកអតីត មានដល់សមណព្រាហ្មណ៍ទាំងនោះ ។

ស័ព្ទថា អន្តោ នេះក្នុងព្រះបាលីនោះ ប្រើក្នុងអត្ថ គឺ ពោះវៀនធំ ខាងក្នុង ព្រំដែន អាក្រក់ បំផុត ចំណែក ។

ពិតមែន អន្ត ស័ព្ទ ប្រើក្នុងអត្ថថា ពោះវៀន ដូចក្នុងប្រយោគមានជាដើមថា អន្តបូរោ ឧទរបូរោ កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង ។

ប្រើក្នុងអត្ថថា **ខាងក្នុង** ដូចក្នុងប្រយោគមានជាដើមថា ចរន្តិ

លោកេ បរិវារឆន្នា អន្តោ អសុទ្ធា ពហិ សោភមានា បុគ្គលមិនសង្រួម ខាងក្នុងមិនបរិសុទ្ធ ស្អាតតែខាងក្រៅ ហែហមដោយបរិវារ ត្រាច់ទៅក្នុងលោកបាន ។

ប្រើក្នុងអត្ថថា **ព្រំដែន** ដូចក្នុងប្រយោគមានជាដើមថា កាយ-ពន្ធនស្ស អន្តោ ជិរតិ សា ហរិតន្តំ វា បថន្តំ វា រីមកាយពន្ធក៏ចាស់ភ្លើងនោះ ឆេះដល់ដែននៃស្មៅស្រស់ខ្លះ ដែននៃផ្លូវធំខ្លះ ។

ប្រើក្នុងអត្ថថា **អាក្រក់** ដូចក្នុងប្រយោគមានជាដើមថា អន្តមិទំ ភិក្ខវេ ជីវិកានំ យទិទំ បិណ្ឌោល្យំ ម្នាលភិក្ខុទាំងឡាយ បណ្តាការចិញ្ចឹមជីវិតទាំងឡាយ ការចិញ្ចឹមជីវិតដោយបិណ្ឌបាត្រនេះ អាក្រក់ ។

ប្រើក្នុងអត្ថថា **ទីបំផុត** ដូចក្នុងប្រយោគមានជាដើមថា ឯសេវន្តោ ទុក្ខស្ស នេះឯង ជាទីបំផុតនៃទុក្ខ ។

ពិតហើយ ការអស់ទៅនៃបច្ច័យទាំងពួង ជាទីបំផុត លោកហៅថា ទីបំផុតនៃទុក្ខ ។

ប្រើក្នុងអត្ថថា **ចំណែកដទៃ** ដូចក្នុងប្រយោគមានជាដើមថា ឯសេ-វន្តោ ទុក្ខស្ស នេះជាចំណែកដទៃពីទុក្ខ ។ មួយទៀត ចំណែកដទៃនៃទុក្ខដែលរាប់ថា ជាបច្ច័យគ្រប់យ៉ាងហៅថា ចំណែកបំផុត ។ ប្រើក្នុងអត្ថថា **ចំណែក** ដូចក្នុងប្រយោគមានជាដើមថា សក្កាយោ ខោ អាវុសោ ឯកោ អន្តោ ម្នាលអាវុសោ សក្កាយនេះឯង ឈ្មោះថា ចំណែកទី១ ។

សូម្បីក្នុងទីនេះ អន្ត សព្ទនេះ ក៏ប្រព្រឹត្តទៅក្នុងអត្ថថា **ចំណែក** ។ សូម្បី កប្ប សព្ទ ក៏ប្រព្រឹត្តទៅក្នុងអត្ថច្រើនយ៉ាង ដូចជា **អាយុកប្ប លេសកប្ប** និង**វិន័យកប្ប**ជាដើម យ៉ាងនេះថា តិដ្ឋតុ ភន្តេ ភគវា កប្បំ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគតាំងព្រះជន្មនៅអស់នៃកប្បចុះ ។ អត្ថិ កប្បោ និបជ្ជិតុំ មានលេសដើម្បីនឹងដេក ។ កប្បកតេន អកប្បកតំ សំសិព្វិតំ ហោតិ ចីវរដែលមិនបានធ្វើគ្រឿងសម្គាល់ទុក ដេរភ្ជាប់ចីវរដែលធ្វើគ្រឿងសម្គាល់ទុក ។ ក្នុងទីនេះគប្បីជ្រាបថា ប្រព្រឹត្តទៅក្នុង អត្ថថា តណ្ហា និងទិដ្ឋិ ។ ប្រការនេះ សូម្បីព្រះសារីបុត្តក៏បានពោលថា ដោយឧទានថា កប្បោ កប្ប: មាន ២ យ៉ាង គឺ តណ្ហាកប្ប: ការកំណត់គឺ តណ្ហា និងទិដ្ឋិកប្ប: ការកំណត់គឺ ទិដ្ឋិ ដូច្នោះ គប្បីជ្រាបសេចក្តីក្នុងពាក្យថា បុព្វន្តកប្បិកា នេះ យ៉ាងនេះថា សមណព្រាហ្មណ៍ពួកណា កំណត់ខន្ធចំណែកអតីត ដោយតណ្ហា និងទិដ្ឋិ តាំងនៅហើយ ហេតុនោះ សមណព្រាហ្មណ៍ទាំងនោះ ឈ្មោះថា បុព្វន្តកប្បិកា អ្នកកំណត់ខន្ធចំណែកអតីត ។

ដែលឈ្មោះថា បុព្វន្តានុទិដ្ឋិនោ ព្រោះសមណព្រាហ្មណ៍ទាំងនោះ អ្នកកំណត់ខន្ធចំណែកអតីតតាំងនៅយ៉ាងនេះ មានការឃើញទៅតាមខន្ធចំណែកអតីតនុ៎ះឯង ដែលកើតឡើងរឿយៗ ។ សមណព្រាហ្មណ៍ទាំងនោះ មានទិដ្ឋិយ៉ាងនេះ កាលមកប្រារព្ធអាស្រ័យខន្ធចំណែកអតីតនោះ ក៏ធ្វើ

ឲ្យអ្នកដទៃឲ្យឃើញតាមផង ពោលពាក្យសម្តែងទិដ្ឋិច្រើនយ៉ាង ដោយហេតុ ១៨ ប្រការ ដូច្នេះ ។

បណ្តាបទទាំងនេះ បទថា អនេកវិហិតានិ បានដល់ ច្រើនយ៉ាង ។ បទថា អធិមុត្តិបទានិ បានដល់ បទដែលជាឈ្មោះ ។

មួយ៉ាងទៀត **ទិដ្ឋិ** ហៅថា **អធិមុត្តិ** ព្រោះប្រព្រឹត្តទៅគ្របសង្កត់ ។ អត្ថដែលពិត មិនកាន់យកតាមសភាវៈដែលពិត ។ បទនៃអធិមុត្តិទាំងឡាយឈ្មោះថា អធិមុត្តិបទានិ បានដល់ ពាក្យដែលសម្តែងទិដ្ឋិ ។

បទថា អដ្ឋារសហិ វត្ថូហិ បានដល់ ដោយហេតុ ១៨ ប្រការ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យមានជាដើមថា សន្តិ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ដើម្បីត្រាស់សួរដោយន័យមានជាដើមថា តេ ច ភោន្តោ ហើយសម្តែងចែកវត្ថុទាំងនោះ ដើម្បីបំណងនឹងសម្តែងវត្ថុ ១៨ ដែលសមណព្រាហ្មណ៍ ទាំងនោះពោល ។

[២៨] ក្នុងព្រះបាលីនោះ ដែលឈ្មោះថា **វាទ** ព្រោះជាគ្រឿងពោល ។ ពាក្យថា វាទៈ នេះ ជាឈ្មោះនៃទិដ្ឋិ ។

ដែលឈ្មោះថា សស្សតវាទ ព្រោះមានវាទៈថា ទៀង ។ អធិប្បាយថា ជាពួកមានការឃើញថា ទៀង ។

សូម្បីបទដទៃៗ ក្រៅអំពីនេះ ដែលមានសភាពដូច្នេះ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។

ពាក្យថា សស្សតំ អត្តានញ្ច លោកញ្ច សេចក្តីថា ប្រកាន់ខន្ធមានរូបជាដើមយ៉ាងណាមួយ ថាជាអត្តា និងថាជាលោក ហើយបញ្ញត្តិអត្តា និងលោកនោះថា យឺនយូរ មិនស្លាប់ ទៀង រឹងមាំ ដូច ត្រាស់ទុកថា បញ្ញត្តិរូបថាជាអត្តានិងលោក បញ្ញត្តិអត្តានិងលោកថា ទៀង ។ មួយទៀត បញ្ញត្តិវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាអត្តានិងលោក បញ្ញត្តិអត្តានិងលោកថា ទៀង ។

ក្នុងពាក្យមានជាដើមថា អាតប្បមន្វាយ មានអធិប្បាយថា សេចក្តីព្យាយាម ឈ្មោះថា **អាតប្ប** ដោយការៈដែលញុំាងកិលេសឲ្យក្តៅ សេចក្តីព្យាយាមនោះឯង ឈ្មោះថា បធាន ដោយជាសេចក្តីតាំងមាំ ឈ្មោះថា អនុយោគ ជាគ្រឿងប្រកបរឿយៗ សេចក្តីថា ប្រព្រឹត្តទៅតាម គឺ អាស្រ័យ គឺ ពឹងផ្អែកសេចក្តីព្យាយាមទាំង ៣ ប្រភេទ ដូចបានពណ៌នាមកដូច្នេះ ។

ការមិននៅប្រាសចាកសតិ ហៅថា ការមិនប្រមាទ ។

បទថា សម្មាមនសិការោ មានអធិប្បាយថា មនសិការដោយឧបាយ គឺ មនសិការគ្រាដំបូង ដោយសេចក្តី បានដល់ បញ្ញា ។

ក៏ **បុព្វេនិវាសានុស្សតិញ្ញាណ** សម្រេចដល់អ្នកដែលតាំងនៅក្នុងមនសិការណា មនសិការនេះ លោកបំណងយក មនសិការ ក្នុងទីនេះ ។ ដូច្នោះ ក្នុងព្រះបាលីនោះទើបមានសេចក្តីសង្ខេបដូច្នេះថា អាស្រ័យសេចក្តី

ព្យាយាម សតិ និងបញ្ញា ។

បទថា តថារូបំ សេចក្តីថា មានជាតិយ៉ាងនោះ ។

បទថា ចេតោសមាធិ សេចក្តីថា ការតាំងមាំនៃចិត្ត ។

បទថា ផុសតិ សេចក្តីថា ប្រសព្វ គឺ បានចំពោះ ។

ប្រការថា យថា សមាហិតេ ចិត្តេ សេចក្តីថា សមាធិដែលជាហេតុតាំងចិត្តទុកប្រពៃ គឺ តាំងទុកដោយល្អ ។

សេចក្តីនៃបទថា អនេកវិហិតំ បុព្វេនិវាសំ ជាដើម ខ្ញុំម្ចាស់ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

ពាក្យថា សោ ឯវមាហ សេចក្តីថា គេជាអ្នកដល់ព្រមដោយអានុភាពនៃឈានយ៉ាងនេះ មានទិដ្ឋិ ទើបពោលយ៉ាងនេះ ។

បទថា វញ្ឈោ សេចក្តីថា មិនមានផល គឺ មិនឲ្យកំណើតដល់នរណាៗ ដូចសត្វចិញ្ចឹមជាមេអា និងត្នោតជាមេអាជាដើម ដូច្នោះ ដោយបទថា វញ្ឈោ នេះ គេទើបបដិសេធភាវៈដែលនឹងឲ្យកំណើតរូបជាដើមនៃគុណវិសេស មានឈានជាដើម ដែលប្រកាន់ថា ជាអត្តា និង ជាលោក ។

ដែលឈ្មោះថា កូដដ្ឋោ ព្រោះតាំងមាំដូចកំពូលភ្នំ ។

ប្រការថា ឯសិកដ្ឋាយី ឋិតោ សេចក្តីថា តាំងមាំដូចជាសសរខឿន ហេតុនោះទើបឈ្មោះថា ឯសិកដ្ឋាយិដ្ឋិតោ ។ អធិប្បាយថា

សសរខឿនដែលកប់ណែន រមែងតាំងមាំមិនញាប់ញ័រ យ៉ាងណា អត្តានិងលោកក៏តាំងមាំ យ៉ាងនោះ ។ ដោយបទទាំងពីរ រមែងសម្តែងថា លោកមិនវិនាស ។ តែអាចារ្យពួកខ្លះពោលជាព្រះបាលីថា ឯសិកដ្ឋាយិដ្ឋិតោ ហើយពោលថា តាំងនៅដូចស្ទោយាប្ញង ។ ក្នុងពាក្យរបស់អាចារ្យពួកខ្លះនោះ មានអធិប្បាយដូច្នេះថា ពាក្យដែលពោលថា រមែងកើតនោះ មានហើយ រមែងលៀនចេញដូចបណ្តូលស្ទោយាប្ញងតាំងនៅ ព្រោះហេតុដែលតាំងនៅ ដូចបណ្តូលស្ទោយាប្ញង ដូច្នោះ សត្វទាំងនោះទើបស្ទុះទៅ គឺ ពីភពនេះ ទៅក្នុងភពដទៃ ។

បទថា សំសរន្តិ សេចក្តីថា ត្រាច់ទៅមកៗ ។

បទថា ចវន្តិ សេចក្តីថា ដល់នូវការរាប់យ៉ាងនេះ ។

បទថា ឧបបជ្ជន្តិ ក៏ដូចគ្នា ។

តែក្នុងអដ្ឋកថា លោកពោលថា ដោយការដែលលោកបានពោលទុកក្នុងខាងដើមថា លោកនិងអត្តាទៀង ដូច្នេះ មកឥឡូវនេះត្រឡប់ជាពោលថា ឯសត្វទាំងនោះរមែងស្ទុះទៅ ដូច្នេះជាដើម សមណៈ ឬព្រាហ្មណ៍អ្នកមានទិដ្ឋិនេះ ឈ្មោះថា រមែងទម្លាយវាទៈរបស់ខ្លួនដោយខ្លួនឯង ឈ្មោះថា ការឃើញរបស់អ្នកមានទិដ្ឋិមិនជាប់គ្នា ញាប់ញ័រដូចបង្គោលដែលបោះក្នុងគំនរអង្កាម និងក្នុងសេចក្តីឃើញនេះ រមែងមានទាំងល្អទាំងមិនល្អ ដូចជុំនំ លាមក និងអាចម៍គោជាដើម ក្នុងកន្ត្រករបស់មនុស្សឆ្កួត ។

បទថា សស្សតិ ក្នុងពាក្យថា អត្ថិ ត្វេវ សស្សតិសមំ នេះ មានសេចក្តីថា រមែងសម្គាល់ផែនដីដ៏ធំថា ទៀង ព្រោះមាននៅជានិច្ច សូម្បីភ្នំសិនេរុ ព្រះចន្ទ ព្រះអាទិត្យ ក៏សម្គាល់យ៉ាងនោះ ដូច្នោះ កាលសម្គាល់អត្តាស្មើដោយវត្ថុទាំងនោះ ទើបពោលថា តែវត្ថុដែលទៀងក៏គង់មានពិត ដូច្នេះ ។

ឥឡូវនេះ សមណៈ ឬព្រាហ្មណ៍អ្នកមានទិដ្ឋិ កាលនឹងសម្តែងហេតុដើម្បីឲ្យសម្រេចបដិញ្ញាថា អត្តានិងលោកទៀងដូច្នេះជាដើម ទើបពោលពាក្យមានជាដើមថា ប្រការរឿងនោះ ព្រោះហេតុអ្វី ព្រោះថា ខ្ញុំអាស្រ័យការព្យាយាម ដូច្នេះ ។

ក្នុងព្រះបាលីនោះ ពាក្យថា ឥមិនា មហំ ឯតំ ជានាមិ សេចក្តីថា សមណៈ ឬព្រាហ្មណ៍អ្នកមានទិដ្ឋិ រមែងសម្តែងពោលថា ដោយការសម្រេចគុណវិសេសនេះ ខ្ញុំទើបដឹងដូច្នេះដោយការប្រចក្ស មិនមែនខ្ញុំពោលត្រឹមតែ ការជឿតែម្យ៉ាង ដូច្នេះ ។ ក៏ **ម** អក្សរ ក្នុងព្រះបាលីថា ឥមិនា មហំ ឯតំ ជានាមិ នេះ លោកពោលដើម្បីធ្វើបទសន្ធិ ។

ពាក្យថា ឥទំ ភិក្ខវេ បឋមំ ឋានំ សេចក្តីថា បណ្តាឋានៈទាំង ៤ ដែលត្រាស់ទុកដោយសព្ទថា ដោយហេតុ ៤ យ៉ាង នេះជាឋានៈទី ១ អធិប្បាយថា ការរឭកជាតិបានត្រឹមតែសែនជាតិ ដូច្នេះ ជាហេតុទី ១ ។ សូម្បីក្នុងវាទៈទាំង ២ ខាងដើម ក៏ន័យនេះឯង ។

[ ២៨-២៩ ] ក៏វារៈនេះ ត្រាស់ដោយរឭកបានសែនជាតិតែម្យ៉ាង ។ ២ វារៈក្រៅពីនេះ ត្រាស់ដោយរឭកបាន ១០ ដល់ ៤០ សំវដ្តកប្ប និងវិវដ្តកប្ប ។

ពិតហើយ តិរ្ថិយអ្នកមានបញ្ញាតិច រឭកបានប្រមាណសែនជាតិ អ្នកមានបញ្ញាកណ្តាល រឭកបាន ១០ សំវដ្តកប្ប និងវិវដ្តកប្ប អ្នកមានបញ្ញាមុតស្រួច រឭកបាន ៤០ សំវដ្តកប្ប និងវិវដ្តកប្ប មិនច្រើនជាងនោះ ។

[ ៣០ ] ក្នុងវារៈទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

សមណៈ ឬព្រាហ្មណ៍ពួកខ្លះ ដែលឈ្មោះថា តក្កី ព្រោះត្រិះរិះ ន័យមួយទៀត ឈ្មោះថា តក្កី ព្រោះថា មានសេចក្តីត្រិះរិះ ពាក្យថា តក្កីនេះ ជាឈ្មោះរបស់អ្នកត្រិះរិះ សញ្ជឹងគិតហើយចាប់យក ជាទិដ្ឋិ ។

ដែលឈ្មោះថា វិមំសី ពិចារណា ព្រោះប្រកបដោយបញ្ញាពិចារណា ។ ឈ្មោះថា ការថ្លឹងថ្លែង ការពេញចិត្ត ការត្រូវចិត្តដោយបញ្ញាពិចារណា ។ សេចក្តីថា បុរសប្រើឈើច្រត់ស្ទង់ជម្រៅទឹកមើលហើយ ទើបចុះ យ៉ាងណា អ្នកដែលថ្លឹងថ្លែង ចិត្តពេញចិត្ត ត្រូវចិត្តហើយ ទើបសម្រេចក្នុងការឃើញនោះ គប្បីជ្រាបថា ឈ្មោះថា វិមំសី ដូចគ្នា ។

បទថា តក្កបរិយាហតំ សេចក្តីថា កំណត់យកដោយសេចក្តីត្រិះរិះ អធិប្បាយថា ត្រិះរិះទៅតាមផ្លូវនោះៗ ។

បទថា វិមំសានុចរិតំ សេចក្តីថា ដំណើរតាមបញ្ញាពិចារណា មានប្រការដែលពោលហើយនោះ ។

បទថា សយំ ចាដិភាណំ សេចក្តីថា កើតពីបដិភាណរបស់ខ្លួនប៉ុណ្ណោះ ។

បទថា ឯវមាហ សេចក្តីថា ប្រកាន់ដោយសស្សតទិដ្ឋិ ទើបពោលយ៉ាងនេះ ។

ក្នុងព្រះបាលីនោះ អ្នកត្រិះរិះ មាន ៤ ពួក គឺ

១. អនុស្សុតិកោ ត្រិះរិះតាមដែលបានស្តាប់រឿងរ៉ាវមក

២. ជាតិស្សរោ ត្រិះរិះដោយរឭកជាតិបាន

៣. លាភី ត្រិះរិះតាមតែដែលនឹកបាន

៤. សុទ្ធតក្កិកោ ត្រិះរិះយកសុទ្ធៗ

ក្នុង ៤ ពួកនោះ **អ្នកណាស្តាប់រឿងរ៉ាវមកថា** មានព្រះរាជាព្រះនាមថា វេស្សន្តរ ដូច្នេះជាដើម ហើយក៏ត្រិះរិះថា ដោយហេតុនោះឯង បើព្រះមានព្រះភាគ គឺ ព្រះវេស្សន្តរ អត្តាក៏ទៀង ដូច្នេះ ហើយប្រកាន់ដោយទិដ្ឋិ អ្នកនេះឈ្មោះថា ត្រិះរិះតាមដែលបានស្តាប់រឿងរ៉ាវមក ។

**អ្នកដែលរឭកជាតិបាន** ២-៣ ជាតិ ហើយត្រិះរិះថា កាលមុនយើងនេះឯង បានកើតមកហើយក្នុងទីឈ្មោះឯណោះ ដូច្នោះ អត្តាទើបទៀងដូច្នេះ ឈ្មោះថា នឹកដោយរឭកជាតិបាន ។

មួយទៀត អ្នកណាត្រិះរិះថា អត្តារបស់យើងក្នុងកាលឥឡូវនេះ មានសេចក្តីសុខយ៉ាងណា សូម្បីក្នុងអតីត ក៏មានសេចក្តីសុខមកហើយ សូម្បីក្នុងអនាគតក៏នឹងមានសេចក្តីសុខដូចគ្នា ដូច្នោះ ការប្រកាន់ ជាទិដ្ឋិ ដែល បានដល់ ខ្លួន អ្នកនេះឈ្មោះថា ត្រិះរិះតាមដែលនឹកបាន ។

មួយទៀត **អ្នកដែលប្រកាន់ ដោយត្រឹមតែត្រិះរិះខ្លួនឯងប៉ុណ្ណោះ** ថា បើដូច្នេះ ក៏នឹងជាយ៉ាងនេះ ដូច្នេះ ឈ្មោះថា ត្រិះរិះសុទ្ធៗ ។

ពាក្យថា ឯតេសំ វា អញ្ញតរេន សេចក្តីថា ដោយហេតុ ៤ យ៉ាង ទាំងនេះណាមួយ គឺ តែមួយយ៉ាងខ្លះ ពីរយ៉ាងខ្លះ បីយ៉ាងខ្លះ ។

ពាក្យថា នត្ថិ ឥតោ ពហិទ្ធា សេចក្តីថា ព្រះមានព្រះភាគទ្រង់បន្លឺសីហនាទ ដែលនរណាៗ នឹងជំទាស់មិនបានថា ក៏ហេតុដទៃសូម្បីត្រឹមតែម្យ៉ាង ក្រៅពីហេតុទាំងនេះ មិនមាន ដើម្បីនឹងបញ្ញត្តិថា ទៀង ។

ពាក្យថា តយិទំ ភិក្ខវេ តថាគតោ បជានាតិ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ រឿងនេះ គឺ ទិដ្ឋិទាំង ៤ ប្រការ តថាគតរមែងដឹងដោយប្រការផ្សេងៗ ។

លំដាប់នោះ កាលនឹងទ្រង់សម្តែងអាការ គឺ ទ្រង់ដឹងច្បាស់នោះ ទើបត្រាស់ព្រះបាលីមានជាដើមថា ឋានៈជាទីតាំងនៃទិដ្ឋិទាំងនេះ ដូច្នេះ ។

ក្នុងព្រះបាលីនោះ ទិដ្ឋិទាំងឯង ឈ្មោះថា ឋានៈជាទីតាំងនៃទិដ្ឋិ ។ ម្យ៉ាងទៀត សូម្បីហេតុនៃទិដ្ឋិទាំងឡាយ ក៏ឈ្មោះថា ឋានៈជាទីតាំងនៃ

ទិដ្ឋិដូចគ្នា ដូចព្រះសារីបុត្រសម្ដែងទុកថា ឋានៈជាទីតាំងនៃទិដ្ឋិ ៨ យ៉ាង អ្វីខ្លះ ? គឺ ខន្ធខ្លះ អវិជ្ជាខ្លះ ផស្សៈខ្លះ សញ្ញាខ្លះ វិតក្កខ្លះ អយោនិសោមនសិការខ្លះ បាបមិត្តខ្លះ ការស្ដាប់មកពីអ្នកដទៃខ្លះ តែមួយយ៉ាងៗ ជាឋានៈជាទីតាំងនៃទិដ្ឋិ ព្រោះដូច្នោះ ខន្ធជាហេតុជាបច្ច័យ ដោយអត្ថថា ជាសមុដ្ឋានដើម្បីការកើតឡើងនៃទិដ្ឋិទាំងឡាយ ខន្ធខ្លះ ជាឋានៈជាទីតាំងនៃទិដ្ឋិយ៉ាងនេះ ។ អវិជ្ជាជាហេតុ ។ល។ បាបមិត្តជាហេតុ ។ល។ សម្លេងពួតៗ គ្នាពីអ្នកដទៃជាបច្ច័យ ដោយអត្ថថា ជាសមុដ្ឋានដើម្បីការកើតឡើងនៃទិដ្ឋិទាំងឡាយ សម្លេងពួតៗ គ្នាពីអ្នកដទៃ ជាឋានៈជាទីតាំងនៃទិដ្ឋិយ៉ាងនេះ ។

ពាក្យថា ឯវំ គហិតា សេចក្ដីថា ឋានៈជាទីតាំងនៃទិដ្ឋិខាងដើមពោលគឺ ទិដ្ឋិដែលបុគ្គលប្រកាន់ ចាប់ទុក គឺ ប្រព្រឹត្តទៅហើយយ៉ាងនេះថា អត្តានិងលោកទៀង ។

ពាក្យថា ឯវំ បរាមដ្ឋា សេចក្ដីថា ប្រកាន់ទុករឿយៗ ព្រោះភាពជាអ្នកមានចិត្តមិនសង្ស័យ ឈ្មោះថា ប្រកាន់មាំហើយ គឺ ឲ្យសម្រេចថា នេះប៉ុណ្ណោះពិត យ៉ាងដទៃទទេ ។ ចំណែកឋានៈជាទីតាំងនៃទិដ្ឋិ ពោលគឺហេតុ កាលប្រកាន់ដោយប្រការណា រមែងញ៉ាំងទិដ្ឋិទាំងឡាយឲ្យតាំងឡើងដែលបុគ្គលប្រកាន់ហើយ ដោយប្រការនោះ ដោយភាពជាអារម្មណ៍ ដោយការប្រព្រឹត្តទៅ និងដោយការសេព ប្រកាន់ទុក ដោយការប្រកាន់រឿយៗ

ព្រោះឃើញថា មិនមានទោស ។

ពាក្យថា ឯវំ គតិកា សេចក្តីថា មាននិរយគតិ តិរច្ឆានគតិ និង បេត្តវិស័យគតិណាមួយ យ៉ាងនេះ ។

ពាក្យថា ឯវំ អភិសម្បរាយា នេះ ជាវេវចនៈរបស់បទដំបូងនុ៎ះឯង មានពាក្យអធិប្បាយថា មានលោកនេះ និងលោកដទៃ យ៉ាងនេះ ។

ពាក្យថា តញ្ច តថាគតោ បជានាតិ សេចក្តីថា តថាគតនឹង ដឹងច្បាស់ចំពោះទិដ្ឋិ ព្រមទាំងហេតុ ព្រមទាំងគតិតែម្យ៉ាងក៏ទេ ដែលពិត តថាគតរមែងដឹងច្បាស់ទាំងអស់ និងដឹងច្បាស់នូវសីល សមាធិ និងព្រះ សព្វញ្ញុតញ្ញាណ ដែលជាគុណធម៌ក្រៃលែងជាងនោះ ។

ពាក្យថា តញ្ច បជានំ ន បរាមសតិ សេចក្តីថា ក៏សូម្បីនឹងដឹង ច្បាស់គុណវិសេសដ៏កំពូលយ៉ាងនេះ តែក៏មិនប្រកាន់មាំ ដោយការប្រកាន់ មាំគឺ តណ្ហា ទិដ្ឋិ មានះ ថាយើងដឹងច្បាស់ ។

ពាក្យថា អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្វុតិ វិទិតា សេចក្តីថា កាលមិនប្រកាន់មាំយ៉ាងនោះ តថាគតក៏ដឹងការរលត់នៃកិលេស គឺ ការ ប្រកាន់មាំទាំងនោះឯងតែម្តង ប្រកាន់ដោយខ្លួននុ៎ះឯង ព្រោះការមិន ប្រកាន់មាំជាបច្ច័យ ។ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ និព្វានរបស់ តថាគតប្រាកដហើយ ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងវត្តបដិបត្តិ ដែលព្រះតថាគតទ្រង់

បដិបត្តិហើយ ជាហេតុឲ្យទ្រង់សម្រេចការរលត់នោះ ពួកតិរ្ថិយគ្រែកអរហើយ ក្នុងវេទនាពួកណា រមែងចូលទៅកាន់ការប្រកាន់ដោយទិដ្ឋិថា យើងនឹងជាអ្នកមានសេចក្ដីសុខក្នុងទីនេះ យើងនឹងជាអ្នកមានសេចក្ដីសុខក្នុងធម៌នេះ ដូច្នេះ កាលនឹងត្រាស់ប្រាប់កម្មដ្ឋានដោយវេទនាទាំងនោះឯង ទើបត្រាស់ព្រះបាលីមានជាដើមថា វេទនានំ សមុទយញ្ច ដូច្នេះ ។

ក្នុងព្រះបាលីនោះ ពាក្យថា យថាភូតំ វិទិត្វា សេចក្ដីថា ព្រោះអវិជ្ជាកើត វេទនាទើបកើត ដូច្នោះ បុគ្គលរមែងឃើញការកើតនៃវេទនា-ខន្ធ ដោយអត្ថ គឺ ការកើតឡើងនៃបច្ច័យ , វេទនាកើត ព្រោះតណ្ហាកើត , ព្រោះកម្មកើត , ព្រោះផស្សៈកើត ។ សូម្បីកាលឃើញលក្ខណៈនៃការកើត ឈ្មោះថា រមែងឃើញការកើតនៃវេទនាខន្ធ ដឹងតាមសេចក្ដីពិតនូវការកើតនៃវេទនា ដោយលក្ខណៈទាំង ៥ នេះ ព្រោះអវិជ្ជារលត់ វេទនាទើបរលត់ , ព្រោះតណ្ហារលត់ , ព្រោះកម្មរលត់ , ព្រោះផស្សៈរលត់ វេទនាទើបរលត់ ដូច្នេះ ។ បុគ្គលរមែងឃើញការអស់ទៅនៃវេទនាខន្ធ ដោយអត្ថ គឺ ការរលត់នៃបច្ច័យ សូម្បីឃើញលក្ខណៈប្រែប្រួល ឈ្មោះថា រមែងឃើញការសាបសូន្យនៃវេទនាខន្ធ ដឹងតាមពិតនូវការដល់ភាពតាំងនៅមិនបាននៃវេទនាទាំងឡាយ ដោយលក្ខណៈទាំង ៥ អាស្រ័យវេទនាណាកើត សុខសោមនស្សនេះ ជាអស្សាទៈនៃវេទនា ដឹងតាមពិតនូវអស្សាទៈនៃវេទនា ដូច្នេះ ។ វេទនាមិនទៀង ជាទុក្ខ មានការប្រែប្រួល

ជាធម្មតា នេះជាអាទីនវៈនៃវេទនា ដឹងតាមពិតនូវអាទីនវៈនៃវេទនា ដូចពោលនេះ ។ ការកម្ចាត់បង់នូវឆន្ទរាគៈ ការលះបង់ឆន្ទរាគៈក្នុងវេទនាណា នេះជាហេតុរលាស់ចេញចាកវេទនា ដឹងតាមសេចក្តីពិតនូវហេតុ រលាស់ចេញចាកវេទនា ដូចពោលមកនេះ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះមានឆន្ទរាគៈទៅប្រាសហើយ តថាគតទើបមិនប្រកាន់មាំ ទើបរួចផុត កាលនៅមានឧបាទានណា បុគ្គលក៏គប្បីប្រកាន់ធម៌អ្វីៗ និងខន្ធ ក៏នឹងគប្បីមាន ព្រោះការប្រកាន់ទុក ម្នាលភិក្ខុទាំងឡាយ តថាគតមិនប្រកាន់ធម៌អ្វីៗ ព្រោះមិនមានឧបាទាននោះ ទើបរួចផុតហើយដូច្នេះ ។

ពាក្យថា ឥមេ ខោ តេ ភិក្ខវេ សេចក្តីថា ធម៌ គឺ ព្រះសព្វញ្ញុត-ញ្ញាណណា ដែលតថាគតបានសម្តែងទុកហើយដល់អ្នកទាំងឡាយ យ៉ាងនេះថា តថាគតបានសួរហើយថា ក៏ធម៌ទាំងនេះ ជ្រាលជ្រៅដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនេះឯង តថាគត រមែងដឹងច្បាស់ដល់សេចក្តីនោះ និងដឹងច្បាស់ដ៏ក្រៃលែងជាងនោះផង ដូច្នេះ ធម៌ទាំងនោះ គប្បីជ្រាបថា ជ្រាលជ្រៅ និងឃើញបានលំបាក ។ល។ ដឹងបានចំពោះតែបណ្ឌិត ដែលជាហេតុឲ្យបុថុជ្ជន និងព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម នរណាម្នាក់មិនអាចនឹងពោលសរសើរតថាគតតាមសេចក្តីពិតបានដែលពិត តថាគតប៉ុណ្ណោះ កាលពោលសរសើរតាមសេចក្តីពិត ក៏នឹង

គប្បីពោលបានដោយប្រពៃដូច្នេះឯង ។

ព្រះមានព្រះភាគ សូម្បីកាលត្រាស់អធិប្បាយយ៉ាងនេះ ក៏ត្រាស់សួរចំពោះសព្វញ្ញុតញ្ញាណ សូម្បីកាលនឹងប្រគល់ឲ្យ ក៏ប្រគល់ឲ្យចំពោះព្រះ-សព្វញ្ញុតញ្ញាណនោះ តែទ្រង់បានចែកទិដ្ឋិទុកក្នុងចន្លោះ ដូច្នេះឯង ។

វណ្ណនាភាណវារៈទី ១ ចប់

## ពណ៌នា ឯកច្ចសស្សតវាទ

[៣១] ក្នុងព្រះបាលីនោះ បទថា ឯកច្ចសស្សតិកា សេចក្ដីថា មានវាទៈថា ទៀងខ្លះ ។ ពួកដែលមានវាទៈថា ទៀងខ្លះ មាន ២ ពួក គឺ ពួកដែលមានវាទៈថា សត្វទៀងខ្លះ ១ ពួកដែលមានវាទៈថា សង្ខារទៀងខ្លះ ១ ក្នុងទីនេះលោកកាន់យកទាំង ២ ពួក តែម្ដង ។

បទថា យំ ត្រឹមតែនិបាត ។

បទថា កទាចិ សេចក្ដីថា ក្នុងកាលខ្លះ ។

បទថា ករហចិ ជាវេវចនៈរបស់បទថា កទាចិ នោះឯង ។

បទថា ទីឃស្ស អទ្ធុនោ បានដល់ កាលយូរ ។

បទថា អច្ចយេន បានដល់ ដោយកន្លងទៅ ។

បទថា សំវដ្ដតិ បានដល់ វិមែងវិនាស ។

បទថា យេភុយ្យេន ត្រាស់សំដៅយកពួកសត្វដ៏សេសពីពួកសត្វដែលកើតក្នុងព្រហ្មលោកជាន់ខ្ពស់ ឬក្នុងអរូបព្រហ្ម ។

ដែលឈ្មោះថា **សម្រេចតាមផ្លូវចិត្ត** ព្រោះកើតដោយឈានចិត្ត ។

ដែលឈ្មោះថា **មានបីតិជាអាហារ** ព្រោះសត្វទាំងនោះ មានបីតិជាកិច្ចា គឺ ជាអាហារ ។

ដែលឈ្មោះថា **មានរស្មីក្នុងខ្លួន** ព្រោះសត្វទាំងនោះ មានរស្មីជា

របស់ខ្លួនឯង ។

ដែលឈ្មោះថា **អ្នកត្រាច់ទៅតាមអាកាសបាន** ព្រោះធ្វើដំណើរទៅតាមអាកាស ។

ដែលឈ្មោះថា សុភដ្ឋាយិនោ ព្រោះនៅក្នុងស្ថានទីដែលស្អាតល្អ មានឧទ្យាន វិមាន និងដើមកប្បព្រឹក្សជាដើម ។ម្យ៉ាងទៀត ដែលឈ្មោះថា សុភដ្ឋាយិនោ ព្រោះជាអ្នកស្អាត គឺ មានសំពត់ និងអាភរណៈដែលគួរពេញចិត្ត ។

បទថា ចិរំ ទីឃមទ្ធានំ សេចក្តីថា កំណត់យ៉ាងយូរបំផុតរហូតដល់ ៨ កប្ប ។

បទថា វិវដ្ដតិ បានដល់ តាំងនៅដោយល្អ ។

បទថា សុញ្ញំ ព្រហ្មវិមានំ សេចក្តីថា ឈ្មោះថា សូន្យ ព្រោះមិនមានសត្វកើតតាមប្រក្រតី ភូមិដែលជាទីនៅរបស់ពួកព្រហ្ម រមែងកើត ។ អ្នកសាងក្តី អ្នកប្រើឲ្យសាងក្តី នូវវិមានព្រហ្មនោះ រមែងមិនមាន ។ តែរតនភូមិដែលមានឧតុជាសមុដ្ឋាន រមែងកើតព្រោះកម្មជាបច្ច័យ តាមន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គ ។ ក្នុងរតនភូមិនេះ រមែងកើតឧទ្យាន និងដើមកប្បព្រឹក្សជាដើម ក្នុងទីដែលសត្វកើតតាមប្រក្រតីនុ៎ះឯង គ្រានោះសត្វទាំងឡាយរមែងជាប់ចិត្ត ក្នុងស្ថានទីនៅតាមប្រក្រតី សត្វទាំងនោះចម្រើនបឋមឈានហើយ ចុះចាកស្ថានទីនៅនោះ ព្រោះដូច្នោះ ព្រះមាន-

ព្រះភាគទើបត្រាស់ថា គ្រានោះ មានសត្វណាមួយ ដូច្នេះជាដើម ។

បទថា អាយុក្ខយា វា បុញ្ញក្ខយា វា សេចក្តីថា សត្វពួកណាធ្វើបុញ្ញកម្មទុកច្រើន ហើយទៅកើតក្នុងទេវលោក ដែលមានអាយុតិចក្នុងណាមួយ សត្វទាំងនោះមិនអាចតាំងនៅរហូតដល់អស់អាយុ ដោយកម្លាំងបុណ្យរបស់ខ្លួន នឹងត្រូវចុតិដោយប្រមាណអាយុរបស់ទេវលោកនោះឯងដូច្នោះ ទើបហៅថា ចុតិ ព្រោះអស់អាយុខ្លះ ។ ចំណែកសត្វពួកណាធ្វើបុញ្ញកម្មទុកតិច ហើយទៅកើតក្នុងទេវលោកដែលមានអាយុវែង សត្វទាំងនោះមិនអាចតាំងនៅបានរហូតដល់អស់អាយុ ក៏រមែងចុតិក្នុងចន្លោះនោះ ព្រោះដូច្នោះ ហៅថា ចុតិ ព្រោះអស់បុណ្យខ្លះ ។

បទថា ទីឃមទ្ធានំ តិដ្ឋតិ សេចក្តីថា រហូតដល់អស់កប្ប ឬកន្លះកប្ប ។

បទថា អនភិរតិ សេចក្តីថា ប្រាថ្នាឲ្យសត្វសូម្បីដទៃមក ។ ក៏សេចក្តីធុញទ្រាន់ដែលប្រកបដោយបដិឃៈ មិនមានក្នុងព្រហ្មលោក ។

បទថា បរិតស្សនា សេចក្តីថា សេចក្តីញាប់ញ័រ លំបាកចិត្ត ការរសាប់រសល់ ។

ក៏ការតក់ស្លុតនេះ មាន ៤ យ៉ាងគឺ

១. តាសតស្សនា ការតក់ស្លុត ព្រោះសេចក្តីក្តៅក្រហាយ

២. តណ្ហាតស្សនា ការតក់ស្លុត ព្រោះតណ្ហា

៣. ទិដ្ឋិតស្សនា ការតក់ស្លុត ព្រោះទិដ្ឋិ

៤. ញាណតស្សនា ការតក់ស្លុត ព្រោះញាណ

ក្នុងការតក់ស្លុត ៤ យ៉ាងនោះ ព្រោះអាស្រ័យជាតិ ជរា ព្យាធិ មរណៈ ភ័យ គួរឲ្យភ័យ ភ័យរន្ធត់ ព្រឺរោម តក់ស្លុត ដូច្នេះនេះ ឈ្មោះថា ការតក់ស្លុត ព្រោះសេចក្តីក្តៅក្រហាយ ។

សេចក្តីតក់ស្លុតថា ដូចម្តេចហ្ន៎ សូម្បីពួកសត្វដទៃក៏គប្បីមកយ៉ាងនេះ ដូច្នេះ នេះឈ្មោះថា សេចក្តីតក់ស្លុត ព្រោះតណ្ហា ។

សេចក្តីតក់ស្លុត សេចក្តីក្តៅក្រហាយនុ៎ះឯង ដូច្នេះ នេះឈ្មោះថា សេចក្តីតក់ស្លុត ព្រោះទិដ្ឋិ ។

សេចក្តីតក់ស្លុតថា ពួកទេវតាទាំងនោះ បានស្តាប់នូវធម៌ទេសនារបស់ព្រះតថាគតហើយ ដោយច្រើនរមែងតក់ស្លុត សង្វេគ ញាប់ញ័រគ្រប់គ្នា ដូច្នេះ នេះឈ្មោះថា សេចក្តីតក់ស្លុត ព្រោះញាណ ។

ក៏ក្នុងទីនេះ រមែងគួរទាំងសេចក្តីតក់ស្លុត ព្រោះតណ្ហាទាំងសេចក្តីតក់ស្លុត ព្រោះទិដ្ឋិ ។

ក៏ពាក្យថា **វិមានព្រហ្ម** ក្នុងព្រះបាលីនេះ មិនបានត្រាស់ថា សូន្យ ព្រោះមានសត្វអ្នកកើតមុនហើយ ។

បទថា ឧបបជ្ជន្តិ សេចក្តីថា ចូលទៅដោយការឧប្បត្តិ ។

បទថា សហាព្យតំ សេចក្តីថា ភាវៈរួមគ្នា ។

បទថា អភិភូ សេចក្តីថា ជាអ្នកគ្របសង្កត់ថា យើងជាអ្នកចម្បងបំផុត ។

បទថា អនភិភូតោ អញ្ញេហិ សេចក្តីថា ពួកអ្នកដទៃគ្របសង្កត់មិនបាន ។

បទថា អញ្ញទត្ថុ ជានិបាត ក្នុងអត្ថថា ពិតហើយ ។

ដែលឈ្មោះថា **ទសោ** ដោយការឃើញ ។ អធិប្បាយថា យើងឃើញគ្រប់យ៉ាង ។

បទថា វសវត្តី សេចក្តីថា យើងធ្វើជនទាំងពួងឲ្យនៅក្នុងអំណាចខ្លួន ។

បទថា ឥស្សរោ កត្តា និម្មិតា សេចក្តីថា យើងជាធំក្នុងលោក យើងជាអ្នកសាងលោក និងនិម្មិតផែនដី ព្រៃហិមពាន្ត ភ្នំសិនេរុ ចក្រវាឡ មហាសមុទ្រ ព្រះចន្ទ និងព្រះអាទិត្យ ។

បទថា សេដ្ឋោ សជ្ជិតា សេចក្តីថា រមែងសម្គាល់ថា យើងជាអ្នកប្រសើរបំផុត និងជាអ្នកចាត់ចែងលោក គឺ យើងជាអ្នកចែកសត្វទាំងឡាយយ៉ាងនេះថា អ្នកចូរឈ្មោះថា ក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស សូទ្រ គ្រហស្ថ បព្វជិត ដោយទីបំផុត អ្នកចូរឈ្មោះថា អូដ្ឋ ចូរឈ្មោះថា គោ ដូច្នេះ ។

បទថា វសី បិតា ភូតភព្យានំ សេចក្តីថា រមែងសម្គាល់ថា យើងឈ្មោះថា ជាអ្នកមានអំណាច ព្រោះជាអ្នកសន្សំអំណាចទុក យើង

ជាបិតារបស់ពួកសត្វដែលកើតហើយ និងរបស់ពួកសត្វដែលកំពុងកើត ។

បណ្តាពួកសត្វ ២ ប្រភេទនេះ ពួកសត្វអណ្ឌជៈ និងជលាពុជៈ នៅខាងក្នុងពង និងនៅខាងក្នុងស្បូន ឈ្មោះថា កំពុងកើត តាំងពីវេលាដែលចេញខាងក្រៅ ឈ្មោះថា កើតហើយ ។ ពួកសត្វសំសេទជៈ ក្នុងខណៈចិត្តដួងដំបូង ឈ្មោះថា កំពុងកើត តាំងពីចិត្តដួងទី ២ ទៅ ឈ្មោះថា កើតហើយ ។ ពួកសត្វឱបបាតិកៈ ក្នុងឥរិយាបថដំបូង ឈ្មោះថា កំពុងកើត តាំងពីឥរិយាបថទី ២ ទៅ គប្បីជ្រាបថា ឈ្មោះថា កើតហើយ ។ រមែងសម្គាល់ថា យើងជាបិតារបស់ពួកសត្វដែលកើតហើយ និងរបស់ពួកសត្វដែលកំពុងកើត ដោយការសម្គាល់ថា សត្វទាំងអស់នោះជាបុត្ររបស់យើង ។

ឥឡូវនេះ ព្រះមានព្រះភាគ មានព្រះបំណងនឹងឲ្យសេចក្តីសម្រេចដោយការសាង ទើបទ្រង់ធ្វើបដិញ្ញាថា សត្វទាំងនេះ តថាគតនិម្មិតហើយ ទើបត្រាស់ព្រះបាលីមានជាដើមថា សេចក្តីនោះ ព្រោះហេតុអ្វី ។

បទថា ឥត្ថត្តំ សេចក្តីថា ជាយ៉ាងនេះ អធិប្បាយថា ជាព្រហ្ម ។

បទថា ឥមិនា មយំ នេះ សេចក្តីថា សត្វទាំងនោះ សូម្បីចុតិ សូម្បីឧប្បត្តិដោយកម្មរៀងៗ ខ្លួន តែដោយគ្រាន់តែការសម្គាល់ទៅតែម្យ៉ាងប៉ុណ្ណោះ ក៏សម្គាល់ថា ពួកយើងដែលព្រះព្រហ្មដ៏ចម្រើននិម្មិតហើយ ម្នាក់ៗ ក៏នាំគ្នាបង្អោនខ្លួនចុះទៀបបាទមូលរបស់ព្រះព្រហ្មនោះតែម្តង ដូចស្មៀត

គន្ទឹះ ដែលវៀចតាមប្រហោងដែលវៀច ដូច្នោះ ។

បទថា វណ្ណវន្តតរោ ច សេចក្តីថា មានពណ៌សម្បុរល្អជាង អធិប្បាយថា មានរូបល្អគួរជ្រះថ្លា ។

បទថា មហេសក្ខតរោ សេចក្តីថា មានយសធំជាង ដោយឥស្ស-រិយយស និងបរិវារយស ។

បទថា ឋានំ ខោ បនេតំ សេចក្តីថា ប្រការនេះជាហេតុដែលនឹងមានបាន ។ ដែលត្រាស់ដូច្នេះ សំដៅដល់សត្វនោះថា សត្វនោះចុតិចាកជាន់នោះហើយ មិនទៅក្នុងលោកដទៃ រមែងមកក្នុងលោកនេះ ប៉ុណ្ណោះ ។

បទថា អគារស្មា បានដល់ ចេញចាកផ្ទះ ។

បទថា អនាគារិយំ បានដល់ បព្វជ្ជា ។ ពិតហើយ បព្វជ្ជា លោកហៅថា អនាគារិយៈ ព្រោះមិនមានការងារ មានការធ្វើស្រែ និងចិញ្ចឹមគោជាដើម ដែលជាប្រយោជន៍ដល់ផ្ទះ ។

បទថា បព្វជតិ បានដល់ ចូលដល់ ។

បទថា តតោ បរំ នានុស្សរតិ សេចក្តីថា រឭកមិនបានហួសអំពីខន្ធដែលធ្លាប់នៅអាស្រ័យនោះ កាលមិនអាចរឭកបាន ក៏តាំងនៅក្នុងខន្ធដែលអាស្រ័យនោះ ហើយប្រកាន់ដោយទិដ្ឋិ ។

ក្នុងពាក្យថា និច្ចោ សេចក្តីថា សត្វទាំងនោះ កាលមិនឃើញការកើតរបស់ព្រះព្រហ្មនោះ ទើបពោលថា ទៀង កាលមិនឃើញសេចក្តីស្លាប់

ទើបពោលថា ឋិតថេរ ។ ព្រោះមាននៅគ្រប់កាល ទើបពោលថា ទៀង ។ ព្រោះមិនមានការប្រែប្រួល ស្មើដោយជរា ទើបពោលថា មានការមិនប្រែប្រួលជាធម្មតា ។ ពាក្យដ៏សេសក្នុងវារៈនេះ ងាយទាំងអស់ដូចេ្នះឯង ។

[៣២] ក្នុងវារៈទី ២ មានវិនិច្ឆ័យដូចតទៅនេះ

ពួកទេវតាដែលឈ្មោះថា **ខិឌ្ឌាបទោសិកា** ព្រោះសាបសូន្យ គឺវិនាសដោយការលេង ។ អ្នកសរសេរបាលីជា បទូសិកា ក៏មាន ។ បាលីថា **បទូសិកា** នោះ មិនមានក្នុងអដ្ឋកថា ។

បទថា អតិវេលំ សេចក្ដីថា ហួសកាល គឺ កន្លងកាលយូរ ។

បទថា ហស្សខិឌ្ឌារតិធម្មសមាបន្នា សេចក្ដីថា ជំពាក់ចិត្ត គឺ ពេញចិត្តនៅតែក្នុងការរីករាយ គឺ ការសើចក្អាកក្អាយ និងសេចក្ដីរីករាយ គឺការលេងសើច អធិប្បាយថា ជាអ្នកចិត្តនៅនឹងសេចក្ដីសុខ ដែលកើតពីការលេង ការសើចក្អាកក្អាយ និងសេចក្ដីសុខ ដែលជាការលេងតាមកាយតាមវាចា ជាអ្នកមានសេចក្ដីព្រមព្រៀងដោយសេចក្ដីរីករាយ មានប្រការដូចពោលហើយ ។

បទថា សតិ បមុស្សតិ សេចក្ដីថា ភ្លេចនឹកដល់របស់ទំពារ និងរបស់បរិភោគ ។

បានឮថា ទេវតាពួកខិឌ្ឌាបទោសិកៈទាំងនោះ លេងនក្ខត្តឫក្ស ដោយ សិរីសម្បត្តិដ៏ធំរបស់ខ្លួន ដែលបានមកដោយបុណ្យវិសេស ព្រោះការ

ដែលខ្លួនមានសម្បត្តិធំនោះ ទើបមិនដឹងថា យើងបរិភោគអាហារហើយ ឬនៅ ការហួសវេលាអាហារមួយកាលទៅ ទាំងទំពារស៊ី ទាំងផឹក នៅមិនដាច់រយៈ ក៏ចុតិក្លាម តាំងនៅមិនបាន ព្រោះហេតុអ្វី ? ព្រោះតេជោធាតុ ដែលកើតពីកម្មមានកម្លាំងខ្លាំង ។ ក៏មនុស្សទាំងឡាយ មានតេជោធាតុ ដែលកើតពីកម្មខ្សោយ មានករជ្ជកាយរឹងមាំ និងកាលតេជោធាតុរបស់មនុស្សទាំងនោះខ្សោយ ករជ្ជកាយរឹងមាំ សូម្បីហួសវេលាអាហារដល់ ៧ ថ្ងៃ ក៏អាចប្រើទឹកក្តៅ និងបបរថ្លាជាដើម រក្សាកាយបាន ។ ចំណែកពួកទេវតា មានតេជោធាតុខ្លាំង ករជ្ជកាយខ្សោយ ទេវតាទាំងនោះកាលហួសវេលាអាហារតែមួយពេលប៉ុណ្ណោះ ក៏មិនអាចនឹងតាំងនៅបាន ដូចផ្កាបទុម ឬផ្កាឧប្បល ដែលបុគ្គលដាក់ លើផ្ទាំងថ្មដែលក្តៅក្នុងវេលាថ្ងៃត្រង់នាវដូវក្តៅរហូតដល់ល្ងាច សូម្បីនឹងដងទឹកស្រោចទាំងរយឆ្នាំង ក៏មិនជាប្រក្រតីបាន រមែងវិនាសទៅតែម្យ៉ាង យ៉ាងណា ទេវតាពួកខិឌ្ឌាបទោសិកៈ សូម្បីនឹងទំពារ សូម្បីនឹងផឹក មិនដាច់រយៈក្នុងខាងក្រោយក៏ចុតិក្លាម តាំងនៅមិនបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ព្រោះភ្លេចស្មារតី ទេវតាទាំងនោះ ក៏ច្យុតចាកពួកទេវតានោះ ដូច្នេះ ។

សួរថា ក៏ទេវតាទាំងនោះ ជាពួកណា ?

ឆ្លើយថា ក្នុងអដ្ឋកថា មិនមានការពិចារណាទុកថា ជាពួកឈ្មោះនេះ ៗ តែព្រោះបានពោលទុកដោយមិនផ្សេងគ្នាថា ពួកទេវតា មានតេ-

ដោធាតុដែលកើតពីកម្មខ្លាំង មានករជ្ជកាយខ្សោយ ដូច្នេះ ទេវតាពួកណាមួយដែលអាស្រ័យកវឡិង្ការាហារ ចិញ្ចឹមជីវិតយ៉ាងនេះ ទេវតាទាំងនោះឯងគប្បីជ្រាបថា ចុតិ ដូច្នេះ ។ តែអាចារ្យពួកខ្លះពោលថា ទេវតាជាន់និម្មានរតី និងជាន់បរនិម្មិតវសវត្តី គឺ ទេវតាពួក ខិឌ្ឌាបទោសិកៈនោះ ដោយន័យថា ទេវតាទាំងនេះលោកហៅថា **ខិឌ្ឌាបទោសិកៈ** ដោយហេតុត្រឹមតែចេញ ព្រោះការលេងប៉ុណ្ណោះ ។ ពាក្យដ៏សេសក្នុងវារៈនេះ គប្បីជ្រាបតាមន័យដំបូង នុ៎ះឯង ។

[៣៣] ក្នុងវារៈទី ៣ មានវិនិច្ឆ័យដូចតទៅនេះ

ពួកទេវតា ដែលឈ្មោះថា មនោបទោសិក ព្រោះត្រូវចិត្តប្រទូស្ត គឺ ធ្វើឲ្យសាបសូន្យ ធ្វើឲ្យវិនាស ទេវតាទាំងនេះ ជាទេវតាជាន់ចាតុម្មហារាជ ។

បានឮថា បណ្តាទេវតាទាំងនោះ ទេវបុត្រអង្គមួយគិតថា នឹងលេងនក្ខត្តឫក្ស ទើបធ្វើដំណើរទៅដោយរថព្រមទាំងបរិក្ខារ ។ គ្រានោះទេវបុត្រអង្គដទៃ កាលចេញទៅឃើញទេវបុត្រអង្គនោះទៅខាងមុខ ក៏ក្រោធពោលថា ណែ៎ពួកយើង ទេវបុត្រអង្គនេះជាអ្នកកំណាញ់ បានជួបអ្នកនេះហើយ ក៏ដូចជាមិនធ្លាប់ជួប បើទៅជាមួយនឹងមានការទាស់គ្នា បែកគ្នាដោយសេចក្តីទាស់ចិត្ត ។ ចំណែកទេវបុត្រដែលទៅខាងមុខ ក្រឡេកមកឃើញទេវបុត្រអង្គនោះក៏ក្រោធ ដែលឈ្មោះថា អ្នកក្រោធដល់គ្នានិងគ្នា

រមែងដឹងបានឆាយ ទើបដឹងថា ទេវបុត្រអង្គនោះក្រោធ ក៏ក្រោធតបថា លោកក្រោធនឹងយើង តើធ្វើអ្វីយើងបាន សម្បត្តិនេះយើងបានមកដោយអំណាចបុណ្យ មានទាន សីលជាដើម មិនមែនបានមកដោយអំណាចរបស់លោក ។ បើកាលទេវបុត្រមួយអង្គក្រោធ មួយអង្គទៀតមិនក្រោធ ក៏នៅរក្សាបាន ។ តែកាលក្រោធទាំង ២ ចំណែក សេចក្តីក្រោធរបស់មួយចំណែក រមែងជាបច្ច័យដល់មួយចំណែកទៀត សូម្បីសេចក្តីក្រោធរបស់ចំណែកនោះ ក៏ជាបច្ច័យដល់មួយចំណែកទៀត ដូច្នោះ ទាំង ២ ចំណែកទើបចុតិ ទាំងនាងទេពកញ្ញាក៏កំពុងនាំគ្នាទួញយំនុ៎ះឯង ។ នេះជារឿងធម្មតាក្នុងការក្រោធរបស់ពួកទេវតា ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលនុ៎ះឯង ។

[៣៤] ក្នុងវារៈរបស់អ្នកត្រិះរិះ មានវិនិច្ឆ័យដូចតទៅនេះ ៖

សមណៈ ឬព្រាហ្មណ៍អ្នកត្រិះរិះនេះ រមែងឃើញការបែកធ្លាយរបស់ចក្ខុជាដើម តែព្រោះហេតុដែលចិត្តដួងដំបូងៗ ល្មមឲ្យបច្ច័យដល់ដួងក្រោយៗ ទើបរលត់ទៅដូច្នោះ ទើបមិនឃើញការបែកធ្លាយរបស់ចិត្ត សូម្បីនឹងមានកម្លាំងជាងការបែកធ្លាយរបស់ចក្ខុ ជាដើម ។ សមណៈ ឬព្រាហ្មណ៍អ្នកត្រិះរិះនោះ កាលមិនឃើញការបែកធ្លាយរបស់ចិត្តនោះ ទើបប្រកាន់ថា កាលអត្តភាពនេះបែកធ្លាយហើយ ចិត្តរមែងទៅកាន់អត្តភាពដទៃ ដូចជាសត្វលះបង់ដើមឈើមួយ ហើយទៅចាប់យកដើមដទៃ ដូច្នោះ

ទើបពោលយ៉ាងនេះ ។ ពាក្យដ៏សេសក្នុងវារៈនេះ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

# អធិប្បាយ អន្តានន្តវាទ

[៣៥-៣៧] បទថា អន្តានន្តិកា សេចក្តីថា មានវាទៈថា លោកមានទីបំផុត និងមិនមានទីបំផុត អធិប្បាយថា មានវាទៈប្រព្រឹត្តទៅប្រារព្ធលោកថា មានទីបំផុតក៏មាន មិនមានទីបំផុតក៏មាន ពេលខ្លះមានទីបំផុតនិងមិនមានទីបំផុត មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ។

បទថា អន្តសញ្ញី លោកស្មិំ វិហរតិ សេចក្តីថា សមណៈ ឬព្រាហ្មណ៍មិនបានពង្រីកបដិភាគនិមិត្តទៅដល់កណ្តាប់ចក្រវាឡ ប្រកាន់យកកណ្តាប់ចក្រវាឡនោះថា ជាលោក ទើបមានការសម្គាល់ក្នុងលោកថា មានទីបំផុត តែក្នុងកសិណដែលពង្រីកចេញទៅដល់កណ្តាប់ចក្រវាឡ មានការសម្គាល់ថា លោកមិនមានទីបំផុត មួយទៀត មិនបានពង្រីកទៅផ្នែកខាងលើ និងផ្នែកខាងក្រោម ពង្រីកទៅតែផ្នែកខាងទទឹង ទើបមានការសម្គាល់ក្នុងលោកថា ផ្នែកខាងលើ និងផ្នែកខាងក្រោម មានទីបំផុត មានការសម្គាល់ក្នុងលោកថា ផ្នែកខាងទទឹងមិនមានទីបំផុត ។

[៣៨] វាទៈរបស់សមណៈ ឬព្រាហ្មណ៍អ្នកត្រិះរិះ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

*វាទៈទាំង ៤ យ៉ាងនេះ ចាត់ចូលក្នុងបុព្វន្តកប្បិកវាទៈ ព្រោះប្រកាន់ដោយទិដ្ឋិ តាមទំនងដែលខ្លួនធ្លាប់ឃើញហើយនុ៎ះឯង ។*

## អមរាវិក្ខេបវាទ

[៣៩] ដែលឈ្មោះថា **អមរា** ព្រោះមិនស្លាប់ ។

អមរានោះ គឺ អ្វី ?

គឺ ការឃើញ និងវាទៈរបស់អ្នកឃើញ ដែលវៀរចាកការមិនមានទីបំផុត ដោយន័យមានជាដើមថា ការឃើញរបស់យើងយ៉ាងនេះ ក៏មិនមែនដូច្នេះ ។

ដែលឈ្មោះថា វិក្ខេបោ ព្រោះបោះសំដីទៅមានប្រការផ្សេងៗ ។

ដែលឈ្មោះថា អមរាវិក្ខេបោ ព្រោះទិដ្ឋិនិងវាចាបោះសំដីមិនឲ្យស្លាប់ខ្លួន ។

សមណៈ ឬព្រាហ្មណ៍ ឈ្មោះថា **អមរាវិក្ខេបិកៈ** ព្រោះមានទិដ្ឋិនិងវាចាបោះសំដីមិនឲ្យស្លាប់ខ្លួន ។

ន័យមួយទៀត ត្រីប្រភេទមួយ ឈ្មោះ **អមរា** ។ ត្រីអមរានោះកាលត្រាច់ទៅក្នុងទឹកដោយការផុសឡើងនិងមុជចុះជាដើម អ្នកណាៗ មិនអាចចាប់បាន សូម្បីវាទៈនេះក៏ដូចដូច្នោះ ត្រាច់ទៅ ខាងឯណោះ ខាងនេះ មិនចូលដល់អាការដែលនឹងចាប់ទុក ព្រោះហេតុនោះ ទើបហៅថា **អមរាវិក្ខេបៈ** ។ សមណៈ ឬព្រាហ្មណ៍ដែលឈ្មោះថា **អមរាវិក្ខេបិកៈ** ព្រោះមានទិដ្ឋិនិងបោះពាក្យសំដី ដូចត្រីអមរា ។

បទថា ឥទំ កុសលន្តិ យថាភូតំ នប្បជានាតិ សេចក្ដីថា មិនដឹងកុសលកម្មបថ ១០ តាមសេចក្ដីពិត ៗ សូម្បីក្នុងចំណែកអកុសល បំណាំងយកអកុសលកម្មបថ ១០ នុ៎ះឯង ៗ

បទថា សោ មមស្ស វិឃាតោ សេចក្ដីថា គប្បីកើតសេចក្ដីក្ដៅក្រហាយ គឺ គប្បីកើតសេចក្ដីទុក្ខដល់យើង ព្រោះកើតសេចក្ដីក្ដៅចិត្តថា យើងពោលកុហកហើយ ៗ

បទថា សោ មមស្ស អន្តរាយោ សេចក្ដីថា សេចក្ដីក្ដៅក្រហាយនោះ គប្បីអន្តរាយដល់សួគ៌ និងមគ្គរបស់យើង ៗ

បទថា មុសាវាទភយា មុសាវាទបរិជេគុច្ឆា សេចក្ដីថា ព្រោះសេចក្ដីខ្លាច និងព្រោះសេចក្ដីខ្ពើម ក្នុងការនិយាយកុហក ៗ

បទថា វាចាវិក្ខេបំ អាបជ្ជតិ សេចក្ដីថា ទើបពោលបោះពាក្យសំដីមិនឲ្យស្ទាប់ខ្លួន គឺ បោះសំដីទៅមិនមានទីបំផុត ៗ

ក្នុងពាក្យថា ឯវន្តិបិ មេ នោ ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា ការយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែននេះ ជាពាក្យឃាត់អាការស្មួរណាៗ ដែលមិនមានកំណត់ ៗ

ពាក្យថា ការយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះក៏មិនមែន លោកបដិសេធវាទៈថា ទៀង ដែលពោលទុកថា អត្តានិងលោកទៀង ៗ

ពាក្យថា ការយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃក៏មិនមែន លោកបដិសេធវាទៈថា ទៀងខ្លះ ថាមិនទៀងខ្លះ ដែលពោលទុកដោយប្រការដទៃក្រៅពីសេចក្ដីទៀង ។

ពាក្យថា ការយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ លោកបដិសេធវាទៈថា ដាច់សូន្យ ដែលពោលទុកថា ខាងមុខអំពីសេចក្ដីស្លាប់ទៅ សត្វមិនមាន ។

ពាក្យថា ការយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិនមែនដែរ លោកបដិសេធវាទៈរបស់អ្នកត្រិះរិះ ដែលពោលទុកថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ក៏បុគ្គលអ្នកមានសេចក្ដីឃើញបណ្ដោះបណ្ដែ មិនឲ្យស្លាប់ខ្លួននេះ ត្រូវសួរថា នេះជាកុសល ឬអកុសល រមែងមិនតបអ្វីៗ ឬត្រូវសួរថា នេះជាកុសលឬ ក៏ពោលថា សេចក្ដីឃើញរបស់យើងថា យ៉ាងនេះក៏មិនមែន ។ លំដាប់នោះ កាលគេពោលថា អ្វីជាកុសល ក៏ពោលថា ការឃើញរបស់យើងថា យ៉ាងនោះក៏មិនមែន , កាលគេពោលថា យ៉ាងដទៃអំពីទាំង ២ យ៉ាងឬ ក៏ពោលថា សេចក្ដីឃើញរបស់យើងថា យ៉ាងដទៃក៏មិនមែន ។ លំដាប់នោះ កាលគេពោលថា លទ្ធិរបស់លោកថា មិនមែនទាំង ៣ យ៉ាងឬ ក៏ពោលថា សេចក្ដីឃើញរបស់យើងថា មិនមែន ក៏មិនមែនដែរ ។ លំដាប់នោះ កាលគេពោលថា លទ្ធិរបស់លោកថា មិនមែនក៏មិនមែនដែរ

ឬ ក៏ពោលបណ្តោះបណ្តៃទៅយ៉ាងនេះទៀតថា សេចក្តីឃើញរបស់យើង ថា មិនមែន មិនមែនក៏មិនមែនដែរ ដូច្នេះ មិនតាំងនៅស៊ប់ក្នុងចំណែកមួយ ។

[៤០] បទថា ឆន្ទោ វា រាគោ វា សេចក្តីថា ស៊ប់កាលមិនត្រេកអរ ក៏ប្រញាប់ឆ្លើយកុសលទាំងឯងថា ជាកុសល ឆ្លើយអកុសលទាំងឯងថា ជាអកុសល ហើយសួរបណ្ឌិតពួកដទៃថា ដែលយើងឆ្លើយជាមួយអ្នកឈ្មោះឯណោះទៅយ៉ាងនេះ ពាក្យឆ្លើយនោះ ឆ្លើយល្អហើយឬ ? កាលបណ្ឌិតទាំងនោះឆ្លើយថា ឆ្លើយល្អហើយ អ្នកដ៏ចម្រើន កុសលទាំងឯង លោកឆ្លើយថា កុសល អកុសលទាំងឯង លោកក៏ឆ្លើយថា អកុសល ក៏នឹងគប្បីមានសេចក្តីពេញចិត្តខ្លះ ភាពជាប់ចិត្តខ្លះក្នុងសេចក្តីនេះ យ៉ាងនេះថា បណ្ឌិតដូចជាយើងមិនមាន ។ ក៏ក្នុងព្រះបាលីនេះ សេចក្តីពេញចិត្ត បានដល់ ការជាប់ចិត្ត ការជាប់ចិត្ត បានដល់ ការជាប់ចិត្តយ៉ាងខ្លាំង ។

បទថា ទោសោ វា បដិឃោ វា សេចក្តីថា ស៊ប់ជាកុសល ក៏ឆ្លើយថា ជាអកុសល ឬដែលជាអកុសល ក៏ឆ្លើយថា ជាកុសល ដូច្នេះ ហើយសួរបណ្ឌិតពួកដទៃ កាលបណ្ឌិតទាំងនោះឆ្លើយថា លោកឆ្លើយមិនល្អ ក៏មានការតូចចិត្តខ្លះ ទាស់ចិត្តខ្លះ ដល់យើង ក្នុងសេចក្តីនោះថា រឿងស៊ប់ត្រឹមតែប៉ុណ្ណោះ យើងក៏មិនដឹង ។ ស៊ប់ក្នុងព្រះបាលីនេះ ការតូចចិត្ត បានដល់ សេចក្តីក្រោធមានកម្លាំងខ្សោយ សេចក្តីទាស់ចិត្ត បាន

ដល់ សេចក្តីក្រោធមានកម្លាំង ។

បទថា តំ មមស្ស ឧបាទានំ សោ មមស្ស វិឃាតោ សេចក្តីថា ការពេញចិត្ត និងការជាប់ចិត្ត ទាំង ២ នោះ នឹងគប្បីជាឧបាទានរបស់យើង ការតូចចិត្ត និងការទាស់ចិត្ត ទាំង ២ នឹងគប្បីជាសេចក្តីក្តៅក្រហាយ ដល់យើង ឬទាំង ២ យ៉ាង ជាឧបាទានដោយអំណាចសេចក្តីប្រកាន់មាំ ជាសេចក្តីលំបាកចិត្តដោយអំណាចការខ្វាំងខ្វប់ ។ ពិតហើយ ការជាប់ចិត្ត រមែងចាប់យកអារម្មណ៍ ដោយមិនប្រាថ្នានឹងលែង ដូចឈ្លើងទាម ។ ការអាក់អន់ចិត្ត រមែងចាប់យកអារម្មណ៍ ដោយប្រាថ្នានឹងឲ្យវិនាស ដូច អាសិរពិស និងទាំង ២ នេះ រមែងធ្វើឲ្យក្តៅក្រហាយ ដោយអត្ថថា ដុតពេលទាំងអស់ ដូច្នោះ លោកទើបពោលថា ជាឧបាទាន និងថា ជាការលំបាកចិត្ត ។ ពាក្យដ៏សេស ដូចគ្នានឹងវារៈដំបូងនុ៎ះឯង ។

[៤១] បទថា បណ្ឌិតា សេចក្តីថា អ្នកប្រកបដោយគុណជាបណ្ឌិត ។

បទថា និបុណា សេចក្តីថា អ្នកចម្រើនដោយបញ្ញាដ៏ល្អិតសុខុមអាចចាក់ធ្លុះនូវអត្ថដ៏ពិសេសល្អិតសុខុម ។

បទថា កតបរប្បវាទា សេចក្តីថា ការតទល់វាទៈ និងធ្លាប់ស្គាល់ការតទល់ជាមួយនឹងបុគ្គលដទៃ ។

បទថា វាលវេធិរូបា សេចក្តីថា ដូចនឹងនាយខ្មាន់ធ្នូ បាញ់ត្រូវរោម

ទ្រាយ ។

បទថា តេ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ រមែងត្រាច់ទៅ ដូចជាទម្លាយទិដ្ឋិរបស់បុគ្គលពួកដទៃសូម្បីសុខុម ដោយកម្លាំងបញ្ញារបស់ខ្លួន ដូចនាយខ្មាន់ធ្នូ បាញ់ត្រូវរោមទ្រាយដូច្នោះ ។

បទថា តេ មំ តត្ថ សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ សាកសួរដេញដោល សួរចំពោះអាត្មាអញក្នុងសេចក្តីជាកុសល និងអកុសលនោះៗ ។

បទថា សមនុយុញ្ជេយ្យុំ សេចក្តីថា គប្បីសួរដល់លទ្ធិថា លោកចូរពោលលទ្ធិរបស់ខ្លួនថា អ្វីជាកុសល អ្វីជាអកុសល ។

បទថា សមនុគ្គាហេយ្យុំ សេចក្តីថា កាលឆ្លើយថា រឿងឈ្មោះនេះជាកុសល ជាអកុសល ក៏នឹងគប្បីសួរដល់ហេតុថា លោកឲ្យកាន់យកសេចក្តីនេះដោយហេតុអ្វី ។

បទថា សមនុភាសេយ្យុំ សេចក្តីថា កាលឆ្លើយដល់ហេតុថា ដោយហេតុឈ្មោះនេះ ក៏នឹងបង្ហាញទោស ដេញដោលសួរយ៉ាងនេះថា លោកមិនដឹងហេតុនេះ លោកក៏កាន់យកសេចក្តីនេះ ចូរលះសេចក្តីនេះចេញ ។

បទថា ន សម្បាយេយ្យុំ សេចក្តីថា យើងគប្បីឲ្យពាក្យឆ្លើយនឹងគេមិនបាន គឺ មិនអាចនឹងពោលតបគេបាន ។

បទថា សោ មមស្ស វិឃាតោ សេចក្តីថា ឈ្មោះថា សូម្បីនឹងនិយាយដដែលៗ ក៏តទល់ឆ្លើយនឹងគេមិនបាន នឹងជាការលំបាកចិត្ត គឺ

ជាទុក្ខ ព្រោះធ្វើឲ្យបបូរមាត់ ពិតាន អណ្តាត និងក ស្ងួតតែម្តងជល់យើង ។ ពាក្យដ៏សេសសូម្បីក្នុងវារៈទី ៣ នេះ ដូចគ្នានឹងវារៈដំបូងនុ៎ះឯង ។

[៤២] បទថា មន្ទោ សេចក្តីថា មានបញ្ញាទន់ខ្សោយ ។ ពាក្យនេះ ជាឈ្មោះរបស់អ្នកមិនមានបញ្ញានុ៎ះឯង ។

បទថា មោមូហោ សេចក្តីថា ជាអ្នកស្រវឹងច្រើន ។ សត្វលោក ប្រាថ្នាយកថា តថាគតោ ក្នុងពាក្យថា ហោតិ តថាគតោ ជាដើម ។ ពាក្យដ៏សេសក្នុងវារៈទី ៤ សូម្បីនេះ ងាយទាំងអស់ ។

**អមរាវិក្ខេបិក** ទាំង ៤ នេះ ចាត់ចូលក្នុង **បុព្វន្តកប្បិកវាទ** ព្រោះ សមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ការឃើញតាមទំនងនៃធម៌ ដែលប្រព្រឹត្ត ទៅមុននុ៎ះឯង ។

## អធិប្បាយ អធិច្ចសមុប្បន្នវាទ

[៤៣] សេចក្តីឃើញថា អត្តា និងលោក កើតឡើងដោយឯងៗ ឈ្មោះថា អធិច្ចសមុប្បន្ន ។ សមណព្រាហ្មណ៍ ដែលឈ្មោះថា អធិច្ច-សមុប្បន្និកៈ ព្រោះមានការឃើញថា អត្តា និងលោក កើតឡើងឯងៗ ។

បទថា អធិច្ចសមុប្បន្នំ សេចក្តីថា កើតឡើងដោយមិនមានហេតុ ។

ពាក្យថា អសញ្ញីសត្តា នេះ ជាប្រធាននៃទេសនា សេចក្តីថា មាន

អត្តភាពត្រឹមតែរូប ព្រោះមិនមានចិត្តកើតឡើង ។ គប្បីជ្រាប ការឧប្បត្តិរបស់ពួកអសញ្ញីសត្វទាំងនោះ យ៉ាងនេះ ។

ក៏បុគ្គលណាមួយ បួសក្នុងលទ្ធិតិរ្ថិយហើយ ធ្វើបរិកម្មក្នុងវាយោ-កសិណ ញុំាងចតុត្ថជ្ឈានឲ្យកើត ចេញចាកឈានហើយ ឃើញទោសក្នុងចិត្តថា កាលមានចិត្ត រមែងមានទុក្ខ ព្រោះត្រូវកាត់ដៃជាដើម និងមានភ័យទាំងពួងគ្រប់គ្នាដោយសារតែចិត្តនេះ ការមិនមានចិត្ត ទើបស្ងប់ពិតកាលឃើញទោសក្នុងចិត្តយ៉ាងនេះហើយ ជាអ្នកមានឈានមិនសាបសូន្យធ្វើកាលៈហើយ ទៅកើតក្នុងពួកអសញ្ញីសត្វ ចិត្តរបស់បុគ្គលនោះ រមែងត្រឡប់មកក្នុងលោកនេះ ដោយការរលត់នៃចុតិចិត្ត ។ ក្នុងពួកអសញ្ញីសត្វនោះ ប្រាកដត្រឹមតែរូបក្ខន្ធប៉ុណ្ណោះ ។ ធម្មតាថា កូនសរដែលត្រូវបាញ់ចេញទៅដោយកម្លាំងធ្នូ រមែងទៅក្នុងអាកាសស្មើនឹងកម្លាំងខ្សែធ្នូនោះឯងយ៉ាងណា អសញ្ញីសត្វទាំងនោះ ក្នុងជាន់អសញ្ញីសត្វនោះ ត្រូវទៅដោយកម្លាំងនៃឈាន កើតឡើងហើយ ក៏នឹងតាំងនៅបានរហូតដល់អស់កាលស្មើកម្លាំងឈានដែលនៅមានប៉ុណ្ណោះ ដូច្នោះឯង ។ តែកាលកម្លាំងឈានសាបសូន្យ រូបក្ខន្ធក្នុងជាន់អសញ្ញីសត្វនោះ ក៏នឹងអន្តរធាន បដិសន្ធិ-សញ្ញា រមែងកើតឡើងក្នុងលោកនេះ ក៏ព្រោះសញ្ញាដែលកើតឡើងក្នុងលោកនេះ ជាហេតុឲ្យប្រាកដ ការចុតិរបស់អសញ្ញីសត្វទាំងនោះ ក្នុងជាន់អសញ្ញីសត្វនោះ ដូច្នោះ ទើបត្រាស់តទៅថា ក៏ទេវតាទាំងនោះ រមែង

រមែងចុតិចាកជាន់នោះ ព្រោះការកើតឡើងនៃសញ្ញា ។

បទថា សន្តតាយ សេចក្តីថា ដើម្បីសេចក្តីស្ងប់ ។

ពាក្យដ៏សេសក្នុងវារៈនេះ ងាយទាំងអស់នោះឯង ។

[៤៤] សូម្បីវាទៈរបស់អ្នកត្រិះរិះ ក៏គប្បីជ្រាបតាមន័យដែលពោលហើយ ដូច្នេះឯង ។

# អធិប្បាយ អបរន្តកប្បិកវាទ

[៤៥] *ព្រះមានព្រះភាគ គ្រានឹងទ្រង់សម្តែងបុព្វន្តកប្បិកទិដ្ឋិ ១៨ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់មានព្រះបំណងនឹងសម្តែងអបរន្ត-កប្បិកទិដ្ឋិ ៤៤ ប្រការ ទើបត្រាស់ព្រះបាលីមានជាដើមថា ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ដូច្នេះ ។*

*ក្នុងព្រះបាលីនោះ សមណព្រាហ្មណ៍ដែលឈ្មោះថា អបរន្តកប្បិក ព្រោះកំណត់អបរន្តៈ ពោលគឺ ប្រកាន់ខន្ធចំណែកអនាគត ។ មួយវិញទៀតដែលឈ្មោះថា អបរន្តកប្បិកៈ ព្រោះមានការកំណត់ខន្ធចំណែកអនាគត ។ សូមជ្រាបពាក្យដ៏សេស ក៏គប្បីជ្រាបតាមន័យដែលពោលហើយក្នុងខាងដើមដោយប្រការដូច្នេះ ។*

# អធិប្បាយ សញ្ញីវាទ

[៤៦] បទថា ឧទ្ធមាឃតនិកា សេចក្តីថា សេចក្តីស្លាប់ ហៅថា អាឃាតនៈ សមណព្រាហ្មណ៍ ដែលឈ្មោះថា ឧទ្ធមាឃតនិកា ព្រោះពោល អត្តភាពខាងមុខអំពីសេចក្តីស្លាប់ ។

វាទៈដែលប្រព្រឹត្តទៅថា មានសញ្ញា ឈ្មោះថា សញ្ញីវាទៈ ។

ក្នុងពាក្យថា ខ្លួនមានរូបជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

រមែងបញ្ញត្តិខ្លួននោះថា ខ្លួនមានរូប ទៀង មានសញ្ញាក្នុងខាងមុខ អំពីសេចក្តីស្លាប់ ដូច្នេះ ព្រោះប្រកាន់រូបកសិណថា ជាខ្លួន និងប្រកាន់ សញ្ញាដែលប្រព្រឹត្តទៅក្នុងរូបកសិណនោះថា ជាសញ្ញារបស់ខ្លួននោះ ឬព្រោះ ត្រឹមតែនឹកយកប៉ុណ្ណោះ ដូចពួកក្រៅសាសនា មានអាជីវកជាដើម ។

ក្នុងព្រះបាលីនោះ បទថា អរោគោ សេចក្តីថា ទៀង ។

មួយទៀត រមែងបញ្ញត្តិខ្លួននោះថា ខ្លួនមិនមានរូប មានសញ្ញា ដូច្នេះ ព្រោះប្រកាន់និមិត្តនៃអរូបសមាបត្តិថាជាខ្លួន និងប្រកាន់សញ្ញានៃ សមាបត្តិថាជាសញ្ញារបស់ខ្លួននោះ ឬព្រោះត្រឹមតែនឹកយកប៉ុណ្ណោះ ដូច ពួកក្រៅសាសនា មាននិគ្រន្ថជាដើម ។

ចំណែកវាទៈទី ៣ ជាទិដ្ឋិដែលប្រព្រឹត្តទៅដោយអំណាចការប្រកាន់ លាយគ្នា ។

វាទៈទី ៤ ជាទិដ្ឋិដែលប្រព្រឹត្តទៅព្រោះសេចក្តីប្រកាន់ ដោយការនឹកយកប៉ុណ្ណោះ ។

ចតុក្កៈទី ២ គប្បីជ្រាបតាម ន័យដែលពោលហើយក្នុងអន្តានន្តិកវាទៈនោះឯង ។

ក្នុងចតុក្កៈទី ៣ គប្បីជ្រាបថា ៖

ខ្លួនមានសញ្ញាដូចគ្នា ដោយអំណាចនៃអ្នកបានសមាបត្តិ

ខ្លួនមានសញ្ញាផ្សេងគ្នា ដោយអំណាចនៃអ្នកមិនបានសមាបត្តិ

ខ្លួនមានសញ្ញាតិច ដោយអំណាចនៃកសិណបន្តិចបន្តួច

ខ្លួនមានសញ្ញាប្រមាណមិនបាន ដោយអំណាចនៃកសិណដែលបរិបូណ៌

ចំណែកក្នុងចតុក្កៈទី ៤ អធិប្បាយថា បុគ្គលមានទិព្វចក្ខុ ឃើញសត្វកើតក្នុងតិកជ្ឈានភូមិ និងចតុក្កជ្ឈានភូមិ រមែងប្រកាន់ថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង ឃើញសត្វកើតក្នុងនរក រមែងប្រកាន់ថា ខ្លួនមានទុក្ខតែម្យ៉ាង ឃើញសត្វកើតក្នុងពួកមនុស្ស រមែងប្រកាន់ថា ខ្លួនមានសុខ និងទុក្ខលាយគ្នា ឃើញសត្វកើតក្នុងទេពជាន់វេហប្ផលៈ រមែងប្រកាន់ថា ខ្លួនមិនមានទុក្ខក៏មិនមែន មិនមានសុខក៏មិនមែន ។

ដោយចំពោះយ៉ាងក្រៃលែង ពួកដែលបានបុព្វេនិវាសានុស្សតិញ្ញាណ ជាពួកបុព្វន្តកប្បិកៈ , ពួកដែលបានទិព្វចក្ខុ ជាពួកអបរន្តកប្បិកៈ ដូច្នេះឯង ។

## អធិប្បាយ អសញ្ញីនេវសញ្ញីនាសញ្ញីវាទ

[៨៧-៨៨] *អសញ្ញីវាទ: បណ្ឌិតគប្បីជ្រាបដោយអំណាចចតុក្កៈ ទាំង ២ ដែលពោលទុកខាងដើមក្នុងសញ្ញីវាទៈ ។*

*នេវសញ្ញីនាសញ្ញីវាទៈ ក៏ដូចគ្នា ។*

*ក៏ត្រឹមតែក្នុងសញ្ញីវាទៈនោះ ទិដ្ឋិទាំងនោះ របស់ពួកដែលប្រកាន់ថា ខ្លួនមានសញ្ញា , ក្នុងអសញ្ញីវាទៈ និងនេវសញ្ញីនាសញ្ញីវាទៈនេះ ទិដ្ឋិទាំងនោះ របស់ពួកដែលប្រកាន់ថា ខ្លួនមិនមានសញ្ញា និងថា ខ្លួនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។*

*ក្នុងទិដ្ឋិទាំងនោះ គប្បីពិចារណាហេតុការណ៍ មិនមែនដោយចំណែកតែមួយ ។ ខ្ញុំម្ចាស់បានពោលទុកហើយថា សេចក្តីប្រកាន់សូម្បីរបស់អ្នកមានទិដ្ឋិ ក៏ដូចគ្នានឹងកន្ត្រកបស់មនុស្សខ្វាក់ ។*

## អធិប្បាយ ឧច្ឆេទវាទ

[៨៥] ក្នុងឧច្ឆេទវាទៈ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សតោ បានដល់ មាននៅ ។

បទថា ឧច្ឆេទំ បានដល់ ការដាច់សូន្យ ។

បទថា វិនាសំ បានដល់ ការមិនជួបប្រទះ ។

បទថា វិភវំ បានដល់ ការប្រាសចាកភព ។

ពាក្យទាំងអស់នេះ ជាវេវចនៈនៃគ្នានិងគ្នានោះឯង ។

ក្នុងឧច្ឆេទវាទៈនោះ មានអ្នកប្រកាន់ដោយឧច្ឆេទទិដ្ឋិ ២ ពួក គឺ អ្នកបានបុព្វេនិវាសានុស្សតិញ្ញាណ ១ អ្នកមិនបានបុព្វេនិវាសានុស្សតិញ្ញាណ ១ , អ្នកដែលបានបុព្វេនិវាសានុស្សតិញ្ញាណ កាលរឭកតាម មានទិព្វចក្ខុ ឃើញចុតិ មិនឃើញឧប្បត្តិ យ៉ាងទៀត អ្នកណាអាចឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនឃើញឧប្បត្តិ អ្នកនោះឈ្មោះថា ប្រកាន់ដោយឧច្ឆេទទិដ្ឋិ ។

អ្នកដែលមិនបានបុព្វេនិវាសានុស្សតិញ្ញាណ គិតថា អ្នកណាហ្ន៎ ដឹងបរលោក រមែងប្រកាន់យកការដាច់សូន្យ ព្រោះតម្លៃដែលខ្លួនជាអ្នកត្រូវការកាមសុខ ឬព្រោះការនឹកយកដោយខ្លួនឯងជាដើមថា សត្វទាំងឡាយក៏ដូចគ្នានឹងស្លឹកឈើដែលជ្រុះចាកដើម មិនដុះតទៅដូច្នោះ ។

ក៏ក្នុងអធិការនេះ គប្បីជ្រាបថា ទិដ្ឋិ ៧ ទាំងនេះ កើតឡើងដោយ

អំណាចតណ្ហា និងទិដ្ឋិ ឬព្រោះកំណត់យកយ៉ាងនោះ និងយ៉ាងដទៃ ។

ក្នុងព្រះបាលីនោះ បទថា រូបី បានដល់ អ្នកមានរូប ។

បទថា ចាតុម្មហាភូតិកោ បានដល់ សម្រេចដោយមហាភូត ៤ ។

ដែលឈ្មោះថា មាតាបេត្តិកំ ព្រោះមានមាតា និងបិតានោះ បានដល់អ្វី ? បានដល់ សុក្កៈ និងលោហិត ។

ដែលឈ្មោះថា មាតាបេត្តិកសម្ភវោ ព្រោះសម្ភព គឺ កើតដោយសុក្កៈ និងលោហិតរបស់មាតានិងបិតា ។

សមណៈ ឬព្រាហ្មណ៍អ្នកមានវាទៈ និងទិដ្ឋិ រមែងពោលអត្តភាពរបស់មនុស្សថា ខ្លួន ដោយលើករូបកាយឡើងជាប្រធាន ។

បទថា ឥត្ថេកេ កាត់បទជា ឥត្ថំ ឯកេ សេចក្តីស្មើគ្នានឹង ឯវមេកេ ដោយប្រការដូច្នេះឯង ។

សមណៈ ឬព្រាហ្មណ៍ពួកទី ២ បដិសេធសេចក្តីនោះ ពោលអត្តភាពដែលជាទិព្វ ។

បទថា ទិព្វោ សេចក្តីថា កើតក្នុងទេវលោក ។

បទថា កាមាវចរោ បានដល់ រាប់បញ្ចូលក្នុងទេវតាជាន់កាមាវចរ ៦ ជាន់ ។

ដែលឈ្មោះថា កពឡិង្ការាហារភក្ខោ ព្រោះស៊ីអាហារ គឺ ពំនូតបាយ ។

បទថា មនោមយោ បានដល់ កើតដោយឈានចិត្ត ។

បទថា សព្វង្គបច្ចង្គី បានដល់ ប្រកបដោយអវយវៈតូចធំគ្រប់គ្រាន់ ។

បទថា អហីនិន្ទ្រិយោ បានដល់ មានឥន្ទ្រិយបរិបូណ៌ ។

ពាក្យនេះ លោកពោលដោយអំណាចនៃឥន្ទ្រិយ ដែលមានក្នុងព្រហ្ម-លោក និងដោយអំណាចទ្រង់ទ្រាយរបស់ឥន្ទ្រិយក្រៅពីនេះ ។

សេចក្ដីរបស់ពាក្យថា សព្វសោ រូបសញ្ញានំ សមតិក្កមា ដូច្នេះជាដើម ខ្ញុំម្ចាស់ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

ចំណែកក្នុងពាក្យថា អាកាសានញ្ចាយតនុបគោ ជាដើម គប្បីជ្រាបន័យសេចក្ដីយ៉ាងនេះថា ចូលដល់កពជាន់អាកាសានញ្ចាយតនៈ ។ ពាក្យដ៏សេសក្នុងឧច្ឆេទវាទៈនេះ ងាយទាំងអស់ដូច្នេះឯង ។

## អធិប្បាយ ទិដ្ឋធម្មនិព្វានវាទ

[៥០] ក្នុងទិដ្ឋធម៌និព្វានវាទៈ មានវិនិច្ឆ័យដូចតទៅនេះ ៖

ធម៌ដែលប្រចក្ស ហៅថា **ទិដ្ឋធម្ម** ។

ពាក្យនេះ ជាឈ្មោះរបស់អត្តភាពដែលបានចំពោះ ក្នុងភពនោះៗ ។ និព្វានក្នុងទិដ្ឋធម្ម ឈ្មោះថា និព្វានបច្ចុប្បន្ន អធិប្បាយថា ទុក្ខស្ងប់ក្នុងអត្តភាពនេះឯង ។

សមណព្រាហ្មណ៍ ឈ្មោះថា ទិដ្ឋធម្មនិព្វានវាទៈ ព្រោះពោលនិព្វានបច្ចុប្បន្ននោះ ។

បទថា បរមទិដ្ឋនិព្វានំ បានដល់ និព្វានបច្ចុប្បន្នជាធម៌យ៉ាងក្រៃលែង អធិប្បាយថា ខ្ពង់ខ្ពស់បំផុត ។

បទថា បញ្ចហិ កាមគុណេហិ សេចក្តីថា ដោយចំណែកនៃកាម ឬដោយគ្រឿងចង ៥ យ៉ាង មានរូបជាទីពេញចិត្ត និងជាទីស្រឡាញ់ជាដើម ។

បទថា សមប្បិតោ បានដល់ ជាអ្នកនៃបនិត្យ គឺ តាំងណែនដោយល្អ ។

បទថា សមង្គីភូតោ បានដល់ ប្រកប ។

បទថា បរិចារេតិ សេចក្តីថា ញ៉ាំងឥន្ទ្រិយឲ្យត្រាច់ទៅ ឲ្យសញ្ចរទៅ នាំចូលទៅខាងឯណោះខ្លះ ខាងនេះខ្លះ តាមសប្បាយក្នុងកាមគុណ

ទាំងនោះ ។ ក៏ន័យម្យ៉ាងទៀត រមែងពេញចិត្ត រមែងត្រេកអរ រមែងលេង ។

ក៏កាមគុណក្នុងទីនេះមាន ២ យ៉ាង គឺ ដែលជារបស់មនុស្ស ១ ដែលជាទិព្វ ១ ។ កាមគុណដែលជារបស់មនុស្ស គប្បីឃើញដូចកាមគុណរបស់ព្រះបាទមន្ធាតុរាជ ចំណែកកាមគុណដែលជាទិព្វ គប្បីឃើញដូចកាមគុណរបស់បរនិម្មិតវសវត្តីទេវរាជ ដូច្នេះ ។

ក៏សមណព្រាហ្មណ៍ទាំងនោះ រមែងបញ្ញត្តិការសម្រេចនិព្វានបច្ចុប្បន្នរបស់បុគ្គលដែលចូលដល់កាម បែបនេះ ។

ក្នុងវារៈទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

កាមទាំងឡាយ គប្បីជ្រាបថា ឈ្មោះថា មិនទៀង ដោយអត្ថថា មានហើយត្រឡប់មិនមាន , ឈ្មោះថា ជាទុក្ខ ដោយអត្ថថា បៀតបៀន , ឈ្មោះថា មានសេចក្តីប្រែប្រួលជាធម្មតា ដោយអត្ថថា លះបង់ប្រក្រតី ។

បទថា តេសំ វិបរិណាមញ្ញថាភាវា សេចក្តីថា ព្រោះកាមទាំងនោះ ក្លាយជាយ៉ាងដទៃ ពោលគឺ ប្រែប្រួល ទើបមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត កើតឡើង ដោយន័យដូចពោលហើយ សូម្បីវត្ថុណាមានដល់យើង សូម្បីវត្ថុនោះ មិនមានដល់យើង ដូច្នេះ ។

ក្នុងបណ្តាទាំង ៥ យ៉ាងនោះ សេចក្តីសោក មានលក្ខណៈដុតពេលក្នុងខាងក្នុង , សេចក្តីខ្សឹកខ្សួល មានលក្ខណៈពោលរៀបរាប់អាស្រ័យ

សេចក្ដីសោកនោះ , សេចក្ដីទុក្ខ មានលក្ខណៈបៀតបៀនកាយ , ទោមនស្ស មានលក្ខណៈលំបាកចិត្ត , សេចក្ដីចង្អៀតចង្អល់ចិត្ត មានលក្ខណៈដុតរោលចិត្តយ៉ាងខ្លាំង ។

សេចក្ដីរបស់ពាក្យថា វិវិច្ចេវ កាមេហិ ដូច្នេះជាដើម ខ្ញុំម្ចាស់ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា វិតក្កិតំ សេចក្ដីថា វិតក្កៈដែលប្រព្រឹត្តទៅដោយអំណាចលើកចិត្តឡើងកាន់អារម្មណ៍ ។

បទថា វិចារិតំ សេចក្ដីថា វិចារៈដែលប្រព្រឹត្តទៅ ដោយអំណាចស្ទាបអង្អែលអារម្មណ៍ ។

បទថា ឯតេនេតំ សេចក្ដីថា បឋមឈាននេះ ប្រាកដថា គ្រោតគ្រាតដូចមានបន្លា ព្រោះនៅមានវិតក្កៈ និងវិចារៈ ។

បទថា បីតិគតំ បានដល់ បីតិនុ៎ះឯង ។

បទថា ចេតសោ ឧព្បិលាវិតត្តំ បានដល់ ជាហេតុធ្វើឲ្យចិត្តតក់ស្លុត ។

បទថា ចេតសោ អាភោគោ សេចក្ដីថា ចេញចាកឈានហើយចិត្តក៏នៅសញ្ជឹងគិត គឺ នឹកដល់ វិលវល់នៅក្នុងសុខនោះរឿយៗ ។

ពាក្យដ៏សេសក្នុងទិដ្ឋធម្មនិព្វានវាទៈនេះ ងាយទាំងអស់ ។

ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ជាការត្រាស់ដល់ទិដ្ឋិ ៦២ ទាំងអស់ ដែលបែងចែកជាឧច្ឆេទទិដ្ឋិ ៧ ប៉ុណ្ណោះ ដ៏សេសជាសស្សតទិដ្ឋិ ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ប្រមូលបុព្វន្តកប្បិកទិដ្ឋិទាំងអស់នោះ ចូលជាមួយគ្នា ដោយវារៈនេះថា ឥធេ ខោ តេ ភិក្ខវេ ជាដើម ហើយទ្រង់វិសជ្ជនាដោយព្រះសព្វញ្ញុតញ្ញាណ ។ ទ្រង់ប្រមូលអបរន្តកប្បិកទិដ្ឋិ និងបុព្វន្តអបរន្តកប្បិកទិដ្ឋិទាំងអស់នោះ ចូលជាមួយគ្នា ដោយវារៈថា ឥធេ ខោ តេ ភិក្ខវេ ជាដើម ហើយទ្រង់វិសជ្ជនាដោយព្រះញាណនោះឯង សូម្បីកាលត្រាស់សួរ ក្នុងព្រះតម្រាស់ថា កតមេ ច តេ ភិក្ខវេ ធម្មា ជាដើម ក៏ត្រាស់សួរដោយព្រះសព្វញ្ញុតញ្ញាណនុ៎ះឯង សូម្បីទ្រង់វិសជ្ជនា ក៏ទ្រង់លើកទិដ្ឋិ ៦២ ប្រការឡើង ហើយទ្រង់វិសជ្ជនាដោយព្រះសព្វញ្ញុតញ្ញាណនុ៎ះឯង ដូចទ្រង់ថ្លឹងអធ្យាស្រ័យរបស់សត្វទាំងឡាយ ដោយជញ្ជីង ដូចទ្រង់លើកខ្សាច់អំពីជើងភ្នំសិនេរុដូច្នោះ ដោយប្រការដូច្នេះ ។

ព្រះធម៌ទេសនានេះ មកហើយដោយអំណាចតាមលំដាប់អនុសន្ធិយ៉ាងនេះ ។

ក៏ព្រះសូត្រមានអនុសន្ធិ ៣ យ៉ាង គឺ ៖

១. **បុច្ឆានុសន្ធិ** ព្រះធម៌ទេសនាដែលត្រាស់ឆ្លើយពាក្យសួរ ។

២. **អជ្ឈាសយានុសន្ធិ** ព្រះធម៌ទេសនា ដែលទ្រង់សម្ដែងតាម

អធ្យាស្រ័យរបស់សត្វ ។

៣. **យថានុសន្ធិ** ព្រះធម៌ទេសនា ដែលទ្រង់សម្ដែងតាមលំដាប់រឿង ។

ក្នុងអនុសន្ធិនៃព្រះសូត្រ ៣ យ៉ាងនោះ គប្បីជ្រាប **បុច្ឆានុសន្ធិ** ដោយអំណាចនៃព្រះសូត្រ ដែលព្រះមានព្រះភាគត្រាស់វិសជ្ជនាដល់អ្នកដែលទូលសួរយ៉ាងនេះថា កាលព្រះពុទ្ធអង្គត្រាស់យ៉ាងនេះហើយ នន្ទិគោបាល បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ត្រើយអាយបានដល់អ្វី ត្រើយនាយបានដល់អ្វី ការលិចចុះត្រង់កណ្ដាលបានដល់អ្វី ការសោត់ទៅលើគោកបានដល់អ្វី មនុស្សចាប់យកបានដល់អ្វី អមនុស្សចាប់យកបានដល់អ្វី ទឹកវល់ក្ដួចបានដល់អ្វី ការស្អុយក្នុងបានដល់អ្វី ។

គប្បីជ្រាប **អជ្ឈាសយានុសន្ធិ** ដោយអំណាចនៃព្រះសូត្រដែលព្រះមានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យរបស់សត្វពួកដទៃ ហើយត្រាស់យ៉ាងនេះថា គ្រានោះ ភិក្ខុមួយរូបមានសេចក្ដីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ដែលនិយាយគ្នាថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាអនត្តា ដូច្នេះ កម្មដែលអនត្តាធ្វើហើយ នឹងពាល់ត្រូវដល់អត្តាដូចម្ដេចបាន លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បានជ្រាបនូវសេចក្ដីត្រិះរិះរបស់ភិក្ខុនោះ ដោយព្រះហឫទ័យរបស់ព្រះអង្គហើយ ទើប

ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក៏ឋានៈដែលនឹងមានបាន ដែលមានមោឃបុរសពួកខ្លះក្នុងធម្មវិន័យនេះ ធ្លាក់នៅក្នុងអវិជ្ជា មានចិត្ត ដែលមានជាតណ្ហាធំ នឹងគប្បីយល់សត្ថុសាសន៍ចំពោះមុខថា ម្នាលអ្នកដ៏ចម្រើន ដែលនិយាយគ្នាថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអនត្តា កម្មដែលអនត្តាធ្វើ នឹងពាល់ត្រូវអត្តាដូចម្ដេច ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច រូបទៀង ឬមិនទៀង ដូច្នេះ ។

តែគប្បីជ្រាប **យថានុសន្ធិ** ដោយអំណាចនៃព្រះសូត្រទាំងឡាយ ដែលមកនៃព្រះធម៌ទេសនាក្នុងខាងមុខ ដោយអំណាចនៃធម៌ដែលចូលគ្នាបាន ឬដោយអំណាចនៃធម៌ដែលជំទាស់គ្នាដល់ធម៌ ដែលជាហេតុឲ្យព្រះ-ធម៌ទេសនាតាំងឡើងក្នុងខាងដើម ដូចក្នុងអាកង្ខេយ្យសូត្រ ធម្មទេសនាតាំងឡើងដោយសីលក្នុងផ្នែកខាងដើម អភិញ្ញា ៦ មកក្នុងផ្នែកខាងចុង , ក្នុងវត្ថុសូត្រ ទេសនាតាំងឡើងដោយអំណាចកិលេសក្នុងផ្នែកខាងដើម ព្រហ្ម-វិហារមកក្នុងផ្នែកខាងចុង , ក្នុងកោសម្ពិកសូត្រ ទេសនាតាំងឡើងដោយការឈ្លោះក្នុងផ្នែកខាងដើម សារាណីយធម៌ មកក្នុងផ្នែកខាងចុង , ក្នុងកកចូបមសូត្រ ទេសនាតាំងឡើងដោយសេចក្ដីមិនអត់ធន់ ក្នុងផ្នែកខាងដើម ឧបមាដោយរណាមកក្នុងផ្នែកខាងចុង ។ ក្នុងព្រហ្មជាលសូត្រនេះ ទេសនាតាំងឡើងដោយអំណាចនៃទិដ្ឋិក្នុងផ្នែកខាងដើម ការប្រកាសសុញ្ញតាមកក្នុងផ្នែកខាងចុង ។ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបបានពោលទុកថា ព្រះធម៌-

*ទេសនានេះ មកហើយដោយអំណាចនៃយថានុសន្ធិយ៉ាងនេះ ដូច្នេះ ។*

# បរិតស្សិតវិប្ផន្ទិតវារ

[៥១] ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងការចែកដែនកំណត់ ព្រះ-មានព្រះភាគ ទើបទ្រង់ផ្ដើមទេសនាថា តត្រ ភិក្ខវេ ដូច្នេះជាដើម ។

ពាក្យថា តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ដូច្នេះ ។ សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះ កើតសោមនស្ស ដោយសេចក្ដីត្រេកអរក្នុងទិដ្ឋិ ដោយសេចក្ដីសុខក្នុងទិដ្ឋិ ដោយសេចក្ដីរំពូកដឹងក្នុងទិដ្ឋិណា រមែងបញ្ញត្តិខ្លួននិងលោកថា ទៀង ដោយហេតុ ៤ ប្រការ សូម្បីសេចក្ដីនោះ ក៏ជាសេចក្ដីរំពូកដឹងរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ អ្នកមិនដឹង មិនឃើញសភាពនៃធម៌ទាំងឡាយតាមសេចក្ដីពិត ជាអ្នកនៅមានតណ្ហា ការរំពូកដឹងនោះ ជារបស់អ្នកដែលនៅមានតណ្ហាប៉ុណ្ណោះតែម្យ៉ាង ក៏ការរំពូកដឹងនេះឯង ជាសេចក្ដីក្ដៅក្រហាយ ជាការស្វែងរកប៉ុណ្ណោះ គឺជាសេចក្ដីតក់ស្លុតប៉ុណ្ណោះ ជាសេចក្ដីញាប់ញ័រប៉ុណ្ណោះ ដោយសេចក្ដីក្ដៅក្រហាយ ពោលគឺ ទិដ្ឋិ និងតណ្ហា ដូចគ្នានឹងបង្គោលដែលបោះទុកក្នុងគំនរអង្កាម មិនមែនមិនញាប់ញ័រ ដូចទស្សនៈរបស់ព្រះសោតាបន្ន ។

[៥២-៦៣] សូម្បីក្នុងឯកច្ចសស្សតវាទជាដើម ក៏ន័យនេះឯង ។

# ផស្សបច្ចយវារ

[៦៤] *ព្រះបាលីថា* តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា ដូច្នេះជាដើម ព្រះមានព្រះភាគទ្រង់ផ្ដើមទុកទៀត ដើម្បីទ្រង់សម្ដែងបច្ច័យតៗ គ្នាមក ។

ក្នុងព្រះបាលីនោះ ដោយព្រះតម្រាស់ថា តទបិ ផស្សប្បច្ចយា ដូច្នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា សមណព្រាហ្មណ៍ទាំងនោះ កើតសោមនស្សដោយសេចក្ដីត្រេកអរក្នុងទិដ្ឋិ ដោយសេចក្ដីសុខក្នុងទិដ្ឋិ ដោយសេចក្ដីរំពុកដឹងក្នុងទិដ្ឋិយ៉ាងណា រមែងបញ្ញត្តិខនិងលោកថា **ទៀង** ដោយហេតុ ៤ ប្រការ សូម្បីសេចក្ដីនោះ ក៏គឺ ការដឹង ក្ដៅក្រហាយ ព្រោះតណ្ហា និងទិដ្ឋិ ព្រោះមានផស្សៈជាបច្ច័យ ដូច្នេះ ។

[៦៥-៧៦] ក្នុងវារៈទាំងពួង ក៏ន័យនេះ ។

[៧៧] ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងការៈដែលជាបច្ច័យនោះ មានកម្លាំងក្នុងការដឹង ក្នុងទិដ្ឋិ ព្រះមានព្រះភាគទើបត្រាស់ព្រះបាលីទៀតថា តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ ដោយពាក្យថា តេ វត អញ្ញត្រ ផស្សា ដូច្នេះ ព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីថា ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ វៀរចាកពីផស្សៈ នឹងដឹង សេចក្ដីដឹងនោះ ដូច្នេះនោះមិនមានជាហេតុ

ដែលនឹងប្រព្រឹត្តទៅបាន ឧបមាដូចជា ឈ្មោះថា សសរ រមែងជាបច្ច័យដ៏មានកម្លាំង ដើម្បីប្រយោជន៍ក្នុងការទ្រទប់ផ្ទះអំពីខ្យល់ មិនមាន សសរទ្រទប់ទុក មិនអាចនឹងតាំងនៅបានយ៉ាងណា សូម្បីផស្សៈក៏មានឧបមេយ្យដូច្នោះឯង ជាបច្ច័យដ៏មានកម្លាំងដល់វេទនា វៀរផស្សៈនោះចេញ ការដឹងក្នុងទិដ្ឋិនេះ រមែងមិនមាន ដូច្នេះ ។

[៧៨-៨៩] ក្នុងវារៈទាំងពួង ក៏ន័យនេះ ។

# ទិដ្ឋិគតិកាធិដ្ឋានវដ្ដកថា

[៩០] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ប្រមូលសេចក្ដីដឹង ក្នុងទិដ្ឋិទាំងពួង ដោយន័យមានជាដើមថា ម្នាលភិក្ខុទាំងឡាយ បណ្ដា ពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទបញ្ញត្តិខ្លួន និងលោកថា ទៀង ដោយហេតុ ៤ ប្រការ សូម្បីសមណព្រាហ្មណ៍ទាំងនោះណា ជាឯកច្ចសស្សតិកៈ បណ្ដាសមណព្រាហ្មណ៍ទាំងនោះដូច្នេះ ។

ព្រោះហេតុអ្វី ?

ព្រោះដើម្បីត្រូវការនឹងផ្ដើមផស្សៈខាងមុខ ។

យ៉ាងណា ?

សមណព្រាហ្មណ៍ទាំងអស់នោះពាល់ត្រូវហើយ ដោយផស្សាយតនៈទាំង ៦ រមែងសោយវេទនា ។ ដែលឈ្មោះថា ផស្សាយតនៈទាំង ៦ ក្នុងសេចក្ដីនោះ បានដល់ ផស្សាយតនៈ ៦ ទាំងនេះ គឺ ចក្ខុផស្សាយតនៈ ១ សោតផស្សាយតនៈ ១ ឃានផស្សាយតនៈ ១ ជិវ្ហាផស្សាយតនៈ ១ កាយផស្សាយតនៈ ១ មនោផស្សាយតនៈ ១ ។

ក៏អាយតនៈសព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា ទីកើត ទីប្រជុំ ហេតុ និងបញ្ញត្តិ ។ ក្នុងអត្ថទាំងនោះ **អាយតនៈ** សព្ទ ប្រព្រឹត្តទៅក្នុង

អត្ថថា **ទីកើត** ដូចក្នុងពាក្យថា ជនបទកម្ពោជៈ ជាទីកើតនៃសេះទាំងឡាយ ទក្ខិណាបថ ជាទីកើតរបស់គោទាំងឡាយ ដូច្នេះ អធិប្បាយថា ក្នុងទីជាទីកើត ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ទីប្រជុំ** ដូចក្នុងពាក្យថា កាលដើមឈើធំនោះ ជាទីប្រជុំ ជាទីគួររីករាយចិត្ត បក្សីទាំងឡាយ រមែងនាំគ្នាអាស្រ័យដើមឈើនោះ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ហេតុ** ដូចក្នុងពាក្យថា កាលបើហេតុមាន ។

ប្រព្រឹត្តទៅក្នុងអត្ថថា **បញ្ញត្តិ** ដូចក្នុងពាក្យថា រមែងសម្មតិបញ្ញត្តិថា នាដងព្រៃក្នុងបណ្ណកុដិ (កុដិស្លឹក) ។

អាយតនៈស័ព្ទនេះ ក្នុងទីនេះ រមែងគួរក្នុងអត្ថទាំង ៣ មានទីកើតជាដើម ។

ពិតមែន ធម៌ទាំងឡាយមានផស្សៈជាប្រធាន រមែងកើត រមែងប្រជុំក្នុងចក្ខុជាដើម សូម្បីចក្ខុជាដើមទាំងនោះ ក៏ជាហេតុរបស់ធម៌ទាំងនោះ ហេតុនោះ ទើបឈ្មោះថា អាយតនៈ ។ ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ផស្សាយតនៈទាំង ៦ ជាដើមទុក ដើម្បីទ្រង់សម្ដែងការត ៗ គ្នា នៃបច្ច័យ រាប់តាំងពីផស្សៈជាដើមទៅ លើកព្រះធម៌ទេសនា ដោយលើកផស្សៈជាប្រធានទុំះឯង ដោយន័យនេះថា អាស្រ័យចក្ខុ និងរូប ទើបកើតចក្ខុវិញ្ញាណ ទាំង ៣ ប្រជុំចូលគ្នា ទើបជា ផស្សៈ ដូច្នេះ ។

បទថា ផុស្ស ផុស្ស បដិសំវេទេន្តិ សេចក្តីថា ពាល់ត្រូវ ពាល់ត្រូវ ទើបវេទនាសោយ ។

ក៏ក្នុងព្រះបាលីនេះ សូម្បីទីងបានត្រាស់ដូចអាយតនៈទាំងឡាយមានការពាល់ត្រូវជាកិច្ចទុកក៏ពិតមែនហើយ ក៏មិនគប្បីយល់ថា អាយតនៈទាំងនោះ មានការពាល់ត្រូវជាកិច្ច ។ ព្រោះថា អាយតនៈទាំងឡាយពាល់ត្រូវមិនបាន ចំណែកផស្សៈ រមែងពាល់ត្រូវអារម្មណ៍នោះ ៗ ។ ក៏អាយតនៈទាំងឡាយ ទ្រង់សម្តែងបញ្ចូលទុកក្នុងផស្សៈ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងព្រះបាលីនេះ យ៉ាងនេះថា សមណព្រាហ្មណ៍ទាំងអស់នោះពាល់ត្រូវអារម្មណ៍ មានរូបជាដើមដោយផស្សៈ ដែលកើតពីផស្សាយតនៈ ៦ ហើយសោយវេទនាក្នុងទិដ្ឋិនោះ ។

ក្នុង ២ ថា តេសំ វេទនាបច្ចយា តណ្ហា ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា វេទនា សេចក្តីថា វេទនាកើតអំពីផស្សាយតនៈ ៦ ។ វេទនានោះ រមែងជាបច្ច័យដោយឧបនិស្ស័យប្បច្ច័យដល់តណ្ហា មានរូបតណ្ហាជាដើម ដោយហេតុនេះ ទើបត្រាស់ថា ព្រោះវេទនារបស់សមណព្រាហ្មណ៍ទាំងនោះជាបច្ច័យ ទើបកើតតណ្ហា ដូច្នេះ ។ និងតណ្ហានោះ ក៏ជាបច្ច័យដោយឧបនិស្ស័យប្បច្ច័យ និងដោយសហជាតប្បច្ច័យដល់ឧបាទាន ៤ យ៉ាង ។ ឧបាទាន ក៏ជាបច្ច័យដល់ភពយ៉ាងនោះ ។ ភពជាបច្ច័យដោយឧបនិស្ស័យ-

ប្បច្ច័យដល់ជាតិ ។ ក៏ក្នុងពាក្យថា **ជាតិ** នេះ គប្បីឃើញថា បានដល់ ខន្ធ ៥ ព្រមទាំងវិការ ។ ជាតិជាបច្ច័យ ដោយឧបនិស្ស័យប្បច្ច័យដល់ជរា-មរណៈ និងសោកៈជាដើម ។ នេះជាសេចក្ដីសង្ខេបក្នុងព្រះបាលីនេះ ។ ចំណែកកថាពោលដោយបដិច្ចសមុប្បាទ បានពោលទុកហើយដោយពិស្ដារ ក្នុងវិសុទ្ធិមគ្គ ។ ក៏ក្នុងទីនេះ គប្បីជ្រាបល្មមប្រមាណតាមព្រះបាលីនោះប៉ុណ្ណោះ ។

ក៏ព្រះមានព្រះភាគ កាលត្រាស់វដ្តកថា រមែងត្រាស់ដោយស័ព្ទដែលជាប្រធាន គឺ **អវិជ្ជា** យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជា រមែងមិនប្រាកដ ក្នុងកាលមុននេះ អវិជ្ជាមិនមាន តែខាងក្រោយទើបមាន ព្រោះហេតុនោះ តថាគតពោលពាក្យនេះ យ៉ាងនេះ ដូច្នោះ អវិជ្ជាមាន ព្រោះសេចក្ដីនេះជាបច្ច័យ ទើបប្រាកដ ដូច្នេះខ្លះ ដោយស័ព្ទ ដែលជាប្រធាន គឺ **តណ្ហា** យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវតណ្ហា រមែងមិនប្រាកដ ក្នុងកាលមុនអំពីនេះ ឬថា ភវតណ្ហាមិនមាន តែខាងក្រោយទើបមាន ព្រោះហេតុនោះ តថាគតពោលពាក្យនេះ យ៉ាងនេះ ដូច្នេះ ភវតណ្ហាមាន ព្រោះសេចក្ដីនេះជាបច្ច័យ ទើបត្រាស់ដូច្នេះខ្លះ , ដោយស័ព្ទដែលជាប្រធាន គឺ **ទិដ្ឋិ** យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវទិដ្ឋិ មិនប្រាកដ ក្នុងកាលមុនអំពីនេះ ភវទិដ្ឋិមិនមាន តែខាងក្រោយទើបមាន ព្រោះហេតុ

នោះ តថាគតពោលយ៉ាងនេះ កាលដូច្នោះ ភវទិដ្ឋិមាន ព្រោះសេចក្តីនេះជាបច្ច័យ ទើបប្រាកដ ដូច្នេះខ្លះ ។ ក៏ក្នុងព្រះសូត្រនេះ កាលត្រាស់ដោយស័ព្ទដែលជាប្រធាន គឺ ទិដ្ឋិ ត្រាស់ទិដ្ឋិទាំងឡាយ ដែលកើតឡើងដោយការជាប់ចិត្តក្នុងវេទនា ទើបត្រាស់បដិច្ចសមុប្បាទដែលមានវេទនាជាមូល ។ ដោយហេតុនោះ ទើបទ្រង់សម្តែងសេចក្តីនេះថា សមណព្រាហ្មណ៍ម្ចាស់ទិដ្ឋិទាំងនេះ ប្រកាន់ការឃើញនេះហើយ ត្រាច់ទៅ អន្ទោលទៅក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ អំពីនេះទៅនោះ អំពីនោះមកនេះ ដូច្នេះ រមែងវិលវល់ទៅតាមវដ្តទុក្ខតែម្យ៉ាង មិនអាចនឹងងើយសីសៈឡើងចាកវដ្តទុក្ខបាន ដូចគោដែលគេទឹមទុកក្នុងគ្រឿងយន្ត ដូចកូនសុនខដែលគេចងទុកត្រង់សសរ និងដូចទូកដែលក្រឡាប់ចុះដោយខ្យល់ដូច្នោះ ។

# វិវដ្ដជាដើម

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់វដ្ដៈដែលជាទីតាំងអាស្រ័យរបស់មនុស្សមានទិដ្ឋិយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងវិវដ្ដៈ ញុំាងភិក្ខុដែលប្រកបសេចក្ដីព្យាយាមឡើងជាទីតាំង ទើបត្រាស់ព្រះបាលីថា យតោ ខោ ភិក្ខវេ ភិក្ខុ ជាដើម ។

ក្នុងព្រះបាលីនោះ បទថា យតោ ប្រែថា ក្នុងកាលណា ។

បទថា ឆន្នំ ផស្សាយតនានំ សេចក្ដីថា វដ្ដៈរមែងវិលទៅចំពោះមនុស្សមានទិដ្ឋិ អ្នកពាល់ត្រូវដោយផស្សាយតនៈពួកណា សោយវេទនានៃផស្សាយតនៈ៦ ពួកនុ៎ះឯង ។

ក្នុងពាក្យថា សមុទយំ គប្បីជ្រាបការកើតនៃផស្សាយតនៈ តាមន័យដែលត្រាស់ទុកក្នុងវេទនាកម្មដ្ឋានថា ព្រោះអវិជ្ជាកើត ចក្ខុទើបកើត ដូច្នេះជាដើម ។ ដូចក្នុងវេទនាកម្មដ្ឋាននោះ ត្រាស់ទុកថា ព្រោះផស្សៈកើត ព្រោះផស្សៈរលត់ ដូច្នេះយ៉ាងណា ក្នុងព្រះបាលីនេះក៏ដូច្នោះ គប្បីជ្រាបអាយតនៈនោះថា ក្នុងចក្ខុជាដើម ព្រោះអាហារកើត ព្រោះអាហាររលត់ ក្នុងមនាយតនៈ ព្រោះនាមរូបកើត ព្រោះនាមរូបរលត់ ដូច្នេះឯង ។

បទថា ឧត្តរិតរំ បជានាតិ សេចក្ដីថា បុគ្គលអ្នកមានទិដ្ឋិ រមែងដឹងច្បាស់ចំពោះទិដ្ឋិប៉ុណ្ណោះ ចំណែកភិក្ខុនេះ រមែងដឹងទិដ្ឋិ និងក្រៃលែង

ឡើងទៅជានទិដ្ឋិ គឺ សីល សមាធិ បញ្ញា និងវិមុត្តិ ដរាបដល់ព្រះអរហត្ត គឺ ព្រះខីណាស្រពក៏ដឹង ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន ក៏ដឹង ភិក្ខុដែលជាពហុស្សុត ទ្រទ្រង់គន្ថធុរៈក៏ដឹង ភិក្ខុដែលប្រារព្ធវិបស្សនាក៏ដឹង ។

ក៏ព្រះធម៌ទេសនា ដែលព្រះមានព្រះភាគទ្រង់ធ្វើឲ្យចប់ដល់កំពូល គឺ ព្រះអរហត្តតែម្ដង ដូច្នេះឯង ។

ព្រះមានព្រះភាគ កាលត្រាស់វិវដ្ដៈយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងទ្រង់សម្ដែងថា ដែលឈ្មោះថា អ្នកមានទិដ្ឋិដែលរួចផុតចាកសំណាញ់ គឺ ព្រះធម៌ទេសនារមែងមិនមាន ទើបត្រាស់តទៅថា យេ ហិ កេចិ ភិក្ខវេ ជាដើម ។

ក្នុងព្រះបាលីនោះ បទថា អន្តោជាលិកតា សេចក្ដីថា នៅខាងក្នុងសំណាញ់ គឺ ទេសនារបស់ព្រះតថាគតនេះឯង ។

បទថា ឯត្ថ សិតា វ សេចក្ដីថា នៅអាស្រ័យ គឺ ធ្លាក់នៅក្នុងសំណាញ់ គឺ ទេសនារបស់ព្រះតថាគតនេះឯង ។

ពាក្យថា កាលងើបក៏ងើប មានពាក្យអធិប្បាយយ៉ាងណា ?

មានពាក្យអធិប្បាយថា សមណៈ ឬព្រាហ្មណ៍ទាំងនោះ មុជចុះ ខ្លះងើបឡើងខ្លះ ក៏ជាអ្នកនៅក្នុងសំណាញ់ គឺ ទេសនារបស់ព្រះតថាគត មុជចុះ និងងើបឡើង ។

បទថា ឯត្ថ បរិយាបន្នា សេចក្ដីថា ជាអ្នកជាប់ក្នុងសំណាញ់ គឺទេសនារបស់ព្រះតថាគតនេះ ដែលសំណាញ់ គឺ ទេសនានេះគ្របទុកដូចនៅខាងក្នុងសំណាញ់ កាលងើប ក៏ងើបឡើង ដែលឈ្មោះថា អ្នកមានទិដ្ឋិ ដែលមិនសង្គ្រោះចូលក្នុងសំណាញ់ គឺ ទេសនានេះ រមែងមិនមានដូច្នេះឯង ។

បទថា សុខុមច្ឆិទ្ទកេន សេចក្ដីថា ដោយសំណាញ់ក្រឡាល្អិតញឹក ។

ពិតហើយ ព្រះមានព្រះភាគប្រៀបដូចអ្នកប្រមង់ ព្រះធម៌ទេសនាប្រៀបដូចសំណាញ់ ម៉ឺនលោកធាតុប្រៀបដូចទឹកតិច សមណៈ ឬព្រាហ្មណ៍អ្នកមានទិដ្ឋិ ៦២ ប្រៀបដូចសត្វធំ កិរិយាដែលព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីដែលសមណៈ ឬព្រាហ្មណ៍អ្នកមានទិដ្ឋិទាំងអស់ ធ្លាក់នៅខាងក្នុងសំណាញ់ គឺ ព្រះធម៌ទេសនា ប្រៀបដូចកិរិយាដែលអ្នកប្រមង់នោះ ឈរត្រើឡុកមើលនៅមាត់ច្រាំង ឃើញសត្វធំៗ នៅខាងក្នុងសំណាញ់ដូច្នោះ ។

ការប្រៀបធៀប ដោយសេចក្ដីឧបមាក្នុងព្រះធម៌ទេសនានេះ គប្បីជ្រាបដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេចក្ដីដែលសមណព្រាហ្មណ៍អ្នកមានទិដ្ឋិទាំងអស់ ជាអ្នកជាប់ក្នុងសំណាញ់ គឺ ព្រះធម៌ទេសនានេះ ព្រោះទិដ្ឋិទាំងអស់សង្គ្រោះចូលដោយទិដ្ឋិ ៦២ ទាំងនេះ យ៉ាងនេះហើយ

ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តីដែលព្រះអង្គជាអ្នកដាច់ក្នុងប្រការណាៗ ទើបត្រាស់ព្រះបាលីថា ឧច្ឆិន្នភវនេត្តិកោ ភិក្ខវេ តថាគតស្ស កាយោ ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា នេត្តិ ព្រោះអត្ថថា ជាគ្រឿងនាំទៅ ។

ពាក្យថា នយន្តិ សេចក្តីថា ចងកអូសទាញមក នេះជាឈ្មោះរបស់ខ្សែ ។ ក៏ក្នុងទីនេះ ភវតណ្ហាទ្រង់ប្រាថ្នាយកថា នេត្តិ ព្រោះដូចខ្សែជាគ្រឿងនាំទៅ ។ ពិតហើយ ភវតណ្ហានោះ រមែងចងកមហាជននាំទៅ គឺ នាំចូលទៅកាន់ភពនោះៗ ហេតុនោះ ទើបឈ្មោះថា ភវនេត្តិ ។ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពនោះ នៃកាយរបស់ព្រះតថាគតដាច់ហើយ ដោយសស្ត្រា ឬអរហត្តមគ្គ ហេតុនោះ កាយរបស់ព្រះតថាគត ទើបឈ្មោះថា មានតណ្ហានាំសត្វទៅកាន់ភពថ្មីទៀត ដាច់អស់ហើយ ។

បទថា កាយស្ស ភេទា ឧទ្ធំ សេចក្តីថា បន្ទាប់ពីកាយបែកធ្លាយទៅ ។

បទថា ជីវិតបរិយាទានា សេចក្តីថា ព្រោះអស់ជីវិតហើយ គឺ អស់ជុំវិញហើយដោយប្រការទាំងពួង ព្រោះមិនបដិសន្ធិតទៅ ។

បទថា ន តំ ទក្ខន្តិ សេចក្តីថា ទេវតាក្តី មនុស្សក្តី នឹងមិនឃើញព្រះតថាគតនោះ នឹងដល់ភាពជាអ្នកមិនមានបញ្ញត្តិ ។

ក៏ក្នុងពាក្យឧបមាថា សេយ្យថាបិ ភិក្ខវេ ដូច្នេះជាដើម មានពាក្យប្រៀបដូចត ទៅនេះ ៖

ក៏កាយរបស់ព្រះតថាគត ប្រៀបដូចដើមស្វាយ តណ្ហាដែលអាស្រ័យកាយនេះប្រព្រឹត្តទៅក្នុងភពមុន ប្រៀបដូចទងធំដែលកើតអំពីដើម កាលនៅមានតណ្ហា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ដែលជាសភាពជាប់នៅជាមួយតណ្ហានឹងកើតតទៅ ប្រៀបដូចចង្កោមផ្លែស្វាយទុំប្រមាណ ៥ ផ្លែខ្លះ ១២ ផ្លែខ្លះ ១៨ ផ្លែខ្លះ ជាប់នៅត្រង់ទងនោះ ។ សេចក្តីថា កាលទងនោះដាច់ ស្វាយទាំងអស់នោះ រមែងជាប់ទងនោះទៅ អធិប្បាយថាទៅតាមទងនោះឯង ដាច់ទៅដូចគ្នា ព្រោះទងដាច់ សេចក្តីនោះយ៉ាងណាទងតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពមិនទាន់ដាច់ ក៏គប្បីជាហេតុឲ្យកើតខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ធម៌ទាំងអស់នោះ រមែងជាប់តាមទងតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពនោះ អធិប្បាយថា ទៅតាមតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព កាលតណ្ហានោះដាច់ហើយ ក៏ដាច់ទៅដូចគ្នាដូច្នោះឯង ។

មួយទៀត កាលដើមឈើនោះ អាស្រ័យផស្សៈដែលជាពិសរបស់ធ្នុងត្រីក្រពែល ក៏ស្វិតស្រពោនចុះដោយលំដាប់ មានត្រឹមតែវោហារថាក្នុងទីនេះមានដើមឈើឈ្មោះនេះប៉ុណ្ណោះ នរណាៗ មិនបានឃើញដើមឈើនោះ សេចក្តីនេះយ៉ាងណា កាលកាយនេះ អាស្រ័យសម្ផស្សរបស់

អរិយមគ្គ ព្រោះជ័រ គឺ តណ្ហាអស់ទៅហើយ ទើបស្ងួតស្រពោនចុះតាមលំដាប់ ហើយបែកធ្លាយទៅ បន្ទាប់ពីកាយបែកធ្លាយហើយ ទេវតា និងមនុស្សទាំងឡាយនឹងមិនឃើញ សូម្បីព្រះតថាគត នឹងមានត្រឹមតែវោហារថា បានឮថា នេះជាសាសនារបស់ព្រះសាស្ដាបែបនេះប៉ុណ្ណោះ ព្រះមាន-ព្រះភាគទ្រង់សម្ដែងព្រះធម៌ទេសនាដល់អនុបាទិសេសនិព្វានធាតុ ដោយប្រការដូច្នេះ ។

ប្រការថា ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ សេចក្ដីថា កាលព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ យ៉ាងនេះហើយ ព្រះអានន្ទ-ត្ថេរ បានប្រមូលព្រះសូត្រទាំងអស់តាំងពីដើមមក ហើយគិតថា យើងនឹងសម្ដែងកម្លាំងរបស់ព្រះពុទ្ធ ព្រះមានព្រះភាគ ទ្រង់មិនបានតាំងនាមព្រះសូត្រដែលត្រាស់ បើដូច្នោះ យើងនឹងក្រាបទូលឲ្យទ្រង់ដាក់ឈ្មោះព្រះសូត្រដែលត្រាស់នោះ ដូច្នេះហើយ ទើបបានក្រាបទូលព្រះមានព្រះភាគដូច្នេះ ។

ក្នុងបទថា តស្មាតិហ ត្វំ ដូច្នេះជាដើម មានពាក្យប្រកបសេចក្ដីដូចតទៅនេះ ៖

ម្នាលអានន្ទ ព្រោះក្នុងធម្មបរិយាយនេះ តថាគតបានចែកទាំងប្រយោជន៍ក្នុងលោកនេះ ទាំងប្រយោជន៍ក្នុងលោកមុខ ដូច្នោះឯង អ្នកចូរចាំធម្មបរិយាយនេះថា **អត្ថជាល** ក៏បាន មួយទៀត ព្រោះក្នុងធម្មបរិយាយ

នេះ តថាគតបានពោលធម៌ដែលជាបែបផែនយ៉ាងច្រើន ដូច្នោះ អ្នកចូរចាំធម្មបរិយាយ ដែលជាបែបផែននេះថា **ធម្មជាល** ក៏បាន មួយទៀត ព្រោះក្នុងធម្មបរិយាយនេះ តថាគតបានចែកព្រះសព្វញ្ញុតញ្ញាណ ដែលឈ្មោះថា **ព្រហ្ម** ដោយអត្ថថា ប្រសើរបំផុត ដូច្នោះ អ្នកចូរចាំធម្ម-បរិយាយនេះថា **ព្រហ្មជាល** ក៏បាន ព្រោះក្នុងធម្មបរិយាយនេះ តថាគតបានចែកទិដ្ឋិ ៦២ ដូច្នោះ អ្នកចូរចាំធម្មបរិយាយនេះថា **ទិដ្ឋិជាល** ក៏បាន មួយទៀត ព្រោះនរណាៗ ស្ដាប់ធម្មបរិយាយនេះហើយ អាចនឹងញាំញីទេវបុត្តមារខ្លះ ខន្ធមារខ្លះ មច្ចុមារខ្លះ កិលេសមារខ្លះ ដូច្នោះ អ្នកចូរចាំធម្មបរិយាយនេះថា **សង្គាមវិជយ** ក៏បាន ដូច្នេះឯង ។

បទថា ឥទមវោច ភគវា សេចក្ដីថា ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រទាំងអស់នេះ ចាប់ផ្ដើមតាំងពីចប់ពាក្យនិទាន ដរាបដល់ត្រាស់ថា អ្នកចូរចាំធម្មបរិយាយនេះថា វិជ័យសង្គ្រាមដ៏កំពូល ដូច្នេះ ទ្រង់ប្រកាសព្រះសព្វញ្ញុតញ្ញាណ ដ៏ជ្រាលជ្រៅយ៉ាងក្រៃលែង ដែលមានទីតាំងអាស្រ័យដែលនរណាៗ មិនគប្បីបានដោយបញ្ញារបស់ជនពួកដទៃ ទ្រង់កម្ចាត់ងងឹតដ៏ធំ គឺ ទិដ្ឋិ ដូចព្រះអាទិត្យកម្ចាត់សេចក្ដីងងឹត ដូច្នោះ ។

បទថា អត្តមនា តេ ភិក្ខូ សេចក្ដីថា ភិក្ខុទាំងនោះ មានចិត្តរីករាយជារបស់ខ្លួន អធិប្បាយថា ជាអ្នកមានចិត្តផុសផុលឡើងដោយបីតិទៅក្នុងព្រះពុទ្ធ ។

បទថា ភគវតោ ភាសិតំ សេចក្ដីថា ព្រះសូត្រនេះប្រកបដោយទេសនាវិលាស មានន័យដ៏វិចិត្រយ៉ាងនេះ គឺ ជាព្រះតម្រាស់របស់ព្រះ-មានព្រះភាគត្រាស់ដោយព្រះសូរសៀងដ៏ពីរោះ ដូចសម្លេងសត្វការវេក ពីរោះត្រចៀក ជាព្រះសូរសៀងដូចសម្លេងនៃព្រហ្ម ដូចជាទ្រង់ស្រោចស្រប់ទឹកអម្រឹតចុះក្នុងហទយៈនៃបណ្ឌិតជន ។

បទថា អភិនន្ទុំ សេចក្ដីថា អនុមោទនាផង ទទួលយកផង ។

ក៏ អភិនន្ទ ស័ព្ទនេះ មកក្នុងអត្ថថា **តណ្ហា** ក៏មាន ដូចក្នុងពាក្យថា អភិនន្ទតិ អភិភវតិ រមែងក្ដៅក្ដៅន រមែងពោលសរសើរ ជាដើម ។

មកក្នុងអត្ថថា **ចូលទៅជិតក៏មាន** ដូចក្នុងប្រយោគថា គឺ ទេវតានិងមនុស្ស ទាំងពីរពួក រមែងចូលទៅជិតអាហារ ជាដើម ។

មកក្នុងអត្ថថា **ទទួល** ក៏មាន ដូចក្នុងប្រយោគថា ៖

ញាតិ មិត្ត និងអ្នកមានចិត្តល្អ រមែងទទួលបុគ្គលអ្នកបែកគ្នាអស់កាលយូរ ដែលត្រឡប់មកអំពីចម្ងាយដោយសួស្ដីជាដើម ។

មកក្នុងអត្ថថា **អនុមោទនា ក៏មាន** ដូចក្នុងប្រយោគថា អភិនន្ទិត្វា អនុមោទិត្វា ប្រែថា ត្រេកអរហើយ អនុមោទនាហើយ ជាដើម ។

អភិនន្ទ ស័ព្ទនេះ ក្នុងទីនេះ រមែងគួរក្នុងសេចក្ដីថា អនុមោទនា និងទទួលដោយសេចក្ដីរីករាយ ។ ដោយហេតុនេះ ខ្ញុំម្ចាស់ទើបពោលថា បទថា អភិនន្ទុំ សេចក្ដីថា អនុមោទនាផង ទទួលដោយសេចក្ដីរីករាយ

ផង ដូច្នេះ ។

ភិក្ខុទាំងឡាយនាំគ្នាអនុមោទនាសុភាសិត ដែលព្រះមាន-
ព្រះភាគត្រាស់ល្អហើយ ទទួលដោយសិរសា ពោលថា
សាធុ សាធុ ដូច្នេះឯង ។

បទថា ឥមស្មឹ ច បន វេយ្យាករណស្មឹ សេចក្ដីថា ព្រះសូត្រដែលមិនមានគាថាលាយ ។ ក៏ព្រះសូត្រនេះ ហៅថា វេយ្យាករណ៍ ព្រោះមិនមានគាថាលាយ ។

បទថា ទសសហស្សីលោកធាតុ សេចក្ដីថា លោកធាតុប្រមាណម៉ឺនចក្រវាឡ ។

បទថា អកម្បិត្ថ គប្បីជ្រាបថា មិនមែនបានញាប់ញ័រក្នុងកាលចប់ព្រះសូត្រតែម្យ៉ាងនោះទេ សេចក្ដីនេះ សមដូចដែលព្រះអានន្ទពោលទុកថា កាលកំពុងត្រាស់ ដូច្នោះ គប្បីជ្រាបថា កាលទ្រង់កំពុងសម្ដែងទម្លាយទិដ្ឋិ ៦២ បានកម្រើកញាប់ញ័រហើយក្នុងឋានៈ ៦២ ប្រការ គឺ កាលទេសនាទិដ្ឋិនោះៗ ចប់សព្វគ្រប់ ។

ក្នុងសេចក្ដីនោះ គប្បីជ្រាបផែនដីកម្រើកដោយហេតុ ៨ ប្រការ គឺ ៖

១. ធាតុកម្រើក

២. អានុភាពរបស់អ្នកមានឫទ្ធិ

៣. ព្រះពោធិសត្វឈានចុះកាន់ព្រះគភ៌

៤. ស្ដេចចេញចាកគភ៌ព្រះមាតា

៥. សម្រេចព្រះសម្ពោធិញ្ញាណ

៦. ទ្រង់សម្ដែងព្រះធម្មចក្ក

៧. ទ្រង់ដាក់ព្រះជន្មាយុសង្ខារ

៨. ស្ដេចរលត់ខន្ធបរិនិព្វាន

វិនិច្ឆ័យហេតុសម្បីទាំងនោះ ខ្ញុំនឹងពោលក្នុងគ្រាវណ្ណនាព្រះបាលីដែលមកក្នុងមហាបរិនិព្វានសូត្រយ៉ាងនេះថា ម្នាលអានន្ទ ឯហេតុបច្ច័យទាំង ៨ នេះឯង ដែលឲ្យកម្រើកផែនដី ។ ក៏ផែនដីដ៏ធំនេះ បានកម្រើកសម្បីក្នុងឋានៈ ៨ ដទៃ គឺ ៖

១. កាលស្ដេចមហាភិនេស្រ្កមណ៍

២. កាលស្ដេចចូលកាន់ពោធិមណ្ឌស្ថាន

៣. កាលទទួលសំពត់បង្សុកូល

៤. កាលបោកសំពត់បង្សុកូល

៥. កាលសម្ដែងកាឡាមសូត្រ

៦. កាលសម្ដែងគោតមកសូត្រ

៧. កាលសម្ដែងវេស្សន្តរជាតក

៨. កាលសម្ដែងព្រហ្មជាលសូត្រនេះ

ក្នុង ៨ យ៉ាងនោះ កាលស្ដេចមហាភិនេស្រ្កមណ៍ និងកាលស្ដេច

ចូលកាន់ពោធិមណ្ឌស្ថាន ផែនដីបានកម្រើក ដោយកម្លាំងនៃព្រះវីរិយៈ ។

កាលទទួលសំពត់បង្សុកូល ផែនដីត្រូវកម្លាំងសេចក្ដីអស្ចារ្យប៉ះខ្ទប់ហើយថា ព្រះមានព្រះភាគទ្រង់លះមហាទ្វីប ៤ ដែលមានទ្វីបពីរពាន់ជាបរិវារចេញព្រះផ្នួសទៅកាន់ព្រៃជាទីចោលសាកសព កាន់យកសំពត់បង្សុកូល ទ្រង់បានធ្វើកម្មដែលធ្វើបានលំបាក ដូច្នេះ បានកម្រើកហើយ កាលបោកសំពត់បង្សុកូល និងកាលសម្ដែងវេស្សន្តរជាតក ផែនដីបានកម្រើក ដោយការកម្រើកមិនមានកាល កាលសម្ដែងកាលាមសូត្រ និងកាលសម្ដែងគោតមកសូត្រ ផែនដីបានកម្រើកដោយភាពជាសក្ខីថា បពិត្រព្រះ-មានព្រះភាគ ខ្ញុំព្រះអង្គសូមជាសក្ខី តែកាលសម្ដែងព្រហ្មជាលសូត្រនេះ កាលទ្រង់ សម្ដែងទម្លាយទិដ្ឋិ ៦២ ប្រការហើយ គប្បីជ្រាបថា បានកម្រើកដោយអំណាចថ្វាយសាធុការ ។

មួយទៀត មិនមែនតែក្នុងឋានៈទាំងនេះតែម្យ៉ាងប៉ុណ្ណោះទេ ដែលផែនដីកម្រើក សេចក្ដីពិត ផែនដីកម្រើកហើយ សូម្បីក្នុងកាលសង្គាយនាទាំង ៣ កាល សូម្បីក្នុងថ្ងៃដែលព្រះមហិន្ទត្ថេរមកកាន់ទ្វីបនេះ សម្ដែងធម៌ក្នុងជាតិវ័ន និងកាលព្រះបិណ្ឌបាតិយត្ថេរ បោសសំអាតលានព្រះចេតិយក្នុងកល្យាណីវិហារ ហើយអង្គុយក្នុងលានព្រះចេតិយនោះឯង ញុំាងបីតិមានព្រះពុទ្ធជាអារម្មណ៍ ផ្ដើមសូត្រព្រះសូត្រនេះ វេលាចប់ព្រះសូត្រ ផែនដីបានកម្រើកទៅដល់ទឹកទ្រផែនដីជាទីបំផុត ។ មានស្ថានដែលឈ្មោះ

**អម្ពលដ្ឋិក** នៅផ្ទៃកទិសខាងកើតនៃលោហប្រាសាទ ព្រះថេរៈអ្នកពោលគម្ពីរទីឃនិកាយអង្គុយក្នុងស្ថានទីនោះ ផ្តើមសូត្រព្រហ្មជាលសូត្រ សូម្បីក្នុងវេលាដែលព្រះថេរៈទាំងនោះសូត្រចប់ ផែនដីក៏បានកម្រើកទៅដល់ទឹកទ្រផែនដីជាទីបំផុតដូចគ្នា ដូច្នេះឯង ។

ដោយអានុភាពនៃព្រះសូត្រដ៏ប្រសើរណា ដែលព្រះសយម្ភូទ្រង់បានសម្តែងហើយ ផែនដីបានកម្រើកច្រើនកាលយ៉ាងនេះ សូមបណ្ឌិតទាំងឡាយសិក្សាដោយគោរពនូវអត្ថធម៌របស់ព្រះសូត្រនោះ ដែលមានឈ្មោះថាព្រហ្មជាលសូត្រ ក្នុងព្រះសាសនានេះ ហើយបដិបត្តិដោយឧបាយនៃប្រាជ្ញាហោង ។

ចប់ការពណ៌នាព្រហ្មជាលសូត្រ សូត្រទី ១

# សាមញ្ញផលសូត្រ ទី ២

## រាជាមច្ចុកថា

[៩១] ព្រះបាលីក្នុងសាមញ្ញផលសូត្រថា ឯវម្មេ សុតំ ឯកំ សមយំ ភគវា រាជគហេ អម្ពវនេ មហតា ភិក្ខុសង្ឃេន ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ មានការពណ៌នាតាមលំដាប់ដូចតទៅនេះ ៖

បទថា រាជគហេ ទៀបក្រុងរាជគ្រឹះ សេចក្តីថា ក្នុងព្រះនគរដែលមានឈ្មោះយ៉ាងនោះ ពិតហើយ ព្រះនគរនោះ ហៅថា រាជគ្រឹះ ព្រោះព្រះបាទមន្ធាតុរាជ និងមហាគោវិន្ទព្រាហ្មណ៍ជាដើម គ្រប់គ្រង ។

ក៏ក្នុងពាក្យថា រាជគ្រឹះនេះមានអ្នកប្រាជ្ញដទៃៗ ពណ៌នាទុកច្រើនណាស់ នឹងមានប្រយោជន៍អ្វី ដោយពាក្យទាំងនោះ ព្រោះពាក្យនោះត្រឹមតែជាឈ្មោះរបស់ក្រុងប៉ុណ្ណោះ ។

ព្រះនគររាជគ្រឹះនេះ ជាក្រុងទាំងក្នុងពុទ្ធកាល ទាំងក្នុងចក្រពត្តិកាល ចំណែកក្នុងកាលដ៏សេស ជាក្រុងទំនេរគ្រប់គ្រងដោយពួកយក្សជាព្រៃទីនៅអាស្រ័យរបស់យក្ខទាំងនោះ ។

ពាក្យថា វិហរតិ ទ្រង់គង់នៅនេះ តាមធម្មតា ជាពាក្យសម្តែងដល់សេចក្តីព្រមព្រៀង ដោយវិហារធម៌យ៉ាងណាមួយ បណ្តាឥរិយាបថ-

វិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ។

តែក្នុងទីនេះ សម្តែងដល់ការឈរ ដើរ អង្គុយ ដេក ដែលជាឥរិយាបថដែលផ្លាស់ប្តូរគ្នាប៉ុណ្ណោះ ដូច្នោះ ព្រះមានព្រះភាគ នឹងទ្រង់ឈរក៏ដោយ ទ្រង់យាងទៅក៏ដោយ គង់ក៏ដោយ ផ្ទំក៏ដោយ គប្បីជ្រាបថា ទ្រង់គង់ប្រថាប់នៅទាំងអស់នោះឯង ។ សេចក្តីថា ព្រះអង្គទ្រង់បំបាត់សេចក្តីលំបាកនៃឥរិយាបថមួយ ដោយឥរិយាបថមួយ ទ្រង់រក្សាអត្តភាពមិនឲ្យទ្រង់លំបាកព្រះវរកាយ ដូច្នោះ ទើបហៅថា វិហរតិ ទ្រង់គង់ប្រថាប់នៅ ។

ពាក្យថា ជីវកស្ស កោមារភច្ចស្ស អម្ពវនេ នេះ ជាពាក្យសម្តែងកន្លែងស្នាក់នៅជិតក្រុងរាជគ្រឹះនោះ ល្មមដែលនឹងចូលទៅអាស្រ័យបិណ្ឌបាតបាន ព្រោះដូច្នោះ ក្នុងសេចក្តីនេះគប្បីជ្រាបសេចក្តីយ៉ាងនេះថា ពាក្យថា រាជគហេ វិហរតិ ជីវកស្ស កោមារភច្ចស្ស អម្ពវនេ សេចក្តីថា ប្រថាប់នៅក្នុងសួនអម្ពវ័នរបស់ពេទ្យជីវកកោមារភត្ត ក្រុងរាជគ្រឹះ ព្រោះពាក្យនេះជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត , ទៀប ។

ក្នុងព្រះបាលីនោះ ដែលឈ្មោះថា **ជីវក** ដោយអត្ថថា នៅរស់ ដែលឈ្មោះថា **កោមារភត្ត** ដោយអត្ថថា ព្រះរាជកុមារទ្រង់ចិញ្ចឹម ។

ដូចបានឮមកថា ព្រះអភ័យរាជកុមារ ស្តេចទៅជួបទារក ក៏ត្រាស់សួរថា "អ្វីនុ៎ះនាយ ដែលហ្វូងក្អែកកំពុងចោមរោម" ទូលថា

"ទារកព្រះអង្គ" "នៅរស់ឬ" "នៅរស់ព្រះអង្គ" "បើយ៉ាងនោះ ចូរនាំទារកនោះចូលទៅខាងក្នុងនគរ ហើយប្រគល់ឲ្យមេដោះទាំងឡាយចិញ្ចឹមរក្សា" ។

មនុស្សទាំងឡាយ ទើបបានដាក់ឈ្មោះទារកនោះថា **ជីវក** ព្រោះនៅរស់ និងតាំងឈ្មោះថា កោមារភច្ច ព្រោះព្រះរាជកុមារទ្រង់ចិញ្ចឹម ។

នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ចំណែកសេចក្តីពិស្តារ រឿងពេទ្យជីវក មានមកហើយក្នុងចីវរក្ខន្ធកៈនុ៎ះឯង សូម្បីកថាដែលវិនិច្ឆ័យរឿងពេទ្យជីវកនេះ ក៏បានពោលទុក អដ្ឋកថាវិន័យឈ្មោះ សមន្តប្បាសាទិកា ។

ក៏ពេទ្យជីវកនេះ សម័យមួយ ធ្វើឲ្យព្រះវរកាយរបស់ព្រះមានព្រះភាគ ដែលស្រពាប់ស្រពោនដោយរោគ ឲ្យសះស្បើយជាប្រក្រតីហើយ ថ្វាយសំពត់មួយគូ ដែលត្បាញអំពីដែនសិវី ព្រះពុទ្ធអង្គទ្រង់អនុមោទនា ពេលអនុមោទនាការថ្វាយសំពត់ចប់ហើយ ពេទ្យជីវកបានតាំងនៅក្នុងសោតាបត្តិផល ទើបគិតថា យើងគួរនឹងទៅគាល់បំរើព្រះពុទ្ធ មួយថ្ងៃ ២-៣ ដង ។ ក៏ភ្នំគិជ្ឈកូដនេះ និងព្រះវិហារវេឡុវ័ននៅឆ្ងាយហួសប្រមាណ ។ តែសួនអម្ពវ័នរបស់យើងនៅជិតផង បើដូច្នោះ យើងនឹងសាងវិហារថ្វាយចំពោះព្រះមានព្រះភាគ ក្នុងសួនអម្ពវ័នរបស់យើងនេះ ។ ពេទ្យជីវកនោះ ទើបសាងទីនៅពេលយប់ ទីនៅពេលថ្ងៃ ទីសម្រាក កុដិ

និងមណ្ឌបជាដើម ហើយឲ្យសាងព្រះគន្ធកុដិ ដែលសមគួរដល់ព្រះមាន-ព្រះភាគ ក្នុងសួនអម្ពវ័ននោះ ឲ្យសាងកំពែង មានពណ៌ដូចសំពត់ក្រហម កំពស់ ១៨ ហត្ថ ហោមព័ទ្ធសួនអម្ពវ័ន ទំនុកបម្រុងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយចីវរ និងភត្តាហារ បានស្រោចទឹកទក្ខិណោទក វេរថ្វាយសួនអម្ពវ័នជាព្រះវិហារ ។

ពាក្យថា ជីវកស្ស កោមារភច្ចស្ស អម្ពវនេ នោះ លោកពោលសំដៅយកព្រះវិហារ ដូចពោលមកនោះ ។

បទថា **រាជា** ក្នុងបទទាំងឡាយ មានបទថា **រាជា** ជាដើម សេចក្តីថា ឈ្មោះថា **រាជា** ដោយអត្ថថា ធ្វើមហាជនឲ្យត្រេកអរ ឬឲ្យចម្រើនដោយឥស្សរិយសម្បត្តិរបស់ខ្លួន ឬដោយសង្គហវត្ថុ ៤ ប្រការ ។

ឈ្មោះថា មាគធោ ដោយអត្ថថា ជាធំលើអ្នកដែនមគធៈទាំងឡាយ ។

ឈ្មោះថា **អជាតសត្តុ** ដោយអត្ថថា នេមិត្តកាចារ្យទាំងឡាយទាយប្រាប់ទុកថា មិនទាន់កើតក៏នឹងជាសត្រូវដល់ព្រះរាជា ។

បានឮថា កាលព្រះបាទអជាតសត្តុ នៅក្នុងព្រះគភ៌ ព្រះទេវីកើតការចាញ់គភ៌ដល់កម្រិតយ៉ាងនេះថា "ឱហ្ន៎ យើងគប្បីបានផឹកលោហិតព្រះពាហាខាងស្តាំរបស់ព្រះរាជា" ។ ព្រះនាងមានព្រះតម្រិះថា ការចាញ់គភ៌កើតឡើងក្នុងឋានៈដ៏ធ្ងន់ មិនអាចប្រាប់ឲ្យអ្នកណាដឹងបាន កាលមិន

អាចប្រាប់បាន ទើបស្គមស្គាំងពណ៌សម្បុរស្រអាប់ចុះ ។ ព្រះរាជាត្រាស់សួរព្រះនាងថា "នៃនាងដ៏ចម្រើន រាងកាយរបស់នាងមានពណ៌សម្បុរមិនប្រក្រតី មានហេតុអ្វីឬ ។" ទូលថា "មេត្តាកុំសួរឡើយ ក្រាបទូល ។" ទទួលបង្គាប់ថា "នៃព្រះនាង កាលមិនអាចប្រាប់សេចក្ដីប្រាថ្នារបស់ព្រះនាងដល់ខ្ញុំ ព្រះនាងនឹងប្រាប់ដល់អ្នកណា" ដូច្នេះ ទ្រង់សួរដេញដោលដោយប្រការនោះៗ ឲ្យព្រះនាងប្រាប់ទាល់តែបាន លុះទ្រង់បានជ្រាបប៉ុណ្ណោះ ក៏ត្រាស់ថា "ព្រះនាងនេះល្ងង់ ក្នុងរឿងនេះ នាងមានសញ្ញាធ្ងន់ក្រាស់ មិនមែនឬ" ដូច្នោះ ទើបបង្គាប់ឲ្យហៅពេទ្យមកឲ្យយកកាំបិតមាសវះព្រះពាហា ហើយត្រងព្រះលោហិតដោយពែងមាសលាយដោយទឹក ហើយឲ្យព្រះនាងសោយ ។

នេមិត្តកាចារ្យទាំងឡាយបានជ្រាបដំណឹងដូច្នោះ នាំគ្នាព្យាករណ៍ថា "ព្រះឱរសក្នុងគភ៌អគ្គនេះ នឹងជាសត្រូវដល់ព្រះរាជា ព្រះរាជានឹងត្រូវព្រះឱរសអគ្គនេះជាក់ព្រះជន្ម" ។

ព្រះទេវីទ្រង់ស្ដាប់ដំណឹងដូច្នោះ មានព្រះតម្រិះថា "ព្រះឱរសដែលចេញចាកផ្ទៃរបស់យើងនឹងសម្លាប់ព្រះរាជា" ទើបមានព្រះបំណងនឹងទម្លាយគភ៌ឲ្យធ្លាក់ទៅ ស្ដេចទៅព្រះរាជឧទ្យានឲ្យប្របាច់ព្រះគភ៌ តែព្រះគភ៌ក៏មិនធ្លាក់សោះ , ព្រះនាងស្ដេចទៅឲ្យធ្វើយ៉ាងនោះរឿយៗ ។ ព្រះរាជាតាមដានមើលថា ព្រះទេវីនេះទៅព្រះរាជឧទ្យានរឿយៗ ដើម្បីអ្វី

ទ្រង់ជ្រាបហេតុនោះហើយ ទើបទ្រង់ហាមថា "ព្រះនាង ក្មេងក្នុងផ្ទៃរបស់ព្រះនាងនៅមិនទាន់ដឹងថា ជាប្រុស ឬស្រីឡើយ ព្រះនាងក៏ធ្វើយ៉ាងនេះចំពោះទារកដែលកើតដល់ខ្លួនចេញហើយ ទោសដ៏ធំរបស់យើងដូចពោលនេះនឹងខ្ចរខ្ចាយទៅទូទាំងជម្ពូទ្វីប សូមព្រះនាងចូរកុំធ្វើយ៉ាងនេះទៀតឡើយ" ហើយបានប្រទានការរក្សា ។ ព្រះនាងបានគិតទុកថា វេលាប្រសូតនឹងសម្លាប់ចោល ។ សូម្បីក្នុងវេលាដែលប្រសូតនោះ ពួកមនុស្សដែលរក្សា ក៏បាននាំព្រះកុមារចេញទៅ ។ សម័យតមក ព្រះកុមារចម្រើនវ័យហើយ ទើបនាំមកបង្ហាញដល់ព្រះទេវី ។ លុះទតឃើញព្រះកុមារហើយព្រះនាងក៏កើតសេចក្តីស្រឡាញ់ព្រះឱរស ។ ដូច្នោះ ទើបមិនអាចសម្លាប់ព្រះកុមារនោះបាន ។ លំដាប់តមក សូម្បីព្រះរាជា ក៏បានព្រះរាជទានតំណែងឧបរាជដល់ព្រះឱរស ។

សម័យតមក ព្រះទេវទត្តនៅក្នុងទីស្ងាត់គិតថា ព្រះសារីបុត្រក៏មានបរិស័ទច្រើន ព្រះមោគ្គល្លានក៏មានបរិស័ទច្រើន ព្រះមហាកស្សបៈក៏មានបរិស័ទច្រើន លោកទាំងនេះមានធុរៈផ្សេងៗ គ្នាយ៉ាងនេះ ដូច្នេះសូម្បីយើងក៏នឹងសម្តែងធុរៈត្រឹមតែមួយយ៉ាង ។ ព្រះទេវទត្តនោះ កាលមិនមានលាភ ក៏មិនអាចធ្វើបរិស័ទឲ្យកើតឡើងបាន ទើបគិតថា "ណ្ហើយ! យើងនឹងធ្វើលាភឲ្យកើតឡើង" ទើបប្រើឥទ្ធិបាដិហារ្យធ្វើឲ្យអជាតសត្តុរាជកុមារជ្រះថ្លា តាមន័យដែលមកក្នុងខន្ធកៈ លុះដឹងថា ព្រះកុមារ

អជាតសត្តុ ជ្រះថ្លាជិតជិតក្រៃលែង រហូតដល់មកកាន់ទីបម្រុងរបស់ខ្លួន ទាំងព្រឹកល្ងាចព្រមដោយបរិវារពេញរថ ៥០០ ថ្ងៃមួយទើបចូលទៅរក ពោលថា "ម្នាលកុមារ កាលមុនពួកមនុស្សមានអាយុយឺនយូរ តែឥឡូវ នេះមានអាយុតិច ម្នាលកុមារបើយ៉ាងនោះ ព្រះរាជកុមារចូរដាក់ព្រះជន្ម ព្រះបិតាចេញ ហើយធ្វើព្រះរាជា ។ អាត្មាភាពនឹងដាក់ព្រះជន្មព្រះមាន-ព្រះភាគហើយ នឹងធ្វើជាព្រះពុទ្ធ" ហើយបញ្ជូនព្រះកុមារទៅដាក់ព្រះជន្ម ព្រះបិតា ។ ព្រះកុមារអជាតសត្តុនោះ វង្វេងជឿថា "លោកម្ចាស់ ទេវទត្តមានអានុភាពច្រើន វត្ថុដែលព្រះទេវទត្តមិនដឹងច្បាស់មិនមាន" ទើបសៀតកាំបិតមុខស្រួច (ព្រះខាន់) ត្រង់ព្រះឧរុ ប្រាថ្នានឹងសម្លាប់ ពេលថ្ងៃក្តៅថែស មានសេចក្តីភ័យខ្លាចស្ងន់ស្ញោ តក់ស្លុតក្លាក់ផ្អើល ចូលទៅខាងក្នុងព្រះរាជស្ថាន ធ្វើអាការប្លែកៗ មានប្រការដូចពោល ហើយ ។ កាលនោះ ពួកអាមាត្យចាប់អជាតសត្តុរាជកុមារបាន បញ្ជូន មកប្រឹក្សាទោសថា ព្រះកុមារនឹងត្រូវប្រហារ ព្រះទេវទត្តនឹងត្រូវប្រហារ និងភិក្ខុពួកព្រះទេវទត្តទាំងអស់នឹងត្រូវប្រហារ ហើយក្រាបទូលព្រះរាជា ថា ពួកខ្ញុំព្រះអង្គនឹងធ្វើតាមព្រះរាជអាជ្ញា ។ ព្រះរាជាទ្រង់ទម្លាក់ តំណែងរបស់ពួកអាមាត្យដែលប្រាថ្នាដាក់ទោសប្រហារ ទ្រង់តាំងពួក អាមាត្យដែលមិនត្រូវការឲ្យដាក់ទោសប្រហារទុកក្នុងតំណែងខ្ពស់ៗ ហើយ ត្រាស់សួរព្រះកុមារថា "កូនត្រូវការនឹងសម្លាប់បិតាដើម្បីអ្វី" ។ ព្រះ-

កុមារក្រាបទូលថា "ខ្ញុំម្ចាស់ត្រូវការរាជសម្បត្តិ ក្រាបទូល" ។ ព្រះរាជាបានព្រះរាជទានរាជសម្បត្តិដល់ព្រះឱរសនោះ ។

អជាតសត្តុរាជកុមារ ប្រាប់ដល់ព្រះទេវទត្តថា "សេចក្ដីប្រាថ្នារបស់យើងសម្រេចហើយ" ។ លំដាប់នោះ ព្រះទេវទត្តពោលនឹងព្រះកុមារថា "ព្រះអង្គដូចអ្នកយកចចកទុកខាងក្នុងស្គរ ដណ្ដប់ស្បែក ហើយសម្គាល់ថា ធ្វើកិច្ចសម្រេចរៀបរយហើយ ពីរបីថ្ងៃទៀត ព្រះបិតារបស់ព្រះអង្គទ្រង់គិតថា ព្រះអង្គធ្វើការមើលងាយ ហើយក៏នឹងជាព្រះរាជាដោយខ្លួនឯង" ។ ព្រះកុមារសួរថា "បើយ៉ាងនោះ ខ្ញុំនឹងធ្វើយ៉ាងណា" ។ ព្រះទេវទត្តឆ្លើយថា "ចូរសម្លាប់ផ្ដាច់ទាំងឫសតែម្ដង" ។ ព្រះកុមារត្រាស់ថា "ព្រះបិតារបស់ខ្ញុំមិនគួរសម្លាប់ដោយសស្ត្រាមិនមែនឬ" ។ ព្រះទេវទត្តទើបពោលថា "ចូរសម្លាប់ព្រះអង្គ ដោយការកាត់ព្រះក្រយាហារ" ។ ព្រះកុមារ ទើបបង្គាប់ឲ្យយកព្រះបិតាដាក់ចូលក្នុងគុកអប់ ។ ដែលឈ្មោះថា គុកអប់ គឺ គុកមានផ្សែងដែលធ្វើទុកដើម្បីដាក់ទោសដល់អ្នកទោស ។ ព្រះកុមារបង្គាប់ទុកថា "ក្រៅពីព្រះមាតារបស់យើងហើយ កុំឲ្យអ្នកដទៃសួរសុខទុក្ខ" ។

ព្រះទេវី ទ្រង់ដាក់កត្តាហារក្នុងផ្ដិលមាស ហើយវេចដាយសំពត់ស្បៀតចូលសួរសុខទុក្ខព្រះរាជា ។ ព្រះរាជាសោយកត្តាហារនោះ ទើបមានព្រះជន្មនៅបាន ។ ព្រះកុមារត្រាស់សួរថា ព្រះបិតារបស់យើងនៅ

មានព្រះជន្មបានយ៉ាងណា ។ កាលទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ត្រាស់បង្គាប់ហាម មិនឲ្យព្រះមាតានាំវត្ថុដាក់ជាយសំពត់ស្បៀតចូលសួរសុខទុក្ខ ។

តាំងពីនោះ ព្រះទេវីក៏ដាក់ភត្តាហារទុកក្នុងព្រះមោលី ចូលសួរសុខទុក្ខ ។ ព្រះកុមារទ្រង់ជ្រាបសូម្បីដូច្នោះ បង្គាប់ហាមមិនឲ្យព្រះមាតាបួងព្រះមោលី (ផ្នួងសក់) ចូលសួរសុខទុក្ខ ។

លំដាប់នោះ ព្រះទេវីទ្រង់ដាក់ភត្តាហារទុកក្នុងទ្រនាប់ព្រះបាទមាសបិទល្អហើយ ទ្រង់ពាក់ទ្រនាប់ព្រះបាទមាសចូលសួរសុខទុក្ខ ។ ព្រះរាជានៅមានព្រះជន្មដោយភត្តាហារនោះ ។ ព្រះកុមារត្រាស់សួរទៀតថា ព្រះបិតានៅមានព្រះជន្មបានយ៉ាងណា កាលទ្រង់ជ្រាបសេចក្ដីនោះ ត្រាស់បង្គាប់ ហាមមិនឲ្យសូម្បីតែទ្រង់ពាក់ទ្រនាប់ព្រះបាទចូលសួរសុខទុក្ខ ។

តាំងពីនោះព្រះទេវី ក៏ទ្រង់ស្រោចស្រប់ព្រះវរកាយដោយទឹកក្រអូបហើយលាបព្រះវរកាយដោយអាហារមានរសឆ្ងាញ់ ៤ យ៉ាង ហើយទ្រង់ដណ្ដប់ព្រះភូសាចូលសួរសុខទុក្ខ ។ ព្រះរាជាទ្រង់លិទ្ធព្រះវរកាយរបស់ព្រះទេវីទ្រទ្រង់ព្រះជន្មនៅបាន ។ ព្រះកុមារត្រាស់សួរទៀត កាលទ្រង់ជ្រាបដូច្នោះហើយ ទើបត្រាស់បង្គាប់ថា តាំងពីនេះទៅ ហាមព្រះមាតាចូលសួរសុខទុក្ខ ។

តតពីនោះ ព្រះទេវីប្រថាប់ឈរទៀបទ្វារ ទ្រង់កន្ទ្រងទូញយំថា

"បពិត្រព្រះស្វាមីពិម្ពិសារ វេលាដែលគេនេះជាក្មេង ព្រះអង្គក៏មិនឲ្យឱកាសសម្លាប់គេ ទ្រង់ចិញ្ចឹមសត្រូវរបស់ព្រះអង្គទុកដោយព្រះអង្គឯងពិតៗ ឥឡូវនេះ ការឃើញព្រះអង្គលើកនេះ ជាលើកចុងក្រោយបង្អស់ តពីនេះទៅខ្ញុំព្រះអង្គនឹងមិនបានឃើញព្រះអង្គទៀតឡើយ បើទោសរបស់ខ្ញុំម្ចាស់មាននៅ សូមបានមេត្តាព្រះរាជទានអភ័យទោសផងចុះព្រះអង្គ" ហើយក៏ស្តេចត្រឡប់ ។ តាំងពីនោះមកព្រះរាជាក៏មិនមានព្រះក្រយាហារ នៅមានព្រះជន្មដោយសេចក្តីសុខប្រកបដោយមគ្គផល (ទ្រង់ជាព្រះសោតា-បន្ន) ដោយវិធីដើរចង្ក្រម ព្រះវរកាយរបស់ព្រះអង្គក៏ស្រស់បស់ក្រៃលែងឡើង ។

ព្រះកុមារត្រាស់សួរថា "នែនាយ ព្រះបិតារបស់យើងនៅមានព្រះជន្មបានយ៉ាងណា" កាលទ្រង់ជ្រាបថា "នៅមានព្រះជន្មបានដោយវិធីដើរចង្ក្រម ថែមទាំងមានព្រះវរកាយនៅស្រស់បស់ក្រៃលែងឡើងទៀត" ទើបទ្រង់ត្រិះរិះថា "យើងនឹងកាត់មិនឲ្យព្រះបិតាដើរចង្ក្រម បានក្នុងកាលឥឡូវនេះ" ទ្រង់បង្គាប់ជាងកោរកាត់ទាំងឡាយថា "ពួកលោកចូរយកកាំបិតកោរវះព្រះបាទទាំង ២ របស់ព្រះបិតារបស់យើង ហើយយកប្រេងផ្សំជាមួយអំបិលលាប ហើយចូររោលដោយរងើកភ្លើងគគី ដែលឆេះភ្លើងគគុកមិនមានអណ្តាតឡើយ" ហើយបញ្ជូនទៅ ។ ព្រះរាជាទតឃើញពួកជាងកោរកាត់ ទ្រង់ត្រិះរិះថា "កូនរបស់យើង គង់នឹងមានអ្នក

ណាជាស់តឿនឲ្យពួកជីវូនពិតហើយ ជាងកោរកាត់ទាំងនេះគង់នឹងមក កោរពុកមាត់របស់យើង" ។

ជាងកោរកាត់ទាំងនោះ ទៅថ្វាយបង្គំហើយឈរ កាលត្រូវត្រាស់សួរថា "មកហេតុដូចម្តេច" ទើបក្រាបទូលឲ្យទ្រង់ជ្រាប ព្រះរាជាពិម្ពិសារទើបត្រាស់ថា "ពួកអ្នកឯងចូរធ្វើតាមចិត្តព្រះរាជារបស់អ្នកឯងចុះ" ពួកជាងកោរកាត់ទើបក្រាបទូលថា "ប្រថាប់ចុះព្រះអង្គ" ថ្វាយបង្គំព្រះបាទពិម្ពិសារ ហើយក្រាបទូលថា "បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គចាំបាច់ត្រូវធ្វើតាមព្រះរាជឱង្ការ សូមព្រះអង្គកុំទ្រង់ពិរោធនឹងពួកខ្ញុំព្រះអង្គឡើយ ការធ្វើដូច្នេះ មិនសមគួរដល់ព្រះរាជាអ្នកទ្រទ្រង់ធម៌ដូចព្រះអង្គ" ហើយចាប់កព្រះបាទដោយដៃឆ្វេង ប្រើដៃស្តាំកាន់កាំបិតកោរវះផ្ទៃព្រះបាទទាំង ២ ខាង យកប្រេងផ្សំអំបិលលាប ហើយអាំងដោយរងើកភ្លើងឈើគគីដែលកំពុងឆេះគគុកមិនមានអណ្តាតឡើយ ។

បានឮមកថា ក្នុងកាលមុន ព្រះរាជាពិម្ពិសារទ្រង់បានពាក់ស្បែកព្រះបាទចូលទៅក្នុងលានព្រះចេតិយ និងយកព្រះបាទដែលមិនបានជម្រះជាន់កន្ទេលកក់ ដែលគេក្រាលទុកសម្រាប់អង្គុយ នេះជាផលរបស់បាបនោះ ។

ព្រះរាជាពិម្ពិសារ ទ្រង់កើតទុក្ខវេទនាយ៉ាងខ្លាំងក្លា ទ្រង់រំលឹកថា អហោ ពុទ្ធោ អហោ ធម្មោ អហោ សង្ឃោ ឱហ្ន៎ ព្រះពុទ្ធ , ឱហ្ន៎

ព្រះធម៌ , ឱហ្ន៍ ព្រះសង្ឃ ប៉ុណ្ណោះ ទ្រង់ស្ថិតស្រពោនក្រៀមទៅ ដូចកម្រងផ្កាឈើដែលគេដាក់ទុកក្នុងលានព្រះចេតិយ កើតជាយក្ខឈ្មោះ **ជនវសភៈ** ជាអ្នកនៅបម្រើរបស់ស្តេចវេស្សវ័ណ ក្នុងទេវលោកជាន់ចាតុម្មហារាជ ។

និងក្នុងថ្ងៃនោះឯង ព្រះឱរសរបស់ព្រះបាទអជាតសត្តុក៏ប្រសូតិ ។ សំបុត្រ ២ ច្បាប់ គឺ ដំណឹងព្រះឱរសប្រសូតិមួយច្បាប់ ដំណឹងព្រះបិតាសុគតមួយច្បាប់ មកដល់ក្នុងខណៈតែមួយ ។

ពួកអាមាត្យប្រឹក្សាគ្នាថា ពួកយើងនឹងទូលដំណឹងព្រះឱរសប្រសូតមុន ទើបយកសំបុត្រដំណឹងប្រសូតិនោះ តម្កល់ថ្វាយក្នុងព្រះហស្តរបស់ព្រះបាទអជាតសត្តុ ។ សេចក្តីស្រឡាញ់កូនកើតឡើងដល់ព្រះអង្គ ក្នុងខណៈនោះក្លាម ផ្សព្វផ្សាយទៅពេញទាំងព្រះវរកាយ ផ្សាយទៅរហូតខួរក្នុងឆ្អឹង ។ ក្នុងខណៈនោះ ព្រះអង្គបានដឹងខ្លួនរឭកដល់គុណរបស់ព្រះបិតាថា សូម្បីកាលយើងកើត ព្រះបិតារបស់យើងក៏គង់កើតសេចក្តីស្រឡាញ់យ៉ាងនេះដូចគ្នា ។ ទើបប្រញាប់បង្គាប់ថា "នែនាយ ចូរទៅលែងព្រះបិតារបស់យើង" ។ ពួកអាមាត្យទូលថា "ព្រះអង្គ បង្គាប់ឲ្យលែងអ្វី ក្រាបទូល" ហើយថ្វាយសំបុត្រមួយច្បាប់ទៀតលើព្រះហស្ត ។ លុះទ្រង់ជ្រាបការប្រព្រឹត្តទៅដូច្នោះ ព្រះបាទអជាតសត្តុទ្រង់កន្សែង ស្តេចទៅគាល់ព្រះមាតា ទូលថា "បពិត្រ ព្រះមាតា កាលទូលបង្គំកើត ព្រះបិតា

របស់ទូលបង្គំកើតសេចក្តីស្រឡាញ់ ទូលបង្គំឬហ្ន៎” ព្រះនាងវេទេហីមានព្រះសវនីយ៍ថា “កូនល្ងង់ អ្នកឯងនិយាយអ្វី វេលាដែលកូននៅតូច កើតបូសត្រង់ម្រាមដៃ កាលនោះ ពួកមេដោះទាំងឡាយមិនអាចធ្វើឲ្យកូនដែលកំពុងស្រែកយំឈប់ស្រែកបាន ទើបនាំកូនទៅគាល់ស្តេចបិតារបស់កូន ដែលប្រថាប់នៅក្នុងសាលាស្តេច បិតារបស់កូនបានជញ្ជក់ម្រាមដៃរបស់កូនដរាបបូសបែកក្នុងព្រះឱស្ឋនោះឯង កាលនោះព្រះបិតារបស់កូនទ្រង់មិនបានក្រោកពីទីប្រថាប់ ទ្រង់លេបខ្ទុះលាយនឹងលោហិតនោ ដោយសេចក្តីស្រឡាញ់កូន ព្រះបិតារបស់កូន មានសេចក្តីស្រឡាញ់កូន យ៉ាងនេះ” ។ ព្រះបាទអជាតសត្តុទ្រង់កន្ទ្រងទ្រួញយំ បានថ្វាយភ្លើងព្រះសាកសពព្រះបិតា ។

ចំណែកព្រះទេវទត្ត ចូលគាល់ព្រះបាទអជាតសត្តុទូលថា “មហាបពិត្រ ព្រះអង្គចូរបង្គាប់មនុស្ស ដែលនឹងផ្តាច់ជីវិតព្រះសមណគោតម” ហើយបញ្ជូនមនុស្សទាំងឡាយ ដែលព្រះបាទអជាតសត្តុព្រះរាជទាន ខ្លួនឯងឡើងភ្នំគិជ្ឈកូដ ប្រមៀលសិលា ហើយឲ្យលែងដំរីនាឡាគិរី ដោយឧបាយមិនថា យ៉ាងណាមួយ ក៏មិនអាចផ្តាច់ព្រះជន្មព្រះមានព្រះភាគបាន ក៏សាបសូន្យលាភសក្ការៈ ទើបសូមវត្ថុ ៥ ប្រការ កាលមិនបានវត្ថុ ៥ ប្រការនោះ ក៏ប្រកាសថា “បើយ៉ាងនោះ នឹងឲ្យមហាជនយល់រឿងរហូតអស់ជានិច្ច” ទើបធ្វើសង្ឃភេទ កាលព្រះសារីបុត្រ និងព្រះមោគ្គលាន

នាំបរិស័ទត្រឡប់វិញបាន ទើបក្អួតឈាមចេញក្តៅៗ ដេកនៅលើគ្រែអ្នកជម្ងឺ ៩ ខែ ក្តៅក្រហាយចិត្ត សួរថា "ឥឡូវនេះ ព្រះសាស្តាប្រថាប់នៅទីណា" កាលបានដឹងថា "ទ្រង់នៅក្នុងវត្តជេតពន" ទើបពោលថា "ពួកលោកចូរយកគ្រែ សែងយើងទៅគាល់ព្រះសាស្តា" កាលគេសែងមក ព្រោះមិនបានធ្វើកម្មដែលគួរនឹងបានគាល់ព្រះមានព្រះភាគ ទើបត្រូវផែនដីស្រូបនៅទីជិតស្រះបោក្ខរណីក្នុងព្រះជេតពនទុំះឯង ធ្លាក់ទៅក្នុងមហា-នរក ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ឯន័យនៃរឿងយ៉ាងពិស្តារមកក្នុងសង្ឃភេទក្ខន្ធកវិន័យហើយ ។ ក៏ព្រោះរឿងនេះមកក្នុងខន្ធកវិន័យហើយ ទើបមិនបានពោលទាំងអស់ ដោយប្រការដូច្នេះ ។

ព្រះកុមារនេះពេលកើតមក ក៏នឹងជាសត្រូវដល់ព្រះរាជា ពួកនេមិត្តកាចារ្យទាយទុកយ៉ាងនេះ ដូច្នោះ ទើបឈ្មោះថា អជាតសត្តុ ដោយប្រការដូច្នេះ ។

បទថា វេទេហិបុត្តោ រាជបុត្ររបស់ព្រះនាងវេទេហី សេចក្តីថា ព្រះកុមារនេះ ជាព្រះឱរសរបស់ព្រះធីតាព្រះបាទកោសល មិនមែនរបស់ព្រះបាទវិទេហរាជ ។

ក៏ពាក្យថា វេទេហី នេះ ជាឈ្មោះរបស់បណ្ឌិត ។ ដូចដែលពោលថា វេទេហិកា គហបតានី គហបតានី ជាបណ្ឌិត , អយ្យោ អានន្ទោ វេទេហមុនិ ព្រះអានន្ទជាម្ចាស់ ជាអ្នកប្រាជ្ញ ។

ក្នុងពាក្យថា វេទេហី នោះ មានអធិប្បាយចំពោះពាក្យដូចតទៅនេះ ឈ្មោះថា វេទៈ ដោយអត្ថថា ជាគ្រឿងដឹង ពាក្យថា វេទៈ នេះ ជាឈ្មោះនៃការដឹង ។

ឈ្មោះថា វេទេហី ដោយអត្ថថា ដំណើរការបន្តព្យាយាមដោយសេចក្តីដឹង ។ ឱរសរបស់ព្រះនាងវេទេហី ឈ្មោះថា វេទេហីបុត្រ ។

បទថា តទហុ ស្មើនឹងបទ តស្មិំ អហុ សេចក្តីថា ក្នុងថ្ងៃនោះ ។

ឈ្មោះថា **ឧបោសថ** ដោយអត្ថថា ថ្ងៃជាទីចូលទៅនៅ (សមាទានសីល) ។ អធិប្បាយថា ពាក្យថា ចូលទៅនៅសមាទានសីល គឺជាអ្នកចូលដល់ដោយសីល ឬដោយអាការដែលមិនខ្វល់ខ្វាយ ឈ្មោះថាជាអ្នកនៅរក្សាសីល ។

ក៏ក្នុងពាក្យថា **ឧបោសថ** នេះ មានការពង្រីកសេចក្តីដូចតទៅនេះ

ការសូត្របាតិមោក្ខ ឈ្មោះថា **ឧបោសថ** ដូចក្នុងបាលីមានជាដើមថា អាយាមាវុសោ កប្បិន ឧបោសថំ គមិស្សាម មកចុះ លោកម្ចាស់កប្បិន ពួកយើងនឹងទៅធ្វើឧបោសថរួមគ្នា ។

សីល ឈ្មោះថា **ឧបោសថ** ដូចក្នុងបាលីមានជាដើមថា ឯវំ អដ្ឋង្គសមន្នាគតោ ខោ វិសាខេ ឧបោសថោ ឧបវុត្ថោ ម្នាលនាងវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលគប្បីរក្សា ។ យ៉ាងនេះ ការរក្សាសីល ឈ្មោះថា **ឧបោសថ** ដូចក្នុងបាលីមានជាដើមថា សុទ្ធស្ស

វេ សទា ជគ្គុ សុទ្ធស្សុបោសថោ សទា ផគ្គុន ឫក្ស តែងមានសព្វ ៗ កាល ដល់បុគ្គលដែលបរិសុទ្ធ ឧបោសថតែងមានសព្វ ៗ កាល ដល់បុគ្គលដែលបរិសុទ្ធ ។

**បញ្ញត្តិ** ឈ្មោះថា **ឧបោសថ** ដូចក្នុងបាលីមានជាដើមថា ឧបោសថោ នាម នាគរាជា ស្តេចដំរី ឈ្មោះថា ឧបោសថ ។

ថ្ងៃដែលគប្បីរក្សាសីល ឈ្មោះថា **ឧបោសថ** ដូចក្នុងបាលីមានជាដើមថា ន ភិក្ខវេ តទហុបោសថេ សភិក្ខុកា អាវាសា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថនោះ ភិក្ខុមិនត្រូវចេញពីអាវាសដែលមានភិក្ខុ ហើយទៅកាន់អាវាសដែលគ្មានភិក្ខុឡើយ ។

សូម្បីក្នុងទីនេះ ក៏បំណងថ្ងៃដែលគប្បីរក្សាសីលនុ៎ះឯង ។ ក៏ថ្ងៃដែលរក្សាសីលនេះ មាន ៣ គឺ ថ្ងៃ ៨ ថ្ងៃ ១៤ ថ្ងៃ ១៥ ព្រោះដូច្នោះ ដែលពោលក្នុងបាលីថា ថ្ងៃ ១៥ ក៏ដើម្បីហាមថ្ងៃ ៨ និងថ្ងៃ ១៤ ទាំង ២ ថ្ងៃ ។ ដូច្នោះទើបពោលថា ឈ្មោះថា **ឧបោសថ** ដោយអត្ថថា ថ្ងៃជាទីចូលទៅនៅ (រក្សាសីល) ។

បទថា កោមុទិយា ជាកាលមានផ្កាកុមុទរីក សេចក្តីថា មានផ្កាកុមុទរីក ។ បានឮថា វេលានោះផ្កាកោមុទរីកពាសពេញ ។

ឈ្មោះថា កោមុទិ ដោយអត្ថថា ជារដូវមានផ្កាកោមុទ ។

បទថា ចាតុមាសិនិយា ជាទីបំផុតនៃខែ ៤ សេចក្តីថា ចុងបំផុត

នៃ ៤ ខែ ។

ពិតមែន ថ្ងៃឧបោសថនោះជាថ្ងៃចុងបំផុតនៃខែ ៤ ហេតុនោះ ទើបឈ្មោះថា ចាតុមាសី ។ តែក្នុងទីនេះលោកហៅថា ចាតុមាសិនី ។

ព្រោះហេតុដែលថា ថ្ងៃនោះល្មមល្អពេញខែ ពេញរដូវ ពេញឆ្នាំ បរិបូរណ៍ ទើបឈ្មោះថា បុណ្ណា ។

ស័ព្ទថា មា លោកហៅព្រះចន្ទ ។

ព្រះចន្ទពេញវង់ក្នុងថ្ងៃនោះ ហេតុនោះ ទើបឈ្មោះថា បុណ្ណមា ។

ក្នុងបទទាំង ២ គឺ បុណ្ណាយ ពេញបូណ៌មី និង បុណ្ណមាយ ព្រះចន្ទពេញវង់នេះ គប្បីជ្រាបសេចក្តីដូចពោលមកនេះ ។

បទថា រាជា អមច្ចបរិវុតោ មានរាជអាមាត្យចោមរោម សេចក្តីថា ព្រះរាជាហែហមដោយអាមាត្យទាំងឡាយ ក្នុងរាត្រីដ៏ស្ងាត់ស្ងៃ ទៅដោយពន្លឺចន្ទពេញវង់ដែលប្រាសចាកគ្រឿងសៅហ្មង ៤ ប្រការ ប្រដូចជាទិសាភាគ ដែលជម្រះលាងដោយធារទឹកដោះ មានពន្លឺប្រាក់ចេញជាចង្កោម និងដូចចង្កោមផ្កាកុមុទ ធ្វើដោយសំពត់សាច់ល្អពណ៌ស ហាក់បីដូចជាកួងកែវមុក្តា និងកម្រងផ្កាម្លិះ មានពន្លឺធ្លាត់ធ្លៃងខ្វះខ្វាយដូចវិមានប្រាក់បញ្ចេញរស្មី ។

បទថា ឧបរិបាសាទវរគតោ សេចក្តីថា ប្រថាប់នៅក្នុងមហាប្រាសាទជាន់លើ ។ ប្រថាប់លើព្រះរាជាសនៈមាស ខាងក្រោមមហា-

ស្វេតច្ឆត្រដែលលើកឡើងទុក ដែលគួរដល់ភាពជាធំក្រៃលែង ។

សួរថា ប្រថាប់ធ្វើអ្វី ?

ឆ្លើយថា ដើម្បីបន្ទោបង់ការលង់លក់ ។

ព្រះរាជាអង្គនេះឯង តាំងពីថ្ងៃដែលព្យាយាមផ្តាច់ព្រះជន្មព្រះបិតា លុះធ្លេចព្រះនេត្រទាំង ២ ចុះដោយតាំងព្រះទ័យថា នឹងលក់ ក៏តក់ស្លុតយ៉ាងខ្លាំងដូចត្រូវលំពែងទាំងរយចាក់ដោត ក៏ទ្រង់ភ្ញាក់ (មិនលក់ ព្រោះភ័យរន្ធត់ហួសប្រមាណ) ។ គ្រាពួកអាមាត្យទូលសួរថា "មានហេតុអ្វីក្រាបទូល" ព្រះអង្គក៏មិនបានត្រាស់អ្វីៗ ។ ព្រោះដូច្នោះ ការលក់ទើបមិនបានជាទីពេញព្រះទ័យរបស់ព្រះអង្គ ។ ដូច្នោះទើបប្រថាប់ដើម្បីបន្ទោបង់ការលក់ ។

មួយវិញទៀត ក្នុងថ្ងៃនោះមាននក្ខត្តឫក្សឱឡារិកគគ្រឹកគគ្រេង ។ ពេញព្រះនគរ នាំគ្នាបោសសម្អាតឲ្យរៀបរយ ។ យកខ្សាច់មករោយ ។ ទ្វារផ្ទះ ប្រដាប់ផ្កាឈើ ៥ ពណ៌ ។ លាជ និងឆ្នាំងដាក់ទឹកពេញ ។ គ្រប់ទិសាភាគ ចងទង់ជ័យ ទង់សំពត់ ។ ប្រដាប់ប្រទីបមាលា វិចិត្ររុងរឿង ។ មហាជននាំគ្នាលេងនក្ខត្តឫក្ស សប្បាយរីករាយតាមវិធីថ្នល់មានមុខរីកស្រស់គ្រប់គ្នា ។

អាចារ្យខ្លះលោកពោលថា ប្រថាប់ព្រោះជាថ្ងៃលេងនក្ខត្តឫក្ស ដូច្នេះក៏មាន ។ ក៏ឯគ្រាពោលយ៉ាងនេះហើយ ជាការធ្វើសន្និដ្ឋានថា នក្ខត្តឫក្ស

គ្រប់គ្រាជារបស់រាជត្រកូល តែព្រះរាជាអង្គនេះ ប្រថាប់ដើម្បីបន្ទោបង់ការលង់លក់ប៉ុណ្ណោះ ។

បទថា ឧទានំ ឧទានេសិ សេចក្ដីថា ទ្រង់ថ្លែងឧទាន ។

ប្រេងដែលហៀរពីគ្រឿងវាល់ដរាប មិនអាចវាល់បាន គេហៅថា ប្រេងហៀរហូរ យ៉ាងណា និងទឹកដែលលិចអណ្ដូងដរាបមិនអាចឃាត់ឃាំងឲ្យនៅបាន គេហៅថា អន្លង់ទឹកហៀរហូរ យ៉ាងណា ពាក្យបីតិដែលជ្រួតជ្រាបក្នុងចិត្តដរាបមិនអាចរក្សាទុកបាន តាំងនៅខាងក្នុងចិត្តមិនបានហៀរចេញមកខាងក្រៅនោះ ហៅថា **ឧទាន** ដូច្នោះ ។ ព្រះរាជាទ្រង់ថ្លែងពាក្យដែលសម្រេចដោយបីតិបែបដូច្នេះ ។

បទថា ទោសិនា សេចក្ដីថា ប្រាសចាកទោស ។ អធិប្បាយថា ប្រាសចាកគ្រឿងសៅហ្មង ៤ ប្រការទាំងនេះ គឺ អ័ព្ទ ទឹកសន្សើម ដុំផ្សែង និងរាហូ ។

រាត្រីនោះមានពាក្យសរសើរ ៥ ប្រការ មានជាទីគួររីករាយជាដើម ក៏រាត្រីនោះឈ្មោះថា រមណីយា ព្រោះអត្ថថា ធ្វើចិត្តរបស់មហាជនឲ្យត្រេកអរ ។

ឈ្មោះថា អភិរូចា ព្រោះអត្ថថា ល្អក្រៃលែងណាស់ ព្រោះភ្លឺដោយពន្លឺចន្ទដែលស្រឡះផុតពីទោសដូចពោលហើយ ។

ឈ្មោះថា ទស្សនីយា ព្រោះអត្ថថា គួរជាទីចង់មើល ។

ឈ្មោះថា ធាសាធិកា ព្រោះអត្ថថា ធ្វើចិត្តឲ្យថ្លាផូរផង់ ។

ឈ្មោះថា លក្ខញ្ញា ព្រោះអត្ថថា គួរដល់ និងកំណត់ថ្ងៃ និងខែជាដើម ។

បទថា កំ នុ ខ្វជ្ជ កាត់បទជា កំ នុ ខោ អជ្ជ ។

បទថា សមណំ វា ព្រាហ្មណំ វា សេចក្តីថា ឈ្មោះថា សមណៈ ព្រោះជាអ្នកស្ងប់បាប ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបណ្តេតបាប ។

បទថា យន្នោ បយិរុធាសតោ សេចក្តីថា ចិត្តរបស់យើងអ្នកចូលទៅរកសមណៈ ឬព្រាហ្មណ៍ដែលធ្លាត និយាយដើម្បីសួរបញ្ហាគប្បីជ្រះថ្លា ព្រោះបានស្តាប់ធម៌ដ៏ពីរោះ ។

ដោយព្រះតម្រាស់សូម្បីទាំងអស់នេះ ព្រះបាទអជាតសត្តុទ្រង់បានធ្វើពន្លឺភ្លឺឲ្យជានិមិត្ត ដោយប្រការដូច្នេះ ។ ទ្រង់ធ្វើដល់អ្នកណា ? ដល់ពេទ្យជីវក ។ ដើម្បីអ្វី ?

ដើម្បីគាល់ព្រះមានព្រះភាគ ។ ក៏ព្រះបាទអជាតសត្តុមិនអាចចូលគាល់ព្រះមានព្រះភាគដោយខ្លួនឯងបានឬ ? ត្រូវហើយ មិនអាច ។ ព្រោះហេតុអ្វី ? ព្រោះព្រះអង្គមានកំហុសច្រើន ។

ដោយថា ព្រះបាទអជាតសត្តុបានផ្តាច់ព្រះជន្មជីវិតព្រះបិតារបស់ព្រះអង្គអ្នកជាឧបដ្ឋាករបស់ព្រះមានព្រះភាគ និងជាអរិយសាវក និងព្រះទេវទត្ត ក៏បានអាស្រ័យព្រះបាទអជាតសត្តុនោះឯង ធ្វើសេចក្តីវិនាស

ធំដល់ព្រះមានព្រះភាគ ។ កំហុសទើបច្រើនដោយប្រការដូច្នេះ ។ ព្រោះព្រះអង្គមានកំហុសច្រើននោះ ទើបស្តេចមិនអាចទៅគាល់ដោយព្រះអង្គឯង ។ មួយទៀត ពេទ្យជីវក ក៏ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ។ ព្រះបាទអជាតសត្តុ ទើបបានទ្រង់ធ្វើពន្លឺឲ្យជានិមិត្ត ដោយសំដៅព្រះទ័យថា យើងនឹងគាល់ព្រះមានព្រះភាគ ដោយតាមក្រោយពេទ្យជីវកនោះ ។

ពេទ្យជីវកដឹងថា ព្រះរាជាទ្រង់ធ្វើពន្លឺឲ្យជានិមិត្តដល់ខ្លួនឬ ? ដឹងយ៉ាងល្អ ។ កាលដឹងហេតុណាទើបនៅស្ងៀម ? ដើម្បីកាត់សេចក្តីក្រវល់ក្រវាយ ។ ដោយថា ក្នុងបរិស័ទនោះ មានឧបដ្ឋាករបស់គ្រូទាំង ៦ កំពុងប្រជុំគ្នាច្រើន ។ គេទាំងនោះ សូម្បីខ្លួនឯងក៏មិនបានទទួលការសិក្សាឡើយ ព្រោះអ្នកមិនបានទទួលការសិក្សានៅកៀកជិត កាលយើងផ្តើមពោលដល់ព្រះគុណរបស់ព្រះមានព្រះភាគ គេទាំងនោះ ក៏នឹងម្តងក្រោកម្តងអង្គុយក្នុងចន្លោះៗ ពោលគុណនៃសាស្តារបស់ខ្លួនៗ កាលដូច្នេះ គុណកថានៃព្រះសាស្តារបស់យើង ក៏នឹងមិនដល់ទីបញ្ចប់បានចំណែកព្រះរាជា កាលទ្រង់ជួបកុលុបកៈរបស់គ្រូទាំង ៦ ពួកនេះ ហើយមិនបានពេញព្រះទ័យក្នុងគុណកថារបស់គ្រូទាំង ៦ ពួកនោះ ព្រោះមិនមានសារៈដែលនឹងកាន់យកបាន ក៏ទ្រង់នឹងត្រឡប់មកសួរយើង លុះដល់ពេលនោះ យើងនឹងពោលព្រះគុណរបស់ព្រះសាស្តា ដោយប្រាសចាកសេចក្តីក្រវល់ក្រវាយ ហើយនឹងនាំព្រះបាទអជាតសត្តុទៅកាន់សម្នាក់របស់

ព្រះសាស្តា ពេទ្យជីវកដឹងច្បាស់នៅយ៉ាងនេះ ទើបនៅស្ងៀម ដើម្បីកាត់សេចក្តីក្រវល់ក្រវាយ ដូច្នេះឯង ។

អាមាត្យស្ទូម្បីទាំងនោះនាំគ្នាគិតយ៉ាងនេះថា ថ្ងៃនេះព្រះរាជាទ្រង់សរសើររាត្រីដោយបទ ៥ បទ គង់មានព្រះបំណងនឹងចូលទៅរកសមណៈ ឬព្រាហ្មណ៍អង្គណាមួយ សួរបញ្ហាហើយស្តាប់ធម៌ជាពិត បើព្រះរាជានេះនឹងទ្រង់ស្តាប់ធម៌របស់សមណៈ ឬព្រាហ្មណ៍អង្គណាហើយ ទ្រង់ជ្រះថ្លា និងទ្រង់ធ្វើសក្ការៈធំដល់សមណៈ ឬព្រាហ្មណ៍អង្គនោះ សមណៈអ្នកជាកុលុបកៈរបស់អ្នកណា បានជាកុលុបកៈរបស់ព្រះរាជា អ្នកនោះរមែងមានសេចក្តីចម្រើន ដូច្នេះ ។

អាមាត្យទាំងនោះគ្រាគិតយ៉ាងនេះហើយ ទើបផ្តើមពោលសរសើរសមណៈដែលជាកុលុបកៈរបស់ខ្លួនៗ ដោយបំណងថា យើងពោលសរសើរសមណៈដែលជាកុលុបកៈរបស់ខ្លួន ហើយនឹងនាំព្រះរាជាទៅ យើងក៏នឹងទៅ ។ ព្រោះដូច្នោះ លោកទើបពោលថា កាលបើព្រះរាជាមានព្រះបន្ទូលយ៉ាងនេះហើយ មានរាជអាមាត្យម្នាក់ ដូច្នេះជាដើម ។

បណ្តាគ្រូទាំង ៦ ពួកនោះ ពាក្យថា **បូរណោ** ជាឈ្មោះនៃសាស្តាបដិញ្ញា ។ ពាក្យថា **កស្សបោ** ជាគោត្រ ។

បានឮថា បូរណកស្សបនោះ ជាទាសៈទី ៩៩ របស់ត្រកូលមួយ ហេតុនោះ គេទើបតាំងឈ្មោះថា បូរណៈ តែព្រោះជាទាសៈដែលជាមង្គល

ទើបមិនមានអ្នកណាចាំស្តីប្រដៅថា ធ្វើល្អ ធ្វើអាក្រក់ ឬថា មិនទាន់ធ្វើ ធ្វើមិនសម្រេច ។ បានឮថា នាយបូរណៈនោះគិតថា យើងនឹងនៅក្នុងទីនេះធ្វើអ្វី ទើបគេចចេញទៅ ។ គ្រានោះពួកចោរបានដណ្តើមយកសំពត់របស់គេទៅ ។ គេមិនដឹងនឹងរកស្លឹកឈើ ឬស្មៅមកបិទបាំងកាយ ទើបអាក្រាតកាយ ចូលទៅក្នុងពួកអ្នកស្រុកមួយកន្លែង ។ មនុស្សទាំងឡាយឃើញគេ យល់ថា លោកនេះជាសមណៈ ជាព្រះអរហន្ត ជាអ្នកប្រាថ្នាតិច មនុស្សដូចលោកនេះមិនមាន ទើបកាន់យកវត្ថុទាំងឡាយមាននំបង្អែម និងចម្អាបជាដើម ចូលទៅរក ។ គេគិតថា ព្រោះយើងមិនស្លៀកសំពត់ ទើបកើតលាភនេះ តាំងពីនោះមក សូម្បីបានសំពត់ក៏មិនស្លៀក បានកាន់ការអាក្រាតកាយនោះឯងជាបព្វជ្ជា ។ សូម្បីមនុស្សដទៃៗ ប្រមាណ ៥០០ នាក់ ក៏នាំគ្នាបួសតាមក្នុងសំណាក់របស់បូរណកស្សបនោះ ។ លោកពោលថា បូរណោ កស្សបោ សំដៅដល់អ្នកបួស បូរណកស្សប ដែលពោលរឿងមកហើយនោះ ។

ឈ្មោះថា សង្ឃី ដោយអត្ថថា មានពួក ពោលគឺ ពួកអ្នកបួស ។

ឈ្មោះថា គណី ដោយអត្ថថា មានគណៈនោះ នុ៎ះឯង ។

ឈ្មោះថា គណាចរិយោ ដោយអត្ថថា ជាអាចារ្យរបស់គណៈនោះ ដោយឋានៈទូន្មានមារយាទ ។

បទថា ញាតោ ប្រែថា ដឹងគ្រប់គ្នាយ៉ាងប្រាកដ ។

ឈ្មោះថា យសស្សី ជាអ្នកមានយស ដោយអត្ថថា មានកិត្តិយស ដែលលាន់ឮទៅយ៉ាងនេះថា ប្រាជ្ញាតិច សន្តោស សូម្បីសំពត់ក៏មិនស្លៀក ព្រោះប្រាជ្ញាតិច ។

បទថា តិត្ថករោ ប្រែថា មេលទ្ធិ ។

បទថា សាធុសម្មតោ សេចក្ដីថា គេលើកតម្កើងយ៉ាងនេះថា លោកនេះ ល្អៗ ជាសប្បុរស ។

បទថា ពហុជនស្ស សេចក្ដីថា បុថុជ្ជនអន្ធពាលអ្នកមិនបានស្ដាប់ ។

ឈ្មោះថា រត្តញ្ញូ ដោយអត្ថថា ដឹងរាត្រីច្រើនដែលកន្លងមកហើយ តាំងពីបួស ។

ឈ្មោះថា ចិរបព្វជិតោ ដោយអត្ថថា បួសមកយូរអង្វែង ។ ព្រោះពាក្យរបស់អ្នកដែលបួសមិនយូរ ជាពាក្យមិនគួរជឿ ដូច្នោះ លោកទើបពោលថា បួសយូរ ។

បទថា អទ្ធគតោ ប្រែថា មានអាយុយឺនយូរ អធិប្បាយថា កន្លងទៅ ២-៣ រជ្ជកាល ។

បទថា វយោអនុប្បត្តោ សេចក្ដីថា នៅរហូតមកដល់បច្ឆិមវ័យ ។

សូម្បីពាក្យទាំង ២ នេះ លោកពោលសំដៅយកពាក្យរបស់មនុស្សកម្លោះដែលមិនគួរជឿ ។

បទថា តុណ្ហី អហោសិ សេចក្ដីថា ព្រះរាជាទ្រង់ដូចជាបុរស

ដែលត្រូវការនឹងស៊ីស្វាយទុំមានពណ៌ដូចមាស មានរសឆ្ងាញ់ កាលជួប មក្លៀទុំដែលនាំមកដាក់ទុកក្នុងដៃ ក៏មិនពេញចិត្ត យ៉ាងណា ព្រះរាជា ក៏យ៉ាងនោះ មានព្រះបំណងស្តាប់ធម្មកថាដ៏ពីរោះ ប្រកបដោយគុណ មានឈាន និងអភិញ្ញាជាដើម និងសរុបចុះដោយព្រះត្រៃលក្ខណ៍ សួម្បី កាលមុនធ្លាប់បានជួបបូរណកស្សបៈ ក៏មិនពេញព្រះទ័យ មកឥឡូវនេះ ក្រៃលែងមិនពេញព្រះទ័យឡើងទៅទៀត ព្រោះការពណ៌នាគុណ ទើប ទ្រង់នៅស្ងៀម សួម្បីមិនពេញព្រះទ័យ ក៏មានព្រះតម្រិះថា បើយើងនឹង គំរាមអ្នកដែលក្រាបទូលនោះហើយ ឲ្យគេចាប់កនាំចេញទៅ អ្នកណាម្នាក់ សួម្បីដទៃ ក៏នឹងខ្លាចថា ព្រះរាជាទ្រង់ធ្វើយ៉ាងនេះដល់អ្នកដែលនិយាយ នោះៗ នឹងមិននិយាយអ្វីៗ ដូច្នោះ ទើបទ្រង់អត់ទ្រាំពាក្យនោះ សួម្បីមិន ជាទីពេញព្រះទ័យ បានជាទ្រង់នៅស្ងៀម ។

លំដាប់នោះ អាមាត្យម្នាក់ទៀតគិតថា យើងនឹងពោលគុណរបស់ សមណព្រាហ្មណ៍អ្នកជាកុលុបកៈរបស់ខ្លួន ទើបផ្តើមទូល ។ ព្រោះដូច្នោះ លោកទើបពោលថា អាមាត្យម្នាក់ទៀត ដូច្នេះជាដើម ។ ពាក្យនោះ ទាំងអស់ គប្បីជ្រាបតាមន័យដែលពោលហើយ ។

ក៏ក្នុងបណ្តាគ្រូទាំង ៦ នេះ ពាក្យថា មក្ខលិ ជាឈ្មោះរបស់ គ្រូម្នាក់នោះ ។

ពាក្យថា គោសាល ជាឈ្មោះបន្ទាប់ ព្រោះកើតត្រង់រោងគោ ។

បានឮថា គេកាន់ធ្នាំងប្រេងដើរទៅលើផ្ទៃដីមានភក់ ។ ចៅហ្វាយនាយពោលថា "កុំឲ្យរអិលដួលណា" ។ គេរអិលដួល ព្រោះធ្វេសប្រហែស ទើបផ្តើមគេចចេញព្រោះខ្លាចចៅហ្វាយនាយ ។ ចៅហ្វាយនាយរត់ទៅតោងជាយសំពត់ជាប់ ។ គេទើបចោលសំពត់ អាក្រាតកាយគេចចេញទៅ ។ សេចក្តីដ៏សេស ដូចគ្នានឹងបូរណកស្សបន៉ុះឯង ។

ពាក្យថា អជិត ជាឈ្មោះរបស់គ្រូម្នាក់នោះ ។ ឈ្មោះថា កេសកម្ពល ដោយអត្ថថា ស្លៀកសំពត់កម្ពល ដែលត្បាញដោយសក់មនុស្ស ។ រួមឈ្មោះទាំង ២ ចូលជាមួយគ្នា ទើបហៅថា អជិតកេសកម្ពល ។ ក្នុង ២ ឈ្មោះនោះ សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស ឈ្មោះថា កេស-កម្ពល ។ ឈ្មោះថា សំពត់ដែលមានសាច់គ្រោតគ្រាតជាងសំពត់កេសកម្ពលនោះ មិនមាន ។ សមដូចដែលព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ " ។

ពាក្យថា បកុធ ជាឈ្មោះរបស់គ្រូម្នាក់នោះ ។ ពាក្យថា កច្ចាយន ជាគោត្រ ។ រួមឈ្មោះ និងគោត្រចូលជាមួយគ្នា ទើបហៅថា

បក្ខុធកច្ចាយន ។ គ្រូបកុធកច្ចាយនៈនេះ ហាមទឹកត្រជាក់ សូម្បី បន្ទោបង់ឧច្ចារៈ ក៏មិនប្រើទឹកលាង ។ បានទឹកក្ដៅ ឬទឹកបាយ ទើប ធ្វើការលាង ។ គ្រាឆ្លងទន្លេ ឬទឹកតាមផ្លូវ គិតថា សីលរបស់យើងដាច់ ហើយ ទើបពូនពំនូកខ្សាច់អធិដ្ឋានសីល ហើយទើបទៅ ។ គ្រូនេះមាន លទ្ធិដែលប្រាសចាកសិរី មានសភាពបែបនេះ ។

ពាក្យថា សញ្ជ័យ ជាឈ្មោះរបស់គ្រូម្នាក់នោះ ។ ឈ្មោះថា វេលដ្ឋបុត្រ ព្រោះជាបុត្ររបស់វេលដ្ឋៈ ។ គ្រូម្នាក់ ឈ្មោះថា និគ្រន្ថ ដោយអំណាចឈ្មោះដែលបានហើយ ព្រោះនិយាយស្មើថា ពួកយើងមិន មានកិលេសដែលរួបរឹត ដែលខ្ចីមរអើម ពួកយើងវៀរចាកកិលេស ដែលរុំព័ទ្ធ ។ ឈ្មោះថា ឆាដបុត្រ ព្រោះជាបុត្ររបស់អ្នកលេងរបាំ ។

# កោមារភច្ចជីវក

[៩២] បទថា អថ ខោ រាជា សេចក្ដីថា បានឮថា ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់អាមាត្យទាំងនោះហើយ មានព្រះរាជតម្រិះថា "យើងមិនត្រូវការស្ដាប់ពាក្យនិយាយរបស់អ្នកណាៗ អ្នកនោះៗ រមែងនិយាយរៀបរាប់ទៅអស់ ចំណែកពាក្យនិយាយរបស់អ្នកណា ដែលយើងត្រូវការស្ដាប់ គេនោះ ត្រឡប់ជានៅស្ងៀម ដូចគ្រុឌត្រូវឫទ្ធិនាគចូលទៅហើយឈរស្ងៀម យើងវិនាសអស់ហើយហ្ន៎" រួចហើយទ្រង់ព្រះតម្រិះថា "ពេទ្យជីវកជាឧបដ្ឋាករបស់ព្រះមានព្រះភាគដ៏ស្ងប់រម្ងាប់ សូម្បីខ្លួនឯងក៏ស្ងប់-រម្ងាប់ ដូច្នោះ ទើបអង្គុយស្ងៀមដូចភិក្ខុដែលសម្បូរណ៍ដោយវត្ត ពេទ្យជីវកនេះ កាលយើងមិននិយាយ ក៏នឹងមិននិយាយ ក៏កាលនឹងចាប់ដំរីគួរនឹងចាប់ជើងដំរីនុ៎ះឯង" ទើបទ្រង់ប្រឹក្សានឹងពេទ្យជីវកនោះដោយព្រះអង្គឯង ។ ព្រោះហេតុនោះ លោកទើបពោលថា អថ ខោ រាជា ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា គឺ តុណ្ហី សេចក្ដីថា ស្ងៀមព្រោះហេតុអ្វី ព្រះរាជាត្រាស់សួរថា "កាលអាមាត្យទាំងនេះ ពោលគុណនៃសមណៈអ្នកជាកុលុបកៈរបស់ខ្លួនៗ នៅមាត់ មិនពេញចិត្តពោលសមណៈដែលជាកុលុបកៈរបស់លោក ដូចគ្រូរបស់អាមាត្យទាំងនេះ មិនមានឬលោកជាអ្នកក្រឬ ព្រះបិតារបស់យើង ប្រទានភាពជាធំដល់លោកហើយ

មិនមែនឬ ឬថា លោកមិនមានសទ្ធា” ។

លំដាប់នោះ ពេទ្យជីវក ទើបគិតក្នុងចិត្តថា “ព្រះរាជាព្រះអង្គនេះឲ្យយើងពោលគុណនៃសមណៈអ្នកជាកុលុបកៈ ឥឡូវនេះយើងមិនមែនវេលាដែលយើងនឹងស្ងៀម ដូចអាមាត្យទាំងនេះ ថ្វាយបង្គំព្រះរាជាហើយអង្គុយចុះ ពោលគុណរបស់សមណៈអ្នកកុលុបកៈរបស់ខ្លួនៗ យ៉ាងណា យើងនឹងពោលគុណរបស់ព្រះសាស្ដារបស់យើង ដូចអាមាត្យទាំងនេះមិនគួរទេ” ត្រិះរិះបណ្ដើរក្រោកឡើងចាកពីអាសនៈ បែរមុខទៅទីដែលប្រថាប់របស់ព្រះមានព្រះភាគ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីដែលរុងរឿងទៅដោយទសនខសមោធាន លើព្រះសិរសា ហើយទូលថា “បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់កុំមានព្រះទ័យថា ជីវកនេះនឹងនាំទៅជួបសមណៈដែលល្អដែលអាក្រក់ ព្រោះព្រះសាស្ដារបស់ទូលបង្គំនេះ ក្នុងការចុះចាប់បដិសន្ធិក្នុងគភ៌ព្រះមាតា ក្នុងការប្រសូតិចាកគភ៌ព្រះមាតា ក្នុងការស្ដេចចេញព្រះផ្នួស ក្នុងការត្រាស់ដឹង និងក្នុងការប្រកាសធម្មចក្កញាប់ញ័រពេញទូទាំងម៉ឺនលោកធាតុ ទ្រង់ធ្វើយមកបាដិហារ្យក៏យ៉ាងនេះ គ្រាស្ដេចចុះចាកពីទេវលោកក៏យ៉ាងនេះ ទូលបង្គំនឹងពោលគុណនៃព្រះ-សាស្ដារបស់ទូលបង្គំ សូមព្រះអង្គតាំងព្រះទ័យឲ្យមាំស្ដាប់ចុះ ក្រាបទូល” ។ គ្រាក្រាបទូលដូច្នេះហើយ ទើបពោលពាក្យជាដើមថា “បពិត្រព្រះសម្មតិទេព ព្រះមានព្រះភាគអង្គនេះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ” ដូច្នេះ ។

ក្នុងព្រះបាលីនោះ ពាក្យថា នំ ៧ បន ជាទុតិយាវិភត្តិប្រើក្នុងអត្ថនៃឥត្ថម្ភូតាខ្យាន គឺ ឲ្យប្រែថា របស់ព្រះមានព្រះភាគអង្គនោះ ។

បទថា កល្យាណោ សេចក្ដីថា ប្រកបដោយសេចក្ដីល្អ គឺ គុណ-ធម៌ ។ មានអធិប្បាយថា ប្រសើរបំផុត ។

បទថា កិត្តិសទ្ទោ សេចក្ដីថា ល្បីឈ្មោះ ឬសម្លេងការសរសើរព្រះកិត្តិគុណដ៏គឹកកង ។

បទថា អព្ភុគ្គតោ សេចក្ដីថា ឮសុះសាយទៅពេញទូទាំងលោករួមទាំងទេវលោកថា ព្រះមានព្រះភាគអង្គនោះ សូម្បីព្រោះហេតុនេះ ទើបជាព្រះអរហន្ត សូម្បីព្រោះហេតុនេះ ទ្រង់ទើបជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។ល។ សូម្បីព្រោះហេតុនេះ ទ្រង់ទើបជាអ្នកចែកព្រះធម៌ដូច្នេះ ។

ក្នុងបទព្រះពុទ្ធគុណនោះ មានការភ្ជាប់បទដូច្នេះ ព្រះមានព្រះភាគអង្គនោះ សូម្បីព្រោះហេតុនេះ ទើបជាព្រះអរហន្ត សូម្បីព្រោះហេតុនេះ ទើបជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។ល។ សូម្បីព្រោះហេតុនេះ ទើបជាអ្នកចែកព្រះធម៌ អធិប្បាយថា ព្រោះហេតុនេះផង នេះផង ។

បទទាំងអស់នេះ ក្នុងព្រះបាលីនោះ បានអធិប្បាយយ៉ាងពិស្ដារក្នុងពុទ្ធានុស្សតិនិទ្ទេសក្នុងវិសុទ្ធិមគ្គ ចាប់ផ្ដើមតាំងពីអធិប្បាយថា ព្រះ

មានព្រះភាគអង្គនោះ គប្បីជ្រាបថា ជាព្រះអរហន្តដោយហេតុទាំងនេះមុន គឺ ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ១ ព្រោះកាច់បំបាក់កាំចក្រនៃសង្សារវដ្ត ១ ព្រោះគួរដល់បច្ច័យជាដើម ១ ព្រោះមិនធ្វើបាបក្នុងទីកំបាំង ១ សេចក្តីពិស្តារនៃបទពុទ្ធគុណទាំងនោះ គប្បីកាន់យកចាកពីវិសុទ្ធិមគ្គនោះ ។

ក៏ពេទ្យជីវកពណ៌នាពុទ្ធគុណម្តងមួយបទចប់សេចក្តីអស់ ទូលថា "បពិត្រព្រះមហារាជ ព្រះសាស្តារបស់ទូលបង្គំ ជាព្រះអរហន្តយ៉ាងនេះ ជាសម្មាសម្ពុទ្ធៈយ៉ាងនេះ ។បេ។ ជាអ្នកចែកធម្មរតន៍យ៉ាងនេះ" ហើយទូលសរុបថា "បពិត្រព្រះសម្មតិទេព ទ្រង់មេត្តាចូលទៅគាល់ព្រះមានព្រះភាគចុះ បើកាលព្រះអង្គចូលគាល់ព្រះមានព្រះភាគ ព្រះទ័យក៏គប្បីថ្លាផូរផង់" ។

ក៏ក្នុងព្រះបាលីពេលនេះ កាលពេទ្យជីវកទូលថា "សូមព្រះសម្មតិទេពមេត្តាចូលទៅគាល់ព្រះមានព្រះភាគចុះ" ដូច្នេះ ស្មើនឹងការទូលថា "បពិត្រព្រះមហារាជ កាលទូលបង្គំត្រូវព្រះរាជាដូចព្រះអង្គទាំងរយ ទាំងពាន់ ទាំងសែនត្រាស់សួរ រមែងមានកម្លាំងពលំ និងកម្លាំងដែលនឹងពោលគុណកថារបស់ព្រះសាស្តាឲ្យចូលចិត្តដល់អ្នកទាំងអស់បាន ព្រះអង្គក៏ទ្រង់ជិតជិត មេត្តាចូលទៅគាល់ទូលសួរបញ្ហាចុះ ក្រាបទូល" ។

កាលព្រះរាជាទ្រង់ស្តាប់គុណកថា របស់ព្រះមានព្រះភាគរឿយៗ

ហើយនោះ មានបីតិ ៥ ប្រការ ផ្សាយទៅពេញព្រះវរកាយ ពាល់ត្រូវ រហូតគ្រប់វេលា ព្រះអង្គមានព្រះបំណងនឹងស្ដេចទៅក្នុងខណៈនោះតែម្ដង មានព្រះតម្រិះថា "កាលយើងនឹងទៅគាល់ព្រះទសពលក្នុងវេលានេះ មិនមានអ្នកណាដទៃដែលនឹងអាចចាត់យានពាហនៈបានរហ័ស ក្រៅពីពេទ្យជីវក" ទើបបន្ទាប់ថា "នៃជីវកៈជាសំឡាញ់ បើដូច្នោះ ចូរអ្នកឲ្យរៀបចំយានដំរីទាំងឡាយចុះ" ។

បណ្ដាបទទាំងនោះ បទថា តេនហិ ជានិបាត ប្រើក្នុងអត្ថថា បញ្ជូនទៅ អធិប្បាយថា ទៅចុះជីវកៈសម្លាញ់ ។

បទថា ហត្ថិយានានិ សេចក្ដីថា "បណ្ដាយានពាហនៈ មានសេះ និងរថជាដើម ដែលមានច្រើន យានពាហនៈ គឺ ដំរី ជាយានខ្ពស់បំផុត គួរនឹងនាំទៅសំណាក់របស់ព្រះសាស្ដា ដែលទ្រង់ខ្ពស់បំផុត ដោយយានពាហនៈដែលខ្ពស់បំផុតដូចគ្នា" ។ ព្រះរាជាមានព្រះតម្រិះដូច្នេះហើយ និងមានព្រះតម្រិះតទៅទៀតថា "យានពាហនៈ គឺ សេះ និងរថមានសំឡេងខ្លាំង សម្លេងរបស់យានពាហនៈទាំងនោះ បានឮទៅឆ្ងាយតែម្ដង ចំណែកយានពាហនៈ គឺ ដំរី សូម្បីអ្នកដែលដើរតាមស្នាមជើង ក៏មិនបានឮសម្លេង គួរនឹងទៅសំណាក់របស់ព្រះមានព្រះភាគដែលទ្រង់ស្ងៀមស្ងាត់ ដូចយានពាហនៈដែលស្ងៀមស្ងាត់ដូចគ្នា" ដូច្នេះ ហើយទើបត្រាស់ថា ហត្ថិយានានិ ជាដើម ។

បទថា បញ្ចមត្តានិ ហត្ថិនិយាសតានិ សេចក្តីថា ដំរីប្រមាណ ៥០០ ។

បទថា កប្បាបេត្វា សេចក្តីថា ឲ្យត្រៀមដំរីជាព្រះទីនាំង ។

បទថា អារោហណីយំ សេចក្តីថា គួរដល់ការឡើង អធិប្បាយថា បិទបាំង ។

សួរថា ពេទ្យជីវកនេះ បានធ្វើវត្ថុដែលព្រះរាជាត្រាស់ ឬមិនបានត្រាស់ ?

ឆ្លើយថា បានធ្វើវត្ថុដែលព្រះរាជាមិនបានត្រាស់ ។

ព្រោះហេតុអ្វី ? ព្រោះជាបណ្ឌិត ។

បានឮថា ពេទ្យជីវកនោះមានគំនិតយ៉ាងនេះថា "ព្រះរាជាត្រាស់បង្គាប់ថា យើងនឹងទៅក្នុងវេលានេះ ។

ធម្មតាព្រះរាជាទាំងឡាយ មានសត្រូវច្រើន បើនឹងមានអន្តរាយណាមួយក្នុងចន្លោះផ្លូវ សូម្បីយើងក៏នឹងត្រូវមនុស្សទាំងឡាយតិះដៀលថា "ពេទ្យជីវកគិតថា ព្រះរាជាជឿពាក្យយើង ទើបនាំព្រះរាជាចេញទៅក្នុងវេលាមិនគួរ" សូម្បីព្រះមានព្រះភាគ ក៏នឹងត្រូវតិះដៀលថា "ព្រះសមណគោតមប្រាជ្ញានឹងទេសនា មិនកំណត់កាលគួរមិនគួរ ហើយសម្តែងធម៌" ដូច្នេះខ្លះ ព្រោះដូច្នោះ យើងនឹងធ្វើមិនឲ្យកើតការរិះគន់ដល់យើង និងដល់ព្រះមានព្រះភាគ ទាំងព្រះរាជាក៏នឹងបានទទួលរក្សាយ៉ាងល្អ" ។ តពី

នោះ ពេទ្យជីវកគិតថា "ព្រោះអាស្រ័យស្ត្រីទាំងឡាយ ភ័យរមែងមិនមានដល់បុរសទាំងឡាយ ព្រះរាជាមានស្ត្រីហែហម ស្តេចទៅសប្បាយរីករាយ" ទើបឲ្យត្រៀមដំរី ៥០០ ឲ្យស្រី ៥០០ បន្លំជាប្រុស បង្គាប់ថា "ពួកនាងចូរកាន់ដាវ និងលំពែងហែហមព្រះរាជា" ហើយពេទ្យនៅគិតទៀតថា ព្រះរាជាអង្គនេះ មិនមានឧបនិស្ស័យនៃមគ្គផលក្នុងអត្តភាពនេះ និងធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់ឃើញឧបនិស្ស័យមុន ទើបសម្តែងធម៌ណា្គៃ យើងនឹងឲ្យមហាជនប្រជុំគ្នា កាលជាដូច្នេះ ព្រះសាស្តាទ្រង់សម្តែងធម៌តាមឧបនិស្ស័យរបស់អ្នកណាៗ ត្រឹមតែម្នាក់ ព្រះធម៌ទេសនានោះនឹងជាឧបការៈដល់មហាជន" ។ ពេទ្យជីវកនោះ បញ្ជូនសាសន៍ (ដំណឹង) ឲ្យវាយស្គរប្រកាសក្នុងទីនោះៗ ថា "ថ្ងៃនេះ ព្រះរាជាស្តេចនឹងទៅគាល់ព្រះមានព្រះភាគ សូមឲ្យអ្នកគ្រប់គ្នាថ្វាយរក្សាព្រះរាជា តាមសមគួរដល់សម្បត្តិរៀងៗ ខ្លួន" ។

លំដាប់នោះ មហាជនគិតថា "បានឮថា ព្រះរាជានឹងស្តេចទៅគាល់ព្រះមានព្រះភាគ លោកដ៏ចម្រើន ព្រះធម៌ទេសនារបស់ព្រះមាន-ព្រះភាគ តើជាយ៉ាងណាហ្ន៎ ពួកយើងនឹងវល់តែនាំគ្នាលេងនក្ខត្តឫក្សធ្វើអ្វី បើដូច្នោះ យើងទៅក្នុងទីនោះចុះ" ។ គ្រប់គ្នាកាន់របស់ក្រអូប និងផ្កាឈើជាដើម ឈររង់ចាំការស្តេចយាងមករបស់ព្រះរាជានៅតាមផ្លូវ ។ សូម្បីពេទ្យជីវក ក៏ទូលយាងស្តេចព្រះរាជាថា "បពិត្រព្រះសម្មតិទេវ ទូលបង្គំ

ត្រៀមយានពាហនៈដំរីរួចស្រេចហើយ សូមព្រះអង្គចូរដឹងវេលាដែលគួរក្នុងកាលឥឡូវនេះចុះ” ។

ក្នុងបទទាំងនោះ បទថា យស្សទានិ កាលំ មញ្ញសិ ជាពាក្យទូលជាស់តឿន ។ អធិប្បាយថា រឿងណាដែលព្រះអង្គទ្រង់បង្គាប់ទុករឿងនោះ ទូលបង្គំធ្វើរួចស្រេចហើយ ឥឡូវនេះ សូមព្រះអង្គចូរដឹងវេលាដែលស្តេចនឹងយាង ឬស្តេចមិនយាង សូមព្រះអង្គទ្រង់ធ្វើតាមព្រះទ័យរបស់ព្រះអង្គចុះ” ។

បទថា បច្ចេកា ឥត្ថិយោ កាត់បទជា បដិឯកា ឥត្ថិយោ អធិប្បាយថា ដំរីតែមួយ មានស្រីម្នាក់ប្រចាំ ។

បទថា ឧក្កាសុ ធារិយមានាសុ សេចក្តីថា មានអ្នកកាន់ប្រទីបមានជន (គប់ភ្លើង) ។

បទថា មហច្ចរាជានុភាវេន សេចក្តីថា ដោយអានុភាពរបស់ព្រះរាជាដ៏ធំក្រៃលែង ។ បាលីថា មហច្ចា ក៏មាន សេចក្តីថា ធំក្រៃលែងនេះជាលិង្គបរិយាយ ។

រាជឫទ្ធិ ហៅថា រាជានុភាព ។ ក៏អ្វីជារាជឫទ្ធិ ? សិរី គឺ ភាពជាធំនៃរដ្ឋធំ ២ ដែលមានផ្ទៃដីប្រមាណ ៣០០ យោជន៍ ជារាជឫទ្ធិ ។

ពិតហើយ ក្នុងថ្ងៃមុនឯណោះ មិនបានមានការត្រៀមទុកជាមុនដោយបំណងថា ព្រះរាជាស្តេចនឹងទៅគាល់ព្រះតថាគត ពេទ្យជីវកចាត់

បែងក្នុងខណៈនោះឯង យកស្រី ៥០០ អ្នកបន្ទំជាប្រុស ចងសំពត់ជួតក្បាល ពាក់ព្រះខាន់លើស្មា កាន់លំពែងមានដងជាកែវមណីចេញទៅ ដែលព្រះសង្គីតិកាចារ្យសំដៅដល់ ពោលថា បច្ចេកា ឥត្ថិយោ អាវោបេត្វា ដូច្នេះ ។

ស្រីរបាំលោមព័ទ្ធនាងក្សត្រិយ៍ ចំនួនប្រមាណ ១ ម៉ឺន ៦ ពាន់នាក់ទៀត ហែហមព្រះរាជា ។ តពីក្បួនស្រីលេងរបាំទាំងនោះ មានមនុស្សគម មនុស្សតឿ និងមនុស្សក្រេះជាដើម ។ តពីក្បួនអ្នកទាំងនោះមានអ្នកជិតជិត អ្នកថែរក្សាខាងក្នុងព្រះនគរ ។ តពីក្បួនអ្នកជិតជិតទាំងនោះ មានមហាមាត្យប្រមាណ ៦ ម៉ឺននាក់ តែងខ្លួនប្រកបដោយយសស្រស់ល្អ ។ តពីក្បួនមហាមាត្យទាំងនោះ មានកូនស្តេចប្រទេសរាជ ប្រមាណ ៩ ម៉ឺននាក់ ប្រដាប់ដោយគ្រឿងប្រដាប់ច្រើនយ៉ាង ហាក់បីដូចវិទ្យាធរកម្លោះកាន់អាវុធប្រភេទផ្សេងៗ ។ តពីក្បួន កូនស្តេចប្រទេសរាជ មានព្រាហ្មណ៍ប្រមាណ ១ ម៉ឺននាក់ ស្លៀកសំពត់មានតម្លៃទាំងរយ ដណ្តប់សំពត់ធៀងស្មាម្ខាងតម្លៃ ៥០០ ផ្ងូតទឹកលាបស្រឡាបយ៉ាងល្អ ល្អដោយគ្រឿងប្រដាប់ផ្សេងៗ មានផ្កាឈើមាសជាដើម ដើរលើកដៃស្តាំ ហើយបន្លឺថាជយោ ។ តពីក្បួនព្រាហ្មណ៍ទាំងនោះ មានតន្ត្រីប្រកបដោយអង្គ ៥ ។ តពីក្បួនតន្ត្រីទាំងនោះ មាននាយខ្មាន់ធ្នូលោមព័ទ្ធជារង្វង់ ។ តពីពួកខ្មាន់ធ្នូ មានដំរីមានពោងជិតគ្នា ។ តពីដំរី មានសេះរៀងគ្នា ក និង ក

ជិតគ្នា ។ តពីពួកសេះ មានរថជិតគ្នានឹងគ្នា ។ តពីរថ មានទាហានដៃនិងដៃប៉ះខ្ទប់គ្នា ។ តពីទាហានទាំងនោះ មានសេនា ១៨ ពួក រុងរឿងដោយគ្រឿងប្រដាប់ដែលសមគួរដល់ខ្លួនៗ ។

ពេទ្យជីវកចាត់មនុស្សថ្វាយព្រះរាជា ប្រភេទកូនសរ ដែលអ្នកឈរខាងចុងបំផុតនៃក្បួន បាញ់ទៅក៏មិនដល់ព្រះរាជា ខ្លួនឯងនៅជាប់តាមមិនឆ្ងាយពីព្រះរាជា ដោយបំណងថា បើនិងមានអន្តរាយអ្វីៗ យើងនឹងថ្វាយជីវិតដើម្បីព្រះរាជា មុនមនុស្សដទៃទាំងអស់ ។ មួយទៀតគប់ភ្លើង ក៏កំណត់មិនបានថា ប៉ុណ្ណេះរយ ឬពាន់ប៉ុណ្ណេះ ។

ពាក្យថា ព្រះបាទអជាតសត្តុ ស្តេចទៅសួនអម្ពវ័នរបស់ពេទ្យជីវកកោមារភច្ច ដោយរាជានុភាពយ៉ាងធំក្រៃលែង ព្រះសង្គីតិកាចារ្យពោលសំដៅយករាជឫទ្ធិបែបនេះឯង ។

ក្នុងពាក្យថា អហុទេវ ភយំ នេះ ភ័យ មាន ៤ យ៉ាង គឺ ភ័យព្រោះចិត្តតក់ស្លុត ១ ភ័យព្រោះញាណ ១ ភ័យព្រោះអារម្មណ៍ ១ ភ័យព្រោះឱត្តប្បៈ ១ ។

ក្នុងភ័យ ៤ យ៉ាងនោះ ភ័យដែលត្រាស់ទុកដោយន័យជាដើមថា ព្រោះអាស្រ័យជាតិ មានការខ្លាចរអា ដូច្នេះ ឈ្មោះថា ភ័យព្រោះចិត្តតក់ស្លុត ។

ភ័យ ដែលមកហើយយ៉ាងនេះថា សូម្បីពួកគេទាំងនោះ បាន

ស្ដាប់ធម៌ទេសនារបស់ព្រះតថាគតហើយ ច្រើនតែដល់នូវសេចក្ដីកិតភ័យតក់ស្លុត ញ័របំប្រប់ ដូច្នេះឈ្មោះថា **ភ័យព្រោះញាណ** ។

ភ័យ ដែលពោលហើយក្នុងពាក្យនេះថា មកដល់ភ័យគួរខ្លាចនោះពិតៗ ដូច្នេះ ឈ្មោះថា **ភ័យព្រោះអារម្មណ៍** ។

ភ័យនេះក្នុងពាក្យនេះថា ជនទាំងឡាយ តែងសរសើរបុគ្គលខ្លាចបាប មិនសរសើរបុគ្គលក្លៀវក្លាក្នុងបាបនោះទេ ឯសប្បុរសមិនធ្វើបាបព្រោះខ្លាចបាប ដូច្នេះ ឈ្មោះថា **ភ័យព្រោះឧត្តប្បៈ** ។

ក្នុងភ័យ ៤ យ៉ាងនោះ ក្នុងទីនេះសំដៅយកភ័យព្រោះចិត្តតក់ស្លុត អធិប្បាយថា មានចិត្តតក់ស្លុតហើយ ។

បទថា ឆម្ភិតត្តំ សេចក្ដីថា សេចក្ដីភ្ញាក់ផ្អើល អធិប្បាយថា ញ័រពេញទូទៅរាងកាយ ។

បទថា លោមហំសោ បានដល់ រោមបះឡើង អធិប្បាយថា រោមបះប្រួង ។ ក៏រោមបះឡើងនេះ រមែងមានដោយបីតិក្នុងវេលាកើតសេចក្ដីឆ្អែតចិត្ត ក្នុងខណៈស្ដាប់ធម៌ជាដើម ក៏មានដោយសេចក្ដីខ្លាច ព្រោះឃើញការកាប់សម្លាប់គ្នា និងឃើញខ្មោច ជាដើមក៏មាន ។ ក្នុងទីនេះគប្បីជ្រាបថា រោមបះឡើង ព្រោះខ្លាច ។

សួរថា ក៏ព្រះរាជានេះទ្រង់ខ្លាច ព្រោះហេតុអ្វី ?

អាចារ្យពួកមួយពោលថា ព្រោះភាពងងឹត ។

បានឮថា ក្នុងក្រុងរាជគ្រឹះ មានទ្វារធំ ៣២ ទ្វារ ទ្វារតូច ៦៤ ទ្វារ ។ សួនអម្ពវ័ន របស់ពេទ្យជីវក នៅចន្លោះកំពែងក្រុង និងភ្នំគិជ្ឈកូដជាប់គ្នា ។ ព្រះបាទអជាតសត្តុ ស្តេចចេញតាមទ្វារទិសខាងលិច ស្តេចចូលទៅក្នុងស្រមោលរបស់ភ្នំ ។ ទីត្រង់នោះ ព្រះចន្ទត្រូវកំពូលភ្នំបាំងជិត សេចក្តីងងឹតទើបមានឡើង ព្រោះស្រមោលរបស់ភ្នំនិងស្រមោលរបស់ដើមឈើ ។ សូម្បីពាក្យដែលពោល ក៏មិនមែនហេតុដែលសមគួរ ។ ដោយថា ក្នុងវេលានោះ គប់ភ្លើងតាំងឡើង សែនដួងក៏កំណត់មិនបាន ។ ក៏ព្រះបាទអជាតសត្តុនេះ អាស្រ័យសេចក្តីស្ងៀមស្ងាត់ ទើបកើតសេចក្តីខ្លាច ព្រោះរង្កៀសពេទ្យជីវក ។

បានឮថា ពេទ្យជីវក បានទូលព្រះអង្គឯប្រាសាទជាន់លើតែម្តងថា "បពិត្រព្រះមហារាជ ព្រះមានព្រះភាគ ប្រាថ្នាសេចក្តីស្ងៀមស្ងាត់ គួរចូលគាល់ដោយសេចក្តីស្ងៀមស្ងាត់ទុំះឯង" ព្រោះហេតុនោះ ព្រះរាជាទើបទ្រង់ហាមសម្លេងតន្ត្រី ។ តន្ត្រីទាំងឡាយ ពេលព្រះរាជាឲ្យឈប់ប៉ុណ្ណោះ ។ ក្បួនតាមស្តេច ទើបមិនបន្លឺសំឡេងខ្លាំង តគ្នាមកដោយសញ្ញាម្រាមដៃ ។ សូម្បីក្នុងសួនអម្ពវ័ន ក៏មិនបានឮសូម្បីសម្លេងគ្រហែមរបស់អ្នកណាៗ ។ ធម្មតាព្រះរាជាទាំងឡាយ រមែងត្រេកអរក្នុងសម្លេងក្រៃលែងណាស់ ។ ព្រះបាទអជាតសត្តុ អាស្រ័យសេចក្តីស្ងៀមស្ងាត់នោះ កើតព្រះទ័យអផ្សុកនាំរង្កៀសសូម្បីក្នុងពេទ្យជីវកថា "ពេទ្យជីវក

នេះពោលថា ទីសួនអម្ពវ័នរបស់ខ្ញុំព្រះអង្គមានភិក្ខុ ១,២៥០ រូប ក៏ក្នុងទីនេះ យើងមិនបានឮសូម្បីតែសម្លេងគ្រហែម ពាក្យពេទ្យជីវកប្រាកដដូចជាមិនពិត ពេទ្យជីវកនេះលួងលោមនាំយើងចេញចាកក្រុង ពួនស្មាក់កងពលទុកខាងមុខ ត្រូវការចាប់យើងហើយឡើងគ្រងរាជសម្បត្តិដោយខ្លួនឯង ក៏ពេទ្យជីវកនេះមានកម្លាំងស្មើនឹង ៥ ដំរីសារ និងដើរមិនឆ្ងាយពីយើង មនុស្សរបស់យើងដែលកាន់អាវុធនៅជិត ក៏មិនមានត្រឹមតែម្នាក់ គួរអស្ចារ្យ យើងវិនាសអស់ហើយហ្ន៎" ។ ក៏គ្រាទ្រង់ខ្លាចយ៉ាងនេះហើយ ក៏មិនអាចតាំងខ្លួនឲ្យដូចជាអ្នកមិនខ្លាចបាន ទើបត្រាស់ប្រាប់សេចក្ដីដែលព្រះអង្គខ្លាចដល់ពេទ្យជីវកនោះ ។ ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ៖

គ្រានោះឯង ព្រះរាជាដែនមគធ នាមថាអជាតសត្តុ ។ល។

មិនមានសំឡេងគឹកកងសោះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា សម្ម សេចក្ដីថា នេះជាពាក្យហៅមនុស្សជំទង់ប្រហែលគ្នា ។ អធិប្បាយថា សម្លាញ់នេះ មិនបញ្ឆោតយើងទេឬ ។

បទថា ឆ បលម្ភេសិ សេចក្ដីថា លោកពោលវត្ថុដែលមិនមានថាមាន ដូច្នេះ មិនលួងលោមយើងទេឬ ។

បទថា និគ្ឃោសោ សេចក្ដីថា ពាក្យពោលសន្ទនាអ៊ូអែ ។

បទថា មា ភាយិ មហារាជ សេចក្ដីថា ពេទ្យជីវកគិតថា

“ព្រះរាជាព្រះអង្គនេះ មិនស្គាល់យើង បើយើងមិនលួងលោមព្រះអង្គឲ្យស្រាលព្រះទ័យថា “ជីវកនេះមិនសម្លាប់អ្នកជាទេ” ដូច្នេះ ក៏វិនាស” ទើបទូលលួងលោមឲ្យមានព្រះទ័យតាំងមាំថា “បពិត្រមហារាជ សូមព្រះអង្គកុំខ្លាចឡើយ” ហើយទើបទូលថា ន តំ ទេវ ដូច្នេះជាដើម ។

បទថា អភិក្កម សេចក្តីថា មេត្តាស្តេចចូលទៅចុះ អធិប្បាយថា ចូរចូលទៅ ។ ក៏កាលពោលតែម្តងនឹងមិនតាំងមាំបាន ដូច្នោះ ពេទ្យជីវកទើបប្រញាប់ពោល ២-៣ ដង ។

បទថា ឯតេ មណ្ឌលមាលេ បទីបា ឈាយន្តិ សេចក្តីថា ពេទ្យជីវកទូលថា បពិត្រព្រះមហារាជ ធម្មតាកម្លាំងរបស់ចោរនឹងមិនអុជប្រទីបតាំងទុក តពីនោះប្រទីបដែលនៅត្រង់រោងមូល នៅភ្លឺ សូមព្រះអង្គស្តេចទៅតាមសញ្ញានៃប្រទីបនោះចុះ ព្រះអង្គ ។

## សាមញ្ញផលបុច្ឆា

បទថា នាគស្ស ភូមិ សេចក្តីថា ក្នុងទីណា អ្នកជិះដំរីអាចទៅបាន ទីនេះឈ្មោះថា ជាផ្លូវដីដំរីទៅបាន ។

បទថា នាគា បច្ចោរោហិត្វា សេចក្តីថា ចុះពីដំរីត្រង់ខ្លោងទ្វារខាងក្រៅដែលប្រថាប់ ។ ក៏តេជៈនៃព្រះមានព្រះភាគ ផ្សាយទៅកាន់ព្រះសរីរៈរបស់ព្រះរាជារហូតគ្រប់វេលា ដែលប្រថាប់ក្នុងទីប្រថាប់ ។

ក្នុងវេលានោះ ព្រះសេទោហូរចេញចាកទូទៅ ព្រះសរីរៈរបស់ព្រះរាជា ។ សំពត់ទ្រង់ មានសភាពដូចជាប្រឡាក់ទឹកហូរ សេចក្តីខ្លាចយ៉ាងខ្លាំងបាន កើតឡើង ព្រោះទ្រង់រឭកដល់កំហុសរបស់ព្រះអង្គ ស្តេចមិនអាចយាងទៅ សំណាក់របស់ព្រះមានព្រះភាគត្រង់ៗ ទ្រង់តោងដៃពេទ្យជីវក ធ្វើហាក់បី ដូចជាស្តេចទតសួនបណ្តើរ ត្រាស់សរសើរទីប្រថាប់ថា "ជីវកសម្លាញ់ នេះលោកឲ្យធ្វើបានល្អ នេះលោកសាងបានល្អ" ស្តេចចូលទ្វាររោងមូល ដោយលំដាប់ អធិប្បាយថា ដល់ព្រមហើយ ។

ដោយពាក្យថា កហំ បន សម្ម ដូច្នេះ ព្រះបាទអជាតសត្តុ ត្រាស់សួរព្រោះអ្វី ? អាចារ្យពួកមួយពោលថា ទ្រង់មិនជ្រាបមកមុន ។

បានឮថា ក្នុងវេលាដែលទ្រង់នៅជាព្រះកុមារ ព្រះរាជានេះ ធ្លាប់ គាល់ព្រះមានព្រះភាគជាមួយព្រះបិតា តែខាងក្រោយ ព្រោះសេពគប់មិត្ត អាក្រក់ ទើបធ្វើបិតុឃាត បញ្ជូននាយខ្មាន់ធ្នូ ឲ្យលែងដំរីធនបាល មាន កំហុសច្រើន មិនហ៊ានចូលទៅជិតព្រះភ័ក្ត្រព្រះមានព្រះភាគ ដែលថា ទ្រង់មិនជ្រាប ទើបត្រាស់សួរនោះ មិនមែនហេតុដែលសមគួរ ។

សេចក្តីពិត ព្រះមានព្រះភាគ មានព្រះវរលក្ខណ៍ពេញ ដែលប្រដាប់ ដោយអនុព្យញ្ជនៈ បញ្ចេញព្រះឆព្វណ្ណរង្សីស្វាងស្វៃពេញសួន ហែហមទៅ ដោយពួកភិក្ខុ ដូចព្រះចន្ទពេញវង់ហែហមដោយពួកផ្កាយ ប្រថាប់គង់ កណ្តាលរោងមូល អ្នកណានឹងមិនស្គាល់ព្រះអង្គ ។ តែព្រះបាទអជាតសត្តុ

ត្រាស់សួរនេះ ក៏ដោយអាកប្បកិរិយានៃភាពជាធំរបស់ព្រះអង្គ ។ កាលដឹងក៏ដោយ មិនដឹងក៏ដោយ សួរលមើល នេះជាប្រក្រតីធម្មតារបស់រាជ-ត្រកូលទាំងឡាយ ។

ចំណែកពេទ្យជីវក ស្តាប់ព្រះតម្រាស់នោះហើយ គិតថា "ព្រះរាជាព្រះអង្គនេះ ដូចជាប្រថាប់ឈរលើផែនដី សួរថា ផែនដីនៅទីណា មើលផ្ទៃមេឃ ហើយសួរថា ព្រះចន្ទព្រះអាទិត្យនៅទីណា ឈរត្រង់ជើងភ្នំសិនេរុ សួរថា ភ្នំសិនេរុនៅទីណា ប្រថាប់ឈរចំពោះព្រះភ័ក្ត្រព្រះទសពលតែម្តង ត្រាស់សួរថា ព្រះមានព្រះភាគប្រថាប់នៅឯណា ណ្ហើយ យើងនឹងសម្តែងព្រះមានព្រះភាគចំពោះព្រះអង្គ" ទើបផ្គងអញ្ជលីទៅកាន់ទីដែលព្រះមានព្រះភាគគង់ប្រថាប់ ហើយទូលពាក្យថា ឯសោ មហារាជ ដូច្នេះជាដើម ។

បទថា បុរក្ខតោ សេចក្តីថា ប្រថាប់ខាងមុខភិក្ខុសង្ឃ ដែលអង្គុយហែហមព្រះអង្គ ។

បទថា យេន ភគវា តេនុបសង្កមិ សេចក្តីថា ចូលទៅគាល់នៅទីជិតព្រះមានព្រះភាគ ក្នុងទីដែលព្រះមានព្រះភាគប្រថាប់ ។

បទថា ឯកមន្តំ អដ្ឋាសិ សេចក្តីថា ព្រះរាជាតែមួយព្រះអង្គប៉ុណ្ណោះ ថ្វាយបង្គំព្រះមានព្រះភាគ ហើយប្រថាប់ឈរក្នុងប្រទេសមួយកន្លែង ដែលសមគួរដល់ព្រះអង្គនឹងប្រថាប់ឈរបាន មិនបៀតបៀន

ព្រះមានព្រះភាគ ឬភិក្ខុសង្ឃ ។

បទថា តុណ្ហីភូតំ តុណ្ហីភូតំ សេចក្តីថា នឹងក្រឡេកមើលទៅទីណាៗ ក៏ស្ងៀមអស់ក្នុងទីនោះៗ ។ ពិតមែន ក្នុងទីនោះមិនមានភិក្ខុសូម្បីត្រឹមតែមួយរូប ដែលសម្តែងសេចក្តីឃ្នើសឃ្នងដៃ ឃ្នើសឃ្នងជើង ឬសម្លេងគ្រហែម ។ ភិក្ខុសូម្បីមួយរូប ក៏មិនបានក្រឡេកមើលព្រះរាជា ឬបរិស័ទរបស់ព្រះរាជា ទីនៅត្រង់ព្រះភ័ក្ត្រព្រះមានព្រះភាគ មានសុទ្ធតែនាងរបាំ ជាបរិវារ ប្រដាប់ដោយអលង្ការគ្រប់គ្រាន់ ។ ភិក្ខុគ្រប់រូបអង្គុយមើលព្រះមានព្រះភាគប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងសេចក្តីស្ងប់របស់ភិក្ខុទាំងនោះ ទ្រង់ត្រួតមើលភិក្ខុសង្ឃដែលមានឥន្ទ្រិយស្ងប់ដូចអន្លង់ទឹកថ្លា ព្រោះប្រាសចាកភក់ រឿយៗ ទ្រង់ថ្លែងឧទាន ។

ក្នុងបទទាំងនោះ ដោយបទថា ឥមិនា នេះ សម្តែងថា ដោយសេចក្តីស្ងប់នេះ ដែលភិក្ខុសង្ឃស្ងប់ផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ដោយសេចក្តីស្ងប់ គឺ សីល ។ ព្រះរាជាត្រាស់យ៉ាងនេះក្នុងទីនោះ មិនបានទ្រង់សំដៅដល់សេចក្តីនេះថា ឱ ! ហ្ន៎ សូមឲ្យកូនរបស់យើងបួសហើយគប្បីស្ងប់ដូចភិក្ខុទាំងនេះ ។ តែព្រះអង្គទតឃើញភិក្ខុសង្ឃហើយទ្រង់ជ្រះថ្លា ទើបទ្រង់រឭកដល់ព្រះឱរស ។ ក៏ការបានវត្ថុដែលបានដោយលំបាក ឬឃើញវត្ថុអស្ចារ្យហើយ រឭកដល់អ្នកស្រឡាញ់មានញាតិនិងមិត្តជាដើម ជាប្រក្រតីរបស់លោកតែម្តង ។ ព្រះរាជានេះទតឃើញ

ភិក្ខុសង្ឃហើយ ទ្រង់រឭកដល់ព្រះឱរស ទើបត្រាស់យ៉ាងនេះ ដោយប្រការដូច្នេះ ។ មួយាងទៀត ព្រះអង្គមានសេចក្តីមិនទុកព្រះទ័យក្នុងព្រះឱរស កាលទ្រង់ប្រាថ្នាឲ្យព្រះឱរសមានសេចក្តីស្ងប់ ទើបត្រាស់យ៉ាងនេះ ។ បានឮថា ព្រះអង្គទ្រង់បរិវិតក្កៈយ៉ាងនេះថា កូនរបស់យើងនឹងសួរថា ព្រះបិតារបស់យើងនៅកម្ទោះ ព្រះជីតារបស់យើងទៅណា កាលស្តាប់ថា ព្រះជីតានោះ ព្រះបិតារបស់ព្រះអង្គសម្លាប់ចោលហើយដូច្នេះ នឹងមានការគិតថា យើងនឹងសម្លាប់ព្រះបិតាហើយគ្រងរាជសម្បត្តិ ។ ព្រះអង្គមានសេចក្តីមិនទុកព្រះទ័យក្នុងព្រះឱរស កាលទ្រង់ប្រាថ្នាឲ្យព្រះឱរសមានសេចក្តីស្ងប់ ទើបត្រាស់យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក៏ព្រះរាជាត្រាស់យ៉ាងនេះក៏ពិតមែនហើយ តែថា ព្រះឱរសក៏នឹងសម្លាប់ព្រះអង្គទុំះឯង ។ ក៏ក្នុងវង្សនោះ មានការសម្លាប់បិតាដល់ ៥ ជួររជ្ជកាល ។

**គឺ ព្រះបាទអជាតសត្តុ សម្លាប់ព្រះបាទពិម្ពិសារ , ព្រះបាទឧទ័យ សម្លាប់ព្រះបាទអជាតសត្តុ , ព្រះឱរសរបស់ព្រះបាទឧទ័យ ព្រះនាមថា មហាមុណ្ឌិកៈ សម្លាប់ព្រះបាទឧទ័យ , ព្រះឱរសរបស់ព្រះបាទមហា-មុណ្ឌិកៈ ព្រះនាមថា អនុរុទ្ធៈ សម្លាប់ព្រះបាទមហាមុណ្ឌិកៈ , ព្រះឱរសរបស់ព្រះបាទអនុរុទ្ធៈ ព្រះនាមថា នាគទាសៈ សម្លាប់ព្រះបាទអនុរុទ្ធៈ ។**

អ្នកក្រុងក្រោធថា ពួកនេះ ជាព្រះរាជាកាត់ផ្តាច់វង្សត្រកូល មិន

មានប្រយោជន៍ ទើបសម្លាប់ព្រះបាទនាគទាសៈចោល ។

ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះថា អាគមា ខោ ត្វំ ដូច្នេះ ។

បានឮថា កាលព្រះរាជាមិនមានព្រះតម្រាស់ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា "ព្រះរាជានេះស្ដេចមក ប្រថាប់ស្ងៀមមិនមានសម្ដេង ទ្រង់ត្រិះរិះយ៉ាងណាហ្ន៎ លុះទ្រង់ជ្រាបសេចក្ដីគិតរបស់ព្រះរាជាហើយ ទ្រង់ត្រិះរិះថា ព្រះរាជានេះមិនអាចចរចាជាមួយយើង ទ្រង់គន់មើលភិក្ខុសង្ឃហើយទ្រង់រឭកដល់ព្រះឱរស ក៏កាលតថាគតមិនពោលឡើងមុន ព្រះរាជានេះនឹងមិនអាចត្រាស់ពាក្យអ្វីៗ ឡើយ តថាគតនឹងចរចាជាមួយព្រះអង្គ" ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ក្នុង លំដាប់នៃព្រះរាជតម្រាស់ថា អាគមា ខោ ត្វំ មហារាជ យថា បេមំ ជាដើម ។ សេចក្ដីរបស់ព្រះពុទ្ធតម្រាស់នោះថា មហាបពិត្រ ទឹកដែលធ្លាក់ក្នុងទីខ្ពស់ រមែងហូរទៅកាន់ទីទំនាបយ៉ាងណា សូមព្រះអង្គចូរក្រឡេកមើលភិក្ខុសង្ឃហើយបដិបត្តិតាមសេចក្ដីស្រឡាញ់យ៉ាងនោះចុះ" ។ គ្រានោះ ព្រះរាជាមានព្រះរាជតម្រិះថា " ឱ ! ព្រះពុទ្ធគុណគួរអស្ចារ្យ ឈ្មោះថា អ្នកដែលធ្វើខុសចំពោះព្រះមានព្រះភាគ ដូចយើងមិនមាន ដោយថា យើងសម្លាប់អគ្គឧបដ្ឋាករបស់ព្រះមានព្រះភាគ និងជឿពាក្យរបស់ព្រះទេវទត្ត បញ្ជូននាយខ្មាន់ធ្នូ លែងដំរីនាឡាគិរី ព្រោះអាស្រ័យយើង ព្រះទេវទត្តទើប

ប្រមៀលសិលា យើងមានកំហុសធំសម្បើម ដល់យ៉ាងនេះ ព្រះទសពលនៅត្រាស់ហៅដោយព្រះឱស្ឋនឹងមិនល្មម ឱ ! ព្រះមានព្រះភាគប្រតិស្ឋាននៅដោយល្អ ក្នុងលក្ខណៈរបស់អ្នកនៅដោយអាការ ៥ យ៉ាង យើងនឹងមិនលះបោលព្រះសាស្ដាបែបនេះ ហើយស្វែងរកសាស្ដាខាងក្រៅឡើយ" ទ្រង់ព្រះសោមនស្ស កាលទ្រង់សន្ទនានឹងព្រះមានព្រះភាគ ទើបត្រាស់ថា បិយោ មេ ភន្តេ ជាដើម ។

[៩៣] បទថា ភិក្ខុសង្ឃស្ស អញ្ជលឹ ឧបនាមេត្វា សេចក្ដីថា បានឮថា ព្រះបាទអជាតសត្តុនោះ មានព្រះរាជត្រិះថា "យើងថ្វាយបង្គំព្រះមាន-ព្រះភាគហើយ ទៅសំពះភិក្ខុសង្ឃខាងឯណោះខាងនេះ រមែងនឹងត្រូវបែរខ្នងឲ្យព្រះមានព្រះភាគ ក៏នឹងមិនជាការធ្វើសេចក្ដីគោរពព្រះមានព្រះភាគ ព្រោះអ្នកដែលថ្វាយបង្គំព្រះរាជាហើយ ថ្វាយបង្គំឧបរាជ រមែងជាការមិនធ្វើសេចក្ដីគោរពព្រះរាជា" ដូច្នោះ ព្រះអង្គទើបថ្វាយបង្គំព្រះមានព្រះភាគហើយប្រណមអញ្ជលីចំពោះភិក្ខុសង្ឃត្រង់ទីប្រថាប់ឈរនុ៎ះឯង ទើបប្រថាប់អង្គុយក្នុងដែលសមគួរមួយកន្លែង ។

បទថា កញ្ចិទេវ ទេសំ លេសមត្តំ បានដល់ ឱកាសណាមួយ ។ គ្រានោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ជួយព្រះបាទអជាតសត្តុឲ្យកើតឧស្សាហ៍ក្នុងការសួរបញ្ហា ទើបត្រាស់ថា "បពិត្រមហារាជ បើទ្រង់ប្រាថ្នា

នឹងសួរនូវប្រស្នាណា សូមទ្រង់សួរមកចុះ” ។

ព្រះពុទ្ធតម្រាស់នោះ មានសេចក្ដីថា អញ្ជើញសួរចុះ កាលទ្រង់ព្រះបំណង តថាគតមិនមានសេចក្ដីធុនចិត្តក្នុងការវិសជ្ជនាបញ្ហា មួយ៉ាងទៀតព្រះមានព្រះភាគទ្រង់បវារណាបែបជាសព្វញ្ញុបវារណា ដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក និងមហាសាវកទាំងឡាយថា អញ្ជើញសួរចុះ ព្រះអង្គទ្រង់ប្រាថ្នាប្រការណាៗ តថាគតនឹងវិសជ្ជនាថ្វាយប្រការនោះៗ គ្រប់ប្រការ ចំពោះព្រះអង្គ ។

ពិតមែន ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក និងមហាសាវកទាំង នោះរមែងមិនពោលថា យទាកង្ខសិ បើទ្រង់ប្រាថ្នា រមែងពោលថា ស្ដាប់ហើយនឹងដឹងបាន ។ តែព្រះពុទ្ធទាំងឡាយ រមែងត្រាស់ថា “ម្នាលអាវុសោ បើអ្នកចង់សួរ ក៏សួរមកចុះ” ឬថា “បពិត្រមហារាជ បើទ្រង់ប្រាថ្នានឹងសួរនូវប្រស្នាណា សូមទ្រង់សួរមកចុះ” ។

ឬថា “ម្នាលវាសវៈ មហារាជមានព្រះទ័យប្រាថ្នានឹងសួរនូវប្រស្នាណា ចូរសួរនូវប្រស្នានោះចំពោះតថាគតចុះ តថាគតនឹងធ្វើទីបំផុតនៃប្រស្នានោះៗ ថ្វាយមហាបពិត្របាន” ។

ឬថា “ម្នាលភិក្ខុ បើដូច្នោះ អ្នកចង់សួរប្រស្នាណា ចូរអង្គុយលើអាសនៈរបស់ខ្លួន សួរប្រស្នានោះចុះ” ។

ឬថា “ សេចក្ដីសង្ស័យទាំងអស់របស់ពាវរីព្រាហ្មណ៍ផង របស់

អ្នកផង របស់ពួកជនទាំងអស់ផង ចូរប្រាថ្នា (សួរ) ទុកក្នុងចិត្តនូវហេតុណាមួយចុះ” ។

ឬថា “ម្នាលសភិយៈ អ្នកប៉ងក្នុងចិត្ត ចំពោះប្រស្នាណាមួយ ចូរសួរប្រស្នានោះមកតថាគតចុះ តថាគតនឹងធ្វើនូវទីបំផុតនៃប្រស្នានោះៗ ដល់អ្នក” ។

ព្រះពុទ្ធទាំងឡាយ រមែងបវារណាបែបជាសព្វញ្ញូបវារណា ដល់យក្ខ អ្នកជាធំលើមនុស្ស ទេវតា សមណៈ ព្រាហ្មណ៍ និងបរិព្វាជកទាំងឡាយនោះៗ ។ ក៏សេចក្ដីនេះមិនជាអស្ចារ្យទេ ព្រោះព្រះមានព្រះភាគទ្រង់សម្រេចពុទ្ធភូមិហើយ ទើបបវារណាយ៉ាងនោះ ។ សូម្បីកាលតាំងនៅក្នុងញាណលំដាប់ភូមិព្រះពោធិសត្វ ត្រូវឥសីទាំងឡាយអង្វរឲ្យជួយដោះស្រាយបញ្ហា ដើម្បីប្រយោជន៍ដល់ស្ដេចសក្កៈជាដើមយ៉ាងនេះថា ៖

“បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពដ៏ល្អអារាធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះស្រាយប្រស្នានុ៎ះ ជាទំនៀម តែងមានក្នុងពួកមនុស្ស ប្រស្នាណាមកកាន់សេចក្ដីចម្រើន ប្រស្នានោះ ជាភារៈរបស់លោក ។

ក្នុងកាលជាសរភង្គតាបស យ៉ាងនេះថា “លោកដ៏ចម្រើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវប្រស្នាណានីមួយ ដែលលោកប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខដោយ

ខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន” ។

និងក្នុងសម្ភវជាតក មានព្រាហ្មណ៍ដ៏ស្អាតត្រាច់ទៅទូទាំងជម្ពូទ្វីប ៣ ដង មិនជួបអ្នកដែលនឹងដោះស្រាយបញ្ហាបាន គ្រាព្រះពោធិសត្វឲ្យឱកាសហើយ វេលានោះព្រះពោធិសត្វកើតមកបាន ៧ ឆ្នាំ លេងធូលីនៅលើថ្នល់ អង្គុយស្ទឹងស្មាធិ៍កណ្តាលថ្នល់នុ៎ះឯង បវារណាប្រដូចសព្វញ្ញុបវារណាថា ៖

“សូមអញ្ជើញចុះ យើងនឹងប្រាប់ដល់លោក ដូចជាអ្នកឈ្លាសវៃប្រាប់ និងព្រះរាជាទ្រង់នឹងជ្រាបសេចក្តីនោះថា នឹងធ្វើបាន ឬមិនបាន ។

កាលព្រះមានព្រះភាគ ទ្រង់បវារណាសព្វញ្ញុបវារណាយ៉ាងនេះហើយ ព្រះបាទអជាតសត្តុទ្រង់ពេញព្រះទ័យ កាលនឹងទូលសួរបញ្ហា បានក្រាបទូលថា យថា នុ ខោ ឥមានិ ភន្តេ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ សិល្បៈនុ៎ះឯង ឈ្មោះសិប្បាយតនៈ ។

បទថា បុថុសិប្បាយតនានិ ប្រែថា សិល្បៈជាច្រើន ។

បទថា សេយ្យថីទំ សេចក្តីថា ក៏សិល្បសាស្ត្រទាំងនោះអ្វីខ្លះ ?

ដោយបទថា ហត្ថារោហា ជាដើម ព្រះបាទអជាតសត្តុ ទ្រង់សម្តែងពួកជនដែលអាស្រ័យសិល្បៈនោះៗ ចិញ្ចឹមជីវិត ។ សេចក្តីថា ព្រះអង្គមានព្រះរាជបំណងដូច្នេះថា ផលនៃសិល្បៈដែលប្រចក្យ ព្រោះអាស្រ័យសិល្បៈនោះៗ រមែងប្រាកដដល់អ្នកដែលចូលទៅអាស្រ័យសិល្បៈ

ចិញ្ចឹមជីវិតទាំងនេះ យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចប្រកាស សាមញ្ញផល ដែលប្រចក្សក្នុងបច្ចុប្បន្ន ដូច្នោះបាន ឬមិនបានហ្ន៎ ដូច្នេះ ។ ព្រោះដូច្នោះ ព្រះបាទអជាតសត្តុ ទើបទ្រង់ផ្ដើមសិល្បសាស្ត្រទាំងឡាយ មកសម្ដែងដល់អ្នកដែលចូលទៅអាស្រ័យសិល្បៈចិញ្ចឹមជីវិត ។

ក្នុងបទទាំងនេះ ដោយបទថា ហត្ថារោហា រមែងសម្ដែងដល់ អាចារ្យបង្ហាត់ដំរី ពេទ្យរក្សាដំរី និងអ្នកចងដំរីជាដើមទាំងអស់ ។

បទថា អស្សារោហា បានដល់ គ្រូបង្ហាត់សេះ ពេទ្យរក្សាសេះ និងអ្នកចងសេះជាដើមទាំងអស់ ។

បទថា រថិកា បានដល់ គ្រូបង្ហាត់ពលរថ ទាហានរថ និងអ្នករក្សារថជាដើមទាំងអស់ ។

បទថា ធនុគ្គហា បានដល់ គ្រូបង្ហាត់ពលធ្នូ និងបញ្ញាការធ្នូ ។

បទថា ចេលកា បានដល់ អ្នកកាន់ទង់ជ័យទៅខាងមុខ ក្នុងសមរភូមិច្បាំង ។

បទថា ចលកា បានដល់ អ្នកចាត់ក្បួនទ័ពយ៉ាងនេះថា ព្រះរាជានៅត្រង់នេះ មហាអាមាត្យឈ្មោះឯណោះនៅត្រង់នេះ ។

បទថា បិណ្ឌទាយិកា បានដល់ ទាហានធំដែលស៊ូស្លាប់ ពួកៃ ។ បានឮថា ទាហានទាំងនោះ ចូលក្នុងកងទ័ពសត្រូវ កាត់សីសៈសត្រូវ ដូចដុំបាយ ហើយនាំទៅ អធិប្បាយថា លោតចេញទៅលឿនរហ័ស ។

ម្យ៉ាងទៀត ពាក្យថា **បិណ្ឌទាយិកា** នេះ ជាឈ្មោះរបស់អ្នកដែលកាន់កាជន៍អាហារចូលទៅឲ្យដល់ទាហាន កណ្ដាលសង្គ្រាម ។

បទថា ឧគ្គា ច រាជបុត្តា បានដល់ ពួករាជបុត្រដែលចូលសង្គ្រាមមានឈ្មោះថា ឧគ្គតៈ ឧគ្គតៈ ។

បទថា បក្ខន្ទិនោ បានដល់ ទាហានពួកណា ពោលថា ពួកយើងនឹងនាំសីសៈ ឬអាវុធរបស់អ្នកណាៗ មក គ្រាបានទទួលពាក្យបង្គាប់ថា របស់អ្នកឯណោះ ក៏ត្រាច់ចូលកាន់សង្គ្រាម នាំវត្ថុដែលបង្គាប់នោះឯងមកបាន ទាហានទាំងនេះឈ្មោះថា បក្ខន្ទិនោ ដោយអត្ថថា ត្រាច់ទៅ (វាយសម្រុកចូល) ។

បទថា មហានាគា បានដល់ ជាអ្នកខ្លាំងក្លាច្រើនដូចស្ដេចនាគ ។

ពាក្យថា មហានាគា នេះ ជាឈ្មោះរបស់ពួកទាហាន ដែលសូម្បីកាលដំរីជាដើមរត់មកត្រង់មុខ ក៏មិនថយត្រឡប់ ។

បទថា សូរា បានដល់ ខ្លាំងក្លាជាទីបំផុត ដែលគ្របដោយក្រឡាសំណាញ់ក៏ដោយ ពាក់ក្រោះស្បែកក៏ដោយ ក៏អាចឆ្លងសមុទ្របាន ។

បទថា ចម្មយោធិនោ បានដល់ ពួកដែលពាក់អាវស្បែក ឬកាន់ខែលស្បែក ។ សម្រាប់ទប់ទល់គ្រាប់ធ្នូចម្បាំង ។

បទថា ទាសកបុត្តា បានដល់ ពួកកូនទាសៈក្នុងផ្ទះ ជាទីស្រឡាញ់របស់នាយចៅហ្វាយ ជាកម្លាំង ។

បទថា អាឡារិកា បានដល់ ពួកធ្វើនំ ។

បទថា កប្បកា បានដល់ ពួកជាងកោរកាត់ ។

បទថា ន្ហាបកា បានដល់ ពួកអ្នកផ្ងូតទឹក ។

បទថា សូទា បានដល់ ពួកធ្វើអាហារ ។

ពួកជាងផ្កាឈើជាដើម ជាក់ច្បាស់ហើយ ។

បទថា គណកា បានដល់ ពួកអ្នកចេះលេខនិព្វន្ត ។

បទថា មុទ្ទិកា បានដល់ ពួកអាស្រ័យវិជ្ជារាប់ម្រាមដៃចិញ្ចឹមជីវិត ។

បទថា យានិ វា បនញ្ញានិបិ បានដល់ ពួកជាងដែក ជាងចោះទម្លុះក្លុក និងជាងសរសេរក្បាច់ជាដើម ។

បទថា ឯវំ គតានិ បានដល់ ប្រព្រឹត្តទៅយ៉ាងនេះ ។

បទថា តេ ទិដ្ឋេវ ធម្មេ សេចក្តីថា ពួកពលដំរីជាដើម ពួកនោះសម្តែងសិល្បសាស្ត្រច្រើនយ៉ាងទាំងនោះ បានសម្បត្តិច្រើនពីរាជត្រកូលចូលទៅអាស្រ័យផលនៃសិល្បៈ ដែលឃើញប្រចក្សនុ៎ះឯង ចិញ្ចឹមជីវិតបាន ។

បទថា សុខេន្តិ ប្រែថា ធ្វើឲ្យជាសុខ ។

បទថា បិណេន្តិ បានដល់ ធ្វើឲ្យឆ្អែតស្កប់ស្កល់ មានថាមពលនិងកម្លាំង ។

បទថា ឧទ្ធគ្គិកា ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា ឧទ្ធគ្គិកា ព្រោះអត្ថថា មានផលកំពូល លើសផលដែលកើតខ្ពស់ឡើងទៅ ។

ឈ្មោះថា សោវគ្គិកា ព្រោះអត្ថថា គួរដល់អារម្មណ៍ដ៏ប្រសើរ ។

ដែលឈ្មោះថា សុខវិបាកា ព្រោះអត្ថថា មានសុខជាវិបាក ។

ដែលឈ្មោះថា សគ្គសំវត្តនិកា ព្រោះអត្ថថា ញ៉ាំងធម៌ ១០ ប្រការ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ អាយុ វណ្ណៈ សុខ យស និងភាពជាធំក្រៃលែងឲ្យប្រព្រឹត្តទៅ គឺ ឲ្យកើតឡើង អធិប្បាយថា តាំងទក្ខិណាទានបែបនោះទុក ។

ក្នុងបទថា សាមញ្ញផលំ នេះ ដោយបរមត្ថ **សាមញ្ញ** សំដៅដល់មគ្គ **សាមញ្ញផល** សំដៅដល់អរិយផល ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចុះសាមញ្ញៈតើដូចម្តេច ? មគ្គប្រកបដោយអង្គ ៨ ដែលជាអរិយៈនេះឯង ជាសាមញ្ញៈ មគ្គប្រកបដោយអង្គ ៨ ដែលជាអរិយៈ គឺ អ្វីខ្លះ ? គឺ សម្មាទិដ្ឋិ ។ល។ សម្មាសមាធិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សាមញ្ញ** ម្នាលភិក្ខុទាំងឡាយ ក៏សាមញ្ញផលទាំងឡាយ ដូចម្តេច ? សោតាបត្តិផល ។ល។ អរហត្តផល នេះឯងជា **សាមញ្ញផល** ព្រះរាជាអង្គនេះ មិនបានដល់សាមញ្ញផលនោះ ក៏ព្រះអង្គត្រាស់សួរដល់សាមញ្ញផល ដែលប្រៀបដោយទាសៈ និងអ្នកស្រែដែលមានមក បានយ៉ាងប្រសើរ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់មិនបានវិសជ្ជនាបញ្ហាភ្លាម ទ្រង់ព្រះតម្រិះថា អាមាត្យរបស់ព្រះរាជាទាំងនេះ ជាសាវករបស់អន្យតិរ្ថិយ ច្រើនាំស់មកក្នុងទីនេះ ពួកអាមាត្យទាំងនោះ កាលតថាគតសម្តែងចំណែកខ្មៅ និងចំណែកស នឹងតិះដៀលថា ព្រះរាជារបស់ពួកយើងស្តេចមកក្នុងទីនេះដោយឧស្សាហ៍ធំ តាំងពីព្រះអង្គស្តេចមកហើយ ព្រះសមណគោតមត្រាស់សេចក្តីកោលាហលរបស់សមណៈ ឲ្យជារឿងសមណៈឈ្មោះគ្នាចេញ នឹងមិនស្តាប់ធម៌ដោយគោរព តែកាលព្រះរាជាត្រាស់ ពួកអាមាត្យនឹងមិនអាចតិះដៀល នឹងអនុវត្តតាមព្រះរាជាប៉ុណ្ណោះ ធម្មតាមនុស្សលោករមែងអនុវត្តតាមអ្នកធំ តថាគតនឹងធ្វើឲ្យជាភារៈរបស់ព្រះរាជាតែមួយអង្គ កាលព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាភារៈរបស់ព្រះរាជា ទើបត្រាស់ថា អភិជានាសិ នោ ត្វំ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា អភិជានាសិ នោ ត្វំ ស្មើនឹង អភិជានាសិ នុ ត្វំ និង នោ សព្ទនេះ គប្បីប្រកបដោយបទ បុច្ឆិតា ខាងមុខ ។ អធិប្បាយថា មហាបពិត្រ បញ្ហានេះព្រះអង្គធ្លាប់សួរសមណព្រាហ្មណ៍ពួកដទៃខ្លះឬហ្ន៎ ។ ព្រះអង្គនៅចាំបានដល់ការដែលសួរបញ្ហានោះ ព្រះអង្គមិនបានភ្លេចសមណព្រាហ្មណ៍ទាំងនោះឬ ។

បទថា សចេ តេ អគរុ សេចក្តីថា បើសមណព្រាហ្មណ៍នោះៗព្យាករណ៍យ៉ាងណា ការដែលព្រះអង្គត្រាស់យ៉ាងនោះក្នុងទីនេះ នឹងមិន

ជាការជូនព្រះទ័យដល់ព្រះអង្គ ។ អធិប្បាយថា បើទីងមិនមានសេចក្ដីមិនសុខស្រួលអ្វីៗ សូមឲ្យព្រះអង្គត្រាស់ចុះ ។

បទថា ន ខោ មេ ភន្តេ នេះ ព្រះរាជាត្រាស់បំណាងដល់អ្វី ? បំណាងថា ក៏ការពោលក្នុងសំណាក់របស់បណ្ឌិតទាំងឡាយ រមែងជាការលំបាក ។ បណ្ឌិតធៀបទាំងនោះ រមែងឲ្យទោសគ្រប់ៗ បទ គ្រប់ៗ អក្សរតែម្ដង ។ ចំណែកលោកដែលជាបណ្ឌិតពិត ស្ដាប់ពាក្យហើយ រមែងសរសើរ ពាក្យដែលពោលល្អ ក្នុងពាក្យដែលពោលមិនល្អ ខុសបាលី ខុសបទ ខុសអត្ថ និងខុសព្យញ្ជនៈត្រង់កន្លែងណាៗ បណ្ឌិត រមែងជួយធ្វើឲ្យត្រូវត្រង់កន្លែងនោះៗ ។ ដែលឈ្មោះថា បណ្ឌិត ដូចព្រះមាន-ព្រះភាគ រមែងមិនមាន ។ ព្រោះដូច្នោះ ព្រះបាទអជាតសត្រូ ទើបទូលថា ក្នុងកន្លែងដែលព្រះមានព្រះភាគ ឬអ្នកប្រៀបផ្ទឹមដោយព្រះមានព្រះភាគប្រថាប់នៅ ខ្ញុំព្រះអង្គមិនធុញ់ចិត្តទេ ព្រះអង្គ ។

## ពណ៌នា បូរណកស្សប

[៩៤] ក្នុងបទថា ឯកមិទាហំ នេះ កាត់បទជា ឯកំ ឥធ អហំ ប្រែថា ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយខ្ញុំព្រះអង្គ ។

បទថា សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា សេចក្ដីថា ញុំាងពាក្យដែលឲ្យកើតសេចក្ដីរីករាយ គួរឲ្យរឭកដល់គ្នាចប់ស្រេចហើយ ។

ក្នុងពាក្យថា ករោតោ ខោ មហារាជ ការយតោ បពិត្រមហារាជ បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើជាដើម មាននិទ្ទេសដូចតទៅនេះ ៖

បទថា ករោតោ បានដល់ ធ្វើដោយដៃរបស់ខ្លួន ។

បទថា ការយតោ បានដល់ បង្គាប់ឲ្យធ្វើ ។

បទថា ឆិន្ទតោ បានដល់ កាត់ដៃជាដើមរបស់អ្នកដទៃ ។

បទថា បចតោ បៀតបៀនគេដោយខ្លួនឯង បានដល់ ប្រើអាជ្ញាបៀតបៀនខ្លះ គំរាមខ្លះ ។

បទថា សោចយតោ សេចក្ដីថា ធ្វើគេឲ្យសោកសៅដោយខ្លួនឯងខ្លះ ប្រើឲ្យអ្នកដទៃធ្វើឲ្យគេសោកសៅខ្លះ ដោយការលួចវត្ថុរបស់អ្នកដទៃជាដើម ។

បទថា កិលមយតោ សេចក្ដីថា ឲ្យគេលំបាកដោយខ្លួនឯងខ្លះ ប្រើឲ្យអ្នកដទៃធ្វើឲ្យគេលំបាកខ្លះ ដោយការផ្ដាច់អាហារ និងដាក់គុកជាដើម ។

បទថា ផន្ទតោ ផន្ទាបយតោ សេចក្ដីថា ក្នុងវេលាដែលចងរឹតអ្នកដទៃឲ្យក្ដៅក្រហាយ សូម្បីខ្លួនឯងក៏ក្ដៅក្រហាយ ធ្វើអ្នកដទៃឲ្យក្ដៅក្រហាយ ។

បទថា ចាណមតិចាតាបយតោ សម្លាប់សត្វដោយខ្លួនឯង ឬប្រើ

អ្នកដទៃឲ្យសម្លាប់ សេចក្ដីថា សម្លាប់ដោយខ្លួនឯងខ្លះ ឲ្យអ្នកដទៃសម្លាប់ខ្លះ នូវសត្វមានជីវិត ។

ក្នុងពាក្យគ្រប់បទ គប្បីជ្រាបសេចក្ដីដោយអំណាចនៃការធ្វើ ដោយខ្លួនឯង និងការឲ្យអ្នកដទៃធ្វើនុ៎ះឯង ដោយប្រការដូច្នេះ ។

បទថា សន្ធឹ បានដល់ ទី-តនៃផ្ទះ ។

បទថា និល្លោបំ បានដល់ ប្លន់ដ៏ធំ ។

បទថា ឯកាគារិកំ បានដល់ លោមព័ទ្ធប្លន់ផ្ទះមួយខ្នងប៉ុណ្ណោះ ។

បទថា បរិបន្ថេ បានដល់ ឈរស្ទាក់នៅត្រង់ផ្លូវដើម្បីដណ្ដើមទ្រព្យរបស់អ្នកដែលធ្លងទៅមក ។

ដោយពាក្យថា ករោតោ ន ករិយាតិ ចាបំ សម្ដែងថា សូម្បីកាលធ្វើដោយយល់ថា យើងធ្វើបាបណាមួយ បាបមិនជាការធ្វើ បាបមិនមាន ។ តែសត្វទាំងឡាយយល់យ៉ាងនេះថា យើងធ្វើ ។

បទថា ខុរបរិយន្តេន សេចក្ដីថា ប្រើចក្រដែលមានកងមុតដូចកាំបិតកោរ ឬមានវង់មូលមុត ដូចកាំបិតកោរ ។

បទថា ឯកមំសខលំ បានដល់ ដុំសាច់មួយដុំ ។

បទថា បុញ្ជំ ជាវេវចនៈរបស់បទថា ខលំ នុ៎ះឯង ។

បទថា តតោនិទានំ សេចក្ដីថា មានការធ្វើឲ្យជាគំនរសាច់ដែលដូចគ្នាតែមួយជាហេតុ ។

បទថា ឧក្កិណំ សេចក្ដីថា ពួកមនុស្សក្នុងត្រើយខាងនាយ ជាមនុស្សអាក្រក់ សាហាវ ឃោរឃៅ លោកពោលថា ហនន្តោ ជាដើម សំដៅដល់មនុស្សទាំងនោះ ។

ពួកមនុស្សក្នុងត្រើយអាយ ជាអ្នកមានសទ្ធាជ្រះថ្លា រាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជារបស់ខ្លួន លោកពោលពាក្យថា ទទន្តោ ជាដើម សំដៅដល់មនុស្សទាំងនោះ ។

បណ្ដាបទទាំងនោះ បទថា យជន្តោ បានដល់ ធ្វើការបូជាធំ ។

បទថា ទមេន បានដល់ ដោយការទូន្មានឥន្ទ្រិយ ឬដោយឧបោសថកម្ម ។

បទថា សញ្ញមេន បានដល់ ការសង្រួមសីល ។

បទថា សច្ចវាចេន បានដល់ ដោយការនិយាយពាក្យពិត ។

បទថា អាគមោ សេចក្ដីថា មក គឺ ប្រព្រឹត្តទៅ ។ គ្រូបូរណកស្សបៈបដិសេធការធ្វើបាប និងបុណ្យទាំងឯង សូម្បីដោយប្រការទាំងពួង ។

ដែលឈ្មោះថា បុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់ដើមខ្នុរវិញ បានដល់ អ្នកដែលកាលត្រូវសួរថា តើស្វាយយ៉ាងដូចម្ដេច ? ឬដើម ស្លឹក ផ្កា ផ្លែរបស់ស្វាយ តើយ៉ាងដូចម្ដេច ? ដូច្នេះហើយ ឆ្លើយថា ខ្នុរសម្លជាយ៉ាងនេះ ដើម ស្លឹក ផ្កា ផ្លែរបស់ខ្នុរសម្ល ជាយ៉ាងនេះ ។

បទថា វិជិតេ បានដល់ ក្នុងប្រទេសដែលនៅក្នុងអំណាចឃុំគ្រង ។

បទថា អបសាទេតព្វំ សេចក្តីថា គប្បីបៀតបៀន ។

បទថា អនភិនន្ទិត្វា បានដល់ មិនធ្វើការសរសើរ យ៉ាងនេះថា ល្អណាស់ៗ ។

បទថា អប្បដិក្កោសិត្វា បានដល់ មិនហាម យ៉ាងនេះថា នែ៎ មនុស្សល្ងង់លោកនិយាយមិនល្អ ។

បទថា អនុគ្គណ្ហន្តោ បានដល់ មិនកាន់យកជាសារៈ ។

បទថា អនិក្កុជ្ជេន្តោ បានដល់ មិនរក្សាទុកក្នុងចិត្តថា នេះជានិស្សរណៈ នេះជាបរមត្ថ ព្រោះប្រកាន់ជាសារៈបានតែម្តង ។ តែព្រះបាទអជាតសត្តុ ទ្រង់សិក្សាព្យញ្ជនៈហើយ ទ្រង់លះបង់ចេញ ។

## ពណ៌នា មក្ខលិគោសាល

**[៩៥] ក្នុងវាទៈរបស់គ្រូមក្ខលិគោសាល មានវិនិច្ឆ័យដូចតទៅនេះ ៖**

ពាក្យថា បច្ចយោ ជាវេវចនៈនៃពាក្យថា **ហេតុ** ។

សូម្បីដោយបទថា មិនមានហេតុ មិនមានបច្ច័យទាំង ២ គឺគ្រូមក្ខលិគោសាល បដិសេធបច្ច័យនៃសេចក្តីសៅហ្មងរបស់កាយទុច្ចរិតជាដើម និងបច្ច័យនៃសេចក្តីបរិសុទ្ធិរបស់កាយសុចរិតជាដើម ដែលមានហើយនុ៎ះឯង ។

បទថា អត្តការេ សេចក្ដីថា ការធ្វើរបស់ខ្លួនឯង សត្វទាំងនេះដល់ភាពជាទេវតាក្ដី មារក្ដី ព្រហ្មក្ដី ការត្រាស់ដឹងជាព្រះសាវកក្ដី ការត្រាស់ដឹងជាព្រះបច្ចេកពុទ្ធក្ដី ភាពជាព្រះសព្វញ្ញូក្ដី ដោយកម្មដែលខ្លួនធ្វើហើយយ៉ាងណា គ្រូមក្ខលិគោសាលបដិសេធកម្មនោះ ។

ដោយបទទីពីរ (នត្ថិ បរការេ) គឺ គ្រូមក្ខលិគោសាលបដិសេធការធ្វើរបស់អ្នកដទៃ គឺ ជនដ៏សេស វៀរព្រះមហាសត្វ អាស្រ័យឱវាទានុសាសនីរបស់អ្នកដទៃ ដែលជាការធ្វើរបស់អ្នកដទៃ តាំងពីសាងសេចក្ដីសោភាគ្យរបស់មនុស្ស ដរាបសម្រេចព្រះអរហត្ត ។ ជនពាលនេះឈ្មោះថា រមែងឲ្យការប្រហារក្នុងជិនចក្រ ដោយប្រការដូច្នេះ ។

បទថា នត្ថិ បុរិសការេ សេចក្ដីថា សត្វទាំងឡាយ រមែងដល់សម្បត្តិទាំងឡាយ ដែលមានប្រការដូចពោលហើយ ដោយការធ្វើរបស់បុរសណា គ្រូមក្ខលិគោសាលបដិសេធការធ្វើរបស់បុរសសូម្បីនោះ ។

បទថា នត្ថិ ពលំ សេចក្ដីថា សត្វទាំងឡាយតាំងនៅក្នុងកម្លាំងរបស់ខ្លួនយ៉ាងណា ធ្វើសេចក្ដីព្យាយាមដល់សម្បត្តិទាំងនោះ គ្រូមក្ខលិ-គោសាលបដិសេធកម្លាំងយ៉ាងនោះ ។

បទថា នត្ថិ វីរិយំ ជាដើមទាំងអស់ ជាវេវចនៈរបស់បទថា បុរិសការេ តែបទទាំងនេះ កាន់យកទុកផ្នែកមួយ ដោយអាចបដិសេធពាក្យដែលប្រព្រឹត្តទៅ យ៉ាងនេះថា នេះប្រព្រឹត្តទៅដោយសេចក្ដីព្យាយាម

របស់បុរស នេះប្រព្រឹត្តទៅដោយកម្លាំងពលំរបស់បុរស នេះប្រព្រឹត្តទៅដោយសេចក្តីតស៊ូព្យាយាមរបស់បុរស ។

ដោយបទថា សព្វេ សត្តា លោករួមយក អូដ្ឋ គោ លាជាដើម ដោយមិនមានសល់ ។

ដោយបទថា សព្វេ ទាណា លោកពោលដោយពាក្យជាដើមថា បាណៈមានឥន្រ្ទិយមួយ បាណៈមានឥន្រ្ទិយពីរ ។

ដោយបទថា សព្វេ ភូតា លោកពោលសំដៅយកកូនទាំងឡាយ ដែលកើតក្នុងពង និងកើតក្នុងស្បូន ។

ដោយបទថា សព្វេ ជីវា លោកពោលសំដៅយកស្រូវសាលី ស្រូវខ្សាយ និងស្រូវជំណើបជាដើម ក៏ក្នុងជីវៈទាំងនោះ គ្រូមក្ខលិគោសាលនោះយល់ថា ជីវៈ ដែលដុះបាន ។

បទថា អវសា អពលា អវីរិយា សេចក្តីថា ជីវៈទាំងនោះមិនមានអំណាច ឬកម្លាំង ឬសេចក្តីព្យាយាមរបស់ខ្លួន ។

ក្នុងបទថា និយតិ សង្គតិ ភាវបរិណតា នេះ វិនិច្ឆ័យថា ៖

និយតិ បានដល់ គ្រោះ ។

សង្គតិ បានដល់ ការទៅក្នុងភពនោះៗ របស់អភិជាតិទាំង ៦ ។

ភាវ បានដល់ សភាវៈនុះឯង ។

សេចក្តីប្រែទៅតាមគ្រោះ តាមសេចក្តីជួបប្រសព្វនិងតាមសភាវៈ

ដល់កាលជាប្រការផ្សេងៗ គ្រូមក្ខលិគោសាលសម្តែងថា ក៏អ្នកណាគប្បី កើតដោយប្រការណា អ្នកនោះ រមែងកើតដោយប្រការនោះឯង អ្នកណា មិនគប្បីកើត អ្នកនោះ រមែងមិនកើត ។

ដោយបទថា ឆស្វេវាភិជាតីសុ គ្រូមក្ខលិគោសាលសម្តែងថា អ្នកតាំងនៅក្នុងអភិជាតិ ៦ នុ៎ះឯង រមែងសោយសុខ និងទុក្ខ ភូមិដែល ឲ្យកើតសុខកើតទុក្ខដទៃមិនមាន ។

បទថា យោនិប្បមុខសតសហស្សានិ សេចក្តីថា កំណើតដែលជា ប្រធាន គឺ កំណើតខ្ពស់បំផុត ១,៤០៦,៦០០ ។

បទថា បញ្ច ច កម្មុនោ សតានិ បានដល់ កម្ម ៥០០ ។

គ្រូមក្ខលិគោសាល សម្តែងទិដ្ឋិដែលគ្មានប្រយោជន៍ ដោយហេតុ ត្រឹមតែការត្រិះរិះ ។

សូម្បីក្នុងបទថា បញ្ច ច កម្មានិ តីណិ ច កម្មានិ ជាដើម ក៏ន័យនេះដូចគ្នា ។

តែអាចារ្យពួកខ្លះពោលថា បទថា បញ្ច ច កម្មានិ នោះ លោក ពោលសំដៅឥន្ទ្រិយ ៥ និងកម្ម ៣ លោកពោលសំដៅកាយកម្មជាដើម ។

ក៏ក្នុងបទថា កម្មេ ច ឧបឌ្ឍកម្មេ ច នេះ គ្រូមក្ខលិគោសាលនោះ មានលទ្ធិថា កាយកម្ម និងវចីកម្ម ជាកម្ម មនោកម្មជាពាក់កណ្តាលកម្ម ។

បទថា ទ្វដ្ឋិបដិបទា សេចក្តីថា គ្រូមក្ខលិគោសាលពោលថា

បដិបទា ៦២ ។

បទថា ទ្វដ្ឋន្តរកប្បា សេចក្តីថា ក្នុងកប្បមួយ មានអន្តរកប្ប ៦៤ ។ តែគ្រូមក្ខលិគោសាលនេះ មិនដឹងអន្តរកប្ប ២ ទៀត ទើបពោលយ៉ាងនេះ ។

បទថា ឆឡាភិជាតិយោ សេចក្តីថា គ្រូមក្ខលិគោសាលពោលដល់អភិជាតិ ៦ ទាំងនេះ គឺ អភិជាតិខ្មៅ អភិជាតិខៀវ អភិជាតិក្រហម អភិជាតិលឿង អភិជាតិស អភិជាតិសក្រៃលែង ។

ក្នុងអភិជាតិ ៦ ទាំងនោះ អ្នកសម្លាប់ពពែ អ្នកសម្លាប់បក្សី អ្នកសម្លាប់ម្រឹគ អ្នកសម្លាប់ជ្រូក ពួកព្រាន ពួកអ្នកសម្លាប់ត្រី ពួកចោរ ពួកអ្នសម្លាប់ចោរ ពួកអ្នកជាប់គុក ឬពួកជនណាមួយក្រៅពីនេះ ដែលមានអំពើអាក្រក់ គ្រូមក្ខលិគោសាល ហៅថា អភិជាតិខ្មៅ គេហៅភិក្ខុទាំងឡាយថា អភិជាតិខៀវ ។

បានឮថា ភិក្ខុទាំងនោះ យកបន្លា ដាក់ក្នុងបច្ច័យ ៤ ហើយឆាន់ ។ មួយទៀត គ្រូមក្ខលិគោសាល ហៅភិក្ខុទាំងឡាយថា មានការប្រព្រឹត្តដូចបន្លា ។ នេះឯងជាលំនាំរបស់គ្រូមក្ខលិគោសាលពោលដល់ ។

មយ៉ាងទៀត គ្រូមក្ខលិគោសាលពោលថា បព្វជិតទាំងនោះ ឈ្មោះថា អ្នកមានការប្រព្រឹត្តដូចបន្លា ។

គ្រូមក្ខលិគោសាលពោលថា ពួកនិគ្រន្ថដែលមានសំពត់តែ ១ ឈ្មោះថា អភិជាតិក្រហម ។ បានឮថា ពួកអភិជាតិក្រហមទាំងនេះ សជាង

២ ពួកខាងដើម ។

ពួកគ្រហស្ថអ្នកស្លៀកដណ្តប់សំពត់ស ជាសាវករបស់ពួកអចេល ហៅថា អភិជាតិលឿង ។

គ្រូមក្ខលិគោសាល ធ្វើអ្នកឲ្យបច្ច័យដល់ខ្លួន ឲ្យជាអ្នកចម្រើនបំផុតជាងនិគ្រន្ថទាំងឡាយយ៉ាងនេះ ។ គេហៅអាជីវកប្រុស និងអាជីវកស្រីថា អភិជាតិស ។ បានឮថា ពួកអភិជាតិសទាំងនោះ សជាង ៤ ពួកខាងដើម ។ លោកពោលថា នន្ទ វច្ឆ កិស សង្កិច្ច គ្រូមក្ខលិ-គោសាល ជាអភិជាតិសក្រៃលែង ។ បានឮថា អ្នកទាំងនោះ សជាងអ្នកដទៃៗ ទាំងអស់ ។

បទថា អដ្ឋ បុរិសភូមិយោ សេចក្តីថា គ្រូមក្ខលិគោសាល ពោលថា ភូមិ ៨ ទាំងនេះ គឺ មន្ទភូមិ ខិឌ្ឌាភូមិ បទវីមំសភូមិ ឧជុគតភូមិ សេក្ខភូមិ សមណភូមិ ជិនភូមិ បន្នភូមិ ជាបុរិសភូមិ ។

ក្នុងភូមិ ៨ នោះ តាំងពីថ្ងៃប្រសូតមក ក្នុង ៧ ថ្ងៃ សត្វទាំងឡាយនៅវង្វេង ព្រោះចេញមកពីទីចង្អៀត គ្រូមក្ខលិគោសាល ហៅមនុស្សភូមិនេះថា មន្ទភូមិ ។

ចំណែកអ្នកដែលមកពីទុគ្គតិ រមែងបញ្ចេញសម្លេងស្រែកយំរឿយៗ អ្នកដែលមកចាកពីសុគតិ រឭកដល់សុគតិនោះរឿយៗ រមែងសើច នេះឈ្មោះថា ខិឌ្ឌាភូមិ ។

ក្មេងដែលចាប់ដៃ ឬជើងរបស់មាតាបិតា ឬចាប់គ្រែ ឬតាំងយោលគ្រវីជើងលើផែនដី ឈ្មោះថា បទវីមំសភូមិ ។

ក្មេងក្នុងវេលាដែលអាចដើរបាន ឈ្មោះថា ឧជុគតភូមិ ។

ក្នុងវេលាសិក្សាសិល្បៈទាំងឡាយ ឈ្មោះថា សេក្ខភូមិ ។

ក្នុងវេលាចេញចាកផ្ទះបួស ឈ្មោះថា សមណភូមិ ។

ក្នុងវេលាដែលគប់រកអាចារ្យហើយដឹងវិជ្ជា ឈ្មោះថា ជិនភូមិ ។ សមណៈដែលមិនបានស្វាធ្យាយ ហៅថា បន្នភូមិ ដូចដែលពោលទុកថា ភិក្ខុក្តី ពួកបន្នកៈ ឬជិនៈក្តី មិនពោលសូមអ្វីៗ ។

បទថា ឯកូនបញ្ញាស អាជីវកសតេ ពួកអាជីវកៈទាំង ១៤៩ បានដល់ ការប្រព្រឹត្តរបស់អាជីវក ៤,៩០០ ។

បទថា បរិព្វាជកសតេ បានដល់ បរិព្វាជកដែលបព្វជ្ជាមួយរយពួក ។

បទថា នាគវាសសតេ បានដល់ មណ្ឌលរបស់នាគមួយរយមណ្ឌល ។

បទថា វីសេ ឥន្ទ្រិយសតេ បានដល់ ឥន្ទ្រិយ ១២០ ។

បទថា តឹសេ និរិយសតេ បានដល់ នរក ១៣០ ។

ដោយបទថា រជោធាតុយោ លោកពោលសំដៅយកឋានដែលប្រឡាក់ប្រឡូសធូលី មានខ្នងដៃខ្នងជើងជាដើម ។

ដោយបទថា សត្តសញ្ញីគព្ភា លោកពោលសំដៅយក អូដ្ឋ គោ លា ពពែ សត្វបិញ្ចឹម ម្រឹគ ក្របី ។

ដោយបទថា សត្តអសញ្ញីគព្ភា លោកពោលសំដៅយកស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រូវស្រងែ ថ្ពៅ ស្កួយ និងស្មៅកេលលក ។

ដោយបទថា និគ្គណ្ឋិគព្ភា លោកពោលសំដៅយកពូជដែលដុះត្រង់ថ្នាំង មានអំពៅ ឫស្សី និងបបុសជាដើម[1] ។

ដោយបទថា សត្តទេវា លោកពោលថា ទេវតាចំនួនច្រើន ។ តែគ្រូមក្ខលិគោសាលហៅថា សត្វ ។ សូម្បីមនុស្សទាំងឡាយដែលមិនមានទីបំផុត គ្រូមក្ខលិគោសាល ក៏ហៅថា សត្វ ។

ដោយបទថា សត្តបិសាចា គ្រូមក្ខលិគោសាលពោលថា ពួកសត្វធំៗ ឈ្មោះថា បិសាច ។

ដោយបទថា សរា បានដល់ ស្រះធំ ។ គ្រូមក្ខលិគោសាលពោលបញ្ជាក់ស្រះឈ្មោះកណ្ណមុណ្ឌកៈ ស្រះឈ្មោះរថការៈ ស្រះឈ្មោះអនោត្តតៈ ស្រះឈ្មោះសីហបបាតៈ ស្រះឈ្មោះឆទ្ទន្ត ស្រះឈ្មោះមន្ទាកិនី និងស្រះឈ្មោះកុណាលៈ ។

បទថា បវុដា បានដល់ បំពង់ផ្សែង (ឬអំផូង)។

បទថា បបាតា បានដល់ ជ្រោះធំ ។

បទថា បបាតសតានិ បានដល់ ជ្រោះតូចទាំងរយ ។

បទថា សុបិនា បានដល់ យល់សប្តិធំ ។

បទថា សុបិនសតានិ បានដល់ យល់សប្តិតូច ទាំងរយសុបិន ។

បទថា មហាកប្បិនោ បានដល់ មហាកប្ប ។

ក្នុងបទថា មហាកប្បិនោ នោះ គ្រូមក្ខលិគោសាលពោលថា គ្រប់ៗ រយឆ្នាំ អ្នកនាំទឹកតំណក់មួយទៅពីស្រះធំប្រមាណប៉ុណ្ណេះ ដោយចុងស្បូវ ធ្វើស្រះទឹកនោះឲ្យមិនមានទឹក ៧ ដង ជាមហាកប្បមួយ ។ មហាកប្បបែបនេះអស់ទៅ ៨ លាន ៤ សែនមហាកប្ប ទាំងអ្នកល្ងង់ទាំងអ្នកឆ្លាត រមែងអស់ទុក្ខបាន ។ នេះជាលទ្ធិរបស់គ្រូមក្ខលិគោសាល ។

បានឮថា សូម្បីបណ្ឌិតក៏មិនអាចបរិសុទ្ធិក្នុងចន្លោះបាន ។ សូម្បីជនពាលក៏មិនហួសកាលយូរនោះទៅបាន ។

បទថា សីលេន បានដល់ ដោយសីលអចេល ឬសីលដទៃណាមួយ ។

បទថា វត្តេន បានដល់ ដោយវត្តដូច្នោះឯង ។

បទថា តបេន បានដល់ ដោយការបំពេញតបៈ ។

អ្នកណាបរិសុទ្ធិក្នុងរវាងពាក់កណ្ដាល ដោយសម្គាល់ថា យើងជាបណ្ឌិត អ្នកនោះឈ្មោះថា បួម វត្ថុដែលមិនមានដែលលោកថា នឹងធ្អិនបាន ។

អ្នកណាកន្លងហួសវេលាដែលកំណត់ទុកថា យើងនៅល្ងង់ណាស់ អ្នកនោះឈ្មោះថា សម្ផស្សពាល់ត្រូវកម្មដែលផ្ដល់ផលហើយ ធ្វើឲ្យអស់បំផុតបាន ។

បទថា ហេវំ នត្ថិ បានដល់ មិនមានយ៉ាងនេះ ។ ដោយថា គ្រូមក្ខលិគោសាល រមែងសម្តែងទាំង ២ យ៉ាងនោះថា មិនអាចធ្វើបាន ។

បទថា ទោណមិតេ បានដល់ ដូចវាល់ដោយនាឡិ ។

បទថា សុខទុក្ខេ បានដល់ សុខ និងទុក្ខ ។

បទថា បរិយន្តកតេ បានដល់ ធ្វើទីបំផុតតាមកាល មានប្រមាណដូចពោលហើយ ។

បទថា នត្ថិ ហាយនវឌ្ឍនេ បានដល់ មិនមានសេចក្តីសាបសូន្យ និងសេចក្តីចម្រើន ។ អធិប្បាយថា សង្សារវដ្តមិនបានសាបសូន្យដល់បណ្ឌិត មិនបានចម្រើនដល់ជនពាល ។

បទថា ឧក្កំសាវក្កំសេ បានដល់ ខ្ពស់ និងទាប បទនេះជាវេវចនៈរបស់សេចក្តីសាបសូន្យ និងសេចក្តីចម្រើន ។

ឥឡូវនេះ កាលនឹងញុំាងសេចក្តីនោះឲ្យសម្រេចដោយឧបមា គ្រូមក្ខលិគោសាលទើបពោលថា សេយ្យថាបិ នាម ជាដើម ។

ក្នុងព្រះបាលីនោះ បទថា សុត្តគុលេ បានដល់ សំណុំអំបោះដែលគេមូរទុក ។

ដោយបទថា និព្វេឋិយមានមេវ បលេតិ គ្រូមក្ខលិគោសាលសម្តែងថា ហួសកាលដែលពោលហើយ មិនមានអ្នកណានឹងទៅបាន ឧបមាដូចអ្នកឈរលើភ្នំ ឬចុងឈើ បោះសំណុំអំបោះឲ្យរលាចេញទៅតាមប្រមាណ

របស់អំពោះ កាលអំពោះអស់ហើយ អំពោះក៏ឈប់ត្រង់នោះ មិនទៅទៀត ដូច្នោះ ។

## ពណ៌នា អជិតកេសកម្ពល

[៩៦] ក្នុងវាទៈរបស់គ្រូអជិតកេសកម្ពល មានវិនិច្ឆ័យដូចតទៅនេះ ៖

ដោយពាក្យថា នត្ថិ ទិន្នំ គ្រូអជិតកេសកម្ពល ពោលសំដៅយកសេចក្ដីគ្មានផលរបស់ទានដែលឲ្យហើយ ។

ការបូជាធំ ហៅថា យិដ្ឋ ។

បទថា ហុតំ បំណងយកសក្ការៈដែលល្មមគ្រប់គ្រាន់ ។

ទាំង ២ ប្រការនោះ គ្រូអជិតកេសកម្ពលបដិសេធទៅដល់ការគ្មានផលតែម្យ៉ាង ។

បទថា សុកតទុក្កដានំ សេចក្ដីថា កម្មដែលធ្វើល្អ ធ្វើអាក្រក់ បានដល់ កុសល ។

ដោយបទថា ផលំ វិបាកោ គ្រូអជិតកេសកម្ពលពោលថា វត្ថុណាដែលហៅថាផលក្ដី ថាវិបាកក្ដី វត្ថុនោះមិនមាន ។

បទថា នត្ថិ អយំ លោកោ សេចក្ដីថា លោកនេះមិនមានសម្រាប់អ្នកដែលរស់នៅលោកដទៃ ។

បទថា នត្ថិ បរលោកោ សេចក្ដីថា លោកដទៃមិនមាន សូម្បី

សម្រាប់អ្នកដែលរស់នៅលោកនេះ ។

គ្រូអជិតកេសកម្ពលសម្តែងថា សត្វគ្រប់ជំពូក រមែងដាច់សូន្យក្នុងភពនោះៗ ឯង ។

ដោយបទថា នត្ថិ មាតា នត្ថិ បិតា គ្រូអជិតកេសកម្ពលពោលសំដៅដល់សេចក្តីគ្មានផលនៃការបដិបត្តិត្រូវ និងការបដិបត្តិខុសក្នុងមាតាបិតាទាំងនោះ ។

ដោយបទថា នត្ថិ សត្តា ឱបបាតិកា គ្រូអជិតកេសកម្ពល ពោលថាឈ្មោះថា សត្វដែលចុតិហើយឧប្បត្តិ មិនមាន ។

បទថា ចាតុម្មហាភូតិកោ បានដល់ សម្រេចដោយមហាភូតរូប ៤ ។

បទថា បឋវី បឋវីកាយំ បានដល់ បឋវីធាតុដែលជាខាងក្នុងជាប់តាមបឋវីធាតុដែលជាខាងក្រៅ ។

បទថា អនុបេតិ ប្រែថា ជាប់តាម ។

បទថា អនុបគច្ឆតិ ជាវេវចនៈរបស់បទថា អនុបេតិ ន៉ុះឯងសេចក្តីថា អនុគច្ឆតិ ដូច្នេះក៏មាន ។ ដោយបទទាំង ២ គ្រូអជិត-កេសកម្ពលសម្តែងថា ឧបេតិ ឧបគច្ឆតិ ។

សូម្បីក្នុងអាបោធាតុជាដើម ក៏មានន័យនេះ ។

បទថា ឥន្ទ្រិយានិ បានដល់ ឥន្ទ្រិយទាំងឡាយ មានចិត្តជាទី ៦ រមែងស្ទុះទៅកាន់អាកាស ។

បទថា អាសន្ទិបញ្ចមា បានដល់ មានគ្រែជាគម្រប់ ៥ , អធិប្បាយថា គ្រែ និងបុរស ៤ នាក់ ដែលឈរកាន់ជើងគ្រែទាំង ៤ ។

បទថា យាវា ឡាហនា បានដល់ ព្រៃស្មសាន ។

បទថា បទានិ បានដល់ បទសម្តែងគុណ និងទោស ដែលប្រព្រឹត្តទៅក្នុងន័យជាដើមថា អ្នកនេះ ជាអ្នកមានសីលយ៉ាងនេះ ជាអ្នកទ្រុស្តសីលយ៉ាងនេះ ។ម្យ៉ាងទៀត សរីរៈនុ៎ះឯង ទ្រង់បំណងយកថា បទានិ ក្នុងបទថា បទានិ នេះ ។

បទថា កាបោតកានិ បានដល់ ជើងគ្រែពណ៌ដូចសត្វព្រាប ។ អធិប្បាយថា មានពណ៌ដូចចំពុះព្រាប ។

បទថា ភស្សន្តា បានដល់ មានផេះជាទីបំផុត ។

ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។

បទថា ហុតិយោ បានដល់ ទានដែលបុគ្គលឲ្យហើយ ផ្សេងដោយរបស់ទទួលភ្ញៀវជាដើម យ៉ាងណា ទាននោះទាំងអស់ រមែងមានផេះជាទីបំផុតប៉ុណ្ណោះ មិនឲ្យផលច្រើនជាងនោះ ។

បទថា ទត្តុបញ្ញត្តំ បានដល់ ទានដែលមនុស្សល្ងង់ខ្លៅបញ្ញត្តិ ទុក , អធិប្បាយថា ទាននេះ បុគ្គលល្ងង់ គឺ អ្នកមិនមានបញ្ញាបញ្ញត្តិទុក មិនមែនបណ្ឌិតបញ្ញត្តិ គ្រូអជិតកេសកម្ពលសម្តែងថា អ្នកល្ងង់ឲ្យទាន អ្នកឆ្លាតទទួលទាន ។

បណ្ដាគ្រូទាំង ៦ នោះ បូរណៈប្រកាសថា កាលធ្វើបាប ក៏មិនជាការធ្វើ ឈ្មោះថា រមែងបដិសេធកម្ម ។

អជិតៈប្រកាសថា ព្រោះកាយបែកធ្លាយ សត្វរមែងដាច់សូន្យ ឈ្មោះថា បដិសេធវិបាក ។

មក្ខលិពោលថា មិនមានហេតុ ឈ្មោះថា បដិសេធទាំងកម្ម និងវិបាកទាំង ២ ។

ក្នុងសេចក្ដីនោះ សូម្បីកាលបដិសេធកម្ម ក៏ឈ្មោះថា បដិសេធវិបាកផង ។ សូម្បីកាលបដិសេធវិបាក ក៏ឈ្មោះថា បដិសេធកម្មផង ។ ដូច្នោះ មេលទ្ធិសូម្បីទាំងអស់នោះ ពោលដោយអត្ថ គឺ បដិសេធទាំងកម្ម ទាំងវិបាករបស់កម្មទាំង ២ រមែងជាអហេតុកវាទៈផង ជាអកិរិយ-វាទៈផង ជានត្ថិកវាទៈផង ។

ក៏បុគ្គលពួកណាកាន់លទ្ធិរបស់មេលទ្ធិទាំងនោះ អង្គុយស្វាធ្យាយពិចារណាក្នុងទីសម្រាកពេលយប់ ក្នុងទីសម្រាកពេលថ្ងៃ បុគ្គលទាំងនោះរមែងមានមិច្ឆាសតិផ្ដោតចិត្តនៅក្នុងអារម្មណ៍នោះថា ធ្វើបាបមិនមែនជាការធ្វើ ហេតុមិនមាន បច្ច័យមិនមាន សត្វស្លាប់ហើយដាច់សូន្យ ដូច្នេះ រមែងមានចិត្តតម្កល់មាំ ជវនៈទាំងឡាយ រមែងស្ទុះទៅ ក្នុងបឋមជវនៈនៅល្មមជួយកែបាន ។ ក្នុងជវនៈទី ២ ជាដើមក៏ដូចគ្នា ។ លុះតម្កល់មាំក្នុងជវនៈទី ៧ សូម្បីព្រះពុទ្ធច្រើនអង្គ ក៏ទ្រង់ជួយកែមិនបាន មានការមិន

ត្រឡប់ជាធម្មតា ដូចសាមណេរអរិដ្ឋៈ និងភិក្ខុកណ្ដកៈ ។

ក្នុងនិយតមិច្ឆាទិដ្ឋិទាំង ៣ នោះ អ្នកខ្លះស្កងចុះកាន់តែមួយទស្សនៈ អ្នកខ្លះពីរទស្សនៈ អ្នកខ្លះបីទស្សនៈក៏មាន កាលស្កងចុះទៅក្នុងតែមួយទស្សនៈក្តី ក្នុងពីរ ឬបីទស្សនៈក្តី រមែងជានិយតមិច្ឆាទិដ្ឋិ ហាមផ្លូវសួគ៌ និងហាមផ្លូវនិព្វាន មិនគួរទៅសួគ៌ សូម្បីក្នុងភពដែលជាប់តគ្នានោះ នឹងពោលទៅថ្វីដល់និព្វានហ្ន៎ សត្វនេះឈ្មោះថា ជាបាទវដ្ដៈ ជាអ្នកនៅចាំផែនដី ដោយច្រើនអ្នកមានទិដ្ឋិបែបនេះ ចេញចាកភពមិនបាន ។

ព្រោះដូច្នោះ ៖

**បណ្ឌិតអ្នកឃើញប្រយោជន៍ ប្រាថ្នាសេចក្តីចម្រើន**
**គប្បីវៀរអកល្យាណបុថុជ្ជនឲ្យឆ្ងាយ ដូចអ្នកវៀរ**
**ឆ្ងាយពីក្បាលពស់ដែលមានពិសកាច ដូច្នោះ ។**

## ពណ៌នា បកុទ្ធកច្ចាយន

**[៩៧] ក្នុងវាទៈរបស់គ្រូបកុទ្ធកច្ចាយនៈ មានវិនិច្ឆ័យដូចតទៅនេះ**

បទថា អកដា ប្រែថា មិនមានអ្នកណាធ្វើ ។

បទថា អកដវិធា ប្រែថា មិនមានវិធីដែលអ្នកណាធ្វើទុក , អធិប្បាយថា សូម្បីឲ្យអ្នកណាៗ ធ្វើ ថាចូរធ្វើយ៉ាងនេះ ក៏មិនជាការធ្វើ ។

បទថា អនិម្មិតា បានដល់ មិនមានអ្នកណានិម្មិត សូម្បីដោយឫទ្ធិ ។

បទថា អនិម្មាតា បានដល់ មិនមាន អ្នកណាឲ្យនិម្មិត ។ អាចារ្យពួកខ្លះពោលបទថា អនិម្មាបេតព្វា បទនោះ មិនប្រាកដក្នុងបាលីនិងក្នុងអដ្ឋកថា ។

បីបទមានបទថា វញ្ឈា ជាដើម មានសេចក្ដីដូចពោលហើយនុ៎ះឯង ។

បទថា ន ឥញ្ជន្តិ សេចក្ដីថា មិនញាប់ញ័រ ព្រោះតាំងមាំដូចសសរខឿន ។

បទថា នវិបរិណាមន្តិ បានដល់ មិនលះប្រក្រតី ។

បទថា នអញ្ញមញ្ញំ ព្យាពាធេន្តិ បានដល់ មិនប៉ះខ្ទប់គ្នានិងគ្នា ។

បទថា នាលំ បានដល់ មិនអាច ។

ក្នុងបទថា បថវីកាយោ ជាដើម បានដល់ គំនរដី ឬដីរួមគ្នា ក៏គឺដីនុ៎ះឯង ។

បទថា តត្ថ បានដល់ ក្នុងកាយដែលមានជីវៈជាទី ៧ ទាំងនោះ ។

បទថា សត្តន្នំយេវ កាយានំ សេចក្ដីថា សស្ត្រារមែងចូលទៅតាមចន្លោះ គឺ ប្រហោងរបស់កាយទាំង ៧ ដូចយ៉ាងសស្ត្រាដែលកាប់ទៅក្នុងគំនរសណ្ដែកបាយជាដើម រមែងចូលទៅ តាមចន្លោះសណ្ដែកបាយ

ជាដើមដូច្នោះ ។ គ្រូបកុទ្ធកច្ចាយនៈពោលថា ក្នុងសត្វនិកាយនោះ មាន ត្រឹមតែសញ្ញាថា យើងនឹងផ្តាច់សត្វនេះចាកជីវិតតែម្យ៉ាងប៉ុណ្ណោះ (មិន មែនជាការផ្តាច់ជីវិតទេ) ។

## ពណ៌នា និគណ្ឋនាដបុត្ត

**[៩៨] ក្នុងវាទៈរបស់និគ្រន្ថនាដបុត្ត មានវិនិច្ឆ័យដូចតទៅនេះ ៖**

បទថា ចាតុយាមសំវរសំវុតោ សេចក្តីថា សង្រួមទាំង ៤ ផ្នែក ។ បទថា សព្វវារិវារិតោ ច សេចក្តីថា ជាអ្នកហាមទឹកទាំងពួង , អធិប្បាយថា ជាអ្នកហាមទឹកត្រជាក់ទាំងអស់ ។

បានឮថា គ្រូនិគ្រន្ថនាដបុត្រនោះ យល់ថា ទឹកត្រជាក់មានសត្វ មានជីវិត ដូច្នោះ ទើបមិនប្រើទឹកត្រជាក់នោះ ។

បទថា សព្វវារិយុត្តោ បានដល់ ប្រកបដោយគ្រឿងរាំងបាប ទាំងពួង ។

បទថា សព្វវារិធុតោ បានដល់ កម្ចាត់បាបដោយគ្រឿងរាំងបាប ទាំងពួង ។

បទថា សព្វវារិផុដ្ឋោ បានដល់ ដែលគ្រឿងរាំងបាបទាំងពួង ពាល់ត្រូវហើយ ។

បទថា គតត្តោ បានដល់ មានចិត្តដល់ ទីបំផុត ។

បទថា យតត្តោ បានដល់ មានចិត្តសង្រួមហើយ ។

បទថា ឋិតត្តោ បានដល់ មានចិត្តតាំងមាំល្អហើយ ។

ក្នុងវាទៈរបស់គ្រូនិគ្រន្ថនាដបុត្រនេះ មានចំណែកខ្លះដែលចូលគ្នានឹងសាសនាបានខ្លះ ។ តែព្រោះជាលទ្ធិមិនបរិសុទ្ធិ ទើបកើតជាទិដ្ឋិទាំងអស់ទៀយ ។

## ពណ៌នា សញ្ជយវេលដ្ឋបុត្ត

[៩៩] *វាទៈរបស់គ្រូសញ្ជ័យវេលដ្ឋបុត្រ* មានន័យដូចពោលហើយក្នុងអមរាវិក្ខេបវាទៈ (ក្នុងព្រហ្មជាលសូត្រ) នុ៎ះឯង ។

## បឋមសន្ទិដ្ឋិកសាមញ្ញផល

[១០០] បទថា សោហំ ភន្តេ ជាដើម សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានសារៈក្នុងវាទៈរបស់តិរ្ថិយទាំងឡាយ ដូចជាម្ចាស់ ខ្សាច់មិនបានប្រេង ទើបសូមទូលសួរព្រះមានព្រះភាគ ។

បទថា យថា តេ ខមេយ្យ សេចក្តីថា តាមដែលពេញព្រះទ័យ ។

បទថា ទាសោ បានដល់ ទាសៈក្នុងផ្ទះ ទាសៈដែលទិញមកដោយទ្រព្យ ទាសៈដែលជាឈ្លើយសឹក និងទាសៈដែលស្ម័គ្រជាទាសៈដោយខ្លួនឯង ណាមួយ ។

បទថា កម្មការោ បានដល់ មិនខ្ជិលច្រអូស ធ្វើការងារជានិច្ច ។

ឈ្មោះថា បុព្វុដ្ឋាយី ដោយអត្ថថា សូម្បីឃើញចៅហ្វាយមកពីចម្ងាយ ក្រោកឡើងមុនក្លាយ ។

ឈ្មោះថា បច្ឆានិបាតី ដោយអត្ថថា ក្រោកឡើងយ៉ាងនេះហើយ ក្រាលអាសនៈឲ្យចៅហ្វាយ ធ្វើកិច្ចដែលគួរធ្វើ មានលាងជើងជាដើម ហើយទើបសម្រាក គឺ ដេកក្នុងខាងក្រោយ ។

ន័យមួយទៀត ឈ្មោះថា បុព្វុដ្ឋាយី ដោយអត្ថថា ក្រោកឡើងមុន កាលចៅហ្វាយមិនទាន់ក្រោកចាកទីដេក ។

ឈ្មោះថា បច្ឆានិបាតី ដោយអត្ថថា ធ្វើកិច្ចទាំងពួងតាំងពីព្រឹក

ព្រលឹម ផកាបដល់ចៅហ្វាយចូលដេកក្នុងរាត្រី ខ្លួនទើបសម្រាក គឺ ដេក ក្នុងខាងក្រោយ ។

ឈ្មោះថា កឹការបដិស្សាវី ដោយអត្ថថា នៅរង់ចាំស្តាប់បញ្ជា នឹងឲ្យធ្វើអ្វី ដោយតាំងចិត្តយ៉ាងនេះថា យើងនឹងធ្វើអ្វី ។

ឈ្មោះថា មនាបចារី ដោយអត្ថថា ធ្វើតែកិរិយាដែលគួរពេញ ចិត្តប៉ុណ្ណោះ ។

ឈ្មោះថា បិយវាទី ដោយអត្ថថា និយាយតែពាក្យដែលគួរឲ្យ ស្រឡាញ់ប៉ុណ្ណោះ ។

ឈ្មោះថា មុខមុល្លិកោ ដោយអត្ថថា ចាំមើលមុខនាយចៅហ្វាយ ដែលស្រស់ថ្លារីកពាយ ។

បទថា ទេវោ មញ្ញេ បានដល់ ដូចទេវតា ។

បទថា សោ វតស្សាហំ បុញ្ញានិ ករេយ្យំ សេចក្តីថា សូម្បី យើងនោះឯង ក៏គប្បីជាស្តេចផែនដីដូចអង្គនេះ បើយើងធ្វើបុណ្យទាំង ឡាយ ។

បាឋៈថា សោ វតស្សាយំ ដូច្នេះក៏មាន សេចក្តីក៏យ៉ាងនេះដូចគ្នា ។

ដោយបទថា យន្នូនាហំ សម្តែងការគិតយ៉ាងនេះថា បើយើងនឹង ឲ្យទានសូម្បីរហូតដល់អស់ជីវិត យើងក៏មិនអាចឲ្យសូម្បីត្រឹមតែមួយភាគ របស់ទាន ដែលព្រះរាជាព្រះរាជទានក្នុងមួយថ្ងៃបាន ទើបធ្វើឧស្សាហ៍

ក្នុងបព្វជ្ជា ។

បទថា កាយេន សំវុតោ បានដល់ សង្រួមកាយ បិទទ្វារមិនឲ្យអកុសលចូលទៅបាន ។

សូម្បីក្នុង ២ បទ ដ៏សេសក៏ន័យនេះឯង ។

បទថា ឃាសច្ឆាទនបរមតាយ សេចក្តីថា ដោយមានអាហារនិងគ្រឿងស្លៀកដណ្តប់យ៉ាងក្រៃលែង គឺ យ៉ាងប្រសើរ ។ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការបួសនេះពិតៗ ទើបលះអនេសនា សន្តោសដោយសល្លេខបដិបត្តិ ដ៏កំពូល ។

បទថា អភិរតោ បវិវេកេ សេចក្តីថា ត្រេកអរក្នុងវិវេក ៣ យ៉ាងដែលលោកពោលទុកយ៉ាងនេះថា កាយវិវេកសម្រាប់អ្នកដែលមានកាយចៀសចេញ ដើម្បីសេចក្តីស្ងាត់ ១ ចិត្តវិវេកសម្រាប់អ្នកដែលត្រេកអរការចេញចាកកាម ដល់ភាពផូរផង់យ៉ាងក្រៃលែង ១ ឧបធិវិវេក សម្រាប់បុគ្គលអស់កិលេស អស់គ្រឿងតាក់តែង ១ លះសេចក្តីច្របូកច្របល់ដោយពួក ពួនសម្ងំនៅតែម្នាក់ឯង លះកលល្បិចអាក្រក់ដោយកិលេសផ្សំចិត្ត នៅតែម្នាក់ឯង ដោយអំណាចសមាបត្តិ ៨ ចូលផលសមាបត្តិឬនិរោធសមាបត្តិ ហើយសម្រេចព្រះនិព្វាន ។

បទថា យគ្ឃេ ជានិបាត ប្រើក្នុងអត្ថថា ដាស់តឿន ។

បទថា អាសនេនបិ និមន្តេយ្យាម សេចក្តីថា គួរនឹងចាត់អាសនៈ

សម្រាប់អង្គុយ ហើយពោលថា និមន្តអង្គុយលើអាសនៈនេះចុះ ។

បទថា អភិនិមន្តេយ្យាមបិ នំ សេចក្តីថា គួរនឹងអញ្ជើញគេចូលមក ។ ក្នុងសេចក្តីនោះ មានការអញ្ជើញ ២ យ៉ាង គឺ ដោយវាចា ១ ដោយកាយ ១ ។

ពិតហើយ ទាយកដែលពោលថា ខ្ញុំសូមជម្រាបឲ្យជ្រាប លោកត្រូវការវត្ថុណា មានចីវរជាដើម សូមប្រាប់ក្នុងខណៈដែលលោកត្រូវការគ្រប់គ្រា ដូច្នេះ ឈ្មោះថា ការអញ្ជើញឲ្យមកដោយវាចា ។ ចំណែកទាយកដែលសង្កេតឃើញថា ចីវរជាដើមខ្វះខាត ទើបថ្វាយចីវរទាំងនោះ ដោយពោលថា មេត្តាទទួលចីវរនេះ ដូច្នេះ ឈ្មោះថា ការអញ្ជើញចូលមកដោយកាយ ។

លោកពោលថា អភិនិមន្តេយ្យាមបិ នំ សំដៅយកការអញ្ជើញទាំង ២ យ៉ាងនោះ ។

ក៏ថ្នាំជាទីសប្បាយដល់អ្នកជម្ងឺយ៉ាងណាមួយ ឈ្មោះថា គិលានភេសជ្ជបរិក្ខារ ក្នុងទីនេះ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា រក្ខាវរណគុត្តឹ បានដល់ ការឃុំគ្រង ពោលគឺ ការរក្សានិងការការពារ ។

ក៏ការឃុំគ្រង ដែលជាការរក្សា និងការពារនេះ មិនមែនចាត់បុរសកាន់អាវុធឈររក្សាទុក នឹងឈ្មោះថា ឃុំគ្រងជាធម៌ទេ ត្រឹមតែ

ចាត់ការរក្សាមិនឲ្យអ្នករកខុស អ្នករើសស្លឹកឈើជាដើម ចូលទៅក្នុងវិហារក្នុងវេលាដែលមិនសមគួរ ឬមិនឲ្យព្រានម្រឹគជាដើម ចាប់ម្រឹគ ឬត្រីក្នុងវត្ត ក៏ឈ្មោះថា ឃុំគ្រងជាធម៌ ។

លោកពោលថា ធម្មិកំ សំដៅដល់ ការឃុំគ្រងជាធម៌ដូចពោលហើយនោះ ។

បទថា យតោ ឯវំ សន្តេ សេចក្តីថា កាលបើទោសៈរបស់ព្រះអង្គបានទទួលបដិសណ្ឋារៈ មានអភិវាទជាដើម អំពីសំណាក់របស់ព្រះអង្គដូច្នោះ ។

ពាក្យថា អទ្ធា ជាពាក្យកំណត់សេចក្តីចុះទៅក្នុងចំណែកតែមួយ ។

បទថា បឋមំ សេចក្តីថា កាលពោលដល់ទី ១ រមែងសម្តែងថា នៅមានដទៃៗ តទៅ ។

## ទុតិយសន្និដ្ឋិកសាមញ្ញផល

[១០១] ដោយបទថា បឋមំ ទុំះឯង ព្រះរាជាទើបទូលថា សក្កា បន ភន្តេ អញ្ញំបិ ដូច្នេះជាដើម ។

ឈ្មោះថា ជាវិធា ដោយអត្ថថា ក្ជុរស្រែ ។

ឈ្មោះថា គហបតី ដោយអត្ថថា ជាធំក្នុងផ្ទះ គឺ ជាប្រធានត្រឹមតែក្នុងផ្ទះមួយខ្នង ។

ឈ្មោះថា អ្នកឲ្យពន្ធអាករ ដោយអត្ថថា បង់តម្លៃ ពោលគឺធ្វើពលី ។

ឈ្មោះថា ជាអ្នកប្រមូលព្រះរាជទ្រព្យ ដោយអត្ថថា ប្រមូលស្រូវនិងគំនរទ្រព្យ ។

បទថា អប្បំ វា បានដល់ តិច ដោយទីបំផុត សូម្បីត្រឹមតែអង្ករមួយនាឡិ ។

បទថា ភោគក្ខន្ធំ បានដល់ គំនរភោគៈ ។

បទថា មហន្តំ វា បានដល់ បរិបូណ៌ ។

ដើម្បីសម្តែងថា ក៏ការដែលនឹងលះភោគៈច្រើនទៅបួស ធ្វើបានលំបាក យ៉ាងណាភោគៈសូម្បីតិច ក៏លះបង់ទៅបួសបានលំបាក ដូច្នោះទ្រង់ទើបសម្តែងទុកទាំង ២ យ៉ាង ។

ក៏នឹងវិនិច្ឆ័យក្នុងវារៈនៃទាសៈ ព្រោះហេតុដែលទាសៈមិនមានឥស្សរៈចំពោះខ្លួន នឹងចាំបាច់ពោលទៅថ្វីដល់ភោគៈទាំងឡាយ ក៏ទ្រព្យណារបស់ទាសៈនោះ ទ្រព្យនោះក៏ជារបស់នាយចៅហ្វាយនុ៎ះឯង ដូច្នោះទើបមិនបានប្រកាន់ថា ជាភោគៈ ។

សាលោហិតា ក៏គឺ ញាតិនុ៎ះឯង ។

# បណីតតរសាមញ្ញផល

[១០២] ប្រការថា សក្កា បន ភន្តេ អញ្ញម្បិ ទិដ្ឋេ វ ធម្មេ សេចក្តីថា ក្នុងទីនេះព្រះបាទអជាតសត្តុមិនបានទូលថា ឯវមេវ ។ បើនឹងសួរថា ប្រការនោះព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកាលបើព្រះបាទអជាតសត្តុទូលថា ឯវមេវ ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងសាមញ្ញផល ដោយឧបមាទាំងឡាយបែបនោះ រហូតដល់ពេញមួយថ្ងៃ ឬយូរជាងនោះ ដើម្បីឲ្យល្មមដល់ព្រះបាទអជាតសត្តុ ដែលរវល់តែស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះ-ភាគនៅក្នុងទីនោះ មិនមានទីបំផុតដោយពិត ។ សូម្បីយ៉ាងនោះ សេចក្តីក៏មានត្រឹមតែប៉ុណ្ណោះឯង ។ ព្រះបាទអជាតសត្តុមានព្រះតម្រិះដូច្នេះ ដើម្បីនឹងទូលសួរឲ្យវិសេសឡើងទៅ ទើបមិនបានទូលថា ឯវមេវ តែទូលក្រៃលែងឡើងទៅថា អភិក្កន្តតរំ បណីតតរំ ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា អភិក្កន្តតរំ បានដល់ ដែលគួរពេញចិត្តជាង គឺ ប្រសើរក្រៃលែងជាង ។

បទថា បណីតតរំ បានដល់ ខ្ពស់បំផុត ។

បទថា តេនហិ ជានិបាត ប្រើក្នុងអត្ថថា លើកសរសើរ ។

ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់លើកសរសើរក្នុងការស្តាប់ ទើបបានត្រាស់ចំពោះព្រះបាទអជាតសត្តុនោះ យ៉ាងនេះ ។

បទថា សុណោហិ សេចក្តីថា ព្រះអង្គ ចូរស្តាប់សាមញ្ញផលដែលល្អជាង និងប្រណីតជាង ។

ក្នុងបទថា សាធុកំ មនសិករោហិ នេះ ពាក្យថា សាធុកំ និង សាធុ នេះ មានអត្ថដូចគ្នា ។

ក៏ សាធុ សព្ទនេះ ប្រែបានច្រើនយ៉ាង ដូចជា សូមឱកាស ទទួលពាក្យ ធ្វើឲ្យរីករាយ ប្រពៃ និងធ្វើឲ្យមាំជាដើម ។

ដែលប្រែថា **សូមឱកាស** ដូចក្នុងប្រយោគថា សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមឱកាស សូមព្រះមានព្រះភាគ ប្រោសសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ព្រះអង្គ ដូច្នេះជាដើម ។

ដែលប្រែថា **ទទួលពាក្យ** ដូចក្នុងប្រយោគថា សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភិក្ខុនោះ ទទួលពាក្យថា ពិរោះណាស់ព្រះអង្គ ហើយរីករាយអនុមោទនាភាសិត របស់ព្រះមានព្រះភាគ ដូច្នេះជាដើម ។

ដែលប្រែថា **ធ្វើឲ្យរីករាយ** ដូចក្នុងប្រយោគថា សាធុ សាធុ សារីបុត្ត ប្រពៃហើយ ប្រពៃហើយ សារីបុត្ត ដូច្នេះជាដើម ។

ដែលប្រែថា **ប្រពៃ** ដូចក្នុងគាថាជាដើមថា

សាធុ ធម្មរុច រាជា សាធុ បញ្ញាណវា នរោ

សាធុ មិត្តានមន្តុត្ថា ចាបស្សាករណំ សុខំ ។

ព្រះរាជាទ្រង់ធម៌ ទើបប្រពៃ , នរៈមានប្រាជ្ញា ទើបប្រពៃ , ការមិនប្រទូស្តមិត្ត ទើបប្រពៃ , កិរិយាមិនធ្វើបាប ទើបប្រពៃ ។

ដែលប្រែថា **ធ្វើឲ្យមាំ** ដូចក្នុងប្រយោគថា តេនហិ ព្រាហ្មណ សាធុកំ សុណាហិ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរស្តាប់ឲ្យប្រពៃចុះ សាធុកំ សព្ទនោះឯង អ្នកខ្លះប្រែថា បង្គាប់ ក៏មាន ។ សូម្បីក្នុងទីនេះ គប្បីជ្រាបថា ប្រែថា ធ្វើឲ្យមាំនេះឯងផង ប្រែថា បង្គាប់ផង ។ សូម្បីប្រែថា ប្រពៃ ក៏គួរ ។

ពិតហើយ ដោយប្រែថា **ធ្វើឲ្យមាំ** រមែងបំភ្លឺសេចក្តីថា ចូរស្តាប់ធម៌នេះឲ្យមាំ ប្រកាន់ទុកយ៉ាងល្អ ។

ដោយប្រែថា បង្គាប់ រមែងបំភ្លឺសេចក្តីថា **ចូរស្តាប់តាមបង្គាប់** របស់យើង ។

ដោយប្រែថា **ប្រពៃ** រមែងបំភ្លឺសេចក្តីថា ចូរស្តាប់ធម៌ដោយប្រពៃ គឺ ឲ្យបានខ្លឹមសារនៃពាក្យ ឃ្លា សេចក្តី ។

បទថា មនសិករោហិ សេចក្តីថា ចូរនឹក រួបរួម , អធិប្បាយថា ចូរមានចិត្តតម្កល់មាំ ផ្ចៀងសោតៈ តាំងចិត្ត ។

មួយ៉ាងទៀត ពាក្យថា សុណាហិ ក្នុងព្រះបាលីនេះ ជាការហាមសេចក្តីរវើរវាយនៃសោតិន្ទ្រិយ ។

ពាក្យថា សាធុកំ មនសិករោហិ ជាការហាមសេចក្តីរវើរវាយនៃមនិន្ទ្រិយ ដោយប្រកបឲ្យមាំក្នុងមនសិការ ។

ក្នុង ២ ពាក្យនេះ ពាក្យដើមហាមកាន់ព្យញ្ជនៈឃ្លៀងឃ្លាត ពាក្យក្រោយហាមកាន់អត្ថឃ្លៀងឃ្លាត ។

និងដោយពាក្យដើម បបួលឲ្យស្តាប់ធម៌ ដោយពាក្យក្រោយបបួលឲ្យចងចាំ និងរិះគិតធម៌ដែលស្តាប់ហើយជាដើម ។

និងដោយពាក្យដើមសម្តែងថា ធម៌នេះ ដល់ដោយព្រមព្យញ្ជនៈ ព្រោះដូច្នោះ ទើបគួរស្តាប់ ដោយពាក្យក្រោយសម្តែងថា ធម៌នេះ ដល់ព្រមដោយអត្ថ ព្រោះដូច្នោះ ទើបគួរធ្វើទុកក្នុងចិត្តឲ្យល្អ ។

ម្យ៉ាងទៀត បទថា សាធុកំ គប្បីប្រកបដោយបទទាំង ២ (ថា សាធុកំ សុណាហិ សាធុកំ មនសិករោហិ) ។

ព្រោះធម៌នេះ ជ្រៅដោយធម៌ និងជ្រៅដោយទេសនា ដូច្នោះ ទើបត្រូវស្តាប់ឲ្យល្អ និងធម៌នេះ ជ្រៅដោយអត្ថ និងជ្រៅដោយបដិវេធ ដូច្នោះ ទើបត្រូវធ្វើទុកក្នុងចិត្តឲ្យល្អ គប្បីប្រកបសេចក្តីយ៉ាងនេះឯង ។

បទថា ភាសិស្សាមិ សេចក្តីថា តថាគតនឹងសម្តែងសាមញ្ញផលដែលបានបដិញ្ញាទុកយ៉ាងនេះថា អាច មហាបពិត្រ ដូច្នេះ ដោយពិស្តារ ។

បទថា ទេសិស្សាមិ ជាការសម្តែងដោយសង្ខេប ។

បទថា ភាសិស្សាមិ តថាគតនឹងពោល ជាការសម្តែងដោយពិស្តារ ។

ព្រោះហេតុនោះ ព្រះវង្គីសត្ថេរៈទើបពោលថា ៖

ព្រះមានព្រះភាគ ទេសនាដោយសង្ខេបខ្លះ សម្ដែងដោយពិស្ដារខ្លះ ទ្រង់មានព្រះសូរសៀងក្រអាងក្រអៅ ពីរោះ ដូចសំឡេងសាលិកា ព្រមទាំងប្រកបដោយបដិភាណ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះបាទអជាតសត្តុ-វេទេហីបុត្រស្ដេចផែនដីមគធៈ ក៏កើតព្រះឧស្សាហ៍ទទួលព្រះពុទ្ធតម្រាស់ អធិប្បាយថា ទទួលចំពោះហើយ ។

គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះដល់ ព្រះបាទ-អជាតសត្តុនោះ ។ អធិប្បាយថា បានត្រាស់ព្រះសូត្រទាំងអស់ មានពាក្យថា ឥធ មហារាជ ជាដើម ដែលគួរនឹងត្រាស់ក្នុងកាលឥឡូវនេះ ។

បទថា ឥធ ក្នុងព្រះបាលីនោះ ជានិបាតប្រើក្នុងអត្ថថា ទីស្ថាន ។ ឥធ ស័ព្ទនេះ កន្លែងខ្លះលោកពោលសំដៅដល់ **លោក** ដូចដែលពោលថា ព្រះតថាគត កើតឡើងក្នុងលោកនេះ ។

កន្លែងខ្លះសំដៅដល់ សាសនា ដូចទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី១ ក៏មានក្នុងសាសនានេះប៉ុណ្ណោះ សមណៈទី២ ក៏មានក្នុងសាសនានេះ ។

កន្លែងខ្លះសំដៅដល់ **ឱកាស** ដូចដែលពោលថា ៖

កាលដែលអាត្មាអញកើតជាទេវតា ឋិតនៅក្នុងឱកាសនេះ អាត្មា

អញបាននូវអាយុថ្មីទៀត ម្នាលគ្នាយើង អ្នកចូរដឹងយ៉ាងនេះចុះ ។

កន្លែងខ្លះត្រឹមតែជាបទបូរណៈប៉ុណ្ណោះ ដូចដែលត្រាស់ថា ឥធាហំ ភិក្ខវេ ភុត្តាវី អស្មិំ បវារិតោ ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគហើយ ហាមឃាត់ហើយ ។

ក៏ក្នុងទីនេះ គប្បីជ្រាបថា ត្រាស់សំដៅដល់ **លោក** ។

ពាក្យថា **មហារាជ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ហៅថា “មហាបពិត្រ” ទៀត ដើម្បីទ្រង់សម្តែងទេសនាតាមដែលទ្រង់បដិញ្ញាទុក ។ ពាក្យនេះមានអធិប្បាយថា **មហាបពិត្រ** តថាគត រមែងកើតឡើងក្នុងលោកនេះ ជាព្រះអរហន្ត ជាអ្នកវិកហើយ ជាអ្នកចែកព្រះធម៌ ។

**តថាគត** ស័ព្ទ ក្នុងព្រះបាលីនោះ ត្រាស់ទុកក្នុងព្រហ្មជាលសូត្រ ស័ព្ទថា **អរហំ** ជាដើម ពោលទុកក្នុងវិសុទ្ធិមគ្គដោយពិស្តារ ។

ក៏ក្នុងព្រះបាលីថា លោកេ ឧប្បជ្ជតិ ពាក្យថា លោកមាន ៣ យ៉ាង គឺ ឱកាសលោក សត្វលោក សង្ខារលោក ។ តែក្នុងទីនេះទ្រង់បំណងយកសត្វលោក ។ ព្រះតថាគត សូម្បីកាលកើតក្នុងសត្វលោក នឹងបានកើតក្នុងទេវលោក ឬព្រហ្មលោកក៏ទេ រមែងកើតក្នុងមនុស្ស-លោកប៉ុណ្ណោះ ។ សូម្បីក្នុងមនុស្សលោក ក៏មិន កើតក្នុងចក្រវាឡដទៃ រមែងកើតក្នុងចក្រវាឡនេះប៉ុណ្ណោះ ។ សូម្បីក្នុងចក្រវាឡនេះ ក៏មិន កើតក្នុងទីទូទៅ រមែងកើតក្នុងមជ្ឈិមប្រទេស ដោយបណ្តោយ ៣០០

យោជន៍ ដោយទទឹង ២៥០ យោជន៍ដោយជុំវិញ ៩០០ យោជន៍ ដែលលោកកំណត់ទុកយ៉ាងនេះថា ទិសខាងកើត មាននិគមឈ្មោះ **ជង្គល** , បន្ទាប់ពីនិគមឈ្មោះជង្គលៈនោះ មាននិគម ឈ្មោះ **មហាសាល** , បន្ទាប់ពីនោះជា **បច្ចន្តជនបទ** , ខាងក្នុងជា **មជ្ឈិមជនបទ** ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះ **សេតកណ្ណិក** , បន្ទាប់ពីនោះជា **បច្ចន្តជនបទ** , ខាងក្នុងជា **មជ្ឈិមជនបទ** ។ ទិសខាងលិចមាន **ព្រាហ្មណ៍គ្រាម** ឈ្មោះ **ថូនៈ** បន្ទាប់ពិនោះជា **បច្ចន្តជនបទ** , ខាងក្នុងជា **មជ្ឈិជនបទ** ។ ទិសខាងកើត មានភ្នំឈ្មោះ **ឧសីរធជ** , បន្ទាប់ពីនោះជា **បច្ចន្តជនបទ** , ខាងក្នុងជា **មជ្ឈិមជនបទ** ។ និងមិនមែនតែព្រះតថាគតប៉ុណ្ណោះ ព្រះ-បច្ចេកពុទ្ធទាំងឡាយ ព្រះអគ្គសាវកទាំងឡាយ ព្រះអសីតិមហាថេរៈទាំងឡាយ ព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ស្តេចចក្រពត្តិ ព្រាហ្មណ៍ និងគហបតីទាំងឡាយ រមែងកើតក្នុងមជ្ឈិមប្រទេសនេះប៉ុណ្ណោះ ។

ក្នុងពាក្យថា តថាគតោ លោកេ ឧប្បជ្ជតិ នោះ ព្រះតថាគតតាំងពីសោយបាយមធុបាយាស ដែលនាងសុជាតាថ្វាយ រហូតដល់អរហត្ត-មគ្គ ឈ្មោះថា **រមែងឧប្បត្តិ** , កាលសម្រេចអរហត្តផល ឈ្មោះថា **ឧប្បត្តិហើយ** ឬថា តាំងពីមហាភិនេស្រ្កម៍ រហូតដល់អរហត្តមគ្គ ឬថា តាំងពីកពជាន់តុសិត រហ៊ូតដល់អរហត្តមគ្គ ឬថា តាំងពីបាទមូលរបស់ព្រះពុទ្ធទីបង្ករ រហូតដល់អរហត្តមគ្គ ឈ្មោះថា **រមែងឧប្បត្តិ** , កាល

សម្រេចអរហត្តផល ឈ្មោះថា **ឧប្បត្តិហើយ** ។ ពាក្យថា ឧប្បជ្ជតិ ក្នុងព្រះបាលីនេះ លោកពោលសំដៅយកការៈដែលឧប្បត្តិហើយមុនទាំងអស់ ។ ក៏ក្នុងទីនេះមានសេចក្តីដូច្នេះថា ព្រះតថាគតឧប្បត្តិហើយក្នុងលោក ។

បទថា សោ ឥមំ លោកំ សេចក្តីថា ព្រះមានព្រះភាគនោះ ទ្រង់ធ្វើលោកនេះឲ្យច្បាស់ ។ ឥឡូវនេះ នឹងសម្តែងពាក្យដែលគួរពោល ។

បទថា សទេវកំ សេចក្តីថា ព្រមទាំងទេវតាទាំងឡាយ ឈ្មោះសទេវកៈ នឹងមារ ឈ្មោះសមារកៈ តែម្យ៉ាងដូចគ្នានិងព្រហ្ម ឈ្មោះសព្រហ្មកៈ នឹងសមណព្រាហ្មណ៍ទាំងឡាយ ឈ្មោះ សស្សមណព្រាហ្មណី ។ ឈ្មោះពួកសត្វ ព្រោះកើតទូទៅ ដែលពួកសត្វនោះ និងទេវតា និងមនុស្សទាំងឡាយ ឈ្មោះសទេវមនុស្សៈ ។

ក្នុងបទទាំងនោះ ដោយពាក្យថា សទេវកៈ គប្បីជ្រាបថា កាន់យកកាមាវចរទេព ៥ ជាន់ ។ ដោយពាក្យថា សមារកៈ គប្បីជ្រាបថា កាន់យកកាមាវចរទេពជាន់ទី ៦ ។ ដោយពាក្យថា សព្រហ្មកៈ កាន់យកព្រហ្ម មានជាន់ព្រហ្មកាយិកៈជាដើម ។ ដោយពាក្យថា សស្សមណព្រាហ្មណី កាន់យកសមណព្រាហ្មណ៍ ដែលជាសត្រូវ និងបច្ចាមិត្តចំពោះព្រះសាសនា និងកាន់យកសមណព្រាហ្មណ៍ដែលរម្ងាប់បាប បណ្តេតបាបបានហើយ ។ ដោយពាក្យថា **បជា** កាន់យកសត្វលោក ។ ដោយ

ពាក្យថា សទេវមនុស្សៈ កាន់យកសម្មតិទេព និងមនុស្សដ៏សេស ។

ដោយបទ ៣ បទ ក្នុងទីនេះ គប្បីជ្រាបថា លោកកាន់យកសត្វលោក និងឱកាសលោក ។ ចំពោះសត្វលោក ទ្រង់កាន់យកដោយពាក្យថា **បជា** ដោយបទទាំង ២ ដោយប្រការដូច្នេះ ។

ន័យមួយទៀត ដោយស័ព្ទថា សទេវកៈ ទ្រង់កាន់យកអរូបាវចរទេវលោក ។ ដោយស័ព្ទថា សមារកៈ ទ្រង់កាន់យកឆកាមាវចរទេវលោក ។ ដោយស័ព្ទថា សព្រហ្មកៈ ទ្រង់កាន់យករូបព្រហ្មទេវលោក ។ ដោយស័ព្ទថា សស្សមណព្រាហ្មណីជាដើម ទ្រង់កាន់យកមនុស្សលោក និងសម្មតិទេពទាំងឡាយ ជាបរិស័ទ ៤ ឬកាន់យកសត្វលោកទាំងអស់ដ៏សេស ។

ម្យ៉ាងទៀត ក្នុងបទទាំងនេះ ដោយពាក្យថា សទេវកៈ លោកពោលដល់ព្រះមានព្រះភាគ ដែលទ្រង់ធ្វើលោកទាំងពួងឲ្យច្បាស់ ដោយការកំណត់យ៉ាងខ្ពស់ ។ លំដាប់នោះ ជនពួកណាមានសេចក្តីគិតថា វសវត្តីមារ អ្នកមានអានុភាពច្រើន ជាធំក្នុងសួគ៌ជាន់កាមាវចរ ។ វសវត្តីមារនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យច្បាស់ដែរឬ ។ កាលនឹងកម្ចាត់សេចក្តីសង្ស័យរបស់ជនទាំងនោះ ទ្រង់ទើបត្រាស់ថា សមារកំ ដូច្នេះ ។

ក៏ជនពួកណា មានសេចក្តីគិតថា ព្រហ្មដែលមានអានុភាពធំ

ផ្សាយពន្លឺទៅក្នុងពាន់ចក្រវាឡដោយមួយអង្គុលី..... ដោយ ២ អង្គុលី ផ្សាយពន្លឺទៅក្នុងមួយចក្រវាឡដោយ ១០ អង្គុលី និងសោយសុខក្នុងឈានសមាបត្តិដ៏កំពូល ព្រហ្មនោះ ព្រះមានព្រះភាគទ្រង់ធ្វើឲ្យច្បាស់ដែរឬ កាលនឹងកម្ចាត់សេចក្ដីសង្ស័យរបស់ជនទាំងនោះ ទើបទ្រង់ត្រាស់ពោលថា សព្រហ្មកំ ដូច្នេះ ។

លំដាប់នោះ ជនពួកណាគិតថា សមណព្រាហ្មណ៍ជាច្រើន ដែលជាសត្រូវចំពោះព្រះសាសនា សមណព្រាហ្មណ៍ទាំងនោះ ព្រះមានព្រះភាគទ្រង់ធ្វើឲ្យច្បាស់ដែរឬ កាលនឹងកម្ចាត់សេចក្ដីសង្ស័យរបស់ជនទាំងនោះ ទ្រង់ទើបត្រាស់ថា សស្សមណព្រាហ្មណឹ បជំ ដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់ប្រកាសសេចក្ដីដែលព្រះអង្គទ្រង់ធ្វើឋានៈដាន់ខ្ពស់ទាំងឡាយឲ្យច្បាស់ហើយ លំដាប់នោះ កាលនឹងទ្រង់ប្រកាសសេចក្ដីដែលព្រះអង្គទ្រង់ធ្វើសត្វលោកដ៏សេស រហូតដល់ថ្នាក់សម្មតិទេព និងមនុស្សដ៏សេសទាំងឡាយ ដោយកំណត់យ៉ាងខ្ពស់ ទើបត្រាស់ថា សទេវមនុស្សំ ដូច្នេះ នេះជាលំដាប់ការអធិប្បាយសេចក្ដីក្នុងទីនេះ ។

ក៏ព្រះបុរាណាចារ្យទាំងឡាយពោលថា បទថា សទេវកំ បានដល់លោកដ៏សេស ព្រមទាំងទេវតាទាំងឡាយ ។

បទថា សមារកំ បានដល់ លោកដ៏សេស ព្រមទាំងមារ ។

បទថា សព្រហ្មកំ បានដល់ លោកដ៏សេស ព្រមទាំងព្រហ្មទាំងឡាយ ។

ក្នុងការអធិប្បាយនេះ ជាការរួបរួមសត្វ ចូលក្នុងកព ៣ ទាំងអស់ក្នុងបទទាំង ៣ ដោយអាការ ៣ ។ កាលនឹងកាន់យក ដោយបទទាំង ២ ទៀត ទើបពោលថា សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ ដូច្នេះ ។

ដោយអធិប្បាយយ៉ាងនេះ ជាការកាន់យកសត្វលោក ដែលជាត្រៃធាតុនោះ ពិតមែនដោយអាការនោះៗ ដោយបទទាំង ៥ ។

ក៏ក្នុងពាក្យថា សយំ អភិញ្ញា សច្ចិកត្វា បវេទេតិ នេះ មានវិនិច្ឆ័យថា

បទថា សយំ បានដល់ ព្រះអង្គឯង គឺ មិនមានអ្នកដទៃណែនាំ ។

បទថា អភិញ្ញា បានដល់ ការត្រាស់ដឹងដ៏ក្រៃលែង អធិប្បាយថា ដឹងដោយញាណដ៏ក្រៃលែង ។

បទថា សច្ចិកត្វា បានដល់ ធ្វើឲ្យប្រចក្ស ។ ដោយបទនេះ ជាការបដិសេធសេចក្ដីប៉ាន់ស្មានជាដើម ។

បទថា បវេទេតិ បានដល់ ឲ្យដឹង ឲ្យជ្រាប គឺ ប្រកាសឲ្យជ្រាបដល់គ្នាទូទៅ ។

សេចក្ដីថា សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់អាស្រ័យ

ភាពជាអ្នកករុណាក្នុងសត្វទាំងឡាយ សូម្បីព្រះអង្គលះបង់សេចក្តីសុខដែលកើតពីវិវេក សម្តែងធម៌ និងកាលទ្រង់សម្តែងធម៌នោះ តិចក៏ដោយច្រើនក៏ដោយ ទ្រង់សម្តែងប្រភេទមានលំអបទដើមជាដើម ទាំងនោះ ។ អធិប្បាយថា សូម្បីក្នុងលំអបទដើម ទ្រង់សម្តែងធ្វើឲ្យល្អ ពិរោះ មិនមានទោសឡើយ សូម្បីលំអបទកណ្តាល បទចុង ក៏ទ្រង់សម្តែងធ្វើឲ្យល្អពីរោះមិនមានទោសឡើយ ។

ក្នុងសេចក្តីដែលពោលមកហើយនោះ ទេសនា មានខាងដើមកណ្តាល និងខាងចុង ។ សាសនាក៏មានខាងដើម កណ្តាល និងខាងចុង ។

នឹងពោលទេសនាមុន ។ ក្នុងគាថា សូម្បីមាន ៤ បាទ បាទដំបូងឈ្មោះថា ជាបទដើម ។ ពីរបាទតពីនោះ ឈ្មោះថា ជាបទកណ្តាល ។ បាទមួយក្នុងខាងក្រោយ ឈ្មោះថា ជាបទចុង ។

ព្រះសូត្រដែលមានអនុសន្ធិតែមួយ មាននិទានជាបទដើម មានពាក្យជាដើមថា ឥទមវោច ជាបទចុង ពាក្យចន្លោះខាងដើម និងខាងចុងទាំង ២ ជាបទកណ្តាល ។

ព្រះសូត្រដែលមានអនុសន្ធិច្រើន មានអនុសន្ធិដំបូង ជាបទដើម មានអនុសន្ធិក្នុងទីបំផុត ជាបទចុង ។ អនុសន្ធិមួយ ឬពីរ ឬច្រើនត្រង់កណ្តាល ជាបទកណ្តាលនោះឯង ។

សម្រាប់សាសនា មានសីល សមាធិ និងវិបស្សនា ឈ្មោះថា ជា

ខាងដើម ។ សមពិតដូចទ្រង់ត្រាស់ទុកថា អ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ? គឺ សីលដ៏បរិសុទ្ធិ ១ ទិដ្ឋិត្រង់ ១ ជាបទដើម ។

អរិយមគ្គដែលទ្រង់ត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទា ដែលតថាគតត្រាស់ដឹងដោយបញ្ញាដ៏ប្រពៃមានហើយ ឈ្មោះថា ជាបទកណ្ដាល ។

ផល និងនិព្វាន ឈ្មោះថា ជាបទចុង ។

ពិតហើយ ផល ទ្រង់ត្រាស់ថា ជាបទចុង ក្នុងប្រយោគនេះថា ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈនេះ នុ៎ះជាសារៈ នុ៎ះជាទីបំផុត ដូច្នេះ ។

និព្វាន ទ្រង់ត្រាស់ថា ជាបទចុង ក្នុងប្រយោគនេះថា អច្ចយាសិ អាវុសោ វិសាខ បញ្ហំ នាសក្ខិ បញ្ហានំ បរិយន្តំ គហេតុំ ម្នាលវិសាខៈ បុគ្គលនៅចប់ព្រហ្មចរិយៈ ឈមទៅកាន់និព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ។

ក្នុងទីនេះទ្រង់បំណងយក បទដើម បទកណ្ដាល បទចុងនៃទេសនា ។

ពិតហើយ ព្រះមានព្រះភាគកាលទ្រង់សម្ដែងធម៌ ទ្រង់សម្ដែងសីលក្នុងបទដើម ទ្រង់សម្ដែងមគ្គក្នុងបទកណ្ដាល ទ្រង់សម្ដែងនិព្វានក្នុងបទចុង ។ ដូច្នោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា ព្រះមាន-ព្រះភាគនោះ ទ្រង់សម្ដែងធម៌ មានលំអក្នុងខាងដើម លំអត្រង់កណ្ដាល

លំអក្នុងខាងចុង ដូច្នេះ ។

**ព្រោះដូច្នោះ ធម្មកថិកសូម្បីដទៃ កាលសម្ដែងធម៌ គប្បី សម្ដែងសីលក្នុងខាងដើម សម្ដែងមគ្គក្នុងបទកណ្ដាល និងសម្ដែងនិព្វានក្នុងបទចុង នេះជាគោលរបស់ធម្មកថិក ។**

បទថា សាត្ថំ សព្យញ្ជនំ សេចក្ដីថា ក៏អ្នកណាមានទេសនាជាប់ដោយការពណ៌នាដល់យាគូ និងភត្ត ស្រី និងប្រុសជាដើម អ្នកនោះឈ្មោះថា មិនសម្ដែងទេសនាព្រមទាំងអត្ថ តែព្រះមានព្រះភាគទ្រង់លះការសម្ដែងយ៉ាងនោះ ទ្រង់សម្ដែងទេសនាជាប់ដោយសតិប្បដ្ឋាន ៤ ជាដើម ។ ដូច្នោះ លោកទើបពោលថា ទ្រង់សម្ដែងព្រមទាំងអត្ថ ដូច្នេះ ។

ក៏ទេសនារបស់អ្នកណា ប្រកបដោយព្យញ្ជនៈតែមួយជាដើម ឬមានព្យញ្ជនៈបិទមាត់ទាំងអស់ ឬមានព្យញ្ជនៈបើកមាត់ទាំងអស់ និងមានសង្កត់មាត់ទាំងអស់ ទេសនារបស់អ្នកនោះ ជាទេសនាឈ្មោះថា មិនមានព្យញ្ជនៈ ព្រោះព្យញ្ជនៈមិនបរិបូណ៌ ដូចភាសារបស់ពួកមិលក្ខៈ មានពួកពង្រទមិឡៈ ពួកពង្រកិរាតៈ និងពួកពង្រយវនៈជាដើម ។

តែព្រះមានព្រះភាគ ទ្រង់មិនធ្វើព្យញ្ជនៈ ១០ យ៉ាងដែលពោលទុកយ៉ាងនេះថា សិថិល ធនិត ទីឃៈ រស្សៈ លហុ គរុ និគ្គហិត សម្ពន្ធ វិមុត្ត និងប្រភេទនៃការអធិប្បាយរបស់ព្យញ្ជនៈ ដូច្នេះ មិនឲ្យលាយគ្នា ទ្រង់សម្ដែងធម៌ធ្វើព្យញ្ជនៈទាំងឯងឲ្យបរិបូណ៌ ដូច្នោះ លោកទើបពោល

ថា ទ្រង់សម្តែងធម៌ព្រមទាំងព្យញ្ជនៈ ដូច្នេះ ។

បទថា កេវលំ ក្នុងបទថា កេវលបរិបុណ្ណំ នេះ ជាពាក្យហៅសេចក្តីដោយអស់ជើង ។

បទថា បរិបុណ្ណំ ជាពាក្យហៅសេចក្តីមិនខ្វះមិនលើស ។ អធិប្បាយថា ទ្រង់សម្តែងបរិបូណ៌ទាំងអស់តែម្តង មិនមានទេសនាណាមួយដែលមិនបរិបូណ៌ ។

បណ្ឌិតគប្បីជ្រាបថា បរិបូណ៌អស់ជើង ព្រោះមិនមានពាក្យដែលនឹងគប្បីបន្ថែមចូល និងកាត់ចេញ ។

បទថា បរិសុទ្ធំ បានដល់ មិនមានសេចក្តីសៅហ្មង ។

ក៏អ្នកណាសម្តែងធម៌ដោយគិតថា យើងនឹងបានលាភ ឬសក្ការៈព្រោះអាស្រ័យធម៌ទេសនានេះ ទេសនារបស់អ្នកនោះ រមែងមិនបរិសុទ្ធិ ។ តែព្រះមានព្រះភាគ ទ្រង់មិនបានសម្លឹងលោកាមិសៈ មានព្រះហឫទយទោរទន់ដោយមេត្តាភាវនាដែលផ្សាយប្រយោជន៍ ទ្រង់សម្តែងដោយចិត្តដែលតាំងនៅដោយសភាព គឺ ការលើកលំដាប់ឲ្យខ្ពស់ឡើង ។ ដូច្នោះលោកទើបពោលថា ទ្រង់សម្តែងធម៌បរិសុទ្ធិ ។

ក៏ក្នុងពាក្យថា ព្រហ្មចរិយំ បកាសេតិ ស័ព្ទថា **ព្រហ្មចរិយ** នេះប្រាកដក្នុងអត្ថទាំងនេះ គឺ ទាន វេយ្យាវច្ចៈ សីលសិក្ខាបទ ៥ អប្បមញ្ញា មេថុនវិរតិ សទារសន្តោសៈ វីរិយៈ អដ្ឋឧបោសថ អរិយមគ្គ

សាសនា ។

ពិតហើយ ទាន លោកពោលថា ព្រហ្មចរិយៈ ក្នុងបុណ្ណកជាតកថា អ្វីជាវត្ត អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាវិបាកនៃកម្មអ្វី ដែលសន្សំល្អហើយ ការសម្រេចកាពរុងរឿង កម្លាំង សេចក្តីព្យាយាម និងវិមានធំនេះរបស់អ្នក នេះជាផលនៃ កម្មអ្វី , បពិត្រលោកនិរទុក្ខ ខ្ញុំនិងភរិយា ទាំងពីរនាក់ (កាលនៅក្នុងមនុស្សលោក) ជាអ្នកមានសទ្ធា ជាទានបតី ផ្ទះរបស់ខ្ញុំ (ក្នុងកាលនោះ) រមែងញុំាងសមណព្រាហ្មណ៍ ទាំងឡាយឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ទាន នោះជាវត្ត ជាព្រហ្មចារ្យរបស់យើងខ្ញុំ នេះជាវិបាកនៃទាន ដែលសន្សំល្អហើយ ការសម្រេសេចក្តីរុងរឿង កម្លាំង កាយ សេចក្តីព្យាយាម និងការកើត ទាំងវិមានធំនេះ របស់យើងខ្ញុំ នេះជាផលនៃទាន ដែលខ្ញុំសន្សំល្អហើយ ។

វេយ្យាវច្ច ទ្រង់ត្រាស់ថា ព្រហ្មចារ្យ ក្នុងរឿងអង្កុរប្រេតនេះថា បាតដៃរបស់អ្នក អាចឲ្យវត្ថុដែលគួរប្រាថ្នាបាន ដោយ ព្រហ្មចារ្យអ្វី បាតដៃរបស់អ្នកបញ្ចេញមកនូវមធុរសដោយ

ព្រហ្មចារ្យអ្វី បុណ្យសម្រេចក្នុងបាតដៃរបស់អ្នក ដោយព្រហ្មចារ្យអ្វី បាតដៃរបស់ខ្ញុំអាចឲ្យវត្ថុដែលគួរប្រាថ្នាបាន ដោយព្រហ្មចារ្យនោះ ដៃរបស់ខ្ញុំទើបបញ្ចេញនូវមធុរស ដោយព្រហ្មចារ្យនោះ បុណ្យក៏សម្រេចក្នុងបាតដៃរបស់ខ្ញុំ ដោយព្រហ្មចារ្យនោះ ។

**សីលសិក្ខាបទ ៥** ទ្រង់ត្រាស់ថា ព្រហ្មចារ្យ ក្នុងតិត្តិរជាតកនេះថា ឥទំ ខោ តំ ភិក្ខវេ តិត្តិរិយំ នាម ព្រហ្មចរិយំ អហោសិ ម្នាលភិក្ខុទាំងឡាយ សីល ៥ នោះឯង ឈ្មោះថា តិត្តិរិយព្រហ្មចារ្យ ។

**អប្បមញ្ញា ៤** លោកពោលថា ព្រហ្មចារ្យ ក្នុងមហាគោវិន្ទសូត្រនេះថា តំ ខោ បន បញ្ចសិខ ព្រហ្មចរិយំ នេវ និព្វិទាយ ន វិរាគាយ ន និរោធាយ យាវទេវ ព្រហ្មលោកុប្បត្តិយា ម្នាលបញ្ចសិខទេវបុត្ត ព្រហ្មចរិយៈនោះឯង មិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីវិរាគៈ មិនប្រព្រឹត្តទៅដើម្បីនិរោធ ប្រព្រឹត្តទៅដើម្បីចូលដល់ព្រហ្មលោក ប៉ុណ្ណោះ ។

**មេថុនវិរតិ** លោកពោលថា ព្រហ្មចារ្យ ក្នុងសល្លេខសូត្រនេះថា

បរេ អព្រហ្មចារិនោ ភវិស្សន្តិ មយមេត្ថ ព្រហ្មចារិនោ ភវិស្សាម

ជនទាំងឡាយដទៃមិនប្រព្រឹត្តព្រហ្មចារ្យ យើងទាំងឡាយ នឹងជាអ្នកប្រព្រឹត្តនូវព្រហ្មចារ្យ ។

**សទារសន្តោស** លោកពោលថា ព្រហ្មចារ្យ ក្នុងមហាធម្មបាលជាតកថា

មយញ្ច ភរិយា នាតិក្កមាម អម្ហេ ច ភរិយា នាតិក្កមន្តិ

អញ្ញត្រ តាហិ ព្រហ្មចរិយំ ចរាម

តស្មា ហិ អម្ហំ ទហរា ន មីយរេតិ ។

ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយាទេ និងភរិយាក៏មិនប្រព្រឹត្តកន្លងចិត្តយើង លើកលែងតែភរិយាទាំងនោះ ពួកយើងប្រព្រឹត្តព្រហ្មចារ្យ ព្រោះហេតុនោះ ពួកយើងមិនស្លាប់អំពីក្មេង ។

**សេចក្តីព្យាយាម** ទ្រង់ត្រាស់ថា ព្រហ្មចារ្យ ក្នុងលោមហង្សនសូត្រថា អភិជានាមិខោ បនាហំ សារីបុត្ត ចតុរង្គសមន្នាគតំ ព្រហ្មចរិយំ ចរិតា តបស្សី សុទំហោមិ ម្នាលសារីបុត្រ តថាគតដឹងច្បាស់នូវការប្រព្រឹត្តព្រហ្មចារ្យ ប្រកបដោយអង្គ ៤ តថាគតជាអ្នកមានសេចក្តីព្យាយាមដុតកម្តៅកិលេស ។

**ឧបោសថប្រកបដោយអង្គ ៨** ដែលធ្វើដោយអំណាចការទូន្មានខ្លួន

ទ្រង់ត្រាស់ថា ព្រហ្មចារ្យ ក្នុងនិមិជាតកយ៉ាងនេះថា ៖

ហីនេន ព្រហ្មចរិយេន ខត្តិយេ ឧបបជ្ជតិ

មជ្ឈិមេន ច ទេវត្តំ ឧត្តមេន វិសុជ្ឈតិ ។

បុគ្គលកើតជាក្សត្រិយ៍ ដោយព្រហ្មចារ្យថ្នាក់ទាប កើតជាទេវតា ដោយព្រហ្មចារ្យថ្នាក់កណ្ដាល បុគ្គលបរិសុទ្ធិដោយព្រហ្មចារ្យថ្នាក់ខ្ពស់ ។

**អរិយមគ្គ** ទ្រង់ត្រាស់ថា ព្រហ្មចារ្យ ក្នុងមហាគោវិន្ទសូត្រនុ៎ះឯងថា ឥទំ ខោ បន បញ្ចសិខ ព្រហ្មចរិយំ ឯកន្តនិព្វិទាយ វិរាគាយ ។បេ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ម្នាលបញ្ចសិខទេវបុត្ត ព្រហ្មចារ្យនេះ ទើបប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ (កិលេស) ព្រហ្មចារ្យនេះ គឺ មគ្គមានអង្គ ៨ ដែលឆ្ងាយចាកសឹកសត្រូវ គឺ កិលេស ។

**សាសនា** ទាំងអស់ដែលសង្គ្រោះដោយសិក្ខា ៣ ទ្រង់ត្រាស់ថា

ព្រហ្មចារ្យ ក្នុងបាសាទិកសូត្រថា តយិទំ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវទេវ ទេវមនុស្សេហិ សុប្បកាសិតំ ព្រហ្មចារ្យនេះ បរិបូណ៌ មាំមួន ដល់នូវសេចក្ដីចម្រើន មនុស្សដោយច្រើនចូលចិត្ត រីងមាំ មនុស្ស និងទេវតាទាំងឡាយដ៍ច្រើនប្រកាសហើយ ។

ក៏សាសនា ដែលសង្គ្រោះដោយសិក្ខា ៣ នេះឯង ទ្រង់បំណង

យកថា ព្រហ្មចារ្យ ក្នុងទីនេះ ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះ យ៉ាងនេះថា បទថា ព្រហ្មចរិយំ បកាសេតិ សេចក្តីថា ព្រះមានព្រះភាគនោះ ទ្រង់សម្តែងធម៌ មានលំអបទដើម.......... បរិសុទ្ធិ ។ និងកាលទ្រង់សម្តែងយ៉ាងនេះ ទ្រង់ប្រកាសព្រហ្មចរិយៈ គឺ សាសនាទាំងអស់ ដែលសង្គ្រោះដោយសិក្ខា ៣ ។

បទថា ព្រហ្មចរិយំ មានអធិប្បាយថា ការប្រព្រឹត្តជាព្រហ្ម ដោយអត្ថថា ប្រសើរទីបំផុត ឬការប្រព្រឹត្តរបស់ព្រះពុទ្ធជាដើម ដែលជាព្រហ្ម ។

បទថា តំ ធម្មំ សេចក្តីថា ស្តាប់ធម៌ដែលដល់ព្រម ដោយប្រការដូចពោលហើយនោះ ។

បទថា គហបតិ វា សេចក្តីថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបសម្តែងដល់គហបតីមុន ។ ព្រោះកម្ចាត់មានះបង្បាំង ព្រោះគហបតីមានចំនួនច្រើនបង្បាំង ។

ពិតហើយ ដោយច្រើន ពួកដែលចេញចាកខត្តិយត្រកូល បួសរមែងប្រកាន់ខ្លួន ព្រោះអាស្រ័យជាតិ , ពួកដែលចេញចាកត្រកូលព្រាហ្មណ៍បួស រមែងប្រកាន់ខ្លួន ព្រោះអាស្រ័យមន្ត , ពួកដែលចេញចាកត្រកូលទាប បួស មិនអាចនឹងតាំងនៅបាន ព្រោះខ្លួនមានជាតិផ្សេងពីគេ , ចំណែកពួកក្មេងគហបតី ភ្ជួរដីស្រែចំការ ដកាបញើសហូរពីក្លៀក ផ្កា

អំបិលឡើងខ្ពង់ រមែងកម្ចាត់សេចក្ដីប្រកាន់ខ្លួន និងភាពក្រអឺតក្រអោងចេញបាន , ព្រោះមិនមានសេចក្ដីប្រកាន់ខ្លួន គេទាំងនោះបួសហើយ មិនធ្វើសេចក្ដីប្រកាន់ខ្លួន ឬសេចក្ដីក្រអឺតក្រអោង រៀនព្រះពុទ្ធវចនៈតាមកម្លាំង ធ្វើព្រះពុទ្ធវចនៈនោះដោយវិបស្សនា រមែងតាំងនៅក្នុងភាពជាព្រះអរហន្តបាន ។ ចំណែកអ្នកដែល ចេញចាកត្រកូលក្រៅពីនេះ បួសមានមិនច្រើន ។ តែជាគហបតីមានច្រើន , ដូច្នោះ ទើបទ្រង់សម្ដែងដល់គហបតីមុន ព្រោះដើម្បីកម្ចាត់មានះ និងព្រោះមានចំនួនច្រើន ។

បទថា អញ្ញតរស្មឹ វា សេចក្ដីថា ក្នុងត្រកូលណាមួយ បណ្ដាត្រកូលក្រៅពីនេះ ។

បទថា បច្ចាជាតោ បានដល់ កើតដោយចំពោះ ។

បទថា តថាគតេ សទ្ធំ បដិលភតិ សេចក្ដីថា ស្ដាប់ធម៌បរិសុទ្ធិ រមែងបានសទ្ធាក្នុងព្រះតថាគត ទ្រង់ជាធម្មសាមីថា ព្រះមានព្រះភាគអង្គនោះ ជាសម្មាសម្ពុទ្ធហ្ន៎ ។

បទថា ឥតិ បដិសញ្ចិក្ខតិ បានដល់ រមែងពិចារណាយ៉ាងនេះ ។

បទថា សម្ពាធោ ឃរាវាសោ សេចក្ដីថា ប្រសិនបើថា ប្ដីប្រពន្ធនៅក្នុងផ្ទះ ៦០ ហត្ថ ឬសូម្បីក្នុងទីចន្លោះ ១ រយយោជន៍ ការគ្រប់គ្រងផ្ទះក៏នៅតែចង្អៀត ព្រោះអត្ថថា គេទាំងនោះ មានកង្វល់ហួងហែង ។

បទថា រជាបថោ ក្នុងមហាអដ្ឋកថាពន្យល់ថា ដែលជាទីកើត

ឡើងនៃធូលី មានរាគៈជាដើម ។ អ្នកខ្លះពោលថា អាគមបថោ ផ្លូវជាទីមក ដូច្នេះក៏មាន ។

ឈ្មោះថា អព្ភោកាសោ ដោយអត្ថថា ដូចជាកណ្តាលវាល ព្រោះអត្ថថា មិនទើសទាក់ ។

ពិតហើយ **បព្វជិត** សូម្បីនៅក្នុងទីបិទបាំង មានផ្ទះកំពូលប្រាសាទកែវ និងទេវវិមានជាដើម ដែលមានទ្វារបន្ទប់បិទជិត ក៏មិនជាប់ជំពាក់ មិនពាក់ព័ន្ធ ។ ដូច្នោះ ទើបទ្រង់ត្រាស់ថា អព្ភោកាសោ បព្វជ្ជា បព្វជ្ជា ទើបមានពេលទំនេរច្រើន ដូច្នេះ ។

ម្យ៉ាងទៀត ឃរាវាស ឈ្មោះថា ចង្អៀត ព្រោះមិនមានឱកាសធ្វើកុសល ឈ្មោះថា ជាផ្លូវមកនៃធូលី ព្រោះជាទីប្រជុំនៃធូលី គឺកិលេស ដូចគំនរសម្រាមដែលមិនបានរក្សា ជាទីរួមនៃធូលី ដូច្នោះ ។ បព្វជ្ជា ជាផ្លូវរួចផុតស្រឡះ ព្រោះមានឱកាសធ្វើកុសលតាមសប្បាយ ។

ក្នុងព្រះបាលីនេះថា នយិទំ សុករំ ។បេ។ បព្វជេយ្យំ ដូច្នេះ មានកថាសង្ខេប ដូចតទៅនេះ ៖

**ព្រហ្មចារ្យ** គឺ សិក្ខា ៣ ដែលសម្តែងហើយ ឈ្មោះថា គប្បីប្រព្រឹត្តឲ្យបរិបូណ៌តែម្យ៉ាង ព្រោះមិនធ្វើឲ្យដាច់សូម្បីមួយថ្ងៃ ញុំាងចរិមកចិត្តឲ្យឆ្អែតស្កប់ស្កល់បាន ។ ឈ្មោះថា គប្បីប្រព្រឹត្តឲ្យបរិសុទ្ធិដោយចំណែកមួយ ព្រោះមិនធ្វើឲ្យប្រឡាក់ដោយមន្ទិល គឺ កិលេស សូម្បី

មួយថ្ងៃ ញុំាងចរិមកចិត្តឲ្យត្អែតស្កប់ស្កល់បាន ។

បទថា សង្ខលិខិតំ សេចក្ដីថា គប្បីប្រព្រឹត្តឲ្យដូចស័ង្ខដែលខាត់ហើយ គឺ ឲ្យមានចំណែកប្រៀបដូច ស័ង្ខដែលរលោងហើយ ។

ក៏ព្រហ្មចារ្យនេះ ដែលអ្នកនៅគ្រប់គ្រងផ្ទះ នៅត្រង់កណ្ដាលនៃផ្ទះ នឹងប្រព្រឹត្តឲ្យបរិបូណ៌បរិសុទ្ធិតែម្យ៉ាង ដូចស័ង្ខខាត់ហើយ មិនមែនធ្វើបានងាយ បើដូច្នោះ យើងគប្បីកោរសក់ និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចារ្យ ព្រោះជ្រលក់ដោយទឹកអម្ចត់ និងមានពណ៌លឿង ចេញចាកផ្ទះបួស ជាអ្នកមិនមានផ្ទះ ។ ឯក្នុងសេចក្ដីនេះ ព្រោះការងារ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ផ្ទះ ហៅថា ការគ្រប់គ្រងផ្ទះ និងការគ្រប់គ្រងផ្ទះនោះ មិនមានក្នុងបព្វជ្ជា ដូច្នោះ បព្វជ្ជាគប្បីជ្រាបថា មិនមែនការគ្រប់គ្រងផ្ទះ ព្រហ្មចារ្យនោះ មិនមែនការគ្រប់គ្រងផ្ទះ ។

បទថា បព្វជេយ្យំ បានដល់ គប្បីបដិបត្តិ ។

បទថា អប្បំ វា សេចក្ដីថា គំនរភោគៈតិចជាង ចំនួនមួយពាន់ ឈ្មោះថា តិច ។ តាំងពីមួយពាន់ឡើងទៅ ឈ្មោះថា ច្រើន ។

ញាតិនុ៎ះឯង ឈ្មោះថា សាច់ញាតិ ព្រោះអត្ថថា ជាប់ព័ន្ធ ។ សាច់ញាតិសូម្បីនោះ តិចជាង ២០ ឈ្មោះថា តិច ។ តាំងពី ២០ ឡើងទៅ ឈ្មោះថា ច្រើន ។

បទថា បាដិមោក្ខសំវរសំវុតោ បានដល់ ប្រកបដោយការសង្រួម ក្នុងបាតិមោក្ខ ។

បទថា អាចារគោចរសម្បន្នោ បានដល់ ដល់ព្រមដោយអាចារៈ និងគោចរៈ ។

បទថា អណុមត្តេសុ គឺ មានប្រមាណតិច ។

បទថា វជ្ជេសុ បានដល់ ក្នុងអកុសលធម៌ទាំងឡាយ ។

បទថា ភយទស្សាវី គឺ ឃើញភ័យ ។

បទថា សមាទាយ បានដល់ កាន់យកដោយប្រពៃ ។

បទថា សិក្ខតិ សិក្ខាបទេសុ សេចក្តីថា សមាទានសិក្សាសិក្ខាបទនោះៗ ក្នុងសិក្ខាបទទាំងឡាយ ។

នេះជាសេចក្តីសង្ខេបក្នុងសេចក្តីនេះ ចំណែកសេចក្តីពិស្តារ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

ក្នុងព្រះបាលីថា កាយកម្មវចីកម្មេន សមន្នាគតោ កុសលេន បរិសុទ្ធាជីវោ សេចក្តីថា ក៏កាលកាយកម្ម និងវចីកម្មដែលជាកុសល ព្រះមានព្រះភាគទ្រង់កាន់យកដោយស័ព្ទថា អាចារគោចរៈហើយក៏ដោយ ព្រោះឈ្មោះថា អាជីវបារិសុទ្ធិសីលនេះ រមែងមិនកើតក្នុងអាកាស ឬលើចុងឈើជាដើម តែកើតឡើងក្នុងកាយទ្វារ និងវចីទ្វារប៉ុណ្ណោះ ដូច្នោះ លោកទើបពោលថា ប្រកបដោយកាយកម្ម និងវចីកម្ម ដែលជា

កុសល ដើម្បីសម្តែងទ្វារដែលកើតរបស់អាជីវបារិសុទ្ធិសីលនោះ ។ តែព្រោះប្រកបដោយអាជីវបារិសុទ្ធិសីលនោះ ដូច្នោះ ទើបឈ្មោះថា ជាអ្នកមានអាជីវបរិសុទ្ធ ។

ម្យ៉ាងទៀត លោកពោលយ៉ាងនេះ ក៏ដោយអំណាចមុណ្ឌិយបុត្តសូត្រ ។ ពិតណាស់ ក្នុងសូត្រនេះ ទ្រង់ត្រាស់ទុកថា ម្នាលគហបតី កាយកម្មជាកុសល តើដូចម្តេច ? ម្នាលគហបតី សូម្បីអាជីវបរិសុទ្ធ ក៏គជាគតពោលទុកក្នុងសីល ដូច្នេះ ។

ក៏ព្រោះអ្នកបដិបត្តិប្រកបដោយសីលនោះ ដូច្នោះ គប្បីជ្រាបថា ជាអ្នកមានអាជីវបរិសុទ្ធ ។

បទថា សីលសម្បន្នោ សេចក្តីថា ជាអ្នកដល់ព្រមដោយសីល ៣ យ៉ាង បានពោលហើយក្នុងព្រហ្មជាល សូត្រ ។

បទថា ឥន្ទ្រិយេសុ គុត្តទ្វារោ សេចក្តីថា ជាអ្នកបិទទ្វារក្នុងឥន្ទ្រិយទាំងឡាយដែលមានចិត្តជាទី ៦ ។

បទថា សតិសម្បជញ្ញេន សមន្នាគតោ សេចក្តីថា ជាអ្នកប្រកបដោយសតិ និងសម្បជញ្ញៈក្នុងឋានៈ ទាំង ៧ មានឈានទៅមុខ និងថយក្រោយជាដើម ។

បទថា សន្តុដ្ឋោ សេចក្តីថា ប្រកបដោយសន្តោស ៣ យ៉ាង ក្នុងបច្ច័យ ៤ ឈ្មោះថា ជាអ្នកសន្តោស ។

# ពណ៌នា ចូឡមជ្ឈិមមហាសីល

**[១០៣-១២០]** *ព្រះមានព្រះភាគ ទ្រង់ដាក់បទមាតិកាយ៉ាងនេះហើយ កាលទ្រង់ចែកតាមលំដាប់ ទើបត្រាស់ពាក្យជាដើមថា មហាបពិត្រ ភិក្ខុជាអ្នកបរិបូណ៌ដោយសីល ដូចម្តេច ។*

*ក្នុងព្រះបាលីនោះ បទថា* ឥទំបិស្ស ហោតិ សីលស្មឹ *សេចក្តីថា សីល គឺ ចេតនាវៀរចាកបាណាតិបាត របស់ភិក្ខុនោះ នេះជាសីលប្រការ ១ ក្នុងសីល ។ មួយវិញទៀត ពាក្យថា* សីលស្មឹ *ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃបឋមាវិភត្តិ ។*

*ក៏ក្នុងមហាអដ្ឋកថា លោកពោលសេចក្តីនេះតែម្យ៉ាងថា សីល គឺ ចេតនាវៀរចាកបាណាតិបាតនេះ ក៏ជាសីលរបស់សមណៈនោះដូចគ្នា ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយក្នុងព្រហ្មជាលសូត្រនុ៎ះឯង ។*

*បទថា* ឥទមស្ស ហោតិ សីលស្មឹ *នេះ ជាសីលរបស់ភិក្ខុនោះ ។*

**[១២១]** *បទថា* ន កុតោចិ ភយំ សមនុបស្សតិ យទិទំ សីលសំវរតោ *សេចក្តីថា ភ័យពួកណាដែលមានសេចក្តីមិនសង្រួមជាមូល រមែងកើតឡើង បណ្តាភ័យទាំងនោះ ភ័យដែលគប្បីមាន ព្រោះសីលសំវរៈនោះ ភិក្ខុដែលដល់ព្រមដោយសីល នឹងមិនប្រសព្វក្នុងទីណាៗ សូម្បីព្រោះសង្រួម*

តែម្យ៉ាង ។ ព្រោះហេតុអ្វី ព្រោះមិនមានភ័យ ដែលមានការមិនសង្រួមជាមូល ព្រោះការសង្រួម ។

បទថា មុទ្ធាវសិត្តោ សេចក្តីថា ស្រោចទឹកលើព្រះសិរសាដោយខត្តិយាភិសេកដែលចាត់ទុកតាមពិធី ។

បទថា យទិទំ បច្ចត្ថិកតោ សេចក្តីថា រមែងមិនប្រសព្វភ័យដែលនឹងគប្បីមាន អំពីសត្រូវណាម្នាក់ពីទីណាៗ ។ ព្រោះហេតុអ្វី ព្រោះកម្ចាត់បច្ចាមិត្ត បានហើយ ។

បទថា អជ្ឈត្តំ បានដល់ ខាងក្នុងខ្លួន អធិប្បាយថា ក្នុងសន្តានរបស់ខ្លួន ។

បទថា អនវជ្ជសុខំ សេចក្តីថា មិនមានទោស គឺ មិនមានអ្នកណាតិះដៀលបាន ជាកុសល ។ ភិក្ខុដែលមានសីលសម្បូរណ៍ រមែងសោយសុខទាំងផ្លូវកាយផ្លូវចិត្ត ដែលធម៌ គឺ សេចក្តីមិនក្តៅក្រហាយបាមោជ្ជៈ សេចក្តីឆ្អែតចិត្ត និងសេចក្តីស្ងប់ ដែលមានសីលជាបទដ្ឋានប្រកបហើយ ។

ប្រការថា ឯវំ ខោ មហារាជ ភិក្ខុ សីលសម្បន្នោ ឆាម ហោតិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងសីលកថាចប់ស្រេចថា ភិក្ខុដែលប្រកប ដោយសីល ៣ យ៉ាង ដែលទ្រង់សម្តែងពិស្តារជាប់តគ្នាយ៉ាងនេះ ឈ្មោះថា ជាអ្នកមានសីលសម្បូរណ៍ ។

## ពណ៌នា ឥន្ទ្រិយសំវរ

[១២២] ក្នុងការចែកទ្វារ ដែលឃុំគ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ មាន វិនិច្ឆ័យដូចតទៅនេះ ៖

**ចក្ខុ** សព្ទ ក្នុងបទថា ចក្ខុនា រូបំ នេះ ក្នុងទីកន្លែងខ្លះប្រព្រឹត្តទៅក្នុងពុទ្ធចក្ខុ ។ ដូចក្នុងប្រយោគថា ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ ។

ក្នុងទីកន្លែងខ្លះប្រព្រឹត្តទៅក្នុងសមន្តចក្ខុ ពោលគឺ ព្រះសព្វញ្ញុតញ្ញាណ ។ ដូចក្នុងប្រយោគថា ម្នាលសុមេធ ព្រះពុទ្ធទ្រង់មានសមន្តចក្ខុ ស្តេចឡើងប្រាសាទ គឺ ព្រះធម៌ មានឧបមាយ៉ាងនោះ ។

ក្នុងទីកន្លែងខ្លះប្រព្រឹត្តទៅក្នុងធម្មចក្ខុ ដូចក្នុងប្រយោគថា ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ។ ក៏ក្នុងព្រះបាលីនេះ សំដៅយកបញ្ញា គឺ អរិយមគ្គ ៣ ។

**ញាណ** មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ក្នុងព្រះបាលីថា ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ ដូច្នេះ ទ្រង់ហៅថា បញ្ញាចក្ខុ ។

ប្រព្រឹត្តទៅក្នុងទិព្វចក្ខុ ក្នុងទីមកទាំងឡាយ មកដោយទិព្វចក្ខុ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងបសាទចក្ខុ ក្នុងព្រះបាលីនេះថា រូបអាស្រ័យចក្ខុ ដូច្នេះ ។

តែក្នុងទីនេះ **ចក្ខុ** សព្ទនេះ ប្រព្រឹត្តទៅក្នុងចក្ខុវិញ្ញាណដោយវោហារថា បសាទចក្ខុ ។ ព្រោះដូច្នោះ ក្នុងព្រះបាលីនេះ ទើបមានសេចក្តីថា ឃើញរូបដោយចក្ខុវិញ្ញាណ ។

ពាក្យណាដែលគប្បីពោល សូម្បីក្នុងបទដ៏សេស ពាក្យនោះទាំងអស់ ខ្ញុំម្ចាស់បានពោលហើយក្នុងវិសុទ្ធិមគ្គ ។

បទថា អព្យាសេកសុខំ សេចក្តីថា សោយសុខដែលមិនលាយដោយកិលេស គឺ មិនរួមជាមួយកិលេស ព្រោះវៀរចាកកិលេសជាគ្រឿងសៅហ្មង ជាសុខបរិសុទ្ធិ ជាអធិចិត្តសុខ ដូច្នេះឯង ។

" ចប់ ឥន្ទ្រិយសំវរកថា "

## ពណ៌នា សតិសម្បជញ្ញ

[**១២៣**] ក៏ក្នុងការចែកសតិសម្បជញ្ញៈ មានវិនិច្ឆ័យដូចតទៅនេះ ៖

នឹងវិនិច្ឆ័យក្នុងព្រះបាលីនេះថា អភិក្កន្តេ បដិក្កន្តេ មុន ។

ការទៅ ហៅថា អភិក្កន្តេ ឈានទៅមុខ ។

ការត្រឡប់ ហៅថា បដិកន្តេ ឈានថយក្រោយ ។

សូម្បីទាំង ២ នោះ រមែងបានក្នុងឥរិយាបថ ៤ ។

ក្នុងការទៅ កាលនាំកាយទៅខាងមុខ ឈ្មោះថា ឈានទៅ , កាលថយត្រឡប់ ឈ្មោះថា ឈានត្រឡប់ ។

សូម្បីក្នុងការឈរ អ្នកដែលឈរនុ៎ះឯង ឱនកាយទៅខាងមុខ ឈ្មោះថា ឈានទៅ , ងើបកាយឡើង ឈ្មោះថា ឈានត្រឡប់ ។

សូម្បីក្នុងការអង្គុយ អ្នកដែលអង្គុយនុ៎ះឯង ឈ្ងោកមុខទៅកាន់ចំណែកខាងមុខរបស់អាសនៈ ឈ្មោះថា ឈានទៅ , កាលទំរេតកាយទៅកាន់ផ្នែកខាងក្រោយ ឈ្មោះថា ឈានត្រឡប់ ។

សូម្បីក្នុងការដេកក៏ន័យនេះឯង ។

បទថា សម្បជានការី ហោតិ សេចក្តីថា ធ្វើកិច្ចទាំងពួងដោយសម្បជញ្ញៈ ឬធ្វើសម្បជញ្ញៈនុ៎ះឯង ។ ដោយសេចក្តីថា ភិក្ខុនោះរមែងធ្វើសម្បជញ្ញៈរឿយៗ ក្នុងការឈានទៅជាដើម មិនបានវៀរសម្បជញ្ញៈ ក្នុងកាលណាៗ ។

សម្បជញ្ញៈ ក្នុងព្រះបាលីនោះ មាន ៤ យ៉ាង គឺ ៖

១. សាត្ថកសម្បជញ្ញៈ

២. សប្បាយសម្បជញ្ញៈ

៣. គោចរសម្បជញ្ញៈ

៤. អសម្មោហសម្បជញ្ញៈ

ក្នុង ៤ យ៉ាងនោះ កាលចិត្តគិតនឹងទៅកើតឡើង មិនទាន់ទៅតាមដែលគិតមុន ពិចារណាដល់ប្រយោជន៍ និងមិនមែនប្រយោជន៍ថា ការទៅទីនោះ នឹងមានប្រយោជន៍ដល់យើងឬមិនហ្ន៎ ហើយពិចារណា

ប្រយោជន៍ ឈ្មោះថា សាត្ថកសម្បជញ្ញៈ ។

ពាក្យថា ប្រយោជន៍ ក្នុងបទថា សាត្ថកសម្បជញ្ញៈនោះ គឺសេចក្តីចម្រើនដោយធម៌ ដោយបានឃើញព្រះចេតិយ ឃើញដើមព្រះស្រីមហាពោធិ ឃើញព្រះសង្ឃ ឃើញព្រះថេរៈ និងឃើញអសុភជាដើម ។ ដោយសេចក្តីថា ភិក្ខុនោះញុំាងបីតិ មានព្រះពុទ្ធជាអារម្មណ៍ឲ្យកើតឡើង សូម្បីព្រោះឃើញព្រះចេតិយ ឬដើមព្រះស្រីមហាពោធិ ញុំាងបីតិមានព្រះសង្ឃជាអារម្មណ៍ឲ្យកើតឡើង ព្រោះឃើញព្រះសង្ឃ ពិចារណាបីតិនោះឯង ដោយភាពជារបស់អស់ទៅ សាបសូន្យទៅ រមែងសម្រេចព្រះអរហត្ត ឃើញព្រះថេរៈទាំងឡាយ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈទាំងនោះ ឃើញអសុភ ញុំាងបឋមឈានឲ្យកើតឡើងក្នុងអសុភនោះ ពិចារណាអសុភនោះឯង ដោយភាពជារបស់អស់ទៅ សាបសូន្យទៅ រមែងសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទ្រង់ទើបហៅការឃើញវត្ថុទាំងនោះថា មានប្រយោជន៍ ។

តែអាចារ្យពួកខ្លះពោលថា សេចក្តីចម្រើន សូម្បីចំណែកអាមិសក៏មានប្រយោជន៍ដូចគ្នា ព្រោះអាស្រ័យអាមិសនោះ បដិបត្តិដើម្បីអនុគ្រោះព្រហ្មចរិយៈ ។

ចំណែកក្នុងការទៅនោះ ពិចារណាដល់សប្បាយ និងអសប្បាយ ហើយពិចារណាសប្បាយ **ឈ្មោះសាត្ថកសម្បជញ្ញៈ** សេចក្តីនេះយ៉ាងណា

នឹងពេលការឃើញព្រះចេតិយមានប្រយោជន៍មុន ក៏បើបរិស័ទប្រជុំគ្នាក្នុងទី ១០ យោជន៍ ១២ យោជន៍ ដើម្បីបូជាព្រះចេតិយ ទាំងស្រីទាំងប្រុស ប្រដាប់តាក់តែងកាយតាមសមគួរដល់សម្បត្តិរបស់ខ្លួន ហាក់បីដូចជាចិត្រកម្ម នាំគ្នាដើរទៅមក ក៏ក្នុងទីនោះ លោភៈ រមែងកើតឡើងដល់ភិក្ខុនោះ ព្រោះអារម្មណ៍ដែលគួរប្រាថ្នា បដិឃៈ រមែងកើតឡើង ព្រោះអារម្មណ៍ដែលមិនគួរប្រាថ្នា មោហៈ រមែងកើតឡើង ព្រោះមិនពិចារណា រមែងត្រូវអាបត្តិ ព្រោះកាយសំសគ្គៈក៏មាន រមែងមានអន្តរាយដល់ជីវិត និងព្រហ្មចរិយក៏មាន ។ ដោយហេតុដូចពោលមកនេះ ទីនោះទើបជាអសប្បាយ ។ ព្រោះមិនមានអន្តរាយដូចដែលពោលហើយ ទីនោះជាសប្បាយ ។

សប្បាយក្នុងការឃើញដើមព្រះស្រីមហាពោធិ ក៏ន័យនេះឯង ។

សប្បាយការឃើញព្រះសង្ឃ ក៏មានប្រយោជន៍ ។ កាលបើមនុស្សទាំងឡាយសាងមណ្ឌបធំខាងក្នុងស្រុក បបួលគ្នាស្តាប់ធម៌រហូតដល់អស់មួយយប់ រមែងមានទាំងប្រជុំជន ទាំងអន្តរាយ តាមប្រការដែលពោលហើយនុ៎ះឯង ។ ដោយហេតុដូចពោលមកនេះ ទើបជាអសប្បាយ ។ ព្រោះមិនមានអន្តរាយ ទីនោះជាសប្បាយ ។

សប្បាយក្នុងការឃើញព្រះថេរៈដែលមានបរិស័ទបរិវារច្រើន ក៏ន័យដូច្នេះ ។

សូម្បីការឃើញអសុភក៏មានប្រយោជន៍ ។

ក៏រឿងនេះ ដើម្បីសម្តែងប្រយោជន៍នោះ ។

បានឮថា ភិក្ខុកម្លោះមួយរូប នាំសាមណេរទៅរកឈើស្ងួន ។ សាមណេរចៀសចេញពីផ្លូវដើរទៅខាងមុខ ឃើញអសុភ ញុំាងបឋមឈានឲ្យកើត ធ្វើបឋមឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ធ្វើឲ្យច្បាស់ផលទាំង ៣ ហើយឈរកំណត់កម្មដ្ឋាន ដើម្បីត្រូវការមគ្គផលជាន់ខ្ពស់ ។ ភិក្ខុកម្លោះកាលមិនឃើញសាមណេរ ក៏ហៅថា សាមណេរ ។ សាមណេរនោះគិតថា ចាប់ផ្តើមតាំងពីកាលដែលយើងបព្វជ្ជា មិនធ្លាប់ឲ្យភិក្ខុហៅខ្លួនពីរដងឡើយ យើងនឹងញុំាងគុណវិសេសជាន់ខ្ពស់ឲ្យកើត សូម្បីក្នុងថ្ងៃដទៃ ដូច្នេះទើបបានឆ្លើយតបថា "អ្វីលោកម្ចាស់" កាលភិក្ខុកម្លោះហៅថា "មកនេះ" ដោយពាក្យតែមួយម៉ាត់ប៉ុណ្ណោះ សាមណេរនោះក៏មក ពោលថា "លោកម្ចាស់ សូមលោកម្ចាស់និមន្តទៅតាមផ្លូវនេះសិន ហើយឈរបែរមុខទៅផ្លូវទិសខាងកើត ក្រឡេកមើលត្រង់ទីដែលខ្ញុំឈរត្រឹមតែមួយសន្ទុះសិន" ។ ភិក្ខុនោះធ្វើតាមនោះ បានសម្រេចគុណវិសេស ដែលសាមណេរបានសម្រេចហើយដូចគ្នា ។ អសុភតែមួយកើត ប្រយោជន៍ដល់ជន ២ នាក់ ដោយប្រការដូច្នេះ ។

អសុភនេះ សូម្បីមានប្រយោជន៍យ៉ាងនេះក៏ពិត ។ តែអសុភស្រីជាអសប្បាយដល់បុរស និងអសុភប្រុសជាអសប្បាយដល់ស្ត្រី អសុភ

ដែលជាសភាគគ្នា (ភេទតែមួយគ្នា) ប៉ុណ្ណោះ ជាសប្បាយ ការពិចារណាសប្បាយយ៉ាងនេះ ឈ្មោះសប្បាយសម្បជញ្ញៈ ដោយប្រការដូច្នេះ ។

ក៏ការជ្រើសរើសអារម្មណ៍ ពោលគឺ កម្មដ្ឋានដែលខ្លួនពេញចិត្តក្នុងបណ្តាកម្មដ្ឋាន ៣៨ យ៉ាង ហើយកាន់យកអារម្មណ៍នោះប៉ុណ្ណោះ ទៅក្នុងទីដែលភិក្ខាចារ របស់ភិក្ខុដែលពិចារណាដល់ប្រយោជន៍ និងសប្បាយយ៉ាងនេះ ឈ្មោះគោចរសម្បជញ្ញៈ ។

ដើម្បីភាពជាក់ច្បាស់ក្នុងគោចរសម្បជញ្ញៈនោះ បណ្ឌិតគប្បីជ្រាបចតុក្កៈនេះដូចតទៅនេះ ៖

ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅមិននាំមក , រូបខ្លះនាំមកមិននាំទៅ , តែរូបខ្លះ មិននាំទៅមិននាំមក , រូបខ្លះ នាំទៅផងនាំមកផង ។

ក្នុងបណ្តាភិក្ខុ ៤ ជំពូកនោះ ភិក្ខុណាជម្រះចិត្តឲ្យបរិសុទ្ធិចាកធម៌ដែលជាគ្រឿងរារាំង ដោយការចង្រ្កម និងដោយការអង្គុយ ក្នុងពេលថ្ងៃ ពេលបឋមយាម ក្នុងពេលយប់ ក៏បដិបត្តិយ៉ាងនោះ ដេកក្នុងមជ្ឈិមយាម ញ៉ាំងកាលឲ្យកន្លងទៅដោយការអង្គុយ និងការចង្រ្កមសូម្បីក្នុងបច្ឆិមយាម ធ្វើវត្តនៅទីលានព្រះចេតិយ និងលានព្រះស្រីមហាពោធិស្រេចហើយ ស្រោចទឹកដើមព្រះស្រីមហាពោធិ តាំងទឹកឆាន់ ទឹកប្រើទុកប្រព្រឹត្តសមាទានខន្ធកវត្តគ្រប់យ៉ាង មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម ។ ភិក្ខុនោះធ្វើសរីរៈបរិកម្មហើយ ចូលកាន់សេនាសនៈ ឲ្យ

រាងកាយបានទទួលការអប់ឧណ្ហ ២-៣ ស្របក់រួចហើយ ប្រកបរឿយៗ ក្នុងកម្មដ្ឋាន ក្រោកឡើងក្នុងវេលាភិក្ខាចារ កាន់បាត្រ និងចីវរ ដោយកំណត់កម្មដ្ឋានជាគោលនោះឯង ចេញចាកសេនាសនៈ ដាក់ចិត្តដល់កម្មដ្ឋានយ៉ាងនោះ ទៅកាន់លានព្រះចេតិយ បើចម្រើនពុទ្ធានុស្សតិកម្មដ្ឋាន ក៏ចម្រើនពុទ្ធានុស្សតិកម្មដ្ឋាននោះរឿយៗ ទៅ មិនលះកម្មដ្ឋាននោះ ចូលទៅកាន់លានព្រះចេតិយ បើចម្រើនកម្មដ្ឋានដទៃហើយ ដាក់កម្មដ្ឋាននោះ ដូចដាក់វត្ថុដែលកាន់មក ទុកត្រង់ជើងជណ្តើរ ញុំាងបីតិមានព្រះពុទ្ធជាអារម្មណ៍ ឡើងកាន់លានព្រះចេតិយ បើចេតិយធំ ធ្វើប្រទក្សិណ ៣ ជុំ ហើយថ្វាយបង្គំក្នុងឋានៈទាំង ៤ (ទិស) បើចេតិយតូច គប្បីធ្វើប្រទក្សិណយ៉ាងនោះឯង ហើយថ្វាយបង្គំក្នុងឋានៈទាំង ៨ ។ កាលថ្វាយបង្គំព្រះចេតិយហើយ ទៅដល់លានដើមព្រះស្រីមហាពោធិ គប្បីសម្តែងសេចក្តីគោរព ថ្វាយបង្គំព្រះស្រីមហាពោធិ ដូចនៅចំពោះព្រះភ័ក្ត្រ ព្រះមានព្រះភាគ ដូច្នោះ ។ ភិក្ខុនោះថ្វាយបង្គំព្រះចេតិយ និងព្រះស្រីមហាពោធិយ៉ាងនេះហើយ គប្បីកាន់យកកម្មដ្ឋានដែលខ្លួនដាក់ទុក ដូចអ្នកទៅកាន់ទីរក្សារបស់ទុក កាន់យកវត្ថុដែលរក្សាទុកនោះវិញដូច្នោះ កាលទៅជិតដល់ស្រុក ក៏គ្រងចីវរដោយកំណត់កម្មដ្ឋានជាគោលនោះឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។

គ្រានោះ មនុស្សទាំងឡាយឃើញភិក្ខុនោះ ក៏ចេញមកទទួល

ដោយសេចក្ដីត្រេកអរថា លោកម្ចាស់របស់ពួកយើងមកហើយ ទទួលបាត្រ និមន្តឲ្យអង្គុយលើរោងឆាន់ ឬលើផ្ទះ ថ្វាយយាគូក្នុងវេលាដែលកត្តាហារមិនទាន់សម្រេច ក៏លាងជើងលាបប្រេង អង្គុយខាងមុខសួរបញ្ហាខ្លះ សូមស្ដាប់ធម៌ខ្លះ ។

ព្រះអដ្ឋកថាចារ្យពោលថា បើសូម្បីគេមិនសូមឲ្យសម្ដែងធម៌ ក៏គប្បីសម្ដែងធម្មកថា តែម្ដងដើម្បីសង្គ្រោះប្រជាជន ។

ពិតហើយ ធម្មកថា ដែលក្រៅពីកម្មដ្ឋាន រមែងមិនមាន ។ ព្រោះដូច្នោះ ភិក្ខុនោះ កាលពោលធម្មកថាដែលកំណត់កម្មដ្ឋានជាគោលនោះឯង ឆាន់អាហារដោយកំណត់កម្មដ្ឋានជាគោលនោះផង សូម្បីកាលធ្វើអនុមោទនាលាត្រឡប់ ពួកមនុស្សតាមជូនដំណើរចេញអំពីស្រុកហើយ ឲ្យពួកមនុស្សទាំងនោះត្រឡប់ត្រង់ទីនោះ ដើរទៅតាមផ្លូវ ។

គ្រានោះ សាមណេរនិងភិក្ខុចេញមកមុន បានឆាន់ភត្តាហារឯក្រៅស្រុករួចស្រេចហើយ ឃើញភិក្ខុរូបនោះក៏ទៅទទួល ទទួលបាត្រ និងចីវររបស់លោក ។

បានឮថា ក្នុងសម័យបុរាណ នឹងក្រឡេកមើលមុខជាមុនថា នេះឧបជ្ឈាយ៍របស់យើង នេះអាចារ្យរបស់យើង ហើយទើបប្រណិបត្តិក៏ទេ រមែងធ្វើតាមកំណត់ដែលចូលដល់នោះឯង ។ សាមណេរ និងភិក្ខុកម្លោះទាំងនោះសួរលោកថា "លោកដ៏ចម្រើន មនុស្សទាំងនោះជាអ្វីនឹងលោក

ជាញាតិខាងមាតា ឬជាញាតិខាងបិតា” ។ ភិក្ខុនោះពោលថា “ពួកលោកឃើញអ្វីទើបសួរ” ។ សាមណេរ និងភិក្ខុកម្លោះឆ្លើយថា “ឃើញពួកគេទាំងនោះស្រឡាញ់រាប់អានលោកច្រើន” ។ ភិក្ខុនោះពោលសរសើរអ្នកស្រុកទាំងនោះថា “ម្នាលលោកដ៏មានអាយុទាំងឡាយ កិច្ចណាសូម្បីមាតាបិតា ក៏លំបាកដែលនឹងធ្វើបាន កិច្ចនោះ ពួកគេទាំងនោះធ្វើដល់ពួកយើង សូម្បីចីវររបស់ពួកយើង ក៏ជារបស់ពួកគេទាំងនោះដែរ កាលមានភ័យ ក៏ជួយឲ្យផុតភ័យ កាលស្រេកឃ្លាន ក៏ជួយឲ្យឆ្អែត អ្នកដែលមានឧបការៈដល់ពួកយើងដូច្នេះ មិនមានទៀតទេ” ដូច្នេះ ។ នេះហៅថា នាំទៅមិននាំមក ។

ចំណែកភិក្ខុណាធ្វើវត្តបដិបត្តិ មានប្រការដូចពោលហើយក្នុងខាងដើម ភ្លើងធាតុ រមែងដុតអាហារថ្មីអស់ហើយ ក៏ដុតក្រពះអាហារ ។ ញើសហូរស្រោចខ្លួន ។ កម្មដ្ឋានមិនឡើងកាន់វិថីបាន ។ ភិក្ខុនោះកាន់បាត្រ គ្រងចីវរស្រេចហើយ ថ្វាយបង្គំព្រះចេតិយដោយរហ័ស ហើយចូលទៅកាន់ស្រុកដើម្បីសូមយាគូ ក្នុងវេលាហ្វូងគោចេញពីក្រោលនោះឯង (ព្រឹកព្រលឹម) បានយាគូហើយ ទៅឆាន់នៅរោងឆាន់ ។ ពេលនោះល្មមភិក្ខុនោះលេបយាគូចូលទៅបាន ២-៣ ពំនូត តេជោធាតុដែលកើតពីកម្មមិនដុតក្រពះអាហារ បែរមកដុតអាហារថ្មី ។ ភិក្ខុនោះដល់សេចក្តីរលត់ការដុតរោលនៃតេជោធាតុ ដូចបានងូតទឹកទាំងរយក្អាំង ឆាន់យាគូដោយ

កំណត់កម្មដ្ឋានជាគោល លាងបាត្រ និងខ្ពុរមាត់ហើយ ចម្រើនកម្មដ្ឋានរឿយៗ ក្នុងចន្លោះពេលដែលនៅមិនបានឆាន់កត្តាហារ ត្រាច់បិណ្ឌបាតក្នុងទីដែលមិនទាន់បានទៅ ឆាន់អាហារដោយកំណត់កម្មដ្ឋានជាគោល តពីនោះក៏កាន់យកកម្មដ្ឋានដែលខ្លួនរក្សា ត្រង់ទីនោះត្រឡប់មក ។ នេះហៅថា នាំមកមិននាំទៅ ។

ភិក្ខុទាំងឡាយដែលឆាន់យាគូហើយ ផ្ដើមចម្រើនវិបស្សនា បានសម្រេចព្រះអរហត្តក្នុងព្រះពុទ្ធសាសនាដូច្នេះ មានច្រើនដរាបរាប់មិនបាន ក្នុងកោះសីហឡៈនោះ ក្នុងរោងឆាន់តាមភូមិស្រុកនោះៗ មិនមានអាសនៈដែលមិនមានភិក្ខុអង្គុយឆាន់យាគូ ហើយសម្រេចព្រះអរហត្ត ។

ក៏ភិក្ខុដែលនៅដោយសេចក្ដីប្រមាទ លះបោលធុរៈ ទម្លាយវត្តដែលនឹងគប្បីធ្វើ មានចិត្តរឹងត្អឹង សូម្បីដោយចេតោខិលធម៌ ៥ យ៉ាង មិនធ្វើសេចក្ដីសម្គាល់សូម្បីថា កម្មដ្ឋានមាន ចូលទៅបិណ្ឌបាតក្នុងស្រុក ដើរប្រឡុកប្រឡល់ទៅនឹងគ្រហស្ថខ្លះ ស៊ីនៅរួមជាមួយនឹងគ្រហស្ថខ្លះ ដែលមិនសមគួរ ជាអ្នកទំនេរចោលទៅ ។ នេះហៅថា មិននាំទៅមិននាំមក ។

ក៏ភិក្ខុណា ដែលពោលហើយថា នាំទៅផងនាំមកផង ភិក្ខុនោះគប្បីជ្រាបដោយអំណាចភិក្ខុ ដែលប្រព្រឹត្តគតប្បច្ចាគតវត្ត (ដើរទៅក៏ចម្រើនកម្មដ្ឋាន ដើរត្រឡប់មកក៏ចម្រើនកម្មដ្ឋាន) ។

ពិតហើយ កុលបុត្រទាំងឡាយ អ្នកប្រាថ្នាប្រយោជន៍ បួសក្នុង

ព្រះសាសនា ហើយនៅរួមគ្នា ១០ រូបខ្លះ ២០ រូបខ្លះ ៣០ រូបខ្លះ ៤០ រូបខ្លះ ៥០ រូបខ្លះ ១០០ រូបខ្លះ ធ្វើការព្រមព្រៀងគ្នាថា “នែអាវុសោទាំងឡាយ លោកទាំងឡាយមិនមែនបួសគេចពីម្ចាស់បំណុល មិនមែនបួសភៀសខ្លួន មិនមែនបួសដើម្បីអាជីវៈ តែប្រាថ្នាផុតទុក្ខ ទើបបួសក្នុងព្រះសាសនានេះ ។ ព្រោះដូច្នោះ កិលេសកើតឡើងក្នុងខណៈដើរ ចូរគ្របសង្កត់ក្នុងខណៈដើរនោះឯង កិលេសកើតឡើងក្នុងខណៈឈរ ចូរគ្របសង្កត់ក្នុងខណៈឈរនោះឯង កិលេសកើតឡើងក្នុងខណៈអង្គុយ ចូរគ្របសង្កត់ក្នុងខណៈអង្គុយនោះឯង កិលេសកើតឡើងក្នុងខណៈដេក ចូរគ្របសង្កត់ក្នុងខណៈដេកនោះឯង ដូច្នេះ ។ ភិក្ខុទាំងនោះធ្វើការព្រម-ព្រៀងគ្នាយ៉ាងនេះហើយ ទៅភិក្ខាចារ មានផ្ទាំងថ្មក្នុងចន្លោះផ្លូវ កន្លះឧសភៈ ១ ឧសភៈ កន្លះគាវុត និង ១ គាវុត ដើរមនសិការកម្មដ្ឋានដោយសញ្ញានោះឯង ។ បើកិលេសកើតឡើងដល់អ្នកណាៗ ក្នុងខណៈដើរ លោករមែងគ្របសង្កត់កិលេសនោះ ត្រង់នោះឯង កាលមិនអាចនឹងគ្របសង្កត់បានយ៉ាងនោះ ត្រូវឈរ ។ កាលនោះភិក្ខុសូម្បីដែលតាមមកខាងក្រោយភិក្ខុនោះ ក៏ត្រូវឈរ ។ ភិក្ខុនោះដាស់តឿនខ្លួនឯងថា ភិក្ខុនេះដឹងថា វិតក្កៈកើតឡើងដល់លោក លោកធ្វើកម្មមិនសមគួរហើយ ដូច្នេះ ចម្រើនវិបស្សនាហើយ ឈានចុះកាន់អរិយភូមិ បានក្នុងទីនោះឯង ។ កាលមិនអាចនឹងគ្របសង្កត់បានយ៉ាងនោះ ក៏អង្គុយ ។ តមក

ភិក្ខុសូម្បីដែលតាមមកខាងក្រោយភិក្ខុនោះ ក៏ត្រូវអង្គុយ មានន័យដូចពោលនុ៎ះឯង ។ សូម្បីកាលមិនអាចនឹងឈានចុះកាន់អរិយភូមិ ក៏គ្រប
សង្កត់កិលេសនោះទុក ដើរមនសិការកម្មដ្ឋានរឿយៗ ទៅ ។ ភិក្ខុនោះនឹងមិនឈានដោយចិត្តដែលប្រាសចាកកម្មដ្ឋាន ។ បើឈានទៅ ត្រូវថយត្រឡប់មកកាន់ទីដើមទៀត ដូចព្រះមហាបុស្សទេវត្ថេរៈ អ្នកនៅអាលិន្ទកវិហារ ។

បានឮថា ព្រះថេរៈនោះបំពេញគតបច្ចាគតវត្តអស់ ១៩ ឆ្នាំ ។ សូម្បីមនុស្សទាំងឡាយ បានឃើញលោកហើយ គឺ អ្នកដែលកំពុងភ្ជួរស្រែខ្លះ សាបព្រោះស្រូវខ្លះ បែនស្រូវខ្លះ ធ្វើការងារនៅក្នុងចន្លោះផ្លូវខ្លះ ឃើញព្រះថេរៈដើរនៅយ៉ាងនោះ ទើបសន្ទនាគ្នាថា ព្រះថេរៈរូបនេះដើរត្រឡប់ទៅត្រឡប់មករឿយៗ វង្វេងផ្លូវ ឬបាត់របស់អ្វីហ្ន៎ ។ ព្រះថេរៈនោះ មិនយកចិត្តទុកដាក់នឹងពាក្យរបស់មនុស្សទាំងនោះ ហើយធ្វើសមណធម៌ ដោយចិត្តដែលប្រកបដោយកម្មដ្ឋានប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្តក្នុងវស្សា ទី ២០ ។

ក្នុងថ្ងៃដែលសម្រេចព្រះអរហត្តនុ៎ះឯង ទេវតាដែលនៅចុងទីចង្ក្រមរបស់ព្រះថេរៈ បានឈរយកម្រាមដៃធ្វើជាប្រទីបភ្លឺរុងរឿង ។ សូម្បីស្តេចមហារាជទាំង ៤ ។ និងស្តេចសក្កទេវរាជ រហូតដល់ស្តេចសហម្បតីព្រហ្ម ក៏បានមកទំនុកបម្រុងព្រះថេរៈ ។

ក៏ព្រះមហាតិស្សត្ថេរៈអ្នកនៅព្រៃ ឃើញពន្លឺដូច្នោះ ទើបសួរលោកក្នុងថ្ងៃស្អែកឡើងថា កាលពីយប់មិញបានមានពន្លឺក្នុងសំណាក់របស់លោក ពន្លឺនោះជាអ្វី ។ ព្រះថេរៈនិយាយបំបាំងមានជាដើម យ៉ាងនេះថា ធម្មតាពន្លឺ រមែងជាពន្លឺរបស់ប្រទីបខ្លះ ជាពន្លឺរបស់កែវមណីខ្លះដូច្នេះ ។ តពីនោះ បានបង្គាប់ឲ្យព្រះថេរៈអ្នកសួរបិទបាំងរឿងទុកកាលលោកទទួលពាក្យហើយ ទើបរៀបរាប់ឲ្យស្តាប់ ។ និងដូចព្រះមហានាគត្ថេរៈអ្នកនៅកាលវល្លិមណ្ឌប បានឮថា ព្រះថេរៈនោះ ក៏បំពេញគតប្បច្ចាគតវត្ត ជាដំបូងបានអធិដ្ឋានដើរចង្ក្រមអស់ ៧ ឆ្នាំ ដោយតាំងចិត្តថា នឹងបូជាមហាបធានរបស់ព្រះមានព្រះភាគមុន បំពេញគតប្បច្ចាគតវត្តទៀត ១៦ ឆ្នាំ ទើបបានសម្រេចព្រះអរហត្ត ។ ព្រះថេរៈនោះ ឈានដោយចិត្តដែលប្រកបដោយកម្មដ្ឋានប៉ុណ្ណោះ កាលឈានជើងដោយចិត្តដែលប្រាសចាកកម្មដ្ឋានហើយ ក៏ថយត្រឡប់ជាថ្មី គ្រាទៅជិត ពួកអ្នកស្រុកឈរក្នុងប្រទេសដែលគួរសង្ស័យថា មេគោ ឬភិក្ខុហ្ន៎ដណ្តប់ចីវរហើយ លាងបាត្រដោយទឹកអំពីផើងដែលស្អាត ហើយបៀមទឹកទុក ។ ដើម្បីអ្វី ? ដើម្បីត្រូវការថា កាលអ្នកមកថ្វាយភិក្ខាដល់យើង ឬមកសំពះ កម្មដ្ឋានកុំបានឃ្លាត សូម្បីត្រឹមតែពោលថា សូមលោកទាំងឡាយចូរមានអាយុវែង ។ តែកាលត្រូវសួរដល់ថ្ងៃថា លោកម្ចាស់ ថ្ងៃនេះប៉ុន្មានរោច ឬសួរចំនួនភិក្ខុ ឬសួរបញ្ហា ក៏លេបទឹក

ហើយប្រាប់ ។ បើមិនមានអ្នកសួរដល់ថ្ងៃជាដើម ក៏នឹងខ្ចាវទឹកទុកត្រង់ទ្វារស្រុក ទៅក្នុងវេលាគោចេញចាកក្រោល ។ និងដូចភិក្ខុ ៥០ រូប អ្នកចាំវស្សាក្នុងកលម្ពត្ថិថវិហារ ។

បានឮថា ភិក្ខុទាំងនោះ បានធ្វើការព្រមព្រៀងគ្នាក្នុងថ្ងៃពេញបូណ៌មី ខែ ៨ ថា យើងទាំងឡាយមិនទាន់សម្រេចព្រះអរហត្ត នឹងមិននិយាយជជែកគ្នា កាលភិក្ខុទាំងនោះចូលទៅបិណ្ឌបាតក្នុងស្រុក ក៏បៀមទឹកចូលទៅ កាលត្រូវសួរដល់ថ្ងៃជាដើម ក៏បដិបត្តិតាមន័យដែលពោលហើយនុ៎ះឯង ។ មនុស្សទាំងឡាយក្នុងទីនោះឃើញស្នាមខ្ចាវទឹកក៏ដឹងថា ថ្ងៃនេះមកតែមួយអង្គ ថ្ងៃនេះ ២ អង្គ ។

ក៏មនុស្សទាំងនោះ គិតគ្នាយ៉ាងនេះថា ភិក្ខុទាំងនេះមិននិយាយនឹងពួកយើងប៉ុណ្ណោះ ឬថា ពួកគ្នាលោកនោះឯងក៏មិននិយាយគ្នា បើពួកគ្នាលោកនោះឯង ក៏មិននិយាយគ្នាហើយ គង់នឹងវិវាទគ្នាដោយពិតមកពួកយើងនឹងឲ្យភិក្ខុទាំងនោះខមាទោសគ្នានិងគ្នា ។ គេទាំងអស់ទៅវិហារ មិនបានឃើញភិក្ខុ ៥០ រូប នៅក្នុងទីតែមួយជាមួយគ្នាសូម្បី ២ រូប ។ ក្នុងលំដាប់នោះ បណ្តាអ្នកទាំងនោះ មានអ្នកភ្នែកមុតថ្លាម្នាក់ ពោលថា "លោកដ៏ចម្រើនទាំងឡាយ ឱកាសដូច្នេះ មិនមែនទីនៅរបស់ អ្នកដែលឈ្លោះគ្នា លានព្រះចេតិយ លានព្រះស្រីមហាពោធិ ក៏បោស ស្អាតល្អ អំបោសក៏ដាក់ទុករៀបរយ ទឹកឆាន់ ទឹកប្រើ ក៏រៀបចំទុកល្អ" ។ ពួកគេ

នាំគ្នាត្រឡប់ពីទីនោះ ។ សូម្បីភិក្ខុទាំងនោះ ក៏សម្រេចព្រះអរហត្តខាង ក្នុងត្រៃមាសនុ៎ះឯង ក្នុងថ្ងៃមហាបវារណា បានបវារណា វិសុទ្ធិបវារណា ។

ភិក្ខុដែលប្រព្រឹត្តដូចព្រះមហានាគត្ថេរៈ អ្នកនៅកាលវល្លិមណ្ឌប និងដូចភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងកលម្ពតិត្ថវិហារ ដូចពោលមក នោះ ជំហានដោយចិត្តដែលប្រកបដោយកម្មដ្ឋានស្មើតែម្តង ទៅជិតស្រុក ហើយ បៀមទឹកកំណត់ផ្លូវដើរ ផ្លូវណាមិនមានអ្នកឈ្លោះគ្នា មានអ្នក លេងសុរាជាដើម ឬមិនមានដំរីកាច សេះកាចជាដើម ក៏ទៅផ្លូវនោះ ។ និងកាលដើរបិណ្ឌបាតក្នុងស្រុកនោះ ក៏មិនដើររហ័សដូចអ្នកមានធុរៈក្តៅ ។ ដោយថា ធុតង្គដែលកាន់យកការបិណ្ឌបាតជាវត្ត មិនមានអ្វីដែលត្រូវ រហ័ស ។ តែត្រូវទៅសន្សឹមៗ ដូចរទេះផ្ទុកទឹកទៅដល់ទីទួលកន្ទុកៗ ត្រូវទៅសន្សឹមៗ ដូច្នោះ ។ និងចូលទៅតាមលំដាប់ផ្ទះ ហើយសង្កេត មើលថា គេនឹងឲ្យ ឬមិនឲ្យ ចាំនៅមួយកន្លែង វេលាល្មមសមគួរ បាន ភិក្ខាហើយកាន់មកវិហារ ក្នុងស្រុក ឬក្រៅស្រុក អង្គុយក្នុងកន្លែងដែល សមគួរតាមសប្បាយ មនសិការកម្មដ្ឋាន ផ្តើមបដិកូលសញ្ញាក្នុងអាហារ ពិចារណាដោយអំណាចឧបមាថា ប្រេងបន្តក់ក្តៅ ថ្នាំបិតដំបៅ និងសាច់ របស់បុត្រ ឆាន់អាហារប្រកបដោយអង្គ ៨ មិនមែនឆាន់ដើម្បីនឹងលេង មិនមែនឆាន់ដើម្បីនឹងស្រវឹង មិនមែនឆាន់ដើម្បីប្រដាប់ មិនមែនឆាន់ ដើម្បីតាក់តែង គ្រាឆាន់រួចស្រេចហើយ ផឹកទឹក និងខ្ពុរមាត់ សម្រាក

ល្មមឲ្យបាត់លំបាកចិត្តដោយអាហារមួយស្របក់ ហើយមនសិការកម្មដ្ឋានតែម្តង មុនអាហារយ៉ាងណា ក្រោយអាហារក៏យ៉ាងនោះ ទាំងយាមដើម និងយាមក្រោយ ។ នេះហៅថា ទាំងនាំទៅ និងនាំមក ។

ក៏ភិក្ខុបំពេញគតបច្ចាគតវត្ត ពោលគឺ នាំកម្មដ្ឋានទៅ និងនាំត្រឡប់មកនេះ បើជាអ្នកដល់ព្រមដោយឧបនិស្ស័យហើយ នឹងសម្រេចព្រះអរហត្តបានក្នុងបឋមវ័យតែម្តង ។ បើមិនបានសម្រេចក្នុងបឋមវ័យ ក៏នឹងបានសម្រេចក្នុងមជ្ឈិមវ័យ ។ បើមិនបានសម្រេចក្នុងមជ្ឈិមវ័យ ក៏នឹងបានសម្រេចក្នុងវេលាស្លាប់ ។ បើមិនបានសម្រេចក្នុងវេលាស្លាប់ ក៏នឹងទៅជាទេវបុត្រហើយសម្រេច ។ បើមិនទៅជាទេវបុត្រហើយសម្រេច ទៅកើតកាលព្រះពុទ្ធមិនទាន់ឧប្បត្តិ ក៏នឹងសម្រេចបច្ចេក-ពោធិញ្ញាណ ។ បើមិនសម្រេចបច្ចេកពោធិញ្ញាណ កាលទៅកើតជួបព្រះពុទ្ធទាំងឡាយ ក៏នឹងបានជាព្រះអរហន្តប្រភេទខិប្បាភិញ្ញា ដូចព្រះពាហិយទារុចិរិយត្ថេរៈក៏មាន ។ ប្រភេទអ្នកមានបញ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរៈក៏មាន ។ ប្រភេទអ្នកមានឫទ្ធិច្រើន ដូចព្រះមហា-មោគ្គល្លានត្ថេរៈក៏មាន ។ ប្រភេទកាន់ធុតង្គ ដូចព្រះមហាកស្សបត្ថេរៈក៏មាន ។ ប្រភេទបានទិព្វចក្ខុ ដូចព្រះអនុរុទ្ធត្ថេរៈក៏មាន ។ ប្រភេទទ្រទ្រង់ព្រះវិន័យ ដូចព្រះឧបាលិត្ថេរៈក៏មាន ។ ប្រភេទស្ទាត់ជំនាញសម្តែងធម៌ ដូចព្រះបុណ្ណមន្តានីបុត្តត្ថេរៈក៏មាន ។ ប្រភេទនៅព្រៃជាវត្ត

ដូចព្រះរេវតត្ថេរៈក៏មាន ។ ប្រភេទពហុសូត ដូចព្រះអានន្ទត្ថេរៈក៏មាន ។ ប្រភេទប្រាថ្នាការសិក្សាដូចព្រះរាហុលត្ថេរៈ ដែលជាពុទ្ធបុត្រក៏មាន ។

ក្នុងវត្តបដិបត្តិ ៤ ប្រការនេះ ភិក្ខុណា ទាំងនាំទៅ និងនាំមក គោចរសម្បជញ្ញៈរបស់ភិក្ខុនោះ រមែងដល់ទីបំផុតនៃការបដិបត្តិ ដោយប្រការដូច្នេះ ។

ក៏សេចក្ដីមិនវង្វេងក្នុងការឈានទៅជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញ** ។ អសម្មោហសម្បជញ្ញៈនោះ គប្បីជ្រាបយ៉ាងនេះ បុថុជ្ជនអ្នកអន្ធពាល កាលឈានទៅជាដើម រមែងវង្វេងខុសថា ខ្លួនឈានទៅ ការឈានទៅខ្លួនធ្វើឲ្យកើតឡើង ដូច្នេះខ្លះ ថាយើងឈានទៅ ការឈានទៅ យើងធ្វើឲ្យកើតឡើង ដូច្នេះខ្លះ យ៉ាងណា ភិក្ខុក្នុងព្រះសាសនានេះ មិនវង្វេងខុសដូច្នោះ កាលចិត្តគិតថា យើងនឹងឈានទៅកើតឡើង វាយោធាតុដែលកើតពីចិត្ត ញុំាងវិញ្ញត្តិឲ្យកើត រមែងកើតឡើងដោយចិត្តនុ៎ះឯង ដូច្នោះគ្រោងឆ្អឹងដែលសម្មតិថា កាយនេះ រមែងឈានទៅ ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ដោយប្រការដូច្នេះ ។ កាលគ្រោងឆ្អឹងនោះឈានទៅយ៉ាងនេះ ក្នុងខណៈដែលលើកជើងឡើងម្ខាង ធាតុទាំង ២ គឺ បឋវីធាតុ អាបោធាតុ រមែងខ្សោយកម្លាំងចុះ ។ ធាតុ ២ ទៀត ក្រៅនេះ រមែងមានកម្លាំងឡើង ។ ក្នុងខណៈដែលដាក់ជើងចុះ ធាតុទាំង ២ គឺ តេជោធាតុ

វាយោធាតុ រមែងមានកម្លាំងខ្សោយ ធាតុ ២ ក្រៅនេះ រមែងមានកម្លាំងក្រៃលែងឡើង ។ ក្នុងខណៈដែលចុះជើងចុចផែនដី និងជាន់ពេញបាតជើង ក៏ដូចគ្នា ។

រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅ ក្នុងខណៈដែលលើកជើងឡើង រមែងមិនដល់ខណៈដែលឈានជើង ។ រូបធម៌ និងនាមធម៌ដែលប្រព្រឹត្តទៅក្នុងខណៈដែលដាក់ជើង រមែងមិនដល់ខណៈដែលឈានទៅខាងមុខដូចគ្នា ។ ដែលប្រព្រឹត្តទៅក្នុងខណៈដែលឈានទៅខាងមុខ រមែងមិនដល់ខណៈដែលដាក់ជើងចុះ ។ ដែលប្រព្រឹត្តទៅក្នុងខណៈដែលដាក់ជើងចុះ រមែងមិនដល់ខណៈដែលចុះជើងចុចផែនដី ។ ដែលប្រព្រឹត្តទៅក្នុងខណៈដែលចុះជើងចុចផែនដី រមែងមិនដល់ខណៈដែលជាន់ពេញបាតជើង ។ រូបធម៌ និងអរូបធម៌ រមែងជាផ្នែកៗ ជាកំណាត់ៗ ជាសង្កាត់ៗ រលត់ទៅក្នុងឥរិយាបថនោះៗ ឯង ដូចគ្រាប់ល្ងដែលដាក់ចុះក្នុងក្បៀងក្តៅ រមែងផ្ទុះបែកមានសំឡេងប្រែះៗ ។

ក្នុងការឈានទៅជាដើមនោះ អ្នកណាម្នាក់ឈានទៅ ឬការឈានទៅរបស់អ្នកណាម្នាក់ ។ តែដោយបរមត្ថ ធាតុទាំងឡាយប៉ុណ្ណោះដើរ ធាតុទាំងឡាយប៉ុណ្ណោះឈរ ធាតុទាំងឡាយប៉ុណ្ណោះអង្គុយ ធាតុទាំងឡាយប៉ុណ្ណោះដេក ។ ក៏ក្នុងចំណែក (នៃឥរិយាបថ) នោះៗ ចិត្តដួងដទៃកើតឡើង ចិត្តដួងដទៃរលត់ទៅព្រមនឹងរូបប្រព្រឹត្តទៅ ដូចជាក្រសែ

ទឹកហូរជាប់តគ្នាទៅមិនដាច់ខ្សែយ៉ាងនោះ ដូច្នេះ ។ សេចក្តីមិនវង្វេងក្នុងការឈានទៅជាដើមយ៉ាងនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ ដូច្នេះឯង ។

ចប់អធិប្បាយបទថា អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ ប៉ុណ្ណោះ ។

ក៏ក្នុងបទថា អាលោកិតេ វិលោកិតេ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ការសម្លឹងមើលទៅខាងមុខ ឈ្មោះ អាលោកិត ។

ការសម្លឹងមើលទៅទិសឈៀង ឈ្មោះ វិលោកិត ។

ឥរិយាបថដទៃៗ ដែលឈ្មោះថា ឱលោកិត ឧល្លោកិត និង អបលោកិត ក៏គឺ ការមើលខាងក្រោម ខាងលើ ខាងក្រោយ ការមើលទាំងនោះ លោកមិនបានកាន់យកក្នុងទីនេះ ។ តែដោយការកាន់យកតាមសេចក្តីសមរម្យ លោកកាន់យកការក្រឡេកមើលពីរយ៉ាងនេះប៉ុណ្ណោះ ។

ន័យមួយទៀត ការក្រឡេកមើលទាំងអស់នោះ លោកកាន់យកដោយមុខនេះ ដោយប្រការដូច្នេះតែម្តង ។

ក្នុងការក្រឡេកមើលពីរយ៉ាងនោះ កាលចិត្តគិតថា យើងនឹងក្រឡេកមើលទៅខាងមុខ ដូច្នេះកើតឡើង នៅមិនទាន់ក្រឡេកទៅដោយអំណាចចិត្តនុ៎ះឯង ពិចារណាកាន់យកប្រយោជន៍ ឈ្មោះសាត្ថកសម្បជញ្ញៈ ។ សាត្ថកសម្បជញ្ញៈនោះ គប្បីមើលព្រះនន្ទៈជាតួយ៉ាង ។

សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បើនទូរមិលមើលទៅទិសខាងកើត គេរមែងប្រមូលនូវចិត្តទាំងអស់មើលទៅកាន់ទិសខាងកើតថា ពេលយើងមើលទៅទិសខាងកើតយ៉ាងនេះ អកុសលធម៌ដ៏លាមក គឺ អភិជ្ឈា និងទោមនស្ស មិនគប្បីជាប់តាម យ៉ាងនេះ ឈ្មោះថា ជាអ្នកមានសាត្ថកសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ បើនទូរមិលមើលទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ទិសខាងលើ ទិសខាងក្រោម និងទិសឈៀង គេរមែងប្រមូលចិត្តទាំងអស់ ពិចារណាមើលទិសឈៀងថា កាលយើងមើលទិសឈៀងយ៉ាងនេះ........ ដូច្នេះ ឈ្មោះថា សាត្ថកសម្បជញ្ញៈ។

មយ៉ាងទៀត សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា ការសម្លឹងមើលទៅខាងមុខ និងការសម្លឹងមើលទៅតាមទិស ជាសាត្ថកសម្បជញ្ញៈ និងជាសប្បាយសម្បជញ្ញៈ ដោយការឃើញព្រះចេតិយជាដើម ដូចពោលហើយក្នុងខាងក្រោយនុ៎ះឯង ។

រីឯគោចរសម្បជញ្ញៈ គឺ ការមិនលះបោលកម្មដ្ឋាននុ៎ះឯង ព្រោះដូច្នោះ ការសម្លឹងមើលទៅខាងមុខ និងការសម្លឹងមើលទៅតាមទិស ក្នុងព្រះបាលីនេះ ភិក្ខុអ្នកចម្រើនវិបស្សនាកម្មដ្ឋាន មានខន្ធ ធាតុ អាយតនៈជាអារម្មណ៍ គប្បីធ្វើដោយអំណាចកម្មដ្ឋានរបស់ខ្លួននោះឯង ឬចំណែកភិក្ខុដែលចម្រើនសមថកម្មដ្ឋាន មានកសិណជាដើមជាអារម្មណ៍ គប្បីធ្វើ

ដោយកំណត់កម្មដ្ឋានជាគោលតែម្តង ។ ឈ្មោះថា ខ្លួនខាងក្នុងរាងកាយ ដែលសម្លឹងមើលទៅខាងមុខ ឬដែលសម្លឹងមើលទៅតាមទិស រមែងមិនមាន ។ ពេលកើតការគិតថា យើងនឹងក្រឡេកមើលទៅខាងមុខ ដូច្នេះ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន ព្រមដោយចិត្តដូងនោះឯង ញុំាង វិញ្ញត្តិឲ្យកើត រមែងកើតឡើង ត្របកភ្នែកក្រោមទាញចុះ ត្របកភ្នែកលើ លើកឡើង ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលកើតពី កិរិយារបស់ចិត្ត ដោយប្រការដូច្នេះ ។ នឹងមានអ្នកណាៗ ឈ្មោះថា ត្រាច់ទៅដោយយន្តក៏ទេ ។ តពីនោះ ចក្ខុវិញ្ញាណញុំាងទស្សនកិច្ចឲ្យ សម្រេច ក៏កើតឡើងដូច្នេះឯង ។ ការដឹងច្បាស់យ៉ាងនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈក្នុងព្រះបាលីនេះ ។ មួយ៉ាងទៀត អសម្មោហសម្ប-ជញ្ញៈក្នុងព្រះបាលីនេះ គប្បីជ្រាបដោយការកំណត់ដឹង ហេតុដើម និង ហេតុត្រាច់តាមមក និងហេតុកើតមួយខណៈៗ ។ គប្បីជ្រាបដោយកំណត់ ដឹងហេតុដើមមុន ។

**ភវង្គកិច្ច អាវជ្ជនកិច្ច ទស្សនកិច្ច សម្បដិច្ឆន្នកិច្ច**
**សន្តីរណកិច្ច វោដ្ឋពូនកិច្ច និងជវនកិច្ច ជាគម្រប់**
**៧ រមែងកើត ។**

ក្នុងវិថីចិត្តទាំងនោះ ភវង្គចិត្ត ញុំាងកិច្ចដែលជាអង្គនៃឧបត្តិភព ឲ្យសម្រេចកើតឡើង ។ កិរិយាមនោធាតុរំពឹងដល់ភវង្គចិត្តនោះ ញុំាង

អាវជ្ជនកិច្ចឲ្យសម្រេចកើតឡើង ។ បន្ទាប់ពីកិរិយាមនោធាតុរលត់ ចក្ខុវិញ្ញាណញុំាងទស្សនកិច្ចឲ្យសម្រេចកើតឡើង ។ បន្ទាប់ពីចក្ខុ-វិញ្ញាណរលត់ វិបាកមនោធាតុញុំាងសម្បដិច្ឆន្នកិច្ចឲ្យសម្រេចកើតឡើង ។ បន្ទាប់ពីវិបាកមនោធាតុរលត់ វិបាកមនោវិញ្ញាណធាតុញុំាងសន្តីរណកិច្ចឲ្យសម្រេចកើតឡើង ។ បន្ទាប់ពីវិបាកមនោវិញ្ញាណធាតុរលត់ កិរិយា-មនោវិញ្ញាណធាតុញុំាងវោដ្ឋព្វនកិច្ចឲ្យសម្រេចកើតឡើង ។ បន្ទាប់ពីកិរិ-យាមនោវិញ្ញាណធាតុរលត់ ជវនចិត្ត រមែងស្ទុះទៅ ៧ ដង ។ ក្នុងវីថិចិត្តទាំងនោះ សូម្បីក្នុងជវនចិត្តទី ១ រមែងមិនមាន , ការក្រឡេកទៅខាងមុខ និងការក្រឡេកទៅតាមទិស ដោយអំណាចតម្រេក ការទាស់ចិត្ត និងការវង្វេងថា នេះជាស្រី នេះជាប្រុស...... សូម្បីក្នុងទុតិយជវនៈ... សូម្បីក្នុងសត្តមជវនៈក៏យ៉ាងនោះ ក៏កាលវិថីចិត្តទាំងនោះរលត់តាំងពីដើមដរាបដល់ទីបំផុត ដូចពួកទាហានក្នុងសមរភូមិ ឈ្មោះថាការក្រឡេក និងការឆាកដោយអំណាចតម្រេក ជាដើមថា នេះជាស្រី នេះជាប្រុស ទើបមានឡើង ។

អសម្មោហសម្បជញ្ញៈ ក្នុងការក្រឡេក និងការឆាកនេះ ដោយអំណាចការកំណត់ដឹងហេតុដើម គប្បីជ្រាបត្រឹមតែប៉ុណ្ណេះចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចក្ខុទ្វារ ក៏កាលរូបារម្មណ៍មកប្រាកដ បន្ទាប់ពីភវង្គចិត្តញ័រ កាលវិថីចិត្តមានអាវជ្ជនចិត្តជាដើម កើតឡើងរលត់ទៅ

ដោយអំណាចធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេច ក្នុងទីបំផុតជវនចិត្ត រមែងកើត ។ ជវនចិត្តនោះ ដូចជាបុរសអ្នកត្រាច់មកក្នុងចក្ខុទ្វារ ដែលត្រឹមតែដូចផ្ទះរបស់អាវជ្ជនចិត្តជាដើម ដែលកើតឡើងមុន ។ កាលបុរសអ្នកត្រាច់មកនោះ ចូលទៅក្នុងផ្ទះរបស់អ្នកដទៃ ដើម្បីនឹងសូមវត្ថុអ្វីៗ សូម្បីកាលពួកម្ចាស់របស់ផ្ទះនៅស្ងៀម ក៏មិនគួរប្រើអំណាច យ៉ាងណា សូម្បីកាលអាវជ្ជនចិត្តជាដើម មិនមានតម្រេក មិនថ្នាំងថ្នាក់ មិនវង្វេងក្នុងចក្ខុទ្វារ ដែលត្រឹមតែដូចជាផ្ទះរបស់អាវជ្ជនចិត្តជាដើម ក៏មិនគួរត្រេកអរ ថ្នាំងថ្នាក់ និងវង្វេង ដូច្នោះ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដូចជាអ្នកត្រាច់មកយ៉ាងនេះ ដោយប្រការដូច្នេះ ។

ចិត្តទាំងឡាយ មានវោដ្ឋព្វនចិត្តជាទីបំផុតទាំងនេះ រមែងកើតឡើងក្នុងចក្ខុទ្វារ ចិត្តទាំងនោះ រមែងរលត់ទៅក្នុងទីនោះៗ ឯង ព្រមនឹងសម្បយុត្តធម៌ រមែងមិនឃើញនូវគ្នានិងគ្នា ដូច្នោះ ចិត្តក្រៅពីនេះ ទើបជាចិត្តដែលមាននៅជាខណៈ ។

ក្នុងសេចក្តីនោះមានអធិប្បាយដូច្នេះ ក្នុងផ្ទះមួយខ្នង កាលមនុស្សទាំងឡាយស្លាប់អស់ហើយសល់តែមួយនាក់ ដែលនឹងត្រូវស្លាប់ក្នុងខណៈនោះឯង រមែងមិនអភិរម្យក្នុងការរាំច្រៀងជាដើម យ៉ាងណា កាលអាវជ្ជនចិត្តជាដើម ដែលជាសម្បយុត្តក្នុងទ្វារមួយរលត់ទៅក្នុងទីនោះៗ ឯង ឈ្មោះថា ការអភិរម្យដោយអំណាចតម្រេក ថ្នាំងថ្នាក់ និងវង្វេង

នុ៎ះឯង ក៏មិនគួរសួម្បីដល់ជវនចិត្តដ៏សេស ដែលនឹងត្រូវលត់ក្នុងខណៈនោះឯង ដូច្នោះ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយអំណាចការប្រព្រឹត្តទៅជាខណៈយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អសម្មោហសម្បជញ្ញៈនេះ គប្បីជ្រាបដោយអំណាចពិចារណាក្នុងខន្ធ អាយតនៈ ធាតុ និងបច្ច័យ ។

ក៏ក្នុងអធិការនេះ ចក្ខុ និងរូប ចាត់ជារូបក្ខន្ធ ទស្សនៈ ជាវិញ្ញាណក្ខន្ធ វេទនាដែលសម្បយុត្តដោយវិញ្ញាណក្ខន្ធនោះ ជាវេទនាខន្ធ សញ្ញាចាត់ជាសញ្ញាខន្ធ សម្បយុត្តធម៌មានផស្សៈជាដើម ជាសង្ខារក្ខន្ធ ។ ការក្រឡេក និងការងាក រមែងប្រាកដ ព្រោះខន្ធ ៥ ទាំងនេះប្រជុំគ្នាដោយប្រការដូច្នេះ ។ ក្នុងការក្រឡេក និងការងាកនោះ អ្នកណាម្នាក់នឹងមើលទៅខាងមុខ អ្នកណាម្នាក់ងាកទៅខាងក្រោយ ។ ចក្ខុក៏ដូចគ្នា ចាត់ជាចក្ខាយតនៈ រូបជារូបាយតនៈ ទស្សនៈជាមនាយតនៈ សម្បយុត្ត-ធម៌ទាំងឡាយមានវេទនាជាដើមជាធម្មាយតនៈ ។ ការមើលទៅខាងមុខ និងការក្រឡេកទៅតាមទិស រមែងប្រាកដ ព្រោះអាយតនៈ ៤ ទាំងនេះប្រជុំគ្នា ដោយប្រការដូច្នេះ ។ ក្នុងការមើលទៅខាងមុខ និងការក្រឡេកទៅតាមទិសនោះ អ្នកណាម្នាក់មើលទៅខាងមុខ អ្នកណាម្នាក់ងាកទៅខាងក្រោយ ។ ចក្ខុក៏ដូចគ្នា ចាត់ជាចក្ខុធាតុ រូបជារូបធាតុ ទស្សនៈជាចក្ខុវិញ្ញាណធាតុ ធម៌ទាំងឡាយមានវេទនាជាដើម ដែល

សម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ជាធម្មធាតុ ។ ការក្រឡេកទៅខាងមុខ និងការក្រឡេកទៅតាមទិស រមែងប្រាកដ ព្រោះធាតុ ៤ ទាំងនេះប្រជុំគ្នា ដោយប្រការដូច្នេះ ។ ក្នុងការមើលទៅខាងមុខ និងការក្រឡេកទៅតាមទិសនោះ អ្នកណាម្នាក់មើលទៅខាងមុខ អ្នកណាម្នាក់ងាកទៅខាងក្រោយ ។ ចក្ខុក៏ដូចគ្នា ជានិស្សយបច្ច័យ រូបជាអារម្មណបច្ច័យ អាវជ្ជនចិត្តជាអនន្តរបច្ច័យ សមនន្តរបច្ច័យ ឧបនិស្សយបច្ច័យ នត្ថិបច្ច័យ និងវិគតបច្ច័យ អាលោកៈជាឧបនិស្សយបច្ច័យ វេទនាជាដើម ជាសហជាតបច្ច័យជាដើម ។ ការមើលទៅខាងមុខ និងការក្រឡេកទៅតាមទិស រមែងប្រាកដ ព្រោះបច្ច័យទាំងនេះប្រជុំគ្នា ដោយប្រការដូច្នេះ ។ ក្នុងការមើលទៅខាងមុខ និងការក្រឡេកទៅតាមទិសនោះ អ្នកណាម្នាក់មើលទៅខាងមុខ អ្នកណាម្នាក់មើលទៅខាងក្រោយ អសម្មោហសម្បជញ្ញៈក្នុងការមើលទៅខាងមុខ និងការមើលទៅតាមទិសនេះ គប្បីជ្រាបដោយអំណាចការពិចារណាក្នុងខន្ធ អាយតនៈ ធាតុ និងបច្ច័យយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា សម្មិញ្ជិតេ បសារិតេ សេចក្តីថា បត់ចូល ឬលាចេញនៃឥរិយាបថទាំងឡាយ ។

ការពិចារណាប្រយោជន៍ និងមិនមែនប្រយោជន៍ ព្រោះការបត់ចូល ឬលាចេញនៃដៃជើងជាបច្ច័យ ហើយពិចារណាតែប្រយោជន៍ដោយ

មិនបានបត់ចូល ឬលាចេញដោយអំណាចចិត្តឡើយ ឈ្មោះថា សាត្ថកសម្បជញ្ញៈក្នុងការបត់ចូល ឬលាចេញនោះ ។ គ្រប់ៗ ខណៈ ដែលភិក្ខុឈរបត់ ឬលាតដៃ និងជើងយូរពេកទៅ វេទនារមែងកើតឡើងក្នុងការបត់ ឬលាតនោះ ចិត្តរមែងមិនបានអារម្មណ៍តែមួយ ។ កម្មដ្ឋានរមែងវិនាសទៅ ។ ភិក្ខុនោះ នឹងមិនសម្រេចគុណវិសេស ។ តែកាលភិក្ខុបត់ចូលល្មមល្អ លាចេញល្មមល្អ វេទនានោះៗ រមែងមិនកើតឡើង ។ ចិត្ត រមែងមានអារម្មណ៍តែមួយ ។ កម្មដ្ឋាន រមែងសម្រេច ។ លោករមែងសម្រេចគុណវិសេសបាន ។ ការពិចារណាប្រយោជន៍ និងមិនមែនប្រយោជន៍ គប្បីជ្រាបយ៉ាងនេះ ដោយប្រការដូច្នេះ ។

មួយវិញទៀត សូម្បីកាលមានប្រយោជន៍ ការពិចារណាដល់អារម្មណ៍សប្បាយ និងអសប្បាយ ហើយពិចារណាតែអារម្មណ៍ដែលជាសប្បាយ ឈ្មោះថា សប្បាយសម្បជញ្ញៈ ។ ក្នុងសប្បាយសម្បជញ្ញៈក្នុងការបត់ចូល ឬលាចេញនោះ មានន័យដូច្នេះ ។

បានឮថា ភិក្ខុឈ្មោះច្រើនរូប ស្វាធ្យាយព្រះធម៌នៅត្រង់លានព្រះចេតិយ ។ ភិក្ខុនីក្រមុំច្រើនរូប ស្តាប់ធម៌នៅខាងក្រោយភិក្ខុទាំងនោះ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុឈ្មោះមួយរូប លូកដៃចេញទៅត្រូវកាយភិក្ខុនី ទើបសឹកជាគ្រហស្ថ ព្រោះហេតុនោះឯង ។

ភិក្ខុមួយរូបទៀត កាលដាក់ជើង បានដាក់ជើងទៅក្នុងភ្នក់ភ្លើង ។

ត្រូវភ្លើងឆេះជើងដល់ឆ្អឹង ។

ភិក្ខុមួយរូបទៀត បានដាក់ជើងទៅទីដំបូក ត្រូវអាសិរពិសខាំ ។ ភិក្ខុមួយរូប លាដៃទៅលើឈើបន្ទោងមុង ត្រូវពស់ខៀវខាំ ។ ព្រោះដូច្នោះ ភិក្ខុមិនគួរលាដៃជើងទៅក្នុងទីដែលជាអសប្បាយដូច្នេះ គួរលាទៅក្នុងទីដែលជាសប្បាយ ។

នេះជាសប្បាយសម្បជញ្ញៈ ក្នុងបទថា សម្មិញ្ជិតេ បសារិតេ នេះ ។

ក៏គោចរសម្បជញ្ញៈ គប្បីសម្ដែងដោយរឿងរបស់ព្រះមហាថេរៈ ។

បានឮថា ព្រះមហាថេរៈអង្គុយនៅក្នុងទីសម្រាកពេលថ្ងៃ សន្ទនាជាមួយអន្តេវាសិកទាំងឡាយ បត់ដៃចូលមកដោយរហ័ស ហើយលាចេញទៅក្នុងទីដើមវិញ ហើយសន្សឹមៗ បត់ចូល អន្តេវាសិកទាំងឡាយសួរលោកថា "បពិត្រលោកដ៏ចម្រើនហេតុអ្វី លោកទើបបត់ដៃចូលមកដោយរហ័ស ហើយលាចេញទៅក្នុងទីដើមវិញ ហើយបត់ចូលសន្សឹមៗម្ដងទៀត" ។ ព្រះមហាថេរៈឆ្លើយថា "ម្នាលអាវុសោទាំងឡាយ តាំងពីយើងផ្ដើមមនសិការកម្មដ្ឋានមក យើងមិនធ្លាប់លះចោល កម្មដ្ឋានបត់ដៃឡើយ តែឥឡូវនេះយើងសន្ទនានឹងលោកទាំងឡាយ បានលះបង់ចោលកម្មដ្ឋានបត់ដៃចូល ព្រោះដូច្នោះ យើងទើបបានលាដៃចេញទៅក្នុងទីដើមវិញ ហើយបត់ចូលទៀត" ។ អន្តេវាសិកទាំងឡាយបានថ្វាយសាធុការថា "ល្អហើយ លោកអាចារ្យ" ដែលឈ្មោះថា ភិក្ខុគួរដូច្នេះ ។

ការមិនលះកម្មដ្ឋានក្នុងទីដូច្នេះ គប្បីជ្រាបថា ឈ្មោះថា គោចរសម្បជញ្ញៈ ដោយប្រការដូច្នេះ ។

អ្នកណាៗ ដែលឈ្មោះថា ខ្លួនក្នុងខាងក្នុង ដែលបត់ចូល ឬលាចេញ រមែងមិនមាន ។ មានតែការបត់ចូល ឬលាចេញដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយាចិត្ត មានប្រការដូចពោលហើយ ដូចមនុស្សយន្ត កម្រើកញ័រដៃជើងបាន ដោយអំណាចសរសៃខ្សែ ដូច្នោះ ។

ក៏ការកំណត់ដឹងយ៉ាងនេះ ដោយប្រការដូច្នេះ គប្បីជ្រាបថា ជាអសម្មោហសម្បជញ្ញៈក្នុងការបត់ចូល ឬលាចេញនេះ ។

ការប្រើប្រាស់ដោយការស្លៀកដណ្ដប់សង្ឃាដិ និងចីវរ និងដោយការទទួលភិក្ខាដោយបាត្រជាដើម ឈ្មោះថា ធារណា ក្នុងបទថា សង្ឃាដិ-បត្តចីវរធារណេ កាលទ្រទ្រង់នូវសង្ឃាដិ បត្តចីវរ នេះ ។

ក្នុងការប្រើប្រាស់សង្ឃាដិបាត្រ និងចីវរនោះ នឹងវិនិច្ឆ័យក្នុងការប្រើប្រាស់សង្ឃាដិ និងចីវរមុន ។ ការដែលភិក្ខុស្លៀក ឬដណ្ដប់ ត្រាច់បិណ្ឌបាតបានអាមិសៈមក គឺ ប្រយោជន៍ មានប្រការដូចដែលព្រះមាន-ព្រះភាគត្រាស់ទុក ដោយន័យជាដើមថា ដើម្បីការពារត្រជាក់ ដូច្នេះនុ៎ះឯង ឈ្មោះថា ប្រយោជន៍ ។ គប្បីជ្រាប សាត្ថកសម្បជញ្ញៈ ដោយអំណាចនៃប្រយោជន៍នោះ ។

ក៏ចីវរសាច់ល្អិត ជាសប្បាយដល់ភិក្ខុសាច់ក្ដៅ និងមានកម្លាំង

តិច ចីវរសាច់ក្រាស់ ៦ ជាន់ ជាសប្បាយដល់ភិក្ខុសាច់ត្រជាក់ ។ ចីវរដែលផុយគ្នាមិនជាសប្បាយ ។ ចីវរចាស់មិនជាសប្បាយដល់ភិក្ខុរូបណាមួយឡើយ ។ សេចក្ដីថា ចីវរចាស់នោះ រមែងធ្វើសេចក្ដីកង្វល់ដល់ភិក្ខុនោះ ព្រោះចាំបាច់ត្រូវដេរប៉ះជាដើម ។ ចីវរប្រភេទសំពត់ធូតពីរជាដើម ជាទីតាំងនៃសេចក្ដីលោភ ធ្វើឲ្យកង្វល់ដូចគ្នា ។ សេចក្ដីថា ចីវរដូច្នោះ រមែងធ្វើអន្តរាយដល់ភិក្ខុដែលនៅក្នុងព្រៃតែមួយរូប នឹងអាចធ្វើអន្តរាយដល់ជីវិតក៏បាន ។

ក៏ចីវរណាកើតឡើងដោយអំណាចមិច្ឆាជីវៈ មាននិមិត្តកម្មជាដើម និងចីវរណាកាលភិក្ខុនោះប្រើប្រាស់ អកុសលធម៌ចម្រើនឡើង កុសល-ធម៌សាបសូន្យទៅ ចីវរនោះជាអសប្បាយដោយត្រង់ ។ ចីវរដែលផុយគ្នា ជាសប្បាយ ។ ក្នុងទីនេះ គប្បីជ្រាបសប្បាយសម្បជញ្ញៈ ដោយអំណាចចីវរដែលជាសប្បាយនោះ និងគប្បីជ្រាបគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះបង់កម្មដ្ឋានទុំះឯង ។

អ្នកណាៗ ឈ្មោះថា ខ្លួនក្នុងខាងក្នុង ដែលឈ្មោះថា ឃ្លុំចីវររមែងមិនមាន ។ មានតែការឃ្លុំចីវរ ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយាចិត្ត មានប្រការដូចពោលហើយប៉ុណ្ណោះ ។

ក្នុងចីវរ និងកាយនោះ សូម្បីចីវរ ក៏មិនមានចេតនា សូម្បីកាយក៏មិនមានចេតនា ។ ចីវរ រមែងមិនដឹងថា យើងឃ្លុំកាយទុក ។ សូម្បី

កាយក៏មិនដឹងថា យើងត្រូវចីវរឃ្មុំទុក ។ ធាតុទាំងឡាយប៉ុណ្ណោះ គ្រប ពួកធាតុ ដូចយកសំពត់ចាស់គ្របគម្ពីរទុក ដូច្នោះ ។ ព្រោះដូច្នោះ ភិក្ខុបានចីវរល្អ ក៏មិនគួរត្រេកអរ បានចីវរមិនល្អ ក៏មិនគួរទាស់ចិត្ត ។ ដូចសេចក្តីថា ដំបូក ព្រះចេតិយ និងដើមឈើដែលស័ក្តិសិទ្ធជាដើម បុគ្គលពួកខ្លះបូជាដោយផ្កាឈើ របស់ក្រអូប ធូប និង សំពត់ជាដើម បុគ្គលពួកខ្លះមិនបូជា បន្ទោបង់លាមក មូត្រ ចោលភក់ និងប្រហារ ដោយដំបង និងសស្ត្រាជាដើម ដំបូក ដល់ដើមឈើជាដើមៗ រមែងមិន សប្បាយចិត្ត ឬទាស់ចិត្តដោយការបូជា និងមិនបូជាទាំងនោះ ភិក្ខុបាន ចីវរល្អ មិនគួរត្រេកអរ បានចីវរមិនល្អមិនគួរទាស់ចិត្តឡើយ ដូច្នោះ ដូចគ្នា គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងការប្រើប្រាស់សង្ឃាដិ និង ចីវរនេះ ដោយអំណាចពិចារណាដែលប្រព្រឹត្តទៅយ៉ាងនេះ ដោយប្រការ ដូច្នេះ ។

សូម្បីក្នុងការប្រើប្រាស់បាត្រ គប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយ អំណាចប្រយោជន៍ដែលគប្បីបានចំពោះ ព្រោះភិក្ខុមិនចាប់បាត្រដោយប្រញាប់ តែចាប់បាត្រដោយពិចារណាយ៉ាងនេះថា កាលយើងចាប់បាត្រនេះ ត្រាច់ ទៅបិណ្ឌបាត្រនឹងបានភិក្ខា ដូច្នេះជាបច្ច័យ ។

ក៏បាត្រធ្ងន់មិនជាសប្បាយដល់ភិក្ខុដែលមានរាងកាយស្គម មាន កម្លាំងតិច ។ បាត្រដែលដិបរដុបមាន ៤-៥ ថ្នេរ លំបាកលាង មិនជា

សប្បាយដល់ភិក្ខុរូបណាមួយឡើយ ។ សូម្បីបាត្រដែលលំបាកលាង ក៏មិនគួរ ។ ដោយន័យថា កាលលាងបាត្រនោះ លោកនឹងមានកង្វល់ ។

ក៏បាត្រ ដែលមានពណ៌ដូចកែវមណី ជាទីតាំងនៃសេចក្តីលោភ មិនជាសប្បាយតាមន័យដែលពោលហើយក្នុងចីវរនុ៎ះឯង ។

មួយវិញទៀត បាត្រដែលបានមកដោយអំណាចនិមិត្តកម្មជាដើម មិនជាសប្បាយ និងបាត្រណាកាលភិក្ខុប្រើប្រាស់ អកុសលធម៌ទាំងឡាយរមែងចម្រើនឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ បាត្រនេះជាអសប្បាយតែម្យ៉ាងប៉ុណ្ណោះ ។ បាត្រដែលផ្ទុយគ្នា ជាសប្បាយ ។ ក្នុងការប្រើប្រាស់បាត្រនេះ គប្បីជ្រាបសប្បាយសម្បជញ្ញៈ ដោយអំណាចបាត្រនោះ ។ គប្បីជ្រាបគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះបង់កម្មដ្ឋាននុ៎ះឯង ។

អ្នកណាៗ ឈ្មោះថា ខ្លួនក្នុងខាងក្នុង កាន់បាត្រ រមែងមិនមាន ។ មានតែការកាន់បាត្រ ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយាចិត្ត មានប្រការដូចពោលហើយប៉ុណ្ណោះ ។

ក្នុងការកាន់បាត្រនោះ សូម្បីបាត្រក៏មិនមានចេតនា សូម្បីដៃក៏មិនមានចេតនា ។ បាត្រមិនដឹងថា យើងត្រូវដៃកាន់ ។ សូម្បីដៃទាំងឡាយក៏មិនដឹងថា យើងកាន់បាត្រ ។ ធាតុទាំងឡាយប៉ុណ្ណោះកាន់ពួកធាតុ ដូចយកដង្កាប់ចាប់បាត្រដែលក្តៅដូចភ្លើង ដូច្នោះ ។ គប្បី

ជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងការប្រើប្រាស់បាត្រនេះ ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត មនុស្សទាំងឡាយឃើញមនុស្សអនាថាម្នាក់ កំបុតដៃជើង មានខ្ទុះឈាម និងពួកដង្កូវចេញពីមុខដំបៅ មានរុយក្បាលខៀវចោមរោម ដេកនៅលើសាលាជាទីអាស្រ័យរបស់មនុស្សអនាថា អ្នកដែលមានសេចក្តីអាណិតយកសំពត់រុំដំបៅមកឲ្យខ្លះ យកថ្នាំដាក់អំបែងក្បឿងជាដើមមកឲ្យខ្លះ ដល់មនុស្សអនាថាទាំងនោះ បណ្តារបស់ទាំងនោះ សំពត់រុំដំបៅរបស់អ្នកខ្លះជាសំពត់សាច់ល្អិតក៏មាន របស់អ្នកខ្លះជាសំពត់សាច់គ្រោតគ្រាតក៏មាន អំបែងក្បឿងដាក់ថ្នាំរបស់អ្នកខ្លះ រូបរាងស្អាតក៏មាន របស់អ្នកខ្លះរូបរាងមិនស្អាតក៏មាន មនុស្សអនាថាទាំងនោះ រមែងមិនត្រេកអរ ឬរង្កៀសក្នុងវត្ថុទាំងនោះ ដោយសេចក្តីថា មនុស្សអនាថាទាំងនោះ ត្រូវការត្រឹមតែសំពត់បិទដំបៅប៉ុណ្ណោះ និងអំបែងក្បឿងក៏ត្រឹមតែដាក់ថ្នាំទុកប៉ុណ្ណោះ សេចក្តីនេះយ៉ាងណា ក៏ភិក្ខុណាពិចារណាចីវរដូចសំពត់រំដំបៅ បាត្រដូចអំបែងក្បឿងដាក់ថ្នាំ និងភិក្ខាដែលបានក្នុងបាត្រដូចថ្នាំ ភិក្ខុនេះក៏ដូច្នោះ គប្បីជ្រាបថា ជាអ្នកធ្វើសេចក្តីដឹងខ្លួនខ្ពស់បំផុតដោយអសម្មោហសម្បជញ្ញៈក្នុងការប្រើប្រាស់សង្ឃាដិ បាត្រ និងចីវរ ។

ក្នុងបទថា អសិតេ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា អសិតេ បានដល់ ក្នុងការឆាន់បិណ្ឌបាត ។

បទថា បីតេ បានដល់ ក្នុងការហុតយាគូជាដើម ។

បទថា ខាយិតេ បានដល់ ក្នុងការទំពារស៊ី របស់ទំពារស៊ី ដែលធ្វើដោយម្សៅជាដើម ។

បទថា សាយិតេ លិទ្ធ បានដល់ ក្នុងការភ្លក់រសទឹកឃ្មុំ និងទឹកអំពៅជាដើម ។

ប្រយោជន៍សូម្បី ៨ ដូចដែលត្រាស់ទុកដោយន័យមានជាដើមថា នេវ ទវាយ មិនមែនឆាន់ដើម្បីលេង ដូច្នេះ ឈ្មោះថា ប្រយោជន៍ គប្បីជ្រាប សាត្ថកសម្បជញ្ញៈ ដោយអំណាចប្រយោជន៍នោះ ។

ក៏បណ្តាភោជនដែលថោកទាប ឬប្រណីត ប្រៃ ឬផ្អែមជាដើម ភិក្ខុណាមិនសុខស្រួល ព្រោះភោជនណា ភោជននោះ មិនជាសប្បាយ ដល់ភិក្ខុនោះ ។

មួយវិញទៀត ភោជនណា ដែលបានមកដោយអំណាចនិមិត្តកម្ម ជាដើម និងភោជនណាកាលភិក្ខុនោះឆាន់នៅ អកុសលធម៌ទាំងឡាយ រមែងចម្រើនឡើង កុសលធម៌ទាំងឡាយរមែងសាបសូន្យទៅ ភោជននោះ ជាអសប្បាយតែម្យ៉ាងប៉ុណ្ណោះ ។ ភោជនដែលផ្ទុយគ្នា ជាសប្បាយ ។ ក្នុងការឆាន់ជាដើមនេះ គប្បីជ្រាប សប្បាយសម្បជញ្ញៈដោយអំណាច ភោជននោះ និងគប្បីជ្រាប គោចរសម្បជញ្ញៈដោយអំណាចការមិន លះបង់កម្មដ្ឋានទុំះឯង ។

អ្នកណាៗ ឈ្មោះថា ខ្ជួនក្នុងខាងក្នុង ជាអ្នកបរិភោគ រមែងមិនមាន ។ ឈ្មោះថា ការកាន់បាត្រ រមែងមានដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយាចិត្តមានប្រការដូចពោលហើយប៉ុណ្ណោះ ។ ឈ្មោះថា ការលូកដៃចុះក្នុងបាត្រ រមែងមានដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយាចិត្តប៉ុណ្ណោះ ។ ការធ្វើពំនូតបាយ ការលើកពំនូតបាយឡើង និងការហាមាត់ រមែងមានដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយាចិត្តប៉ុណ្ណោះ អ្នកណាៗ ក៏ប្រើសោរយន្តខែ្ចងថ្គាមមិនបាន ។ ការប្រកពំនូតបាយក្នុងមាត់ ធ្មេញលើធ្វើនាទី ជាអង្រែ ធ្មេញក្រោមធ្វើនាទីជាត្បាល់ និងអណ្តាតធ្វើនាទីជាដៃ រមែងមានដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។ ក្នុងការបរិភោគនោះ មានទឹកមាត់ខ្លះៗ នៅចុងអណ្តាត ទឹកមាត់ច្រើននៅគល់អណ្តាតលាយច្របល់ ។ របស់ទំពារនោះត្រូវកៀសដោយ ដៃ គឺ អណ្តាតចុះក្នុងត្បាល់ គឺ ធ្មេញក្រោម ទឹក គឺ ទឹកមាត់ធ្វើ ឲ្យសើមជោគ បុកលម្អិតដោយអង្រែ គឺ ធ្មេញលើ ។ មិនមានអ្នកណាមកដួសដាក់ចូលទៅខាងក្នុងដោយស្លាបព្រា ឬវែកទេ ។ ចូលទៅ ដោយវាយោធាតុន៎ុះឯង ។ អាហារដែលធ្លាក់តាមបំពង់កចុះទៅៗ មិនមានអ្នកណាយកវត្ថុដែលក្រាលដោយចំបើង មកទទួលទេ ។ តាំងនៅបានដោយអំណាចវាយោធាតុន៎ុះឯង ។ អាហារដែលតាំងនៅនោះៗ ក៏មិនមានអ្នកណាធ្វើ

ចង្ក្រានបង្កាត់ភ្លើងដាំស្លទេ ។ រមែងឆ្អិនដោយតេជោធាតុនោះឯង ។ អាហារដែលឆ្អិនហើយ មិនមានអ្នកណាប្រើដំបង ឬឈើច្រត់កៀរចេញខាងក្រៅទេ ។ វាយោធាតុនុ៎ះឯងនាំចេញ (បន្ទោបង់) ។

ដោយប្រការដូច្នេះ វាយោធាតុ រមែងនាំអាហារចូល ផ្លាស់ប្តូរតាំងទុក ត្រឡប់ទៅត្រឡប់មក បុកឲ្យល្អិត ធ្វើឲ្យស្ងួត និងនាំចេញ ។ បឋវីធាតុតាំងទុក ត្រឡប់ទៅត្រឡប់មក បុកឲ្យល្អិត និងធ្វើឲ្យស្ងួត ។ អាបោធាតុធ្វើឲ្យស្អិត តាមរក្សាភាពសើមទុក ។ តេជោធាតុធ្វើអាហារដែលចូលទៅខាងក្នុងឲ្យឆ្អិន អាកាសធាតុចែកឲ្យជាដុំៗ ។ វិញ្ញាណធាតុបង្គាប់ការឲ្យធាតុផ្សេង ៗ ធ្វើនាទីឲ្យត្រូវក្នុងរឿងនោះៗ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងការបរិភោគនេះ ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅយ៉ាងនេះ ដោយប្រការដូច្នេះ ។

មួយ៉ាងទៀត គប្បីជ្រាបអសម្មោហសម្បជញ្ញៈក្នុងការបរិភោគនេះ ដោយពិចារណាជារបស់បដិកូល ១០ ប្រការយ៉ាងនេះ គឺ ដោយការទៅ ១ ដោយការស្វែងរក ១ ដោយការបរិភោគ ១ ដោយទីអាស្រ័យ ១ ដោយប្រឡាក់ប្រឡូស ១ ដោយមិនទាន់រលួយ ១ ដោយរលួយហើយ ១ ដោយផល ១ ដោយហូរចេញ ១ ដោយប្រលាក់ ១ ។ ចំណែកសេចក្តីពិស្តារក្នុងរឿងនេះ គប្បីកាន់យកពីអាហារេបដិកូលសញ្ញានិទ្ទេសក្នុងវិសុទ្ធិមគ្គ ។

បទថា ឧច្ចារបស្សាវកម្មេ បានដល់ ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ។

ក្នុងបទនោះ មានអធិប្បាយថា កាលដល់វេលាបន្ទោបង់ហើយ មិនបានបន្ទោបង់ឧច្ចារបស្សាវៈ ញើសហូរចេញចាករាងកាយទាំងអស់ ភ្នែកក្រឡឹតក្រឡាប់ ចិត្តមិនមានអារម្មណ៍តែមួយ និងរោគដទៃៗ រមែងកើតឡើង ។ តែកាលបន្ទោបង់ឧច្ចារបស្សាវៈ គ្រប់យ៉ាងនោះ រមែងមិនមាន នេះជាសេចក្តីក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ គប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយសេចក្តីនោះ ។

ក៏ភិក្ខុបន្ទោបង់ឧច្ចារបស្សាវៈ ក្នុងទីមិនសមគួរ រមែងជាអាបត្តិ រមែងខូចឈ្មោះ ជាអន្តរាយដល់ជីវិត កាលបន្ទោបង់ឧច្ចារបស្សាវៈក្នុងទីសមគួរគ្រប់យ៉ាងនោះ រមែងមិនមាន ដូច្នោះការដឹងខ្លួនក្នុងការបន្ទោបង់ឧច្ចារបស្សាវៈនេះ ទើបជាសប្បាយ ។ គប្បីជ្រាបសប្បាយសម្បជញ្ញៈ ដោយសប្បាយនោះ ។ គប្បីជ្រាបគោចរសម្បជញ្ញៈ ដោយមិនលះបង់កម្មដ្ឋានទុំះឯង ។

ឈ្មោះថា ខ្លួនក្នុងខាងក្នុង អ្នកបន្ទោបង់ឧច្ចារបស្សាវៈ រមែងមិនមាន ។ មានតែការបន្ទោបង់ឧច្ចារបស្សាវៈ ដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។

ឬថា ព្រោះបូសបែក កាលបូសទុំ ខ្ទុះ និងឈាម រមែងហូរ

ចេញដោយមិនមានអ្នកណាត្រូវការ យ៉ាងណា ភាជនៈទឹកដែលពេញប្រៀប ទឹករមែងហូរចេញ ដោយមិនមានអ្នកណាត្រូវការ យ៉ាងណា ឧច្ចារបស្សាវៈដែលសន្សំនៅក្នុងពោះវៀនធំ និងក្រពះនោម ត្រូវកម្លាំងខ្យល់សង្កត់ រមែងហូរចេញ សូម្បីដោយមិនមានអ្នកណាត្រូវការ ដូច្នោះ ។

ក៏ឧច្ចារបស្សាវៈនេះ កាលហូរចេញយ៉ាងនេះ រមែងមិនជារបស់ភិក្ខុនោះ មិនជារបស់អ្នកដទៃ ជាកាកអាហារដែលហូរចេញពីរាងកាយប៉ុណ្ណោះឯង ។ ដូចអ្វី ។ ដូចជាអ្នកដែលដួសទឹកចាស់ ចេញពីពាងទឹក ទឹកចាស់នោះ រមែងមិនជារបស់ខ្លួន មិនជារបស់អ្នកដទៃ គឺ ត្រឹមតែលាងពាងប៉ុណ្ណោះឯង ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងការបន្ទោរបង់ឧច្ចារបស្សាវៈនេះ ដោយពិចារណាការប្រព្រឹត្តទៅ ដោយប្រការដូច្នេះ ។

ក្នុងបទថា គតេ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា គតេ បានដល់ ក្នុងការដើរ ។

បទថា ឋិតេ បានដល់ ក្នុងការឈរ ។

បទថា និសិន្នេ បានដល់ ក្នុងការអង្គុយ ។

បទថា សុត្តេ បានដល់ ក្នុងការដេក ។

បទថា ជាគរិតេ បានដល់ ក្នុងការភ្ញាក់ ។

បទថា ភាសិតេ បានដល់ ក្នុងការនិយាយ ។

បទថា តុណ្ហីភាវេ បានដល់ ការនៅស្ងៀម ។

ក៏ក្នុងព្រះសូត្រនេះថា ភិក្ខុកាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ដូច្នេះ ទ្រង់ត្រាស់ដល់ឥរិយាបថធំ ។

ក្នុងពាក្យនេះថា ក្នុងការដើរទៅមុខ ក្នុងការថយក្រោយ ក្នុងការក្រឡេកមើលទៅមុខ ក្នុងការក្រឡេកមើលទៅទិសផ្សេងៗ ក្នុងការបត់ចូល ក្នុងការលាចេញ ដូច្នេះ ត្រាស់ដល់ឥរិយាបថកណ្តាល ។

តែក្នុងទីនេះថា ក្នុងការដើរ ការឈរ ការអង្គុយ ការដេកលក់ ការភ្ញាក់ឡើង ដូច្នេះ ទ្រង់ត្រាស់ដល់ឥរិយាបថតូចៗ ។ ព្រោះដូច្នោះ គប្បីជ្រាប ភាពជាអ្នកធ្វើសេចក្តីដឹងខ្លួនក្នុងឥរិយាបថ សូម្បីទាំងនោះ ដោយន័យដែលពោលហើយនុ៎ះឯង ។

ក៏ព្រះមហាសិវត្ថេរៈអ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា ភិក្ខុណាដើរ ឬចង្ក្រមយូរ ខាងក្រោយឈរស្ងៀម រមែងពិចារណាឃើញដូច្នេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅក្នុងវេលាចង្ក្រម រលត់ទៅក្នុងខណៈឈរស្ងៀមនោះឯង ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើសេចក្តីរឭកដឹងខ្លួនក្នុងការដើរ ។

ភិក្ខុណាស្វាធ្យាយក្តី វិសជ្ជនាបញ្ហាក្តី មនសិការកម្មដ្ឋានក្តី ឈរយូរ ខាងក្រោយអង្គុយចុះ រមែងពិចារណាឃើញដូច្នេះថា រូបធម៌ និង

អរូបធម៌ដែលប្រព្រឹត្តទៅក្នុងវេលាឈរ រលត់ទៅក្នុងខណៈអង្គុយចុះនោះឯង ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើសេចក្ដីរឭកដឹងខ្លួនក្នុងការឈរ ។

ភិក្ខុណាអង្គុយយូរ ដោយធ្វើការស្វាធ្យាយជាដើម ខាងក្រោយក្រោកឡើង រមែងពិចារណាឃើញដូច្នេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅក្នុងវេលាអង្គុយ រលត់ទៅក្នុងខណៈក្រោកឡើងនោះឯង ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើសេចក្ដីរឭកដឹងខ្លួនក្នុងការអង្គុយ ។

តែភិក្ខុណាដេកទន្ទេញក្ដី មនសិការកម្មដ្ឋានក្ដី លក់ទៅ កាលក្រោកឡើង រមែងពិចារណាឃើញដូច្នេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅក្នុងវេលាដេករលត់ទៅក្នុងខណៈក្រោកឡើងនោះឯង ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើសេចក្ដីរឭកដឹងខ្លួនក្នុងការដេកលក់ និងការភ្ញាក់ ។ ក៏ចិត្តដែលមិនធ្វើការងារឈ្មោះថា លក់ ដែលធ្វើការងារឈ្មោះថា ភ្ញាក់ ។

ភិក្ខុណាកំពុងនិយាយហើយ មានសតិសម្បជញ្ញៈថា ឈ្មោះថាសម្លេងនេះ រមែងកើតព្រោះអាស្រ័យបបូរមាត់ ធ្មេញ អណ្ដាត ពិតាន និងសេចក្ដីព្យាយាមដែលសមគួរដល់រឿងនោះៗ របស់ចិត្ត ដូច្នេះ និយាយឬថា ស្វាធ្យាយក៏ដោយ ពោលធម៌ក៏ដោយ ចម្រើនកម្មដ្ឋានក៏ដោយ វិសជ្ជនាបញ្ហាក៏ដោយ រហូតដល់អស់កាលយូរ ហើយស្ងៀមទៅក្នុងខាងក្រោយ រមែងពិចារណាឃើញដូច្នេះថា រូបធម៌ និងអរូបធម៌ដែលកើតឡើងក្នុងវេលានិយាយ រលត់ទៅក្នុងខណៈស្ងៀមនោះឯង ភិក្ខុនេះឈ្មោះ

ថា ជាអ្នកធ្វើសេចក្តីរឭកដឹងខ្លួនក្នុងការនិយាយ ។

ភិក្ខុណាស្ងៀម ហើយញ៉ាំងមនសិការក្នុងព្រះធម៌ ឬកម្មដ្ឋានអស់វេលាយូរ ខាងក្រោយពិចារណាឃើញដូច្នេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងវេលាស្ងៀម រលត់ទៅក្នុងខណៈស្ងៀមនេះឯង ដោយសេចក្តីថា កាលឧបាទាយរូបកើត ឈ្មោះថា **និយាយ** កាលមិនកើត ឈ្មោះថា ស្ងៀម ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើសេចក្តីរឭកដឹងខ្លួនក្នុងភាពជាអ្នកស្ងៀម ដោយប្រការដូច្នេះ ។ រឿងនេះ ព្រះមហាសីវត្ថេរៈពោលទុកហើយ ។

នាទីរបស់អសម្មោហសម្បជញ្ញៈ លោកប្រាប់ថាក្នុងមហាសតិប្បដ្ឋានសូត្រ ។ តែក្នុងសាមញ្ញផលសូត្រនេះ រមែងបានសម្បជញ្ញៈ ៤ យ៉ាង សូម្បីទាំងអស់ដូច្នោះ គប្បីជ្រាប ភាពជាអ្នកធ្វើសេចក្តីរឭកដឹង ខ្លួនដោយអំណាចនៃសម្បជញ្ញៈ ៤ ក្នុងទីនេះ តាមន័យដែលពោលហើយនុ៎ះឯង ។

ក៏បទថា សម្បជានការី នេះ គប្បីជ្រាបសេចក្តីដោយសម្បជញ្ញៈ ដែលសម្បយុត្តដោយសតិនោះឯង គ្រប់ៗ បទ ។ បទថា សតិសម្បជញ្ញេនសមន្នាគតោ ក៏មានសេចក្តីពិស្តារប៉ុណ្ណេះ ។

តែក្នុងវិភង្គប្បករណ៍ ទ្រង់ចែកបទទាំងនេះទុក យ៉ាងនេះថា សតោ សម្បជានោ អភិក្កមតិ សតោ សម្បជានោ បដិក្កមតិ ជាអ្នកមាន

សតិសម្បជញ្ញៈ ឈានទៅមុខ ជាអ្នកមានសតិសម្បជញ្ញៈ ឈានត្រឡប់ដូច្នេះឯង ។

បទថា ឯវំ ខោ មហារាជ សេចក្តីថា ភិក្ខុកាលញ៉ាំងការឈានទៅជាដើម ឲ្យប្រព្រឹត្តទៅ ដោយសម្បជញ្ញៈដែលសម្បយុត្តដោយសតិយ៉ាងនេះ រមែងឈ្មោះថា ជាអ្នកប្រកបដោយសតិសម្បជញ្ញៈ ។

## ពណ៌នា សន្តោសកថា

[១២៤] បទថា សន្តុដ្ឋោ ក្នុងសេចក្តីថា ឥធ មហារាជ ភិក្ខុ សន្តុដ្ឋោ ហោតិ មានសេចក្តីថា ជាអ្នកប្រកបដោយសេចក្តីត្រេកអរក្នុងបច្ច័យតាមមានតាមបាន ។

ក៏សន្តោសនេះ មាន ១២ យ៉ាង អ្វីខ្លះ ?

សន្តោសក្នុងចីវរ ៣ យ៉ាង គឺ យថាលាភសន្តោសៈ យថាពលសន្តោសៈ យថាសារុប្បសន្តោសៈ ។

ក្នុងបិណ្ឌបាតជាដើម ក៏យ៉ាងនេះ ។

សន្តោសៈ ១២ ប្រភេទនោះ មានអធិប្បាយដូចតទៅនេះ ៖

ភិក្ខុក្នុងធម្មវិន័យនេះ បានចីវរល្អក៏ដោយ មិនល្អក៏ដោយ លោកប្រើប្រាស់ចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ ដល់បាន ក៏មិនទទួល នេះជា យថាលាភសន្តោសៈ ក្នុងចីវររបស់លោក ។

តមកខាងក្រោយ លោកមានកម្លាំងតិចតាមធម្មតាក្តី ត្រូវជម្ងឺគ្របសង្កត់ក្តី ត្រូវជរាគ្របសង្កត់ក្តី កាលដណ្តប់ចីវរធ្ងន់ រមែងលំបាក លោកប្តូរចីវរនោះនឹងភិក្ខុដែលត្រូវគ្នា សូម្បីប្រើប្រាស់ចីវរស្រាលហើយ ក៏នៅជាអ្នកសន្តោសដែរ នេះជា យថាពលសន្តោសៈ ក្នុងចីវររបស់លោក ។

ភិក្ខុមួយរូបទៀត បានបច្ច័យយ៉ាងប្រណីត គ្រាលោកបានបាត្រនិងចីវរជាដើមយ៉ាងណាមួយ ជាបាត្រ ចីវរមានតម្លៃច្រើន ឬមានចំនួនច្រើន លោកថ្វាយដោយគិតថា នេះសមគួរដល់ព្រះថេរៈទាំងឡាយអ្នកបួសយូរ នេះសមគួរដល់ភិក្ខុពហុស្សូត នេះសមគួរដល់ភិក្ខុឈឺ នេះចូរមានដល់ភិក្ខុដែលមានលាភតិច ដូច្នេះ ឬទទួលយកចីវរចាស់របស់ភិក្ខុទាំងនោះ ឬរើសយកសំពត់ដែលមិនមានជាយ ពីគំនរសម្រាមជាដើម សូម្បីយកសំពត់ទាំងនេះមកធ្វើជាសង្ឃាដិគ្រង ក៏នៅជាអ្នកសន្តោសនុ៎ះឯង នេះជា យថាសារុប្បសន្តោសៈ ក្នុងចីវររបស់លោក ។

មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាតសៅហ្មង ឬប្រណីត លោកប្រើប្រាស់បិណ្ឌបាតនោះប៉ុណ្ណោះ មិនប្រាថ្នាបិណ្ឌបាតដទៃ ដល់បានក៏មិនទទួល នេះជា យថាលាភសន្តោសៈ ក្នុងបិណ្ឌបាតរបស់លោក ។

ក៏ភិក្ខុណា បានបិណ្ឌបាតដែលមិនត្រូវនឹងរាងកាយប្រក្រតី ឬមិនត្រូវនឹងរោគរបស់ខ្លួន ដែលលោកបរិភោគហើយ នឹងមិនសប្បាយ លោក

ឲ្យបិណ្ឌបាតនោះដល់ភិក្ខុដែលពេញចិត្ត សូម្បីឆាន់គោជនដែលសប្បាយ តែដៃរបស់ភិក្ខុនោះធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្តោស នេះជាយថាពលសន្តោសៈ ក្នុងបិណ្ឌបាតរបស់លោក ។

ភិក្ខុមួយរូបទៀត បានបិណ្ឌបាតប្រណីតចំនួនច្រើន លោកថ្វាយបិណ្ឌបាតនោះដល់ព្រះថេរៈអ្នកបួសយូរ ដល់អ្នកពហុស្សូត ដល់អ្នកមានលាភតិច ដល់ភិក្ខុឈឺ ដូចចីវរនោះ សូម្បីទទួលអាហារដែលសេសសល់របស់ភិក្ខុនោះៗ ឬត្រាច់បិណ្ឌបាតហើយឆាន់អាហារដែលលាយគ្នា ក៏ជាអ្នកសន្តោសផងដែរ នេះជា យថាសារុប្បសន្តោសៈ ក្នុងបិណ្ឌបាតរបស់លោក ។

មួយវិញទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានសេនាសនៈដែលពេញចិត្ត ឬមិនពេញចិត្ត មិនសប្បាយចិត្ត មិនទាស់ចិត្ត ព្រោះសេនាសនៈនោះ ត្រេកអរតាមដែលបានប៉ុណ្ណោះ ដោយទីបំផុតសូម្បីជាកម្រាលក្រងដោយស្មៅ នេះជា យថាលាភសន្តោសៈក្នុងសេនាសនៈរបស់លោក ។

ក៏ភិក្ខុណា បានសេនាសនៈដែលមិនត្រូវនឹងរាងកាយប្រក្រតី ឬមិនត្រូវនឹងរោគរបស់ខ្លួន កាលលោកនៅមិនសប្បាយ លោកឲ្យសេនាសនៈនោះ ដល់ភិក្ខុដែលពេញចិត្ត សូម្បីនៅក្នុងសេនាសនៈដែលសប្បាយដែលជារបស់ភិក្ខុនោះ ក៏ជាអ្នកសន្តោសដែរ នេះជា យថាពលសន្តោសៈក្នុងសេនាសនៈរបស់លោក ។

ភិក្ខុមួយរូបទៀតមានបុណ្យច្រើន បានសេនាសនៈដែលប្រណីត ចំនួនច្រើន មានគុហា មណ្ឌប ផ្ទះកំពូលជាដើម លោកឲ្យសេនាសនៈទាំងនោះ ដល់ព្រះថេរៈអ្នកបួសយូរ អ្នកពហុស្សូត អ្នកមានលាភតិច និងអ្នកឈឺ ដូចចីវរ សូម្បីនៅក្នុងសេនាសនៈកន្លែងណាមួយ ក៏ជាអ្នកសន្តោសដែរ នេះជា យថាសារុប្បសន្តោសៈ ក្នុងសេនាសនៈរបស់លោក ។

ក៏ភិក្ខុណាពិចារណាឃើញយ៉ាងនេះថា ឈ្មោះថា សេនាសនៈថ្នាក់ល្អប្រសើរ ជាទីតាំងនៃសេចក្តីប្រមាទ អង្គុយក្នុងសេនាសនៈនោះរមែងងងុយដោកងក់លក់ទៅ កាលភ្ញាក់ឡើងទៀត ក៏សញ្ញឹងគិតតែរឿងកាម ហើយមិនទទួលសេនាសនៈដូច្នោះ សូម្បីត្រូវបានហើយ លោកហាមសេនាសនៈនោះ សូម្បីនៅក្នុងទីវាល ឬគល់ឈើជាដើម ក៏ជាអ្នកសន្តោសដែរ នេះ ក៏ជាយថាសារុប្បសន្តោសៈ ក្នុងសេនាសនៈ ។

មួយវិញទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈសៅហ្មង ឬប្រណីត លោកត្រេកអរតាមដែលបានប៉ុណ្ណោះ មិនប្រាថ្នាភេសជ្ជៈដទៃ ដល់បានក៏មិនទទួល នេះជា យថាលាភសន្តោសៈ ក្នុងគិលានប្បច្ច័យរបស់លោក ។

ក៏ភិក្ខុណាត្រូវការប្រេង បានទឹកអំពៅ លោកឲ្យទឹកអំពៅនោះ ដល់ភិក្ខុដែលគាប់ចិត្តគ្នា ហើយកាន់យកប្រេងពីដៃរបស់ភិក្ខុនោះ ឬស្វែងរករបស់ដទៃ សូម្បីកាលបានភេសជ្ជៈ ក៏ជាអ្នកសន្តោសទាំងឯង នេះ

ជា យថាពលសន្តោសៈ ក្នុងគិលានប្បច្ច័យរបស់លោក ។

ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានភេសជ្ជៈដែលប្រណីត មានប្រេង ទឹកអំពៅជាដើមចំនួនច្រើន លោកឲ្យភេសជ្ជៈនោះ ដល់ព្រះថេរៈអ្នកបួសយូរ អ្នកពហុស្សូត អ្នកមានលាភតិច និងអ្នកឈឺ ដូចចីវរ ហើយព្យាបាលអត្តភាពដោយភេសជ្ជៈយ៉ាងណាមួយ ដែលភិក្ខុទាំងនោះនាំមក ក៏ជាអ្នកសន្តោសដែរ ។

មួយទៀត ភិក្ខុណាដាក់សម៉ត្រាំទឹកមូត្រគោទុកក្នុងភាជនៈមួយ មានអ្នកមកប្រាប់ពោលដល់របស់ឆ្ងាញ់ ៤ យ៉ាង ក្នុងភាជនៈមួយថា កាន់យកចុះលោកម្ចាស់ បើត្រូវការ ដូច្នេះ លោកគិតថា បើរោគរបស់លោកនឹងបាត់ សូម្បីដោយរបស់ឆ្ងាញ់យ៉ាងណាមួយក្នុង ៤ យ៉ាងនោះ ទោះជាយ៉ាងនោះ ឈ្មោះថា សម៉ត្រាំទឹកមូត្រគោ ព្រះពុទ្ធជាដើមទ្រង់សរសើរហើយ ដូច្នេះ ហាមរបស់ឆ្ងាញ់ ៤ យ៉ាង ធ្វើភេសជ្ជៈដោយសម៉ត្រាំទឹកមូត្រគោប៉ុណ្ណោះ រមែងជាអ្នកសន្តោសយ៉ាងក្រៃលែង នេះជា យថាសារុប្បសន្តោសៈ ក្នុងគិលានប្បច្ច័យរបស់លោក ។

ក៏បរិក្ខារ ៨ គឺ ត្រៃចីវរ បាត្រ កាំបិតកោរ ឈើជំរះធ្មេញ ម្ជុល វត្ថពន្ធចង្កេះ និងសំពត់តម្រងទឹក រមែងគួរដល់ភិក្ខុដែលប្រកបដោយសេចក្តីត្រេកអរក្នុងបច្ច័យ តាមមានតាមបាន ១២ យ៉ាងនេះ ។ សមពិតដូចដែលទ្រង់ត្រាស់ទុកថា ៖

*ត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ រួមទាំងសំពត់តម្រងទឹក ជាគម្រប់ ៨ ទាំងនេះ ជាបរិក្ខាររបស់ភិក្ខុដែលប្រកបសេចក្តីព្យាយាម ។*

បរិក្ខារទាំងអស់នោះ ជាគ្រឿងបរិហារកាយក៏បាន ជាគ្រឿងបរិហារផ្ទៃក៏បាន ។ បរិហារយ៉ាងណា ? នឹងនិយាយដល់ចីវរមុន ភិក្ខុរក្សាកាយ ក្នុងវេលាស្លៀកដណ្តប់ចីវរត្រាច់ទៅ ដូច្នោះ ចីវរទើបឈ្មោះថា ជាគ្រឿងបរិហារកាយ ភិក្ខុចិញ្ចឹមរក្សាផ្ទៃ ក្នុងវេលាយកជាយចីវរត្រងទឹកហើយផឹក និងក្នុងវេលាយកចីវរគ្របរបស់គួរទំពារ និងផ្លែឈើតូចធំ ដូច្នោះ ចីវរទើបឈ្មោះថា ជាគ្រឿងបរិហារផ្ទៃ ។

សូម្បីបាត្រ រមែងជាគ្រឿងបរិហារកាយ ក្នុងវេលាយកបាត្រដងទឹកងូត និងក្នុងវេលាប្រោះព្រំកុដិ រមែងជាគ្រឿងបរិហារផ្ទៃ ក្នុងវេលាទទួលអាហារបរិភោគ ។

សូម្បីកាំបិត រមែងជាគ្រឿងបរិហារក្នុងវេលាកាត់ឈើជំរះធ្មេញដោយកាំបិតនោះ និងក្នុងវេលាតាក់តែងជើងគ្រែ និងដងក្ងស់ រមែងជាគ្រឿងបរិហារផ្ទៃក្នុងវេលាកាត់អំពៅ និងបកដូងជាដើម ។

សូម្បីម្ជុល រមែងជាគ្រឿងបរិហារកាយក្នុងវេលាដេរចីវរ រមែងជាគ្រឿងបរិហារផ្ទៃ ក្នុងវេលាចាក់នំ ឬផ្លែឈើធាន់ ។

វត្ថពន្ធចង្កេះ រមែងជាគ្រឿងបរិហារកាយ ក្នុងវេលាក្រវាត់ត្រាច់

ទៅ ជាគ្រឿងបរិហារផ្ទៃ ក្នុងវេលាចងអំពៅជាដើម ។

សំពត់តម្រងទឹក ជាគ្រឿងបរិហារកាយក្នុងវេលាប្រើសំពត់តម្រងទឹកនោះត្រងទឹកងូត និងក្នុងវេលាធ្វើការប្រោះព្រំសេនាសនៈ ជាគ្រឿងបរិហារផ្ទៃក្នុងវេលាត្រងទឹកផឹក និងក្នុងវេលាប្រើសំពត់តម្រងទឹកនោះឯងដាក់ល្ង អង្ករ និងអាហារក្រៀមជាដើមឆាន់ ។

គប្បីជ្រាបសេចក្តីក្នុងបរិក្ខារ ៨ ជាបរិក្ខារ ប៉ុណ្ណេះចុះ ។

ក៏កម្រាលដែលក្រាលទុកក្នុងទីនោះ ឬសោរ រមែងគួរដល់ភិក្ខុដែលមានបរិក្ខារ ៩ យ៉ាង ចូលទៅកាន់ទីដេក ។

សំពត់ក្រាលអង្គុយ ឬផ្ទាំងស្បែក រមែងគួរដល់ភិក្ខុដែលមានបរិក្ខារ ១០ យ៉ាង ។

ឈើច្រត់ ឬបំពង់ប្រេង រមែងគួរដល់ភិក្ខុដែលមានបរិក្ខារ ១១ យ៉ាង ។

ឆត្រ ឬស្បែកជើង រមែងគួរដល់ភិក្ខុដែលមានបរិក្ខារ ១២ យ៉ាង ។

ក៏បណ្តាភិក្ខុទាំងនេះ ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ឈ្មោះថាអ្នកសន្តោស ក្រៅពីនេះឈ្មោះថា មិនសន្តោស តែមិនគួរហៅថា ប្រាថ្នាច្រើន ឬចិញ្ចឹមលំបាក ។

ពិតហើយ ភិក្ខុទាំងនេះជាអ្នកប្រាថ្នាតិចនោះឯង ជាអ្នកសន្តោស ជាអ្នកចិញ្ចឹមងាយ ជាអ្នកមានការប្រព្រឹត្តស្រាល តែព្រះមានព្រះភាគ

មិនបានត្រាស់ព្រះសូត្រនេះចំពោះភិក្ខុទាំងនោះ ត្រាស់ចំពោះភិក្ខុដែលមានបរិក្ខារ ៨ ។

ដោយន័យថា ភិក្ខុដែលមានបរិក្ខារ ៨ នោះ យកកាំបិតតូចនិងម្ជុលដាក់ក្នុងសំពត់តម្រងទឹក ហើយដាក់ទុកខាងក្នុងបាត្រ ស្ពាយបាត្រពាក់លើចង្កេះ ដណ្តប់កាយដោយត្រៃចីវរ ចៀសទៅសប្បាយតាមប្រាថ្នា ។ មិនមានវត្ថុដែលឈ្មោះថា លោកនឹងត្រូវត្រឡប់មកកាន់យក ។

កាលទ្រង់សម្តែងសេចក្តីដែលភិក្ខុនោះ ជាអ្នកមានការប្រព្រឹត្តស្រាលដោយប្រការដូច្នេះ ព្រះមានព្រះភាគបានត្រាស់ថា ភិក្ខុនេះជាអ្នកសន្តោសដោយចីវរគ្រឿងបរិហារកាយជាដើម ។

ក្នុងបទទាំងនោះ បទថា កាយបរិហារិកេន បានដល់ ចីវរល្មមជាគ្រឿងរក្សាកាយ ។

បទថា កុច្ឆិបរិហារិកេន បានដល់ ចីវរល្មមជាគ្រឿងរក្សាផ្ទៃ ។

បទថា សមាទាយេវ បក្កមតិ សេចក្តីថា កាន់យកត្រឹមតែបរិក្ខារ ៨ នោះប៉ុណ្ណោះ ជាប់តាមខ្លួនទៅ ។ មិនមានសេចក្តីហួងហែងឬជាប់ជំពាក់ថា វិហារ បរិវេណ ឧបដ្ឋាករបស់យើង ។ លោកដូចជាកូនសរដែលរបូតចាកបំពង់ព្រួញ និងដូចដំរីចុះប្រេងចៀសចេញពីហ្វូង ។ បរិភោគសេនាសនៈតាមដែលប្រាថ្នា ជាដងព្រៃ គល់ឈើ ញកភ្នំក្នុងព្រៃ

តែមួយរូបប៉ុណ្ណោះ ឈរតែមួយរូបប៉ុណ្ណោះ អង្គុយតែមួយរូប មិនមានសម្លាញ់ ក្នុងឥរិយាបថទាំងពួង រមែងដល់ភាពជាអ្នកដូចកុយរមាសដែលលោកពណ៌នាទុកយ៉ាងនេះថា

**ភិក្ខុត្រេកអរតាមមានតាមបាន រមែងត្រាច់ទៅក្នុងទិសទាំង ៤ មិនទើសទាក់ ជាអ្នកអត់ធន់ចំពោះអន្តរាយទាំងឡាយ មិនញាប់ ជាបុគ្គលតែម្នាក់ឯង ត្រាច់ទៅដូចកុយរមាស ដូច្នេះ ។**

ឥឡូវនេះ កាលនឹងញាំងសេចក្តីនោះឲ្យសម្រេចដោយឧបមា ទើបត្រាស់ថា សេយ្យថាបិ ជាដើម ។

ក្នុងបទទាំងនោះ បទថា បក្ខី សកុណោ បានដល់ សត្វមានស្លាប ។

បទថា ឌេតិ បានដល់ ហើរទៅ ។

ក៏សេចក្តីសង្ខេបក្នុងរឿងនេះដូច្នេះ ។ ធម្មតាសត្វទាំងឡាយដឹងថា ទីប្រទេសឯណោះ ដើមឈើមានផ្លែទុំហើយ មកពីទិសផ្សេងៗ ចោះចឹកស៊ីផ្លែរបស់ដើមឈើនោះ ដោយក្រចក និងចំពុះជាដើម សត្វទាំងនោះមិនបានគិតថា ផ្លែឈើនេះ នឹងមានសម្រាប់ថ្ងៃនេះ ផ្លែឈើនេះនឹងមានសម្រាប់ថ្ងៃស្អែកនេះ និងកាលផ្លែឈើអស់ហើយ ក៏មិនបានតាំងរក្សាដើមឈើឡើយ មិនបានដាក់ស្លាប ក្រចក ឬនឹងចំពុះទុកត្រង់ដើម

ឈើនោះ ដែលពិត មិនបានផ្តោតចិត្តក្នុងដើមឈើទាំងឡាយ សត្វណា ប្រាថ្នានឹងទៅទិសាភាគណាៗ សត្វនោះ មានតែស្វាបរបស់ខ្លួនជា ភារៈ ហើរទៅតាមទិសាភាគនោះៗ ភិក្ខុនេះក៏យ៉ាងនោះដូចគ្នា មិនជាប់ជំពាក់ មិនផ្តោតចិត្ត នឹងចៀសទៅតាមសេចក្តីត្រូវការដោយខ្លួនឯង ដូច្នេះឯង ។

## នីវរណប្បហានកថា

[១២៥] ព្រះមានព្រះភាគទ្រង់សម្តែងដូចម្តេច ដោយពាក្យថា សោ ឥមិនា ច ដូច្នេះជាដើម ។

ទ្រង់សម្តែងបច្ច័យសម្បត្តិរបស់ភិក្ខុដែលនៅព្រៃ ។

ភិក្ខុណាមិនមានបច្ច័យទាំង ៤ នេះ ការនៅព្រៃរបស់ភិក្ខុនោះ រមែងមិនសម្រេច ភិក្ខុនោះ រមែងត្រូវប្រៀបស្មើនឹងសត្វតិរច្ឆាន ឬព្រាន ព្រៃ ។ ទេវតាដែលស្ថិតនៅក្នុងព្រៃ ធ្វើឲ្យឮសម្លេងដែលគួរ ខ្លាចថា "ការនៅព្រៃរបស់ភិក្ខុអាក្រក់ដូច្នេះ នឹងមានប្រយោជន៍អ្វី" យកដៃខោក ក្បាលហើយគេចចេញទៅ ។ ទោសមិនមែនយស រមែងល្បីខ្ចរខ្ចាយ ទៅថា ភិក្ខុរូបឯណោះចូលព្រៃ បានធ្វើកម្មអាក្រក់យ៉ាងនេះខ្លះ យ៉ាង នេះខ្លះ ។

តែភិក្ខុណា មានបច្ច័យ ៤ ទាំងនេះ ការនៅព្រៃរបស់ភិក្ខុនោះ រមែងសម្រេច ។ សេចក្តីថា លោកពិចារណាសីលរបស់ខ្លួនហើយ កាល

មិនឃើញភាពសៅហ្មងណាៗ ញុំាងបីតិឲ្យកើតឡើង ហើយពិចារណាបីតិនោះ ដោយសេចក្តីអស់ទៅ សាបសូន្យទៅ រមែងចុះកាន់អរិយភូមិ ។ ទេវតាដែលស្ថិតនៅក្នុងព្រៃ មានសេចក្តីពេញចិត្ត នាំគ្នាសរសើរ ។ យសរបស់ភិក្ខុនេះ រមែងព្រុះសាយទៅ ដូចតំណក់ប្រេងដែលធ្លាក់ចុះក្នុងទឹកដូច្នោះ ។

ក្នុងបទទាំងនោះ បទថា វិវិត្ត សេចក្តីថា ទំនេរ អធិប្បាយថា មានសម្លេងតិច គឺ មិនព្រួងខ្លាំង ។ ពិតហើយ ក្នុងវិភង្គបករណ៍ លោកពោលសំដៅដល់សេចក្តីស្ងាត់នេះទុកថា បទថា វិវិត្តំ សេចក្តីថា សូម្បីថា មានសេនាសនៈនៅក្នុងទីជិត និងសេនាសនៈនោះ មិនច្របូកច្របល់ដោយគ្រហស្ថខ្លះ បព្វជិតខ្លះ ព្រោះហេតុនោះ សេនាសនៈនោះ ឈ្មោះថា ស្ងាត់ ។

ឈ្មោះថា **សេនាសន** ព្រោះអត្ថថា ជាទីដេកផង ជាទីអង្គុយផង ។ ពាក្យនេះ ជាឈ្មោះរបស់គ្រែ និងតាំងជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា បទថា **សេនាសន** បានដល់ គ្រែក្តី តាំងក្តី ពូកក្តី ខ្នើយក្តី វិហារក្តី ប្រាសាទវែងក្តី ប្រាសាទ ៤ ជ្រុងក្តី ប្រាសាទមានដំបូលរលីងក្តី ល្អាងក្តី ប៉មក្តី រោងមូលក្តី ទីពួនសម្ងំក្តី គុម្ពឬស្សីក្តី គល់ឈើក្តី មណ្ឌបក្តី ឈ្មោះថា **សេនាសន** ឬថា ភិក្ខុផ្លាស់ឥរិយាបថក្នុងទីណា ទីនោះទាំងអស់ ឈ្មោះថា **សេនាសន** ។

ម្យ៉ាងទៀត សេនាសនៈនេះ គឺ វិហារ ប្រាសាទវែង ប្រាសាទ ៤ ជ្រុង ប្រាសាទមានដំបូលរលីង ល្អាង ឈ្មោះថា **សេនាសន** ប្រភេទទីលំនៅ ។

សេនាសនៈនេះ គឺ គ្រែ តាំង ពូក ខ្នើយ ឈ្មោះថា សេនាសនៈសម្រាប់គ្រែ តាំង ។

សេនាសនៈនេះ គឺ ស្រោមខ្នើយ ផ្ទាំងស្បែក កម្រាលដែលក្រងដោយស្មៅ កម្រាលដែលធ្វើដោយស្លឹកឈើ ឈ្មោះថា សេនាសនៈជាកម្រាល ។

សេនាសនៈ ដែលជាទីផ្លាស់ឥរិយាបថរបស់ភិក្ខុទាំងឡាយ នេះ ឈ្មោះថា សេនាសនៈតាមឱកាស ។

សេនាសនៈ មាន ៤ យ៉ាង ដោយប្រការដូច្នេះ ។ សេនាសនៈទាំងអស់នោះ ទ្រង់សង្គ្រោះដោយសព្ទថា **សេនាសន** នោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈ ដែលសមគួរដល់ភិក្ខុដែលទៅក្នុង ៤ ទិស ដូចសត្វនោះ ដូច្នេះ ត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា អរញ្ញំ រុក្ខមូលំ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា អរញ្ញំ ព្រៃ បានដល់ ព្រៃទីនៅក្រៅខេត្តក្រុង ទាំងអស់នេះ ឈ្មោះថា **ព្រៃ** ព្រៃនេះសម្រាប់ភិក្ខុនីទាំងឡាយដោយប្រការដូច្នេះ ។

សេនាសនៈដែលតាំងនៅទីបំផុត ៥០០ ជង្ឃ ឈ្មោះថា ព្រៃ ក៏សេនាសនៈព្រៃនេះ សមគួរដល់ភិក្ខុនេះ ដោយប្រការដូច្នេះ ។ លក្ខណៈរបស់ព្រៃនោះ ពោលទុកហើយក្នុងធុតង្គនិទ្ទេសក្នុងវិសុទ្ធិមគ្គ ។

បទថា រុក្ខមូលំ បានដល់ គល់ឈើដែលស្ងាត់ មានម្លប់ត្រឈឹងត្រឈៃទីណាមួយ ។

បទថា បព្វតំ បានដល់ សិលា ។ ក៏កាលភិក្ខុប្រើទឹកក្នុងអណ្តូងទឹកត្រង់ទីនោះហើយ អង្គុយក្រោមម្លប់ឈើត្រជាក់ កាលទិសផ្សេងៗ ប្រាកដ ខ្យល់ត្រជាក់បក់មក ចិត្តរមែងមានអារម្មណ៍តែមួយ ។

ដោយបទថា កន្ទរំ ទ្រង់ត្រាស់ហៅទឹកថា ស្ថានទីនៃភ្នំ ដែលទឹកជ្រោះ ទឹកទម្លាយ ដែលទ្រង់ត្រាស់ថា នទីតុម្ពៈខ្លះ នទីកុញ្ជៈខ្លះ ។ ក៏ក្នុងទីនោះ មានខ្សាច់ដូចផែនប្រាក់ ។ ព្រៃក្រាស់ខាងលើដូចពិតានកែវមណី ។ ទឹកដូចជាគំនរកែវមណីហូរទៅ ។ កាលភិក្ខុចុះក្នុងទឹកជ្រោះយ៉ាងនេះ ផឹកទឹកហើយ ធ្វើរាងកាយឲ្យត្រជាក់ ពូនខ្សាច់ឡើង ក្រាលសំពត់បង្សុកូល អង្គុយបំពេញសមណធម៌ ចិត្តរមែងមានអារម្មណ៍តែមួយ ។

បទថា គិរិគុហំ បានដល់ ប្រហោងធំនៃចន្លោះភ្នំ ២ ឬប្រហោងធំដូចឧម្មង្គភ្នំមួយ ។ លក្ខណៈរបស់ព្រៃស្មសាន បានពោល ហើយក្នុងវិសុទ្ធិមគ្គ ។

បទថា វនបត្ថំ បានដល់ ស្ថានទីហួសអំពីស្រុក មិនមែនជាទីភ្ជួរ ទីសាបព្រោះរបស់មនុស្សទាំងឡាយ ។ ព្រោះហេតុ នោះឯង ទើបទ្រង់ត្រាស់ថា ពាក្យថា វនបត្ថំ នេះ ជាឈ្មោះរបស់ សេនាសនៈដែលឆ្ងាយដូច្នេះជាដើម ។

បទថា អព្ភោកាសំ ទីវាល បានដល់ ទីមិនបានប្រក់បាំង ។

កាលភិក្ខុប្រាថ្នានឹងធ្វើក្ដស់នៅក្នុងទីនេះ ក៏បាន ។

បទថា បលាសបុញ្ជំ បានដល់ គំនរចំបើង ។

ក៏ភិក្ខុទាញចំបើងចេញពីគំនរចំបើងធំ ធ្វើទីនៅអាស្រ័យដូចដែលពួនសម្ងំក្នុងញកក្នំ ។ ពេលខ្លះ យកចំបើងដាក់ខាងលើជន្ទល់ឈើ គល់ឈើជាដើម អង្គុយបំពេញសមណធម៌នៅខាងក្រោម ទ្រង់ត្រាស់សំដៅយកទីនោះ ។

បទថា បច្ឆាភត្តំ បានដល់ ខាងក្រោយអាហារ ។

បទថា បិណ្ឌបាតបដិក្កន្តោ បានដល់ ត្រឡប់មកពីការស្វែងរកបិណ្ឌបាត ។

បទថា បល្លង្កំ បានដល់ អង្គុយចម្រើនសមាធិ ។

បទថា អាភុជិត្វា បានដល់ អង្គុយពែនភ្នែន ។

បទថា ឧជុំ កាយំ បណិធាយ បានដល់ តាំងកាយកំណាត់លើឲ្យត្រង់ ឲ្យទីបំផុតនៃឆ្អឹងខ្នង ១៨ កង់ ទល់គ្នា ។

ដោយថា កាលអង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃ ទាំងឡាយ មិនតឹង ។ កាលបើដូច្នេះ វេទនាដែលនឹងត្រូវកើតឡើង ក្នុងគ្រប់ៗ ខណៈ ព្រោះស្បែក សាច់ សរសៃតឹងជាបច្ច័យ ក៏មិនកើត ឡើងដល់ភិក្ខុនោះ កាលវេទនាទាំងនោះមិនកើតឡើង ចិត្តរមែងមាន អារម្មណ៍តែមួយ កម្មដ្ឋាន រមែងមិនធ្លាក់ចុះ រមែងចូលដល់ភាពចម្រើន លូតលាស់ល្អបរិបូណ៌ ។

បទថា បរិមុខំ សតឹ ឧបដ្ឋបេត្វា សេចក្តីថា មានសតិឆ្ពោះត្រង់ កម្មដ្ឋាន ឬតាំងកម្មដ្ឋានទុកចំពោះត្រង់មុខ ។ ព្រោះហេតុនោះឯង ក្នុង វិភង្គទើបពោលទុកថា សតិនេះ រមែងតាំងមាំនៅត្រង់ចុងច្រមុះ ហេតុនោះ ទ្រង់ទើបត្រាស់ថា តម្កល់សតិទុកចំពោះមុខ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបសេចក្តីតាមន័យដែល ពោលហើយក្នុងបដិសម្ភិទាយ៉ាងនេះថា បទថា បរិ មានអត្ថថា កំណត់, បទថា មុខំ មានអត្ថថា នាំចេញ , បទថា សតិ មានអត្ថថា ចូល ទៅតាំងមាំ , ព្រោះហេតុនោះ ទ្រង់ទើបត្រាស់ពាក្យថា បរិមុខំ សតឹ ដូច្នេះ ។ រួមសេចក្តីក្នុងពាក្យនោះថា ធ្វើសតិឲ្យជាទីកំណត់ ជាទីនាំចេញ ។

ក្នុងបទថា អភិជ្ឈំ លោកេ នេះ ឧបាទានក្ខន្ធ ៥ ឈ្មោះថា លោក ដោយអត្ថថា បែកធ្លាយ ព្រោះដូច្នោះ ក្នុងបទនេះ ទើបមានសេចក្តីដូច្នេះ ថា លះរាគៈ គឺ គ្របសង្កត់កាមច្ឆន្ទៈក្នុងឧបាទានក្ខន្ធ ៥ បាន ។

បទថា វិគតាភិជ្ឈេន សេចក្ដីថា មានការសម្លឹងរំពៃទៅប្រាស ហើយ ព្រោះលះបានដោយវិក្ខម្ភនប្បហាន ដូចចក្ខុវិញ្ញាណ ។

បទថា អភិជ្ឈាយ ចិត្តំ បរិសោធេតិ សេចក្ដីថា ជម្រះចិត្តចាក ការសម្លឹងរំពៃ អធិប្បាយថា ការសម្លឹងរំពៃនោះប្រាសទៅហើយ និង កាលរួចផុតហើយ មិនមកចាប់ចិត្តទៀតបានដោយប្រការណា លោក រមែងធ្វើដោយប្រការនោះ ។

សូម្បីក្នុងបទថា ព្យាបាទបទោសំ បហាយ ជាដើម ក៏ន័យនេះឯង ។

ឈ្មោះថា ព្យាបាទៈ ដោយអត្ថថា ចិត្ត រមែងព្យាបាទដោយ ទោសចិត្តនេះ គឺ លះប្រក្រតីដើម ដូចនំកុម្មាសផ្អូមជាដើម ។

ឈ្មោះថា បទោស ដោយអត្ថថា ប្រទូសរ៉ាយរហូតពិការ ឬធ្វើ អ្នកដទៃឲ្យក្ដៅក្រហាយ គឺ វិនាស ។

ក៏ទាំង ២ ពាក្យនេះ ជាឈ្មោះនៃសេចក្ដីក្រោធនុ៎ះឯង ។

ភាពដែលចិត្តមានជម្ងឺ ឈ្មោះថា ថីន ។

ចេតសិកមានជម្ងឺ ឈ្មោះថា មិទ្ធ ។ ថីនៈ និងមិទ្ធៈ ឈ្មោះថា ថីនមិទ្ធៈ ។

បទថា អាលោកសញ្ញី សេចក្ដីថា ប្រកបដោយសញ្ញាដែល បរិសុទ្ធិប្រាសចាកនីវរណៈ ព្រោះអាចកំណត់ដឹងពន្លឺ ដែលឃើញទាំង ពេលយប់ ទាំងពេលថ្ងៃ ។

បទថា សតោ សម្បជានោ បានដល់ ប្រកបដោយសតិ និង ដោយញាណ ។

ពាក្យទាំង ២ នេះ ទ្រង់ត្រាស់ហើយ ព្រោះជាឧបការៈដល់ អាលោកសញ្ញា ។

សេចក្តីរាយមាយ និងសេចក្តីក្តៅក្រហាយ ឈ្មោះថា ឧទ្ធច្ចកុក្កុច្ច ។

បទថា តិណ្ណវិចិកិច្ឆោ បានដល់ ឆ្លង គឺ ឈានកន្លងវិចិកិច្ឆា ហើយ ។

ឈ្មោះថា មិនមានសេចក្តីសង្ស័យ ដោយអត្ថថា មិនប្រព្រឹត្តទៅ យ៉ាងនេះថា នេះយ៉ាងណា នេះយ៉ាងណា ។

បទថា កុសលេសុ ធម្មេសុ បានដល់ ក្នុងធម៌ទាំងឡាយដែល មិនមានទោស , អធិប្បាយថា មិនសង្ស័យ គឺ មិនឆ្ងល់យ៉ាងនេះថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាកុសលបានយ៉ាងណា ។ នេះជាសេចក្តី សង្ខេបក្នុងសេចក្តីនេះ ។ ក៏ពាក្យណាដែលគួរ នឹងពោលក្នុងនីវរណៈ ទាំងនេះ ដោយការបែកសេចក្តីនៃពាក្យ និងលក្ខណៈជាដើម ពាក្យនោះ ទាំងអស់ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

**[១២៦]** ក្នុងឧបមាដែលលោកពោលទុកថា សេយ្យថាបិ មហារាជ នោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឥណំ អាទាយ បានដល់ កាន់យកទ្រព្យ ដើម្បីសេចក្តីចម្រើន ។

បទថា ព្យន្តីករេយ្យ សេចក្តីថា គប្បីធ្វើបំណុលនោះឲ្យអស់ទៅ គឺគប្បីធ្វើមិនឲ្យបំណុលទាំងនោះនៅសល់ ត្រឹមតែមួយកាកណិក អធិប្បាយថា គប្បីសងឲ្យអស់ ។

បទថា តតោនិទានំ បានដល់ មានការមិនមានបំណុល ជាមូលហេតុ ។

ពិតហើយ កាលគេរំពឹងថា យើងមិនមានបំណុល រមែងបានបាមោជ្ជៈជាកម្លាំង រមែងបានសេចក្តីសប្បាយចិត្ត ព្រោះហេតុនោះទ្រង់ទើបត្រាស់ថា លភេថ ចាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ដូច្នេះ ។

ឈ្មោះថា អាពាធ ដោយអត្ថថា កាត់ឥរិយាបថ ៤ ដូចកាត់ដោយរណារ បៀតបៀន ព្រោះកើតវេទនាដែលជាសត្រូវ ។

ឈ្មោះថា អាពាធិក ដោយអត្ថថា មានអាពាធ ។

ឈ្មោះថា ដល់សេចក្តីលំបាក ព្រោះសេចក្តីលំបាកដែលកើតពីអាពាធនោះ ។

បទថា ពាឡ្ហគិលានោ បានដល់ ឈឺធ្ងន់ ។

បទថា នច្ឆាទេយ្យ បានដល់ មិនគប្បីពេញចិត្ត ព្រោះមានព្យាធិធ្ងន់ក្រៃលែង គ្របសង្កត់ហើយ ។

បទថា ពលមត្តា បានដល់ មានកម្លាំងនុ៎ះឯង អធិប្បាយថា គេមានកម្លាំងកាយ ។

បទថា តតោនិទានំ បានដល់ ការមិនមានរោគ ជាដើមហេតុ ។ ក៏កាលគេរំពឹងថា យើងមិនមានរោគ ទាំងបាមោជ្ជៈ និងសោមនស្សនោះ រមែងមានទាំងគូ ។ ព្រោះហេតុនោះ ទ្រង់ទើបត្រាស់ថា លភេថ បាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ដូច្នេះ ។

បទថា ន ចស្ស កិញ្ចិ ភោគានំ វយោ សេចក្តីថា មិនមានសេចក្តីសាបសូន្យ ភោគៈសូម្បីត្រឹមតែមួយកាកណិក ។

បទថា តតោនិទានំ បានដល់ មានការមិនផុតពីចំណងជាដើមហេតុ ។

ពាក្យដ៏សេស គប្បីប្រកបក្នុងបទទាំងអស់ តាមន័យដែលពោលហើយនុ៎ះឯង ។

បទថា អនត្តាធីនោ បានដល់ មិនមានទីពឹងក្នុងខ្លួន នឹងធ្វើអ្វីៗតាមការពេញចិត្ត របស់ខ្លួនមិនបាន ។

បទថា បរាធីនោ បានដល់ ត្រូវពឹងអ្នកដទៃ ប្រព្រឹត្តទៅតាមការពេញចិត្តរបស់អ្នកដទៃប៉ុណ្ណោះ ។

បទថា ន ករាយេន កាមង្គមោ សេចក្តីថា គេប្រាថ្នានឹងទៅដោយទិសាភាគណា ក៏ទៅ ដោយទិសាភាគនោះមិនបាន ។

បទថា ទាសព្យា បានដល់ ចាកភាពជាទាសៈ ។

បទថា ភុជិស្សោ បានដល់ ជាខ្លួនរបស់ខ្លួនឯង ។

បទថា សភោជនំ បានដល់ ជាអ្នកមានឥស្សរៈជាដើមហេតុ ។

បទថា កន្តារទ្ធានមគ្គំ បានដល់ ផ្លូវកន្តារ អធិប្បាយថា ផ្លូវឆ្ងាយមិនមានទឹក ។

បទថា សភោជនំ បានដល់ មានភូមិភាគដែលរួចផុតភ័យជាដើមហេតុ ។

ក្នុងពាក្យថា ឥមេ បញ្ច និវរណេ អប្បហីនេ ព្រះមានព្រះភាគទ្រង់សម្តែងកាមច្ឆន្ទៈដែលលះមិនបាន ដូចបំណុល សម្តែងនីវរណៈដ៏សេសធ្វើឲ្យដូចជារោគជាដើម ក្នុងសេចក្តីនោះមានឧបមាដូច្នេះ ៖

អ្នកណាបុលបំណុលអ្នកដទៃហើយ រមែងវិនាស អ្នកនោះសូម្បីត្រូវម្ចាស់បំណុលទាមទារថា "ចូរសងបំណុល" សូម្បីនិយាយពាក្យគ្រោតគ្រាត សូម្បីត្រូវឃុំឃាំង សូម្បីត្រូវសម្លាប់ ក៏មិនអាចនឹងឆ្លើយឆ្លងអ្វីបាន រមែងអត់ធន់គ្រប់យ៉ាង ដោយសេចក្តីថា បំណុលរបស់គេនោះជាហេតុឲ្យអត់ទ្រាំ អ្នកដែលជាប់ក្នុងវត្ថុដោយកាមច្ឆន្ទៈក៏យ៉ាងនោះ រមែងតោងយកវត្ថុនោះដោយគ្រឿងតោង គឺ តណ្ហា គេសូម្បីត្រូវពោលពាក្យគ្រោតគ្រាត សូម្បីត្រូវឃុំឃាំង សូម្បីត្រូវសម្លាប់ រមែងអត់ទ្រាំគ្រប់យ៉ាង ។ ដោយន័យថា កាមច្ឆន្ទៈរបស់គេនោះ ជាហេតុឲ្យអត់ទ្រាំ

ដូចកាមច្ឆន្ទៈរបស់ស្រីទាំងឡាយ ដែលត្រូវម្ចាស់ផ្ទះសម្លាប់ គប្បីឃើញកាមច្ឆន្ទៈដូចបំណុល ដោយប្រការដូច្នេះឯង ។

ដូចជាអ្នកសោប់រសល់ ព្រោះរោគប្រមាត់ សូម្បីកាលគេឲ្យទឹកឃ្មុំនិងដុំស្ករត្នោតជាដើម ក៏មិនបានរសរបស់ស្ករទាំងនោះ រមែងរអ៊ូរទាំថា ល្វីង ល្វីង ប៉ុណ្ណោះ ព្រោះខ្លួនសោប់រសល់ដោយរោគប្រមាត់ យ៉ាងណា អ្នកមានចិត្តព្យាបាទ ក៏យ៉ាងនោះដូចគ្នា សូម្បីអាចារ្យ និងឧបជ្ឈាយ៍ ដែលមានបំណងល្អ ពោលត្រឹមតែបន្តិចបន្តួចក៏មិនទទួលឱវាទ ពោលថា "លោកទាំងឡាយខ្វល់ខ្វាយហួសប្រមាណ" ជាដើម លាចាកសិក្ខាបទទៅ គេមិនបានរសរបស់ព្រះសាសនា ប្រភេទសុខក្នុងឈានជាដើម ព្រោះជាអ្នកសោប់រសល់ដោយសេចក្តីក្រោធ ដូចបុរសនោះមិនបានរសផ្អែម មានទឹកឃ្មុំ និងដុំស្ករត្នោតជាដើម ព្រោះជាអ្នកសោប់រសល់ ដោយរោគប្រមាត់ គប្បីឃើញការព្យាបាទដូចរោគ ដោយប្រការដូច្នេះឯង ។

ដូចអ្នកដែលត្រូវឃុំឃាំងក្នុងគុក ក្នុងថ្ងៃនក្ខត្តឫក្ស រមែងមិនឃើញខាងដើម កណ្តាល ទីបំផុតរបស់នក្ខត្តឫក្សឡើយ លុះព្រឹកឡើងគេរួចអំពីគុក សូម្បីបានស្តាប់ពាក្យជាដើមថា "ឱ កាលម្សិលមិញនក្ខត្តឫក្សគួរពេញចិត្ត របាំ រាំច្រៀងគួរពេញចិត្ត" ដូច្នេះ ក៏រកពាក្យឆ្លើយមិនបាន ។ ព្រោះហេតុអ្វី ? ព្រោះមិនបានមើលនក្ខត្តឫក្សយ៉ាងណា ភិក្ខុត្រូវថីនមិទ្ធៈគ្របសង្កត់ក៏យ៉ាងនោះ កាលស្តាប់ធម៌ សូម្បីមានន័យ

វិចិត្រកំពុងប្រព្រឹត្តទៅ រមែងមិនដឹងខាងដើម កណ្ដាល ខាងចុងរបស់ធម៌នោះ លុះក្រោយ កាលក្រោកដកការស្ដាប់ធម៌ឡើងហើយ មនុស្សនាំគ្នាសរសើរការស្ដាប់ធម៌ថា "ឱ!ការស្ដាប់ធម៌ ឱ!ហេតុផល ឱ!ឧបមា" សូម្បីស្ដាប់ ក៏រកពាក្យឆ្លើយមិនបាន ។ ព្រោះហេតុអ្វី ។ ព្រោះដោយអំណាចថីនមិទ្ធៈ ធ្វើឲ្យស្ដាប់ធម៌មិនដឹងរឿង ។ គប្បីឃើញថីនមិទ្ធៈដូចគុក ដោយប្រការដូច្នេះ ។

ដូចទាសៈ សូម្បីលេងនក្ខត្តឫក្សហើយ ចៅហ្វាយពោលថា "មានការងារដែលត្រូវធ្វើប្រញាប់បន្ទាន់ ឈ្មោះនេះ អ្នកឯងចូរប្រញាប់ទៅទីនោះ បើមិនទៅ យើងនឹងកាត់ដៃ និងជើង ឬត្រចៀក និងច្រមុះរបស់អ្នកឯង" គេប្រញាប់ទៅភ្លាម រមែងមិនបានសរសើរខាងដើម កណ្ដាល និងទីបំផុតរបស់ការងារនក្ខត្តឫក្ស ។ ព្រោះហេតុអ្វី ។ ព្រោះមានអ្នកដទៃជាទីពឹងយ៉ាងណា ភិក្ខុដែលមិនដឹងទូទៅក្នុងព្រះវិន័យ ក៏យ៉ាងនោះ សូម្បីចូលព្រៃដើម្បីត្រូវការវិវេក កាលកើតសេចក្ដីសម្គាល់ក្នុងកប្បិយ-មំសៈយ៉ាងណាមួយ ដោយទីបំផុតថា ជាអកប្បិយមំសៈ ត្រូវលះបង់វិវេក ទៅសំណាក់ព្រះវិន័យធរដើម្បីជម្រះសីល រមែងមិនបានសោយសុខដែលកើតពីវិវេក ។ ព្រោះហេតុអ្វី ។ ព្រោះត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ គប្បីឃើញឧទ្ធច្ចកុក្កុច្ចៈដូចជាទាសៈ ដោយប្រការដូច្នេះឯង ។

ដូចបុរសដើរផ្លូវឆ្ងាយដែលកន្តារ បានឃើញទីដែលមនុស្សទាំង

ឡាយត្រូវពួកចោរប្លន់ និងត្រូវសម្លាប់ ល្មមបានឮសម្លេងកំណាត់ឈើ ក្តីសម្លេងសត្វក្តី រមែងរង្កៀសសង្ស័យថា "ពួកចោរមកហើយ ដើរ ទៅខ្លះឈរខ្លះ ត្រឡប់ក្រោយខ្លះ កន្លែងដែលមកអំពីទីទៅហើយ មានច្រើនជាង" គេរមែងដល់ទីរួចផុតភ័យដោយលំបាក ដោយក្រ ឬមិនផុតឡើយ យ៉ាងណា អ្នកដែលកើតវិចិកិច្ឆាក្នុងឋានៈ ៨ ក៏យ៉ាងនោះសង្ស័យដោយន័យជាដើមថា ព្រះពុទ្ធមាន ឬមិនមានហ្ន៎ ងឿងឆ្ងល់មិនអាចកាន់យកដោយសទ្ធា កាលមិនអាច រមែងមិនសម្រេចមគ្គ ឬផលបាន ។ ដូច្នោះ ដូចក្នុងផ្លូវឆ្ងាយ ដែលកន្តារ រមែងមានសេចក្តីរង្កៀសក្រែងរឿយៗ ថា ពួកចោរមាន ឬមិនមាន ធ្វើឲ្យចិត្តមិនជឿ មានសេចក្តីភ័យខ្លាចកើតឡើង រមែងធ្វើអន្តរាយដល់ការដែលរួចផុតភ័យ យ៉ាងណាសូម្បីវិចិកិច្ឆាក៏យ៉ាងនោះ ធ្វើឲ្យកើតការងឿងឆ្ងល់រឿយៗ ដោយន័យថាព្រះពុទ្ធមាន ឬមិនមានហ្ន៎ ដូច្នេះជាដើម ចិត្តមិនតាំងមាំ តក់ស្លុតខ្លាចរមែងធ្វើអន្តរាយដល់ការចូលកាន់អរិយភូមិ គប្បីឃើញវិចិកិច្ឆា ដូចផ្លូវកន្តារ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់សម្តែងប្រៀបធៀប អ្នកដែលលះបង់កាមច្ឆន្ទនីវរណៈបាន ថា ដូចអ្នកមិនមានបំណុល អ្នកដែលលះបង់នីវរណៈដ៏សេសបាន ថា ដូចអ្នកមិនមានរោគជាដើម ក្នុងព្រះបាលីនេះថា សេយ្យថាបិ មហារាជ អាណណ្យំ ដូច្នេះ ។ ក្នុងសេចក្តីនោះ មាន

ឧបមាដូច្នេះ ។

ដូចជាបុរសជំពាក់បំណុល ហើយប្រកបការងារ រហូតមានទ្រព្យ បានគិតថា "ឈ្មោះថា បំណុលនេះជាមូលនៃសេចក្ដីកង្វល់" ទើបសង បំណុលព្រមទាំងការប្រាក់ហើយហែកបញ្ជីខ្ចីចេញ កាលបើដូច្នោះ មិនមានអ្នកណាបញ្ជូនមនុស្សទៅទារគេ តាំងអំពីនោះមក បញ្ជីខ្ចីក៏មិនមាន គេសូម្បីឃើញម្ចាស់បំណុលទាំងឡាយ បើប្រាថ្នានឹងត្រូវទទួល ក៏ក្រោកចាកអាសនៈ បើមិនប្រាថ្នា ក៏មិនក្រោក ។ ព្រោះហេតុអ្វី ? ព្រោះមិនបានជាប់ត មិនបានជាប់ជំពាក់នឹងម្ចាស់បំណុលទាំងនោះ យ៉ាងណា ភិក្ខុ (អ្នកបដិបត្តិ) ក៏យ៉ាងនោះដូចគ្នា គិតថា ឈ្មោះថា កាមច្ឆន្ទៈនេះ ជាមូលនៃសេចក្ដីកង្វល់ ទើបចម្រើនធម៌ ៦ ប្រការ ហើយលះកាមច្ឆន្ទនីវរណៈចេញ ។ ក៏ធម៌ ៦ ប្រការទាំងនោះ បានពណ៌នាក្នុងមហាសតិប្បដ្ឋានសូត្រ ។

កាលភិក្ខុនោះលះកាមច្ឆន្ទៈបានយ៉ាងនេះ រមែងមិនខ្លាច មិនតក់ស្លុត ដូចបុរសដែលដោះបំណុលហើយ ឃើញម្ចាស់បំណុលទាំងឡាយ រមែងមិនខ្លាច មិនតក់ស្លុត យ៉ាងណា រមែងមិនមានការជាប់ជំពាក់ មិនមានការពាក់ព័ន្ធក្នុងវត្ថុរបស់អ្នកដទៃ យ៉ាងនោះដូចគ្នា កាលឃើញរូបសូម្បីជាទិព្វ កិលេសក៏មិនកម្រើក ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ការលះកាមច្ឆន្ទៈបាន ដូចការមិនមានបំណុល ។

ដូចបុរសអ្នករសាប់រសល់ ព្រោះរោគប្រមាត់នោះ ធ្វើរោគនោះឲ្យស្ងប់ដោយការផឹកថ្នាំ តាំងអំពីនោះ ក៏បានរសនៃទឹកឃ្មុំ និងដុំស្ករត្នោតជាដើម យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា គិតថា ឈ្មោះថាព្យាបាទនេះ ធ្វើសេចក្ដីវិនាស ទើបចម្រើនធម៌ ៦ ប្រការ លះព្យាបាទ-នីវរណៈបាន ។ យើងពណ៌នាធម៌ ៦ ប្រការ ក្នុងនីវរណៈទាំងអស់ ក្នុងមហាសតិប្បដ្ឋានសូត្រនុ៎ះឯង ។ ក៏ធម៌ ៦ ប្រការទាំងនោះ មិនមែនចម្រើនដើម្បីលះថីនមិទ្ធៈជាដើមតែម្យ៉ាង នឹងបានពណ៌នានីវរណៈទាំងអស់នោះ ក្នុងមហាសតិប្បដ្ឋានសូត្រនោះឯង ។ ភិក្ខុនោះ លះព្យាបាទបានយ៉ាងនេះហើយ ទទួលសិក្ខាបទទាំងឡាយ មានអាចារប្បញ្ញត្តិជាដើមយ៉ាងពេញចិត្តដោយសិរសា ចាប់ចិត្តសិក្សា ដូចបុរសសះស្បើយពីរោគប្រមាត់ហើយ រមែងបរិភោគរសទឹកឃ្មុំ និងដុំស្ករត្នោតជាដើម យ៉ាងពេញចិត្ត ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ ការលះព្យាបាទដូចការជាសះស្បើយពីរោគ ។

បុរសអ្នកត្រូវជាប់គុកក្នុងថ្ងៃនក្ខត្តឫក្សនោះ ក្នុងថ្ងៃនក្ខត្តឫក្ស គេគិតថា "សូម្បីកាលមុន យើងត្រូវឃុំឃាំង ព្រោះទោសដែលប្រមាទមិនបានរីករាយនឹងនក្ខត្តឫក្ស ព្រោះហេតុនោះ ឥឡូវនេះយើងនឹងមិនប្រមាទ" ដូច្នេះ ជាអ្នកមិនប្រមាទ ដែលសត្រូវទាំងឡាយរបស់គេមិនបានឱកាស ទើបបានរីករាយនឹងនក្ខត្តឫក្សថ្លែងឧទានថា ឱ ! នក្ខត្តឫក្ស

ដូច្នេះ យ៉ាងណា ភិក្ខុក៏យ៉ាងនោះ គិតថា "ឈ្មោះថា ថីនមិទ្ធៈនេះ ធ្វើសេចក្ដីវិនាសធំ" ទើបចម្រើនធម៌ ៦ ប្រការ រមែងលះថីនមិទ្ធនីវរណៈបាន លោកលះថីនមិទ្ធៈបានយ៉ាងនេះហើយ បានរីករាយនឹងខាងដើម កណ្ដាល និងទីបំផុតនៃនក្ខត្តឫក្ស គឺ ធម៌ សម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ដូចបុរសដែលរួចផុតចាកការឃុំឃាំង បានរីករាយខាងដើម កណ្ដាល និងទីបំផុតនៃនក្ខត្តឫក្សទាំង ៧ ថ្ងៃ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ការលះថីនមិទ្ធៈបាន ថា ដូចរួចផុតពីទីឃុំឃាំង ។

ដូចទាសៈ ចូលទៅអាស្រ័យមិត្ត អ្នកខ្លះឲ្យទ្រព្យដល់ចៅហ្វាយទាំងឡាយ ហើយធ្វើខ្លួនឲ្យជាអ្នកគ្មានបំណុល តាំងពីនោះ ខ្លួនប្រាថ្នាវត្ថុណា ក៏ធ្វើវត្ថុនោះ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា គិតថា "ឈ្មោះថា ឧទ្ធច្ចកុក្កុច្ចៈនេះ ធ្វើសេចក្ដីវិនាសធំ" ទើបចម្រើនធម៌ ៦ ប្រការ រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ លោកលះឧទ្ធច្ចកុក្កុច្ចៈបានយ៉ាងនេះហើយ រមែងប្រព្រឹត្តទៅកាន់នេក្ខម្មប្បដិបទាបានតាមសប្បាយ ។ ឧទ្ធច្ចកុក្កុច្ចៈមិនអាចឲ្យលោកត្រឡប់ចាកនេក្ខម្មប្បដិបទានោះបាន ដោយពលការ ។ ដូចបុរសអ្នកជា អ្នកគ្មានបំណុល ប្រាថ្នាវត្ថុណា ក៏ធ្វើវត្ថុនោះ មិនប្រាថ្នាវត្ថុណា ក៏មិនធ្វើវត្ថុនោះ ។ មិនមានអ្នកណាៗ នឹងឲ្យគេត្រឡប់ចាកភាពជាអ្នកគ្មានបំណុលនោះ ដោយពលការនោះ ។ ព្រោះដូច្នោះ

ព្រះមានព្រះភាគ ទើបត្រាស់ការលះបង់ឧទ្ធច្ចកុក្កុច្ចៈ ដូចជាអ្នកគ្មានបំណុល ។

ដូចបុរសមានកម្លាំង កាន់យកទ្រព្យដែលមានសារៈជាប់ដៃ ត្រៀមអាវុធព្រមដោយបរិវារ ធ្វើដំណើរតាមផ្លូវកន្តារ ពួកចោរឃើញគេពីចម្ងាយ គប្បីគេចចេញទៅ ។ គេឆ្លងផុតផ្លូវកន្តារនោះដោយសួស្ដី ដល់ដែនក្សេម មានសេចក្ដីរីករាយត្រេកអរ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា គិតថា ឈ្មោះថា វិចិកិច្ឆានេះ ធ្វើសេចក្ដីវិនាស ទើបចម្រើនធម៌ ៦ ប្រការ រមែងលះវិចិកិច្ឆាបាន លោកលះវិចិកិច្ឆាបានយ៉ាងនេះហើយ ឆ្លងផ្លូវកន្តារនៃទុច្ចរិតបាន សម្រេចព្រះអមតមហានិព្វាន ដែលជាភូមិដ៏ក្សេមសប្បាយយ៉ាងក្រៃលែង ដូចបុរសអ្នកមានកម្លាំង ត្រៀមអាវុធព្រមដោយបរិវារក៏រួចផុតភ័យ មិនទាក់ចិត្តពួកចោរ ដូចស្មៅ ចេញទៅដល់ភូមិដែលជាទីរួចផុតភ័យ ដោយសេចក្ដីសួស្ដី ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគ ទើបត្រាស់ការលះវិចិកិច្ឆា ទុកដូចភូមិដែលជាដែនក្សេម ។

**[១២៧]** បទថា ចាមោជ្ជំ ជាយតិ សេចក្ដីថា កើតអាការត្រេកអរ ។

បទថា បមុទិតស្ស បីតិ ជាយតិ សេចក្ដីថា បីតិកើតជ្រួតជ្រាបទូទាំងសរីរៈរបស់អ្នកដែលត្រេកអរ ។

បទថា បីតិមនស្ស កាយោ បស្សម្ភតិ សេចក្ដីថា នាមកាយរបស់បុគ្គលដែលមានចិត្តសម្បយុត្តដោយបីតិ រមែងស្ងប់ គឺ ប្រាសចាកសេចក្ដី

ខ្វល់ខ្វាយ ។

បទថា សុខំ វេទេតិ សេចក្តីថា រមែងសោយសុខទាំងផ្លូវកាយ ផ្លូវចិត្ត ។

បទថា ចិត្តំ សមាធិយតិ សេចក្តីថា ចិត្តរបស់អ្នកដែលមានសុខ ដោយនេក្ខម្មសុខនេះ រមែងតាំងមាំ ដោយអំណាចឧបចារឈានក៏មាន ដោយអំណាចអប្បនាឈានក៏មាន ។

## ពណ៌នា បឋមជ្ឈាន

ក៏ពាក្យថា សោ វិវិច្ចេវ កាមេហិ ។បេ។ ដូច្នេះជាដើម គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដើម្បី សម្តែងគុណវិសេសយ៉ាងខ្ពស់ ក្នុងកាលចិត្តតាំងមាំដោយឧបចារសមាធិ និងដើម្បីសម្តែងប្រភេទរបស់ សមាធិនោះ ក្នុងកាលចិត្តតាំងមាំ ដោយអប្បនាសមាធិ ។

បទថា ឥមមេវ កាយំ បានដល់ ករជកាយនេះ ។

បទថា អភិសន្ទេតិ បានដល់ ជ្រួតជ្រាបផ្សាយទៅ គឺ ធ្វើបីតិសុខឲ្យប្រព្រឹត្តទៅក្នុងទីទាំងពួង ។

បទថា បរិសន្ទេតិ បានដល់ ជ្រួតជ្រាបទៅដោយជុំវិញ ។

បទថា បរិបូរេតិ បានដល់ ពេញដូចសប់ដោយខ្យល់ ។

បទថា បរិប្ផរតិ បានដល់ ផ្សាយទៅដោយជុំវិញ ។

បទថា សព្វាវតោ កាយស្ស សេចក្តីថា កាយរបស់ភិក្ខុ (អ្នកបានឈាន) នោះ គ្រប់ចំណែក មិនមានឋានៈត្រង់ណាក្នុងកាយ ដែលមានចិត្តគ្រប់គ្រង និងនៅមានសន្តតិប្រព្រឹត្តទៅហើយ សូម្បីតែតិចតួចតាមស្បែក សាច់ និងលោហិត ដែលសេចក្តីសុខក្នុងបឋមឈាននឹងមិនពាល់ត្រូវ ។

បទថា ទក្ខោ បានដល់ អ្នកឆ្លាត អាចដើម្បីនឹងធ្វើ ដើម្បីនឹងប្រកប ដើម្បីនឹងងូតទឹកជម្រះកាយ ដោយលំអិតសម្រាប់ងូតទឹក ។

បទថា កំសថាលេ ក្នុងភាជន៍សំរឹទ្ធិ បានដល់ ក្នុងភាជនៈដែលធ្វើដោយលោហៈយ៉ាងណាមួយ ។ ភាជនៈដីជារបស់មិនទន់ កាលប្រើងូតរមែងបែក ដូច្នោះ ទើបទ្រង់មិនលើកភាជនៈដីឡើងសម្តែង ។

បទថា បរិប្ផោសកំ បរិប្ផោសកំ បានដល់ ស្រោចហើយស្រោចទៀត ។

បទថា សន្នេយ្យំ បានដល់ កាន់ភាជនៈសំរឹទ្ធិដោយដៃឆ្វេង ក្បង់ទឹកល្មមប្រមាណដោយដៃស្តាំ លាបខ្លួន ធ្វើការក្បង់ម្តងមួយទុកដៃ ។

បទថា ស្នេហានុគតា បានដល់ ការជ្រាបសាយរបស់ទឹក ដែលផ្សាយជ្រួតជ្រាបទៅ ។

បទថា ស្នេហាបរេតា បានដល់ ជ្រាបសាយ ដោយការជ្រួតជ្រាបរបស់ទឹក ។

បទថា សន្ទុរវមាណិរា បានដល់ ការជ្រាបសាយរបស់ទឹកប៉ះត្រូវព្រមទាំងខាងក្នុង និងខាងក្រៅគ្រប់ផ្នែក ។

បទថា ន ច បគ្ឃរតិ សេចក្តីថា មិនមែនទឹកនឹងស្រក់ចេញម្តងមួយតំណក់ៗ ទឹកនោះអាចក្បង់ដោយដៃក៏បាន ដោយអង្គុលី ២-៣ ក៏បាន ស្ទូបរីដោយថ្នក់ក៏ធ្វើបាន ។

## ពណ៌នា ទុតិយជ្ឈាន

[១២៨] ឧបមាសេចក្តីសុខក្នុងទុតិយជ្ឈាន មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឧព្ភិទោទកោ សេចក្តីថា ទឹកជន់ ។ អធិប្បាយថា មិនមែនទឹកដែលបែកខាងក្រោមហើយខ្ទាតឡើង តែជាទឹកដែលកើតឡើងក្នុងខាងក្នុងនុ៎ះឯង ។

បទថា អាយមុខំ បានដល់ ផ្លូវជាទីមក ។

បទថា ទេវោ បានដល់ ភ្លៀង ។

បទថា កាលេន កាលំ ប្រែថា គ្រប់វេលា អធិប្បាយថា រាល់កន្លះខែ ឬគ្រប់ ១០ ថ្ងៃ ។

បទថា ធារំ ប្រែថា ខ្សែភ្លៀង ។

បទថា អនុប្បវេច្ឆេយ្យ សេចក្តីថា ភ្លៀងមិនបង្អុរ គឺ មិនធ្លាក់ ។

បទថា សីតា វារិធារា ឧព្ភិជ្ជិត្វា សេចក្តីថា ទឹកត្រជាក់ធ្វើ

អន្លង់ទឹកឲ្យពេញកើតឡើង ។

ពិតហើយ ទឹកដែលផុលឡើងខាងក្រោម គ្រាផុលឡើងហើយ រមែងធ្វើទឹកដែលបែកឲ្យពេញ ។ ទឹកដែលហូរមកពីទិសទាំង ៤ រមែងធ្វើទឹកឲ្យពេញដោយស្លឹកឈើចាស់ ស្មៅ ឈើ និងកំណាត់ឈើជាដើម ។ ទឹកភ្លៀង រមែងធ្វើទឹកឲ្យពេញដោយខ្សែទឹកដែលធ្លាក់ចុះមក និងពពុះទឹក ។ ទឹកដែលកើតឡើង ដោយជន់យ៉ាងនោះឯង ដូចនិម្មិតដោយឫទ្ធិផ្សាយទៅកាន់ប្រទេសនេះ និងថា មិនផ្សាយទៅកាន់ប្រទេសនេះមិនមាន ។ ឈ្មោះថា ឱកាសដែលទឹកនោះមិនពាល់ត្រូវមិនមាន ដូច្នេះឯង ។

ក្នុងរឿងនេះ ករជកាយដូចអន្លង់ទឹក ។ សុខក្នុងទុតិយជ្ឈានដូចទឹក ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យមានក្នុងកាលមុននោះឯង ។

## ពណ៌នា តតិយជ្ឈាន

**[១២៩]** ឧបមាសេចក្តីសុខក្នុងតតិយជ្ឈាន មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា ឧប្បលិនី ដោយអត្ថថា ជាទីមានផ្កាឧប្បល សូម្បីក្នុងពីរបទដ៏សេសក៏ន័យនេះឯង ។ ក៏ក្នុងរឿងឧបមានេះ បណ្តា ឧប្បលស ឧប្បលក្រហម និងឧប្បលខៀវ ឧប្បលយ៉ាងណាមួយ ឈ្មោះថា ឧប្បលទាំងឯង ផ្កាឈូកដែលមានត្របកតិចជាងមួយរយ ឈ្មោះថា បុណ្ឌរិក , ដែលមានត្របកដល់មួយរយ ឈ្មោះថា បទុម , ម្យ៉ាងទៀត វៀរឈូក

ដែលកំណត់ត្របកចេញ ឈូកស ឈ្មោះបទុម , ឈូកក្រហម ឈ្មោះ បុណ្ឌរិក ក្នុងរឿងឈូកនេះ មានវិនិច្ឆ័យប៉ុណ្ណេះឯង ។

បទថា ឧទកានុគ្គតានិ គឺ បានដល់ មិនទាន់លូតឡើងផុតអំពីទឹក ។

បទថា អន្តោនិមុគ្គចោសិនី លិចនៅក្នុងទឹក សេចក្តីថា លិចនៅក្នុងទឹកនុ៎ះឯង ដែលទឹកចិញ្ចឹមទុកហើយ ដុះល្អបាន ពាក្យដ៏សេសគប្បីជ្រាបតាមន័យមានក្នុងកាលមុននោះឯង ។

## ពណ៌នា ចតុត្ថជ្ឈាន

[១៣០] ឧបមាសេចក្តីសុខក្នុងចតុត្ថជ្ឈាន មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងបទថា បរិសុទ្ធេន ចេតសា បរិយោទាតេន នេះ គប្បីជ្រាបថា ឈ្មោះថា បរិសុទ្ធិ ព្រោះអត្ថថា មិនមានឧបក្កិលេស ឈ្មោះថា ផូរផង់ ព្រោះអត្ថថា ថ្លាផូរផង់ ។

បទថា ឱទាតេន វត្ថេន នេះ ត្រាស់សំដៅដល់ឧតុផ្សាយទៅ ។

ពិតហើយ ការផ្សាយទៅនៃឧតុ រមែងមិនមានដោយសំពត់ចាស់ ។ ការផ្សាយទៅនៃឧតុ រមែងមានកម្លាំងដោយសំពត់ស្អាតដែលនាំក្នុងខណៈនោះ ។ ក៏ដោយឧបមានេះ ករជកាយដូចសំពត់ សេចក្តីសុខក្នុងចតុត្ថជ្ឈានដូចការផ្សាយទៅនៃឧតុ ។ ព្រោះដូច្នោះ កាលបុរសងូតទឹកល្អ

ហើយ យកសំពត់ស្អាតគ្របរហូតផុតសីសៈ ចំហាយក្តៅពីសីសៈ រមែង ផ្សាយទៅពេញផ្ទាំងសំពត់តែម្តង មិនមានចំណែកណាៗ របស់សំពត់ ដែលចំហាយក្តៅនឹងមិនពាល់ត្រូវ យ៉ាងណា ករជកាយរបស់ភិក្ខុក៏យ៉ាង នោះ មិនមានចំណែកណាៗ ដែលសេចក្តីសុខក្នុងចតុត្ថជ្ឈាននឹងមិនពាល់ ត្រូវ ក្នុងសេចក្តីនេះ គប្បីឃើញសេចក្តីនេះ ដោយប្រការដូច្នេះ ។

ក៏ការពណ៌នាតាមលំដាប់បទ និងន័យនៃការនារបស់ឈាន ៤ ទាំងនេះ ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ដូច្នោះ នឹងមិនពោលឲ្យពិស្តារ ក្នុងទីនេះ ។

ក៏ដោយហេតុត្រឹមតែប៉ុណ្ណេះ ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ជា អ្នកបានរូបឈានប៉ុណ្ណោះ មិនទាន់បានអរូបឈានទេ ។ សេចក្តីថា វៀរភាពជាអ្នកជំនាញក្នុងសមាបត្តិទាំង ៨ ដោយអាការ ១៤ ចេញ ហើយ ការសម្រេចអភិញ្ញាជាន់ខ្ពស់នឹងមានមិនបាន តែក្នុងព្រះបាលី មកចំពោះរូបឈានប៉ុណ្ណោះ ទើបគួរនាំអរូបឈានមកពោលផង ។

# វិបស្សនាញាណកថា

[១៣១] ភិក្ខុនោះ ក្នុងពាក្យថា សោ ឯវំ សមាហិតេ ចិត្តេ ។បេ។ អានេញ្ជប្បត្តេ នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា បានដល់ ភិក្ខុដែលមានសេចក្តីជំនាញក្នុងសមាបត្តិទាំង ៨ ដោយអាការ ១៤ ដែលលោកបានសន្សំទុកហើយ ។ ពាក្យដ៏សេសក្នុងព្រះបាលីនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។

ក្នុងបាលីថា ញាណទស្សនាយ ចិត្តំ អភិនីហរតិ នេះ ពាក្យថា ញាណទស្សនៈ ទ្រង់សំដៅដល់មគ្គញាណក៏បាន ផលញ្ញាណក៏បាន សព្វញ្ញុតញ្ញាណក៏បាន បច្ចវេក្ខណញ្ញាណក៏បាន វិបស្សនាញាណក៏បាន ។

ក៏ មគ្គញ្ញាណ ទ្រង់ត្រាស់ថា ញាណទស្សនៈ ក្នុងព្រះបាលីនេះថា ម្នាលអាវុសោ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃញាណទស្សនៈឬ ។

ផលញ្ញាណ ទ្រង់ត្រាស់ថា ញាណទស្សនៈ ក្នុងព្រះបាលីនេះថា ឧត្តរិមនុស្សធម៌ដ៏ទៃ គឺ ញាណទស្សនៈ វិសេសដែលគួរដល់ព្រះអរិយៈ ជាសុខវិហារ ដែលតថាគតសម្រេចហើយ ។

សព្វញ្ញុតញ្ញាណ ទ្រង់ត្រាស់ថា ញាណទស្សនៈ ក្នុងព្រះបាលីនេះថា ញាណទស្សនៈកើតឡើងហើយដល់ព្រះមានព្រះភាគថា អាឡារ-

តាបសកាលាមគោត្រ ធ្វើកាលកិរិយា ៧ ថ្ងៃ ហើយ ។

បច្ចវេក្ខណាញ្ញាណ ទ្រង់ត្រាស់ថា ញាណទស្សនៈ ក្នុងព្រះបាលីនេះថា ញាណទស្សនៈកើតឡើងហើយដល់តថាគត វិមុត្តិរបស់តថាគតមិនកម្រើក ជាតិនេះជាជាតិចុងក្រោយបង្អស់ ។

តែពាក្យថា ញាណទស្សនាយ ចិត្តំ ក្នុងទីនេះ ទ្រង់ត្រាស់សំដៅដល់ញាណទស្សនៈ ដែលជាវិបស្សនាញាណ ។

បទថា អភិនីហរតិ សេចក្តីថា ធ្វើឲ្យបង្អោនទៅ ឲ្យទោរទៅឲ្យឈមទៅ ដើម្បីកើតវិបស្សនាញាណ ។

សេចក្តីរបស់បទថា រូបី ជាដើម បានពោលទុកហើយនោះឯង ។

បទថា ឱទនកុម្មាសុបចយោ សេចក្តីថា ធំធាត់ឡើង ចម្រើនឡើងដោយបាយ និងនំកុម្មាស ។

បទថា អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ សេចក្តីថា មានសេចក្តីមិនទៀងជាធម្មតា ព្រោះអត្ថថា មានហើយមិនមានវិញ មានការត្រូវដុសខាត់ពណ៌សម្បុរជាធម្មតា ព្រោះត្រូវលាបស្រឡាបខ្លួន ដើម្បីត្រូវការកម្ចាត់ក្លិនស្អុយ មានការគក់ប្រចាប់ ធ្វើសរសៃជាធម្មតា ព្រោះត្រូវគក់ប្រចាប់ថ្នមៗ ដើម្បីបន្ទោបង់សេចក្តីឈឺចុកចាប់របស់អវយវៈតូចធំ ឬមានការត្រូវគក់ប្រចាប់ ធ្វើសរសៃជាធម្មតា ព្រោះក្នុងវេលានៅក្មេងគេឲ្យដេកលើភ្លៅទាំង ២ ហើយបន្តក់ថ្នាំភ្នែក និងចាប់ប្រចាប់ជាដើម

ដើម្បីឲ្យអវយវៈដែលកោងមានទ្រង់ទ្រាយមិនល្អនោះៗ ព្រោះនៅក្នុងគភ៌ ឲ្យបានទ្រង់ទ្រាយល្អ សូម្បីរក្សាយ៉ាងនេះ ក៏នៅតែបែកធ្លាយ ខ្ចាត់ខ្ចាយ ជាធម្មតា រមែងបែកធ្លាយទៅ រមែងខ្ចាត់ខ្ចាយទៅ រាងកាយមានសភាពយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងបទថា រូបី ចាតុម្មហាភូតិកោ ជាដើមនោះ ទ្រង់ត្រាស់ការកើតឡើងដោយបទ ៦ បទ ទ្រង់ត្រាស់ការរលត់ទៅដោយបទ ២ បទខាងក្រោយ ព្រមដោយអនិច្ចបទ ។

បទថា ឯត្ថ និស្សិតំ ឯត្ថ បដិពទ្ធំ សេចក្តីថា អាស្រ័យផង ជាប់ជំពាក់ផង ក្នុងកាយដែលប្រកបដោយមហាភូត ៤ នេះ ។

បទថា សុភោ ប្រែថា គឺ ល្អ ។

បទថា ជាតិមា បានដល់ តាំងឡើងដោយអាការដែលបរិសុទ្ធិ ។

បទថា សុបរិកម្មកតោ បានដល់ ជាងច្នៃយ៉ាងល្អ យកថ្មនិងគ្រួសចេញអស់ ។

បទថា អច្ឆោ ប្រែថា សម្បុរភ្លឺ ។

បទថា វិប្បសន្នោ ប្រែថា ថ្លាយង់ ។

បទថា សព្វាការសម្បន្នោ សេចក្តីថា ដល់ព្រមដោយអាការគ្រប់យ៉ាង មានការលាងជម្រះជាដើម ។

ដោយបទថា នីលំ ជាដើម ទ្រង់សម្តែងការប្រកបព្រមដោយពណ៌ ។

ពិតហើយ អំបោះដែលដោតហើយ រមែងប្រាកដនៅដូច្នោះ ។

ក្នុងបទថា ឯវមេវ ខោ គប្បីជ្រាបការប្រៀបធៀបដោយឧបមាដូច្នេះ ។

ករជកាយដូចកែវមណី វិបស្សនាញាណដូចអំបោះដែលដោតទុក ភិក្ខុអ្នកបានវិបស្សនា ដូចបុរសភ្នែកល្អ វេលាដែលកាយប្រកបដោយមហាភូត ៤ ប្រាកដច្បាស់ដល់ភិក្ខុដែលអង្គុយពិចារណាវិបស្សនាញាណ ដូចវេលាដែលកែវមណីប្រាកដច្បាស់ដល់ជាងអ្នកយកកែវមណីទុកក្នុងដៃ ពិចារណាថា នេះឯងកែវមណី វេលាពួក ៥ នៃផស្សៈ ដែលមានវិបស្សនានោះជាអារម្មណ៍ក្តី ចិត្ត និងចេតសិកទាំងពួងក្តី វិបស្សនា-ញាណនុ៎ះឯងក្តី ប្រាកដច្បាស់ដល់ភិក្ខុដែលអង្គុយពិចារណាវិបស្សនាញាណ ដូចវេលាដែលអំបោះប្រាកដច្បាស់ថា នេះអំបោះគេដោតទុកក្នុងកែវមណីនោះ ។ វិបស្សនាញាណនេះ នៅក្នុងលំដាប់នៃមគ្គញាណ សូម្បីដូច្នោះ ព្រោះវិបស្សនាញាណនេះមិនមានអន្តរាវារៈ ក្នុងពេលផ្តើមអភិញ្ញាវារៈ ដូច្នោះ ទើបទ្រង់សម្តែងក្នុងទីនេះតែម្តង ។

មួយទៀត ព្រោះកាលភិក្ខុមិនធ្វើការពិចារណាដោយអនិច្ចលក្ខណៈជាដើម បានឮសម្លេងដែលគួរខ្លាចដោយទិព្វសោត រឭកដល់ខន្ធដែលគួរខ្លាចដោយបុព្វេនិវាសានុស្សតិ បានឃើញរូបដែលគួរខ្លាចដោយទិព្វចក្ខុ សេចក្តីខ្លាច និងសេចក្តីតក់ស្លុត រមែងកើតឡើង អាការដែលគួរខ្លាច

ដូចពោលនេះ រមែងមិនកើតឡើងដល់ភិក្ខុដែលធ្វើការពិចារណាដោយអនិច្ចលក្ខណៈជាដើម ដូច្នោះ ទ្រង់ទើបសម្តែងវិបស្សនាញាណនេះ ក្នុងទីនេះតែម្តង សូម្បីដើម្បីសម្តែងហេតុ ដែលបន្ទោបង់សេចក្តីខ្លាចរបស់ភិក្ខុដែលសម្រេចអភិញ្ញាឲ្យដល់ព្រម ។

ម្យ៉ាងទៀត ព្រោះដែលឈ្មោះថា សេចក្តីសុខក្នុងវិបស្សនានេះ ជាគ្រឿងញ៉ាំងសុខក្នុងមគ្គផលឲ្យដល់ព្រម ជារបស់ចំពោះខ្លួន ជាសាមញ្ញ-ផល ដូច្នោះ ទើបទ្រង់សម្តែងវិបស្សនាញាណនេះ ក្នុងទីនេះជាដើមតែម្តង ។

## មនោមយិទ្ធិញ្ញាណកថា

[១៣២] បទថា មនោមយំ គឺ សម្រេចអំពីចិត្ត ។

បទថា សព្វង្គបច្ចង្គឹ ថែប្រថា ប្រកបដោយអវយវៈតូចធំគ្រប់ចំណែក ។

បទថា អហីនិន្ទ្រិយំ បានដល់ មានឥន្ទ្រិយមិនខ្វះខាតដោយទ្រង់ទ្រាយ ។

ពិតហើយ រូបដែលអ្នកមានឫទ្ធិនិម្មិត បើអ្នកមានឫទ្ធិស សូម្បីរូបដែលនិម្មិតនោះ ក៏ស បើអ្នកមានឫទ្ធិមិនបានចោះត្រចៀក សូម្បីរូបដែលនិម្មិតនោះ ក៏មិនបានចោះត្រចៀក រូបនិម្មិត រមែងដូចជាអ្នកនិម្មិតនោះគ្រប់ប្រការយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពិតហើយ សូម្បីឧបមា ៣ យ៉ាង មាននាំបណ្តូលស្មៅយ៉ាប្លងចេញពីដើម ក៏ដូចស្មៅយ៉ាប្លងជាដើម លោកពោលដើម្បីសម្តែងសេចក្តីដូចគ្នានុ៎ះឯង ។ ក៏បណ្តូលខាងក្នុងស្មៅយ៉ាប្លងនោះ ប៉ុននឹងស្មៅយ៉ាប្លងនុ៎ះឯង ដាវក៏ប៉ុននឹងស្រោមនុ៎ះឯង ។ ដែលស្រោមជ្រួញៗ ដាវក៏ជ្រួញៗផង ទើបដាក់ចូលទៅបាន ដែលស្រោមសំប៉ែត ដាវក៏សំប៉ែត ។

ពាក្យថា ករណ្ឌា នេះ ជាឈ្មោះរបស់សំណកពស់ មិនមែនជាឈ្មោះរបស់ស្រោមដែលរួញ ៗ ។ ពិតហើយ សំណកពស់រមែងប៉ុន

ទីងខ្លួនពស់នុ៎ះឯង ។

ក្នុងឧបមានោះ លោកសម្តែងថា ដូចទាញពស់ចាកពីសំណកដោយដៃ បុរសគប្បីទាញពស់ចេញពីសំណក ដូច្នេះ ក៏ពិតមែនហើយ តែថាក៏គប្បីជ្រាបថា នាំរូបនិម្មិតនោះ ចេញដោយចិត្តនុ៎ះឯង ។

ក៏ឈ្មោះថា ពស់នេះ តាំងនៅក្នុងជាតិរបស់ខ្លួន អាស្រ័យរន្ធឈើ ឬចន្លោះដើមឈើ សកសំណកចាស់ ដូចជារឹតដងខ្លួនដោយកម្លាំងពោលគឺ ព្យាយាមទាញដងខ្លួនចេញពីសំណក ពស់រមែងសកសំណកបានខ្លួនឯងដោយហេតុ ៤ ប្រការនេះ ដោយប្រការដូច្នេះ មិនអាចសកសំណកបានដោយហេតុដទៃពី ៤ យ៉ាងនោះ ព្រោះដូច្នោះ គប្បីជ្រាបថាពាក្យនេះ លោកពោលសំដៅយកការសកដោយចិត្ត ។

ដោយប្រការដូច្នេះ សរីរៈរបស់ភិក្ខុនេះ ក៏ដូចគ្នានឹងស្នោយ៉ាប្លងជាដើម រូបនិម្មិត ក៏ដូចគ្នានឹងបណ្តូលស្នោយ៉ាប្លងជាដើម នេះជាការប្រៀបដោយឧបមាក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។

ក៏វិធីនិម្មិតក្នុងរឿងនេះ និងកថា ពោលអំពីអភិញ្ញា ៥ មានឥទ្ធិវិធីជាដើម តែទីដទៃពោលទុកពិស្តារក្នុងវិសុទ្ធិមគ្គ ដោយអាការទាំងពួង ដូច្នោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងទីនោះចុះ ។ ដោយសេចក្តីថា ត្រឹមតែឧបមាប៉ុណ្ណោះ ក៏ច្រើនហើយក្នុងទីនេះ ។

# ឥទ្ធិវិធញ្ញាណាទិកថា

**[១៣៣]** ក្នុងព្រះបាលីនោះ ភិក្ខុដែលបានឥទ្ធិវិធញ្ញាណ គប្បីឃើញដូចស្មូនឆ្នាំងដែលឈ្លាសវៃជាដើម ។ ឥទ្ធិវិធញ្ញាណ គប្បីឃើញដូចដីឥដ្ឋដែលប្រចាប់ទុកយ៉ាងល្អ ។ ការសម្ដែងឫទ្ធិបានផ្សេងៗ របស់ភិក្ខុនោះ គប្បីឃើញដូចការធ្វើភាជនៈប្រភេទផ្សេងៗ ដែលបានប្រាថ្នាហើយ ។

ឧបមាទិព្វសោតធាតុ មានឧបមាដូចតទៅនេះ

**[១៣៤]** ព្រោះផ្លូវឆ្ងាយដែលជាកន្តារៈ រមែងជាទីរង្កៀស មានភ័យចំពោះមុខ អ្នកដែលមិនមានចិត្តស្មុះទៅក្នុងផ្លូវនោះ មិនអាចកំណត់បានថា នេះសម្លេងស្គរ នេះសម្លេងសម្ភោរដូច្នោះ កាលនឹងសម្ដែងផ្លូវដែលរួចផុតភ័យ ទើបពោលថា អទ្ធានមគ្គប្បដិបន្នោ អ្នកធ្វើដំណើរផ្លូវឆ្ងាយដោយមិនប្រើស័ព្ទថា កន្តារៈ ។

ក៏ផ្លូវដែលរួចផុតភ័យ ដូចអ្នកយកសំពត់ទទូរក្បាល ដើរសន្សឹមៗទៅ រមែងកំណត់សម្លេងផ្សេងៗ ដូចពោលហើយបានយ៉ាងសប្បាយ គប្បីជ្រាបថា វេលាដែលសម្លេងទិព្វ និងសម្លេងមនុស្សទាំងឆ្ងាយ និងជិត ប្រាកដដល់ព្រះយោគី ដូចវេលាដែលសម្លេងនោះៗ ប្រាកដដោយអំណាចការកំណត់សម្លេងបានយ៉ាងសប្បាយនោះ ។

**[១៣៥]** ឧបមា **ចេតោបរិយញ្ញាណ** មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឧហរោ ប្រែថា នៅក្មេង ។

បទថា យុវា បានដល់ ប្រកបដោយភាពជាកម្លោះក្រមុំ ។

បទថា មណ្ឌនជាតិកោ សេចក្ដីថា សូម្បីជាមនុស្សកម្លោះ ក៏មិនខ្ជិលប្រអូស មិនមែនមនុស្សមានសំពត់ និងរាងកាយស្រមេមស្រមាម មានប្រក្រតីតាក់តែងកាយពិតៗ ងូតទឹកមួយថ្ងៃ ២-៣ ដង មានប្រក្រតីស្លៀកដណ្ដប់សំពត់ស្អាត និងតាក់តែងរឿយៗ ។

បទថា សកណិកំ សេចក្ដីថា មានការតិះដៀលណាមួយ ព្រោះមានប្រជ្រុយខ្មៅមុខ ដំបៅ និងមុនជាដើម ។

ក្នុងព្រះបាលីនោះ គប្បីជ្រាបថា ចិត្ត ១៦ យ៉ាង របស់អ្នកដទៃ រមែងប្រាកដដល់ភិក្ខុដែលអន្ទុយបង្អោនចិត្តទៅ ដោយចេតោបរិយញ្ញាណ ដូចតិះដៀលក្នុងមុខ រមែងប្រាកដដល់កម្លោះក្រមុំ ដែលបានពិចារណាស្រមោលមុខដូច្នោះ ។

[១៣៦] ឧបមា **បុព្វេនិវាសញ្ញាណ** មានវិនិច្ឆ័យដូចតទៅនេះ ៖

កិរិយាដែលធ្វើក្នុងថ្ងៃនោះ រមែងប្រាកដ ដូច្នោះ ៣ ស្រុកដែលបុគ្គលទៅក្នុងថ្ងៃនោះឯង ក៏ជាការកំណត់ហើយ ។

ក្នុងព្រះបាលីនោះ ភិក្ខុដែលបានបុព្វេនិវាសញ្ញាណ គប្បីឃើញដូចបុរសដែលទៅ ៣ ស្រុក , ភព ៣ គប្បីឃើញដូចស្រុក ៣ តំបន់ ភាវៈនៃកិរិយាដែលធ្វើក្នុងភព ៣ ប្រាកដដល់ភិក្ខុអ្នកអន្ទុយបង្អោនចិត្ត

ទៅដើម្បីបុព្វេនិវាសញ្ញាណ គប្បីឃើញដូចភាពជាក់ច្បាស់នៃកិរិយាដែលធ្វើក្នុងថ្ងៃនោះក្នុងស្រុកទាំង ៣ របស់បុរសនោះ ។

[១៣៧] ឧបមា **ទិព្វចក្ខុ** មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា វីថឹ សញ្ចរន្តេ បានដល់ ត្រាច់ទៅមក បាឋៈថា វីថឹ ចរន្តេ ក៏មាន ។ សេចក្តីតែមយ៉ាងដូចគ្នា ។

ក្នុងព្រះបាលីនោះ ករជកាយរបស់ភិក្ខុនេះ គប្បីឃើញដូចប្រាសាទក្នុងផ្លូវបែកជា ៣ កណ្តាលនគរ ភិក្ខុដែលសម្រេចទិព្វចក្ខុនេះឯង គប្បីឃើញដូចមនុស្សក្មេកល្អឈរលើប្រាសាទ សត្វដែលចូលទៅក្នុងគភ៌មាតាដោយអំណាចចុតិ និងបដិសន្ធិ គប្បីឃើញដូចអ្នកដែលចូលផ្ទះ សត្វដែលប្រសូតិចាកគភ៌មាតា គប្បីឃើញដូចអ្នកដែលចេញចាកផ្ទះ សត្វដែលសញ្ចរទៅមកៗ គប្បីឃើញដូចអ្នកដែលសញ្ចរទៅតាមថ្នល់ផ្សេងៗ សត្វដែលកើតក្នុងទីនោះៗ ក្នុងភពទាំង ៣ គប្បីឃើញដូចអ្នកដែលអង្គុយនៅត្រង់ផ្លូវបែកជា៣ ត្រង់កណ្តាលដែលជាទីវាលស្រឡះខាងមុខវេលាដែលពួកសត្វអ្នកកើតក្នុងភពទាំង ៣ ប្រាកដច្បាស់ដល់ភិក្ខុដែលអង្គុយបង្អោនចិត្តទៅដើម្បីទិព្វចក្ខុញាណ គប្បីឃើញដូចវេលាដែលមនុស្សទាំងនោះ ប្រាកដច្បាស់ដល់បុរសអ្នកឈរខាងលើផ្ទៃប្រាសាទ ។ ក៏ការប្រៀបធៀបនេះ ទ្រង់ត្រាស់ទុកដើម្បីសប្បាយទេសនាប៉ុណ្ណោះ ។ តែក្នុងអរូបឈានមិនជាអារម្មណ៍របស់ទិព្វចក្ខុ ។

## អាសវក្ខយញ្ញាណកថា

**[១៣៨]** ក្នុងព្រះបាលីថា ភិក្ខុនោះ កាលបើចិត្តតាំងមាំយ៉ាងនេះហើយ គប្បីជ្រាបថា ចិត្តក្នុងចតុត្ថជ្ឈានដែលជាបាទនៃវិបស្សនា ។

បទថា អាសវានំ ខយញាណាយ សេចក្ដីថា ដើម្បីឲ្យកើតអាសវក្ខយញ្ញាណ ។ ក៏ឈ្មោះថា **អាសវក្ខយ** ក្នុងទីនេះ ទ្រង់ត្រាស់ថា មគ្គខ្លះ ផលខ្លះ និព្វានខ្លះ ភង្គៈខ្លះ ។

ពិតហើយ **មគ្គ** ទ្រង់ត្រាស់ថា អាសវក្ខយៈ ក្នុងបាលីថា ខយេ ញាណំ អនុប្បាទេ ញាណំ ញាណក្នុងមគ្គ ញាណក្នុងការមិនកើតឡើង ។

**ផល** ទ្រង់ត្រាស់ថា អាសវក្ខយៈ ក្នុងបាលីនេះថា អាសវានំ ខយា សមណោ ហោតិ ជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។

**និព្វាន** ទ្រង់ត្រាស់ថា អាសវក្ខយៈ ក្នុងគាថា នេះថា ៖

បរវជ្ជានុបស្សិស្ស   និច្ចំ   ឧជ្ឈានសញ្ញិនោ
អាសវា តស្ស វឌ្ឍន្តិ   អារា សោ អាសវក្ខយា

កាលបុគ្គលឃ្លាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ច ជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន គេរមែងនៅឆ្ងាយពីព្រះនិព្វាន ។

**ភង្គៈ** ទ្រង់ត្រាស់ថា អាសវក្ខយៈ ក្នុងបាលីនេះថា អាសវានំ

១យោ វយោ ភេទោ អនិច្ចតា អន្តរធានំ អាសវៈទាំងឡាយអស់ទៅ សាបសូន្យទៅ បែកធ្លាយទៅ មិនទៀង អន្តរធាន ។ តែក្នុងទីនេះទ្រង់ទ្រង់ប្រាប្ដាយកនិព្វាន សូម្បីអរហត្តមគ្គ ក៏ប្រើបានដូចគ្នា ។

បទថា ចិត្តំ អភិនីហរតិ សេចក្ដីថា ធ្វើវិបស្សនាចិត្តឲ្យបង្អោនទៅ ឲ្យឈមទៅ ឲ្យទោរទន់ទៅកាន់អាសវក្ខយញ្ញាណនោះ ។

ក្នុងពាក្យថា សោ ឥទំ ទុក្ខំ ជាដើម សេចក្ដីថា ដឹងច្បាស់នូវទុក្ខសច្ចសូម្បីទាំងអស់តាមសេចក្ដីពិត ដោយចាក់ធ្លុះលក្ខណៈព្រមទាំងកិច្ចថា ទុក្ខមានប្រមាណប៉ុណ្ណេះ ក្រៃលែងជាងនេះមិនមាន និងដឹងច្បាសនូវតណ្ហាដែលជាហេតុឲ្យកើតទុក្ខនោះថា នេះហេតុឲ្យកើតទុក្ខ និងដឹងច្បាស់នូវឋានៈដែលទុក្ខ និងទុក្ខសមុទ័យទាំង ២ នោះ ដល់ហើយរលត់ទៅ គឺការមិនប្រព្រឹត្តទៅ ការរលត់នៃទុក្ខ និងទុក្ខសមុទ័យទាំងនោះថា នេះជាការរលត់នៃទុក្ខ និងដឹងច្បាស់នូវអរិយមគ្គ ដែលញ៉ាំងទុក្ខនិរោធនោះឲ្យដល់ព្រមតាមសេចក្ដីពិត ដោយចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចថា នេះការបដិបត្តិឲ្យដល់សេចក្ដីរលត់ទុក្ខ ។

លុះទ្រង់សម្ដែងសច្ចៈដោយសរុបយ៉ាងនេះហើយ កាលនឹងទ្រង់សម្ដែងដដែលទៀតនូវបរិយាយមួយដោយជាកិលេស ទើបត្រាស់ពាក្យជាដើមថា ឥមេ អាសវា ដូច្នេះ ។

បទថា តស្ស ឯវំ ជានតោ ឯវំ បស្សតោ សេចក្ដីថា កាលភិក្ខុ

នោះដឹង ឃើញយ៉ាងនេះ ទើបត្រាស់មគ្គដល់ទីបំផុត ព្រមដោយវិបស្សនា ។

បទថា កាមាសវា ប្រែថា ចាកអាសវៈ គឺ កាម ។

ដោយបទថា វិមុច្ចតិ នេះ ទ្រង់សម្តែងមគ្គខណៈ ។

ដោយបទថា វិមុត្តស្មឹ នេះ ទ្រង់សម្តែងផលខណៈ ។

ដោយបទថា វិមុត្តមិតិ ញាណំ ហោតិ ទ្រង់សម្តែងបច្ចវេក្ខណញ្ញាណ ។

ដោយបទថា ខីណា ជាតិ ជាដើម ទ្រង់សម្តែងភូមិរបស់បច្ចវេក្ខណញ្ញាណនោះ ។

ព្រោះថា ព្រះខីណាស្រព កាលពិចារណាដោយញាណនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយជាដើម ។

សួរថា ក៏ជាតិណារបស់ភិក្ខុនោះអស់ហើយ និងភិក្ខុនោះ នឹងដឹងច្បាស់ប្រការនោះ បានយ៉ាងណា ។

ឆ្លើយថា ជាតិដែលជាអតីតរបស់ភិក្ខុនោះ មិនទាន់អស់ ព្រោះអស់ទៅហើយក្នុងកាលមុន ។ ជាតិដែលជាអនាគត ក៏មិនទាន់អស់ ព្រោះមិនមានសេចក្តីព្យាយាមក្នុងអនាគត ។ ជាតិដែលជាបច្ចុប្បន្នមិនទាន់អស់ ព្រោះខន្ធបញ្ចកៈរបស់ភិក្ខុនោះនៅមាន ។ តែជាតិណាគប្បីកើតឡើងព្រោះមគ្គមិនទាន់បានអប់រំ ដោយប្រភេទផ្សេងៗ គឺ ខន្ធបញ្ចកៈ ១ និង ៤ និង ៥ ក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព ,

ជាតិនោះឈ្មោះថា អស់ហើយ ព្រោះដល់សេចក្ដីមិនកើតឡើងតទៅជាធម្មតា ព្រោះមគ្គអប់រំហើយ ។ ភិក្ខុនោះពិចារណាកិលេសដែលខ្លួនលះបានដោយមគ្គភាវនា កាលដឹងថា កម្មសូម្បីនៅមាន ក៏មិនធ្វើបដិសន្ធិតទៅ ព្រោះមិនមានកិលេស ដូច្នេះ ឈ្មោះថា រមែងដឹងច្បាស់នូវជាតិនោះ ។

បទថា វុសិតំ ប្រែថា នៅហើយ នៅចប់ហើយ ។

បទថា ព្រហ្មចរិយំ បានដល់ មគ្គព្រហ្មចរិយ ។ ព្រះសេក្ខៈ ៧ ពួក រួមទាំងកល្យាណបុថុជ្ជនទាំងឡាយ ឈ្មោះថា កំពុងនៅព្រហ្មចរិយៈ ។ ព្រះខីណាស្រព ឈ្មោះថា នៅចប់ព្រហ្មចរិយហើយ ។ ព្រោះដូច្នោះ ព្រះខីណាស្រពនោះកាលពិចារណា ដល់ការនៅប្រព្រឹត្តព្រហ្មចរិយរបស់ខ្លួន រមែងដឹងច្បាស់ថា ព្រហ្មចរិយៈ យើងនៅចប់ហើយ ។

បទថា កតំ ករណីយំ សេចក្ដីថា កិច្ច ១៦ យ៉ាង គឺ បរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច ដោយមគ្គ ៤ ក្នុងសច្ចៈ ៤ សម្រេចហើយ អធិប្បាយថា កិលេសដែលមគ្គនោះៗ គប្បីលះ លោកលះបានហើយ ហេតុនៃទុក្ខ លោកកម្ចាត់បង់ហើយ ។

ពិតហើយ កល្យាណបុថុជ្ជនជាដើម នៅធ្វើកិច្ចនោះ ព្រះខីណាស្រព ធ្វើករណីយកិច្ចរួចស្រេចហើយ ព្រោះដូច្នោះ ព្រះខីណាស្រពនោះ កាលពិចារណាករណីយកិច្ចដែលខ្លួនធ្វើហើយ រមែងដឹងច្បាស់ថា កិច្ច

ដែលគួរធ្វើ យើងធ្វើរួចស្រេចហើយ ។

បទថា នាបរំ ឥត្ថត្តាយ សេចក្ដីថា រមែងដឹងច្បាស់ថា កិច្ច គឺមគ្គភាវនាដើម្បីភាពជាយ៉ាងនេះ គឺ ដើម្បី កិច្ច ១៦ យ៉ាង ឬដើម្បីការអស់ទៅនៃកិលេសយ៉ាងនេះទៀតថា ក្នុងកាលឥឡូវនេះ មិនមានដល់យើងឡើយ ។

មួយ៉ាងទៀត បទថា ឥត្ថត្តាយ សេចក្ដីថា រមែងដឹងច្បាស់ថា ខន្ធសន្តានដទៃចាកភាពជាយ៉ាងនេះ គឺ ចាកខន្ធសន្តានដែលកំពុងប្រព្រឹត្តទៅក្នុងពេលឥឡូវនេះ នេះគឺ មានប្រការយ៉ាងនេះ មិនមានដល់យើងក៏បញ្ចក្ខន្ធទាំងនេះ យើងកំណត់ដឹងហើយ តាំងនៅដូចដើមឈើដាច់ឫសបញ្ចក្ខន្ធទាំងនោះនឹងរលត់ ដូចភ្លើងមិនមានគ្រឿងឆេះ ហើយនឹងដល់ការមិនមានបញ្ញត្តិ ព្រោះចរិមកចិត្តរលត់ ។

បទថា បព្វតសង្ខេបេ គឺ លើកំពូលភ្នំ ។

បទថា អនាវិលោ គឺ មិនមានកក់ ។

ខ្យងហោង និងគ្រុំទាំងឡាយ ឈ្មោះថា សិបបិសម្ពុក ដុំគ្រួសនិងអំបែងក្បឿងទាំងឡាយ ឈ្មោះថា សក្ខរកឋល ។

ឈ្មោះថា មច្ឆគុម្ព ដោយអត្ថថា ហ្វូង គឺ ក្រុមត្រីទាំងឡាយ ។

ក្នុងពាក្យថា តិដ្ឋន្តំបិ ចរន្តំបិ សេចក្ដីថា ដុំគ្រួស និងអំបែងក្បឿងនៅព្រងើយៗ ចំណែកហ្វូងត្រីក្រៅនេះ ហែលក៏មាន ឈប់ក៏មាន ។

ដូចក្នុងគោទាំងឡាយដែលឈរក៏មាន ដេកក៏មាន មាននៅរួមៗ គ្នា គោទាំងនេះត្រាច់ទៅដូច្នោះ សូម្បីគោក្រៅពីនេះ គេក៏ហៅថា ត្រាច់ទៅ ព្រោះកំណត់យកគោដែលកំពុងត្រាច់ យ៉ាងណា សូម្បីខ្យង និងហ្វូងត្រី ទាំង ២ ក្រៅពីនេះ ក៏ហៅថា ឈប់ ព្រោះកំណត់យកដុំគ្រួស និងអំបែងក្បឿងដែលនៅស្ងៀម សូម្បីដុំគ្រួស និងអំបែងក្បឿង ក៏ហៅថា ត្រាច់ទៅ ព្រោះកំណត់យកខ្យង និងហ្វូង ត្រីទាំង ២ ក្រៅពីនេះ ដែលហែលយ៉ាងនោះ ។

ក្នុងអាសវក្ខយញ្ញាណនោះ មានឧបមាថា វេលាដែលសច្ចៈ ៤ ប្រាកដច្បាស់ដល់ភិក្ខុ អ្នកអង្គុយបង្អោនចិត្តទៅដើម្បីអាសវក្ខយៈ គប្បីឃើញដូចវេលាដែលខ្យងហោង និងត្រីជាដើម ប្រាកដដល់អ្នកភ្នែកល្អឈរមើលនៅមាត់ច្រាំង ដូច្នោះ ។

ដោយពាក្យអធិប្បាយត្រឹមតែប៉ុណ្ណេះ ជាការសម្តែងវិញ្ញាណ ១០ គឺ វិបស្សនាញាណ មនោមយញ្ញាណ ឥទ្ធិវិធញ្ញាណ ទិព្វសោតញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសញ្ញាណ ញាណជាគូ គឺ អនាគតង្សញ្ញាណ និងយថាកម្មូបគញ្ញាណ ដែលសម្រេចដោយទិព្វចក្ខុ ទិព្វចក្ខុញ្ញាណ អាសវក្ខយញ្ញាណ ។ គប្បីជ្រាបការចែកអារម្មណ៍របស់ញាណទាំង ១០ នោះ ដូចតទៅនេះ ៖

ក្នុងញាណ ១០ ទាំងនោះ **វិបស្សនាញាណ** មានអារម្មណ៍ ៧

យ៉ាង គឺ បរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ ។

**មនោមយញ្ញាណ** ធ្វើត្រឹមតែរូបាយតនៈ ដែលនិម្មិតហើយប៉ុណ្ណោះ ឲ្យជាអារម្មណ៍ដូច្នោះ ទើបជាបរិត្តារម្មណ៍ បច្ចុប្បន្នារម្មណ៍ និងពហិទ្ធា-រម្មណ៍ ។

**អាសវក្ខយញ្ញាណ** ជាអប្បមាណារម្មណ៍ ពហិទ្ធារម្មណ៍ និង អវត្តព្វារម្មណ៍ ។

ប្រភេទរបស់អារម្មណ៍ដ៏សេស ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា ឧត្តរិតរំ វា បណីតតរំ វា សេចក្តីថា ព្រះមានព្រះភាគទ្រង់ឲ្យទេសនាចប់ ស្រេចដោយកំពូល គឺ ព្រះអរហត្តថា ឈ្មោះថា សាមញ្ញផល ដែលប្រសើរជាងនេះ ដោយបរិយាយយ៉ាងណាមួយ មិនមាន ។

## ព្រះបាទអជាតសត្តុប្រកាសខ្លួនជាឧបាសក

[១៣៩] ព្រះរាជាទ្រង់ថ្វាយសាធុការគ្រប់ៗ ពេលទ្រង់ស្តាប់ខាងដើម កណ្តាល និងខាងចុងនៃព្រះពុទ្ធវចនៈដោយគោរព មានព្រះរាជតម្រិះថា ក៏យើង សួរបញ្ហាទាំងនេះចំពោះសមណព្រាហ្មណ៍ជាច្រើន យូរហើយហ្ន៎ មិនបាន សារៈអ្វីៗ ឡើយ ដូចបុកអង្កាម ព្រះមានព្រះភាគ មានគុណ-សម្បត្តិគួរអស្ចារ្យ ទ្រង់វិសជ្ជនាបញ្ហាទាំងនេះដល់យើង ធ្វើសេចក្តីស្វាង ស្វែ ដូចទ្រង់បំភ្លឺពន្លឺប្រទីបពាន់ដួង យើងត្រូវល្ងង់លោម មិនឲ្យដឹង គុណានុភាពរបស់ព្រះទសពលមកតាំងពីយូរ ដូច្នេះ មានព្រះសរីរៈដែល បីតិ ៥ យ៉ាង បានកើតឡើងដោយការរលឹកដល់ព្រះពុទ្ធគុណពាល់ត្រូវ ហើយ កាលនឹងទ្រង់ផ្សាយសេចក្តីជ្រះថ្លារបស់ព្រះអង្គ ទើបទ្រង់ប្រកាស ខ្លួនព្រះអង្គជាឧបាសក ។ ដើម្បីនឹងសម្តែងសេចក្តីនោះ លោកទើបចាប់ ផ្តើមថា ឯវំ វុត្តេ រាជា ដូច្នេះ ។

បណ្តាបទទាំងនោះ អភិក្កន្ត សព្ទ ក្នុងពាក្យថា អភិក្កន្តំ ភន្តេ នេះប្រាកដក្នុងអត្ថថា អស់ទៅ ល្អស្អាត និងគួរត្រេកអរក្រៃលែង ។

ក៏ អភិក្កន្ត សព្ទនេះ ប្រាកដក្នុងអត្ថថា អស់ទៅ ដូចក្នុងបាលី មានជាដើមថា អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរំ និសិន្នោ ភិក្ខុសង្ឃោ វេលារាត្រីអស់ហើយ ព្រះអង្គ បឋមយាមកន្លងទៅ

ហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ ដូច្នេះ ។

ក្នុងសេចក្ដីល្អ ដូចក្នុងបាលីមានជាដើមថា អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច បុគ្គលនេះល្អជាង បុគ្គលនេះប្រណីតជាងបុគ្គលទាំង ៤ ពួកនេះ ដូច្នេះ ។

ក្នុងសេចក្ដីល្អ ដូចក្នុងគាថាមានជាដើមថា ៖

កោ មេ វន្ទតិ ចាទានិ ឥទ្ធិយា យសសា ជលំ
អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ធិសា

អ្នកណាហ្ន៎រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ដូច្នេះ ។

ក្នុងសេចក្ដីថា គួរត្រេកអរណាស់ ដូចក្នុងបាលីមានជាដើមថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ដូច្នេះ ។

សូម្បីក្នុងទីនេះ ក៏ប្រាកដក្នុងអត្ថថា គួរត្រេកអរក្រៃលែងនុ៎ះឯង និងព្រោះប្រាកដថា ក្នុងអត្ថថា គួរត្រេកអរក្រៃលែង ដូច្នោះ គប្បីជ្រាបថា ស្មើនឹងទទួលពាក្យថា សាធុ សាធុ ព្រះអង្គ ដូច្នេះ ។

ក៏សេចក្ដីថា អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ នេះ បណ្ឌិតគប្បីជ្រាបថា ព្រះបាទអជាតសត្តុត្រាស់ ២ ដង ដោយសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធវចនៈនេះ ដោយលក្ខណៈនេះថា អ្នកដឹងគប្បីពោលដដែលៗ ក្នុងខណៈខ្លាច ខណៈក្រោធ ខណៈសរសើរ ខណៈប្រញាប់ប្រញាល់ ខណៈ

ភ្ញាក់ ខណៈរីករាយ ខណៈសោកសៅ និងខណៈជ្រះថ្លា ដូច្នេះ និងដោយសេចក្តីសរសើរ ។

មយ៉ាងទៀត បទថា អភិក្កន្តំ មានអធិប្បាយថា គួរប្រាថ្នាណាស់ គួរប្រាថ្នាក្រៃលែង គួរពេញចិត្តក្រៃលែង ល្អក្រៃលែង ។

ក្នុងព្រះបាលីនេះ ព្រះបាទអជាតសត្តុ ទ្រង់លើកសរសើរព្រះទេសនាដោយ អភិក្កន្ត ស័ព្ទ ស័ព្ទមួយ ទ្រង់លើកសរសើរសេចក្តីជ្រះថ្លារបស់ព្រះអង្គដោយ អភិក្កន្តស័ព្ទ មួយស័ព្ទទៀត ។

ក៏ក្នុងព្រះបាលីនេះមានអធិប្បាយដូច្នេះថា ពេញចិត្តពិតៗ ព្រះអង្គព្រោះព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ គួរគ្រេកអរក្រៃលែងណាស់ព្រះអង្គ ព្រោះខ្ញុំព្រះអង្គអាស្រ័យព្រះធម៌ទេសនា ទើបជ្រះថ្លា ។

មយ៉ាងទៀត ព្រះបាទអជាតសត្តុ ទ្រង់លើកសរសើរព្រះតម្រាស់របស់ព្រះមានព្រះភាគនុ៎ះឯង សំដៅដល់ប្រយោជន៍ ២ យ៉ាង គឺ ព្រះតម្រាស់របស់ព្រះមានព្រះភាគ ល្អណាស់ ព្រោះធ្វើទោសឲ្យវិនាស ល្អណាស់ ព្រោះឲ្យសម្រេចគុណ ។

មួយទៀត គប្បីប្រកបសេចក្តី ដោយហេតុយ៉ាងនេះជាដើមថា ព្រះតម្រាស់របស់ព្រះមានព្រះភាគល្អណាស់ ព្រោះ ៖

១. ឲ្យកើតសទ្ធា

២. ឲ្យកើតបញ្ញា

៣. ប្រកបដោយអត្ថ

៤. ប្រកបដោយព្យញ្ជនៈ

៥. មានបទងាយ

៦. មានអត្ថជ្រាលជ្រៅ

៧. សប្បាយត្រចៀក

៨. ជាប់ចិត្ត

៩. មិនលើកខ្លួន

១០. មិនបន្តុះបង្អាប់អ្នកដទៃ

១១. ត្រជាក់ដោយករុណា

១២. ផូរផង់ដោយបញ្ញា

១៣. ជាគន្លងធម៌គួររីករាយ

១៤. គួរសញ្ជឹងគិតខ្លាំង

១៥. ស្តាប់បានងាយ

១៦. សាកល្បងធ្វើតាម បានប្រយោជន៍

សូម្បីក្រៃលែងទៅជាងនោះ ទ្រង់នៅលើកសរសើរព្រះទេសនានុ៎ះឯង ដោយឧបមា ៤ យ៉ាង ៗ ក្នុងឧបមា ៤ យ៉ាងនោះ បទថា និក្កុជ្ជិតំ សេចក្តីថា ផ្កាប់មាត់កន្តាំងចុះ ឬធ្វើមាត់កន្តាំងទុកខាងក្រោម ៗ

បទថា ឧក្កុជ្ជេយ្យ សេចក្តីថា ធ្វើឲ្យមានមាត់ផ្ងារឡើង ៗ

បទថា បដិច្ឆន្នំ សេចក្តីថា បិទដោយស្មៅ និងស្លឹកឈើជាដើម ។

បទថា វិវរេយ្យ ប្រែថា បើកផ្ទារ ។

បទថា មូឡ្ហស្ស វា ប្រែថា ដល់អ្នកដែល វង្វេងទិស (ផ្លូវ) ។

បទថា មគ្គំ អាចិក្ខេយ្យ សេចក្តីថា ចង្អុលប្រាប់ថា នេះផ្លូវ ។

បទថា អន្ធការេ សេចក្តីថា ក្នុងសេចក្តីងងឹតមាន អង្គ ៤ គឺ ថ្ងៃ ១៤ កេច ១ , ពាក់កណ្តាលយប់ ១ , ព្រៃស្រោងស្រាង ១ , ដុំពពកបាំង ១ ។ សេចក្តីរបស់បទដែលលំបាកមានត្រឹមតែប៉ុណ្ណេះ ។

ចំណែកសេចក្តីអធិប្បាយប្រកបមានដូច្នេះ អ្នកណាៗ ផ្ងារភាជនៈដែលផ្កាប់ទុក យ៉ាងណា ព្រះមានព្រះភាគញ៉ាំងយើងអ្នកបែរខ្នងចំពោះព្រះសទ្ធម្ម ធ្លាក់ចុះទៅក្នុងអសទ្ធម្មឲ្យរួចផុតចាកពីអសទ្ធម្មបាន ដូច្នោះ អ្នកណាៗ បើករបស់ដែលបិទ យ៉ាងណា ព្រះមានព្រះភាគទ្រង់បើកព្រះសាសនា ដែលត្រូវព្រៃក្រាស់ គឺ មិច្ឆាទិដ្ឋិបិទទុក តាំងពីកាលសាសនារបស់ព្រះមានព្រះភាគកស្សបអន្តរធានទៅ ដូច្នោះ អ្នកណាៗ ប្រាប់ផ្លូវដល់អ្នកវង្វេង យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ធ្វើផ្លូវសួគ៌ ផ្លូវនិព្វាន ឲ្យច្បាស់ដល់យើងអ្នកធ្វើដំណើរខុស ដូច្នោះ អ្នកណាៗ បំភ្លឺប្រទីបប្រេងក្នុងទីងងឹត យ៉ាងណា ព្រះមានព្រះភាគរបស់យើងទ្រង់ទុកនូវប្រទីប គឺ ទេសនាដែលកម្ចាត់ចេញនូវសេចក្តីងងឹត គឺ មោហៈ ដែលបិទបាំងព្រះរតនត្រ័យនោះ ទ្រង់ប្រកាសព្រះធម៌ដោយអនេកបរិយាយ

ព្រោះទ្រង់ប្រកាសដោយបរិយាយទាំងនេះ ដល់យើងដែលលិចនៅក្នុងសេចក្ដីងងឹត គឺ មោហៈ មិនឃើញរូបរតនៈ មានព្រះពុទ្ធរតនៈជាដើម យ៉ាងនោះ ។

ព្រះបាទអជាតសត្តុ ទ្រង់សរសើរព្រះទេសនាយ៉ាងនេះហើយ មានព្រះទ័យជ្រះថ្លាក្នុងព្រះរតនត្រ័យ ដោយព្រះទេសនានេះ កាលទ្រង់ធ្វើអាការដែលជ្រះថ្លា ទើបមានព្រះតម្រាស់ថា ឯសាហំ ជាដើម ។

ក្នុងព្រះបាលីនោះ បទថា ឯសាហំ កាត់បទជា ឯសោ អហំ ។

បទថា ភគវន្តំ សរណំ គច្ឆាមិ សេចក្ដីថា ខ្ញុំព្រះអង្គសូមដល់ គឺ សេពគប់ សេព ចូលទៅអង្គុយជិត យល់ដោយព្រះបំណងនេះថា ព្រះមានព្រះភាគ ជាទីពឹង ជាទីគោរព ជាអ្នកកម្ចាត់ជម្ងឺចិត្ត ជាអ្នកចាត់ចែងប្រយោជន៍របស់យើង ។

ក៏ធាតុពួកណា មានន័យថា ទៅ សូម្បីសេចក្ដីដឹង ក៏ជាន័យរបស់ធាតុទាំងនោះ ព្រោះដូច្នោះ សេចក្ដីនៃបទថា គច្ឆាមិ ខ្ញុំព្រះអង្គសូមដល់នេះ លោកទើបពោលយ៉ាងនេះតែម្ដងថា ជានាមិ ពុជ្ឈាមិ ខ្ញុំព្រះអង្គដឹង ខ្ញុំព្រះអង្គយល់ ដូច្នេះ ។

ក៏ក្នុងពាក្យថា ធម្មញ្ច ភិក្ខុសង្ឃញ្ច នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា ព្រះធម៌ ដោយអត្ថថា ទ្រទ្រង់ទុកនូវអ្នកសម្រេចមគ្គ

ហើយ ធ្វើនិរោធឲ្យជាក់ច្បាស់ហើយ និងបដិបត្តិតាមដែលព្រះមានព្រះ-ភាគ ទ្រង់ទូន្មានមិនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ។ ព្រះធម៌នោះដោយអត្ថ ក៏គឺ អរិយមគ្គ និងនិព្វាន ។ សមពិត ដូចដែលព្រះមាន-ព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណាដែលជាអរិយមគ្គ ប្រកបដោយអង្គ ៨ តថាគតត្រាស់ថា ជាកំពូលនៃធម៌ទាំងឡាយនោះ ដូច្នេះ ។ គប្បីជ្រាបសេចក្តីពិស្តារ ។

និងមិនមែនតែអរិយមគ្គ និងនិព្វានតែម្យ៉ាងប៉ុណ្ណោះ ដែលជាព្រះធម៌ សូម្បីបរិយត្តិធម៌ និងអរិយផលទាំងឡាយ ក៏ជាព្រះធម៌ដោយពិតនោះឯង ។ សមពិតដូចដែលពោលទុកក្នុងឆត្តមាណវកវិមាន ថា ៖

**អ្នកចូរដល់នូវធម៌ ដែលប្រាសចាករាគៈ មិនកម្រើក មិន**
**សៅហ្មង មិនបដិកូល មានរសប្រណីត ដែលបណ្ឌិត**
**ចែកទុកដោយល្អថាជា សរណៈ ដែលមានប្រយោជន៍ ។**

ក៏ក្នុងគាថានេះ ដែលថា ធម៌ដែលប្រាសចាករាគៈ លោកពោលសំដៅយកមគ្គ ។

ដែលថា មិនកម្រើក មិនសៅហ្មង សំដៅយកផល ។ ដែលថាជាអសង្ខតធម៌ សំដៅយកនិព្វាន ។

ដែលថា មិនបដិកូល ជាធម៌មានរសប្រណីត ពិតត្រង់ ដែលទ្រង់ចែកត្រឹមត្រូវហើយ សំដៅយកធម្មក្ខន្ធទាំងអស់ ដែលចែកទុកដោយបិដក ៣ ។

ឈ្មោះថា ព្រះសង្ឃ គឺ អ្នកដែលចូលគ្នាបាន ដោយការរួមគ្នា ដោយទិដ្ឋិ និងសីល ព្រះសង្ឃនោះ ដោយអត្ថ ក៏គឺ ពួកនៃព្រះអរិយ-បុគ្គល ៨. សមពិត ដូចដែលត្រាស់ទុកក្នុងវិមានវត្ថុនោះឯងថា ៖

ដែលបុគ្គលថ្វាយហើយ ក្នុងបុញ្ញខេត្តណា ទ្រង់ត្រាស់
ថា មានផលច្រើន បុញ្ញខេត្តនោះគឺ គូនៃបុរស ៤ គូ
ជាអ្នកស្អាត និងរាប់រៀងដោយបុគ្គលមាន ៨ ដែល
ជាអ្នកឃើញធម៌ អ្នកចូរចូលដល់នូវព្រះសង្ឃនេះថាជាសរណៈ
ចុះ ព្រោះមានប្រយោជន៍ច្រើន ។

ពួកនៃភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ។ ព្រះរាជាទ្រង់ប្រកាសការដល់សរណៈ ៣ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ។

## សរណាគមនកថា

ដើម្បីភាពជាអ្នកឆ្លាតក្នុងសរណាគមន៍ទាំងនោះ ឥឡូវនេះ គប្បីជ្រាបវិធីនេះថា សរណៈ សរណាគមន៍ អ្នកដែលចូលដល់សរណៈ ប្រភេទនៃសរណាគមន៍ ផលនៃសរណាគមន៍ ភាពសៅហ្មង និងការដាច់ ។

ប្រការនេះដូចម្តេច ?

នឹងពន្យល់សេចក្តីដោយអត្ថនៃបទមុន ៖

ឈ្មោះថា **សរណ** ដោយអត្ថថា បៀតបៀន អធិប្បាយថា សម្លាប់ បៀតបៀនធ្វើឲ្យវិនាសនូវសេចក្តីភ័យខ្លាច សេចក្តីតក់ស្លុត សេចក្តីទុក្ខ ទុគ្គតិ សេចក្តីសៅហ្មងគ្រប់ផ្នែក ដោយការចូលដល់សរណៈនោះឯង ។ ពាក្យថា សរណៈនេះ ជាឈ្មោះរបស់ព្រះរតនត្រ័យទាំងឯង ។

ម្យ៉ាងទៀត ឈ្មោះថា **ពុទ្ធ** ដោយអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ហេតុឲ្យប្រព្រឹត្តទៅក្នុងវត្ថុដែលជាប្រយោជន៍ និងឲ្យចេញចាកវត្ថុដែលមិនជាប្រយោជន៍ ។

ឈ្មោះថា **ធម៌** ដោយអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ហេតុឲ្យឆ្លងកន្តារៈ គឺ ភពបាន និងឲ្យសម្រេចភាពក្សេមក្សាន្ត ក្តីរាយ រុងរឿង ។

ឈ្មោះថា **សង្ឃ** ដោយអត្ថថា កម្ចាត់ភ័យរបស់សត្វទាំងឡាយ ហេតុធ្វើវត្ថុដែលធ្វើសូម្បីតិច ឲ្យបានផលបរិបូណ៌ ។

ព្រោះដូច្នោះ ព្រះរតនត្រ័យទើបឈ្មោះថា ជាសរណៈ ដោយបរិយាយនេះ ។

ចិត្តុប្បាទដែលប្រព្រឹត្តទៅដោយអាការ មានព្រះរតនត្រ័យនោះជាខាងមុខ មានកិលេសដែលសេចក្ដីជ្រះថ្លា និងសេចក្ដីគោរពក្នុងព្រះ-រតនត្រ័យនោះកម្ចាត់ហើយ ឈ្មោះថា សរណគមន៍ ។

សត្វអ្នកមានព្រះរតនត្រ័យនោះដល់ព្រមហើយ រមែងដល់សរណៈ អធិប្បាយថា រមែងចូលដល់យ៉ាងនេះថា រតនៈទាំង ៣ នេះ ជាទីពឹងរបស់យើង ទាំងនេះជាទីរាប់អានរបស់យើង ដូច្នេះ ដោយចិត្តុប្បាទមានប្រការដូចពោលហើយ ។ គប្បីជ្រាប ៣ យ៉ាងនេះ គឺ សរណៈ ១ សរណគមន៍ ១ និងអ្នកចូលដល់សរណៈ ១ ប៉ុណ្ណេះមុន ។

ក៏ក្នុងប្រភេទនៃសរណគមន៍ មានវិនិច្ឆ័យដូចតទៅនេះ ៖

សរណគមន៍ មាន ២ យ៉ាង គឺ លោកុត្តរសរណគមន៍ និងលោកិយសរណគមន៍ ។ ក្នុង ២ យ៉ាងនោះ លោកុត្តរសរណគមន៍ ពោលដោយអារម្មណ៍ មាននិព្វានជាអារម្មណ៍ រមែងសម្រេចដោយកាត់ផ្ដាច់ឧបក្កិលេសរបស់សរណគមន៍ក្នុងមគ្គ ខណៈនៃព្រះអរិយបុគ្គលអ្នកឃើញសច្ចៈហើយ ពោលអំពីកិច្ច រមែងសម្រេចក្នុងព្រះរតនត្រ័យដោយប្រការទាំងពួង ។ លោកិយសរណគមន៍ ពោលពីអារម្មណ៍ មានព្រះពុទ្ធគុណជាដើមជាអារម្មណ៍ រមែងសម្រេចដោយការគ្របសង្កត់ឧបក្កិលេសរបស់

សរណាគមន៍នៃបុថុជ្ជនទាំងឡាយ ។ លោកិយសរណាគមន៍នោះ ពោលពីអត្ថ បានដល់ ការបានចំពោះនូវសទ្ធាក្នុងវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើម និងសម្មាទិដ្ឋិ ដែលមានសទ្ធាជាមូល ដែលទ្រង់ត្រាស់ថា ទិដ្ឋុជុកម្មៈ ក្នុងបុញ្ញកិរិយាវត្ថុ ១០ ប្រការ ។

លោកិយសរណាគមន៍នេះ ចែកជា ៤ យ៉ាង គឺ ដោយប្រគល់កាយថ្វាយជីវិត ១ ដោយមានព្រះរតនត្រ័យនោះជាប្រធាន ១ ដោយថ្វាយខ្លួនជាសិស្ស ១ ដោយការថ្វាយបង្គំ ១ ។

ក្នុង ៤ យ៉ាងនោះ ដែលឈ្មោះថា **ប្រគល់កាយថ្វាយជីវិត** បានដល់ ការលះបង់ខ្លួនដល់ព្រះពុទ្ធជាដើម យ៉ាងនេះថា "តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមប្រគល់ខ្លួនចំពោះព្រះពុទ្ធ ចំពោះព្រះធម៌ ចំពោះព្រះសង្ឃ" ។

ដែលឈ្មោះថា **មានព្រះរតនត្រ័យនោះជាប្រធាន** បានដល់ ភាពជាអ្នកមានព្រះរតនត្រ័យជាប្រធានយ៉ាងនេះថា "តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយមេត្តាចាំខ្ញុំថា ខ្ញុំជាអ្នកមានព្រះពុទ្ធ មានព្រះធម៌ និងមានព្រះសង្ឃជាប្រមុខ" ។

ដែលឈ្មោះថា **ប្រគល់ខ្លួនជាសិស្ស** បានដល់ ចូលដល់ភាពជាសិស្សយ៉ាងនេះថា "តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយមេត្តាចាំខ្ញុំថា ខ្ញុំជាអន្តេវាសិករបស់ព្រះពុទ្ធ របស់ព្រះធម៌ របស់ព្រះសង្ឃ" ។

ដែលឈ្មោះថា **ការថ្វាយបង្គំ** បានដល់ ការគោរពយ៉ាងក្រៃលែង ក្នុងព្រះពុទ្ធជាដើមយ៉ាងនេះថា “តាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយមេត្តាចាំខ្ញុំថា ខ្ញុំនឹងធ្វើការក្រាបថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម ចំពោះវត្ថុទាំង ៣ មានព្រះពុទ្ធជាដើមប៉ុណ្ណោះ” ។

ក៏កាលធ្វើអាការ ៤ យ៉ាងនេះ សូម្បីណាមួយ រមែងជាការកាន់យកសរណៈហើយដោយពិត ។

ម្យ៉ាងទៀត គប្បីជ្រាប ការប្រគល់កាយថ្វាយជីវិត សូម្បីយ៉ាងនេះថា “ខ្ញុំលះបង់ខ្លួនចំពោះព្រះមានព្រះភាគ លះបង់ខ្លួនចំពោះព្រះធម៌ ចំពោះព្រះសង្ឃ ខ្ញុំលះបង់ជីវិត ខ្ញុំលះបង់ខ្លួនពិតប្រាកដ លះបង់ជីវិតពិតប្រាកដ ខ្ញុំដល់ព្រះពុទ្ធជាទីពឹងរហូតដល់អស់ជីវិត ព្រះពុទ្ធជាទីពឹងជាទីពួនសម្ងំពីភ័យ ជាទីការពារភ័យរបស់ខ្ញុំ” ។

ការប្រគល់ខ្លួនជាសិស្ស គប្បីជ្រាបដូចការដល់សរណៈរបស់ព្រះមហាកស្សបៈសូម្បីយ៉ាងនេះថា ៖

**ខ្ញុំគប្បីឃើញព្រះសាស្តាហ្ន៎ គប្បីឃើញ ព្រះមានព្រះភាគនោះពិតមែន ខ្ញុំគប្បីឃើញព្រះសុគតហ្ន៎ គប្បីឃើញព្រះមានព្រះភាគនោះពិតមែន ខ្ញុំគួរឃើញព្រះសម្មាសម្ពុទ្ធហ្ន៎ គប្បីឃើញ ព្រះមានព្រះភាគនោះពិតមែន ។**

ការមានព្រះរតនត្រ័យនោះជាប្រមុខ គប្បីជ្រាប ដូចការដល់សរណៈ

របស់អឡវកយក្ខជាដើមយ៉ាងនេះថា ៖

ខ្ញុំព្រះអង្គនឹងត្រាច់ទៅអំពីស្រុកកាន់ស្រុក អំពីបុរីកាន់បុរី សូមនមស្ការនូវព្រះសម្ពុទ្ធ (នោះ) ផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ។

ការថ្វាយបង្គំ គប្បីជ្រាបសូម្បីយ៉ាងនេះថា ៖

គ្រានោះឯង ព្រាហ្មណ៍ឈ្មោះព្រហ្មាយុ ក្រោកចាកអាសនៈ ដណ្ដប់សំពត់ឆៀងស្មាម្ខាង ក្រាបចុះត្រង់ព្រះយុគលបាទរបស់ព្រះមានព្រះភាគដោយសីសៈ យកមាត់ជញ្ជក់ព្រះយុគលបាទរបស់ព្រះមានព្រះភាគ និងយកដៃទាំង ២ ប្របាច់ធ្វើសរសៃ ព្រមទាំងប្រកាសឈ្មោះថា "បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ឈ្មោះព្រហ្មាយុ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ឈ្មោះព្រហ្មាយុ ដូច្នេះ ។

ការថ្វាយបង្គំនេះ មាន ៤ យ៉ាង គឺ ព្រោះជាញាតិ ១ ព្រោះខ្លាច ១ ព្រោះជាអាចារ្យ ១ និងព្រោះកាន់ថា ជាទក្ខិណេយ្យបុគ្គល ១ ។

ក្នុង ៤ យ៉ាងនោះ ព្រោះការថ្វាយបង្គំថា ជាទក្ខិណេយ្យបុគ្គល ចាត់ជាសរណាគមន៍ ក្រៅនេះពីមិនមែន ។

ពិតហើយ ព្រោះការរាប់អានព្រះរតនត្រ័យ យ៉ាងប្រសើរនុ៎ះឯង

បុគ្គលរមែងដល់សរណៈបាន និងដាច់បាន ព្រោះដូច្នោះ អ្នកណាដែលជាសក្យៈក៏ដោយ កោលិយៈក៏ដោយ សំពះដោយគិតថា ព្រះពុទ្ធជាញាតិរបស់យើង ដូច្នេះ រមែងមិនមែនជាការដល់សរណៈឡើយ ឬអ្នកណាសំពះដោយសេចក្ដីខ្លាចថា "ព្រះសមណគោតមជាអ្នកដែលព្រះរាជាទ្រង់បូជា មានអានុភាពច្រើន កាលយើងមិនសំពះ នឹងគប្បីធ្វើសេចក្ដីវិនាសឲ្យបាន" ដូច្នេះ រមែងមិនមែនជាការដល់សរណៈឡើយ ឬអ្នកណារឭកដល់មន្តអ្វីៗ ដែលខ្លួនរៀនក្នុងសំណាក់របស់ព្រះមានព្រះភាគ ក្នុងកាលជាព្រះពោធិសត្វ ឬក្នុងកាលជាព្រះពុទ្ធ រៀនអនុសាសនីបែបនេះថា ៖

**បណ្ឌិតអ្នកគ្រប់គ្រងផ្ទះ គប្បីបែងចែកទ្រព្យសម្បត្តិជា ៤ ចំណែក គប្បីប្រើប្រាស់ ១ ចំណែក គប្បីប្រកបការងារ ២ ចំណែក គប្បីរក្សាទុកនូវចំណែកទី ៤ ក្រែងមានអន្តរាយ ដូច្នេះ ។**

ហើយសំពះដោយគិតថា អាចារ្យរបស់យើង ដូច្នេះ មិនមែនជាការដល់សរណៈឡើយ ។ តែអ្នកណាសំពះដោយគិតថា លោកនេះជាទក្ខិណេយ្យបុគ្គលកំពូលលើលោក ដូច្នេះ អ្នកនោះឯងបានដល់សរណៈហើយ ។

ក៏កាលឧបាសក ឬឧបាសិកា អ្នកដល់សរណៈយ៉ាងនេះហើយ បានសំពះញាតិ សូម្បីបួសក្នុងអន្យតិរ្ថិយ ដោយគិតថា អ្នកនេះជាញាតិ

របស់យើង ដូច្នេះ រមែងមិនដាច់សរណគមន៍ មិនចាំបាច់ពោលថ្វី ដល់អ្នកដែលមិនបានបួស ។ អ្នកសំពះព្រះរាជាដោយសេចក្តីខ្លាច ក៏ដូចគ្នា ព្រោះព្រះរាជានោះ កាលអ្នកណាមិនសំពះ នឹងគប្បីធ្វើសេចក្តីវិនាសឲ្យក៏បាន ព្រោះជាអ្នកដែលរដ្ឋបូជាហើយ ដូច្នេះ ។ កាលសំពះសូម្បីតិរ្ថិយអ្នកទូន្មានសិល្បៈណាមួយ ដោយពាក្យថា "អ្នកនេះជាអាចារ្យរបស់យើង" ដូច្នេះ ក៏មិនដាច់សរណគមន៍ ។ គប្បីជ្រាបប្រភេទនៃសរណគមន៍ ដោយប្រការដូច្នេះ ។

ក្នុងទីនេះ សរណគមន៍ដែលជាលោកុត្តរៈ មានសាមញ្ញផល ៤ ជាវិបាកផល មានការអស់ទៅនៃទុក្ខទាំងពួង ជាអានិសង្សផល ។ សមពិត ដូចទ្រង់ត្រាស់ទុកថា ៖

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណៈ ឃើញច្បាស់នូវអរិយសច្ច ដោយបញ្ញាដ៏ប្រពៃ គឺ ឃើញទុក្ខ ហេតុនាំឲ្យកើតទុក្ខ ការរលត់ទុក្ខ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលជាផ្លូវរលត់ទុក្ខ សរណៈរបស់បុគ្គលនោះ ជាសរណៈដ៏ក្សេម ជាសរណៈដ៏ឧត្តម បុគ្គលអាស្រ័យសរណៈនេះហើយ រមែងរួចផុតចាកទុក្ខទាំងពួង ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្សផលនៃសរណគមន៍នេះ សូម្បីដោយការដែលគេមិនចូលដល់ភាវៈ មាននិច្ចសញ្ញាជាដើម ។ សមពិត ដូចទ្រង់ត្រាស់ទុកថា មិនជាឋានៈ មិនជាឱកាស ដែលបុគ្គលដល់ព្រម

ដោយទិដ្ឋិ គប្បីប្រកាន់នូវសង្ខារណាមួយថា ជារបស់ទៀង , ប្រកាន់នូវសង្ខារណាមួយថា ជាសុខ , ប្រកាន់នូវសង្ខារណាមួយថា ជាខ្លួន , គប្បីសម្លាប់មាតា , សម្លាប់បិតា , សម្លាប់ព្រះអរហន្ត , មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឲ្យពុះពង , បំបែកសង្ឃ , ឧទ្ទិសខ្លួនចំពោះគ្រូដទៃ នុ៎ះមិនមែនឋានៈដែលមានបានឡើយ ។

សរណាគមន៍ដែលជាលោកិយៈ មានភវសម្បត្តិខ្លះ ភោគសម្បត្តិខ្លះ ជាផលពិតប្រាកដ ។ សមពិតដូចទ្រង់ត្រាស់ទុកថា ៖

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សហើយ នឹងទៅកាន់ទេវនិកាយ ដូច្នេះ ។

សូម្បីផលយ៉ាងដទៃរបស់សរណាគមន៍ដែលជាលោកិយៈ លោកក៏ពោលទុកថា គ្រានោះឯង សក្កទេវានមិន្ទព្រមទាំងទេវតា ៨ ម៉ឺន អង្គចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវានមិន្ទ ឋិតនៅក្នុងទីដ៏សមគួរហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពោលដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹង លុះបែកធ្លាយរាងកាយស្លាប់ទៅ

តែងកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះឯង សត្វទាំងនោះ រមែងបាន នូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺ អាយុជាទិព្វ ១ ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាទិព្វ ១ ដូច្នេះ ។ ក្នុងព្រះធម៌ និងព្រះសង្ឃក៏ន័យនេះ ។

មួយយ៉ាងទៀត គប្បីជ្រាបផលវិសេសនៃសរណគមន៍ សូម្បីដោយអំណាចវេលាមសូត្រជាដើម ។ គប្បីជ្រាបផលនៃសរណគមន៍យ៉ាងនេះ ។

ក្នុងសរណគមន៍ ទាំងលោកិយៈ និងលោកុត្តរៈនោះ សរណគមន៍ដែលជាលោកិយៈ រមែងសៅហ្មងដោយសេចក្តីមិនដឹង សេចក្តីសង្ស័យ និងសេចក្តីយល់ខុសក្នុងព្រះរតនត្រ័យជាដើម មិនរុងរឿង បរិបូរ ពេញលេញទៅបាន ។

សរណគមន៍ ដែលជាលោកុត្តរៈ មិនមានសេចក្តីសៅហ្មង ។

មួយទៀត សរណគមន៍ដែលជាលោកិយៈ មាន ២ ប្រភេទ គឺ ដែលមានទោស ១ ដែលមិនមានទោស ១ ។

ក្នុង ២ យ៉ាងនោះ ដែលមានទោស រមែងមានដោយហេតុជាដើមថា ប្រគល់ខ្លួនក្នុងសាស្តាដទៃជាដើម ។ សរណគមន៍ដែលមានទោសនោះ មានផលមិនគួរប្រាថ្នា ។ សរណគមន៍ដែលមិនមានទោស រមែងមានដោយកាលកិរិយា ។ សរណគមន៍ ដែលមិនមានទោសនោះ

មិនមានផល ព្រោះមិនមានវិបាក ។ ចំណែកសរណគមន៍ ដែលជាលោកុត្តរៈមិនមានការបែកធ្លាយឡើយ ។ ព្រោះព្រះអរិយសាវកមិនឧទ្ទិសសាស្តាដទៃ សូម្បីក្នុងចន្លោះភព ។ គប្បីជ្រាបសេចក្តីសៅហ្មង និងការបែកធ្លាយនៃសរណគមន៍ ដោយប្រការដូច្នេះ ។

បទថា ឧបាសកំ មំ ភន្តេ ភគវា ធារេតុ សេចក្តីថា សូមព្រះមានព្រះភាគមេត្តាទ្រង់ចាំ គឺ ទ្រង់ជ្រាបខ្ញុំព្រះអង្គទុកយ៉ាងនេះថា "ខ្ញុំព្រះអង្គអជាតសត្តុនេះ ជាឧបាសក" ។

ក៏ដើម្បីភាពជាអ្នកឆ្លាតក្នុងវិធីរបស់ឧបាសក គួរជ្រាបបកិណ្ណកៈក្នុងទីនេះដូច្នេះថា **អ្នកណាជាឧបាសក** ព្រោះហេតុអ្វីទើបហៅថា **ឧបាសក** **អ្វីជាសីលរបស់ឧបាសក អាជីវៈយ៉ាងណា វិបត្តិយ៉ាងណា សម្បត្តិយ៉ាងណា** ។

ក្នុងបកិណ្ណកៈនោះ អ្នកណាជាឧបាសក គឺ គ្រហស្ថណាមួយដែលដល់ព្រះរតនត្រ័យជាទីពឹង ។ សមពិតដូចដែលពោលទុកថា បពិត្រមហានាម ឧបាសកអ្នកដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង ដោយហេតុណា ប៉ុណ្ណោះឯងឈ្មោះថា ឧបាសក ។

ព្រោះហេតុអ្វី ទើបហៅថា **ឧបាសក** ? ព្រោះអង្គុយជិតព្រះរតនត្រ័យ ។

ពិតហើយ ឧបាសកនោះ ឈ្មោះថា **ឧបាសក** ដោយអត្ថថា

អន្ទ្រយជិតព្រះពុទ្ធ ។ អន្ទ្រយជិតព្រះធម៌ ព្រះសង្ឃ ក៏ជាឧបាសកដូចគ្នា ។

**អ្វីជាសីល** របស់ឧបាសកនោះ ?

វេរមណី ៥ ប្រការ ជាសីលរបស់ឧបាសក ។ ដូចដែលពោលទុកថា បពិត្រមហារាជ ឧបាសកជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកទឹកស្រវឹង គឺ សុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ដោយហេតុណា បពិត្រមហារាជ ឧបាសកអ្នកមានសីល ដោយហេតុប៉ុណ្ណោះឯង ។

**អាជីវៈ** យ៉ាងណា ?

គឺ លះការធ្វើជំនួញខុសសីលធម៌ ៥ យ៉ាង ចិញ្ចឹមជីវិតដោយធម៌ស្មើ ។ សមពិតដូចបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ។ ជំនួញ ៥ យ៉ាងតើដូចម្តេច ។ គឺ ការជួញគ្រឿងសស្ត្រាវុធ ការជួញសត្វ ការជួញសាច់សត្វ ការជួញគ្រឿងស្រវឹង ការជួញថ្នាំពិស ។ ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ ប្រការនេះឯង ឧបាសកមិនគួរធ្វើឡើយ ដូច្នេះ ។

**វិបត្តិ** យ៉ាងណា ?

គឺ សីលវិបត្តិ និងអាជីវវិបត្តិ របស់ឧបាសកនោះឯង ជាវិបត្តិរបស់ឧបាសក ។

មយ៉ាងទៀត ឧបាសកនេះ ជាចណ្ឌាល ជាមន្ទិល និងជាអ្នកដែល

គួររង្កៀសដោយកិរិយាណា កិរិយានោះ គប្បីជ្រាបថា ជាវិបត្តិរបស់ឧបាសក ។ ក៏វិបត្តិទាំងនោះ ដោយអត្ថ បានដល់ ធម៌ ៥ យ៉ាង មានភាពជាអ្នកមិនមានសទ្ធាជាដើម ។

ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មន្ទិលឧបាសកផង និងជាឧបាសកដែលគួរឲ្យរង្កៀសផង ៥ យ៉ាងតើដូចម្តេច ។ គឺ ឧបាសកជាអ្នកមិនមានសទ្ធា ជាអ្នកទ្រុស្តសីល ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើលជឿតែមង្គលមិនជឿកម្ម ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ដូច្នេះ ។

**សម្បត្តិ** យ៉ាងណា ?

សីលសម្បត្តិ និងអាជីវសម្បត្តិ របស់ឧបាសកនោះឯង ជាសម្បត្តិរបស់ឧបាសក បានដល់ ធម៌ ៥ ប្រការ មានសទ្ធាជាដើម ដែលធ្វើភាពជាឧបាសករតនៈជាដើមឲ្យសម្រេច ។ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរិក-ឧបាសកផង ធម៌ ៥ យ៉ាងតើដូចម្តេច ។ គឺ ឧបាសកជាអ្នកមានសទ្ធា ជាអ្នកមានសីល ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ជឿតែកម្មមិនជឿមង្គល មិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យ

តែក្នុងព្រះពុទ្ធសាសនានេះ ដូច្នេះ ។

អគ្គំ សេដ្ឋំ ក្នុងបទថា អដ្ឋតគ្គេ ប្រាកដក្នុងអត្ថថា **ជាខាងដើម ខាងចុង ចំណែក** និង **ប្រសើរបំផុត** ។

ប្រាកដក្នុងអត្ថថា **ជាខាងដើម** ក្នុងប្រយោគមានជាដើមថា អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ ម្នាលសម្លាញ់អ្នករក្សាទ្វារ ពីថ្ងៃនេះជាដើមរៀងទៅ យើងនឹងទ្វារទទួល និគ្រន្ថប្រុស និងពួកនិគ្រន្ថស្រី ។

ក្នុងអត្ថថា **ខាងចុង** ក្នុងប្រយោគមានជាដើមថា តេនេវ អង្គុល-គ្គេន តំ អង្គុលគ្គំ បរាមសេយ្យ ឧច្ចគ្គំ វេឡគ្គំ យកនូវចុងម្រាមដៃទល់ចុងម្រាមនោះ យកចុងអំពៅទល់ចុងអំពៅ យកចុងឫស្សីទល់ចុងឫស្សី ។

ក្នុងអត្ថថា **ចំណែក** ក្នុងប្រយោគមានជាដើមថា អនុជានាមិ ភិក្ខ-វេ អម្ពិលគ្គំ វា មធុរគ្គំ វា តិត្តកគ្គំ វា វិហារគ្គេន វា បរិវេណគ្គេន វា ភាជេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបែងចែកចំណែករសជូរក្តី ចំណែករសផ្អែមក្តី ចំណែករសល្វីងក្តី តាមចំណែកនៃវិហារ ឬតាមចំណែកនៃបរិវេណ ។

ក្នុងអត្ថថា **ប្រសើរបំផុត** ក្នុងប្រយោគមានជាដើមថា យាវតា ភិក្ខវេ សត្តា អបទា វា ។បេ។ តថាគតោ តេសំ អគ្គមក្ខាយតិ

ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាដែលឥតជើងក្តី ។ល។ តថាគតប្រាកដជាបុគ្គលប្រសើរជាងពួកសត្វទាំងនោះ ។

តែក្នុងទីនេះ អគ្គ ស័ព្ទនេះ គប្បីឃើញក្នុងអត្ថថា **ជាខាងដើម** ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងបទថា អជ្ជតគ្គេ នេះ យ៉ាងនេះថា តាំងពីថ្ងៃនេះ ជាដើមទៅ ។

បទថា អជ្ជតំ ប្រែថា មានថ្ងៃនេះ បាឋៈថា អជ្ជទគ្គេ ដូច្នេះ ក៏មាន ទ អក្សរធ្វើបទសន្ធិចូលទុក សេចក្តីថា ធ្វើថ្ងៃនេះឲ្យជាដើម ហេតុ ។

បទថា បាណុបេតំ បានដល់ ចូលដល់ដោយជីវិត ។

ព្រះបាទអជាតសត្តុ ដល់សរណៈដោយការប្រគល់ខ្លួនយ៉ាងនេះថា "ជីវិតរបស់ខ្ញុំព្រះអង្គនៅប្រព្រឹត្តទៅដរាបណា សូមព្រះអង្គមេត្តាទ្រង់ ចាំគឺ ទ្រង់ជ្រាបខ្ញុំព្រះអង្គទុកដរាបនោះចុះថា ចូលដល់ហើយ មិនមានអ្នកដទៃជាសាស្តា ដល់សរណៈ ដោយសរណគមន៍ទាំង ៣ ជាឧបាសកជាកប្បិយការកៈ (សិស្សទទួលបម្រើ) ដោយសេចក្តីថា ប្រសិនបើនឹងមានអ្នកណាយកដាវដ៏មុត កាត់សីសៈរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គក៏នឹងមិនគប្បីពោលព្រះពុទ្ធថា មិនមែនព្រះពុទ្ធ មិនគប្បីពោលព្រះធម៌ថា មិនមែនព្រះធម៌ មិនគប្បីពោលព្រះសង្ឃថា មិនមែនព្រះសង្ឃ" ដូច្នេះ កាលប្រកាសកំហុសដែលខ្លួនធ្វើ ទើបត្រាស់ពាក្យជាដើមថា អច្ចយោ មំ ភន្តេ ។

ក្នុងបទទាំងនោះ បទថា អច្ចយោ ប្រែថា កំហុស ។

បទថា មំ អច្ចគមា សេចក្ដីថា ឈានកន្លង គឺ គ្របសង្កត់ខ្ញុំព្រះអង្គប្រព្រឹត្តទៅ ។

ក្នុងបទថា ធម្មិកំ ធម្មរាជានំ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា ធម្មិក ដោយអត្ថថា ប្រព្រឹត្តធម៌ ។

ឈ្មោះថា ធម្មរាជា ដោយអត្ថថា ជាព្រះរាជាប្រកបដោយធម៌តែម្យ៉ាង មិនមែនដោយអធម៌ មានបិតុឃាតជាដើម ។

បទថា ជីវិតា វោរោបេសិំ បានដល់ ផ្ដាច់ជីវិត ។

បទថា បដិគ្គណ្ហាតុ បានដល់ អត់នូវទោសកំហុស ។

បទថា អាយតិំ សំវរាយ សេចក្ដីថា ដើម្បីសំវរៈក្នុងអនាគត គឺដើម្បីមិនធ្វើខុស គឺ ទោស គឺ សេចក្ដីភ្លាំងភ្លាត់បែបនេះទៀត ។

បទថា តគ្ឃ ជានិបាតចុះក្នុងអត្ថថា ចំណែកតែមួយ ។

បទថា យថាធម្មំ បដិករោសិ សេចក្ដីថា ចូរធ្វើតាមធម៌ដែលគប្បីតាំងនៅបាន អធិប្បាយថា ចូរឲ្យអត់ទោសចេញ ។

បទថា តន្តេ មយំ បដិគ្គណ្ហាម សេចក្ដីថា កំហុសរបស់មហាបពិត្រនោះ តថាគតអត់ទោសឲ្យ ។

បទថា វុឌ្ឍិ ហេសា មហារាជ អរិយស្ស វិនយេ សេចក្ដីថា មហាបពិត្រ នេះឈ្មោះថា ជាវឌ្ឍនធម៌ក្នុងវិន័យរបស់ព្រះអរិយៈ គឺ

ក្នុងសាសនារបស់ព្រះមានព្រះភាគ ។

តើបម្រើនយ៉ាងណា ? គឺ ការឃើញទោសដោយភាពជាទោស ហើយធ្វើ គឺ តាមធម៌ ដល់សេចក្ដីសង្រួមតទៅ ។ តែកាលទ្រង់ធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋានតាមសមគួរ ទើបត្រាស់ថា មហារាជ បុគ្គលណាឃើញនូវទោសកំហុសតាមទោសកំហុសពិត ហើយសំដែងទោសតាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅ នេះជាវឌ្ឍនធម៌ក្នុងវិន័យរបស់ព្រះអរិយជាម្ចាស់ ។

[១៤០] បទថា ឯវំ វុត្តេ សេចក្ដីថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ។

ស័ព្ទថា ហន្ទ ក្នុងពាក្យថា ហន្ទ ច ទានិ មយំ ភន្តេ នេះជានិបាតក្នុងអត្ថថា ពាក្យល្អិតល្អន់ ។ ព្រោះថា ព្រះបាទអជាតសត្តុនោះទ្រង់ធ្វើពាក្យទន់ភ្លន់ក្នុងការស្ដេចទៅ ទើបត្រាស់យ៉ាងនេះ ។

បទថា ពហុកិច្ចា បានដល់ មានកិច្ចច្រើន ។

ពាក្យថា ពហុករណីយា ជាវេវចនៈរបស់ពាក្យថា ពហុកិច្ចា នោះឯង ។

បទថា យស្សទានិ ត្វំ សេចក្ដីថា មហាបពិត្រ សូមព្រះអង្គទ្រង់សម្គាល់ គឺ ជ្រាបវេលាដែលស្ដេចទៅក្នុងកាលឥឡូវនេះចុះ អធិប្បាយថា ព្រះអង្គនុ៎ះឯង ទ្រង់ជ្រាបវេលាដល់ព្រះរាជាអង្គនោះ ។

បទថា បទក្ខិណំ កត្វា បក្កាមិ សេចក្តីថា ព្រះបាទអជាតសត្រូវទ្រង់ធ្វើប្រទក្សិណ ៣ ជុំ ផ្គងអញ្ជលីដ៏រុងរឿងដោយទសនខសមោធាន ទុកលើសិរសា បែរព្រះភក្ត្រត្រង់ព្រះមានព្រះភាគ ស្តេចថយក្រោយរយៈមួយទស្សនវិស័យ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងភាគផែនដី ត្រង់ទីដែលផុតទស្សនវិស័យ ហើយស្តេចចៀសចេញទៅ ។

បទថា ខតាយំ ភិក្ខវេ រាជា សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីករំលើងអស់ហើយ ។

បទថា ឧបហតាយំ សេចក្តីថា ព្រះរាជាព្រះអង្គនេះ ត្រូវកម្ចាត់ចេញហើយ ។ អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាព្រះអង្គនេះ ត្រូវជីកចេញហើយ ត្រូវកម្ចាត់ចេញហើយ មានទីពឹងត្រូវទម្លាយហើយ គឺ ខ្លួនឯង ត្រូវខ្លួនឯងជីកចេញហើយ ក៏អស់ទីពឹង ។

បទថា វិរជំ បានដល់ ប្រាសចាកធូលី គឺ មានរាគៈជាដើម ។

ឈ្មោះថា **មានមន្ទិលទៅប្រាសហើយ** ព្រោះប្រាសចាកមន្ទិល គឺ រាគៈជាដើមនុ៎ះឯង ។

បទថា ធម្មចក្ខុំ បានដល់ ចក្ខុក្នុងធម៌ទាំងឡាយ ឬចក្ខុដែលសម្រេចដោយធម៌ ។

ពាក្យថា **ធម្មចក្ខុ** នេះ ជាឈ្មោះរបស់មគ្គ ៣ ក្នុងឋានៈដទៃៗ តែក្នុងទីនេះ ជាឈ្មោះរបស់សោតាបត្តិមគ្គ ប៉ុណ្ណោះ ។

មានអធិប្បាយថា បើព្រះបាទអជាតសត្តុ មិនបានផ្តាច់ព្រះជន្ម ព្រះបិតា ព្រះអង្គប្រថាប់លើអាសនៈនេះឯង ទ្រង់នឹងបានសម្រេចសោ- តាបត្តិមគ្គក្នុងកាលឥឡូវនេះ តែព្រោះទ្រង់សេពគប់មិត្តអាក្រក់ ទើប កើតអន្តរាយដល់ព្រះអង្គ សូម្បីកាលបើដូច្នោះ ព្រះបាទអជាតសត្តុនេះ ចូលគាល់ព្រះតថាគត ដល់ព្រះរតនត្រ័យជាទីពឹង ព្រោះដូច្នោះ ព្រះ បាទអជាតសត្តុនឹងកើតក្នុងលោហកុម្ភី លិចចុះទៅខាងក្រោម ៣ ម៉ឺនឆ្នាំ អណ្តែតឡើងខាងលើ ៣ ម៉ឺនឆ្នាំទៀត ទើបនឹងរួចផុតបាន ដូចអ្នកណាៗ សម្លាប់មនុស្សហើយ គប្បីផុត ទោសបានដោយទណ្ឌកម្មត្រឹមតែផ្កាឈើ មួយក្តាប់ ដូច្នោះ ព្រោះព្រះសាសនារបស់តថាគត មានគុណធំ ។

បានឮថា ពាក្យដែលពោលមកហើយនេះ ព្រះមានព្រះភាគត្រាស់ ទុកហើយតែម្តង តែមិនបានលើកឡើងទុកក្នុងបាលី ។

សួរថា ក៏ព្រះរាជាទ្រង់ស្តាប់ព្រះសូត្រនេះហើយ ទ្រង់បានអានិសង្ស អ្វី ?

ឆ្លើយថា បានអានិសង្សច្រើន ។

ដោយថា តាំងពីវេលាដែលផ្តាច់ព្រះជន្មព្រះជនកហើយ ព្រះរាជា នេះមិនបានផ្ទំលក់ឡើយ ទាំងពេលយប់ពេលថ្ងៃ តែតាំងពីវេលាដែល ចូលគាល់ព្រះសាស្តា ទ្រង់ស្តាប់ព្រះធម៌ទេសនាដ៏ពីរោះ មានឱជានេះ ហើយ ទ្រង់ផ្ទំលក់បាន ទ្រង់បានធ្វើសក្ការៈធំចំពោះព្រះរតនត្រ័យ ឈ្មោះថា

*អ្នកដែលប្រកបដោយសទ្ធាលំដាប់បុថុជ្ជន ដែលស្មើដូចព្រះរាជាអង្គនេះ មិនមាន ។ ក៏ក្នុងអនាគត នឹងជាព្រះបច្ចេកពុទ្ធព្រះនាមថា* ***ជីវិតវិសេស*** *នឹងបរិនិព្វានហោង ។*

*ព្រះមានព្រះភាគបានត្រាស់ពាក្យនេះហើយ ភិក្ខុទាំងនោះរីករាយចិត្ត សរសើរភាសិតរបស់ព្រះមានព្រះភាគ ។*

ចប់ អដ្ឋកថា សាមញ្ញផលសូត្រទី ២

# អដ្ឋកថា អម្ពដ្ឋសូត្រ ទី ៣

## និទានរឿងអម្ពដ្ឋមាណព

**[១៤១]** *អម្ពដ្ឋសូត្រមានបាលីចាប់ផ្តើមថា ឯវម្មេ សុតំ ។បេ។ (សូត្រនេះ) ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងកោសលជនបទ ក្នុងអម្ពដ្ឋសូត្រនោះ មានការពណ៌នាតាមលំដាប់បទដូចតទៅនេះ ៖*

*បទថា ក្នុងកោសលជនបទ គឺ ជនបទ ដែលជានិវាសស្ថានរបស់ព្រះរាជកុមារអ្នកជនបទទាំងឡាយ អ្នកមាននាមថា កោសល សូម្បីជាជនបទតែមួយ លោកក៏ហៅថា កោសលា (ជាពហុវចនៈ) ព្រោះបន្ថែមស័ព្ទចូលមកក្នុងជនបទឈ្មោះ កោសលនោះ ។*

*ក៏ព្រះបុរាណាចារ្យលោកពោលទុកថា ក្នុងកាលមុនព្រះរាជាទ្រង់ស្តាប់ថា ព្រះរាជកុមារនាមថា មហាបនាទៈ អ្នកបានមើលការលេងមានល្ខោនផ្សេងៗ ជាដើម (នានាដកាទីនិ) ក៏មិនធ្វើអាការសូម្បីត្រឹមតែជា ញញឹមរីករាយឡើយ ទើបបានទ្រង់មានបន្ទូលថា អ្នកណាធ្វើឲ្យបុត្ររបស់យើងសើចបាន យើងនឹងប្រដាប់តាក់តែងអ្នកនោះដោយគ្រឿងអលង្ការទាំងពួង ។ តាំងពីនោះមក កាលពួកមហាជនម្នាក់ ៗ បោលសូម្បីដង្កន្លលមករួមប្រជុំគ្នា ពួកមនុស្សទាំងឡាយមកនឹងដល់ការលេង*

ល្បែងផ្សេងគ្នាអស់វេលាយូរជាង ៧ ឆ្នាំ ក៏មិនអាចនឹងឲ្យព្រះរាជកុមារនោះ ទ្រង់សើចសប្បាយបាន ។ ពេលនោះ ស្តេចសក្កទេវរាជទើបទ្រង់បញ្ជូនអ្នកល្ខោនមកសម្តែង ។ ព្រះអង្គទ្រង់សម្តែងល្ខោនដែលជាទិព្វ ទើបទ្រង់ធ្វើឲ្យព្រះរាជកុមារទ្រង់សើចសប្បាយបាន ។ តមកពួកមនុស្សទាំងនោះ ក៏បែកគ្នា ត្រឡប់ទៅកាន់ស្រុកដែលជាទីអាស្រ័យរៀងៗខ្លួន ។ ពួកគេជួបប្រទះមិត្ត និងសម្លាញ់ជាដើមតាមផ្លូវមក កាលនឹងធ្វើបដិសណ្ឋារៈ (រាក់ទាក់ប្រាស្រ័យ) គ្នា ម្នាក់ៗ ក៏និយាយគ្នាថា កិច្ចិ ភោ កុសលំ កិច្ចិ ភោ កុសលំ (លោកដ៏ចម្រើន មានអ្វីល្អខ្លះទេ លោកដ៏ចម្រើន មានអ្វីល្អខ្លះទេ) ព្រោះដូច្នោះ ដែនខេត្តនោះ លោកទើបហៅឈ្មោះថា **កោសល** ព្រោះប្រកាន់យកពាក្យថា កុសលំ កុសលំ នោះ ។

បទថា **ស្តេចចារិក** គឺ ស្តេចយាងផ្លូវឆ្ងាយ ។ ធម្មតាកាលស្តេចចារិករបស់ព្រះមានព្រះភាគ មាន ២ យ៉ាង គឺ ស្តេចចារិកយ៉ាងប្រញាប់ប្រញាល់ ១ ស្តេចចារិកមិនប្រញាប់ប្រញាល់ ១ ។ ក្នុង ២ យ៉ាងនោះ ការដែលព្រះអង្គទ្រង់ទត ឃើញបុគ្គលដែលគួរឲ្យត្រាស់ដឹងបាន សូម្បីក្នុងទីឆ្ងាយ ក៏ស្តេចនឹងទៅដោយរហ័ស ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងរបស់គេ ឈ្មោះថា ស្តេចចារិកយ៉ាងប្រញាប់ប្រញាល់ ។ គប្បីឃើញដូចក្នុងការស្តេចទៅទទួល ព្រះមហាកស្សបៈជាដើម ។

ពិតមែន ព្រះមានព្រះភាគ កាលនឹងទ្រង់ធ្វើការទទួលព្រះមហា-

កស្សបៈ បានស្តេចទៅរហូតដល់អស់ផ្លូវ ៣ គាវុត ដោយត្រឹមតែមួយក្រែត ដើម្បីប្រយោជន៍ដល់អាឡវកយក្ខ បានស្តេចទៅរហូតដល់អស់ផ្លូវ ៣០ យោជន៍ ដើម្បីប្រយោជន៍ដល់ព្រះអង្គុលិមាលក៏ប៉ុណ្ណោះ តែចំពោះបុក្កុសាតិ ស្តេចទៅរហូតដល់អស់ផ្លូវ ៤៥ យោជន៍ ព្រះមហាកប្បិនៈ ១២០ យោជន៍ ដើម្បីប្រយោជន៍ដល់ព្រះធនិយៈ ៧០០ យោជន៍ ។ ចំពោះតិស្សសាមណេរ ជាសទ្ធិវិហារិករបស់ព្រះធម្មសេនាបតីសារីបុត្រ អ្នកពេញចិត្តនៅតែក្នុងព្រៃ ស្តេចទៅរហូតដល់អស់ផ្លូវ ១២០ យោជន៍នឹងទៀត ៣ គាវុតទៀត ។

បានឮថា ថ្ងៃមួយព្រះថេរៈក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់របស់តិស្សសាមណេរ ។ ព្រះមានព្រះភាគត្រាស់ថា សូម្បីយើងក៏នឹងទៅ ហើយត្រាស់ហៅព្រះអានន្ទមក ដោយទ្រង់ត្រាស់ថា អានន្ទ អ្នកចូរប្រាប់ដល់ភិក្ខុដែលសម្រេចអភិញ្ញា ៦ មាន ២០,០០០ រូប ថា ព្រះមានព្រះភាគស្តេចនឹងទៅកាន់សម្នាក់តិស្សសាមណេរ អ្នកពេញចិត្តនៅតែក្នុងព្រៃ ។ តមកក្នុងថ្ងៃទី ២ ព្រះមានព្រះភាគ មានព្រះខីណាស្រព ២០,០០០ រូប ជាបរិវារ ទ្រង់ហោះឡើងទៅក្នុងអាកាស ស្តេចចុះត្រង់ទីទ្វារគោចរគ្រាមរបស់សាមណេរនោះ ក្នុងទីបំផុតផ្លូវបាន ១២០ យោជន៍ ហើយទ្រង់ដណ្តប់សំពត់ចីវរ ។ ពួកមនុស្សគោលធ្វើដំណើរទៅធ្វើការងារ គ្រាឃើញព្រះមាន-

ព្រះភាគ ម្នាក់ៗ និយាយគ្នាថា ព្រះបរមសាស្តាស្តេចមកហើយ ពួកយើងកុំទៅធ្វើការងារឡើយ នាំគ្នាក្រាលអាសនៈ ព្រមទាំងថ្វាយបាយយាគូ កាលនឹងធ្វើបាទវត្ត ទើបសួរពួកភិក្ខុកម្ពោះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះមានព្រះភាគស្តេចនឹងទៅទីណា ។ ម្នាលឧបាសកនិងឧបាសិកាទាំងឡាយ ព្រះមានព្រះភាគមិនស្តេចទៅក្នុងទីដទៃ ស្តេចមកក៏ដើម្បីទ្រង់ត្រូវការនឹងទតតិស្សសាមណេរ ក្នុងទីនេះឯង ។ ពួកមនុស្សទាំងនោះ ម្នាក់ៗ នាំគ្នាសប្បាយរីករាយចិត្តថា បានឮថា ព្រះបរមសាស្តាស្តេចមក ក៏ដើម្បីទ្រង់ត្រូវការនឹងទតព្រះថេរៈអ្នកស្និទ្ធស្នាលនឹងត្រកូលរបស់ពួកយើង ព្រះថេរៈរបស់ពួកយើងមិនមែនអ្នកតូចតាចឡើយ ។

តមកក្នុងវេលាសម្រេចកត្តកិច្ចរបស់ព្រះមានព្រះភាគ សាមណេរត្រាច់ទៅបិណ្ឌបាតក្នុងស្រុកមកហើយទើបសួរថា ម្នាលឧបាសក និងឧបាសិកាទាំងឡាយ ភិក្ខុសង្ឃច្រើនណាស់ ពេលនោះ ពួកគេទើបប្រាប់ដល់សាមណេរថា ព្រះបរមសាស្តាស្តេចមក ព្រះករុណា ។ សាមណេរទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរដោយអើពើ ដោយអាហារបិណ្ឌបាត ព្រះបរមសាស្តា ទ្រង់ចាប់បាត្ររបស់សាមណេរនោះដោយព្រះហស្ត ហើយត្រាស់ថា តិស្សៈ អាហារបិណ្ឌបាតល្មមហើយតថាគតធ្វើភត្តកិច្ចរួចស្រេចហើយ ។ លំដាប់នោះ សាមណេរទើបសួរ

ដោយអើពើចំពោះឧបជ្ឈាយ៍ហើយ ទើបទៅអង្គុយលើអាសនៈដែលត្រូវបានដល់ខ្លួន ធ្វើភត្តកិច្ច (ឆាន់) ។ តមកក្នុងវេលាសាមណេរនោះឆាន់រួចស្រេចហើយ ព្រះបរមសាស្ដាត្រាស់មង្គលហើយ ស្ដេចចេញទៅប្រថាប់ឈរត្រង់ទ្វារស្រុក ត្រាស់សួរថា តិស្សៈ ផ្លូវណាដែលទៅកាន់ទីនៅរបស់អ្នក សាមណេរក្រាបទូលព្រះមានព្រះភាគថា ផ្លូវនេះ ព្រះអង្គ កាលសាមណេរក្រាបទូលចង្អុលផ្លូវថ្វាយហើយ ទើបត្រាស់ថា តិស្សៈ អ្នកចូរទៅខាងមុខ ។

ដូចបានស្ដាប់មក ព្រះមានព្រះភាគ ទ្រង់ជាអ្នកចង្អុលផ្លូវឲ្យដល់លោកព្រមទាំងទេវលោកក៏ដោយ ទ្រង់បានធ្វើឲ្យសាមណេរនោះ ជាអ្នកចង្អុលផ្លូវឲ្យក្នុងចម្ងាយផ្លូវត្រឹមតែ ៣ គាវុតប៉ុណ្ណោះ ដោយទ្រង់តាំងព្រះទ័យថា តថាគតនឹងបានឃើញសាមណេរ សាមណេរនោះទៅកាន់ទីដែលជាទីនៅរបស់ខ្លួន ហើយបានធ្វើវត្តចំពោះព្រះមានព្រះភាគ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់សួរសាមណេរនោះថា តិស្សៈ ទីណាជាទីចង្ក្រមរបស់អ្នក ទើបស្ដេចទៅទីនោះ ប្រថាប់លើដុំថ្មទីអង្គុយរបស់សាមណេរ ហើយត្រាស់សួរថា តិស្សៈ ក្នុងទីនេះអ្នកនៅជាសុខឬ សាមណេរនោះក្រាបទូលថា នៅជាសុខ ព្រះអង្គ កាលខ្ញុំព្រះអង្គនៅក្នុងទីនេះ បានឮសំឡេងស្រែករបស់ពួកសត្វ ពួករាជសីហ៍ ខ្លាធំ ដំរី ប្រើស និងសត្វក្ងោកជាដើម សេចក្ដីសម្គាល់ថា ជាព្រៃក៏កើតឡើង ខ្ញុំព្រះអង្គ

ទៅជាសុខដោយសេចក្ដីសម្គាល់នោះ ។ ពេលនោះ ព្រះមានព្រះភាគ ត្រាស់ចំពោះសាមណេរនោះថា តិស្សៈ អ្នកចូរប្រកាសសង្ឃឲ្យប្រជុំគ្នា តថាគតនឹងឲ្យពុទ្ធទាយាទដល់អ្នក កាលភិក្ខុសង្ឃប្រជុំគ្នាហើយ ទ្រង់ប្រទាន ឧបសម្បទឲ្យហើយ បានស្ដេចទៅកាន់ទីប្រថាប់របស់ព្រះអង្គតែម្ដង នេះ ឈ្មោះថា ការស្ដេចចារិកប្រញាប់ ។

ក៏កាលព្រះអង្គទ្រង់អនុគ្រោះសត្វលោក ស្ដេចទៅ ដោយស្ដេច ទ្រង់បិណ្ឌបាតតាមលំដាប់ស្រុក និងនិគមរាល់ថ្ងៃ ១ យោជន៍ ខ្លះ ២ យោជន៍ខ្លះ នេះចាត់ថា ស្ដេចចារិកមិនប្រញាប់ ។ ក៏ព្រះមានព្រះភាគ កាលស្ដេចចារិកនេះ ក៏ស្ដេចក្នុងមណ្ឌលណាមួយ បណ្ដា ៣ មណ្ឌល ទាំងនេះ គឺ មណ្ឌលធំ មណ្ឌលកណ្ដាល មណ្ឌលតូច ។ ក្នុងបណ្ដា ៣ មណ្ឌលនោះ មណ្ឌលធំមានកំណត់ ៩០០ យោជន៍ មណ្ឌលកណ្ដាល ដែលកំណត់ ៦០០ យោជន៍ មណ្ឌលតូចមានកំណត់ ៣០០ យោជន៍ ។

ព្រះមានព្រះភាគ ទ្រង់មានព្រះបំណងស្ដេចនឹងចារិកក្នុងមណ្ឌល ធំ ព្រះអង្គទ្រង់បវារណាក្នុងថ្ងៃមហាបវារណាហើយ ក្នុងថ្ងៃ ១ រោច នឹងព្រមដោយភិក្ខុសង្ឃពួកធំជាបរិវារ ស្ដេចចេញទៅ ១០០ យោជន៍ ដោយជុំវិញ ក៏នឹងកើតការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ មនុស្សមកដល់មុនៗ ទើបនឹងបាននិមន្ត បណ្ដាមណ្ឌលទាំង ២ ក្រៅចាកពីនេះ សក្ការៈក៏មក រួមចុះចំពោះក្នុងមហាមណ្ឌលប៉ុណ្ណោះ ។ ព្រះមានព្រះភាគ កាលស្ដេច

ប្រថាប់នៅក្នុងស្រុក និងនិគមនោះៗ អស់ ១-២ ថ្ងៃ ទ្រង់អនុគ្រោះមហាជនដោយទ្រង់ទទួលអាមិសទាន និងចម្រើនកុសលដែលជាចំណែកផុតវដ្ដសង្សារដល់គេ ដោយទ្រង់ប្រទានធម៌ ទ្រង់ឲ្យការចារិកសម្រេចទៅអស់ ៩ ខែ ។

តែបើខាងក្នុងវស្សា សមថៈ និងវិបស្សនាកម្មដ្ឋានរបស់ភិក្ខុទាំងឡាយនៅទន់ខ្ចី ព្រះអង្គក៏ទ្រង់មិនបវារណាក្នុងថ្ងៃមហាបវារណា ទ្រង់ប្រទានជ្រើសរើសថ្ងៃបវារណាទៅ ទ្រង់បវារណាក្នុងថ្ងៃពេញបូណ៌មីខែ ១២ ដល់ថ្ងៃ ១ កេច ខែ ១ ទើបព្រមដោយភិក្ខុសង្ឃពួកធំជាបរិវារស្ដេចចេញហើយ ស្ដេចចូលទៅក្នុងមណ្ឌលខាងកណ្ដាល ព្រះអង្គមានព្រះបំណងនឹងស្ដេចចារិកទៅក្នុងមណ្ឌលខាងកណ្ដាល ដោយហេតុយ៉ាងដទៃក៏មានខ្លះ តែនឹងស្ដេចប្រថាប់នៅរហូតដល់អស់ ៤ ខែ ប៉ុណ្ណោះ ហើយស្ដេចក៏នឹងចេញទៅតាមន័យដែលពោលហើយនុ៎ះឯង ។ បណ្ដាមណ្ឌលទាំង ២ ក្រៅនេះ សក្ការៈក៏នឹងមករួមចុះចំពោះក្នុងមណ្ឌលខាងកណ្ដាលប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់អនុគ្រោះសត្វលោក ដោយន័យមុននោះឯង ទ្រង់ឲ្យការចារិកសម្រេចអស់រយៈកាល ៨ ខែ ។

តែកាលបើព្រះមានព្រះភាគ ទ្រង់ចាំវស្សារហូតអស់ ៤ ខែ ហើយក៏ដោយ វេនេយ្យសត្វនៅមានឥន្ទ្រិយមិនទាន់ចាស់ក្លា ព្រះអង្គទ្រង់រង់ចាំឲ្យពួកគេមានឥន្ទ្រិយចាស់ក្លាសិន នឹងស្ដេចប្រថាប់នៅក្នុងទី

នោះឯងទៀត ១ ខែខ្លះ ២-៣-៤ ខែខ្លះ ហើយទើបនឹងស្តេចចេញទៅ ព្រមទាំងភិក្ខុសង្ឃពួកធំជាបរិវារ ។ ដោយទំនងដូចពោលហើយនុ៎ះឯង បណ្តាមណ្ឌលទាំង ២ ក្រៅនេះ សក្ការៈក៏នឹងមករួមចុះចំពោះក្នុងមណ្ឌល ខ្នាតតូចប៉ុណ្ណោះ ។ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះសត្វលោកតាម ទំនងខាងដើមនោះឯង នឹងទ្រង់ឲ្យការចារិកសម្រេចអស់រយៈកាល ៧ ខែខ្លះ ៦ ខែខ្លះ ៥ ខែខ្លះ ៤ ខែខ្លះ ។

ដូចពោលមកនេះ ក្នុងបណ្តាមណ្ឌលទាំង ៣ នេះ ព្រះមាន-ព្រះភាគ កាលស្តេចចារិកទៅក្នុងមណ្ឌលណាមួយ ស្តេចទៅ ព្រោះហេតុនៃលាភផល មានចីវរជាដើមក៏ទេ ។ តែតាមការពិត ព្រះអង្គស្តេចចារិកទៅក៏ព្រោះសេចក្តីអាណិតសត្វលោក ដោយទ្រង់ត្រិះរិះយ៉ាងនេះថា ជនពួកណាដែលជាមនុស្សក្រខ្សត់ នៅល្ងង់ខ្លៅ ជាមនុស្សចាស់ និងមនុស្សមានជម្ងឺ កាលណាមនុស្សទាំងនោះនឹងមកឃើញតថាគតបាន តែកាលតថាគតត្រាច់ចារិកទៅ មហាជននឹងបានឃើញតថាគត ពួកគេទាំងនោះ ពួកខ្លះនឹងធ្វើចិត្តឲ្យជ្រះថ្លាបាន ពួកខ្លះនឹងបូជាដោយគ្រឿងបូជា មានកម្រងផ្កាឈើជាដើម ពួកខ្លះនឹងថ្វាយភិក្ខាហារត្រឹមតែមួយវែក ពួកខ្លះនឹងលះសេចក្តីឃើញខុស ក្លាយជាអ្នកមានសេចក្តីឃើញត្រូវ អំពើនោះនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ពួកគេ រហូតអស់កាលយូរ ។

មួយទៀត ព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ ស្តេចនឹងចារិកទៅដោយហេតុ ៤ ប្រការ គឺ ដើម្បីប្រយោជន៍ឲ្យព្រះវរកាយបាននៅសប្បាយដោយទ្រង់យាងសម្រាក ១ ដើម្បីប្រយោជន៍រង់ចាំវេលាកើតរឿងរ៉ាវ ១ ដើម្បីប្រយោជន៍នឹងទ្រង់បញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយ ១ ដើម្បីប្រយោជន៍នឹងឲ្យសត្វអ្នកគួរត្រាស់ដឹង អ្នកមានឥន្ទ្រិយចាស់ក្លាហើយក្នុងទីនោះៗ បានត្រាស់ដឹង ១ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយស្តេចនឹងចារិកទៅដោយហេតុ ៤ ប្រការ សូម្បីដទៃទៀត ដោយទ្រង់ត្រិះរិះថា សត្វទាំងឡាយនឹងដល់ព្រះពុទ្ធជាសរណៈ នឹងដល់ព្រះធម៌នឹងដល់ព្រះសង្ឃជាសរណៈ ឬថា តថាគតនឹងឲ្យបរិស័ទទាំង ៤ ឆ្អែតស្កប់ស្កល់ដោយការស្តាប់ធម៌ជាធំ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយស្តេចចារិកទៅដោយហេតុ ៥ ប្រការ សូម្បីយ៉ាងដទៃទៀត ដោយទ្រង់ត្រិះរិះថា សត្វទាំងឡាយ នឹងវៀរចាកការធ្វើជីវិតសត្វឲ្យធ្លាក់ចុះខ្លះ វៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យខ្លះ វៀរចាកការប្រព្រឹត្តខុសក្នុងកាមខ្លះ វៀរចាកការពោលកុហកខ្លះ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺ ទឹកស្រវឹង គឺ សុរា និងមេរ័យខ្លះ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយស្តេចចារិកទៅដោយហេតុ ៨ ប្រការ សូម្បីយ៉ាងដទៃទៀត ដោយទ្រង់ត្រិះរិះថា សត្វទាំងឡាយនឹងបានបឋមឈានខ្លះ ទុតិយឈានខ្លះ តតិយ-ឈានខ្លះ ចតុត្ថឈានខ្លះ អាកាសានញ្ចាយតនសមាបត្តិខ្លះ វិញ្ញាណ-

ញ្ចាយតនសមាបត្តិខ្លះ អាកិញ្ចញ្ញាយតនសមាបត្តិខ្លះ នេវសញ្ញានាសញ្ញា-យតនសមាបត្តិខ្លះ ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ស្តេចចារិកទៅ ដោយហេតុ ៨ ប្រការ សូម្បីយ៉ាងដទៃទៀត ដោយទ្រង់ព្រះត្រិះរិះថា សត្វទាំងឡាយ នឹងសម្រេចសោតាបត្តិមគ្គខ្លះ សោតាបត្តិផលខ្លះ សក-ទាគាមិមគ្គខ្លះ សកទាគាមិផលខ្លះ អនាគាមិមគ្គខ្លះ អនាគាមិផលខ្លះ អរហត្តមគ្គខ្លះ នឹងធ្វើឲ្យច្បាស់នូវអរហត្តផលខ្លះ ។ ដូចពោលមកនេះ ចាត់ថា ស្តេចចារិកមិនប្រញាប់ប្រញាល់ ។ ក្នុងទីនេះ លោកប្រាថ្នាយក ស្តេចចារិកមិនប្រញាប់ប្រញាល់ ។

ក៏ការស្តេចចារិកមិនប្រញាប់ប្រញាល់នេះ មាន ២ យ៉ាង គឺ ស្តេចចារិកប្រចាំ ១ ស្តេចចារិកមិនប្រចាំ ១ ។ បណ្តាចារិក ២ យ៉ាង នោះ ស្តេចទៅតាមលំដាប់ភូមិ ស្រុក និងខេត្ត ចាត់ជាស្តេចចារិកប្រចាំ ។ ចំណែកស្តេចទៅ ដើម្បីប្រយោជន៍ដល់សត្វដែលគួរនឹងឲ្យត្រាស់ដឹងបាន មួយនាក់ប៉ុណ្ណោះ ចាត់ជា ស្តេចចារិកមិនប្រចាំ ។ ក្នុងទីនេះលោក សំដៅយក ស្តេចចារិកមិនប្រចាំនេះ ។

បានឮថា ក្នុងកាលនោះ កាលព្រះមានព្រះភាគ ទ្រង់ផ្សាយសំណាញ់ គឺ ព្រះញាណទៅក្នុងម៉ឺនលោកធាតុ ក្នុងវេលាសម្រេចអស់ពុទ្ធកិច្ច ពេល បច្ឆិមយាម ទ្រង់សម្លឹងមើលពួកសត្វអ្នកមានពូជពង្ស គួរនឹងត្រាស់ដឹង បាន ព្រាហ្មណ៍ឈ្មោះ បោក្ខរសាតិ ចូលទៅខាងក្នុងព្រះសព្វញ្ញុតញ្ញាណ ។

ក្នុងនោះព្រះមានព្រះភាគ កាលទ្រង់ពិចារណាមើលថា ព្រាហ្មណ៍នេះមកប្រាកដក្នុងសំណាញ់ គឺ ញាណរបស់តថាគត គេមានឧបនិស្ស័យឬទេហ្ន៎ ទ្រង់ទតឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គហើយ ទ្រង់ត្រិះរិះថា ព្រាហ្មណ៍នេះ កាលតថាគតទៅជនបទនោះ នឹងប្រើឲ្យសិស្សឈ្មោះ អម្ពដ្ឋៈទៅដើម្បីស្វែងរកមើលលក្ខណៈ គេនឹងពោលឆ្លើយឆ្លងនឹងតថាគត និយាយវាចាមិនសុភាពមានប្រការផ្សេងៗ តថាគតនឹងទូន្មានគេធ្វើឲ្យអស់អស្មិមានះ គេក៏បានប្រាប់ដល់អាចារ្យរបស់គេ ពេលនោះ អាចារ្យរបស់គេបានស្តាប់ពាក្យនោះហើយ ក៏នឹងមកគន់រកមើលលក្ខណៈរបស់តថាគត តថាគតនឹងសម្តែងធម៌ដល់គេ ពេលធម៌ទេសនាចប់ គេក៏នឹងតាំងនៅក្នុងសោតាបត្តិផល ទេសនានឹងមានផលល្អ ដល់មហាជនដូច្នេះ ទើបព្រមដោយភិក្ខុ ៥០០ រូប ជាបរិវារ ស្តេចព្រះដំណើរទៅកាន់ជនបទនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប ។

បទថា ស្រុកព្រាហ្មណ៍ឈ្មោះ ឥច្ឆានង្គលៈ នៅទីណា គឺ ស្រុកព្រាហ្មណ៍ឈ្មោះឥច្ឆានង្គលៈ គួរនឹងទៅបានដោយទិសាភាគណា ឬថាស្រុកព្រាហ្មណ៍ឈ្មោះ ឥច្ឆានង្គលៈ តាំងនៅក្នុងប្រទេសណា ។ បាលីថា ឥច្ឆានង្គលំ ក៏មាន ។ បទថា តទវសរិ ស្តេចបានទៅដល់ សេចក្តីថា ស្តេចទៅដោយផ្លូវនោះ ឬថា ស្តេចទៅកាន់ទីនោះ ។ អធិប្បាយថា

ស្តេចទៅដោយទិសាភាគនោះ ឬថា ស្តេចទៅកាន់ប្រទេសនោះ ។

បទថា ប្រថាប់គង់នៅក្នុងដងព្រៃឈ្មោះ ឥច្ឆានង្គលៈ ទៀបស្រុកឥច្ឆានង្គលៈ សេចក្តីថា ព្រះមានព្រះភាគទ្រង់ជាព្រះធម្មរាជា ទ្រង់អាស្រ័យស្រុកព្រាហ្មណ៍ឈ្មោះ ឥច្ឆានង្គលៈ ទ្រង់តាំងបន្ទាយ គឺ សីល ទ្រង់កាន់ព្រះដំបង គឺ សមាធិ ទ្រង់ញ៉ាំងសរ គឺ ព្រះសព្វញ្ញុតញ្ញាណឲ្យប្រព្រឹត្តទៅ ស្តេចប្រថាប់នៅ ដោយការប្រថាប់តាមដែលព្រះអង្គទ្រង់ពេញព្រះទ័យក្រៃលែង ។

# រឿងពោក្ខរសាតិព្រាហ្មណ៍

[១៤២] បទថា សម័យនោះឯង គឺ ព្រះមានព្រះភាគ ស្តេចប្រថាប់នៅក្នុងទីនោះដោយសម័យណា ដោយសម័យនោះ ។ អធិប្បាយថា ក្នុងសម័យនោះ ។ បុគ្គល រមែងរៀនមន្ត ព្រោះដូច្នោះ ទើបឈ្មោះថា **ព្រាហ្មណ៍** អធិប្បាយថា រមែងស្វាធ្យាយមន្ត ។ ក៏ពាក្យនេះឯង ជាពាក្យហៅព្រាហ្មណ៍ដោយកំណើតក្នុងផ្លូវកាសា ។ តែព្រះអរិយៈទាំងឡាយលោកហៅថា **ព្រាហ្មណ៍** ព្រោះមានបាបអណ្តែតហើយ ។ ពាក្យថា **បោក្ខរសាតិ** នេះ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ លោកហៅឈ្មោះថា **បោក្ខរសាតិ** ព្រោះហេតុអ្វី ។ បានឮថា កាយរបស់ព្រាហ្មណ៍នោះ ល្អដូចគ្នានឹងផ្កាឈូកស ប្រដូចសសរខឿនប្រាក់ ដែលគេបោះទុកក្នុងទេវនគរ ។ ចំណែកសីសៈរបស់គេ មានពណ៌ខ្មៅ ដូចនឹងកែវមរកត ។ សូម្បីពុកមាត់ក៏ប្រាកដដូចជាដុំពពកពណ៌ខ្មៅ ក្នុងព្រះចន្ទ ។ គ្រាប់ភ្នែកទាំង ២ ខាងដូចជាផ្កាឈូកខៀវ ។ ច្រមុះមូលរលោង ដូចទឹកប្រាក់ ។ បាតដៃនិងបាតជើង រួមទាំងបបូរមាត់ ស្រស់ល្អប្រដូចលាបដោយទឹកល័ក្ត ។ អត្តភាពរបស់ព្រាហ្មណ៍ចាត់ថា ល្អប្រសើរក្រៃលែងណាស់ ។ ក្នុងទីដែលមិនមានព្រះរាជា សមគួរនឹងតាំងព្រាហ្មណ៍នេះជាព្រះរាជាបាន ។ ព្រាហ្មណ៍នេះ ក៏ជាអ្នកប្រកបដោយសិរីដូច្នេះ ។ ព្រោះហេតុនេះ ជនទាំងឡាយទើប

ហៅគេថា **ពោក្ខរសាតិ** ព្រោះដូចជាផ្កាឈូក ។

ក៏ព្រាហ្មណ៍នេះ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមថា **កស្សប** រៀនចប់វេទទាំង ៣ ថ្វាយទានចំពោះព្រះទសពលហើយ ស្តាប់ធម៌ទេសនា ទៅកើតក្នុងទេវលោក ។ តពីនោះកាលមកកាន់មនុស្សលោក វៀរសការនៅក្នុងផ្ទៃមាតា ទើបទៅកើតក្នុងផ្កាឈូកធំ ក្នុងស្រះធំខាងព្រៃហិមពាន្ត ។ ត្រង់ទីមិនឆ្ងាយអំពីស្រះនោះ មានតាបសអាស្រ័យនៅក្នុងបណ្ណសាលា ។ តាបសនោះ ឈរលើមាត់ច្រាំងមើលឃើញផ្កាឈូកធំនោះ ទើបគិតថា ផ្កាឈូកធំនេះ ធំជាងផ្កាឈូកដទៃ វេលាដែលវារីក យើងនឹងកាច់វា ។ ផ្កាឈូកធំនោះ តាំងនៅអស់ ៧ ថ្ងៃ ហើយក៏មិនទាន់រីក ។ តាបសទើបគិតថា ព្រោះហេតុអ្វីហ្ន៎ ផ្កាឈូកធំនេះ តាំងនៅ ៧ ថ្ងៃហើយ ក៏មិនទាន់រីក ណ្ហើយចុះ យើងនឹងកាច់វាហើយទើបចុះទៅកាច់ ។ ផ្កាឈូកធំនោះ ពេលតាបសក្តិចដាច់ចាកទងប៉ុណ្ណោះ ក៏រីកឡើង ។ ពេលនោះ ក្នុងខាងក្នុងផ្កាឈូកនោះ ក៏បានឃើញទារកមានពណ៌សម្បុរស មានរូបរាងដូចគ្នានឹងប្រាក់ មានពណ៌ដូចកម្ទេចផងមាស មានវណ្ណៈសល្បើងដូចកេសរផ្កាបទុម ។ តាបសទើបគិតថា ទារកនេះ គង់នឹងជាអ្នកមានបុណ្យច្រើន ណ្ហើយចុះ យើងនឹងចិញ្ចឹមរក្សាគេ ទើបពទៅកាន់បណ្ណសាលា ចិញ្ចឹមរក្សា តាំងពីអាយុបាន ៧ ខួប ក៏ឲ្យរៀនវេទទាំង ៣ ។ ទារករៀនចប់វេទទាំង ៣

ហើយ ជាបណ្ឌិតឆ្លាតវៃ បានជាកំពូលព្រាហ្មណ៍ក្នុងជម្ពូទ្វីប ។ ក្នុងវេលាតមក គេបានសម្តែងសិល្បៈដល់ព្រះបាទកោសល ។ ពេលនោះព្រះរាជាទ្រង់ជ្រះថ្លាក្នុងសិល្បៈរបស់គេ ទើបបានព្រះរាជទានមហានគរឈ្មោះ **ឧក្កដ្ឋ** ឲ្យជាព្រហ្មទេយ្យ ។ ព្រោះហេតុនេះ ប្រជាជនទាំងឡាយទើបហៅគេថា **បោក្ខរសាតិ** ព្រោះហេតុដែលគេដេកក្នុងផ្កាឈូក ។

បទថា នៅគ្រប់គ្រងនគរឈ្មោះឧក្កដ្ឋៈ សេចក្តីថា គេនៅ ឬថានៅគ្រប់គ្រងនគរដែលមានឈ្មោះថា **ឧក្កដ្ឋ** គឺ គេជាម្ចាស់ របស់នគរនោះនៅតាមព្រំដែនដែលជននឹងគប្បីនៅបានក្នុងនគរនោះ ។ បានឮថា ប្រជា-ជនដាក់គោមភ្លើងទុកហើយ កាលគោមភ្លើងឆេះសន្ធោសន្ធៅ ទើបនាំគ្នាប្រកាន់យកទីតាំងនគរនោះ ព្រោះដូច្នោះ នគរនោះ លោកទើបហៅថាឧក្កដ្ឋៈ ។ បាលីថា **ឱក្កដ្ឋ** ដូច្នេះក៏មាន ។ មានសេចក្តីដូចគ្នា ។ តែក្នុងទីនេះគប្បីជ្រាបថា ដោយអំណាចឧបសគ្គៈ ធ្វើជាទុតិយាវិភត្តិប្រើជំនួសសត្តមីវិភត្តិបាន ។ និងក្នុងបទដ៏សេស គប្បីជ្រាបថា ពាក្យនោះមិនមែនជាទុតិយាវិភត្តិ ។ លក្ខណៈក្នុងទីនោះ គប្បីស្រាវជ្រាវពីសព្ទសាស្ត្រ ។

បទថា កុះករដោយសត្វ សេចក្តីថា កុះករដោយសត្វទាំងឡាយគឺ មានជនច្រើនសន្ធឹកសន្ធប់ មានមនុស្សពាសពេញ និងកកកុញដោយសត្វច្រើនប្រភេទ មានដំរី សេះ សត្វក្ងោក និងម្រឹគ ដែលគេចិញ្ចឹមទុកជាដើម ។ ក៏ព្រោះហេតុដែលនគរនេះ សម្បូរណ៍ដោយស្មៅជាអាហារ

របស់ដំរី និងសេះជាដើម និងដោយស្មៅប្រក់ដំបូលផ្ទះ ដែលកើតជុំវិញខាងក្រៅនគរ ទាំងសម្បូរណ៍ដោយឈើដែលជាឧស និងឈើដែលប្រើធ្វើជាគ្រឿងផ្ទះ និងព្រោះហេតុដែលខាងក្នុងនគរនោះ មានស្រះបោក្ខរណីមានសណ្ឋានមូល និង ៤ ជ្រុងជាដើម ច្រើនណាស់ ទាំងមានអណ្តូងទឹករាប់មិនបានទៀតផង ស្រស់ល្អដោយផ្កាឈើ ដែលកើតក្នុងទឹក និងពេញប្រៀបដោយទឹកជានិច្ច ដូច្នោះ លោកទើបហៅថា បរិបូណ៌ដោយស្មៅ ឧស និងទឹក ។ នគរដែលប្រព្រឹត្តទៅព្រមដោយស្រូវ ឈ្មោះថា បរិបូណ៌ដោយស្រូវអង្ករ ។ អធិប្បាយថា មានស្រូវគរទុកច្រើនណាស់ មានប្រភេទជាបុព្វណ្ណជាតិ និងអបរណ្ណជាតិជាដើម ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ សេចក្តីថា លោកបានសម្តែងដល់សម្បត្តិ គឺ ភាពមង្គលនៃនគរ ដែលព្រាហ្មណ៍នៅដោយលីលា អាស្រ័យព្រះរាជា ព្រោះលើកស្វេតច័ត្រតែងតាំងឡើង ។

ភោគសម្បត្តិព្រាហ្មណ៍បានមកពីព្រះរាជា ឈ្មោះថា រាជភោគ បើនឹងសួរថា អ្នកណាឲ្យ ។ ក៏ត្រូវឆ្លើយថា ព្រះរាជាទ្រង់ព្រះនាមថា បសេនទិកោសលព្រះរាជទានឲ្យ ។ បទថា រាជទាយំ ប្រែថា ជារបស់ព្រះរាជទាន អធិប្បាយថា ជាមត៌ក ។ បទថា ព្រហ្មទេយ្យំ ប្រែថា ជារង្វាន់ដ៏ប្រសើរបំផុត អធិប្បាយថា ជារបស់ដែលព្រាហ្មណ៍នឹងគប្បីបាំងស្វេតឆត្រ គ្រប់គ្រងដោយទំនងជាព្រះរាជា ។

ន័យមួយទៀត បទថា រាជភោគ្គំ សេចក្ដីថា ជានគរដែលព្រាហ្មណ៍បង្គាប់ឲ្យដាក់ទោសដោយការកាត់អវយវៈ និងការទម្លាយអវយវៈគ្រប់យ៉ាងបាន កាលនឹងរក្សាកាស៊ីក្នុងស្ថានទី មានកំពង់ទូក និងភ្នំជាដើម នឹងត្រូវបាំងស្វេតឆត្រឡើងជាព្រះរាជាគ្រប់គ្រង ។ ក្នុងបទនេះថា នគរនោះ ព្រះរាជាទ្រង់ព្រះនាមថា បសេនទិកោសល ព្រះរាជទានឲ្យជារាជវង្វាន់ សេចក្ដីថា នគរនោះ ព្រោះព្រះរាជាព្រះរាជទាន ទើបឈ្មោះថា **រាជទាយ** ។ ក៏ដើម្បីនឹងសម្ដែងព្រះរាជា ដែលព្រះរាជទាន លោកទើបពោលពាក្យនេះថា ព្រះរាជាទ្រង់ព្រះនាមថា បសេនទិកោសល ព្រះរាជ-ទានឲ្យ ។ បទថា ព្រហ្មទេយ្យំ ប្រែថា ព្រះរាជទានដ៏ប្រសើរបំផុត , អធិប្បាយថា ជារបស់ដែលព្រះរាជទានហើយ ដោយប្រការដែលថា ព្រះរាជទានហើយ នឹងទ្រង់ទារយកវិញមិនមាន គឺ ទ្រង់លះបង់ឲ្យដាច់ខាតបានដល់ **បរិច្ចាគ** ទៅនោះឯង ។

បទថា អស្សោសិ ប្រែថា បានប្រុងចាំស្ដាប់មក គឺ បានប្រសព្វមកបានដល់ បានជ្រាបមកដោយទំនងពាក្យប្រកាសលាន់ឮ មកដល់សោត-ទ្វារ ។ ពាក្យថា ខោ ជានិបាតចុះក្នុងអត្ថអវធារណៈ (កំណត់ពិតប្រាកដដូចពួក ឯវ ស័ព្ទ) ឬជានិបាតចុះទុកត្រឹមតែជាបទបូរណ៍ (ធ្វើបទឲ្យពេញ) ។ ក្នុង ២ ពាក្យនោះ ដោយអត្ថអវធារណៈ គប្បីជ្រាបពាក្យអធិប្បាយដូច្នេះថា ព្រាហ្មណ៍នោះបានស្ដាប់ ប្រុងស្ដាប់មកដោយយកចិត្ត

ទុកដាក់ គឺ មិនបានមានវត្ថុជំទាស់ចំពោះការបានឮ ។ ដោយបទបូរណ៍ ពាក្យនេះមានត្រឹមតែដាក់ទុក ដើម្បីឲ្យបទ និងព្យញ្ជនៈស្អាតរៀបរយឡើងប៉ុណ្ណោះឯង ។ ឥឡូវនេះព្រាហ្មណ៍ឈ្មោះ បោក្ខរសាតិ កាលនឹងប្រកាសសេចក្តីដែលខ្លួនបានស្តាប់ ប្រុងស្តាប់មក ទើបបានពោលពាក្យមានជាអាទិថា បានស្តាប់មកថា ព្រះសមណគោតមដ៏ចម្រើន ។

គប្បីជ្រាបសេចក្តីក្នុងបទទាំងនោះថា បុគ្គលដែលឈ្មោះសមណៈ ក៏ព្រោះមានបាបដែលរម្ងាប់ហើយ ។ សមដូចដែលលោកពោលទុកថា ៖

ធម៌ដែលជាបាប ជាអកុសលរបស់បុគ្គលនោះ រម្ងាប់ទៅហើយ ។ ព្រះមានព្រះភាគទ្រង់ជាអ្នកមានបាបដែលរម្ងាប់បានហើយ ដោយអរិយមគ្គយ៉ាងកំពូល ។ ព្រោះហេតុនោះ ពាក្យថា **សមណ** នេះ ទើបជាព្រះនាមដែលព្រះអង្គទ្រង់បានទទួលតាមព្រះគុណដែលមានពិត ។

ពាក្យថា ខលុ ជានិបាត ចុះក្នុងអត្ថថា តាមដែលបានឮមក ។ ពាក្យថា ភោ ត្រឹមតែពាក្យហៅឈ្មោះ ដែលបានទទួលមកតាមកំណើតរបស់ព្រាហ្មណ៍ ។ សមពិត ដូចដែលលោកពោលទុកថា ៖

បើគេជាអ្នកនៅមានកង្វល់ គេនោះរមែងមានឈ្មោះហៅបានថា អ្នកដ៏ចម្រើន ។

ព្រាហ្មណ៍លើកតម្កើងព្រះមានព្រះភាគថា **គោតម** ដោយអំណាចនៃគោត្រ ព្រោះដូច្នោះ ក្នុងពាក្យថា សមណោ ខលុ ភោ គោតមោ

គប្បីឃើញសេចក្ដីដូច្នេះថា បានឮថា ព្រះសមណគោតមគោត្រដ៏ចម្រើន ។

ចំណែកពាក្យថា **ជាព្រះរាជឱរសនៃសក្យវង្ស** នេះ ជាពាក្យចង្អុលបង្ហាញដល់ព្រះត្រកូលដែលខ្ពស់នៃព្រះមានព្រះភាគ ។ ពាក្យថា **ទ្រង់ព្រះផ្នួសចាកត្រកូលសក្យវង្ស** ជាពាក្យសម្ដែងឲ្យឃើញដល់ការដែលព្រះអង្គទ្រង់ព្រះផ្នួសដោយសទ្ធា អធិប្បាយថា ព្រះអង្គមិនបានទ្រង់ត្រូវសេចក្ដីខ្វះខាតណាៗ បៀតបៀន ទ្រង់លះត្រកូលឧត្ដមសម្បូរណ៍ ទ្រង់ព្រះផ្នួសដោយសទ្ធា ។ តពីនេះទៅ ក៏មានសេចក្ដីដូចពោលហើយនុ៎ះឯង ។ ពាក្យថា តំ ខោ បន ជាដើម បានសម្ដែងទុកហើយ ដូចគ្នានឹងក្នុងសាមញ្ញផលសូត្រ ។

ពាក្យថា **ជាការញុំាងប្រយោជន៍ឲ្យសម្រេច** អធិប្បាយថា ជាការល្អតែម្យ៉ាង គឺ នាំប្រយោជន៍មកឲ្យ នាំសេចក្ដីសុខមកឲ្យ ។ បទថា ព្រះអរហន្ត មានសភាពបែបនោះ គឺ ព្រះអរហន្ត ដែលបានឈ្មោះហៅថា ព្រះអរហន្តក្នុងលោក ព្រោះសម្រេចគុណធម៌តាមសេចក្ដីពិត ដូចគ្នានឹងព្រះគោតមដ៏ចម្រើននោះ ។ បទថា **ការបានឃើញ** សេចក្ដីថា ព្រាហ្មណ៍ធ្វើការបង្អោននឹកទៅយ៉ាងនេះថា ត្រឹមតែថា ការបើកភ្នែកទាំង ២ ខាងដ៏ត្រជាក់ ដោយសេចក្ដីជ្រះថ្លាឡើងសម្លឹងមើល ក៏ជាការសម្រេចនូវប្រយោជន៍ ។

[១៤៣] ពាក្យនេះថា អជ្ឈាយកៈ ជាអ្នកមិនមានឈាន ជាពាក្យពោល

តិះដៀលពួកព្រាហ្មណ៍អ្នកប្រាសចាកឈាន ក្នុងកាលនៃបឋមកប្បយ៉ាងនេះថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រាហ្មណ៍ទាំងនេះ មិនសម្ងំ ក្នុងកាលឥឡូវនេះ ព្រាហ្មណ៍ទាំងនេះ មិនរៀន ក្នុងកាលឥឡូវនេះ ព្រោះហេតុនេះឯង អក្សរទី ៣ ក៏កើតឡើងថា **អជ្ឈាយិកា អជ្ឈាយិកា** ដូច្នេះឯង ទើបកើតឡើង ។

# រឿង អម្ពដ្ឋមាណាព

តែឥឡូវនេះជនទាំងឡាយ ហៅព្រាហ្មណ៍នោះ ធ្វើឲ្យជាពាក្យសរសើរហើយ ដោយអត្ថន័យនេះថា បុគ្គលណា រមែងរៀនសូត្រ បុគ្គលនោះ ឈ្មោះថា អជ្ឈាយក ជាអ្នករាយមន្ត គឺ ស្វាធ្យាយមន្ត ។ បុគ្គលណា រមែងទ្រង់ចាំមន្តទាំងឡាយបាន បុគ្គលនោះឈ្មោះ មន្តធរ អ្នកចេះចាំមន្ត ។ បទថា **ត្រៃវេទ** គឺ **ឥរុវេទ យជុវេទ** និង **សាមវេទ** ។ បុគ្គលណាដល់ហើយនូវត្រើយ ដោយអំណាចធ្វើឲ្យបបូរមាត់ប៉ះខ្ទប់គ្នា បុគ្គលនោះ ឈ្មោះថា អ្នកដល់ត្រើយ (អ្នករៀនចប់ត្រៃវេទ) ។ ត្រៃវេទប្រព្រឹត្តទៅទឹងដោយនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ឈ្មោះថា ព្រមទឹងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។

ពាក្យថា **គម្ពីរនិឃណ្ឌុ** គឺ សាស្ត្រាដែលសម្តែងដល់ពាក្យវេវចនៈរបស់វត្ថុទាំងឡាយ មាននិឃណ្ឌុរុក្ខជាដើម ។

ពាក្យថា **កេដុភ** គឺ កិរិយាកប្បវិកប្ប បានដល់ សាស្ត្រានិយាយពីថ្វីដៃរបស់កវីទាំងឡាយ ។ ត្រៃវេទប្រព្រឹត្តទៅដោយប្រភេទនៃអក្ខរឈ្មោះថា ព្រមទាំងអក្ខរប្បភេទ ។ បទថា **ប្រភេទនៃអក្ខរ** បានដល់ សិក្ខា និងនិរុត្តិ ។ បទថា ដែលមានសាស្ត្រានិយាយអំពីពង្សាវតារជាគម្រប់ ៥ សេចក្តីថា ពង្សាវតារ ពោលគឺ រឿងរ៉ាវចាស់ៗ

ដែលប្រកបដោយពាក្យ ដូច្នេះថា ឥតិហ អស ឥតិហ អស (វត្ថុនេះបានមានមកហើយដូច្នេះ វត្ថុនេះបានកើតមកហើយដូច្នេះ) ជាគម្រប់ ៥ របស់ត្រៃវេទនោះ ព្រោះរាប់អាថព្វវេទជាគម្រប់ ៤ ហេតុនោះ ត្រៃវេទនោះ ទើបឈ្មោះថា មានគម្ពីរពោលអំពីពង្សាវតារជាគម្រប់ ៥ ។ មានសាស្ត្រពោលអំពីពង្សាវតារជាគម្រប់ ៥ ទាំងនោះ ។ អ្នកណារមែងសិក្សា និងរៀនសូត្របទរបស់វេទ និងការព្យាករណ៍ដ៏ពិសេស អ្នកនោះឈ្មោះថា អ្នកសិក្សាវេទ និងជំនាញការព្យាករណ៍ ។ សាស្ត្រពោលអំពីពាក្យនិយាយលេង លោកហៅថា **លោកាយត** ។ បទថា **លក្ខណៈរបស់មហាបុរស** បានដល់ សាស្ត្រាដែលមានគម្ពីរប្រមាណដល់ ១២,០០០ ដែលសម្តែងនូវលក្ខណៈរបស់មហាបុរស មានព្រះពុទ្ធជាដើម ដែលឈ្មោះថា **ជាពុទ្ធមន្ត** ដែលមានបទគាថាប្រមាណ ដល់ ១៦,០០០ មានប្រាកដប្រការផ្សេងគ្នាដូច្នេះ គឺ អ្នកប្រកបដោយលក្ខណៈនេះ ឈ្មោះថា ជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ ជាព្រះអគ្គសាវកទាំង ២ ជាព្រះមហាសាវក ៨០ ជាព្រះពុទ្ធមាតា ជាព្រះពុទ្ធបិតា ជាអគ្គឧបដ្ឋាក ជាអគ្គឧបដ្ឋាយិកា ជាព្រះរាជា ជាស្តេចចក្រពត្តិ ។

បទថា អ្នកពេញ គឺ មិនខ្វះខាតក្នុងមហាបុរសលក្ខណៈដែលជាលោកាយតៈទាំងនេះ បានដល់ រៀនមកយ៉ាងបរិបូណ៌ អធិប្បាយថា មិនមានការធ្លាក់ចុះឡើយ ។ អ្នកណាមិនអាចនឹងទ្រទ្រង់ចាំទុកដោយចិត្ត

និងដោយគម្ពីរ ដល់មហាបុរសលក្ខណៈទាំងនោះ អ្នកនោះឈ្មោះថា នៅខ្វះខាត ។ បទថា អនុញ្ញាតបដិញ្ញាតោ ប្រែថា អ្នកដែលអាចារ្យព្រមទទួល និងទទួលហើយ អធិប្បាយថា អ្នកដែលអាចារ្យព្រមទទួលហើយ ដោយន័យជាដើមថា យើងដឹងវត្ថុណាៗ លោកក៏ដឹងវត្ថុនោះខ្លួនក៏ទទួលហើយដោយពាក្យបដិញ្ញាណ គឺ ការឲ្យពាក្យឆ្លើយដល់អាចារ្យនោះថា បាទ លោកអាចារ្យ ។ ក្នុងរឿងអ្វី ។ ក្នុងពាក្យទូន្មានដែលប្រកបដោយវិជ្ជា ៣ ដែលជារបស់អាចារ្យខ្លួន ។

បានឮថា ព្រាហ្មណ៍នោះគិតថា ក្នុងលោកនេះ ជនជាច្រើននាំគ្នានិយាយដល់នាមរបស់បុគ្គលដែលខ្ពស់បំផុតថា យើងជាព្រះពុទ្ធ យើងជាព្រះពុទ្ធ ព្រោះដូច្នោះ កាលយើងចូលទៅគាល់ដោយហេតុត្រឹមតែបានឮគេមកមិនជាការសមគួរទេ ព្រោះសូម្បីកាលយើងចូលទៅរកអ្នកខ្លះហើយមិនជៀសចេញទៅ ក៏ជាការលំបាក ទាំងមិនកើតប្រយោជន៍យ៉ាងណាឡើយ បើដូច្នេះ យើងឲ្យសិស្សរបស់យើងដឹងថា ជាព្រះពុទ្ធឬមិនមែន បើពិតប្រាកដហើយ គប្បីចូលទៅគាល់ ព្រោះដូច្នោះ គេទើបហៅមាណពមក ហើយពោលពាក្យជាដើមថា នែអម្ពដ្ឋ ព្រះសមណគោតមជាសក្យបុត្រនេះ ដូច្នេះ ។

បទថា **អ្នកដ៏ចម្រើននោះ** គឺ ព្រះសមណគោតមដ៏ចម្រើននោះ ។ បទថា ពិតដូច្នោះមែន គឺ អ្នកនោះដោយពិត ។ សូម្បីក្នុងបទនេះ

ពាក្យនេះ ក៏ជាទុតិយាវិភត្តិដោយអំណាចនៃអត្ថថា ពោលដល់តាមការស់នៅដូច្នោះ ។ ក្នុងបទ នេះថា យថាកថំ បនាហំ ភោ មានសេចក្តីថា នៃអ្នកដ៏ចម្រើន យើងនឹងដឹងព្រះគោតមដ៏ចម្រើននោះ បានយ៉ាងណា ព្រះគោតមនោះ យើងនឹងអាចដឹងបានដោយវិធីណា លោកចូរប្រាប់ព្រះគោតមនោះដល់យើង ដោយវិធីនោះ ។ មួយទៀត ពាក្យថា យថា នេះ ត្រឹមតែនិបាត ។ ពាក្យថា កថំ ជាពាក្យសួរដល់អាការ ។ មានសេចក្តីថា យើងនឹងដឹងព្រះគោតមដ៏ចម្រើននោះ បានដោយហេតុណា ។

បានឮថា កាលពោលដល់យ៉ាងនេះ ព្រាហ្មណ៍ដែលជាឧបជ្ឈាយ៍ទើបពោលពាក្យជាដើមថា នៃបា ! លោករមែងពោលដូចគ្នានឹងមនុស្សឈរលើផែនដីនិយាយថា ខ្ញុំមិនឃើញផែនដី និងអ្នកដែលឈរក្នុងពន្លឺរបស់ព្រះចន្ទ និងព្រះអាទិត្យ និយាយថា ខ្ញុំមិនឃើញព្រះចន្ទ និងព្រះអាទិត្យ ដូច្នេះ ចំពោះគេហើយ កាលនឹងពោលអាការដែលខ្លួនដឹងទើបពោលថា អាគតានិ ខោ តាត ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **មន្តទាំងឡាយ** គឺ ក្នុងវេទទាំងឡាយ ។ ពួកទេវតាជាន់សុទ្ធាវាសជ្រាបថា បានឮថា ព្រះតថាគត នឹងឧប្បត្តិឡើង ទើបបានប្រញាប់ដាក់លក្ខណៈទាំងឡាយទុកក្នុងវេទទាំងឡាយ ហើយបង្រៀនវេទទាំងឡាយ ដោយប្លែងភេទជាព្រាហ្មណ៍ ដោយពោលថា ទាំងនេះឈ្មោះថា ព្រះពុទ្ធមន្ត ដោយគិតថា សត្វអ្នកមានសក្តិធំទាំងឡាយ នឹងស្គាល់

ព្រះតថាគតដោយទំនងនេះ ដូច្នេះ ។

ព្រោះហេតុនោះ មហាបុរសលក្ខណៈទាំងឡាយ ទើបមានមកក្នុងវេទទាំងឡាយមុន ។ តែកាលព្រះតថាគតបរិនិព្វានហើយ ក៏នឹងត្រូវអន្តរធានទៅដោយលំដាប់ ព្រោះហេតុនោះ ឥឡូវនេះ ទើបមិនមាន ។ ពាក្យថា របស់មហាបុរស គឺ របស់បុគ្គលដែលធំដោយគុណ មានការតាំងចិត្តមាំ ការកាន់យកមាំ សេចក្ដីដឹង និងករុណាជាដើម ។ ពាក្យថា គតិ ២ ប៉ុណ្ណោះ គឺ ទីបំផុត ២ យ៉ាងប៉ុណ្ណោះដោយពិត ។ **គតិ** សព្ទនេះប្រព្រឹត្តទៅក្នុងសេចក្ដីផ្សេងគ្នានៃភព ដូចក្នុងពាក្យមានជាដើមថា ម្នាលសារីបុត្ត ភពមាន ៥ ទាំងនេះ ។ ប្រព្រឹត្តទៅក្នុងស្ថានទីអាស្រ័យក្នុងពាក្យជាដើមថា ព្រៃធំ ជាទីអាស្រ័យនៅរបស់ពួកម្រឹគទាំងឡាយ ។ ប្រព្រឹត្តទៅក្នុងបញ្ញា ក្នុងពាក្យជាដើមថា អ្នកមានបញ្ញាច្រើន ដូច្នោះ ។ ប្រព្រឹត្តទៅក្នុងសេចក្ដីផ្សេងៗ ក្នុងពាក្យជាដើមថា គតិគតំ ។ តែក្នុងទីនេះ គប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងទីបំផុត ។ ក្នុងលក្ខណៈទាំងនោះ អ្នកប្រកបដោយលក្ខណៈពួកណា រមែងជាស្ដេចចក្រពត្តិ រមែងមិនជាព្រះសម្មាសម្ពុទ្ធដោយលក្ខណៈទាំងនោះ ដោយពិត ។ តែលោកពោលថា លក្ខណៈនោះៗ ដោយសេចក្ដីស្មើគ្នានៃជាតិ ។ ព្រោះហេតុនោះ លោកទើបពោលថា អ្នកប្រកបដោយលក្ខណៈពួកណា ។

បទថា **បើនៅគ្រប់គ្រងផ្ទះ** គឺ បើនៅក្នុងផ្ទះ ។ បទថា នឹងជា

ស្ដេចចក្រពត្តិ សេចក្ដីថា អ្នកដែលឈ្មោះថា ជាព្រះរាជា ព្រោះធ្វើឲ្យប្រជារាស្ដ្រត្រេកអរដោយអច្ឆរិយធម៌ និងដោយសង្គហវត្ថុ ៤ យ៉ាង អ្នកដែលឈ្មោះថា **ចក្រពត្តិ** ព្រោះញ៉ាំងចក្រឲ្យប្រព្រឹត្តទៅ គឺ ប្រព្រឹត្តទៅព្រមនឹងចក្រ ដែលជាសម្បត្តិ ៤ យ៉ាង និងញ៉ាំងមនុស្សដទៃឲ្យប្រព្រឹត្តទៅផង ។ មួយទៀត ការប្រព្រឹត្តទៅនៃឥរិយាបថចក្រ ដើម្បីប្រយោជន៍ដល់អ្នកដទៃមាននៅក្នុងអ្នកនោះ អ្នកនោះ ឈ្មោះថា ចក្រពត្តិ ។ ក្នុងពាក្យទាំងពីរនេះ ពាក្យថា **រាជា** ជាពាក្យសាមញ្ញធម្មតា ។ ពាក្យថា **ចក្រពត្តិ** ជាពាក្យវិសេស ។ អ្នកឈ្មោះថា **ធម្មិក** ព្រោះប្រព្រឹត្តដោយធម៌ អធិប្បាយថា ប្រព្រឹត្តដោយប្រពៃក្រៃលែង គឺ ដោយស្មោះស្មើ ។ អ្នកឈ្មោះថា **ធម្មរាជា** ព្រោះបានរាជសម្បត្តិដោយធម៌ ទើបបានជាព្រះរាជា ។ មួយប្រការទៀត អ្នកឈ្មោះថា **ធម្មិក** ព្រោះធ្វើសេចក្ដីល្អដែលជាប្រយោជន៍ដល់អ្នកដទៃ អ្នកឈ្មោះថា ធម្មរាជា ព្រោះការធ្វើសេចក្ដីល្អដែលជាប្រយោជន៍ដល់ខ្លួន ។ អ្នកឈ្មោះថា ចាតុរន្តោ ព្រោះជាធំទូទៅទាំង ៤ ទ្វីប អធិប្បាយថា ជាធំលើផែនដី មានមហាសមុទ្រទាំង ៤ ជាព្រំដែន និងព្រមដោយទ្វីបទាំង ៤ ។ អ្នកឈ្មោះថា មានជ័យជំនះទាំងអស់ ព្រោះឈ្នះសត្រូវដែលមានការជំទាស់ជាដើមក្នុងខាងក្នុង និងឈ្នះព្រះរាជាទាំងពួងក្នុងខាងក្រៅ ។ បទថា ដល់ភាពជាអ្នកមាំមួនក្នុងជនបទ គឺ ដល់សេចក្ដីរឹងមាំ គឺ ជាថាវរៈក្នុងជនបទ

អ្នកណាៗ មិនអាចធ្វើឲ្យញាប់ញ័របាន ។ មួយទៀត ជនបទដល់ភាព ជាថាវរៈក្នុងទីនោះៗ មិនត្រូវខ្វល់ខ្វាយ ត្រេកអរតែក្នុងការងាររបស់ខ្លួន មិនញាប់ញ័រ មិនភ័យរន្ធត់ ។

បទថា **យ៉ាងណានេះ** ជានិបាត ។ សេចក្តីថា រតនៈទាំងនេះ របស់ស្តេចចក្រពត្តិនោះ មានអ្វីខ្លះ ។

ក្នុងបទថា **ចក្ករតន៍** ជាដើម ចក្រនោះផង ជារតន៍ ព្រោះអត្ថថា ធ្វើឲ្យកើតសេចក្តីត្រេកអរផង ហេតុនោះ ទើបឈ្មោះថា ចក្ករតន៍ ។ ក្នុងទីគ្រប់កន្លែងក៏មានន័យដូច្នេះ ។ ក៏ក្នុងរតន៍ទាំងនេះ ស្តេចចក្រពត្តិ រមែងទ្រង់ឈ្នះអ្នកដែលមិនឈ្នះដោយចក្ករតន៍ ស្តេចរមែងព្រះរាជដំណើរ ទៅតាមសប្បាយ ក្នុងព្រំដែនដែលព្រះអង្គទ្រង់ឈ្នះហើយ ដោយដំរីកែវ និងសេះកែវ រមែងទ្រង់រក្សាព្រំដែនដែលទ្រង់ឈ្នះហើយ ដោយបរិនាយក កែវ រមែងទ្រង់សោយឧបភោគសុខដោយរតន៍ដ៏សេស ។ គប្បីជ្រាប សេចក្តីសម្ពន្ធគ្នាដូច្នេះ គឺ ការញុំាងសេចក្តីព្យាយាមរបស់ស្តេចចក្រពត្តិ នោះ សម្រេចបរិបូណ៌ហើយដោយចក្ករតន៍ទី ១ ការប្រើអំណាចដោយ មន្ត សម្រេចបរិបូណ៌ហើយដោយរតន៍ចុងក្រោយ ការប្រើអំណាចដោយ **បភុ** (ភាពជាអ្នកធំក្រៃលែង) សម្រេចបរិបូណ៌ហើយដោយគហបតិកែវ ដំរីកែវ និងសេះកែវ ផលនៃការប្រើអំណាច ៣ យ៉ាង បរិបូណ៌ហើយ ដោយស្ត្រីកែវ និងកែវមណី ។ ស្តេចចក្រពត្តិទ្រង់សោយសេចក្តីសុខ

ដែលកើតចាកភោគសម្បត្តិ ដោយស្ត្រីកែវ និងកែវមណី ទ្រង់សោយសេចក្តីសុខ ដែលកើតចាកភាពជាធំ ដោយរតនទាំងឡាយដ៏សេស ។ មួយទៀត គប្បីជ្រាបដោយបែកចេញទៅទៀត ដូច្នេះ រតនៈ ៣ ដំបូង សម្រេចបានដោយអានុភាពនៃកម្មដែលកុសលមូល គឺ ការមិនប្រទូសរ៉ាយឲ្យកើតឡើង , រតនកណ្តាល សម្រេចបានដោយអានុភាពនៃកម្មដែលជាកុសលមូល គឺ សេចក្តីមិនលោភឲ្យកើតឡើង រតនមួយចុងបង្អស់ សម្រេចបានដោយអានុភាពនៃកម្មដែលជាកុសលមូល គឺ សេចក្តីមិនវង្វេងឲ្យកើតឡើង ។ ក្នុងទីនេះពោលត្រឹមតែសង្ខេបប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារគប្បីកាន់យកពីឧបទេសនៃរតនសូត្រ ក្នុងពោជ្ឈង្គសំយុត្ត ។

បទថា **មានចំនួន ១.០០០ ខាងមុខ** គឺ ច្រើនជាង ១,០០០ ។ បទថា អ្នកក្លាហាន គឺ អ្នកមិនខ្លាចក្រែងអ្នកណា ។ បទថា មានរូបរាងជាអ្នកអង់អាច គឺ មានរាងកាយដូចនឹងទេវបុត្រ ។ អាចារ្យពួកខ្លះពណ៌នាទុកដូច្នេះមុន ។

តែក្នុងទីនេះ មានសេចក្តីដូចតទៅនេះ ៖

អ្នកដែលក្លាហានជាទីបំផុត លោកហៅថា **វីរ** ។ អង្គរបស់អ្នកក្លាហាន ឈ្មោះថា **វីរង្គ** គឺ ហេតុនៃសេចក្តីក្លាហាន ។ អធិប្បាយថា ភាពជាអ្នកក្លៀវក្លា ។ រូបរាងដែលអង់អាចរបស់អ្នកទាំងនោះមានហើយ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា មានរូបរាងអង់អាច ។ អធិប្បាយ

ថា មានសរីរៈភាគដែលហ្វឹកហាត់យ៉ាងជំនាញ ។

បទថា **ញាំញីនូវទាហានរបស់សត្រូវ** មានអធិប្បាយថា បើពួកទាហានរបស់សត្រូវ គប្បីប្រឈមមុខគ្នា គេក៏អាចញាំញីបេញបាននូវសត្រូវនោះ ។ បទថា **ដោយធម៌** គឺ ដោយធម៌ គឺ សីល ៥ ដែលមានការមិនសម្លាប់សត្វជាដើម ។

ក្នុងបទនេះថា **ជាព្រះអរហន្តសម្មាសម្ពុទ្ធ** ជាអ្នកមានកិលេសជាគ្រឿងបិទបាំងបើកហើយក្នុងលោក មានសេចក្តីថា កាលសេចក្តីងងឹត គឺ កិលេសរួបរឹតដោយគ្រឿងរួបរឹត គឺ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ អវិជ្ជា និងទុច្ចរិត ៧ យ៉ាង ព្រះអង្គទ្រង់បានបើកដំបូលនោះក្នុងលោកបានហើយ ទ្រង់មានពន្លឺភ្លឺកើតហើយដោយទូទៅដល់ទីប្រថាប់ឈរព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា មានដំបូល គឺ កិលេសបើកហើយ ។ ក្នុងបទទាំងនោះ សេចក្តីដែលព្រះអង្គជាអ្នកគួរបូជា គប្បីជ្រាបថា លោកពោលទុកដោយបទទី ១ ហេតុនៃសេចក្តីដែលព្រះអង្គទ្រង់ជាអ្នកគួរបូជា ព្រោះហេតុដែលព្រះអង្គជាព្រះសម្មាសម្ពុទ្ធនោះ គប្បីជ្រាបថា លោកពោលទុកដោយបទទី ២ សេចក្តីដែលព្រះអង្គទ្រង់ជាអ្នកមានដំបូលដែលបើកហើយ ដែលជាហេតុនៃភាពជាព្រះពុទ្ធ គប្បីជ្រាបថា លោកពោលទុកដោយបទទី ៣ ។ មួយទៀត ព្រះអង្គទ្រង់ជាអ្នកប្រាសចាកវដ្តៈផង ប្រាសចាកដំបូលផង ព្រោះហេតុនោះ ព្រះអង្គទើប

ទ្រង់ព្រះនាមថា ប្រាសចាកវដ្ដៈ និងដំបូល ។ អធិប្បាយថា មិនមាន វដ្ដៈ និងមិនមានដំបូល ។ ព្រោះហេតុនោះ សម្រាប់ ២ បទដំបូងនេះឯង លោកទើបពោលទុកហេតុ ២ យ៉ាង នេះថា ព្រះអង្គទ្រង់ជាព្រះអរហន្ត ព្រោះមិនមានវដ្ដៈ ទ្រង់ជាព្រះសម្មាសម្ពុទ្ធៈ ព្រោះមិនមានដំបូល ។ មួយទៀត បទនេះ សេចក្ដីសម្រេចខាងដំបូងមានដោយវេសារជ្ជញ្ញាណទី ២ សេចក្ដីសម្រេចទី ២ មានបានដោយវេសារជ្ជញ្ញាណទី ១ សេចក្ដីសម្រេចទី ៣ មានដោយវេសាររជ្ជញ្ញាណទី ៣ និងទី ៤ ។ គប្បីជ្រាបទៀតថា ពាក្យដំបូងចន្ទុលបង្ហាញឲ្យឃើញធម្មចក្ខុ ពាក្យទី ២ ពុទ្ធចក្ខុ និងពាក្យដែល ៣ សមន្តចក្ខុ ។ ព្រាហ្មណ៍និយាយឲ្យកើតសេចក្ដីក្លាហានក្នុងមន្តទាំងឡាយដល់មាណពនោះ ដោយពាក្យនេះថា លោកជាអ្នកទទួលមន្ត ដូច្នេះ ។

សូម្បីមាណពនោះ ក៏ប្រាសចាកសេចក្ដីវង្វេងភ្លេចក្នុងលក្ខណៈនៃពាក្យនិយាយរបស់អាចារ្យនោះ មើលឃើញធ្លុះធ្លាយនូវពុទ្ធមន្ត ដូចថាកើតពន្លឺភ្លឺស្វាងតែមួយ ទើបពោលថា លោកដ៏ចម្រើន ជាយ៉ាងនោះ ។ មានសេចក្ដីថា លោកដ៏ចម្រើន លោកពោលយ៉ាងណា ខ្ញុំនឹងធ្វើដូច្នោះ ។ បទថា វឡវាវថមារុយ្ហ ប្រែថា ឡើងកាន់រថដែលទឹមដោយលា ។ ជ្រាបមកថា ព្រាហ្មណ៍ខ្លួនឯងត្រាច់ទៅដោយរថណា ក៏ឲ្យរថនោះឯងបញ្ជូនមាណពទៅ ។ បទថា មាណវកា គឺ ជាអន្តេវាសិករបស់ព្រាហ្មណ៍

ឈ្មោះបោក្ខរសាតិនុ៎ះឯង ។ ន័យថា ព្រាហ្មណ៍នោះ បានឲ្យសញ្ញាដល់ពួកអន្តេវាសិកថា ពួកលោកចូរទៅជាមួយនឹងអម្ពដ្ឋមាណពនោះ ។ បទថា **ទីកន្លែងចតយានមានត្រឹមណា** សេចក្តីថា គេអាចនឹងទៅបានដោយយានរហូតដល់ទីកន្លែងចតត្រឹមណា ។ បទថា **ក៏ចុះពីយាន** គឺគេទៅកាន់ទីជិតខ្លោងទ្វារ ដែលមិនមែនជាទីកន្លែងចតយាន ហើយក៏ចុះពីយាន ។

[១៤៤] បទថា **ក៏ដោយសម័យនោះឯង** គឺ អម្ពដ្ឋមាណពចូលទៅកាន់អារាមក្នុងសម័យណា ក្នុងសម័យនោះឯង គឺ ក្នុងវេលាថ្ងៃត្រង់ ។ សួរថា ភិក្ខុទាំងឡាយ ដើរចង្ក្រមក្នុងវេលានោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ដើម្បីនឹងបន្ទោបង់សេចក្តីងងុយងោកងក់ ដែលមានភោជនប្រណីតជាបច្ច័យ ។ ឬថា ភិក្ខុទាំងនោះបំពេញព្យាយាមក្នុងវេលាថ្ងៃ ។ ព្រោះថា ចិត្តរបស់ភិក្ខុដែលដើរចង្ក្រមក្រោយឆាន់ភត្តាហារហើយ ងូតទឹក ហាលខ្យល់ហើយ អង្គុយធ្វើសមណធម៌ ដូច្នោះ រមែងតម្កល់មាំ ។ បទថា **ភិក្ខុទាំងនោះនៅត្រង់ណា** សេចក្តីថា បានឮថា មាណពនោះគិតថា យើងនឹងមិនដើរក្រៅពីបរិវេណនេះ ទៅកាន់បរិវេណនោះ ដោយគិតថា ព្រះសមណគោតម ស្តេចប្រថាប់នៅក្នុងទីណា នឹងសួរមុនហើយចូលទៅគាល់ ទើបរមិលមើលដូចជាដំរីក្នុងព្រៃ ឃើញភិក្ខុទាំងឡាយអ្នកស្លៀកដណ្តប់សំពត់បង្សុកូល កំពុងដើរចង្ក្រមនៅលើទីចង្ក្រមធំ ទើបបានទៅកាន់

សម្នាក់របស់ភិក្ខុទាំងនោះ ។ លោកសំដៅដល់ហេតុនោះ ទើបបាន ពោលពាក្យនេះថា ភិក្ខុទាំងនោះ នៅត្រង់ណា ។ បទថា ឧបសង្កមិតុំ បានដល់ ដើម្បីនឹងឃើញ ។ សេចក្តីថា ជាអ្នកប្រាថ្នាដើម្បីនឹងជួប ។

បទថា **កាន់យកក្នុងកំណើតមានឈ្មោះបោះសំឡេង** គឺ កើតក្នុង ត្រកូលដែលប្រាកដច្បាស់ ។ បានឮថា ក្នុងកាលនោះ ដែលឈ្មោះថា ត្រកូលអម្ពដ្ឋៈ រាប់ជាត្រកូលប្រាកដច្បាស់ក្នុងជម្ពូទ្វីប ។ បទថា **មាន ឈ្មោះបោះសំឡេង** គឺ ប្រាកដច្បាស់ ដោយរូបសណ្ឋាន កំណើត មន្ត ត្រកូល និងអាវាសដ្ឋាន ។ បទថា **មិនធូន់** គឺ មិនជាការៈ សេចក្តីថា អ្នកណាមិនគប្បីអាចនឹងឲ្យអម្ពដ្ឋមាណពដឹងបាន ការសន្ទនាដោយរឿង រ៉ាវនឹងអម្ពដ្ឋមាណពនោះ របស់អ្នកនោះ គប្បីជាទីធូន់ចិត្ត តែសម្រាប់ ព្រះមានព្រះភាគ ទោះជាត្រូវមាណពដូចអម្ពដ្ឋៈនោះ សួរបញ្ហា រាប់រយ នាក់ក៏ដោយ រាប់ពាន់នាក់ក៏ដោយ ព្រះអង្គទ្រង់មិនមានសេចក្តីបង្អែបង្អង់ ក្នុងការឆ្លើយឡើយ ពួកភិក្ខុទាំងនោះសម្គាល់ដូច្នេះ ទើបគិតថា ការសន្ទនា ដោយរឿងរ៉ាវផ្សេងៗ មិនបានជាទីធូន់ចិត្តឡើយ ។

ពាក្យថា **វិហារ** លោកពោលសំដៅដល់ព្រះគន្ធកុដិ ។ បទថា **មិនប្រញាប់ប្រញាល់** គឺ មិនបង្ខំ សេចក្តីថា ដាក់ជើងចុះក្នុងទីល្មម សមគួរនឹងជើង ធ្វើវត្តហើយ មិនធ្វើឲ្យខ្សាច់ដែលចាក់កោយទុក រៀបរយ ស្មើហើយ ដូចនឹងក្រាលទុកដោយមុក្តា ស្ទឹកឈើ និងឈើ ដូចខ្សាច់

ឲ្យជារណ្តៅជាអណ្តូង ។ បទថា **របៀង** គឺ យ៉មុខ ។ បទថា គ្រហែម គឺ ធ្វើសំឡេងគ្រហែម ។ បទថា **សន្ទុះទ្វារ** គឺ សន្ទឹកទ្វារ ។ បទថា **ចូរគោះ** ពន្យល់សេចក្តីថា លោកចូរយកចុងក្រចកគោះត្រង់ទីជិតសោរតិចៗ ។ លោកអាចារ្យទាំងឡាយ កាលនឹងសម្តែងទំនៀមការគោះទ្វារ ទើបពោលថា បានជ្រាបថា ពួកអមនុស្ស រមែងគោះទ្វារខ្ពស់ពេក ពួកសត្វពស់គោះក្រោមពេក មនុស្សមិនគួរនឹងគោះដូច្នោះ គួរគោះត្រង់ទីកណ្តាលជិតរន្ធសោរ ។ បទថា **ព្រះមានព្រះភាគទ្រង់បើកទ្វារហើយ** សេចក្តីថា ព្រះមានព្រះភាគមិនបានទ្រង់ក្រោកទៅបើកទ្វារ ។ តែព្រះអង្គទ្រង់លាតព្រះហស្តចេញដោយត្រាស់ថា ចូរបើកចូលមកចុះ ។ គួរនឹងពោលថា លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បើកទ្វារដោយព្រះអង្គឯង ដោយត្រាស់ថា ព្រោះអ្នកទាំងឡាយ កាលឲ្យទាននៅជាវេលារាប់កោដិកប្បមិនមែនតិច មិនបានធ្វើកម្ម គឺ ការបើកទ្វារដោយដៃខ្លួនឯងឡើយ ក៏ទ្វារនោះ ដែលទឹកព្រះទ័យរបស់ព្រះមានព្រះភាគទ្រង់ឲ្យបើក ព្រោះហេតុអ្វី ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់បើកទ្វារឲ្យ ។

បទថា **ពួកគេរីករាយជាមួយព្រះមានព្រះភាគ** សេចក្តីថា ព្រះមានព្រះភាគកាលនឹងត្រាស់សួរពាក្យជាដើមថា សប្បាយរីករាយឬ ទ្រង់រីករាយនៅនឹងពួកមាណពទាំងនោះយ៉ាងណា សូម្បីពួកគេទាំងនោះ ក៏មានសេចក្តីរីករាយប្រព្រឹត្ត ទៅដោយទំនងដូចនឹងព្រះមានព្រះភាគយ៉ាងនោះ

គឺ ម្នាក់ៗ មានសេចក្ដីរីករាយរួមគ្នា គឺ ភាពតែមួយជាមួយគ្នា ដូចជាទឹកត្រជាក់រួមគ្នានិងទឹកក្ដៅដូច្នោះ ។ ពួកមាណពទាំងនោះ រីករាយដោយពាក្យយ៉ាងណាថា ព្រះគោតមដ៏ចម្រើន ព្រះអង្គទ្រង់នៅសប្បាយរីករាយឬ ព្រះអង្គទ្រង់ល្មមតាំងព្រះជន្មនៅបានឬ និងព្រះសាវកទាំងឡាយរបស់ព្រះគោតមដ៏ចម្រើន នៅមានអាពាធតិច មិនមានរោគភ័យបៀតបៀន រហ័សរហួន មានកម្លាំង និងការនៅជាសុខស្រួលល្អឬ ដូច្នេះជាដើម ពួកគេម្នាក់ៗ ក៏ពោលពាក្យនោះ ដែលជាទីតាំងនៃសេចក្ដីរីករាយ និងឲ្យរលឹកដល់គ្នា ដោយបរិយាយជាច្រើនយ៉ាងនេះថា ដែលឈ្មោះថា ជាទីតាំងនៃសេចក្ដីរីករាយ ព្រោះជាពាក្យដែលសមគួរនឹងរីករាយចិត្ត ដោយបង្កឲ្យកើតសេចក្ដីរីករាយ ពោលគឺ បីតិ និងបាមោជ្ជៈ និងឈ្មោះថា ជាទីតាំងនៃការឲ្យរលឹកដល់គ្នា ព្រោះជាពាក្យគួររលឹកដោយគួរដល់នឹងឲ្យគ្នានិងគ្នា រលឹកដល់អស់កាលសូម្បីយូរបាន និងប្រព្រឹត្តទៅរហូតអស់កាលជានិច្ច ព្រោះជាពាក្យដែលពីរោះដោយអត្ថ និងព្យញ្ជនៈ មួយទៀត ឈ្មោះថា ជាពាក្យជាទីតាំងនៃសេចក្ដីរីករាយ ព្រោះជាសុខដល់អ្នកស្ដាប់ និងឈ្មោះថា ជាទីតាំងនៃការឲ្យរលឹកដល់គ្នា ព្រោះជាសុខដល់អ្នករំលឹកដល់ មួយទៀត ឈ្មោះថា ពាក្យជាទីតាំងនៃសេចក្ដីរីករាយ ព្រោះមានព្យញ្ជនៈបរិសុទ្ធិ ឈ្មោះថា ពាក្យជាទីតាំងនៃការឲ្យរលឹកដល់គ្នា ព្រោះមានអត្ថដែលបរិសុទ្ធិ ដូច្នេះហើយគ្រាពោលចប់ គឺ

ពោលសម្រេចអស់ហើយ ទើបអង្គុយក្នុងទីមួយដ៏សមគួរ ។

[១៤៥] បទថា អម្ពដ្ឋោ បង មាណវោ មានសេចក្ដីថា ដូចបាន ស្ដាប់មកថា មាណពនោះ មិនធ្វើសូម្បីត្រឹមតែថា សេចក្ដីជ្រះថ្លានៃចិត្ត ក្នុងរូបសម្បត្តិរបស់ព្រះមានព្រះភាគ គិតថា យើងនឹងរុករានព្រះទសពល ទើបស្រាយសំពត់ដែលរុំទុកត្រង់ពោះ យកមកបណ្ដោងទុកត្រង់ក យកដៃ ម្ខាងចាប់ជាយសំពត់ទុក ឡើងទៅកាន់ទីចង្ក្រម ពេលខ្លះក៏បើកដៃ ពេលខ្លះ ក៏បើកពោះ ពេលខ្លះក៏បើកខ្នងឲ្យឃើញ ពេលខ្លះក៏គ្រវីដៃ ពេលខ្លះក៏ ញាក់ចិញ្ចើម បានពោលពាក្យចំអកឡកឡឺយ ដែលធ្វើឲ្យនឹកដល់ការប្រព្រឹត្ត គួរអៀនខ្មាស មានសភាពដូច្នេះថា ព្រះគោតម លោកនៅមានធាតុ ប្រព្រឹត្តស្មើជានិច្ចឬ លោកមិនលំបាកដោយភិក្ខាហារឬ ក៏ឯអាការដែល មិនលំបាកនុ៎ះឯង នៅប្រាកដដល់លោក ដែលតាមពិតអវយវៈតូចធំរបស់ លោក ជាទីតាំងនៃសេចក្ដីជ្រះថ្លា ក្នុងទីកន្លែងដែលលោកទៅហើយ ជន ជាច្រើនទាំងនោះ មានសេចក្ដីរាប់អានច្រើនកើតឡើងដោយគិតថា លោក ជាព្រះរាជាបព្វជិត និងលោកជាព្រះពុទ្ធ ម្នាក់ៗ ក៏ថ្វាយអាហារដែល មានរសឆ្ងាញ់ប្រណីត ពួកលោក ចូរមើលផ្ទះរបស់លោក ហាក់បីដូចជា សាលាដែលស្អាតល្អ និងដូចជាទិព្វប្រាសាទ មើលគ្រែ មើលខ្នើយ កាលលោកនៅក្នុងស្ថានទីមានសភាពដូច្នេះ ការបំពេញសមណធម៌ រមែង ធ្វើបានលំបាក ។ ព្រោះហេតុនោះ លោកទើបពោលថា អម្ពដ្ឋមាណព

សូម្បីកំពុងដើរចង្ក្រម ក៏ពោលសាកានីយកថាណាមួយ ជាមួយព្រះមាន-ព្រះភាគដែលទ្រង់កំពុងគង់ សូម្បីខ្លួនឈរ ក៏នៅពោលសាកានីយកថាណាមួយ ជាមួយព្រះមានព្រះភាគដែលទ្រង់កំពុងគង់ ។

បទថា **គ្រានោះឯង ព្រះមានព្រះភាគ** សេចក្តីថា លំដាប់នោះព្រះមានព្រះភាគទ្រង់ត្រិះរិះថា មាណពនេះ ព្យាយាមនៅក្នុងទីមិនសមគួរ ដូចមនុស្សមានប្រាថ្នានឹងលូកដៃឈោងចាប់ភវគ្គព្រហ្ម ដូចអ្នកមានប្រាថ្នានឹងឈានជើងចេញដើរទៅកាន់នរកជាន់អវិចី ដូចមនុស្សមានប្រាថ្នានឹងឆ្លងមហាសមុទ្រ និងដូចមនុស្សមានបំណងនឹងឡើងទៅកាន់ភ្នំសិនេរុ ណ្ហើយចុះតថាគតនឹងល្បងដេញដោល សួរនឹងគេមើល ដូច្នេះហើយ ទើបបានត្រាស់ពាក្យនេះ ចំពោះអម្ពដ្ឋមាណព ។ បទថា អាចរិយបាចរិយេហិ ប្រែថា ជាមួយអាចារ្យ និងអាចារ្យរបស់អាចារ្យទាំងនោះ ។

## ពណ៌នា ការពោលបន្ទុះបង្អាប់ទី ១

ក្នុងពាក្យថា **កំពុងដើរក្តីនេះ** សេចក្តីពិត ព្រាហ្មណ៍សមគួរនឹងសន្ទនា ប្រាស្រ័យនឹងព្រាហ្មណ៍ដែលជាអាចារ្យ ក្នុងឥរិយាបថទាំង ៣ ។ តែមាណពនេះ ព្រោះហេតុដែលខ្លួនជាអ្នករឹងត្អឹងដោយមានះ កាលនឹងធ្វើការសន្ទនាគិត ថា យើងនឹងប្រើឥរិយាបថសូម្បីទាំង ៤ ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍កំពុងដេក គួរនិយាយជាមួយនឹង

ព្រាហ្មណ៍កំពុងដេកដូចគ្នា ។

ប្រាបថា តពីនោះ ព្រះមានព្រះភាគ បានត្រាស់ចំពោះមាណព នោះថា ម្នាលអម្ពដ្ឋៈ ការដែលអ្នកកំពុងដើរ និយាយជាមួយនឹងអាចារ្យ កំពុងដើរក្តី អ្នកកំពុងឈរនិយាយជាមួយនឹងអាចារ្យកំពុងឈរក្តី អ្នក កំពុងអង្គុយនិយាយជាមួយនឹងអាចារ្យកំពុងអង្គុយក្តី ប្រើបានក្នុងអ្នកគ្រប់ៗ អាចារ្យ តែអ្នកកំពុងដេកនិយាយជាមួយនឹងអាចារ្យកំពុងដេក អាចារ្យ របស់អ្នកជាគោ ឬថា ជាលាទៅហើយឬ ។

អម្ពដ្ឋមាណពនោះក្រោធ ទើបបានពោលពាក្យថា យេ ច ខោ តេភោ គោតម មុណ្ឌកា ដូច្នេះ ។ ក្នុងពាក្យនោះ ការដែលពោល នឹងអ្នកមានសីសៈត្រងោលថា មុណ្ឌា និងចំពោះសមណៈថា សមណា គួរជាង ។ តែមាណពនេះ កាលនឹងប្រមាថមើលងាយទើបពោលថា មុណ្ឌកា មនុស្សក្បាលត្រងោល , សមណកា មនុស្សជាសមណៈ ។ បទថា ឥព្ភា ប្រែថា គហបតី (ជាម្ចាស់ផ្ទះ) ។ បទថា កណ្ហា ប្រែថា អាក្រក់ សេចក្តីថា ជាមនុស្សខ្មៅ ។ បទថា **កើតអំពីព្រះបាទរបស់ព្រហ្ម** ក្នុងទីនេះ ព្រហ្ម លោកបំណងថាពន្ធុ ។ ព្រោះពួកព្រាហ្មណ៍នាំគ្នាហៅ ព្រហ្មនោះថា **បិតាមហ** (ជីតាបុព្វបុរស) ។ ជនទាំងឡាយជាអ្នកកើត អំពីជើងទាំង ២ ទើបឈ្មោះថា ជាត្រកូលកើតអំពីជើង ។ អធិប្បាយថា កើតពីខ្នងជើងរបស់ព្រហ្ម ។ ន័យថា មាណពនោះមានលទ្ធិដូច្នេះ គឺ

ពួកព្រាហ្មណ៍កើតពីមាត់របស់ព្រហ្ម ពួកក្សត្រិយ៍កើតពីទ្រូង ពួកវេស្សៈកើតពីផ្ចិត ពួកសូទ្រៈកើតពីក្បាលជង្គង់ ពួកសមណៈកើតពីខ្នងជើង ។ ក៏ឯមាណពនោះ កាលនឹងពោលយ៉ាងនេះ ក៏ពោលមិនបានចំពោះនរណាក៏ពិត តែការពិតគេពោលសំដៅយកថា យើងពោលសំដៅយកព្រះមានព្រះភាគប៉ុណ្ណោះ ។

លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ត្រិះរិះថា អម្ពដ្ឋមាណពនេះចាប់ផ្ដើមតាំងពីវេលាដែលខ្លួនមកហើយ កាលនិយាយនឹងតថាគត ក៏និយាយព្រោះអាស្រ័យមានះតែម្យ៉ាង មិនស្គាល់ប្រមាណរបស់ខ្លួន ដូចអ្នកចាប់អាសិរពិសត្រង់ក ដូចអ្នកក្រសោបកងភ្លើងទុក ដូចអ្នកស្ទាបអង្អែលដំរីចុះប្រេងត្រង់ក្ដុកដូច្នោះ ណ្ហើយចុះ តថាគតនឹងឲ្យគេយល់ទើបត្រាស់ថា អត្ថិកវតោ ខោ បន តេ អម្ពដ្ឋ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ មានសេចក្ដីថា សេចក្ដីត្រូវការ ពោលគឺ កិច្ចដែលនឹងត្រូវមកធ្វើរបស់ចិត្តនោះមាន ហេតុនោះ ចិត្តរបស់មាណពនោះទើបឈ្មោះថា មានសេចក្ដីត្រូវការ ។ ចិត្តមានសេចក្ដីត្រូវការរបស់គេមាន ហេតុនោះ គេទើបឈ្មោះថា មានចិត្តមានសេចក្ដីត្រូវការរបស់មាណពនោះ ។ សេចក្ដីថា លោកមានចិត្ត មានសេចក្ដីត្រូវការ ទើបបានមកក្នុងទីនេះ ។ ពាក្យថា ខោ បន ត្រឹមតែនិបាត ។ បទថា យាយេវ ខោបនត្ថាយ គឺ ដោយប្រយោជន៍យ៉ាងណា ។ បទថា អាគច្ចេយ្យាថ

សេចក្ដីថា ពួកអ្នកគប្បីមកកាន់សម្នាក់របស់តថាគត ឬរបស់អ្នកដទៃមួយម្នាល ។ ពាក្យនេះថា តមេវ អត្ថំ លោកពោលដោយអំណាចជាភេទប្រុស ។ បទថា **ពួកលោកគប្បីធ្វើទុកក្នុងចិត្ត** គឺ គប្បីធ្វើទុកក្នុងចិត្ត ។ អធិប្បាយថា អ្នក ដែលអាចារ្យប្រើឲ្យមកដោយករណីយកិច្ចរបស់ខ្លួន មិនបានប្រើឲ្យមកដើម្បីត្រូវការមើលងាយតថាគត ព្រោះដូច្នោះអ្នកចូរដាក់ចិត្តចំពោះកិច្ចយ៉ាងនោះចុះ ។ ព្រះមានព្រះភាគ ត្រាទ្រង់សម្ដែងវត្តរបស់អ្នកមកកាន់សម្នាក់របស់អ្នកដទៃ ដល់មាណពនោះយ៉ាងនេះហើយ ដើម្បីទ្រង់គ្របសង្កត់មានះ ទើបត្រាស់ពាក្យថា អវុសិតវាយេវ ខោ បន ជាដើម ។ បទនោះមានសេចក្ដីថា នៃអ្នកដ៏ចម្រើន ពួកអ្នកចូរមើល អម្ពដ្ឋមាណពនេះ រៀនមិនទាន់ចប់ មិនបានសម្រេចការសិក្សាជាអ្នករៀនសូត្រតិច តែមានមានះថា ខ្លួនរៀនចប់ហើយ គឺ សម្គាល់ខ្លួនថា យើងរៀនចប់ហើយ សម្រេចការសិក្សាហើយ ជាអ្នករៀនចេះចាំច្រើន ក៏ហេតុក្នុងការដែលអម្ពដ្ឋៈនោះ រាក់ទាក់ដោយពាក្យគ្រោតគ្រាតយ៉ាងនេះ និងមានអ្វីដទៃទៅក្រៅពីដែលខ្លួនមិនបានសម្រេចការសិក្សាមកនោះ ព្រោះដូច្នោះ បុគ្គលទាំងឡាយដែលមិនបានដឹងនោះឯង មិនបានសិក្សារៀនសូត្រ បានស្ដាប់មកតិចក្នុងត្រកូលរបស់អាចារ្យប៉ុណ្ណោះ ទើបរមែងពោលយ៉ាងនេះ ។

បទថា កុបិតោ ប្រែថា ក្រោធហើយ ។ បទថា អនត្តមនោ

ប្រែថា មានចិត្តមិនមែនជារបស់ខ្លួន (ទាស់ចិត្ត) ។

មានពាក្យសួរថា ក៏ព្រះមានព្រះភាគទ្រង់ជ្រាបថា គេក្រោធ ឬទ្រង់មិនជ្រាបហ្ន៎ ទើបបានត្រាស់យ៉ាងនោះ ។

ឆ្លើយថា ទ្រង់ជ្រាប ។

ព្រោះហេតុអ្វី ទ្រង់ជ្រាបហើយទើបត្រាស់ ។

ដើម្បីត្រូវការនឹងដកចេញនូវមានះ ។

ជាការពិត ព្រះមានព្រះភាគទ្រង់បានជ្រាបហើយថា មាណពនេះកាលតថាគតពោលយ៉ាងនេះ នឹងក្រោធ ហើយជេរពួកញាតិរបស់តថាគតពេលនោះ តថាគតនឹងលើកយកគោត្រដោយគោត្រ ត្រកូល និងប្រទេសដោយត្រកូល និងប្រទេសឡើងនិយាយ កាត់ទង់ គឺ មានះដែលគេលើកឡើងហើយ ប្រៀបដូចនឹងកវគ្គព្រហ្មត្រង់គល់ ហើយធ្វើឲ្យបាត់អស់ទៅដូចគ្រូពេទ្យឆ្លាត លាងជម្រះវត្ថុដែលជាទោស ហើយនាំយកទៅចោលដូច្នោះ ។ បទថា **ពោលទ្រគោះ** គឺ ពោលស៊ិកសៀត ។ បទថា **កាលនឹងពោលសង្កត់** គឺ ប្រមាថមើលងាយ ។

បទថា ចាបិតោ ភវិស្សតិ គឺ នឹងជាអ្នកឲ្យទោស ព្រោះជាអ្នកប្រទូសរ៉ាយជាដើម ។ បទថា **កាច** គឺ ប្រកបដោយសេចក្ដីក្រោធដែលអាស្រ័យមានះកើតឡើង ។ បទថា **គ្រោតគ្រាត** គឺ របុឹងរឹងរុស ។ បទថា **ស្រោល** គឺ ជាអ្នកមានចិត្តស្រោល ។ ពួកគេរមែងត្រេកអរខ្លះ

ប្រទូសរ៉ាយខ្លះ នឹងវត្ថុបន្តិចបន្តួច គឺ សោត់អណ្តែតទៅតាមអារម្មណ៍ រឿងបន្តិចបន្តួចដូចលលាដ៍ឃ្លោក អណ្តែតនៅលើផ្ទៃទឹកដូច្នោះ ។ បទថា រភសា មាត់ច្រើន គឺ ពេញចិត្តនិយាយច្រើន លោកពោលអំពីបំណងថា សម្រាប់ពួកសក្យៈ កាលហាមាត់ហើយ អ្នកដទៃក៏មិនមានឱកាសដែល នឹងនិយាយឡើយ ។ ពាក្យថា សមានា នេះ ជាវេវចនៈរបស់បទជំបូង គឺ សន្តា (ប្រែថាមាន) ។ បទថា **មិនមានសក្ការៈ** គឺ មិនធ្វើដោយអាការ ដែលល្អដល់ពួកព្រាហ្មណ៍ ។ បទថា **មិនគោរព** គឺ មិនធ្វើសេចក្តី គោរពក្នុងពួកព្រាហ្មណ៍ ។ បទថា **មិនរាប់អាន** គឺ មិនស្រឡាញ់ពេញ ចិត្ត ។ បទថា **មិនបូជា** គឺ មិនធ្វើការបូជាដល់ពួកព្រាហ្មណ៍ ដោយ កម្រងផ្កាឈើជាដើម ។ បទថា **មិនគោរពកោតក្រែង** គឺ មិនសម្តែង ការធ្វើសេចក្តីឱនលំទោន គឺ ការប្រព្រឹត្តបន្ទាបខ្លួនដោយការក្រាបថ្វាយ បង្គំជាដើម ។ បទថា តយិទំ កាត់បទជា តំ ឥទំ ប្រែថា (នេះនោះ) ។ បទថា យទិមេ សាក្យា មានសេចក្តីថា ពួកសក្យៈទាំងនេះ មិនសក្ការៈ ពួកព្រាហ្មណ៍ ។ល។ មិនកោតក្រែងពួកព្រាហ្មណ៍ ការមិនធ្វើសក្ការៈ ជាដើម របស់ពួកសក្យៈទាំងនោះគ្រប់យ៉ាង មិនសមគួរ គឺ មិនសមរម្យ ឡើយ ។

## ពណ៌នា ការពោលបន្ទុះបង្អាប់ទី ២

[១៤៦] បទថា **នីចខ្ពស់** គឺ ប្រទូសរ៉ាយ ។

ពាក្យថា ឥធ ក្នុងពាក្យថា ឯកមិទាហំ នេះ ត្រឹមតែនិបាត ។ សេចក្តីថា សម័យមួយខ្ញុំព្រះអង្គ ។ បទថា សណ្ឋាគារ គឺ សាលាវិនិច្ឆ័យក្តីរបស់ព្រះរាជា ។ បទថា **ព្រះសក្យៈត្រកូលទាំងឡាយ** គឺ ព្រះរាជាដែលបានទទួលអភិសេកហើយ ។ បទថា **សក្យកុមារ** គឺ អ្នកនៅមិនទាន់បានទទួលអភិសេក ។ បទថា **លើអាសនៈដ៏ខ្ពស់** គឺ លើអាសនៈច្រើនប្រភេទ មានបល្ល័ង្ក តាំង ទីអង្គុយធ្វើដោយផ្តៅ បន្ទះក្តារ និងកម្រាលដែលស្អាតល្អជាដើម តាមសមគួរ ។ បទថា **កំពុងតែសើចលេង** គឺ សើចសំឡេងខ្លាំង ដោយអំណាចចំអកឡកឡឺយ ។ បទថា **ប្រឡែងគ្នាលេង** គឺ ធ្វើអាការមានការធ្វើត្រឹមតែញញឹមរីករាយ ការផ្ទាត់ម្រាមដៃ និងការទះដៃជាដើម ។ បទថា មមញ្ញេវ មញ្ញេ សេចក្តីថា ខ្ញុំព្រះអង្គសម្គាល់យ៉ាងនេះថា ពួកសក្យៈទាំងឡាយសើចចំអកឲ្យខ្ញុំព្រះអង្គតែម្នាក់ មិនមែនសើចចំអកដល់អ្នកដទៃទេ ។

សួរថា ក៏ពួកសក្យៈទាំងនោះ បានធ្វើយ៉ាងនោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ន័យថា ពួកសក្យៈទាំងនោះ ស្គាល់វង្សត្រកូលរបស់អម្ពដ្ឋៈ ។ និងក្នុងវេលានោះ អម្ពដ្ឋៈនេះ យកដៃម្ខាងចាប់ជាយសំពត់សាដកដែល

គេស្មៀក ធ្លាក់ជាយចុះមកដរាបដល់ចុងជើង សម្រេញធ្មឹងកចុះ ដើរមក ដូចអ្នកដែលស្រវឹងដោយសេចក្តីស្រវឹង គឺ មានះ ពេលនោះពួកសក្យៈ ទាំងឡាយ ទើបពោលថា នែអ្នកដ៏ចម្រើន ពួកលោកចូរមើលហេតុ នៃការមករបស់អម្ពដ្ឋៈជាកណ្ហាយនគោត្រ ដែលជាទាសៈរបស់ពួកយើង ទើបបានធ្វើដូច្នោះ ។ សូម្បីគេក៏ដឹងវង្សត្រកូលរបស់ខ្លួន ។ ព្រោះដូច្នោះ គេទើបក្រាបទូលថា ប្រហែលជាថា ពួកសក្យៈទាំងនោះ សើចចំអក ឲ្យខ្ញុំព្រះអង្គដោយពិត ។

បទថា **ដោយទីអង្គុយ** សេចក្តីថា មិនមានការគោរពអញ្ជើញ ឲ្យអង្គុយយ៉ាងនេះថា នេះអាសនៈលោក ចូរអង្គុយលើអាសនៈនេះ ដូច្នេះ ឡើយ ។ អ្នកណាៗ គេក៏មិនធ្វើដូច្នោះ ។

## ពណ៌នា ការពោលបន្តុះបង្អាប់ទី ៣

[១៤៧] បទថា ***សត្វចាបកបា្ស*** បានដល់ បក្សីតូចៗ ដែលអាស្រ័យ នៅតាមក្រហែងជុំដីក្នុងស្រែ ។ បទថា ***ក្នុងសំបុក*** គឺ ក្នុងទីជាទីនៅ អាស្រ័យ ។ បទថា ***ក៏និយាយទៅតាមចំណង់បាន*** គឺ តែងតែពោលតាមដែលខ្លួនប្រាថ្នា គឺ ខ្លួនត្រូវការវត្ថុណាៗ ក៏ពោលវត្ថុនោះៗ ចេញមក ហង្សក្តី សត្វក្រៀលក្តី សត្វក្ងោកក្តី មកហើយ ក៏មិនបាន ហាមគេថា អ្នកឯងរអ៊ូរទាំធ្វើអ្វី ។ បទថា ***ខឹងសំបារ*** គឺ ដែលខឹងទាស់ទែងដោយ អំណាចនៃសេចក្តីក្រោធ ។

កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ មាណពយល់ថា ព្រះសមណគោតមនេះ ធ្វើព្រះញាតិរបស់ព្រះអង្គឲ្យដូចជានឹងសត្វចាប-កបា្ស ធ្វើពួកយើងឲ្យស្មើនឹងហង្ស សត្វក្រៀល និងសត្វក្ងោក គ្រានេះគង់នឹងអស់មានះហើយ ទើបសម្តែងវណ្ណៈ ៤ ក្រលែងឡើងទៀត ។

## ការញាំញីដោយពាក្យថា កូនទាសី

[១៤៨] បទថា **ញាំញី** គឺ ជាន់ឈ្លី បានដល់ ធ្វើឲ្យអស់សេចក្តីរាប់អាន ។ បទថា **បើដូច្នោះ តថាគត** គឺ ក៏បើយ៉ាងនោះតថាគតត្រូវតែ ។ ន័យថា ពាក្យថា **បពិត្រព្រះគោតមដ៏ចម្រើន** ខ្ញុំព្រះអង្គជាកណ្ហាយនគោត្រ អម្ពដ្ឋៈ បានពោលចេញមក ដោយសំឡេងដ៏ខ្លាំងអស់ ៣ ដង ។

សួរថា គេពោលឡើងព្រោះហេតុអ្វី ? គេមិនដឹងឬថា ជាគោត្រដែលមិនបរិសុទ្ធិ ។

ឆ្លើយថា គេដឹងពិត តែសូម្បីដឹង ក៏សម្គាល់យកថា ហេតុនេះភពបិទបាំងទុក ហេតុនោះ ព្រះសមណគោតមនេះ ក៏ទ្រង់មិនឃើញព្រះមហាសមណៈកាលទ្រង់មិនឃើញ នឹងត្រាស់អ្វីហ្ន៎ ទើបបានពោលឡើង ព្រោះខ្លួនជាអ្នករឹងរូសដោយមានះ ។

បទថា មាតាបេត្តិកំ បានដល់ ជាសម្បត្តិរបស់មាតាបិតា ។ បទថា **ឈ្មោះ និងគោត្រ** គឺ ឈ្មោះ ដោយអំណាចនៃបញ្ញត្តិ គោត្រដោយអំណាចនៃប្រពៃណី ។ បទថា រឮកដល់ គឺ នឹកដល់ បានដល់ បន្តខ្សែទៅជរាបដល់ទីបំផុត របស់ត្រកូល ។ បទថា **ព្រះអង្គម្ចាស់** គឺ ចៅហ្វាយនាយ ។ បទថា **កូននៃទាសី** គឺ ជាកូនរបស់នាងទាសីក្នុងផ្ទះ

(ស្រីបម្រើ) ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបទ្រង់សម្តែងថា អ្នកជាមនុស្សបម្រើ នឹងគប្បីចូលទៅរកដោយប្រការណា ពួកសក្យៈឃើញអ្នកមិនចូលទៅរកដោយប្រការនោះ ទើបពោលចំអកឲ្យ ។

ខាងមុខពីនេះ ព្រះមានព្រះភាគ ទ្រង់ប្រកាសសេចក្តីដែលអម្ពដ្ឋៈនោះជាទាសៈ និងសេចក្តីដែលពួកសក្យៈជាចៅហ្វាយនាយហើយ កាលនឹងទ្រង់នាំវង្សត្រកូលរបស់ព្រះអង្គ និងរបស់អម្ពដ្ឋៈមក ទើបត្រាស់ព្រះតម្រាស់ថា សក្យា ខោ បន ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ធរេន្តិ គឺ តាំងទុក សេចក្តីថា ពួកសក្យៈនិយាយគ្នាថា ព្រះបាទឱក្កាក-រាជ ជាបុព្វបុរសរបស់យើង ។ បានស្តាប់មកថា ក្នុងវេលាដែលព្រះរាជានោះត្រាស់ រស្មីនឹងផ្សាយចេញមកពីព្រះឱស្ឋ ដូចគប់ភ្លើង ព្រោះដូច្នោះជនទាំងឡាយទើបថ្វាយព្រះនាមព្រះអង្គថា **ឱក្កាក** ។

[១៨៩] បទថា **ឲ្យចេញទៅហើយ** គឺ នាំទៅហើយ ។ ឥឡូវនេះព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងពួកសក្យៈទាំងនោះ ដោយអំណាចនៃឈ្មោះ ទើបត្រាស់ព្រះតម្រាស់ថា ឱក្កាមុខំ ជាដើម ។ ក្នុងរឿងនោះមានពាក្យដែលនឹងពោលតាមលំដាប់ ដូចតទៅនេះ ៖

ដូចបានស្តាប់មក ព្រះរាជឱរសរបស់ព្រះបាទមហាសម្មតិរាជ នៃកប្បដែលជាបឋមកប្ប ទ្រង់ព្រះនាមថា **រោជ** ព្រះរាជឱរសរបស់ព្រះបាទរោជៈ ទ្រង់ព្រះនាមថា **វរោជ** , ព្រះរាជឱរសរបស់ព្រះបាទវរោជៈ

ទ្រង់ព្រះនាមថា **កល្យាណ** , ព្រះរាជឱរសរបស់ព្រះបាទកល្យាណៈ ទ្រង់ព្រះនាមថា **វរកល្យាណ** , ព្រះរាជឱរសរបស់ព្រះបាទវរកល្យាណៈ ទ្រង់ព្រះនាមថា **មន្ធាតុ** , ព្រះរាជឱរសរបស់ព្រះបាទមន្ធាតុ ទ្រង់ព្រះនាមថា **វរមន្ធាតុ** , ព្រះរាជឱរសរបស់ព្រះបាទវរមន្ធាតុ ទ្រង់ព្រះនាមថា **ឧបោសថ** , ព្រះរាជឱរសរបស់ព្រះបាទឧបោសថ ទ្រង់ព្រះនាមថា **វរ** , ព្រះរាជឱរសរបស់ព្រះបាទវរៈ ទ្រង់ព្រះនាមថា **ឧបវារ** , ព្រះរាជឱរសរបស់ព្រះបាទឧបវារៈ ទ្រង់ព្រះនាមថា **មឃទេវ** , ព្រះរាជឱរសរបស់ព្រះបាទមឃទេវៈ ដោយបន្តតាមលំដាប់មក ជាក្សត្រិយ៍ ៨៤.០០០ ព្រះអង្គ ។ ក្រោយពីក្សត្រិយ៍ទាំងនោះ មានវង្សត្រកូលរបស់ ព្រះបាទ **ឱក្កាក** ៣ ត្រកូល ។ ក្នុង ៣ ត្រកូលនោះ ព្រះបាទឱក្កាករាជទី ៣ ទ្រង់មានព្រះមហេសី ៥ ព្រះអង្គ គឺ ទ្រង់ព្រះនាមថា **ហត្ថា ចិត្តា ជន្តុ ជាលិនី** និង **វិសាខា** ។ សម្រាប់ព្រះមហេសីតែមួយព្រះអង្គៗ មានស្រ្តី ៥០០ ជាបរិវារ ។ ព្រះមហេសីអង្គធំបំផុត មានព្រះរាជឱរស ៤ ព្រះអង្គ គឺ ទ្រង់ព្រះនាមថា **ឱក្កាមុខ ករកណ្ឌុ ហត្ថិនិក សិនិបុរ** ។ មានព្រះរាជធីតា ៥ ព្រះអង្គ គឺ ទ្រង់ព្រះនាមថា **បិយា សុប្បិយា អានន្ទា វិជិតា វិជិតសេនា** ។ ព្រះអង្គប្រសូតិព្រះរាជបុត្រ និងព្រះរាជធីតា ៩ ព្រះអង្គ ហើយក៏សុគត ដោយប្រការដូច្នេះ ។

តមកព្រះរាជា បានទ្រង់នាំព្រះរាជធីតាអង្គដទៃ ដែលនៅក្រមុំ

ស្អាត មកអភិសេកទុកក្នុងតំណែងជាព្រះអគ្គមហេសី ។ ព្រះនាងប្រសូតិព្រះរាជឱរសទ្រង់ព្រះនាមថា **ជន្តុ** ។ ពេលនោះ ក្នុងថ្ងៃទី ៥ ព្រះនាងទើបប្រដាប់ប្រដាព្រះឱរសនោះហើយ ទូលសម្ដែងព្រះរាជា ។ ព្រះរាជាទ្រង់សប្បាយព្រះទ័យ បានព្រះរាជទានពរដល់ព្រះនាង ។ ព្រះនាងទ្រង់ប្រឹក្សានឹងព្រះញាតិទាំងឡាយហើយ ទើបទូលសូមរាជសម្បត្តិ ឲ្យដល់ព្រះរាជឱរស ។ ព្រះរាជាទ្រង់ស្ដីបន្ទោសថា នៃស្រីថោកទាប នាងចូរវិនាសទៅ នាងប្រាថ្នាអន្តរាយឲ្យដល់បុត្ររបស់យើង ។ ព្រះនាងពេលកំបាំងភ្នែកមនុស្ស ក៏ទូលឲ្យព្រះរាជាឲ្យទ្រង់ត្រេកអររឿយៗ ហើយទូលពាក្យជាដើមថា បពិត្រព្រះមហារាជ ដែលឈ្មោះថា ការត្រាស់ពាក្យកុហកមិនសមគួរទេ ហើយក៏ទូលសូមទ៉ុះឯង ។

លំដាប់នោះ ព្រះរាជា ទើបទ្រង់ត្រាស់បញ្ជាឲ្យហៅព្រះរាជឱរសទាំងឡាយមក ត្រាស់ថា នៃបាទាំងឡាយ យើងឃើញជន្តុកុមារប្អូនតូចរបស់ពួកអ្នក ទើបឲ្យពរដល់ម្ដាយរបស់គេឆាប់ពេក នាងក៏ចង់ឲ្យកូនរបស់នាងបានរាជសម្បត្តិវៀរពួកអ្នក ពួកអ្នកចង់បានដំរីមង្គល សេះមង្គល និងរថមង្គល មានប្រមាណប៉ុនណា ចូរកាន់យកដំរី សេះ និងរថ មានប្រមាណប៉ុណ្ណោះចេញទៅ ហើយគប្បីត្រឡប់មកគ្រងរាជសម្បត្តិ កាលយើងស្លាប់ទៅ ទើបបញ្ជូនចេញទៅព្រមនឹងអាមាត្យ ៨ នាក់ ។

រាជឱរសទាំងនោះ ស្រែកទួញយំមានប្រការផ្សេងៗ ក្រាបទូលថា

បពិត្រព្រះបិតា សូមព្រះអង្គទ្រង់មេត្តាលើកទោសដល់ពួកខ្ញុំព្រះអង្គ ផង ចុះ ហើយក៏ឲ្យព្រះរាជា និងនាងស្រីស្នំរបស់ព្រះរាជាលើកទោសឲ្យ ហើយក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងទៅព្រមជាមួយម្ចាស់បងផង ហើយទើបទូលលាព្រះរាជាចេញទៅ នាំយកព្រះនាងបងទៅ មានពួកសេនាទាំង ៤ ពួក ហែហមចេញចាកព្រះនគរ ។ ពួកមនុស្សទាំងឡាយជាច្រើននាក់នាំគ្នាគិតថា ព្រះរាជកុមារទាំងឡាយ នឹងមកគ្រងរាជសម្បត្តិ ក្នុងកាលព្រះរាជបិតាសុគតហើយ ពួកយើងនឹងទៅបម្រើព្រះអង្គ ក៏នាំគ្នាជាប់តាមទៅផង ។ ក្នុងថ្ងៃដំបូង ពួកសេនាបិកោគសាច់ ត្រង់ប្រមាណផ្លូវដីមួយយោជន៍ ក្នុងថ្ងៃទីពីរ ប្រមាណពីរយោជន៍ ក្នុងថ្ងៃទីបី ប្រមាណបីយោជន៍ ។ ពួករាជកុមារក៏ប្រឹក្សាគ្នាថា កងទ័ពនេះធំសម្បើម បើពួកយើងញាំញីព្រះរាជាក្នុងប្រទេសជិតខាងណាមួយហើយ ដណ្តើមយកជនបទ សូម្បីព្រះរាជានោះ ក៏គង់មិនអាចដណ្តើមបាន នឹងមានប្រយោជន៍អ្វីដោយការបៀតបៀនអ្នកដទៃ ជម្ពូទ្វីបនេះ នៅធំទូលាយ ពួកយើងនឹងនាំគ្នាសាងនគរក្នុងព្រៃ ថាហើយ ក៏ស្តេចធ្វើដំណើរឆ្ពោះព្រះភក្ត្រទៅកាន់ព្រៃហិមពាន្ត ស្វែងរកកន្លែងដែលនឹងតាំងព្រះនគរ ។

ក្នុងសម័យនោះ ព្រះពោធិសត្វរបស់យើង កើតក្នុងត្រកូលព្រាហ្មណ៍អ្នកមានទ្រព្យច្រើន ឈ្មោះថា **កបិលព្រាហ្មណ៍** ចេញបួសជាឥសី សាងបណ្ណសាលាអាស្រ័យនៅក្នុងដងព្រៃ មានដើមសាកៈ ជិតមាត់ស្រះបោក្ខ-

រណី ម្នាងព្រៃហិមពាន្ត ។ ន័យថា ព្រាហ្មណ៍នោះ ដឹងវិជ្ជាឈ្មោះ ភូម្មបាល ដែលជាគ្រឿងឲ្យអ្នកមើលឃើញគុណ និងទោសក្នុងខាងលើ អាកាស មានប្រមាណ ៨០ ហត្ថ និងខាងក្រោម សូម្បីក្នុងផែនដី ។ ក្នុងទីមួយកន្លែង មានគុម្ពស្មៅ និងវល្លិ៍កើតជាទក្ខិណាវដ្ដ (វិលស្តាំ) បែរមុខទៅផ្លូវទិសខាងកើត ។ រាជសីហ៍ និងខ្លាធំជាដើម រត់ដេញតាម ម្រឹគ និងជ្រូកមកក្តី ពស់ និងឆ្មា រត់ដេញតាមកង្កែប និងកណ្តុរមកក្តី មកដល់ទីនោះហើយ មិនអាចនឹងដេញតាមសត្វទាំងនោះតទៅបាន និង ត្រូវសត្វទាំងនោះគម្រាមឲ្យខ្លាច ត្រូវបែរត្រឡប់វិញពិតប្រាកដតែម្តង ។ ព្រាហ្មណ៍នោះជ្រាបថា នេះជាទីដ៏ប្រសើរក្នុងផែនដី ហើយទើបសាង បណ្ណសាលារបស់ខ្លួនក្នុងទីនោះ ។

តមក ព្រាហ្មណ៍នោះ ឃើញព្រះរាជកុមារទាំងនោះស្វែងរកទីកន្លែង តាំងនគរ ដើរមកកាន់ទីកន្លែងជាទីនៅរបស់ខ្លួន ហើយសួរ ជ្រាបការ ប្រព្រឹត្តទៅនោះហើយ កើតសេចក្តីអាណិតក្នុងព្រះរាជកុមារទាំងនោះ ទើប បានទូលថា នគរដែលសាងឡើងក្នុងកន្លែងតាំងបណ្ណសាលានេះ នឹងជានគរ ដ៏ប្រសើរក្នុងជម្ពូទ្វីប ក្នុងបណ្តាប្រុសដែលកើតក្នុងនគរ ម្នាក់ៗ នឹងអាច យកឈ្នះមនុស្ស ១០០ ក៏បាន ១.០០០ នាក់ក៏បាន ពួកព្រះអង្គចូរសាង នគរក្នុងទីនេះចុះ ចូរសាងព្រះរាជមណ្ឌបរបស់ព្រះរាជា ក្នុងទីតាំងបណ្ណ- សាលាចុះ ព្រោះមនុស្សឈរក្នុងទីនេះ ទោះបីជាកូនចណ្ឌាល ក៏នឹងជាអ្នក

ប្រសើរក្រៃលែង ដោយកម្លាំងរបស់ស្តេចចក្រពត្តិ ។ ពួកព្រះរាជកុមារទើបសួរថា នេះជាទីអាស្រ័យរបស់លោកម្ចាស់មិនមែនឬ ។ ពួកលោកកុំគិតថា ជាទីនៅអាស្រ័យរបស់យើង ចូរសាងនគរ ឲ្យបណ្ណសាលារបស់យើងទុកម្ខាង ហើយតាំងឈ្មោះថា **កបិលភស្តុ** ។ ពួករាជកុមារទាំងនោះធ្វើដូច្នោះ ហើយនាំគ្នាអាស្រ័យនៅក្នុងទីនោះ ។

អាមាត្យទាំង ៨ នាក់ គិតថា ព្រះរាជឱរសទាំងនេះ ចម្រើនវ័យហើយ បើព្រះរាជបិតារបស់ពួកគេ គប្បីនៅក្នុងទីជិត ព្រះអង្គគប្បីទ្រង់ធ្វើអាវាហវិវាហមង្គលឲ្យ តែឥឡូវនេះជាការៈរបស់ពួកយើងហើយ ពួកយើងមើលមិនឃើញធីតាក្សត្រិយ៍ ដូចនឹងពួកយើង ទាំងមើលមិនឃើញកុមារក្សត្រិយ៍ដូចបងប្អូន កូនរបស់ពួកយើងដែលកើតឡើង ព្រោះនៅរួមនឹងអ្នកដែលមិនស្មើគ្នា ចាត់ថា ជាអ្នកមិនបរិសុទ្ធិ ផ្នែកខាងមាតា ឬផ្នែកខាងបិតា សូម្បីការផ្សេងគ្នានៃជាតិ ព្រោះដូច្នោះ ពួកយើងទើបពេញចិត្តការនៅរួមជាមួយបងប្អូនប៉ុណ្ណោះ ព្រោះខ្លាចការផ្សេងគ្នានៃជាតិ ទើបតាំងព្រះជេដ្ឋភគិនីទុកក្នុងតំណែងជាមាតា ម្នាក់ៗ ក៏សម្រេចការនៅរួមគ្នានឹងបងប្អូនដ៏សេស ។

កាលព្រះរាជឱរសទាំងនោះចម្រើនដោយបុត្រ និងធីតា តែក្នុងសម័យតមកព្រះជេដ្ឋភគិនីកើតជារោគឃ្លង់ ។ សាច់ខ្លួនដូចគ្នានឹងផ្កាកោវិឡារ ។ ព្រះរាជកុមារទាំងឡាយគិតថា កាលពួកយើងធ្វើការអង្គុយ

ការដេក និងការបរិភោគជាដើម រួមគ្នានឹងព្រះជេដ្ឋកគិនីនេះ រោគនេះក៏នឹងធូងបាន ថ្ងៃមួយទើបធ្វើដូចជាថា ដើរទៅលេងកីឡាក្នុងសួន ឲ្យព្រះជេដ្ឋកគិនីនោះ ឡើងអង្គុយលើយាន ហើយចូលទៅកាន់ព្រៃ បង្គាប់ឲ្យជីកស្រះបោក្ខរណីក្នុងផែនដី ដោយសង្ខេបថា ជាផ្ទះ ឲ្យព្រះនាងចូលទៅក្នុងទីនោះ ព្រមនឹងរបស់ទំពារ និងរបស់បរិភោគ ប្រក់ខាងលើ ដាក់ដីស្រួយចុះទៅ ហើយនាំគ្នាត្រឡប់មក ។

ក្នុងសម័យនោះ ព្រះបាទក្រុងពារាណសីទ្រង់ព្រះនាមថា **រាម** ទ្រង់មានរោគឃ្លង់ ពួកស្រីស្នំ និងពួកអ្នកសម្តែងល្ខោន នាំគ្នារង្កៀសព្រោះសេចក្តីសង្វេគក្នុងចិត្តនោះ ទើបទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ ព្រះរាជឱរសច្បងស្តេចចូលព្រៃ ទ្រង់សោយឫសឈើ ក្នុងព្រៃក្នុងទីនោះ ក្នុងវេលាមិនយូរប៉ុន្មានក៏បាត់ព្រះរោគ មានពណ៌ សម្បុរដូចជាមាស ស្តេចត្រាច់ទៅតាមផ្លូវឯណោះខ្លះ ផ្លូវឯណោះខ្លះ ទតឃើញដើមឈើមានប្រហោងធំ ទ្រង់កាប់ចាំងទីដែលទំនេរមានប្រមាណ ១៦ ហត្ថ ក្នុងផ្ទៃខាងក្នុងនៃដើមឈើនោះ ធ្វើទ្វារ និងបង្អួច ចងជណ្តើរទុក ប្រថាប់នៅក្នុងទីនោះ ។ ព្រះអង្គទ្រង់បង្កាត់ភ្លើងទុកក្នុងត្រឡោកត្រងរងើក ពេលយប់ ទ្រង់ស្តាប់សំឡេងស្រែករបស់ពួកសត្វ មានម្រឹគ និងជ្រូកជាដើម ផ្ទំលក់ទៅ ។ ព្រះអង្គទ្រង់សង្កេតថា ក្នុងទីឯណោះរាជសីហ៍ស្រែក ក្នុងទីឯណោះខ្លាធំស្រែក លុះភ្លឺឡើង ស្តេចក៏ទៅទីនោះ ទ្រង់រើសយកសាច់ដែលជាសំណល់

មកដុតសោយ ។

តមកថ្ងៃមួយ ក្នុងពេលជិតភ្លឺ កាលព្រះអង្គទ្រង់បន្ដាត់ភ្លើង ក្រោកឡើងហើយប្រថាប់ ខ្លាធំដើរមក ព្រោះធុំក្លិនរបស់ព្រះរាជធីតា ទើបកកាយដីខ្ទាត់ខ្ទាយក្នុងទីនោះ ធ្វើជាប្រហោងដាក់ទុកត្រង់ញកក្នុំ ។ ព្រះនាងទតឃើញខ្លាធំតាមប្រហោងនោះ ទ្រង់ខ្លាច ទើបបញ្ចេញសំឡេងស្រែកឮយ៉ាងខ្លាំង ។ ព្រះបាទក្រុងពារាណសី ទ្រង់ស្តាប់សំឡេងនោះ ទ្រង់សម្គាល់បានថា នេះជាសំឡេងស្ត្រី ទើបស្តេចទៅក្នុងទីនោះអំពីព្រឹកតែម្តង ត្រាស់សួរថា អ្នកណានៅក្នុងទីនេះ ។ ព្រះនាងឆ្លើយថា មនុស្សស្រីលោក ។ នាងមានជាតិជាអ្វី ។ ខ្ញុំជាធីតារបស់ព្រះបាទឱក្កាកមហារាជ ។ នាងចូរចេញមកចុះ ។ មិនអាចចេញទៅបានទេលោក ។ ព្រោះហេតុអ្វី ។ ខ្ញុំមានរោគសើស្បែក ។ ព្រះបាទក្រុងពារាណសី ត្រាស់សួរការមកគ្រប់ប្រការហើយ ឲ្យព្រះនាងដែលមិនព្រមចេញមក ព្រោះខត្តិយមានះ ទ្រង់ជ្រាបភាពជាក្សត្រិយ៍របស់ខ្លួនថា សូម្បីយើងក៏ជាក្សត្រិយ៍ ទើបទ្រង់ដាក់ជណ្តើរចុះទៅ ទ្រង់ទាញឡើងមក នាំទៅកាន់ទីប្រថាប់របស់ព្រះអង្គ ព្រះរាជទានថ្នាំ ដែលព្រះអង្គទ្រង់សោយឯងនុ៎ះឯង តមកមិនយូរ ទ្រង់ធ្វើឲ្យព្រះនាងបាត់ព្រះរោគ មានពណ៌សម្បុរដូចជាមាស ទើបទ្រង់នៅរួមនឹងព្រះនាង ។ ព្រោះការនៅរួមគ្រាដំបូងនុ៎ះឯង ព្រះនាងក៏ទ្រង់គភ៌ ប្រសូតិព្រះរាជឱរស ២ ព្រះអង្គ ហើយក៏ប្រសូតិទៀតដល់ ១៦ ដង យ៉ាងនេះ គឺ

ម្តងពីរៗ ដោយប្រការដូច្នេះ ។ ទើបមានបងប្អូនដល់ ៣២ ព្រះអង្គ ។ ព្រះរាជបិតា ក៏ទ្រង់ឲ្យព្រះរាជឱរសទាំងនោះដែលចម្រើនវ័យហើយ សិក្សាសិល្បសាស្ត្រគ្រប់ប្រភេទ ។

តមកថ្ងៃមួយ ព្រានព្រៃអ្នកនៅក្នុងនគររបស់ព្រះបាទរាមៈម្នាក់ ត្រាច់ស្វែងរកកែវនៅត្រង់ភ្នំ ឃើញព្រះរាជាហើយ ចាំបាន ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំចាំព្រះអង្គបាន ។ ពេលនោះព្រះរាជាទើបត្រាស់សួរការប្រព្រឹត្តទៅគ្រប់ប្រការ ។ ក្នុងខណៈនោះឯងពួកក្មេងទាំងឡាយនោះក៏នាំគ្នាមក ។ ព្រានព្រៃឃើញពួកគេហើយ ទូលសួរថា ក្មេងទាំងនេះជាកូនអ្នកណា ។ កាលព្រះរាជា ត្រាស់ថា កូនរបស់យើងហ្នឹងឯង គេទើបទូលសួរដល់វង្សត្រកូល ចំណែកមាតារបស់ក្មេងទាំងនោះ គិតថា ឥឡូវនេះ យើងបានរង្វាន់ហើយ ទើបទៅកាន់នគរក្រាបទូលចំពោះព្រះរាជា ព្រះរាជាទ្រង់ត្រិះរិះថា យើងនឹងទូលយាងស្តេចព្រះរាជបិតាមក ទើបស្តេចទៅក្នុងទីនោះ ព្រមនឹងសេនា ៤ ពួក ថ្វាយបង្គំព្រះរាជបិតា ហើយទូលថា សូមព្រះអង្គ ចូរទ្រង់ទទួលរាជសម្បត្តិចុះព្រះអង្គ ។ ព្រះបាទក្រុងពារាណសីត្រាស់ថា កុំឡើយបាអើយ យើងនឹងមិនទៅក្នុងទីនោះ លោកចូរកាប់ឆ្ការដើមឈើនេះចេញ ហើយសាងនគរឲ្យដល់យើងក្នុងទីនេះឯង ។ ព្រះរាជាទ្រង់ធ្វើតាមព្រះរាជបញ្ជា ហើយតាំងឈ្មោះឲ្យ ២ ឈ្មោះ គឺ ឈ្មោះថា **កោលនគរ** ព្រោះហេតុដែលកាប់

ដើមក្រពៅចេញ ហើយសាងនគរនោះ ឡើង ១ , ឈ្មោះថា **ព្យគ្ឃបថ** ព្រោះសាងឡើងត្រង់ផ្លូវដើររបស់ខ្លាធំ ១ រួចស្រេចហើយ ថ្វាយបង្គំព្រះរាជបិតា បានស្តេចត្រឡប់មកព្រះនគរ ។

តមកព្រះរាជមាតា បានត្រាស់ចំពោះកុមារអ្នកចម្រើនវ័យហើយថា នែកូនៗ ទាំងឡាយ សក្យៈអ្នកនៅក្នុងក្រុងកបិលភស្តុ ជាស្តេចមាររបស់ពួកអ្នក ក៏ពួកធីតារបស់ស្តេចមាររបស់ពួកអ្នក មានការចាប់សក់មានសភាពដូច្នេះ មានការចាប់សំពត់មានសភាពដូច្នេះ នែកូនទាំងឡាយកាលណាពួកគេមកកំពង់ងូតទឹក កាលនោះអ្នកចូរទៅចាប់ធីតាណាដែលខ្លួនពេញចិត្តទុក ។ ពួកគេក៏នាំគ្នាទៅក្នុងទីនោះ កាលព្រះរាជធីតានាំគ្នាមកងូតទឹក កំពុងហាលសីសៈឲ្យស្ងួត ទើបចាប់រាជធីតាអ្នកដែលខ្លួនប្រាថ្នា ហើយប្រកាសឈ្មោះឲ្យជ្រាប ។ ព្រះបាទសក្យៈទាំងឡាយ ទ្រង់ស្តាប់ហើយ ត្រាស់ថា នែនាយ ស្រេចតែគេចុះ ពួកគេជាញាតិរបស់យើង ហើយក៏ទ្រង់ព្រងើយទៅ ។ នេះជារឿងកើតឡើងរបស់សក្យវង្សនិងកោលិយវង្ស ។ កាលសក្យវង្ស និងកោលិយវង្សទាំងនោះ ធ្វើការអាវាហមង្គល និងវិវាហមង្គលដល់គ្នានិងគ្នា វង្សត្រកូលបន្តគ្នាមកមិនដាច់ខ្សែឡើយ ដរាបមកដល់ពុទ្ធកាល ។ ក្នុងរឿងនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងសក្យវង្ស ទើបត្រាស់ព្រះតម្រាស់ថា ព្រះរាជបុត្រទាំងនោះ លុះចេញចាកដែន ទៅអាស្រ័យនៅត្រង់មាត់បោក្ខរណី ឈ្មោះ

**មហាសាក** ម្នាងហិមវន្តប្រទេស ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា សម្មន្តិ ប្រែថា អាស្រ័យនៅ ។ បទថា សក្យា វត ភោ មានសេចក្តីថា ពួកសក្យៈ សូម្បីនឹងចេញទៅនៅក្នុងព្រៃ មិនទម្លាយជាតិវង្ស ជាអ្នកអង់អាច គឺ មានកម្លាំងខ្លាំងក្លាដែលរក្សាវង្សត្រកូលទុកបាន ។ បទថា **តាំងអំពីកាលនោះមក** គឺ រាប់ពីថ្ងៃនោះជាដើមមក បានដល់ ចាប់ផ្តើមតាំងអំពីនោះមក ។ បទថា សោ ច នេសំ បុព្វបុរិសោ សេចក្តីថា ព្រះរាជាទ្រង់ព្រះនាមថា ឧក្កាកៈនោះ ជាបុព្វបុរសរបស់ព្រះរាជកុមារទាំងនោះ សូម្បីត្រឹមតែការផ្សេងគ្នានៃជាតិ-វង្ស ដោយអំណាចជាគហបតីរបស់សក្យៈទាំងនោះ ក៏មិនមាន ។ ព្រះ-មានព្រះភាគទ្រង់ប្រកាសសក្យវង្សឲ្យជ្រាបយ៉ាងនេះហើយ បន្ទាប់អំពីនេះទៅ កាលនឹងទ្រង់ប្រកាស **អម្ពដ្ឋវង្ស** ទើបត្រាស់ព្រះតម្រាស់ថា រញ្ញោ ខោ បន ជាដើម ។

បទថា **នាងទាសីបង្កើតកូន** ឈ្មោះ **កណ្ហ** គឺ ប្រសូតកូនមានសម្បុរខ្មៅ មានធ្មេញកើតឡើង មានសក់ ពុកមាត់ និងពុកចង្កាដុះឡើងតាំងពីនៅក្នុងផ្ទៃ ។ បទថា បព្យាហាសិ សេចក្តីថា កាលពួកមនុស្សក្នុងផ្ទះទាំងឡាយនាំគ្នាគេចចេញទៅ ព្រោះខ្លាចថា យក្ខកើតហើយ បិទទ្វារហើយឈរ នាយកណ្ហៈក៏ដើរទៅខាងឯណោះនិងខាងនេះ និយាយបញ្ចើរស្រែកសំឡេងឮខ្លាំងថា ម្នាលលោកចូរជួយលាងជម្រះខ្ញុំ ដូច្នេះជាដើម ។

[១៥០] បទថា **ពួកមាណពទាំងនោះ** គឺ បានក្រាប ទូលពាក្យនេះនឹងព្រះមានព្រះភាគ គឺ បានក្រាបទូលពាក្យនេះថា មា ភវំ ជាដើម ក៏ដើម្បីដោះពាក្យតិះដៀលរបស់ខ្លួន ។ ន័យថា ពួកមាណពទាំងនោះបានគិតយ៉ាងនេះថា អម្ពដ្ឋៈនេះ ជាសិស្សដ៏ធំរបស់អាចារ្យពួកយើង បើពួកយើងនឹងមិននិយាយខ្លះ ត្រឹមតែពាក្យពីរម៉ាត់ក្នុងឋានៈបែបនេះ អម្ពដ្ឋៈនេះ នឹងទម្លាយពួកយើងក្នុងសម្នាក់អាចារ្យរបស់ពួកយើង ពួកគេទើបបានពោលយ៉ាងនេះ ដើម្បីនឹងដោះពាក្យតិះដៀល តែពួកគេក៏នៅសង្ស័យដោយគិតថា អម្ពដ្ឋៈនេះ នឹងប្រាសចាកសេចក្តីស្រវឹង ។ ន័យថា អម្ពដ្ឋៈនេះ ក៏មិនជាទីស្រឡាញ់សូម្បីរបស់ពួកមាណពទាំងនោះ ព្រោះគេជាមនុស្សមានះ ។ បទថា **និយាយតែពាក្យពីរោះ** គឺ មានពាក្យនិយាយទន់ភ្លន់ ។ បទថា **ក្នុងពាក្យនោះ** គឺ ក្នុងពាក្យដែលជាប់នឹងវេទ ៣ ដែលខ្លួនរៀនមកហើយ ។ បទថា **ដើម្បីប្រឹក្សា** សេចក្តីថា ដើម្បីនឹងពោលប្រឹក្សាគ្នា គឺ ពោលដោះស្រាយបញ្ហាដែលសួរហើយ ។ ន័យមួយទៀតថា ដើម្បីនឹងប្រឹក្សា គឺ ដើម្បីនឹងពោលឲ្យក្រៃលែងក្នុងពាក្យនិយាយថា ជាបុត្រនៃទាសីនោះ ។

បទថា **លំដាប់នោះឯង ព្រះមានព្រះភាគ** មានសេចក្តីថា លំដាប់នោះព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា បើពួកមាណពទាំងនេះ ដែលអង្គុយក្នុងទីនេះ នឹងបញ្ចេញសំឡេងខ្លាំងឡើង ដោយទំនងនេះក៏នឹងនិយាយ

គ្នាមិនចេះចប់ ណ្ហើយចុះ តថាគតនឹងធ្វើឲ្យគេស្វាត់សំឡេង ហើយនិយាយនឹងអម្ពដ្ឋៈប៉ុណ្ណោះ ទើបបានត្រាស់ព្រះតម្រាស់នេះ ចំពោះពួកមាណពទាំងនោះ ។ បណ្ដាបទទាំងនោះ បទថា មន្តេថ្វា ប្រឹក្សា គឺ ពួកអ្នកចូរប្រឹក្សា ។ បទថា មយា សទ្ធឹ មន្តេតុ ចូរពោលជាមួយតថាគត ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ មាណពទាំងឡាយទើបគិតថា អម្ពដ្ឋមាណព ជាអ្នកដែលត្រូវព្រះមានព្រះភាគត្រាស់ថា ជាបុត្ររបស់នាងទាសីសូម្បីត្រឹមនោះ មិនអាចនឹងងើយសីសៈឡើងបាន ។ ដែលបានឈ្មោះថា ពូជអំបូរនេះឯង ដឹងបានលំបាក បើព្រះសមណគោតមនឹងពោលពាក្យណាៗ សូម្បីនឹងអ្នកដទៃថា អ្នកជាទាសៈ អ្នកណានឹងដើរក្តីជាមួយព្រះសមណគោតមនោះ អម្ពដ្ឋៈ ចូរដោះស្រាយសេចក្ដីដែលខ្លួនចងដោយខ្លួនឯងចុះ ដូច្នេះ កាលនឹងដោះខ្លួនចេញ ហើយទម្លាក់ទៅលើអម្ពដ្ឋៈតែម្នាក់ ទើបពោលពាក្យថា បពិត្រព្រះគោតមដ៏ចម្រើន អម្ពដ្ឋមាណពមានកំណើតល្អផង ជាដើម ។

[១៩១] បទថា **ប្រកបដោយធម៌** បានដល់ ប្រព្រឹត្តទៅដោយហេតុ គឺ មានឫសគល់ ។ បទថា **សូមបីមិនពេញចិត្ត ក៏ត្រូវព្យាករណ៍** សេចក្ដីថា ខ្លួនសូម្បីមិនប្រាថ្នា ក៏ត្រូវព្យាករណ៍ គឺ នឹងត្រូវវិសជ្ជនាដោយពិតប្រាកដ ។ បទថា អញ្ញេន វា អញ្ញំ បដិចរិស្សសិ សេចក្ដីថា អ្នកនឹងយកពាក្យមួយទៀតមកធ្វើឲ្យលុបពាក្យមួយទៀត គឺ នឹងយាំងទប់

បានដល់ នឹងបិទបាំង ។ ក៏អ្នកណាដែល គេសួរហើយយ៉ាងនេះថា លោកមានគោត្រអ្វី ? តែពោលថា ខ្ញុំដឹងវេទទាំង ៣ ជាដើម អ្នកនេះឈ្មោះថា យកពាក្យដទៃមកធ្វើឲ្យលុបពាក្យមួយទៀត ។ បទថា បក្កមិស្សសិ វា សេចក្តីថា ទាំងអ្នកដែលដឹងនូវបញ្ហាដែលគេសួរហើយ ត្រឡប់ក្រោកចាកអាសនៈ ចេញទៅ ព្រោះមិនចង់នឹងឆ្លើយឬ ។ បទថា **អម្ពដ្ឋៈបានអង្គុយស្ងៀម** សេចក្តីថា អម្ពដ្ឋៈគិតថា ព្រះសមណគោតមមានព្រះបំណងនឹងឲ្យយើងទូលថា ជាកូននាងទាសីនោះឯងតែម្តង កាលយើងទូលដោយខ្លួនឯង ឈ្មោះថា ទាសៈ រមែងកើតឡើងពិតប្រាកដ តែព្រះសមណគោតមនេះជំទាស់ត្រឹមតែ ២-៣ ដង រួចហើយក៏នឹងទ្រង់នៅដោយតុណ្ហីភាព ពេលនោះ យើងក៏បំភ្លេចពាក្យនេះទៅ ដូច្នេះហើយ ទើបនៅស្ងៀម ។

[១៥២] ពេជ្រមាននៅត្រង់បាតដៃរបស់យក្ខនោះ ហេតុនោះ យក្ខនោះ ទើបឈ្មោះថា **វជិរបាណិ** ។ ពាក្យថា **យក្ស** គប្បីជ្រាបថា មិនមែនយក្សធម្មតា គឺ ជាស្តេចសក្កទេវរាជ ។ បទថា **របស់ក្តៅ** គឺ មានវណ្ណៈជាភ្លើង ។ បទថា សម្បជ្ជលិតំ ប្រែថា ឆេះសន្ធោសន្ធៅ ។ បទថា សំជោតិភូតំ មានពន្លឺដោយជុំវិញ សេចក្តីថា មានអណ្តាតភ្លើងជាប់តគ្នាតែមួយ ។ បទថា **ឈរនៅ** សេចក្តីថា យក្ខនោះនិម្មិតរូបរាងចម្លែក យ៉ាងនេះគឺ សីសៈធំ ចង្កូមដូចគ្នានឹងមើមស្លែស្រស់ ភ្នែក

និងប្រមុះជាដើម មើលគួរខ្លាច ឈរនៅ ។ សួរថា ក៏យក្ខនេះមក ព្រោះហេតុអ្វី ។ ឆ្លើយថា មកដើម្បីនឹងឲ្យអម្ពដ្ឋៈលះបង់ទិដ្ឋិចេញ ។

មួយទៀត យក្ខនេះមកដោយគិតថា កាលព្រះមានព្រះភាគទ្រង់ ដល់ភាពជាអ្នកខ្វល់ខ្វាយតិច កាលទ្រង់សម្ដែងព្រះធម៌ទេសនាយ៉ាងនេះ ថា ក៏តថាគតនេះឯងទោះជាសម្ដែងធម៌បាន តែអ្នកដទៃគេមិនដឹងទូទៅ ដល់ធម៌របស់តថាគតទេ ស្ដេចសក្កៈព្រមនឹងស្ដេចមហាព្រហ្ម ទើបស្ដេច មក បានទ្រង់ធ្វើបដិញ្ញាថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គចូរ ទ្រង់សម្ដែងធម៌ចុះ ពួកអ្នកដែលមិនប្រព្រឹត្តទៅក្នុងអំណាចឃុំគ្រងរបស់ ព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងឲ្យប្រព្រឹត្តទៅឯង ធម្មចក្រចូរជារបស់ព្រះអង្គ អាណាចក្រចូរជារបស់ពួកខ្ញុំព្រះអង្គ ព្រោះដូច្នោះ ថ្ងៃនេះយើងនឹងគម្រាម ឲ្យអម្ពដ្ឋៈខ្លាច តក់ស្លុត ហើយឆ្លើយបញ្ហាឲ្យបាន ។

បទថា **ព្រះមានព្រះភាគទតព្រះនេត្រឃើញ ទាំងអម្ពដ្ឋៈក៏ឃើញ** មានសេចក្ដីថា ក៏បើយក្ខនោះសូម្បីអ្នកដទៃក៏ឃើញ ហេតុនោះក៏មិន សំខាន់ ជនទាំងឡាយគប្បីពោលថា ព្រះសមណគោតមនេះទ្រង់ជ្រាបថា អម្ពដ្ឋៈមិនព្រមនៅក្នុងព្រះតម្រាស់របស់ព្រះអង្គ ទើបនាំយក្ខមកសម្ដែង ពេលនោះ អម្ពដ្ឋៈទើបនិយាយឡើង ព្រោះសេចក្ដីខ្លាច ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ទតឃើញ និងអម្ពដ្ឋៈក៏ឃើញ ។

អម្ពដ្ឋៈគ្រាន់តែឃើញយក្ខនោះប៉ុណ្ណោះ ញើសក៏ហូរចេញពេញខ្លួន ។

ខាងក្នុងពោះក៏រំជើបរំជួលលាន់ឡើង ។ គេទើបគិតថា សូម្បីអ្នកដទៃតើគេឃើញដែរទេហ្ន៎ សម្លឹងមើលជុំវិញបណ្ដើរ ៗ ក៏មិនបានឃើញនរណាៗ សូម្បីទីងមានត្រឹមតែរោមប៉ះឡើង ។ លំដាប់នោះ គេទើបគិតថា ភ័យនេះកើតឡើងចំពោះអញ បើអញនិយាយថា យក្ខ ជនទាំងឡាយគប្បីពោលថា ក្អែករបស់លោកនុ៎ះឯង មានដែរមិនមែនឬ លោកម្នាក់ប៉ុណ្ណោះឃើញយក្ខ អម្ពដ្ឋៈពេលដំបូងមិនឃើញយក្ខ តែត្រូវព្រះ-សមណគោតមទ្រង់បៀតបៀនដោយវាទៈ ទើបឃើញយក្ខ បានសម្គាល់ថា ឥឡូវនេះ ក្នុងទីនេះ ទីពឹងយ៉ាងដទៃរបស់យើងមិនមាន ក្រៅពីព្រះសមណ-គោតម ប៉ុណ្ណោះ លំដាប់នោះឯង អម្ពដ្ឋមាណព ។ល។ បានពោលពាក្យនេះ ចំពោះព្រះមានព្រះភាគ ។

បទថា តាណំ គវេសី ប្រែថា ស្វែងរកទីពឹង ។ បទថា លេណំ គវេសី ប្រែថា ស្វែងរកទីពួន ។ បទថា សរណំ គវេសី ប្រែថា ស្វែងរកជាទីរលឹក ។ ក៏ក្នុងពាក្យទាំងនេះ ដែលឈ្មោះថា **ទីពឹង** ព្រោះរមែងការពារទុក គឺ រក្សាទុក ។ ដែលឈ្មោះថា **ទីពួន** ព្រោះជនទាំងឡាយរមែងពួនសម្ងំនៅក្នុងទីនេះ ។ ដែលឈ្មោះថា **សរណ** ព្រោះរមែងរលឹក សេចក្ដីថា រមែងបៀតបៀន គឺ កម្ចាត់បង់បាននូវភ័យ ។ បទថា **គេចូលទៅអង្គុយជិត** គឺ ចូលទៅអង្គុយលើទីអង្គុយខាងក្រោម ។ បទថា ព្រូតុ ប្រែថា ចូរពោល ។

## ពណ៌នា អំពីវង្សរបស់អម្ពដ្ឋមាណព

[១៥៣] បទថា **ជនបទទិសខាងត្បូង** គឺ ជនបទឋិតនៅទិសខាងត្បូងនៃទន្លេគង្គា ដែលប្រាកដឈ្មោះ ទក្ខិណាបថ ។ បានឮថា ក្នុងកាលនោះក្នុងប្រទេសទិសខាងត្បូងរបស់គង្គា មានព្រាហ្មណ៍ និងតាបសនៅច្រើន ។ អម្ពដ្ឋៈទៅក្នុងទីនោះ ធ្វើឲ្យតាបសម្នាក់ត្រេកអរ ដោយវត្តបដិបត្តិ ។ តាបសនោះ ឃើញឧបការៈរបស់គេ ទើបពោលថា នែបុរសដ៏ចម្រើន យើងនឹងឲ្យមន្តដល់លោក លោកប្រាថ្នាមន្តណា ចូររៀនមន្តនោះចុះ ។ គេទើបពោលថា បពិត្រអាចារ្យ កិច្ចដោយមន្តយ៉ាងដទៃរបស់ខ្ញុំមិនមាន អាវុធធ្វើបាបមិនបានដោយអានុភាពរបស់មន្តណា សូមលោកចូរឲ្យមន្តនោះដល់ខ្ញុំចុះ ។ តាបសនោះពោលថា នែអ្នកដ៏ចម្រើន ល្អហើយ ទើបបានឲ្យវិជ្ជាដែលធ្នូបាញ់មិនចេញ ឈ្មោះថា **អម្ពដ្ឋ** ។ គេរៀនយកវិជ្ជានោះហើយ សាកល្បងក្នុងទីនោះតែម្តងគិតថា ឥឡូវនេះ យើងនឹងឲ្យសេចក្តីស្រមើស្រមៃរបស់យើងពេញលេញនោះឯង ទើបកាន់យកភេទជាឥសី ទៅកាន់សម្នាក់របស់ព្រះបាទឱក្កាកៈ ។ ព្រោះដូច្នោះ លោកទើបពោលថា គាត់ទៅកាន់ទក្ខិណជនបទ បានរៀនន្ធូវព្រហ្មមន្តទាំងឡាយ ហើយចូលទៅគាល់ព្រះបាទឱក្កាករាជ ដូច្នេះ ។

ក្នុងបទនេះ បទថា **ព្រហ្មមន្ត** គឺ មន្តដ៏ប្រសើរ ព្រោះជាមន្តសម្បូរណ៍

ដោយអានុភាព ។ បទថា កោ នេវ រេ មយ្ហំ ទាសិបុត្តោ សេចក្ដីថា នែវើយ នរណាជាកូននាងទាសី (មកសូមកូនក្រមុំ) របស់យើងយ៉ាងនេះ ។ បទថា **ព្រះបាទឱក្កាករាជ** នោះ ទ្រង់មិនអាចនឹងបាញ់កូនសរទៅបាន សេចក្ដីថា ព្រះរាជានោះ ទាញខ្សែធ្នូ ព្រោះព្រះអង្គមានព្រះបំណងនឹងសម្លាប់ឥសីនោះ តែទ្រង់មិនអាចនឹងបាញ់ចេញបាន ទាំងទ្រង់មិនអាចនឹងដោះចេញបាននូវកូនសរនោះ ក្នុងនោះព្រះអង្គ ក៏មានព្រះសេទោហូរពេញព្រះវរកាយ ប្រថាប់ឈរញ័រខ្លួនដោយសេចក្ដីខ្លាច ។

[១៥៤] បទថា **ពួកអាមាត្យ** គឺ មហាមាត្យទាំងឡាយ ។ បទថា **រាជបរិស័ទ** គឺ ប្រជុំជនក្រៅអំពីនេះ ។ បទថា **អាមាត្យទាំងឡាយបានពោលពាក្យនេះ** សេចក្ដីថា ពួកគេគិតថា កាលព្រះរាជាទ្រង់ព្រះនាមថា **ទណ្ឌកី** ទ្រង់ប្រព្រឹត្តខុសក្នុងតាបស ឈ្មោះ កិសវច្ឆ ព្រំដែនទាំងអស់វិនាសដោយភ្លៀងនៃអាវុធ ព្រះបាទនាឡិកេរៈ ទ្រង់ប្រព្រឹត្តខុសក្នុងតាបស ៥០០ នាក់ និងព្រះបាទអជ្ជុនៈ ទ្រង់ប្រព្រឹត្តខុសក្នុងអង្គីរសតាបស ជ្រែកចុះកាន់ផែនដីចូលទៅកាន់នរក ព្រោះសេចក្ដីខ្លាច ទើបបានពោលពាក្យនេះថា បពិត្រលោកដ៏ចម្រើន សូមសួស្ដីចូរមាន ជាដើម ។ កណ្ហតាបសអង្គុយស្ងៀម តពីនោះត្រូវគេសូមអង្វរដោយប្រការផ្សេងៗ ទើបពោលពាក្យជាដើមថា ព្រះរាជារបស់ពួកលោក លើកធ្នូបាញ់ឥសីដូចជាពួកយើងរាប់ថា ធ្វើកម្មធ្ងន់ ហើយទើបបានពោលពាក្យនេះថា សេចក្ដីសួស្ដីនឹង

មានចំពោះព្រះរាជា ដូច្នេះ ក្នុងខាងក្រោយ ។ បទថា **ទឹងធ្លាក់ចុះ** គឺ ទឹងបែកចេញ កណ្ហតាបសនោះគិតថា យើងទឹងឲ្យជនតក់ស្លុត ទើបបាន ពោលកុហកថា ផែនដីទឹងបែកចេញ បីដូចជាក្តាប់អង្កាម ។ សេចក្តីពិត អានុភាពនៃវិជ្ជារបស់កណ្ហតាបសនោះ មានត្រឹមតែបញ្ឈប់កូនសរបាន ប៉ុណ្ណោះ រមែងមិនប្រព្រឹត្តទៅយ៉ាងដទៃបាន ។ ក្នុងពាក្យទាំងឡាយ សូម្បីដទៃពីនេះ ក៏មានន័យទំនងដូចគ្នានេះឯង ។

បទថា បស្សាវោ ប្រែថា មានភោមក្រាបរាបហើយ សេចក្តីថា សូម្បីត្រឹមតែព្រឹភោម ក៏ទឹងមិនមានដល់គេ ។ ន័យថា កណ្ហតាបសឲ្យ ព្រះរាជាធ្វើបដិញ្ញាណហើយ ទើបបានពោលពាក្យនេះថា បើព្រះរាជាទឹង ព្រះរាជទានក្មេងស្រីនោះដល់យើង ដូច្នេះ ។ បទថា ***ព្រះរាជឲ្យកូនសរ ទុកដាក់លើកុមារហើយ*** សេចក្តីថា កាលតាបសនោះរាយមន្តថា សូម ឲ្យកូនសរចុះមក ព្រះរាជាក៏ឲ្យដាក់ចុះផ្ចិតរបស់កុមារ ។ បទថា ***បាន ព្រះរាជទានព្រះរាជធីតាហើយ*** គឺ ទ្រង់ជម្រះសីសៈធ្វើមិនឲ្យជាទាស គឺ ជាទេយ្យ ហើយព្រះរាជទានទៅ និងទ្រង់តាំងទុកក្នុងតំណែងដ៏ធំក្រៃលែង ។ ព្រះមានព្រះភាគ កាលទឹងទ្រង់ប្រកាសថា អម្ពដ្ឋៈជាញាតិរបស់សក្យៈ ទាំងឡាយមួយចំណែក ទើបបានត្រាស់ព្រះតម្រាស់នេះថា មា ខោ តុម្ហេ មាណវកា ដើម្បីទ្រង់ធ្វើឲ្យគេជួរចិត្ត ។ លំដាប់នោះ អម្ពដ្ឋៈដូចជា ត្រូវស្រោចដោយទឹក ១០០ ឆ្នាំង មានសេចក្តីខ្វល់ខ្វាយដែលរម្ងាប់ហើយ

បានជួរចិត្តហើយ ទើបគិតថា ព្រះសមណគោតមទ្រង់ត្រិះរិះថា នឹងឲ្យយើងរីករាយចិត្ត ទើបទ្រង់ធ្វើឲ្យយើងជាញាតិមួយចំណែក ន័យថា យើងជាក្សត្រិយ៍ ។

## ពណ៌នា ខត្តិយសេដ្ឋភាវ

[១៥៥-៦] លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ត្រិះរិះថា អម្ពដ្ឋៈនេះ ធ្វើសេចក្តីសម្គាល់ថា យើងជាក្សត្រិយ៍ មិនដឹងថា ខ្លួនមិនមែនក្សត្រិយ៍ ណ្ហើយចុះ តថាគតនឹងឲ្យគេដឹង កាលនឹងទ្រង់សម្តែងទេសនាក្រៃលែងឡើងទៅ ដើម្បីទ្រង់សម្តែងវង្សក្សត្រិយ៍ ទើបបានត្រាស់ព្រះតម្រាស់ថា ម្នាលអម្ពដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ជាដើម ។ បណ្តាបទទាំងនោះ បទថា ឥធ ប្រែថា ក្នុងលោកនេះ ។ បទថា **ក្នុងព្រាហ្មណ៍ទាំងឡាយ** គឺ ក្នុងរវាងពួកព្រាហ្មណ៍ ។ បទថា ទីអង្គុយឬទឹក គឺ ទីអង្គុយដ៏ល្អប្រសើរ ឬទឹកដ៏ល្អប្រសើរ ។ បទថា សទ្ធេ គឺ ក្នុងភត្តដែលគេធ្វើឧទ្ទិសឲ្យអ្នកស្លាប់ ។ បទថា ថាលិបាកេ គឺ ក្នុងភត្តក្នុងការរោរមង្គលជាដើម ។ បទថា យញ្ញេ គឺ ក្នុងភត្តដែលគេធ្វើទុកបូជាយ័ញ្ញ ។ បទថា បាហុនេ គឺ ក្នុងភត្តដែលគេធ្វើទុកដើម្បីភ្ញៀវទាំងឡាយ ឬថា ក្នុងភត្តដែលគេធ្វើទុកជាបណ្ណាការ ។ បទថា អបិនុស្ស គឺ សម្រាប់ឱរសក្សត្រិយ៍នោះ ខ្វះទេហ្ន៎ ។ បទថា អាវដំ វា អស្ស អនាវដំ វា គឺ ក្នុងស្រីក្រមុំត្រកូលព្រាហ្មណ៍ គប្បីមានការហាម ឬមិន

មានការហាម សេចក្តីថា ឱរសក្សត្រិយ៍នឹងគប្បីបានជាមួយនឹងក្មេងស្រីត្រកូលព្រាហ្មណ៍ ឬមិនគប្បីបាន ។ បទថា អនុបន្នោ សេចក្តីថា សម្បីមិនដល់វង្សក្សត្រិយ៍ គឺ មិនបរិសុទ្ធិ ។

**[១៥៧-៨]** បទថា ឥត្ថិយា វា ឥត្ថឹ ករិត្វា គឺ ស្វែងរកស្រីនិងស្រីឬ ។ បទថា កិស្មិញ្ចិទេវ បករណេ គឺ ក្នុងការធ្វើវត្ថុដែលមិនគួរធ្វើ ដែលជាទោសយ៉ាងណា ដែលសមគួរដល់ព្រាហ្មណ៍ទាំងឡាយ ។ បទថា **ដោយកញ្ចប់ផេះ** សេចក្តីថា យកផេះរោយលើសីរសៈ ។

**[១៥៩]** បទថា ជនេតស្មឹ គឺ ក្នុងពពួកជន សេចក្តីថា ក្នុងពួកប្រជុំជន ។ បទថា យេ គោត្តបដិសារិនោ សេចក្តីថា ក្នុងពពួកជនណាដើរអួតអាងក្នុងរឿងគោត្រថា ខ្ញុំជាគោតមគោត្រ ខ្ញុំជាកស្សបគោត្រ ក្នុងគេទាំងនោះ អ្នកដើរអួតអាងអំពីរឿងគោត្រក្នុងលោក ក្សត្រិយ៍ជាអ្នកប្រសើរ ។

**[១៦០-៦១]** បទថា អនុមតា មយា សេចក្តីថា គាថានេះ សនង្កុមារព្រហ្មសម្តែង ប្រៀបបាននឹងព្រះសព្វញ្ញុតញ្ញាណរបស់តថាគត ព្រោះដូច្នោះ តថាគតទើបព្រមទទួល ។

បឋមភាណវារ និដ្ឋិតា

# ពណ៌នា វិជ្ជាចរណកថា

[១៦២] គាថានេះ អម្ពដ្ឋៈបានឮបទនេះថា អ្នកសម្បូរណ៍ដោយវិជ្ជា និងចរណៈ ទើបគិតថា វេទ ៣ ឈ្មោះថា **វិជ្ជា** , សីល ៥ ឈ្មោះថា **ចរណ** ។ វិជ្ជា និងចរណៈនេះ របស់យើងក៏មាន ប្រសិនបើថា អ្នកសម្បូរណ៍ដោយវិជ្ជា និងចរណៈ ជាអ្នកប្រសើរបំផុត យើងនេះក៏រាប់ថាប្រសើរបំផុតបាន សូម្បីគេយល់ហើយ កាលនឹងទូលសួរដល់វិជ្ជា និងចរណៈ ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ក៏ចរណៈនោះដូចម្តេច ? វិជ្ជានោះដូចម្តេច ? ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះបំណងនឹងបដិសេធវិជ្ជា និងចរណៈ ដែលប្រកបដោយវាទៈប្រារព្ធជាតិជាដើម ដែលមាននៅក្នុងលទ្ធិរបស់ព្រាហ្មណ៍នោះ ហើយទ្រង់សម្តែងវិជ្ជា និងចរណៈដ៏ប្រសើរ ទើបត្រាស់ព្រះតម្រាស់ថា ន ខោ អម្ពដ្ឋ ជាដើម ដល់អម្ពដ្ឋៈនោះ ។

ក្នុងបទទាំងនោះ បទថា ជាតិវាទោ ប្រែថា វាទៈប្រារព្ធជាតិ សេចក្តីថា បានដល់ ពាក្យនិយាយជាដើមថា វត្ថុនេះគួរដល់ព្រាហ្មណ៍ប៉ុណ្ណោះ មិនគួរដល់សូទ្រៈទេ ។ ក្នុងទីគ្រប់កន្លែងក៏មានន័យនេះដែរ ។ បទថា ជាតិវាទវិនិពទ្ធា ប្រែថា អ្នក រវល់ក្នុងវាទៈប្រារព្ធជាតិ ។ ក្នុងទីគ្រប់កន្លែង ក៏មានន័យដូច្នេះដូចគ្នា ។

[១៦៣] លំដាប់នោះ អម្ពដ្ឋៈគិតថា យើងគិតថា ឥឡូវនេះពួកយើងនឹងជាប់នៅក្នុងទីណា ទីនោះព្រះសមណគោតមត្រឡប់គ្រវែងពួកយើងចេញទៅយ៉ាងឆ្ងាយ ដូចអ្នកបាចអង្កាមក្នុងខ្យល់ដ៏ខ្លាំង ក៏ពួកយើងមិនជាប់នៅក្នុងទីណា ព្រះសមណគោតមទ្រង់ទាញពួកយើងទៅក្នុងទីនោះ ការដល់ព្រមដោយវិជ្ជា និងចរណៈរបស់ពួកយើងនេះ សមគួរនឹងដឹងទេ ហើយទើបបានសួរដល់វិជ្ជា និងចរណៈទៀត ។ លំដាប់នោះ ព្រះមាន-ព្រះភាគ ដើម្បីនឹងសម្ដែងវិជ្ជា និងចរណៈ ចាប់ផ្ដើមតាំងអំពីការកើតឡើងដល់អម្ពដ្ឋៈនោះ ទើបត្រាស់ព្រះតម្រាស់ថា ន អម្ពដ្ឋ ជាតិវាទោ ជាដើម ។

ក៏ក្នុងទីនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ចែកសីល ៣ យ៉ាង សូម្បីដែលរាប់ក្នុងចរណៈ មិនត្រាស់បញ្ជាក់ថា នេះជាចរណៈរបស់ភិក្ខុនោះ តែត្រាស់បញ្ជាក់ដោយអំណាចនៃសីលតែម្យ៉ាងថា នេះជាសីលរបស់ភិក្ខុនោះ ។ សួរថា ព្រោះហេតុអ្វី ។ ព្រោះថា សីលណាៗ សូម្បីរបស់ភិក្ខុនោះក៏មាន ព្រោះដូច្នោះ កាលត្រាស់បញ្ជាក់ដោយអំណាចនៃចរណៈ ភិក្ខុគប្បីជាប់នៅក្នុងចរណៈនោះៗ ឯង ដោយគិតថា សូម្បីពួកយើងក៏ដល់ព្រមដោយចរណៈ តែចរណៈណាដែលភិក្ខុនោះ មិនធ្លាប់បានឃើញឡើយ សូម្បីការយល់សប្តិ កាលនឹងត្រាស់បញ្ជាក់ដោយអំណាចនៃចរណៈនោះឯង ទើបត្រាស់ព្រះតម្រាស់ថា ភិក្ខុរមែងចូលដល់ឈានទី ១

សម្បីសេចក្តីនេះ ក៏ជាចរណៈរបស់ភិក្ខុនោះ ។ល។ ភិក្ខុរមែងចូលដល់ឈានទី ៤ សម្បីចេសចក្តីនេះ ក៏ជាចរណៈរបស់ភិក្ខុនោះជាដើម ។ ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណោះ គឺ ព្រះអង្គត្រាស់បញ្ជាក់សម្បីដល់សមាបត្តិទាំង ៨ ថាជាចរណៈ , ចំណែកបញ្ញាសម្បីទាំង ៨ រាប់តាំងពីវិបស្សនាញាណទៅ ព្រះអង្គត្រាស់ថា ជាវិជ្ជា ។

## ចតុអបាយមុខកថា

បទថា អបាយមុខានិ ប្រែថា ប្រធាននៃសេចក្តីវិនាស ។ បទថា **អ្នកនៅមិនទាន់ត្រាស់ដឹង** គឺ មិនទាន់សម្រេច ឬថា មិនទាន់អាច ។ ក្នុងបទថា **កាន់យកគ្រឿងបរិក្ខារតាបស** នេះ បរិក្ខាររបស់តាបសមានឈើពួតភ្លើង កុណ្ឌីទឹក ម្ជុល និងថ្នាំងកន្ទុយ ចាមរីជាដើម ឈ្មោះថា ខារី ។ បទថា វិធោ ប្រែថា អម្រែក ។ ព្រោះដូច្នោះ ទើបមានសេចក្តីថា កាន់យកអម្រែកដ៏ពេញដោយបរិក្ខារតាបស ។ តែអាចារ្យដែលពោលថា ខារិវិវិធំ លោកក៏ពណ៌នាថា ពាក្យថា ខារិ ជាឈ្មោះរបស់អម្រែក ពាក្យថា វិវិធំ គឺ បរិក្ខារច្រើនយ៉ាង មានកុណ្ឌីទឹកជាដើម ។ បទថា បវត្តផលភោជនោ ប្រែថា មានប្រក្រតីបរិភោគផ្លែឈើដែលជ្រុះហើយ ។ បទថា **ជាអ្នកបម្រើ** គឺ ជាអ្នកនៅបម្រើដោយអាចធ្វើវត្ត ដូចធ្វើកប្បិយៈ

ទទួលបាត្រ និងលាងជើងជាដើម ។ សាមណេរជាព្រះខីណាស្រព សូម្បីមានគុណធម៌ខ្ពស់ រមែងជាអ្នកនៅបម្រើភិក្ខុបុថុជ្ជន ដោយន័យដែលពោលហើយដោយពិត តែសមណៈ ឬព្រាហ្មណ៍ មិនដូច្នោះទេ ជាអ្នកនៅក្រោមតែម្យ៉ាង ដោយអំណាចនៃគុណធម៌ខ្លះ ដោយអំណាចនៃការធ្វើការបម្រើខ្លះ ។

សួរថា ក៏ការបួសជាតាបស លោកពោលថា ជាផ្លូវនៃសេចក្ដីវិនាសរបស់សាសនា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះសាសនាដែលកំពុងដំណើរទៅ រមែងថយក្រោយ ដោយអំណាចនៃការបព្វជ្ជាជាតាបស ។ សេចក្ដីពិត អ្នកដែលមានសេចក្ដីខ្មាស ប្រាថ្នាក្នុងការសិក្សាច្រើនវៀងអ្នកដែលបួសក្នុងសាសនានេះ ហើយមិនអាចបំពេញសិក្ខា ៣ ឲ្យពេញបានថា យើងនឹងមិនមានការធ្វើឧបោសថកម្ម បវារណាកម្ម សង្ឃកម្មនឹងលោក ហើយវៀរចេញ ។ សមណៈ ឬព្រាហ្មណ៍នោះគិតថា ការបំពេញវត្តបដិបត្តិឲ្យពេញបរិបូណ៌ក្នុងសាសនាធ្វើបានលំបាក ប្រៀបដូចមុខកាំបិតកោរ ជាទុក្ខ តែការបួសជាតាបស ធ្វើបានងាយ ទាំងជនក៏រាប់អានច្រើនណាស់ ដូច្នេះហើយ ទើបសឹកមកជាតាបស ។ អ្នកដទៃឃើញគេ ក៏នាំគ្នាសួរថា លោកធ្វើអ្វីឬ ។ គេទើបឆ្លើយថា ការងារក្នុងសាសនារបស់ពួកលោកធ្ងន់ណាស់ តែពួកយើង ក៏នៅមានប្រក្រតីប្រព្រឹត្តដោយសេចក្ដីពេញចិត្តក្នុងសាសនានេះ ។ សូម្បីគេក៏គិតថា សូម្បីយើងក៏នឹងបួសក្នុងសាសនានេះខ្លះ ដូច្នេះហើយទើបសិក្សាតាមគេ បួសជា

តាបស សូម្បីពួកដទៃៗ ក៏បួសជាតាបសទំនងនេះខ្លះ ព្រោះដូច្នោះ ពួកតាបស ទើបកើនច្រើនឡើងដោយលំដាប់ ។ ក្នុងកាលដែលពួកតាបសទាំងនោះ កើតឡើង សាសនា ឈ្មោះថា នឹងថយក្រោយ ។ ឈ្មោះថាព្រះពុទ្ធ មានសភាពដូច្នេះ ស្តេចឧប្បត្តិឡើងហើយក្នុងលោក សាសនារបស់ព្រះអង្គ ក៏បានឈ្មោះថា ដូច្នេះ ព្រោះដូច្នោះ សាសនាទើបនឹងមានត្រឹមតែដូចសរសៃអំបោះប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់សេចក្តីនេះ ទើបត្រាស់ថា ការបួសជាតាបស ជាផ្លូវនៃសេចក្តីវិនាសរបស់សាសនា ។

**[១៦៤]** បទថា កុទាលបិដកំ បានដល់ ចប និងល្អី ដើម្បីនឹងប្រមូលមើមដំឡូង មើមឈើ និងផ្លែឈើ ។

**[១៦៥]** បទថា ***ជិតស្រុកឬ*** សេចក្តីថា អ្នកដែលនៅមិនទាន់បានសម្រេចនូវការដល់ព្រមដោយវិជ្ជា និងចរណៈជាដើម ហើយសម្គាល់ថាដំណើរជីវិតដោយកសិកម្មជាដើម ជារបស់លំបាក ដូច្នេះ ដើម្បីនឹងបោកបញ្ឆោតឲ្យមនុស្សពួកច្រើនវង្វេងជឿ ទើបសាងរោងភ្លើងក្នុងទីជិតស្រុកខ្លះ ក្នុងទីជិតតំបន់ខ្លះ បម្រើភ្លើងដោយអំណាចធ្វើការបូជាដោយទឹកដោះថ្លា ប្រេង ទឹកដោះជូរ ទឹកឃ្មុំ ល្ង និងអង្ករជាដើម និងដោយឈើប្រភេទផ្សេងៗ អាស្រ័យនៅ ។

**[១៦៦-៧]** បទថា ***ធ្វើរោងមានទ្វារ ៤*** សេចក្តីថា សាងផ្ទះទឹកផឹក

មានមុខ ៤ ទិសាង សាងមណ្ឌបទុកត្រង់ទ្វារ តាំងទឹកផឹកទុកក្នុងនោះ ចាំអញ្ជើញអ្នកដែលមក ឲ្យផឹកទឹក ។ ពួកអ្នកដើរផ្លូវឆ្ងាយ នឿយហត់ ផឹកទឹកហើយឲ្យវត្ថុណាដល់គេ ជាកញ្ចប់អាហារដែលបរិភោគហើយក្តី ជាអន្ទរជាដើមក្តី ក៏កាន់យកវត្ថុនោះគ្រប់យ៉ាង ធ្វើយាគូជាដើម ហើយឲ្យបាយដល់បុគ្គលខ្លះ ឲ្យភាជនៈ គ្រឿងជាំស្លអាហារដល់អ្នកខ្លះ ដើម្បីនឹងសង្គ្រោះដោយអាមិសឲ្យច្រើនក្រៃលែងឡើង ។ គេកាន់យកអាមិសខ្លះ បុព្វណ្ណជាតិ និងអបរណ្ណជាតិ ជាដើមខ្លះ ដែលពួកគេទាំងនោះឲ្យហើយ ដើម្បីការកពូនឡើង ក៏ប្រើរបស់ទាំងនោះរកប្រយោជន៍តទៅ ។ ដោយប្រការនេះ គេក៏មានសម្បត្តិកើនឡើងរឿយៗ ក៏ធ្វើការទទួលគោ ក្របី ទាសី និងទាសៈតទៅ គេក៏ប្រមូលទ្រព្យសម្បត្តិបានយ៉ាងច្រើន ។ ព្រះមានព្រះភាគទ្រង់ សំដៅយកជំពូកនេះ ទើបត្រាស់ព្រះតម្រាស់នេះថា សាងផ្ទះមានទ្វារ ៤ ដូច្នេះ ។ ចំណែកពាក្យនេះថា អាត្មាអញនឹងបូជាសមណៈ ឬព្រាហ្មណ៍នោះ តាមសេចក្តីដែលអាច តាមកម្លាំង ដូច្នេះ ជាផ្លូវបដិបត្តិរបស់គេ ។ ព្រោះគេបដិបត្តិយ៉ាងនេះ ដោយផ្លូវនេះ ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះ ជាចំណែកដែល ព្រះមានព្រះភាគទ្រង់បានសម្តែងឲ្យឃើញដល់ការបួសជាតាបសដោយសព្វគ្រប់ ។ សួរថា ទ្រង់សម្តែងយ៉ាងណា ? ។ ឆ្លើយថា ទ្រង់សម្តែងថា តាបសនោះមាន ៨ ពួក គឺ នៅមានកូនប្រពន្ធ ១ ពួក , ត្រាច់សូមគេចិញ្ចឹមជីវិត ១ ពួក ,

អនគ្គិបក្កិកៈ ១ ពួក , អសាមបាកៈ ១ ពួក , អយមុដ្ឋិកៈ ១ ពួក , ទន្តវក្កលិកៈ ១ ពួក , បវត្តផលភោជន ១ ពួក , បណ្ឌុបលាសិកៈ ១ ពួក ។

បណ្ដាតាបសទាំងនោះ តាបសពួកណារួបរួមទ្រព្យសម្បត្តិទុកបាន យ៉ាងច្រើន ដូចកេណិយជដិល តាបសទាំងនោះ ឈ្មោះថា មានកូនប្រពន្ធ ។ ចំណែកតាបសពួកណាគិតថា ដែលឈ្មោះថា ភាពជាអ្នកមានកូនប្រពន្ធ មិនសមគួរដល់អ្នកបួស ទើបត្រាច់រកអង្ករ សណ្ដែកបាយ សណ្ដែកពជមាស និងគ្រាប់ល្ងជាដើម ក្នុងទីដែលគេច្រូត និងបោក យកមកដាំស្ល ធាន់ តាបសទាំងនោះ ឈ្មោះថា ត្រាច់សូមគេចិញ្ចឹមជីវិត ។

ចំណែកតាបសពួកណាគិតថា ដែលឈ្មោះថា ការត្រាច់ទៅពីលានឯណោះ កាន់លាននេះ ប្រមូលយកអង្ករមកដាំស៊ីមិនសមគួរ ដូច្នេះហើយ ព្រមទទួលតែភិក្ខាហារ គឺ អង្ករ ក្នុងស្រុក និងនិគមបានហើយ យកមកដាំស្លធាន់ តាបសទាំងនោះ ឈ្មោះថា អ្នកមិនបានដាំស្លដោយភ្លើង ។ ចំណែកតាបសពួកណាគិតថា និងមានប្រយោជន៍អ្វី ដោយការដាំស្លខ្លួនឯងរបស់អ្នកបួស ទើបចូលទៅកាន់ពួកស្រុក ទទួលយកចំពោះតែភិក្ខាហារ ដែលដាំស្លហើយប៉ុណ្ណោះ តាបសទាំងនោះ ឈ្មោះថា អ្នកមិនដាំស្ល ដោយខ្លួនឯង ។

តាបសពួកណាគិតថា ឈ្មោះថា ការស្វែងរកភិក្ខាហាររាល់ៗ ថ្ងៃ

សម្រាប់អ្នកបួសហើយលំបាក ទើបយកអន្ទាក់ដៃដូចថ្ម ដំសំបកឈើមានដើមស្វាយព្រៃជាដើម ទំពារស៊ី តាបសទាំងនោះ ឈ្មោះថា អ្នកមានអន្ទាក់ដៃដូចដែក ។

ចំណែកតាបសពួកណាគិតថា ឈ្មោះថា ការត្រាច់យកថ្មដំសំបកឈើជាការលំបាក ហើយប្រើធ្មេញទុំះឯង ដកឡើងមកទំពារស៊ី តាបសទាំងនោះ ឈ្មោះថា អ្នកប្រើធ្មេញ ។

តាបសពួកណាគិតថា ឈ្មោះថា ការប្រើធ្មេញខាំទំពារស៊ី ចំពោះអ្នកដែលបួសហើយលំបាក ទើបឆាន់ផ្លែឈើ ដែលប្រើដុំដី និងកំណាត់ឈើជាដើម គប់ឲ្យជ្រុះចុះមក តាបសទាំងនោះ ឈ្មោះថា អ្នកឆាន់ចំពោះផ្លែឈើដែលជ្រុះចុះមក ។

ចំណែកតាបសពួកណាគិតថា ឈ្មោះថា ការប្រើដុំដី និងកំណាត់ឈើជាដើម គប់ផ្លែឈើឲ្យជ្រុះចុះមកហើយឆាន់ មិនសមគួរដល់អ្នកបួសឡើយ ទើបទំពារស៊ីផ្កាឈើ ផ្លែឈើ ស្លឹកឈើស្ងួតជាដើម ដែលធ្លាក់ឯងហើយប៉ុណ្ណោះញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ តាបសទាំងនោះ ឈ្មោះថា អ្នកឆាន់ស្លឹកឈើស្ងួត ។

តាបសទាំងនោះ មាន ៣ ប្រភេទ ដោយអំណាចប្រភេទឧក្រិដ្ឋ ប្រភេទកណ្ដាល និងប្រភេទខ្សោយ ។ ក្នុង ៣ ប្រភេទនោះ តាបសពួកណាមិនក្រោកចាកទីដែលខ្លួនអង្គុយ ប្រើដៃរើសយកផ្លែឈើដែលជ្រុះចុះ

ក្នុងទីដែលនឹងឈោងដល់បាន ប៉ុណ្ណោះ ហើយទំពារស៊ី តាបសទាំងនោះ ចាត់ថា ជាប្រភេទឧញ្ឆកិដ្ឋ ។ តាបសពួកណាមិនព្រមទៅកាន់ដើមឈើដទៃចាកពីដើមឈើមួយដើម តាបសទាំងនោះចាត់ថា ជាប្រភេទកណ្ដាល ។ តាបសពួកណា ត្រាច់ស្វែងរកនៅគល់ដើមឈើនោះៗ មក ហើយទំពារស៊ី តាបសទាំងនោះចាត់ថា ជាប្រភេទខ្សោយ ។

តែការបួសជាតាបស សូម្បីទាំង ៨ យ៉ាងនេះ ក៏សង្ខេបចុះ បាន ៤ យ៉ាងប៉ុណ្ណោះ ។ សួរថា សង្ខេបចុះយ៉ាងណា ។ ឆ្លើយថា សេចក្ដីពិត បណ្ដាការបួសជាតាបសទាំងនេះ ការបួសដែលនៅមានកូនប្រពន្ធ ១ , ដែលត្រាច់សូមគេឆាន់ ១ រួមជាអ្នកបម្រើផ្ទះ ។ ដែលមិនប្រើភ្លើងដាំស្ល ១ , ដែលមិនដាំស្លខ្លួនឯង ១ រួមជាអ្នកបម្រើរោងភ្លើង ។ ដែលប្រើអង្កុញដែដូចដែកដំសំបកឈើឆាន់ ១ , ដែលប្រើធ្មេញខាំកកេរឆាន់ ១ រួមជាអ្នកបរិភោគមើមឈើ ឫសឈើ និងផ្លែឈើ ។ ដែលឆាន់ផ្លែឈើជ្រុះឯង ១ , ដែលឆាន់ស្លឹកឈើទុំ ១ រួមជាអ្នកបរិភោគផ្លែឈើជ្រុះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះ គឺ ព្រះមានព្រះភាគ ទ្រង់លើកឡើងសម្ដែងការបួសជាតាបសគ្រប់យ៉ាង ដោយប្រការដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីនឹងទ្រង់សម្ដែងថា អាចារ្យ និង អម្ពដ្ឋៈ នៅមិនទាន់ដល់ សូម្បីផ្លូវនៃសេចក្ដីសាបសូន្យនៃការដល់ព្រម

ដោយវិជ្ជា និងចរណៈ ទើបត្រាស់ព្រះតម្រាស់ថា ម្នាលអម្ពដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្ដេច ? ដូច្នេះជាដើម ។ ពាក្យនោះ ក៏មានន័យងាយហើយនោះឯង ។

## ពណ៌នា ពួកឥសីដែលជាបុព្វបុរស

[១៦៨] បទថា **ជាអ្នកធ្លាក់ទៅកាន់អបាយដោយខ្លួនឯង បំពេញឲ្យសម្បូណ៌មិនបាន** គឺ មានខ្លួនធ្លាក់ទៅកាន់អបាយ មិនបានបំពេញឲ្យសម្បូរណ៌ក្នុងការដល់ព្រមដោយវិជ្ជា និងចរណៈ ។

បទថា ឧត្តិកំ ប្រែថា របស់ដែលព្រះរាជទាន ។ បទថា មិនបានព្រះរាជទានសូម្បីដោយផ្ទាល់ សួរថា ព្រោះហេតុអ្វី ? ទើបមិនព្រះរាជ-ទាន ។ ឆ្លើយថា បានឮថា ព្រាហ្មណ៍នោះដឹងមន្ត ឈ្មោះ **អាវដ្ដនី** (មន្តដែលបណ្ដាលចិត្តធ្វើឲ្យវង្វេង) ចំពោះមុខ ។ កាលណាព្រះរាជាទ្រង់ប្រដាប់ដោយគ្រឿងអលង្ការដែលមានតម្លៃច្រើន កាលនោះ គេក៏នឹងទៅឈរក្នុងទីជិតព្រះរាជា នឹងហៅឈ្មោះគ្រឿងអលង្ការនោះ ។ កាលគេហៅឈ្មោះបានហើយ ព្រះរាជាទ្រង់មិនអាចត្រាស់ថា យើងមិនឲ្យដល់ព្រាហ្មណ៍នោះបានឡើយ គ្រាព្រះអង្គព្រះរាជទានហើយ ក្នុងថ្ងៃមានមហោស្រពទៀតទើបត្រាស់ថា ពួកលោកចូរនាំគ្រឿងអលង្ការមក កាលពួកអាមាត្យក្រាប

ទូល មិនមានទេព្រះអង្គ ព្រះរាជទានដល់ព្រាហ្មណ៍ទៅហើយ ទើបត្រាស់សួរថា ព្រោះហេតុអ្វី ? យើងទើបឲ្យគេទៅ ។ ពួកអាមាត្យទាំងនោះក្រាបទូលថា ព្រាហ្មណ៍នោះដឹងកលមាយាដែលធ្វើឲ្យវង្វេងក្នុងទីចំពោះមុខគេធ្វើព្រះអង្គ ឲ្យវង្វេងដោយកលមាយានោះហើយ ក៏កាន់យកទៅ ។ មួយពួកទៀត អត់ទ្រាំឃើញព្រាហ្មណ៍នោះ ជាសម្លាញ់ស្និទ្ធនឹងព្រះរាជាមិនបាន ទើបបានក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្លួនរបស់ព្រាហ្មណ៍នោះ មានរោគឃ្លង់ឈ្មោះ **សន្ធផលិត** ព្រះអង្គពេលឃើញព្រាហ្មណ៍នោះនឹងក្រសោប ឬស្ទាបអង្អែល ធម្មតាថា រោគឃ្លង់នេះឆ្លងគ្នាបាន ព្រោះអំណាចពាល់ត្រូវសាច់គ្នា សូមព្រះអង្គទ្រង់កុំធ្វើដូច្នោះ ។ ចាប់តាំងពីនោះមក ព្រះរាជាទើបមិនព្រះរាជទានឲ្យព្រាហ្មណ៍នោះ ចូលគាល់ចំពោះព្រះភ័ក្ត្រ ។ តែព្រោះហេតុដែលព្រាហ្មណ៍នោះជាបណ្ឌិត ឆ្លាតក្នុងវិជ្ជាការកសិកម្ម ឈ្មោះថា ការងារដែលប្រឹក្សានឹងគេហើយទើបធ្វើ រមែងមិនខុសក្លាំងក្លាត់ឡើយ ព្រោះដូច្នោះ ព្រះរាជាទើបទ្រង់ឈរខាងក្នុងសំពត់វាំងននដែលបាំងទុក ប្រឹក្សានឹងគេអ្នកឈរខាងក្រៅ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកហេតុនោះ ទើបត្រាស់ថា ព្រះរាជាទ្រង់ប្រឹក្សាអំពីខាងក្រៅព្រះសាណិ (រនាំង) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា តិរោទុស្សន្តេន ពីខាងក្រៅសំពត់វាំងនន ។ មួយទៀត បាលីក៏យ៉ាងនេះឯង ។ បទថា **ប្រកបដោយធម៌**

គឺ មិនមានទោស ។ បទថា **ដែលគេលើកឲ្យ** គឺ ដែលគេនាំមកឲ្យ ។ បទថា កថំ តស្ស រាជា សេចក្តីថា ព្រាហ្មណ៍គប្បីទទួលភិក្ខាហារយ៉ាងនេះរបស់ព្រះរាជាណា ព្រះរាជានោះ មិនគប្បីព្រះរាជទាន សូម្បីការឲ្យគាល់ចំពោះព្រះភក្ត្រដល់ព្រាហ្មណ៍នោះ យ៉ាងណា ។ តែព្រាហ្មណ៍នេះកាន់យករបស់ដែលព្រះរាជាមិនបានព្រះរាជទានដោយកលមាយា ព្រោះហេតុនោះ ព្រះរាជាទើបមិនព្រះរាជទានឲ្យព្រាហ្មណ៍នោះ ផ្ទាល់ចំពោះព្រះភក្ត្រ គប្បីដល់ការធ្លាក់ចុះបានក្នុងសេចក្តីនេះ ដូចពោលមកនេះ ជាអធិប្បាយក្នុងបទនេះ ។ ព្រះមានព្រះភាគទ្រង់ប្រកាសថា ជននឹងដល់ការយល់ព្រមបានថា ក៏អ្នកដទៃណាមិនដឹងហេតុការណ៍នេះទេ វៀរលែងតែព្រះរាជានិងព្រាហ្មណ៍ប៉ុណ្ណោះ នេះជាសេចក្តីកំបាំងផង ទាំងបិទបាំងផង ដោយប្រការដូច្នេះ ។ ព្រះសមណគោតមជាសព្វញ្ញូ ទ្រង់ជ្រាបពិតប្រាកដ ដូច្នេះ ។

[១៦៩] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់នឹងសម្តែងព្រះធម៌ទេសនាបន្ថែមឲ្យក្រៃលែងឡើងទៀត ដើម្បីទ្រង់ដកមានះ អាស្រ័យមន្តរបស់អ្នកទាំង ២ នោះ ព្រោះហេតុដែលអម្ពដ្ឋៈនេះ នឹងអាចារ្យរបស់គេជាអ្នកក្រអឺតក្រអោង ព្រោះអាស្រ័យមន្ត ទើបត្រាស់ព្រះតម្រាស់នេះថា ម្នាលអម្ពដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្តេច ? ព្រះរាជាក្នុងលោកនេះជាដើម ។

បណ្តាបទទាំងនោះ បទថា **លើគ្រឿងក្រាលក្នុងរថ** គឺ លើកន្លែង

ដែលគេក្រាលទុក ដើម្បីជាទីប្រថាប់ឈររបស់ព្រះរាជាក្នុងរថ ។ បទថា **អ្នកធំ** គឺ ជាមួយនឹងអាមាត្យថ្នាក់ខ្ពស់ៗ ឡើងទៅ ។ បទថា **ជាមួយនឹងខែ្សរាជវង្សានុវង្ស** គឺ ជាមួយព្រះកុមារដែលនៅមិនទាន់បានអភិសេក ។ បទថា **ប្រឹក្សាប្រការខ្លះ** បានដល់ រឿងប្រឹក្សាដែលប្រកបដោយមានសភាព ដូច្នេះថា គួរនឹងជីកអណ្តូង ឬធ្វើប្រឡាយក្នុងទីឯណោះ គួរនឹងសាងស្រុក និគម ឬនគរទុកក្នុងទីឯណោះ ដូច្នេះ ។ បទថា **រឿងប្រឹក្សានោះឯង** សេចក្តីថា រឿងរាជការណា ដែលព្រះរាជាទ្រង់ប្រឹក្សា ព្រះអង្គគប្បីប្រឹក្សារឿងរាជការនោះ ដោយព្រះអាការ មានការទ្រង់លើកព្រះសិរសាឡើង និងទ្រង់ញាក់ព្រះកម្ភកាជាដើម ទំនងនោះប៉ុណ្ណោះ ។ បទថា **ព្រះរាជាត្រាស់ហើយ** គឺ ព្រះរាជាត្រាស់ព្រះរាជតម្រាស់ដោយរឿងណា ព្រះរាជតម្រាស់នោះ អាចឲ្យសម្រេចប្រយោជន៍បានដោយប្រការនោះ សេចក្តីថា សូម្បីព្រះបាទបសេនទិកោសល ក៏ត្រាស់ព្រះរាជតម្រាស់ដែលអាចឲ្យសម្រេចប្រយោជន៍នោះបាន ។

បទថា បវត្តារោ ប្រែថា ជាអ្នកប្រាប់ ។ បទថា **ពួកណា** គឺ ជាសម្បត្តិចាស់ៗ របស់ព្រាហ្មណ៍ពួកណា ។ បទថា **បទនៃមន្ត** គឺ មន្តពោលគឺ វេទនុ៎ះឯង ។ បទថា **ច្រៀង** គឺ ដែលព្រាហ្មណ៍ចាស់ៗ ទាំង ១០ មានអដ្ឋកព្រាហ្មណ៍ជាដើមស្វាធ្យាយហើយ ដោយអំណាចការដល់ព្រមដោយសំឡេង ។ បទថា បវុត្តំ បានដល់ ប្រាប់ដល់ពួកមនុស្សដទៃ

សេចក្តីថា ពោលទូន្មាន ។ បទថា **សន្សំទុក** គឺ ប្រមូលទុក បានដល់ធ្វើឲ្យជាគំនរទុក សេចក្តីថា ប្រមូលរួមទុកជាពំនូក ។ បទថា **ច្រៀងតាមមន្តនោះ** សេចក្តីថា ព្រាហ្មណ៍ក្នុងកាលឥឡូវនេះ ច្រៀងតាម គឺ ស្វាធ្យាយតាមនូវមន្តនោះ ដែលព្រាហ្មណ៍ទាំងនោះ ច្រៀងហើយក្នុងកាលមុន ។ បទថា **ពោលតាមមន្តនោះ** គឺ សូត្រតាមមន្តនោះ ។ ពាក្យនេះជាវេវចនៈរបស់ពាក្យដំបូងនុ៎ះឯង ។ បទថា **ពោលទូន្មាននូវមន្តដែលពួកព្រាហ្មណ៍ចាស់ៗ ពោលទូន្មានទុកហើយ** គឺ ទូន្មានតាមមន្តដែលព្រាហ្មណ៍ទាំងនោះទូន្មានហើយដល់អ្នកដទៃ ។ បទថា **ដូចម្តេចខ្លះ** សេចក្តីថា ព្រាហ្មណ៍ទាំងនោះ មានអ្នកណាខ្លះ ។ ពាក្យថា **អដ្ឋក** ជាដើម ជាឈ្មោះរបស់ព្រាហ្មណ៍ទាំងនោះ ។

បានឮថា ព្រាហ្មណ៍ទាំងនោះ សម្លឹងមើលដោយទិព្វចក្ខុ មិនធ្វើការប្រទូសរ៉ាយអ្នកដទៃ តែងមន្ត ប្រៀបផ្ទឹមនឹងពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគកស្សបសម្មាសម្ពុទ្ធ ។ តែពួកព្រាហ្មណ៍ក្រៅនេះ ដាក់បាណាតិបាតជាដើមចុះ ទៅទម្លាយវេទទាំង ៣ បានធ្វើឲ្យខុសឃ្លៀងឃ្លាតនឹងព្រះពុទ្ធវចនៈ ។

បទថា **នោះមិនជាឋានៈដែលនឹងមានបាន** គឺ អ្នកគប្បីជាឥសីដោយហេតុណា ហេតុនោះមិនមាន ។ ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ជ្រាបថា អម្ពដ្ឋៈនេះ សូម្បីត្រូវតថាគតសួរ ដឹងថា ខ្លួនត្រូវបន្តុះបង្អាប់

នឹងមិនឲ្យមានពាក្យឆ្លើយ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់មិនទទួលយកពាក្យបដិញ្ញា បដិសេធភាពជាឥសីនោះ ។

ឥឡូវនេះព្រះមានព្រះភាគ ដើម្បីនឹងទ្រង់សម្តែងសេចក្តីដែលអម្ពដ្ឋៈព្រមទាំងអាចារ្យ ជាអ្នកឆ្ងាយចាកវត្តបដិបត្តិ របស់ព្រាហ្មណ៍ទាំងនោះ ទើបត្រាស់ថា ម្នាលអម្ពដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្តេច ដូច្នេះជាដើម ព្រោះហេតុថា ព្រាហ្មណ៍ជំនាន់ចាស់ទាំង ១០ នាក់នោះ មិនមានក្លិនរបស់ត្រីសាច់ មិនមានក្លិនមនុស្សស្រី ពេញទៅដោយល្អងធូលី និងញើសក្អែល មានប្រក្រតីប្រព្រឹត្តព្រហ្មចរិយៈ មានឫសឈើ និងផ្លែឈើក្នុងព្រៃជាអាហារ អាស្រ័យនៅតាមជើងភ្នំ ក្នុងដងព្រៃ កាលណាប្រាថ្នានឹងទៅក្នុងទីណា កាលនោះ ក៏ហោះទៅបានតាមអាកាសតែម្តង ដោយឫទ្ធិ ពួកគេមិនមានកិច្ចដែលនឹងត្រូវប្រើយានជំនិះ ការចម្រើនព្រហ្មវិហារ មានមេត្តាជាដើមនុ៎ះឯង ជាគ្រឿងឃុំគ្រងរបស់ពួកគេ ក្នុងគ្រប់ទិសាទិស ពួកគេមិនត្រូវការឃុំគ្រងគ្នា គឺ កំពែង និងមនុស្ស និងវត្តបដិបត្តិរបស់ពួកព្រាហ្មណ៍ទាំងនោះ អម្ពដ្ឋៈនេះ ក៏ធ្លាប់បានឮមក ។

បណ្តាបទទាំងនោះ បទថា **មានក្អែកពណ៌ខ្មៅ** រើសចោលទៅ គឺ មានក្អែកពណ៌ខ្មៅដែលរើសហើយ នាំចេញទៅ ។ បទថា **មានសំពត់ពណ៌សដែលទន់** បង្អួនចុះដោយសំពត់រុំ គឺ មានគ្រោងឆ្អឹង (រូបរាង) ដែលទន់ដោយសំពត់រុំ មានផ្ទាំងសំពត់ និងផ្នួងសក់សំពត់ជាដើម ។

បទថា **មានកន្ទុយកាត់ តែងហើយ** គឺ មានកន្ទុយដែលកាត់ហើយ ក្នុងទីដែលគួរកាត់តែង ដើម្បីធ្វើឲ្យស្អាត ។ មួយទៀត ក្នុងពាក្យនេះសូម្បីរថទាំងឡាយ លោកក៏ហៅថា រថជាប់កន្ទុយសេះដែលកាត់ហើយ ព្រោះហេតុដែលរថទាំងឡាយ កាត់កន្ទុយសេះនុ៎ះឯង ទឹមដោយសេះ ។ បទថា មានប្រឡាយព័ទ្ធជុំវិញ គឺ ជីកប្រឡាយទុកជុំវិញ ។ បទថា **មានគន្លឹះភ្ជាប់ទុក** គឺ មានគន្លឹះដែលខ្ទាស់ទុក ។ ការធ្វើការបូកកំបោរទុកខាងក្រោមកំពែងនគរដោយជុំវិញ ដើម្បីការពារមិនឲ្យពួកសត្រូវគោងឡើងមកបាន លោកហៅថា **កំពែង** ក្នុងពាក្យថា កំពែងនគរ តែនគរទាំងឡាយដែលប្រកបដោយកំពែងទាំងនេះ លោកបំណាងយកថា ជាកំពែងនគរក្នុងទីនេះ ។ បទថា **ឲ្យរក្សា** គឺ ពួកគេសូម្បីនឹងនៅក្នុងនគរដូច្នោះ ក៏នៅតែឲ្យមនុស្សការពារខ្លួន ។

បទថា **សេចក្តីសង្ស័យ** គឺ សេចក្តីងឿងឆ្ងល់យ៉ាងនេះថា ជាព្រះ-សព្វញ្ញូ ឬមិនមែនព្រះសព្វញ្ញូ ។ ពាក្យថា វិមតិ ក៏ជាវេវចនៈរបស់ពាក្យនោះឯង សេចក្តីថា ការគិតឃើញដែលខុសប្លែកទៅ អធិប្បាយថា មិនអាចនឹងវិនិច្ឆ័យបាន ។ ព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ការប្រាកដឡើងនៃមគ្គ មិនមានដល់អម្ពដ្ឋៈដោយអត្តភាពនេះ ថ្ងៃក៏នឹងកន្លងទៅទទេតែម្តង ក៏អម្ពដ្ឋៈនេះ មកដើម្បីស្វែងរកលក្ខណៈ សូម្បីកិច្ចនោះ ក៏រលឹកមិនទាន់បាន ណ្ហើយចុះ ដើម្បីនឹងឲ្យកើតសតិ តថាគតនឹង

ឲ្យន័យដល់គេ ។

## ពណ៌នា មហាបុរិសលក្ខណៈ ២ ប្រការ

[១៧០] ក៏ព្រះមានព្រះភាគ គ្រាត្រាស់យ៉ាងនេះហើយ ទើបស្ដេចក្រោកឡើងចាកពីអាសនៈ ស្ដេចចេញទៅខាងក្រៅ ព្រោះហេតុថា កាលព្រះពុទ្ធទាំងឡាយប្រថាប់ក្ដី ផ្ទុំក្ដី នរណាៗ មិនអាចនឹងស្វែងរកលក្ខណៈបាន តែកាលព្រះអង្គប្រថាប់ឈរក្ដី ស្ដេចចង្រ្កមក្ដី គេអាច (ដឹង) , ធម្មតាថា ព្រះពុទ្ធទ្រង់ជ្រាបថា គេមកដើម្បីស្វែងរកមើលលក្ខណៈ ស្ដេចក្រោកឡើងចាកអាសនៈ ទ្រង់អធិដ្ឋានចង្រ្កម នេះជាអាចិណ្ណវត្ត បដិបត្តិរបស់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ លោកទើបពោលថា គ្រានោះ ព្រះមានព្រះភាគ ជាដើម ។

[១៧១] បទថា **ពិចារណាមើល** គឺ សម្លឹងមើល បានដល់ ពិចារណារាប់ ១-២ ។ បទថា **ដោយច្រើន** គឺ ដោយចំណែកច្រើន ។ អធិប្បាយថា បានឃើញហើយដោយចំណែកច្រើន ចំណែកតិចមិនបានឃើញ ។ តពីនោះ ដើម្បីនឹងសម្ដែងមហាបុរសលក្ខណៈ ដែលគេមិនបានឃើញ លោកទើបពោលថា វៀរលែងតែ ២ ប្រការប៉ុណ្ណោះ ។ បទថា **មានសេចក្ដីសង្ស័យ** គឺ ឲ្យកើតសេចក្ដីប្រាថ្នាឡើងមកថា ឱហ្ន៎ យើងគប្បីឃើញ ដូច្នេះ ។

បទថា **មានសេចក្តីងឿងឆ្ងល់** គឺ សម្លឹងមើលមហាបុរសលក្ខណៈទាំងនោះ អំពីទីនោះៗ បានលំបាក បានដល់ មិនអាចនឹងមើលឃើញបាន ។ បទថា **មិនជឿ** គឺ សូម្បីការឃើញមិនបាន ព្រោះសេចក្តីសង្ស័យនោះ ។ បទថា **មិនជ្រះថ្លា** គឺ សូម្បីសេចក្តីជ្រះថ្លាមិនមានក្នុងព្រះមានព្រះភាគថា ព្រះមាន-ព្រះភាគនេះ ទ្រង់មានព្រះលក្ខណៈបរិបូណ៌ ព្រោះហេតុនោះ សេចក្តីសង្ស័យ លោកពោលថា មានកម្លាំងខ្សោយជាងសេចក្តីងឿងឆ្ងល់ ការងឿងឆ្ងល់ មានកម្លាំងកណ្តាល ការមិនជឿមានកម្លាំងខ្លាំង ព្រោះមិនជ្រះថ្លា ចិត្តក៏ នឹងសៅហ្មងដោយធម៌ទាំង ៣ នោះ ។ បទថា **រក្សាទុកក្នុងស្រោម** គឺ បិទបាំងទុកដោយស្រោមស្បែក ។ បទថា **បិទបាំងទុកដោយសំពត់** គឺ ក៏ព្រះអង្គជាតិរបស់ព្រះមានព្រះភាគ ក៏ដូចគ្នានឹងរបស់ដំរីដ៏ប្រសើរ បិទបាំង ទុកក្នុងស្រោម បិទបាំងទុកដោយសំពត់ ដូចបទុមផ្កាឈូកមាស ។ អម្ពដ្ឋៈ មើលមិនឃើញព្រះអង្គជាតិនោះ ព្រោះសំពត់បិទបាំងទុក និងសង្កេតឃើញ មិនបាននូវព្រះជិវ្ហាដែលធំទូលាយ ព្រោះនៅខាងក្នុងព្រះឱស្ឋ ទើបមាន សេចក្តីងឿងឆ្ងល់ និងងឿងឆ្ងល់ក្នុងព្រះលក្ខណៈទាំង ២ នោះ ។

បទថា **មានសភាពដូច្នោះ** គឺ រូបដែលពិតប្រាកដ ក្នុងសេចក្តីនេះ អ្នកដទៃនឹងគប្បីពោលយ៉ាងណា ។ សេចក្តីនេះ ព្រះនាគសេនត្ថេរ ត្រូវ ព្រះបាទមិលិន្ទត្រាស់សួរថា បពិត្រព្រះនាគសេនដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ធ្វើវត្ថុដែលធ្វើបានលំបាកឬ ដូច្នេះបានពោលទុកហើយ ។ ព្រះនាគ-

សេនត្ថេរក្រាបទូលថា បពិត្រមហារាជ ទ្រង់ធ្វើអ្វីឬ ។ ព្រះបាទមិលិន្ទ ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះមានព្រះភាគទ្រង់សម្តែងឱកាស ដែលមហាជនគេប្រកាន់ថា ជាសេចក្តីខ្មាសដល់អន្តេវាសិករបស់ព្រហ្មា- យុព្រាហ្មណ៍ ដល់ព្រាហ្មណ៍ ១៦ នាក់ជាអន្តេវាសិករបស់ព្រាហ្មណ៍ឧត្តរៈ និងរបស់ព្រាហ្មណ៍ពាវរី និងដល់មាណព ៣០០ នាក់ ដែលជាអន្តេវាសិក របស់សេលព្រាហ្មណ៍ ។

ព្រះនាគសេនក្រាបទូលថា បពិត្រមហារាជ ព្រះមានព្រះភាគទ្រង់ មិនបានសម្តែងព្រះគុយ្ហៈ ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះឆាយា ទ្រង់ បណ្តាលដោយឫទ្ធិ សម្តែងត្រឹមតែព្រះរូបជាស្រមោលៗ ទ្រង់នៅស្លៀក ស្បង់ដដែល ទ្រង់ចងក្រវាត់វត្ថពន្ធចង្កេះដដែល និងទ្រង់ដណ្តប់សំពត់ ចីវរដដែល មហាបពិត្រ ។

ព្រះបាទមិលិន្ទ កាលឃើញព្រះឆាយាហើយ ក៏ជាការឃើញព្រះគុយ្ហៈ ផងមែនទេ លោកម្ចាស់ ។

ព្រះនាគសេន សេចក្តីនោះលើកទុកចុះ សត្វដែលឃើញហទយរូប ហើយដឹងបាន គប្បីមាន ព្រះសម្មាសម្ពុទ្ធ ក៏គប្បីនាំព្រះហទយមំសៈចេញ មកសម្តែង ។ ព្រះបាទមិលិន្ទ ព្រះករុណា លោកម្ចាស់នាគសេន លោក ម្ចាស់និយាយត្រឹមត្រូវហើយ ។

បទថា **ទ្រង់លៀន** គឺ ទ្រង់នាំចេញមក ។ បទថា **ទ្រង់មូរត្រឡប់**

**ទៅ** គឺ ទ្រង់មូរត្រឡប់ទៅ ធ្វើឲ្យដូចគ្នានឹងម្ជុលដេរសំពត់កឋិន ។ គប្បីជ្រាបអធិប្បាយថា ក៏ក្នុងទីនេះ លោកសម្តែងឲ្យឃើញដល់សេចក្តីទន់ភ្លន់ ដោយទ្រង់ធ្វើដូច្នោះ , សម្តែងឲ្យឃើញដល់ប្រវែង ដោយការស៊កចូលទៅក្នុងរន្ធព្រះកាណ៌ , សម្តែងឲ្យឃើញដល់កម្រាស់ ដោយការបិទបាំងនូវមណ្ឌលព្រះនលាដ ។

[១៧២] បទថា **នៅទទួល** គឺ រង់ចាំ សេចក្តីថា ប្រាថ្នាការមករបស់គេ នៅចាំសម្លឹងមើល ។ បទថា **សន្ទនាប្រាស្រ័យ** គឺ ការនិយាយនិងការចរចាគ្នា សេចក្តីថា ការពោល និងការពោលតប ។

[១៧៣] បទថា អហោ វត នេះជាពាក្យតិះដៀល ។ ពាក្យថា រេ នេះ ជាពាក្យហៅដោយអំណាចការស្តីបន្ទោស ។ ព្រាហ្មណ៍បោក្ខរសាតិស្អប់អម្ពដ្ឋៈនុ៎ះឯង ទើបបានពោលថា អ្នកប្រាជ្ញ ។ សូម្បីក្នុង ២ បទដ៏សេសក៏មានន័យតែម្យ៉ាងគ្នានេះ ។ ព្រាហ្មណ៍បោក្ខរសាតិ សំដៅយកសេចក្តីនេះថា បុគ្គលគប្បីទៅកាន់នរកបាន ព្រោះកាលមានអ្នកប្រព្រឹត្តប្រយោជន៍ គឺ អ្នកធ្វើប្រយោជន៍ ដូចគ្នានឹងលោកមិនគប្បីទៅបាន ព្រោះហេតុដទៃ ដូច្នេះ ទើបបានពោលបទនេះថា អ្នកដ៏ចម្រើន បានឮថា អ្នកគប្បីទៅកាន់នរកបាន ព្រោះបុគ្គលអ្នកប្រព្រឹត្តប្រយោជន៍បែបនេះ ។ បទថា ស្មាក់ជំទាស់ គឺ និយាយដៀមដាម ។ បទថា **សូម្បីនាំពួកយើងចូលទៅប្រៀបធៀប យ៉ាងនេះៗ** សេចក្តីថា ព្រះគោតមត្រាស់ថា

ម្នាលអម្ពដ្ឋៈ បោក្ខរសាតិព្រាហ្មណ៍ ដូច្នេះជាដើម ទ្រង់នាំពួកយើងចូលទៅប្រៀបធៀបយ៉ាងនេះៗ ទ្រង់បើកបង្ហាញហេតុដែលបិទបាំងចេញហើយ លើកយកភាពជាសូទ្រៈ និងទាសៈជាដើម ឡើងមកត្រាស់ អធិប្បាយថា ពួកយើងក៏ត្រូវលោកឲ្យជេរផង ។ បទថា **រុញដោយជើង** គឺ យកជើងរុញឲ្យអម្ពដ្ឋមាណពដួលចុះទៅលើដីហើយ ។

ក៏ក្នុងកាលមុន អម្ពដ្ឋៈឡើងរថទៅនឹងអាចារ្យ ជាសារថីដេញទៅកាន់ទីណា អាចារ្យដណ្ដើមយកទីនោះរបស់គេចេញទៅ បានឲ្យគេដើរទៅដោយជើងខាងមុខរថ ។ បទថា **កន្លងហួសវេលាវិកាលហើយ** គឺ ជាវេលាវិកាលហើយ បានដល់ មិនមានវេលាដែលនឹងពោលសម្មោទនីយកថានឹងគ្នាឡើយ ។

## រឿង ព្រាហ្មណ៍ឈ្មោះចោក្ខរសាតិ

[១៧៤] បទថា អាគមា នុ ខ្វិធ ភោ ប្រែថា បពិត្រព្រះគោតមដ៏ចម្រើន អម្ពដ្ឋៈ បានមកក្នុងទីនេះដែរឬ ។

[១៧៥] បទថា អធិវាសេតុ ប្រែថា សូមទ្រង់ទទួល ។

បទថា **សម្រាប់ថ្ងៃនេះ** សេចក្ដីថា កាលខ្ញុំព្រះអង្គធ្វើសក្ការៈចំពោះព្រះអង្គ វត្ថុណានឹងមានក្នុងថ្ងៃនេះ គឺ បុណ្យផង បីតិ និង

បាមោជ្ជៈផង ដើម្បីប្រយោជន៍ដល់វត្ថុនោះ ។ បទថា **ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនបានឲ្យចំណែកព្រះវរកាយ ឬចំណែកព្រះវាចាកម្រើកឡើយ ទ្រង់តម្កល់ព្រះខន្តិទុកក្នុងខាងក្នុងនុ៎ះឯង ហើយទ្រង់ទទួលនិមន្តដោយតុណ្ហីភាព គឺ ទ្រង់ទទួលដោយព្រះទ័យ ដើម្បីនឹងទ្រង់អនុគ្រោះព្រាហ្មណ៍ ។

[១៧៦] បទថា **បណីត** គឺ ខ្ពង់ខ្ពស់ ។ បទថា សហត្ថា គឺ ដោយដៃខ្លួនឯង ។ បទថា **ឲ្យឆ្អែត** គឺ ឲ្យឆ្អែតល្អហើយ បានដល់ ធ្វើឲ្យបរិបូណ៌ គឺ ពេញប្រៀប បានដល់ ការឆ្អែត ។ បទថា សម្បវារេត្វា គឺ ឲ្យល្មមគ្រប់គ្រាន់ហើយ គឺ ឲ្យហាមដោយសញ្ញាដែថា ល្មមហើយ គ្រប់គ្រាន់ហើយ ។ បទថា ភុត្តាវី ទ្រង់សោយរួចហើយ ។ បទថា **ឱនីត-បត្តបាណឹ** ប្រែថា មានព្រះហស្តលើកចេញហើយពីបាត្រ ។ អធិប្បាយថា មានព្រះហស្តដកចេញហើយ ។ បាលីថា **ឱនិត្តបាណឹ** ក៏មាន ។ ពាក្យនេះអធិប្បាយថា ទ្រង់ដាក់បាត្រដែលទ្រង់ឈប់លូកព្រះហស្តចូលហើយ គឺ វៀរអាហារផ្សេង ៗ ពីបាតព្រះហស្តរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ព្រះអង្គទើប ឈ្មោះថា **ឱនិត្តបត្តបាណឹ** ។

អធិប្បាយថា ទ្រង់លាងព្រះហស្តនិងបាត្រហើយ ទ្រង់ដាក់បាត្រទុកក្នុងទីម្ខាង ប្រថាប់ហើយ ។ បទថា **អង្គុយក្នុងទីសមគួរមួយ** សេចក្តីថា ជ្រាបថា ព្រះមានព្រះភាគទ្រង់សោយរួចស្រេចហើយ ដូច្នោះ ទើប

អន្តុយក្នុងទីម្នាង ។

បទថា អនុបុព្វិកថំ ប្រែថា ពាក្យដែលគួរពោលតាមលំដាប់ ។ ដែលឈ្មោះថា **អនុបុព្វីកថា** បានដល់ ពាក្យដែលសម្តែងសេចក្តីទាំងនេះ គឺ សីលក្នុងលំដាប់អំពីទាន សួគ៌ក្នុងលំដាប់អំពីសីល មគ្គក្នុងលំដាប់អំពីសួគ៌ ។ ព្រោះហេតុនោះឯង លោកទើបពោលថា គឺ ទានកថាជាដើម ។ បទថា **អាក្រក់** គឺ ទាបថោក បានដល់ ជារបស់លាមក ។ បទថា សាមុក្កំសិកា ប្រែថា ដែលព្រះអង្គទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង សេចក្តីថា ដែលព្រះអង្គទ្រង់លើកឡើង គឺ កាន់យកដោយព្រះអង្គឯង គឺ ដែលព្រះអង្គទ្រង់សម្លឹងឃើញដោយព្រះសយម្ភូញាណ អធិប្បាយថា ជារបស់មិនទូទៅដល់ពួកជនដទៃ ។ សួរថា ក៏ព្រះធម៌ទេសនានោះ គឺអ្វី ? ឆ្លើយថា គឺ ទេសនាពោលអំពីអរិយសច្ច ។ ព្រោះដូច្នោះនុ៎ះឯង លោកទើបពោលថា ទុក្ខ សមុទ័យ និរោធ មគ្គ ។ ក្នុងបទថា ធម្មចក្ខុ នេះ លោកបំណងសំដៅយកសោតាបត្តិមគ្គ ។ ដើម្បីនឹងសម្តែងដល់អាការកើតឡើងនៃធម្មចក្ខុនោះ លោកទើបពោលថា ធម្មជាតណានីមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅជាធម្មតា ។ ក៏ធម្មចក្ខុនោះ ធ្វើនិរោធឲ្យជាអារម្មណ៍កើតឡើង ចាក់ធ្លុះនូវសង្ខតធម៌ទាំងពួងយ៉ាងនេះ ដោយអំណាចនៃកិច្ច ។

[១៧៧] អរិយសច្ចធម៌ ដែលបុគ្គលនោះឃើញហើយ ព្រោះហេតុ

នោះ ឈ្មោះថា អ្នកមានធម៌ដែលឃើញហើយ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ សេចក្តីសង្ស័យ ដែលបុគ្គលនេះឆ្លងបានហើយ ព្រោះហេតុនោះ ឈ្មោះថា អ្នកមានសេចក្តីសង្ស័យឆ្លងបានហើយ ។ ការមិនជឿជាក់របស់បុគ្គលនោះទៅប្រាសហើយ ព្រោះហេតុនោះ ឈ្មោះថា អ្នកមានការមិនជឿជាក់ទៅប្រាសហើយ ។ បទថា វេសារជ្ជប្បត្តោ ប្រែថា ដល់ភាពជាអ្នកក្លាហានហើយ ។

សួរថា តើក្លាហានក្នុងអ្វី ? ។

ឆ្លើយថា ក្នុងពាក្យទូន្មានរបស់ព្រះសាស្តា ។

បុគ្គលដទៃជាបច្ច័យ មិនមានដល់អ្នកនេះ គឺ សេចក្តីជឿចំពោះបុគ្គលដទៃមិនប្រព្រឹត្តទៅក្នុងបុគ្គលនេះ ព្រោះដូច្នោះ ឈ្មោះថា មិនមានបុគ្គលដទៃជាបច្ច័យ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ព្រោះមានន័យដូចពោលហើយក្នុងខាងដើម និងព្រោះមានសេចក្តីយល់ងាយហើយ ។

ចប់ អដ្ឋកថា អម្ពដ្ឋសូត្រទី ៣

# អដ្ឋកថា សោណទណ្ឌសូត្រទី ៤

[១៧៨] *សោណទណ្ឌសូត្រ មានបាលីចាប់ផ្ដើមថា ឯវម្មេ សុតំ ។បេ។ អង្គេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។*

*ក្នុងសោណទណ្ឌសូត្រនោះ មានការពណ៌នាតាមលំដាប់បទ ដូចតទៅនេះ ៖*

*បទថា **ក្នុងអង្គជនបទ** មានសេចក្ដីថា រាជកុមារទាំងឡាយ នាមថា អង្គៈ ដែលអ្នកជនបទជាច្រើននាំគ្នាហៅយ៉ាងនេះ ក៏ព្រោះជាអ្នកមានរូបរាងគួរជ្រះថ្លា ជនបទសូម្បីតែមួយ ដែលជាទីអាស្រ័យនៅរបស់រាជកុមារទាំងនោះ លោកក៏ហៅថា **អង្គជនបទ** ព្រោះស័ព្ទដែលបន្ថែមចូលមក ។ ក្នុងជនបទឈ្មោះអង្គៈនោះ ។ បទថា ចារិក សូម្បីក្នុងជនបទនេះ លោកសំដៅយក កាលស្ដេចទ្រង់ចារិកមិនប្រញាប់រួសរាន់ និងស្ដេចទ្រង់ចារិកប្រចាំ បានឮថា ក្នុងកាលនោះ កាលព្រះដ៏មានព្រះភាគទ្រង់សម្លឹងមើលលោកធាតុទាំងម៉ឺនហើយ សោណទណ្ឌព្រាហ្មណ៍ ក៏ចូលទៅប្រាកដខាងក្នុងសំណាញ់ គឺ ព្រះញាណ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពិចារណាថា ព្រាហ្មណ៍នេះប្រាកដក្នុងសំណាញ់ គឺ ញាណរបស់តថាគត ព្រាហ្មណ៍នេះមានឧបនិស្ស័យឬទេហ្ន៎ ក៏បានទតព្រះនេត្រឃើញថា កាលតថាគតទៅក្នុងទីនោះ ពួកកូនសិស្សរបស់គេនឹងនាំគ្នាពោលសរសើរព្រាហ្មណ៍*

ដោយអាការ ១២ ហើយនឹងមិនព្រមឲ្យគេមកកាន់សំណាក់របស់តថាគត តែព្រាហ្មណ៍នោះ នឹងទម្លាយវាទៈរបស់ពួកកូនសិស្សទាំងនោះចេញ ហើយពោលសរសើរតថាគតដោយអាការ ២៩ និងចូលមករកតថាគតសួរបញ្ហា ក្នុងទីបំផុតការឆ្លើយបញ្ហា គេក៏នឹងដល់សរណៈ ដូច្នេះហើយ ទើបស្តេចទ្រង់ទៅកាន់ជនបទនោះ ព្រមដោយភិក្ខុសង្ឃ ៥០០ រូបជាបរិវារ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះដ៏មានព្រះភាគស្តេចចារិកទៅក្នុងអង្គជនបទ ស្តេចទ្រង់ដល់ក្រុងចម្បា ដូច្នេះ ។

បទថា គគ្គរាយ បោក្ខរណិយា តីរេ ត្រង់មាត់ស្រះបោក្ខរណី ឈ្មោះ **គគ្គរា** មានសេចក្តីថា ក្នុងទីមិនឆ្ងាយក្រុងចម្បានោះ មានស្រះបោក្ខរណី ដែលហៅថា **គគ្គរា** ព្រោះព្រះមហេសីរបស់ព្រះរាជាទ្រង់ព្រះនាមថា **គគ្គរា** ជីកទុក ដោយជុំវិញស្រះនោះ មានព្រៃដើមចម្បាធំប្រដាប់ប្រដាដោយផ្កាឈើ ៥ ពណ៌ មានពណ៌ខៀវជាដើម ព្រះដ៏មាន-ព្រះភាគ ស្តេចប្រថាប់នៅក្នុងព្រៃដើមចម្បា ដែលមានក្លិនក្រអូបរីករាយស្រស់ស្រាយ ដោយក្លិនក្រអូបរបស់ផ្កាឈើ ។ លោកសំដៅយកដើមចម្បានោះ ទើបពោលថា ត្រង់មាត់ស្រះបោក្ខរណី ឈ្មោះ **គគ្គរា** ។

[១៧៩] ក្នុងបទនេះថា ***ព្រះបាទពិម្ពិសារ ទ្រង់គ្រប់គ្រងដែនមគធៈ មានសេនាធំ*** ព្រះរាជាអង្គនោះ ឈ្មោះថា អ្នកគ្រប់គ្រងដែនមគធៈ ព្រោះទ្រង់ជាអ្នកធំរបស់អ្នកដែនមគធៈ ឈ្មោះថា **មានសេនាធំ** ព្រោះប្រកប

ព្រមដោយសេនាធំ ។ បទថា តិម្ពិ ប្រែថា **មាស** ។ ព្រោះដូច្នោះ លោកទើបហៅថា **ពិម្ពិសារ** ព្រោះជាអ្នកមានពណ៌សម្បុរដូចគ្នានឹងមាសនោះឯង ។

ជនជាច្រើនមករួមគ្នា ព្រោះហេតុនោះ ទើបឈ្មោះថា **ពួក** ។ ពួកជនក្នុងទិសតែមួយរបស់ជនទាំងនោះមានហើយ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា មានពួក ។ គ្រាជំបូងជនទាំងនោះ មិនបានជាគណៈគ្នាក្នុងខាងក្នុងក្រុង តែចេញទៅខាងក្រៅក្រុងហើយ ទើបរួមគ្នាជាគណៈ ព្រោះហេតុនោះ ទើបឈ្មោះថា រួមគ្នាជាគណៈ ។

[១៨០] បទថា **ទើបហៅទីប្រឹក្សាមក** សេចក្តីថា មហាមាត្យអ្នកអាចឆ្លើយបញ្ហាដែលត្រូវសួរបាន ហៅថា **ខត្ត** (ទីប្រឹក្សា) ហៅទីប្រឹក្សានោះមក ។ បទថា អាគមេន្តុ រង់ចាំមួយភ្លែត សេចក្តីថា កុំទាន់ទៅ ។

## គុណកថារបស់សោណទណ្ឌព្រាហ្មណ៍

[១៨១] បទថា **អ្នកស់នៅដែនផ្សេង** សេចក្តីថា ព្រាហ្មណ៍ទាំងឡាយដែលកើតក្នុងដែនផ្សេងៗ គ្នា គឺ ក្នុងដែន មានដែនកាសី និងដែនកោសលជាដើម អ្នកលះបង់ដែនទាំងនោះ ដែលជាទីនៅអាស្រ័យរបស់ពួកគេ ឬថា ពួកគេមកពីដែននោះ ព្រោះដូច្នោះ ព្រាហ្មណ៍ទាំងនោះ ឈ្មោះថា ព្រាហ្មណ៍ទាំងឡាយអ្នកមានដែនផ្សេងៗ គ្នា គឺ អ្នកនៅដែនផ្សេង

គ្នានោះឯង ។ បទថា **ដោយករណីយកិច្ចឯណានីមួយ** សេចក្ដីថា បានឮថា ពួកព្រាហ្មណ៍ទាំងឡាយក្នុងនគរនោះ ប្រជុំគ្នាដោយករណីយកិច្ចពីរយ៉ាង គឺ ដើម្បីរួមធ្វើការបូជាយញ្ញ និងដើម្បីការស្វាធ្យាយមន្ត ។ ក្នុងគ្រានោះ ក្នុងនគរនោះ មិនមានការបូជាយញ្ញ ។ តែព្រាហ្មណ៍ទាំងនោះ មកប្រជុំគ្នាក្នុងសំណាក់របស់សោណទណ្ឌព្រាហ្មណ៍ ដើម្បីស្វាធ្យាយមន្ត លោកពោលថា ដោយករណីយកិច្ចឯណានីមួយ សំដៅយកការស្វាធ្យាយមន្តនោះ ។

ព្រាហ្មណ៍ទាំងនោះ បានជ្រាបថា ការទៅរបស់សោណទណ្ឌ-ព្រាហ្មណ៍នោះ ហើយសោណទណ្ឌព្រាហ្មណ៍នេះ ជាព្រាហ្មណ៍ជាន់ខ្ពស់ និងព្រាហ្មណ៍ពួកដទៃជាច្រើនគិតថា គាត់នឹងដល់សមណគោតមជាសរណៈ សោណទណ្ឌព្រាហ្មណ៍នេះប៉ុណ្ណោះ មិនទាន់ទៅ បើគេនេះឯងនឹងទៅ គេក៏នឹងត្រូវមាយារបស់ព្រះសមណគោតមធ្វើឲ្យកាំងស្មារតី ធ្វើឲ្យវង្វេង ហើយនឹងដល់ព្រះគោតមជាសរណៈពិតប្រាកដ តអំពីនោះទៅ សន្និបាតរបស់ពួកព្រាហ្មណ៍ ដែលមានក្នុងផ្ទះរបស់សោណទណ្ឌព្រាហ្មណ៍នោះ ក៏នឹងមិនមាន ណ្ហើយចុះ យើងនឹងជំទាស់មិនឲ្យគេទៅបាន ដូច្នេះ ប្រឹក្សាគ្នាហើយ ទើបទៅក្នុងទីនោះ លោកសំដៅយកប្រការនោះ ទើបបានពោលពាក្យជាដើមថា គ្រានោះឯង ព្រាហ្មណ៍ទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ដោយអង្គនេះ** គឺ ដោយហេតុនេះ ។

ពួកព្រាហ្មណ៍កាលពោលហេតុនោះ យ៉ាងនេះហើយ ក៏គិតទៀតថា ធម្មតាបុគ្គលកាលគេពោលសរសើរខ្លួនដែលនឹងមិនត្រេកអរមិនមានទេ ណ្ហើយចុះ ពួកយើងនឹងហាមការទៅរបស់គេ ដោយការពោលសរសើរគេ ទើបពោលហេតុច្រើនយ៉ាងជាដើមថា សោណទណ្ឌព្រាហ្មណ៍ដ៏ចម្រើន ជាឧភតោសុជាតិ ជាដើម ។

បទថា **ទាំងពីរចំណែក** គឺ អំពីចំណែកទាំងពីរ គឺ អំពីមាតានិងអំពីបិតា ។ សោណទណ្ឌព្រាហ្មណ៍ដ៏ចម្រើន ជាឧភតោសុជាតទាំងចំណែកមាតាទាំងចំណែកបិតាយ៉ាងនេះ គឺ មាតារបស់សោណទណ្ឌ-ព្រាហ្មណ៍ដ៏ចម្រើន ជានាងព្រាហ្មណី មាតារបស់មាតាជានាងព្រាហ្មណី មាតាសួម្បីរបស់មាតារបស់មាតានោះ ក៏ជានាងព្រហ្មណី បិតាជាព្រាហ្មណ៍ បិតារបស់បិតាជាព្រាហ្មណ៍ បិតាសួម្បីរបស់បិតានោះ ក៏ជាព្រាហ្មណ៍ ។ បទថា **មានគភ៌ដែលបដិសន្ធិបរិសុទ្ធិល្អ** សេចក្ដីថា គភ៌ដែលបដិសន្ធិ គឺ ផ្ទៃរបស់មាតាបរិសុទ្ធិល្អ ។ តែក្នុងបទនេះថា សមវេបាកិនិយា គហ-ណិយា ភ្លើងធាតុដែលកើតអំពីកម្ម លោកហៅថា **គហណី** (គភ៌ដែលបដិសន្ធិ) ។ ក្នុងបទថា **រហូត ៧ តំណរនេះ** សេចក្ដីថា បិតារបស់បិតាឈ្មោះថា **បិតាមហ** (ជីតា) យុគនៃបិតាមហៈឈ្មោះ **បិតាមហយុគ** ។ ការប្រមាណនៃអាយុ លោកហៅថា **យុគ** ។ ក៏ពាក្យនេះជាឈ្មោះយុគប៉ុណ្ណោះ ។ តែដោយសេចក្ដី បិតាមហៈនោះឯង ឈ្មោះបិតាមហយុគ

បុព្វបុរសសូម្បីទាំងពួង ចំណែកខាងលើពីបិតាមហៈនោះទៅ លោកក៏ប្រើពាក្យដោយបិតាមហៈស័ព្ទនេះឯង គេជាអ្នកមានគភ៌ ដែលបដិសន្ធិដ៏បរិសុទ្ធល្អរហូតដល់អស់ ៧ តំណរមនុស្ស ដោយប្រការដូច្នេះ ។

មួយទៀត ព្រាហ្មណ៍ទាំងឡាយសម្តែងថា គេជាមនុស្សដែលអ្នកណាមើលងាយមិនបាន មិនត្រូវតិះដៀលដោយការពោលអាងដល់ជាតិ ។ បទថា **អ្នកដែលនរណាៗ មើលងាយមិនបាន** គឺ នរណាៗ មើលងាយមិនបាន មិនធ្លាប់ជេរស្តីថា ពួកលោកបណ្តេញគេចេញទៅ ឬតិះដៀលឡើយ ។ សួរថា ព្រោះហេតុណា ។

ឆ្លើយថា ព្រោះការពោលអាងដល់ជាតិ ។ សេចក្តីថា ព្រោះពាក្យបែបនេះថា សូម្បីព្រោះហេតុនេះ គេជាអ្នកមានជាតិថោកទាប ដូច្នេះ ។

បទថា **ជាអ្នកស្តុកស្តម្ភ** គឺ ជាអ្នកធំ ។ បទថា **មានទ្រព្យច្រើន** គឺ ប្រកបព្រមដោយទ្រព្យច្រើន ។ ព្រាហ្មណ៍ទាំងឡាយសម្តែងថា ក៏ក្នុងផ្ទះរបស់លោកដ៏ចម្រើនមានទ្រព្យច្រើន ប្រៀបដូចធូលី និងខ្សាច់ក្នុងផែនដី តែព្រះសមណគោតមមិនមានទ្រព្យ ត្រាច់សូមគេល្មមតែពេញពោះចិញ្ចឹមជីវិត ។ បទថា **មានភោគច្រើន** គឺ មានគ្រឿងឧបភោគច្រើន ដោយអំណាចនៃកាមគុណប្រាំ ។ ពួកព្រាហ្មណ៍ទាំងឡាយសម្គាល់ថា ជនទាំងឡាយពោលគុណណាៗ ពួកយើងនឹងសម្តែងវត្ថុដែលមិនមែនគុណតែម្យ៉ាងដោយអំណាចជាបដិបក្ខចំពោះគុណនោះ ៗ ដូច្នេះ ទើបបានពោលយ៉ាង

នោះ ។

បទថា **មានរូបល្អ** គឺ មានរូបល្អក្រៃលែង បានដល់ មានរូបរាងល្អក្រៃលែងជាងពួកមនុស្សដទៃៗ ។ បទថា ទស្សនីយោ គួរមើល គឺ ឈ្មោះថា គួរមើល ព្រោះធ្វើឲ្យមិនឆ្អែតស្កប់ស្កល់ដល់ជនអ្នកមើលនោះ សូម្បីអស់មួយថ្ងៃ ឈ្មោះថា បាសា គួរជ្រះថ្លា ព្រោះឲ្យកើតសេចក្ដីជ្រះថ្លានៃចិត្ត ដោយការមើលនុ៎ះឯង ។ ភាពល្អស្អាត លោកហៅថា **សេចក្ដីស្អាត** គឺ ពណ៌សម្បុរស្អាត ឈ្មោះថា មានសម្បុរល្អស្អាត សេចក្ដីថា ប្រកបដោយវណ្ណសម្បត្តិនោះ ។ តែបុរាណាចារ្យទាំងឡាយពោលថា ជនទាំងឡាយហៅសរីរៈថា **បោក្ខរ** វណ្ណៈនោះឯងថា វណ្ណៈ ។ តាម មតិរបស់បុរាណាចារ្យទាំងនោះ វណ្ណៈដោយរូបរាង ដោយឈ្មោះ វណ្ណៈរូបរាង ការមាននៃពណ៌សម្បុរ និងរូបរាង ទាំងអស់នោះឈ្មោះថា ការមានពណ៌សម្បុរ និងរូបរាង ។ គេប្រកបដោយពណ៌សម្បុរ និងរូបរាងយ៉ាងក្រៃលែងដោយប្រការដូច្នេះ សេចក្ដីថា ប្រកបដោយពណ៌-សម្បុរ និងសម្បត្តិនៃសរីរៈសណ្ឋានដែលបរិសុទ្ធិយ៉ាងខ្ពស់បំផុត ។

បទថា ព្រហ្មវណ្ណិ មានពណ៌សម្បុរដូចព្រហ្ម គឺ មានពណ៌សម្បុរដ៏ប្រសើរបំផុត សេចក្ដីថា ប្រកបព្រមដោយពណ៌សម្បុរដូចមាសដ៏ប្រសើរបំផុត សូម្បីក្នុងបណ្ដាអ្នកមានពណ៌សម្បុរដែលបរិសុទ្ធទាំងឡាយ ។ បទថា **មានរូបរាងព្រហ្ម** គឺ ប្រកបព្រមដោយរូបរាងប្រៀបដូចជារូបរាងរបស់ស្ដេច

ស្តេចមហាព្រហ្ម ។ បទថា **គួរមើលដោយជនមិនមែនតិច** គឺ ចន្លោះផ្លូវដែលមើលក្នុងរូបកាយរបស់លោកដ៏ចម្រើន មិនមែនតិចតួច គឺ ច្រើន ។ ព្រាហ្មណ៍ទាំងឡាយ សម្តែងថា អវយវៈតូចធំរបស់លោកសូម្បីគ្រប់ចំណែកជារបស់គួរមើល និងអវយវៈតូចធំទាំងនោះ ក៏ធំផង ដូច្នេះ ។ សីលរបស់បុគ្គលនោះមាន ហេតុនោះ គេឈ្មោះថា ជាអ្នកមានសីល សីលដែលចម្រើនហើយ គឺ លូតលាស់ហើយ របស់បុគ្គលនោះមានហើយ ហេតុនោះគេឈ្មោះថា ជាអ្នកមានសីលដែលចម្រើនហើយ ។ បទថា វុឌ្ឍសីលី មានសីលដែលចម្រើន គឺ ដោយសីលដែលចម្រើន នុ៎ះឯង គឺ ដែលលូតលាស់ល្អហើយ ។ បទថា សមន្នាគតោ មកដល់ ព្រមហើយ គឺ ប្រកបហើយ ។ ពាក្យនេះជាវេវចនៈរបស់បទថា មានសីលដែលចម្រើន ។ ពាក្យទាំងអស់នោះ លោកពោលសំដៅយកត្រឹម តែសីល ៥ ប៉ុណ្ណោះ ។

ក្នុងបទទាំងឡាយ មានបទថា កល្យាណវាចោ មានវាចាល្អជាដើម មានសេចក្តីថា វាចាដែលស្អាត គឺ ល្អ បានដល់ មានបទនិងព្យញ្ជនៈមូលក្លំរបស់បុគ្គលនោះ ហេតុនោះ គេឈ្មោះថា មានវាចាស្អាត ។ បទថា កល្យាណវាក្ករណោ មានសំនៀងពីរោះ គឺ សំនៀងដ៏ពីរោះ គឺ ទន់ក្លន់របស់បុគ្គលនោះ ហេតុនោះ គេឈ្មោះថា មានសំនៀងពីរោះ ។ បទថា **សំនៀង** បានដល់ សម្លេងកងរំពងដែលថ្លែងចេញ ។ វាចារបស់អ្នកក្រុង ព្រោះបរិបូណ៌ដោយគុណសេចក្តីល្អ ហេតុនោះ

ទើបឈ្មោះថា ជារបស់អ្នកក្រុង ។ មួយទៀត ឈ្មោះថា ចៅរី ព្រោះមានវាចាដូចស្ត្រីអ្នកក្រុង , ដោយវាចាស្ត្រីអ្នកក្រុងនោះ ។

បទថា វិស្សដ្ឋាយ សេចក្តីថា មិនបែក គឺ វៀរចាកទោស មានសេចក្តីបង្អែបង្អង់ដែលខ្ញុំនឃើញហើយជាដើម ។

បទថា **រកទោសមិនបាន** គឺ វៀរចាកការលេបទឹកមាត់ ។ ពិតហើយ កាលនរណាៗ កំពុងនិយាយ ទឹកមាត់ហូរចូល ឬថា ទឹកមាត់ហូរចេញ ឬថា ពពុះទឹកមាត់បែកខ្ទាតចេញមក វាចារបស់អ្នកនោះ ឈ្មោះថា សើមដោយទឹកមាត់ សេចក្តីថា វាចាដែលផ្ទុយគ្នានឹងវាចានោះ ។ បទថា **ឲ្យដឹងសេចក្តីបាន** គឺ អាចឲ្យដឹងសេចក្តីដែលពោលបាន ច្បាស់លាស់ទាំងខាងដើម កណ្តាល និងខាងចុង ។

បទថា **ចាស់ហើយ** គឺ ជាមនុស្សចាស់ ព្រោះជាអ្នកគ្រាំគ្រាដោយជរា ។ បទថា **ព្រឹទ្ធាចារ្យ** គឺ ដល់ទីបំផុតនៃសេចក្តីចម្រើនរបស់អវយវៈតូចធំ ។ បទថា **ភាពជាអ្នកធំ** គឺ ប្រកបព្រមដោយភាពជាអ្នកធំដោយជាតិ អធិប្បាយថា កើតមកយូរហើយ ។ បទថា **យូរណាស់មកហើយ** គឺ កន្លងវេលាយូរ អធិប្បាយថា កន្លងមកទាំង ២-៣ រជ្ជកាលហើយ ។ បទថា **មានវ័យកន្លងហើយ** គឺ កន្លងដល់បច្ឆិមវ័យហើយ ជាចំណែកទីបី ដែលជាទីបំផុតនៃ ១០០ ឆ្នាំ ឈ្មោះថា បច្ឆិមវ័យ ។

*ន័យមួយទៀត បទថា **ចាស់ហើយ** គឺ កើតយូរហើយ អធិប្បាយថា ប្រព្រឹត្តទៅតាមវង្សត្រកូល ដែលប្រព្រឹត្តទៅហើយអស់កាលយូរ ។ បទថា **ព្រឹទ្ធាចារ្យ** គឺ ប្រកបដោយសេចក្ដីចម្រើនដោយគុណ មានសីលនិងអាចារៈជាដើម ។ បទថា **ជាអ្នកធំ** គឺ ប្រកបព្រមដោយភាពជាអ្នកធំដោយសម្បត្តិ ។ បទថា **យូរណាស់មកហើយ** គឺ ធ្វើដំណើរមកបានដល់ មានប្រក្រតីមិនប្រព្រឹត្តកន្លងល្មើសមារយាទ មានវត្តចរិយាជាដើមរបស់ពួកព្រាហ្មណ៍ ។*

*បទថា **ចម្រើនវ័យហើយ** គឺ ដល់ចូលមកដល់ភាពជាអ្នកចម្រើនដោយជាតិ ដែលជាវ័យចុងក្រោយហើយ ។*

## ពុទ្ធគុណាកថា

[១៨២] *បទថា **កាលពួកព្រាហ្មណ៍ពោលយ៉ាងនេះហើយ** សេចក្ដីថា កាលពួកព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះហើយ សោណទណ្ឌព្រាហ្មណ៍គិតថា ពួកព្រាហ្មណ៍ទាំងនេះ ពោលសរសើរគុណរបស់យើងដោយជាតិជាដើម តែការដែលយើងនឹងត្រេកអរក្នុងការពោលសរសើរគុណរបស់ខ្លួនមិនសមគួរដល់យើងឡើយ ណ្ហើយចុះ យើងនឹងទម្លាយវាទៈរបស់ពួកគេចេញ ហើយឲ្យពួកគេដឹងថា ព្រះសមណគោតមជាអ្នកធំ និងធ្វើឲ្យពួកគេទៅក្នុងទីនោះ ដូច្នេះ ហើយទើបពោលពាក្យជាដើមថា លោកដ៏ចម្រើន*

បើដូច្នោះ សូមពួកលោកចូរស្តាប់ពាក្យរបស់ខ្ញុំខ្លះ ។ សោណទណ្ឌព្រាហ្មណ៍ សម្គាល់ឃើញគុណទាំងឡាយដ៏ក្រៃលែង ជាងគុណរបស់ខ្លួនថា ក្នុងគុណទាំងនោះ គុណសូម្បីពួកណា ដូចគ្នានឹងគុណរបស់ខ្លួនមានថា ឧភតោ-សុជាតជាដើម គុណសូម្បីទាំងនោះ ក៏ជាគុណ មានជាតិសម្បត្តិជាដើម របស់ព្រះសមណគោតម ដូច្នេះ ទើបបានប្រកាសគុណទាំងនេះ ដើម្បីនឹងសម្តែងដល់ព្រះដ៏មានព្រះភាគ មានព្រះគុណធំក្រៃលែងដោយចំណែកមួយដោយពិត ។

ក៏សោណទណ្ឌព្រាហ្មណ៍ កាលនឹងកំណត់យ៉ាងនេះថា មយមេវ ពួកយើងនោះឯងគួរទៅគាល់ ទើបសម្តែងពាក្យនេះ ក្នុងទីនេះថា បើមានបុគ្គលដែលគួរចូលទៅរក ព្រោះជាអ្នកមានគុណធំ ព្រោះដូច្នោះពួកយើងទុំះឯង គួរនឹងចូលទៅគាល់ដើម្បីទស្សនាព្រះគោតមដ៏ចម្រើននោះ ប្រៀបដូចគ្រាប់ស្ពៃ កាលនាំទៅប្រៀបធៀបនឹងភ្នំសិនេរុ ស្នាមជើងគោ កាលនាំទៅប្រៀបធៀបនឹងមហាសមុទ្រ តំណក់ទឹកសន្សើម កាលនាំទៅប្រៀបធៀបនឹងទឹកក្នុងស្រះធំទាំង ៧ ក៏ជារបស់តូច គឺ បន្តិចបន្តួច យ៉ាងណា គុណរបស់ពួកយើង កាលនាំទៅប្រៀបធៀបនឹង ព្រះគុណ មានព្រះជាតិសម្បត្តិជាដើម របស់ព្រះសមណគោតម ជារបស់តូច គឺ តិចតួច ដូច្នោះ ព្រោះដូច្នោះពួកយើងនោះឯង គួរទៅគាល់ព្រះគោតមដ៏ចម្រើន ។

បទថា **ទ្រង់លះបង់ពួកញាតិដ៏ច្រើន** គឺ ទ្រង់លះបង់ត្រកូល

ញាតិមួយសែនប្រាំមួយម៉ឺន យ៉ាងនេះ គឺ ចំណែកព្រះមាតា ៨ ម៉ឺន ចំណែកព្រះបិតា ៨ ម៉ឺន ។

ក្នុងបទនេះថា **ដែលឋិតនៅក្នុងផែនដី និងឋិតនៅឯអាកាស** ទ្រព្យដែលគេជីកស្រះបោក្ខរណី លាបកំបោរលោងក្នុងព្រះរាជវាំង និងក្នុងព្រះរាជឧទ្យាន ដាក់កែវ ៧ ប្រការ ដរាបពេញ ហើយកប់ទុកក្នុងផែនដី ឈ្មោះថា ទ្រព្យឋិតនៅក្នុងផែនដី ។ ចំណែកទ្រព្យដែលតាំងទុកដរាបពេញប្រសាទ និងប៉មជាដើម ឈ្មោះថា តាំងនៅក្នុងអាកាស ។ ទ្រព្យដែលមានមកតាមវង្សត្រកូល មានត្រឹមតែប៉ុណ្ណោះឯង ។ តែក្នុងថ្ងៃដែលព្រះតថាគតឧប្បត្តិឡើងហើយនុ៎ះឯង មានរណ្ដៅទ្រព្យ ៤ រណ្ដៅ គឺរណ្ដៅទ្រព្យឈ្មោះសង្ខ: ១ ឈ្មោះឯល: ១ ឈ្មោះឧប្បល: ១ ឈ្មោះបុណ្ឌរិក: ១ ផុសឡើងហើយ ។ បណ្ដារណ្ដៅទ្រព្យទាំង ៤ នោះ រណ្ដៅទ្រព្យឈ្មោះសង្ខ:មានមួយគាវុត រណ្ដៅទ្រព្យឈ្មោះឯល:មានកន្លះយោជន៍ រណ្ដៅទ្រព្យឈ្មោះឧប្បល:មានបីគាវុត រណ្ដៅទ្រព្យឈ្មោះបុណ្ឌរិក:មានមួយយោជន៍ ទ្រព្យដែលកាន់យកសូម្បីអំពីក្នុងរណ្ដៅទ្រព្យទាំងនោះ ក៏ត្រឡប់ពេញវិញ ។

គប្បីជ្រាបថា ព្រះដ៏មានព្រះភាគ ទ្រង់លះមាសប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ហើយចេញព្រះផ្នួស ដោយប្រការដូច្នេះ ។

បទថា **ទ្រង់នៅកម្លោះ** គឺ ទ្រង់នៅក្មេង ។ បទថា **មានព្រះកេសា**

**ខ្មៅស្រស់** គឺ មានព្រះកេសាខ្មៅក្រិប សេចក្ដីថា មានព្រះកេសាដូចគ្នានឹងពណ៌ថ្នាំបន្ដក់ភ្នែក ។

បទថា **ចម្រើន** គឺ ល្អ ។ បទថា **វ័យទីមួយ** គឺ បឋមវ័យក្នុងបណ្ដាវ័យទាំងបី ។

បទថា **មិនពេញព្រះទ័យ** គឺ មិនប្រាថ្នា ។ ពាក្យនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថថាអនាទរ ។ ទឹកភ្នែកត្រង់មុខរបស់ជនទាំងនោះមាន ហេតុនោះ គេឈ្មោះថា មនមុខជោកដោយទឹកភ្នែក ។ សេចក្ដីថា កាលព្រះមាតាបិតាទាំងនោះ មានព្រះភ័ក្ត្រជោកដោយទឹកព្រះនេត្រ គឺ មានព្រះភ័ក្ត្រសើមជោកដោយទឹកព្រះនេត្រ ។ បទថា **ទ្រង់ព្រះកន្សែង** គឺ ទ្រង់ព្រះកន្សែងទួញយំ ។

ក្នុងបទថា **ចន្លោះមិនមែនតិច** នេះ គប្បីជ្រាបសេចក្ដីថា ចន្លោះផ្លូវដែលនឹងបានឃើញព្រះដ៏មានព្រះភាគ រកប្រមាណមិនបាន ។ ក្នុងទីនេះ មានរឿងដូចតទៅនេះ ៖

បានឮថា ក្នុងក្រុងរាជគ្រឹះមានព្រាហ្មណ៍ម្នាក់ ជ្រាបថា គេដំណាលថា អ្នកណា ៗ រមែងមិនអាចនឹងកាន់យកប្រមាណ ចំពោះព្រះសមណគោតមបាន ក្នុងវេលាដែលព្រះដ៏មានព្រះភាគ ស្ដេចចូលទៅបិណ្ឌបាត កាន់យកឫស្សីប្រវែង ៦០ ហត្ថ ឈរខាងក្រៅទ្វារក្រុង កាលព្រះដ៏មានព្រះភាគស្ដេចមកដល់ បានកាន់យកឫស្សីបញ្ឈរក្នុងទីជិត ។ ឫស្សីមានប្រវែង

ត្រឹមព្រះជានុរបស់ព្រះដ៏មានព្រះភាគ ។ ក្នុងថ្ងៃស្អែក គេបានតបូស្សីពីរដើម ហើយបានកាន់ឈរក្នុងទីជិត ។ សូម្បីព្រះដ៏មានព្រះភាគ ក៏ទ្រង់ប្រាកដត្រឹមព្រះចង្កេះតែប៉ុណ្ណោះ លើបូស្សីពីរដើមនោះ ទើបត្រាស់ថា ព្រាហ្មណ៍លោកធ្វើអ្វី ។ គេទូលថា ខ្ញុំព្រះអង្គនឹងវាស់កម្ពស់កាយរបស់ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ព្រាហ្មណ៍ សូម្បីបើលោកតបូស្សីដែលមានក្នុងចក្រវាឡទាំងអស់ចូលជាមួយគ្នាក៏ដោយ លោកក៏មិនអាចវាស់តថាគតបាន ព្រោះថា បារមីរហូតអស់បួនអសង្ខេយ្យ និងសែនកប្បតថាគតមិនបានបំពេញដោយប្រការដែលអ្នកដទៃគប្បីនឹងវាស់តថាគតបាន ម្នាលព្រាហ្មណ៍ តថាគត នរណាៗ នឹងថ្លឹងមិនបាន នរណាៗ នឹងប្រមាណមិនបាន ដូច្នេះ ហើយត្រាស់គាថាក្នុងធម្មបទថា ៖

**កាលបូជាដល់អ្នកមានចិត្តត្រជាក់ហើយ មិនមានភ័យអំពីទីណាៗ ដូច្នោះ នរណាៗ មិនអាចរាប់បុណ្យបានថា មានត្រឹមប៉ុណ្ណេះ ដូច្នេះ ។**

ក្នុងទីបំផុតនៃគាថា សត្វ ៨៤.០០០ បានផឹកទឹកអម្រឹតហើយ ។

នៅមានរឿងសូម្បីដទៃទៀត ។ បានឮថា ស្តេចអសុរិន្ទរាហូខ្ពស់បាន ៤.៨០០យោជន៍ ។ ប្រវែងដៃរបស់គេវាស់បាន ១.២០០ យោជន៍ ចន្លោះដោះវាស់បាន ៦០០ យោជន៍ ។ ផ្ទៃបាតដៃ និងផ្ទៃបាតជើងក្រាស់បាន ៣០០ យោជន៍ ។ ម្រាមបាន ៥០ យោជន៍ ។ ចន្លោះចញ្ចើមប្រវែង

៥០ យោជន៍ ។ មុខប្រវែង ២០០ យោជន៍ ។ ជ្រៅបាន ៣០០ យោជន៍ ។ មានបរិមណ្ឌលបាន ៣០០ យោជន៍ ។ កប្រវែង ៣០០ យោជន៍ ។ ថ្ងាស់ទំហំ ៣០០ យោជន៍ ។ សីសៈប្រវែងបាន ៩០០ យោជន៍ ។ គេគិតថា យើងខ្ពស់ណាស់ មិនអាចនឹងបន្អោនខ្លួនចុះក្រឡេកមើលព្រះសាស្ដាបាន ដូច្នេះ ទើបមិនមកគាល់ ។ ថ្ងៃមួយគេបានស្ដាប់ព្រះគុណរបស់ព្រះដ៏-មានព្រះភាគ ទើបគិតថា យើងនឹងមើលដោយអាការបែបណាហ្ន៎ ។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបអធ្យាស្រ័យរបស់គេហើយ ទ្រង់ត្រិះរិះថា តថាគតនឹងសម្ដែងដោយឥរិយាបថណា ក្នុងបណ្ដាឥរិយាបថទាំងបួន ទ្រង់ត្រិះរិះថា ធម្មតាអ្នកឈរ សូម្បីនឹងទាបក៏ប្រាកដដូចជាអ្នកខ្ពស់ តែតថាគតនឹងដេកសម្ដែងខ្លួនដល់គេ ដូច្នេះ ហើយទើបត្រាស់ថា អានន្ទ អ្នកចូររៀបចំគ្រែក្នុងបរិវេណគន្ធកុដិ ហើយទ្រង់សម្រេចសីហសេយ្យាលើគ្រែនោះ ។ អសុរិន្ទរាហូមកហើយ អើតកឡើងសម្លឹងមើលព្រះដ៏-មានព្រះភាគប្រថាប់ផ្ទំ ហាក់បីដូចជាព្រះចន្ទពេញវង់ត្រង់កណ្ដាលផ្ទៃអាកាស និងកាលព្រះដ៏មានព្រះភាគ ត្រាស់ថា អសុរិន្ទៈ នេះអ្វី ទើបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានមកគាល់ដោយគិតថា យើងមិនអាចនឹងបន្អោនខ្លួនចុះក្រឡេកមើលបាន ដូច្នេះ ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា អសុរិន្ទៈ តថាគតមិនបានឱនមុខបំពេញបារមីទេ តថាគតឲ្យទានធ្វើឲ្យជាកំពូល ដូច្នេះ ។ ថ្ងៃនោះ អសុរិន្ទរាហូ បានដល់សរណៈ ។

ព្រះដ៏មានព្រះភាគ ទ្រង់គួរមើល គួរសរសើរមិនមែនតិច ដោយប្រការដូច្នេះ ។

បុគ្គលឈ្មោះថា មានសីល ព្រោះបារិសុទ្ធិសីល ៤ ក៏សីលនោះជារបស់ប្រសើរ គឺ ខ្ពង់ខ្ពស់ បានដល់ ជាសីលបរិសុទ្ធិ ព្រោះហេតុនោះ លោកទើបពោលថា មានសីលដ៏ប្រសើរ ។ សីលនោះឯង ជាកុសល ព្រោះអត្ថថា មិនមានទោស ព្រោះហេតុនោះ លោកទើបពោលថា មានសីលជាកុសល ។ ពាក្យថា ដោយសីលជាកុសលនេះ ជាវេវចនៈរបស់ពាក្យថា មានសីលជាកុសលនោះ ។

បទថា **ជាអាចារ្យ និងបាចារ្យ** របស់ជនជាច្រើន សេចក្តីថា ក្នុងការសម្តែងធម៌មួយលើកៗ របស់ព្រះដ៏មានព្រះភាគ សត្វមានប្រមាណ ៨៤.០០០ និងទេវតា និងមនុស្សទាំងឡាយរកប្រមាណមិនបាន រមែងបានផឹកទឹកអម្រឹត គឺ មគ្គ និងផល ព្រោះដូច្នោះ ព្រះអង្គទើបចាត់ថា ជាអាចារ្យរបស់ជនជាច្រើន និងជាបាចារ្យរបស់សាវកដែលជាវេនេយ្យ ។

ក្នុងបទថា **កាមរាគៈទៅប្រាសហើយ** សេចក្តីថា កិលេសទាំងពួងរបស់ព្រះដ៏មានព្រះភាគទៅប្រាសហើយដោយពិត ។ តែព្រាហ្មណ៍មិនដឹងកិលេសទាំងនោះ ទើបពោលគុណនៅក្នុងឋានៈនៃសេចក្តីដឹងរបស់ខ្លួនប៉ុណ្ណោះឯង ។ បទថា **ឈប់ប្រដាប់តាក់តែងហើយ** គឺ វៀរចាកការប្រដាប់តាក់តែងកាយ ដែលលោកពោលទុកយ៉ាងនេះថា ការតាក់តែងបាត្រ ការ

គាក់តែងចីវរ ការគាក់តែងសេនាសនៈ ការស្អិតស្អាងនូវកាយដ៏ស្អុយនេះ ។

បទថា **ទ្រង់មិនប្រទូសរ៉ាយ** គឺ សម្តែងការគោរពព្រះធម៌ ដែលមិនជាបាប គឺ លោកុត្តរធម៌ ៩ ។ បទថា **ដល់ប្រជាជនដែលជាព្រាហ្មណ៍** គឺ ដល់បុគ្គលដែលជាព្រាហ្មណ៍ផ្សេងៗ គ្នា ជាដើមថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហាកស្សបៈ និងព្រះអគ្គ ជាអ្នកសម្តែងសេចក្តីរាប់អានអំពីប្រជាជននោះ អធិប្បាយថា ក៏ប្រជាជននេះ ធ្វើព្រះសមណគោតមទុកខាងមុខ ឲ្យប្រព្រឹត្តទៅ ។ ប្រការមួយទៀត បទថា **ទ្រង់មិនប្រទូសរ៉ាយ** សេចក្តីថា ទ្រង់មិនធ្វើបាបទុកខាងមុខ គឺ មិនប្រាថ្នាលាមក អធិប្បាយថា ទ្រង់មិនបំណងប្រទូស្តចំពោះប្រជាជន ដែលជាព្រាហ្មណ៍នោះ គឺ ចំពោះប្រជាជនដែលជាព្រាហ្មណ៍ សូម្បីនឹងជាបដិបក្ខនឹង គឺ ជាអ្នកប្រាថ្នាប្រយោជន៍សុខតែតែម្យ៉ាង ។

បទថា **រដ្ឋផ្សេងៗ** គឺ ពីរដ្ឋដទៃ ។ បទថា **ជនបទផ្សេងៗ** គឺ ពីជនបទដទៃ បទថា **នាំគ្នាមកសាកសួរបញ្ហា** សេចក្តីថា ក្សត្រិយ៍ និងបណ្ឌិតជាដើមក្តី ទេវតា ព្រហ្ម នាគ និងគន្ធព្វក្តី ត្រៀមបញ្ហាផ្សេងៗ មកគាល់ ដោយគិតថា ពួកយើងនឹងសួរ ។ ក្នុងបណ្តាជនទាំងនោះ ពួកខ្លះកំណត់ឃើញទោសនៃការសួរ ឬសេចក្តីដែលខ្លួនមិនមានសមត្ថភាពក្នុងការព្រមទទួលចម្លើយ ទើបមិនទូលសួរឡើយ ហើយអង្គុយនៅស្ងៀម ពួកខ្លះទូលសួរ ចំណែកពួកខ្លះ ព្រះមានព្រះភាគទ្រង់ឲ្យកើតសេចក្តីឧស្សាហ៍

ក្នុងការសួរ ទើបទ្រង់ធ្វើសេចក្ដីងឿងឆ្ងល់របស់ជនទាំងនោះ សូម្បីទាំងអស់ មកដល់ព្រះដ៏មានព្រះភាគហើយ ក៏សាបសូន្យបាត់ទៅ ដូចរលកក្នុងមហាសមុទ្រមកដល់ច្រាំងហើយ ក៏រលាយបាត់ទៅដូច្នោះ ដោយប្រការដូច្នេះ ។

បទថា **មានប្រក្រតីពោលស្វាគមន៍** សេចក្ដីថា ព្រះអង្គរមែងត្រាស់ចំពោះអ្នកមកកាន់សំណាក់របស់ព្រះអង្គនោះ ៗ មិនថា ជាទេវតា មនុស្ស បព្វជិត និងគ្រហស្ថ យ៉ាងនេះថា អ្នកចូរមកចុះ មកល្អហើយ (តថាគតសូមទទួលលោក) ដូច្នេះ ។ បទថា **ទ្រង់មានព្រះវាចាចងមេត្រី** គឺទ្រង់ប្រកបព្រមដោយព្រះតម្រាស់ចងមេត្រី ដែលលោកពោលទុកដោយន័យជាដើមថា បណ្ដាវាចាទាំងនោះ ពាក្យនិយាយចងមេត្រីដូចម្ដេច ? ពាក្យនិយាយចងមេត្រី គឺ វាចាដែលរកទោសមិនបាន វាចាល្អ ពីរោះដល់ត្រចៀក ដូច្នេះ អធិប្បាយថា មានព្រះតម្រាស់ទន់ភ្លន់ ។ បទថា **ទ្រង់ទទួលរាក់ទាក់** គឺ ទ្រង់ឆ្លាតក្នុងការបដិសណ្ឋារៈ សេចក្ដីថា ព្រះអង្គទ្រង់ធ្វើសម្មោទនីយកថាមុនតែម្ដង ដូចទ្រង់រម្ងាប់សេចក្ដីខ្វល់ខ្វាយ ព្រោះការដើរផ្លូវឆ្ងាយរបស់ពួកបរិស័ទទាំងបួន អ្នកមកហើយៗ ឲ្យអស់ទៅ ដោយន័យជាដើមថា ភិក្ខុ អ្នកសប្បាយរីករាយទេឬ ការឆាន់អាហារល្មមប្រព្រឹត្តបានទេឬ ។ បទថា **ព្រះភក្ត្រមិនក្រញូវ** សេចក្ដីថា អ្នកខ្លះចូលទៅកាន់ទីប្រជុំហើយមានមុខក្រញូវ មានមុខមិនស្រស់ស្រាយ យ៉ាង

ណា ព្រះអង្គមិនបានជាដូច្នោះ ។ តែកាលឃើញព្រះភក្ត្ររបស់ព្រះមាន-ព្រះភាគនោះ ដូចជាផ្កាបទុមដែលរីកដោយត្រូវពន្លឺថ្ងៃស្រទន់ ឬហាក់បីដូចជារស្មីនៃព្រះចន្ទពេញវង់ ។

បទថា **មានព្រះភក្ត្ររីករាយ** សេចក្ដីថា លោកសម្ដែងទុកថា មនុស្សជំពូកខ្លះមានមុខឱនចុះ កាលជំនុំជនមកប្រជុំគ្នាហើយ ក៏មិននិយាយអ្វី ជាអ្នកដែលមានពាក្យនិយាយបានដោយលំបាក យ៉ាងណា តែព្រះសមណគោតមមិនជាដូច្នោះ ព្រះអង្គជាអ្នកមានព្រះវាចាបានដោយងាយសម្រាប់អ្នកដែលមកកាន់សំណាក់របស់ព្រះអង្គ មិនកើតសេចក្ដីក្ដៅក្រហាយចិត្តថា ពួកយើងមកក្នុងទីនេះ ព្រោះហេតុណា តែជនទាំងឡាយបានស្ដាប់ធម៌ហើយ រមែងមានចិត្តត្រេកអរដោយពិត ។ បទថា **មានប្រក្រតីត្រាស់មុន** គឺ ព្រះអង្គកាលនឹងត្រាស់ រមែងត្រាស់មុន និងព្រះតម្រាស់ក៏ប្រកបដោយកាល ។ ព្រះអង្គ ក៏ត្រាស់តែពាក្យដោយប្រមាណ អាស្រ័យប្រយោជន៍ដោយពិត មិនត្រាស់ពាក្យដែលរកប្រយោជន៍មិនបាន ។

បទថា **ក្នុងស្រុកនោះឬ** សេចក្ដីថា បានឮថា ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីណា ទេវតាអ្នកមានសក្តិធំរមែងថ្វាយការរក្សា ។ ព្រោះអាស្រ័យទេវតាទាំងនោះ ឧបទ្រវៈរមែងមិនមានដល់មនុស្សទាំងឡាយ ។ ក៏បិសាចទាំងឡាយ មានបិសាចប្រឡាក់ធូលីជាដើម រមែងបៀតបៀនមនុស្ស ។ បិសាចទាំងនោះ រមែងចៀសទៅឆ្ងាយដោយអានុភាពរបស់

ទេវតាទាំងនោះ ។ មួយវិញទៀត សូម្បីព្រោះកម្លាំងនៃព្រះមេត្តារបស់ព្រះដ៏មានព្រះភាគ ពួកអមនុស្សក៏មិនបៀតបៀនមនុស្ស ។

ក្នុងបទទាំងឡាយមានបទថា **ជាមេពួកជាដើម** សេចក្តីថា ពួកអ្នកដែលគប្បីទូន្មាន ឬដែលអ្នកឲ្យកើតឯងរបស់បុគ្គលនោះមានហើយ ហេតុនោះគេឈ្មោះថា មេពួក ។ មួយទៀត គណៈរបស់បុគ្គលនោះមាន ហេតុនោះគេឈ្មោះថា ជាគណៈ ។

មួយទៀត ពាក្យនេះជាវេវចនៈរបស់បទដំបូង ។ ព្រះអង្គទ្រង់ជាអាចារ្យរបស់គណៈ ដោយអំណាចនៃការឲ្យគេសិក្សាក្នុងអាចារៈ ហេតុនោះ ទើបឈ្មោះថា ជាគណាចារ្យ ។ បទថា **នៃម្ចាស់លទ្ធិដ៏ច្រើន** គឺ នៃម្ចាស់លទ្ធិចំនួនច្រើន ។

បទថា **ដោយប្រការណាមួយ** គឺ ដោយហេតុសូម្បីត្រឹមតែមួយថា មិនស្លៀកសំពត់ជាដើមណាមួយ បទថា **រមែងរុងរឿង** គឺ រមែងចូលទៅដល់ដោយជុំវិញ បានដល់ ចម្រើនក្រៃលែងឡើង ។

បទថា **គេទាំងនោះជាភ្ញៀវ** សេចក្តីថា គេទាំងនោះជាអាគន្តុកៈ គឺជាភ្ញៀវថ្មីរបស់ពួកយើង ។ បទថា **វៀនដឹង** គឺ ដឹងច្បាស់ ។ ដោយបទថា **មានព្រះគុណដែលគប្បីរាប់មិនបាន** សោណទណ្ឌព្រាហ្មណ៍សម្តែងថា មានព្រះគុណដែលរកអ្វីប្រៀបផ្ទឹមមិនបាន សូម្បីដោយព្រះសព្វញ្ញូបែបនោះ នឹងចាំបាច់ពោលថ្វីដល់បុគ្គលដូចយើង ។ សមពិតដូចដែល

លោកពោលទុកថា ៖

> **សូម្បីព្រះពុទ្ធ ត្រាស់ព្រះគុណរបស់ព្រះពុទ្ធ មិនត្រាស់យ៉ាងដទៃឡើយក្នុងកប្បមួយ ក៏នឹងគប្បីអស់ទៅក្នុងចន្លោះ ជាវេលាយូរ ព្រះគុណរបស់ព្រះតថាគតមិនអស់ទៅទេ ដូច្នេះ ។**

[១៨៣] ក៏ពួកព្រាហ្មណ៍ទាំងនោះ បានស្តាប់គុណកថា របស់ព្រះសាស្តានេះហើយ នាំគ្នាគិតថា សោណទណ្ឌព្រាហ្មណ៍ ពោលគុណរបស់ព្រះសមណគោតម ព្រះគោតមដ៏ចម្រើននោះ មានព្រះគុណរកប្រមាណមិនបាន ក៏ឯអាចារ្យអ្នកដឹងគុណរបស់ព្រះគោតមនោះ យ៉ាងនេះបានទទួលនូវផលយូរណាស់ហើយ ណ្ហើយចុះ ពួកយើងនឹងបណ្តោយតាមគេ ដូច្នេះ ក៏បណ្តោយតាមហើយ ។ ព្រោះដូច្នោះ លោកទើបពោលថា កាលសោណទណ្ឌព្រាហ្មណ៍ពោលយ៉ាងនេះហើយ ពួកព្រាហ្មណ៍ទាំងនោះដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សមគួរតែម្យ៉ាង** គឺ គួរតែម្យ៉ាង ។ បទថា **សូម្បីដោយស្បៀង** , ស្បៀងអាហារ លោកហៅថា ចុងដោស សេចក្តីថា សូម្បីនឹងកាន់ស្បៀងនោះយកទៅគាល់ ក៏គួរ ។ បាលីថា បដំសេន ដូច្នេះក៏មាន ។ បទនោះមានអធិប្បាយថា កញ្ចប់អ៊ីវ៉ាន់លើស្មារបស់បុគ្គលនោះមានហើយ ហេតុនោះ គេឈ្មោះថា មានកញ្ចប់អ៊ីវ៉ាន់

លើស្មា ។ ដោយស្មាមានកញ្ចប់អ៊ីវ៉ាន់នោះ ។ មានអធិប្បាយថា ដោយស្មាដែលលីស្បៀងទៅ ដូច្នេះក៏មាន ។

## សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍

បទថា **ចូលផុតអំពីជង់ព្រៃហើយ** គឺ អ្នកទៅកាន់ក្នុងជង់ព្រៃ អធិប្បាយថា អ្នកចូលទៅកាន់ខាងក្នុងវិហារហើយ ។

[១៨៤] បទថា **បណាមេ្យអញ្ជលី** សេចក្តីថា ពួកព្រាហ្មណ៍ដែលមានពីរផ្នែកគិតយ៉ាងនេះថា សួម្បីថា ពួកមិច្ឆាទិដ្ឋិនឹងប្រចាំងពួកយើងថា ព្រោះហេតុអ្វី ពួកលោកទើបថ្វាយបង្គំព្រះសមណគោតម ពួកយើងនឹងពោលដល់គេថា សួម្បីដោយការធ្វើត្រឹមតែអញ្ជលី ក៏ឈ្មោះថា ថ្វាយបង្គំដែរឬ បើថា ពួកសម្មាទិដ្ឋិនឹងប្រចាំងពួកយើងថា ព្រោះហេតុណាពួកលោកទើបមិនថ្វាយបង្គំព្រះដ៏មានព្រះភាគ ពួកយើងនឹងប្រាប់ថា ការយកសីសៈប៉ះខ្ទប់ផ្ទៃផែនដីទុំះឯង ទើបនឹងជាការសំពះឬ សួម្បីការធ្វើអញ្ជលី ក៏ឈ្មោះថា ការសំពះដូចគ្នាមិនមែនឬ ។

បទថា **ឈ្មោះ និងគោត្រ** សេចក្តីថា ពួកព្រាហ្មណ៍កាលក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាបុត្ររបស់អ្នកឈ្មោះឯណោះ ឈ្មោះទត្តៈ ឈ្មោះមិត្តៈ មកក្នុងទីនេះ ដូច្នេះ ឈ្មោះថាប្រកាសឈ្មោះ ពាក្យដែលពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ

ឈ្មោះវាសេដ្ឋ: ឈ្មោះកច្ចាន: មកក្នុងទីនេះដូច្នេះ ឈ្មោះថា ប្រកាសគោត្រ ។ បានឮថា ពួកព្រាហ្មណ៍ទាំងនោះ ជាកុលបុត្រដែលលំបាកដរាបដល់ចាស់ បានធ្វើយ៉ាងនេះ ក្នុងកណ្ដាលទីប្រជុំ ដោយគិតថា ពួកយើងនឹងប្រាកដដោយអំណាចនៃឈ្មោះ និងគោត្រ ។

ចំណែកព្រាហ្មណ៍ពួកណា អង្គុយនៅស្ងៀម ព្រាហ្មណ៍ទាំងនោះជាពួកបោកបញ្ឆោត និងជាអន្ធពាល ។ បណ្ដាព្រាហ្មណ៍ពីរពួកនោះ ពួកព្រាហ្មណ៍ដែលបោកបញ្ឆោតគិតថា បុគ្គលកាលធ្វើសម្បីការជជែកគ្នា ត្រឹមតែពាក្យពីរម៉ាត់ក៏ជិតដិតគ្នាបាន ក្រោយមកកាលមានភាពជិតដិតគ្នាហើយនឹងមិនឲ្យកិក្ខាហារ ១-២ ពំនូត មិនគួរ ដូច្នេះ គេចវេះខ្លួនចាកការជិតដិតនោះ ទើបអង្គុយនៅស្ងៀម ។ ពួកព្រាហ្មណ៍ដែលជាអន្ធពាល ព្រោះហេតុដែលមិនដឹងអ្វីទាំងឯង ទើបអង្គុយនៅស្ងៀម មិនថាក្នុងទីណាៗ ដូចជាដុំដីស្អិត ដែលគេគ្រវែងចោលហើយ ។

## ការបញ្ញត្តិថា ជាព្រាហ្មណ៍

[១៨៥] បទថា **ការត្រិះរិះក្នុងចិត្តដោយព្រះទ័យ** សេចក្ដីថា ព្រះដ៏មានព្រះភាគទ្រង់ពិចារណាមើលថា ព្រាហ្មណ៍នេះ ចាប់ផ្ដើមតាំងពីកាលដែលខ្លួនមកហើយ ឱនមុខ មានខ្លួនរីង អង្គុយគិតអ្វី កំពុងគិតអ្វីហ្ន៎ ក៏បានទ្រង់ជ្រាបចិត្តរបស់ព្រាហ្មណ៍នោះ ដោយព្រះទ័យរបស់ព្រះអង្គ ព្រោះ

ហេតុនោះ ទើបលោកពោលថា ទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្តដោយព្រះទ័យ ដូច្នេះ ។ បទថា **រមែងក្តៅក្រហាយ** គឺ លំបាកចិត្ត ។

[១៨៦] បទថា **ត្រាច់ទៅមើលជំនុំជន** សេចក្តីថា សោណទណ្ឌ-ព្រាហ្មណ៍ មានកាយ និងចិត្តស្ងប់រម្ងាប់ហើយ ហាក់បីដូចលិចចុះក្នុងទឹកដោយការត្រាស់សួរបញ្ហាក្នុងលទ្ធិរបស់ខ្លួន ត្រូវព្រះដ៏មានព្រះភាគ ទ្រង់លើកឡើងដាក់លើគោក ដូចជានឹងពោលថា សូមលោកដ៏ចម្រើនចូរពិចារណាមើលពាក្យនិយាយរបស់ខ្ញុំព្រះអង្គ ដោយការសញ្ជូរទៅនៃទិដ្ឋិសូម្បីដើម្បីសង្គ្រោះជំនុំជន ដូច្នេះ ហើយក្រឡេកមើលជំនុំជន បានក្រាបទូលពាក្យនោះចំពោះព្រះដ៏មានព្រះភាគ ។

បទថា **អ្នកទទួលការបូជា** សេចក្តីថា ជាអ្នកទី ១ ឬទី ២ ក្នុងបណ្តាព្រាហ្មណ៍ដែលទទួលការបូជា ដើម្បីប្រយោជន៍ដល់ការបូជាយញ្ញ ។ បុរាណាចារ្យពោលថា អ្នកទទួលការបូជាយញ្ញធំ ដែលគេឲ្យហើយដើម្បីបូជា ។ ព្រាហ្មណ៍ឆ្លើយបញ្ហាត្រឹមត្រូវពិត ដោយអំណាចលទ្ធិរបស់ខ្លួនដោយប្រការដូច្នេះ ។

[**១៨៧-១៨៩**] តែព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងដល់ព្រាហ្មណ៍ដ៏ប្រសើរជាពិសេស ទើបត្រាស់ព្រះតម្រាស់ជាដើមថា ឥមេសំ បន ដូច្នេះ ។

[១៩០] បទថា **ពួកព្រាហ្មណ៍បានពោលពាក្យនេះ** សេចក្តីថា ពួកព្រាហ្មណ៍គិតថា បើព្រាហ្មណ៍អ្នកសម្បូរណ៍ដោយជាតិ វណ្ណៈ និង

មន្តមិនមាន កាលបើដូច្នោះ នរណាហ្ន៎នឹងជាព្រាហ្មណ៍ក្នុងលោក សោណទណ្ឌព្រាហ្មណ៍នេះ ធ្វើឲ្យពួកយើងវិនាស ណ្ហើយចុះ យើងនឹងពោលជំទាស់វាទៈរបស់គេ ដូច្នេះ ទើបបានពោលពាក្យនេះ ។ បទថា **ពោលលុបគុណ** គឺ ពោលប្រឆាំងតទល់ ។ បទថា **ពោលបណ្តោយតាមទៅ** ។ ពួកព្រាហ្មណ៍ពោលពាក្យនេះដោយមានបំណងថា បើលោកប្រាថ្នានឹងដល់ព្រះសមណគោតមជាទីពឹងដោយអំណាចនៃសេចក្តីជ្រះថ្លា លោកចូរចេញទៅ កុំមកទម្លាយលទ្ធិរបស់ព្រាហ្មណ៍ឡើយ ដូច្នេះ ។

បទថា **បានត្រាស់តម្រាស់នេះ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា កាលពួកព្រាហ្មណ៍ទាំងនេះវិវាទគ្នា មានសម្លេងតែមួយយ៉ាងនេះ កថានេះនឹងមិនដល់ទីបំផុតបាន ណ្ហើយចុះ តថាគតនឹងធ្វើឲ្យពួកគេស្ងៀមស្ងាត់ ហើយនិយាយនឹងសោណទណ្ឌព្រាហ្មណ៍ប៉ុណ្ណោះ ដូច្នេះហើយ ទើបបានត្រាស់ព្រះតម្រាស់នេះថា សចេ ខោ តុម្ហាកំ ជាដើម ។

[១៩១] បទថា **ប្រកបដោយធម៌** គឺ ប្រកបដោយហេតុ ។

[១៩២] បទថា **មានវណ្ណៈដូចគ្នា** គឺ ស្មើដោយភាពជាអ្នកដូចគ្នា វៀរលែងតែភាពជាអ្នកស្មើគ្នាដោយឯកទេស អធិប្បាយថា ស្មើគ្នាដោយអាការទាំងពួង ។ បទថា **យើងដឹងមាតា និងបិតារបស់គេ** គឺ គេមិនដឹងមាតា និងបិតារបស់ប្អូនស្រីបានយ៉ាងណា គេពោលសំដៅដល់ការសម្តែងលំដាប់ត្រកូលផ្សេងៗ ។ បទថា **គប្បីពោលកុហកខ្លះ** គឺ គប្បី

ពោលពាក្យកុហកដែលកាត់បង់នូវប្រយោជន៍ ។ បទថា **វណ្ណៈនឹងធ្វើអ្វីបាន** គឺ កាលគុណដែលសេចក្ដីល្អខាងក្នុងមិនមាន វណ្ណៈនឹងធ្វើអ្វីបាន អធិប្បាយថា គេនឹងអាចរក្សាភាពជាព្រាហ្មណ៍របស់គេទុកបានយ៉ាងណា ។ សូម្បីបើនឹងគប្បីមានទៀត កាលព្រាហ្មណ៍អ្នកតាំងនៅក្នុងបកតីសីលអង្គដទៃៗ ក៏ញុំាងភាពជាព្រាហ្មណ៍ឲ្យសម្រេចបាន ព្រោះសីលតែម្យ៉ាងក៏ឲ្យសម្រេចជាព្រាហ្មណ៍បានយ៉ាងនេះ ក៏គ្រាបកតីសីលនោះរបស់គេមិនមាន ភាពជាព្រាហ្មណ៍ក៏មិនមាន ព្រោះដូច្នោះ អង្គទាំងឡាយ មានវណ្ណៈជាដើម ជាវត្ថុល្ងង់ ។

ក៏ព្រាហ្មណ៍ទាំងឡាយ បានឮពាក្យនេះហើយ បានជាអ្នកនៅស្ងៀមដោយគិតថា អាចារ្យពោលត្រឹមត្រូវ និងពួកយើងពោលទោសដោយគ្មានហេតុ ។

## ពោលអំពីសីល និងបញ្ញា

**[១៩៣]** លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលព្រាហ្មណ៍ពោលឆ្លើយបញ្ហាហើយ ដើម្បីនឹងទ្រង់សាកល្បងគេថា ក៏ក្នុងសេចក្ដីនេះនឹងអាចបញ្ជាក់ឲ្យច្បាស់ ឬមិនអាចទេ ទើបបានត្រាស់ព្រះតម្រាស់ថា ឥមេសំ បន ព្រាហ្មណា ជាដើម ។

បទថា **ជម្រះសីលឲ្យបរិសុទ្ធិ** គឺ បរិសុទ្ធិបានព្រោះសីល ។ បទថា

យត្ថ សីលំ តត្ថ បញ្ញា សីលមានក្នុងទីណា បញ្ញាក៏មានក្នុងទីនោះ គឺសីលមានក្នុងបុគ្គលណា បញ្ញាក៏មានក្នុងបុគ្គលនោះ ។ ក្នុងបុគ្គលដែលទ្រុស្តសីល បញ្ញានឹងមានមកពីទីណា ឬថាក្នុងបុគ្គលដែលវៀរចាកបញ្ញា ដែលល្ងង់ខ្លៅ ដែលថ្លង់ផងគផង សីលនឹងមានមកពីទីណា បទថា សីលនិងបញ្ញា គឺ សីលផង បញ្ញាផង ឈ្មោះថា សីលប្បញ្ញា បទថា បញ្ញាណំ គឺ បញ្ញានុ៎ះឯង ។

**[១៩៤]** ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ព្រមទទួលពាក្យនិយាយរបស់ព្រាហ្មណ៍ ទើបបានត្រាស់ថា ព្រាហ្មណ៍ សេចក្តីនោះយ៉ាងហ្នឹងហើយ ។ បណ្តាទាំងនោះ បទថា **បញ្ញាដែលសីលជម្រះឲ្យបរិសុទ្ធិហើយ** គឺ ដែលបារិសុទ្ធិសីល ៤ ជម្រះហើយ ។ សួរថា **បុគ្គលរមែងជម្រះបញ្ញាដោយសីលយ៉ាងណា** ។ ឆ្លើយថា សីលរបស់បុថុជ្ជនណា មិនដាច់មិនធ្លុះធ្លាយរហូតអស់ ៦០ ឆ្នាំ និង ៨០ ឆ្នាំ សូម្បីក្នុងវេលាដល់កម្ម គេសម្លាប់កិលេសទាំងអស់បាន ជម្រះបញ្ញាដោយសីល ហើយកាន់យកព្រះអរហត្តបាន ដូចព្រះមហាសដ្ឋិវស្សត្ថេរៈ នៅក្នុងបរិវេណដើមសាលៈក្នុងញកក្ន ដូច្នោះ ។

បានឮថា កាលព្រះថេរៈដេកនៅលើគ្រែដែលនឹងមរណភាព ស្រែកថ្ងូរព្រោះវេទនាខ្លាំងក្លា តិស្សវេសកមហារាជ ស្តេចទៅដោយទ្រង់ត្រិះរិះថា យើងនឹងសួរសុខទុក្ខព្រះថេរៈ ហើយប្រថាប់ឈរត្រង់ទ្វារបរិវេណ

ទ្រង់ស្តាប់សម្លេងនោះ ទើបត្រាស់សួរថា នេះសម្លេងរបស់អ្នកណា ។ សម្លេងស្រែកថ្ងូររបស់ព្រះថេរៈ ភិក្ខុកម្លោះអ្នកឧបដ្ឋាកទូល ។ ព្រះអង្គទ្រង់ត្រិះរិះថា ព្រះថេរៈមានវស្សាដល់ ៦០ ដោយការបព្វជ្ជា មិនបានធ្វើសុបិ្ប ត្រឹមតែការកំណត់ដឹងវេទនា ឥឡូវនេះ យើងនឹងមិនសំពះលោកទេ ដូច្នេះហើយ ស្តេចត្រឡប់ទៅនមស្ការដើមមហាពោធិ ។ លំដាប់នោះភិក្ខុកម្លោះអ្នកឧបដ្ឋាក ទើបនិយាយនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដូចម្តេច លោកទើបធ្វើឲ្យពួកខ្ញុំបានទទួលសេចក្តីអៀនខ្មាសព្រះរាជាទាំងដែលទ្រង់មានសទ្ធា ញាំងទ្រង់បដិសារស្តេចចេញទៅ ដោយទ្រង់ត្រិះរិះថា យើងនឹងមិនសំពះ ។ ព្រះថេរៈពោលថា ព្រោះហេតុណាអ្នកមានអាយុ ។ ភិក្ខុកម្លោះអ្នកឧបដ្ឋាកឆ្លើយថា ព្រោះទ្រង់ស្តាប់សម្លេងស្រែកថ្ងូររបស់លោក ព្រះថេរៈពោលថា បើដូច្នោះពួកលោកចូរឲ្យឱកាសដល់យើង ដូច្នេះហើយ គ្របសង្កត់វេទនានោះ បានសម្រេចព្រះអរហត្តទើបឲ្យសញ្ញាដល់ភិក្ខុកម្លោះថា អ្នកមានអាយុ លោកចូរទៅឥឡូវនេះ លោកចូរឲ្យព្រះរាជាមកសំពះយើងបានហើយ ។ ភិក្ខុកម្លោះទៅហើយទូលថា ន័យថា ឥឡូវនេះ សូមព្រះអង្គទ្រង់សំពះព្រះថេរៈចុះ ព្រះរាជាកាលនឹងទ្រង់សំពះព្រះថេរៈដោយការដេកទ្រាប ដូចក្រពើ ទើបត្រាស់ថា ខ្ញុំករុណា មិនបានសំពះព្រះអរហត្តរបស់លោកម្ចាស់ទេ តែសំពះលោកម្ចាស់ដែលតាំងនៅក្នុងភូមិនៃបុថុជ្ជន តែរក្សាសីលទេតើ ដូច្នេះ ។ បុគ្គល

ឈ្មោះថា ជម្រះបញ្ញាដោយសីល ដោយប្រការដូច្នេះ ។

ក៏ក្នុងខាងក្នុងរបស់អ្នកណា ការសង្រួមក្នុងសីលមិនមាន តែព្រោះហេតុជាអ្នកដឹងខ្លួនឆាប់រហ័ស ក្នុងទីបំផុតនៃគាថាប្រកបដោយបួនបទ គេនោះជម្រះសីលដោយបញ្ញាហើយ សម្រេចអរហត្តព្រមដោយបដិសម្ភិទា ។ អ្នកនេះឈ្មោះថា ជម្រះសីលដោយបញ្ញា ដូចសន្តតិមហាអាមាត្យ ។

ព្រោះហេតុណា ទើបព្រះដ៏មានព្រះភាគត្រាស់ថា ព្រាហ្មណ៍ ចុះសីលនោះដូចម្ដេច បានឮថា ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ព្រាហ្មណ៍ទាំងឡាយរមែងបញ្ញត្តសីល ៥ ថាជាសីល រមែងបញ្ញត្តការដឹងជុំវិញក្នុងត្រៃទេវថា ជាបញ្ញាក្នុងលទ្ធិរបស់ព្រាហ្មណ៍ មិនដឹងវត្ថុដែលវិសេសក្រៃលែងទៅ បើកាលណា តថាគតគប្បីសម្ដែងមគ្គសីល ផលសីល មគ្គបញ្ញា និងផលបញ្ញា ដែលជារបស់វិសេសក្រៃលែងដល់ព្រាហ្មណ៍ គប្បីឲ្យទេសនាចប់ស្រេចដល់កំពូល គឺ អរហត្ត ដូច្នេះ ។ លំដាប់នោះព្រះអង្គកាលនឹងត្រាស់សួរព្រាហ្មណ៍ដោយកថេតុកាម្យតាបុច្ឆា (សួរដោយមានព្រះបំណងនឹងទ្រង់ឆ្លើយដោយព្រះអង្គឯង) ទើបត្រាស់ថា ព្រាហ្មណ៍ សីលនោះដូចម្ដេច បញ្ញានោះដូចម្ដេច ដូច្នេះ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា បញ្ហាយើងឆ្លើយហើយ ដោយអំណាចនៃលទ្ធិរបស់ខ្លួន តែព្រះសមណគោតមត្រឡប់ជាសាកសួរយើងទៀត ឥឡូវនេះ យើងនឹងគប្បីឆ្លើយបញ្ហា ធ្វើឲ្យព្រះទ័យរបស់ព្រះអង្គ

ត្រេកអរ ឬមិនអាច បើយើងនឹងមិនអាច សេចក្តីខ្វាសរបស់យើង សូម្បីដែលកើតក្នុងគ្រាដំបូង នឹងទម្លាយទៅ តែទោសក្នុងការពោលថា ខ្ញុំមិនអាច ដូច្នេះ មិនមានដល់យើងអ្នកមិនអាច ដូច្នេះ ទើបត្រឡប់មកធ្វើឲ្យជាការៈដល់ព្រះដ៏មានព្រះភាគម្តងទៀត ទើបក្រាបទូលពាក្យជាដើមថា ក៏ខ្ញុំព្រះអង្គទាំងឡាយមានសេចក្តីដឹងត្រឹមតែប៉ុណ្ណេះ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **មានការដឹងត្រឹមតែប៉ុណ្ណេះ** គឺ សីល និងបញ្ញាប៉ុណ្ណេះ បានដល់ សីល និងបញ្ញាត្រឹមតែប៉ុណ្ណោះ ជាយ៉ាងក្រៃលែងរបស់ខ្ញុំព្រះអង្គទាំងឡាយ សេចក្តីថា ពួកខ្ញុំព្រះអង្គទាំងនោះ មានសីល និងបញ្ញាត្រឹមតែប៉ុណ្ណេះ ជាយ៉ាងក្រៃលែង គឺ មិនជ្រាបសេចក្តីនៃពាក្យដែលត្រាស់នោះ ក្រៃលែងឡើងទៅជាងនោះទេ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសីល និងបញ្ញា ចាប់ផ្តើមពីការឧប្បត្តិរបស់ព្រះតថាគត ដែលទ្រង់ជាឫសគល់នៃសីល និងបញ្ញាដល់គេ ទើបត្រាស់ព្រះតម្រាស់ថា ព្រាហ្មណ៍ តថាគតក្នុងលោកនេះ ដូច្នេះជាដើម ។

សេចក្តីនៃបទនោះ គប្បីជ្រាបតាមន័យដែលលោកពោលទុកហើយក្នុងសាមញ្ញផលសូត្រនោះឯង ។ តែប្រការផ្សេងពីនេះមានដូចតទៅនេះ ៖

ក្នុងទីនេះ សីលសូម្បីទាំងបីយ៉ាងនោះ ព្រះដ៏មានព្រះភាគទ្រង់ចង្អុលច្បាស់ថា ជាសីល ដោយពិតយ៉ាងនេះថា សូម្បីប្រការនេះ ក៏ជាត់

នៅក្នុងសីលរបស់អ្នក ។ ឈាន ៤ មានបឋមជ្ឈានជាដើម ដោយចាត់ជាបញ្ញាសម្បទា ។ ព្រះដ៏មានព្រះភាគ មិនបានទ្រង់ចង្អុលបង្ហាញដោយអំណាចនៃបញ្ញា ទ្រង់សម្តែងដោយត្រឹមតែជាបទដ្ឋាននៃបញ្ញា មានវិបស្សនាជាដើម ទ្រង់ចង្អុលបង្ហាញដល់បញ្ញា ចាប់ផ្តើមតាំងពីវិបស្សនាបញ្ញា ដោយប្រការដូច្នេះ ។

## សោណទណ្ឌព្រាហ្មណ៍សម្តែងខ្លួនជាឧបាសក

[១៩៦-៩៧] បទថា **ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ** គប្បីជ្រាបសេចក្តីតាមន័យដែលពោលហើយក្នុងពាក្យនេះថា ដើម្បីឆាន់ក្នុងថ្ងៃនុ៎ះឯង ។

[១៩៨] បទថា **ជំនុំជននោះគប្បីតិះដៀលខ្ញុំព្រះអង្គ** ព្រោះហេតុនោះ សេចក្តីថា ជំនុំជននោះគប្បីតិះដៀលខ្ញុំព្រះអង្គ ព្រោះហេតុដែលឃើញព្រះអង្គអំពីចម្ងាយហើយ ក្រោកចាកអាសនៈនោះថា សោណទណ្ឌ-ព្រាហ្មណ៍នេះជាមនុស្សចាស់ តាំងនៅក្នុងបច្ឆិមវ័យហើយ តែព្រះគោតមនៅកម្លោះ នៅក្មេង សូម្បីត្រឹមជាចៅរបស់គាត់ក៏មិនទាន់បាន គាត់នៅតែក្រោកចាកអាសនៈរបស់ខ្លួនឲ្យដល់ព្រះគោតម ដែលមិនទាន់ដល់សូម្បីចៅរបស់ខ្លួន ។

បទថា **ការផ្គងអញ្ជលីនោះ ជំនួសការក្រោកពីអាសនៈរបស់ខ្ញុំព្រះអង្គ** សេចក្តីថា សោណទណ្ឌព្រាហ្មណ៍ក្រាបទូលថា ដែលឈ្មោះថា

ការមិនក្រោក ព្រោះមិនគោរពរបស់ខ្ញុំព្រះអង្គ មិនមាន , តែខ្ញុំព្រះអង្គនឹងមិនក្រោក ព្រោះខ្លាចភោគសម្បត្តិនឹងវិនាស ប្រការនោះគប្បីមាន , ព្រះអង្គ និងខ្ញុំព្រះអង្គនឹងត្រូវជ្រាប ព្រោះដូច្នោះ សូមព្រះគោតមដ៏ចម្រើនមេត្តាប្រោសទ្រង់ទទួលការផ្គងអញ្ជលីនោះ ជាការជំនួសការក្រោកឡើងទទួល ។ បានឮថា អ្នកបោកបញ្ឆោត ដូចនឹងសោណទណ្ឌព្រាហ្មណ៍នេះរកបានលំបាក ។ ក៏ឈ្មោះថា ការមិនគោរពក្នុងព្រះដ៏មានព្រះភាគ របស់ព្រាហ្មណ៍នេះមិនមាន ព្រោះដូច្នោះ គេពោលយ៉ាងនោះ ដោយការបោកបញ្ឆោត ព្រោះខ្លាចថា ភោគសម្បត្តិវិនាស ។ សូម្បីក្នុងបទដទៃ ក៏មានន័យដូចគ្នានេះ ។

ក្នុងបទថា **ដោយកថាដែលប្រកបដោយធម៌** ជាដើម មានសេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងឲ្យឃើញពិត នូវប្រយោជន៍ដែលជាបច្ចុប្បន្ន និងខាងមុខ ទ្រង់ឲ្យគេកាន់យក គឺ ឲ្យកាន់យកធម៌ដែលជាកុសល ទ្រង់ឲ្យគេអាចហ៊ានក្នុងធម៌ដែលជាកុសលនោះ គឺ ធ្វើឲ្យគេមានសេចក្តីឧស្សាហ៍ ធ្វើឲ្យគេរីករាយ ដោយភាពជាអ្នកមានឧស្សាហ៍នោះ និងគុណដែលមានយ៉ាងដទៃ ទ្រង់ឲ្យភ្លៀង គឺ ព្រះធម្មរតនៈធ្លាក់ចុះហើយ ស្តេចក្រោកចាកអាសនៈ ចៀសចេញទៅ ។

ក៏ព្រាហ្មណ៍ ព្រោះហេតុដែលខ្លួនជាអ្នកបោកបញ្ឆោត កាលព្រះ-មានព្រះភាគទ្រង់ឲ្យភ្លៀង គឺ ព្រះធម៌ធ្លាក់ចុះហើយ សូម្បីដោយប្រការដូច្នេះ ក៏មិនអាចនឹងញុំាងគុណវិសេសឲ្យកើតឡើងបាន កថាទាំងអស់

*បានជាកថាខាងដើម និងខាងចុង ដើម្បីប្រយោជន៍ដល់និព្វាន ក្នុងកាលតទៅ និងដើម្បីជាចំណែកនៃវាសនារបស់ព្រាហ្មណ៍តែម្យ៉ាង ។*

ចប់ អដ្ឋកថា សោណទណ្ឌសូត្រ ទី ៤

អដ្ឋកថាឈ្មោះ សុមង្គលវិលាសិនី

អដ្ឋកថា នៃព្រះសុត្តន្តបិដក ទីឃនិកាយ បឋមភាគ

លេខ ១៤ រួមមាន៖

អដ្ឋកថាព្រហ្មជាលសូត្រ , អដ្ឋកថាសាមញ្ញផលសូត្រ

អដ្ឋកថាអម្ពដ្ឋសូត្រ , អដ្ឋកថាសោណទណ្ឌសូត្រ

ចប់ដោយប្រការដូច្នេះ ។

# នាមសប្បុរសជន

## ចូលរួមជាធម្មទាន

-ព្រះភិក្ខុ ធម្មប្បញ្ញោ វ៉ាន វឿន ................................ 150 $
-ព្រះភិក្ខុ អគ្គទិន្នោ នូវ ប៊ូរ៉ា ................................ ២០០.០០០ ៛០០
-ឧបាសិកា ចាន់ បុប្ផាណា ព្រមទាំងបុត្ត ........................ 100 $
-ឧបាសិកា ពូ ហ៊ាង ................................ 50 $
-លោក ពៅ សូតូង អ្នកស្រី ស៊ុំ យក់លី ព្រមទាំងបុត្ត
-ឧបាសិកា ពៅ សូរ៉ាង ................................ 50 $